**សាកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រ និងវិទ្យាសាស្ត្រសេដ្ឋកិច្ច**

Université Royale de Droit et des Sciences Economiques

Royal University of Law and Economics


# សារណាបញ្ចប់ការសិក្សា

# ការរៀបចំសណ្តាប់ធ្នាប់ និង សោភ័ណភាពក្រុងសៀមរាប

ស្រាវជ្រាវពីថ្ងៃទី១៨ ខែមីនា ឆ្នាំ២០១៩ ដល់ថ្ងៃទី១៦ ខែឧសភា ឆ្នាំ២០១៩


ស្រាវជ្រាវដោយ

និស្សិតឈ្មោះ **ក. ពេជ្រ រក្សា**

**ក. យស វណ្ណាថា**

សាស្ត្រាចារ្យណែនាំ

លោកបណ្ឌិត **អ៊ុន សកក្ខដា**


ថ្នាក់បរិញ្ញាបត្រ **រដ្ឋបាលសាធារណៈ**

ជំនាន់ទី ១២ (អាហារូបករណ៍)

ឆ្នាំចូលសិក្សា ២០១៥

ឆ្នាំសរសេរសារណា ២០១៩

# សាកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រ និងវិទ្យាសាស្ត្រសេដ្ឋកិច្ច

Université Royale de Droit et des Sciences Economiques

Royal University of Law and Economics

# សារណាបញ្ចប់ការសិក្សា

# ការរៀបចំសណ្ដាប់ធ្នាប់
# និង សោភ័ណភាពក្រុងសៀមរាប

ស្រាវជ្រាវពីថ្ងៃទី១៨ ខែមីនា ឆ្នាំ២០១៩ដល់ថ្ងៃទី១៦ ខែឧសភា ឆ្នាំ២០១៩

ស្រាវជ្រាវដោយ

និស្សិតឈ្មោះ: **ក. ពេជ្រ រក្សា**

**ក. យស វណ្ណាថា**

សាស្ត្រាចារ្យណែនាំ

លោកបណ្ឌិត **អ៊ុន សកក្ខុដា**

ថ្នាក់បរិញ្ញាបត្រ **រដ្ឋបាលសាធារណៈ**

ជំនាន់ទី ១២ (អាហារូបករណ៍)

ឆ្នាំចូលសិក្សា ២០១៥

ឆ្នាំសរសេរសារណា ២០១៩

# សេចក្តីថ្លែងអំណរគុណ

ជាបឋមនាងខ្ញុំឈ្មោះ **ពេជ្រ រក្សា** និងនាងខ្ញុំឈ្មោះ **យស វណ្ណាថា** ជានិស្សិតថ្នាក់បរិញ្ញាបត្ររដ្ឋបាលសាធារណៈជំនាន់ទី ១២ នៃសាកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រ និងវិទ្យាសាស្ត្រសេដ្ឋកិច្ចក្នុងឆ្នាំសិក្សា ២០១៨-២០១៩។ សូមថ្លែងអំណរគុណចំពោះ ៖

**លោកឪពុក ឌុយ សារិន** **លោកឪពុក យស តិរិទ្ធ**

**អ្នកម្តាយ សុត គីមស៊ាន** **អ្នកម្តាយ ហេង រស្មី**

កូនសូមសម្តែងនូវមហាកតញ្ញូតាធមិជាអនេកប្បការ ចំពោះលោកអ្នកមានគុណទាំងពីរដែលបានផ្តល់កំណើត និងខិតខំបីបាច់ថែរក្សាចិញ្ចឹមរូបកូនតាំងពីនៅក្នុងផ្ទៃរហូតដល់កូនក្លាយជាយុវតីពេញរូបរាង ព្រមទាំងបានទទួលនូវការអប់រំទូន្មានតាំងពីបឋមសិក្សា មធ្យមសិក្សា រហូតដល់ឧត្តមសិក្សានេះ។ ព្រះគុណដ៏ធំធេងនេះធ្វើឲ្យកូនចងចាំ និងគ្មានអ្វីអាចបំភ្លេចបានឡើយ។ កូនសូមគោរពផ្ញើស្នាដៃនេះ ជូនចំពោះលោកអ្នកមានគុណទាំងពីរជាទីគោរពសក្ការៈដ៏ខ្ពង់ខ្ពស់។

សូមគោរពចំពោះ ឯកឧត្តមសាកលវិទ្យាធិការ សាកលវិទ្យាធិការរង ព្រឹទ្ធបុរស ព្រឹទ្ធបុរសរង ព្រមទាំងលោក លោកស្រីសាស្ត្រាចារ្យនៃសាកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រ និងវិទ្យាសាស្ត្រសេដ្ឋកិច្ច ដែលបានជួយតម្រង់ទិសដល់យើងខ្ញុំ តាំងពីឆ្នាំមូលដ្ឋាន រហូតដល់បញ្ចប់ថ្នាក់បរិញ្ញាបត្រនេះ។

ជាពិសេសសូមថ្លែងអំណរគុណចំពោះលោកសាស្ត្រាចារ្យ **បណ្ឌិត អ៊ុន សកក្កដា** ដែលបានចំណាយពេលវេលា កម្លាំងកាយ កម្លាំងចិត្ត ប្រាជ្ញាស្មារតីជួយណែនាំអំពី អត្ថន័យ ខ្លឹមសារ ឃ្លាឃ្លោង ព្រមទាំងគំនិតយោបល់ល្អៗ សម្រាប់រៀបរៀងអត្ថបទសារណានេះចាប់តាំងពីដំណាក់កាលនៃការចាប់ផ្តើមរហូតដល់បានសម្រេចជាស្ថាពរ។

ជាចុងបញ្ចប់ យើងខ្ញុំទាំងពីរសូមថ្លែងអំណរគុណយ៉ាងជ្រាលជ្រៅ និងសូមប្រសិទ្ធិពរ សិរីមង្គល កើតមានចំពោះលោកអ្នកមានគុណ លោក លោកស្រីសាស្ត្រាចារ្យ ព្រមទាំងក្រុមគ្រួសារឲ្យជួបតែពុទ្ធពរទាំងបួនប្រការ គឺអាយុ វណ្ណៈ សុខៈ ពលៈកុំបីឃ្លៀងឃ្លាតឡើយ។

# អារម្ភកថា

បន្ទាប់ពីបានឆ្លងកាត់នូវការសិក្សា និងក្រេបយកចំណេះដឹងអស់រយៈពេល ៤ឆ្នាំនៅសាកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រ និងវិទ្យាសាស្ត្រសេដ្ឋកិច្ច យើងខ្ញុំបានទទួលនូវចំណេះដឹងជាច្រើនទៅលើជំនាញរដ្ឋបាលសាធារណៈ ជាពិសេសទៅលើវិស័យនគរូបនីយកម្ម។ ទន្ទឹមនេះ យើងខ្ញុំចង់ប្រើប្រាស់ចំណេះដឹងទាំងអស់នេះ បង្កើតជាស្នាដៃសម្រាប់អ្នកជំនាន់ក្រោយ ដោយបានសម្រេចចិត្តជ្រើសរើសយកប្រធានបទស្តីអំពី«**ការរៀបចំសណ្តាប់ធ្នាប់ និងសោភ័ណភាពក្រុងសៀមរាប** » ដែលមានលោកសាស្ត្រាចារ្យ **បណ្ឌិត អ៊ុន សតក្កដា** ជាសាស្ត្រាចារ្យដឹកនាំ ដើម្បីចងក្រងជាឯកសារបញ្ចប់ការសិក្សាថ្នាក់បរិញ្ញាបត្ររដ្ឋបាលសាធារណៈ។ ការសម្រេចជ្រើសរើសយកប្រធានបទខាងលើ មកសិក្សាស្រាវជ្រាវជាសារណាបញ្ចប់ការសិក្សាថ្នាក់បរិញ្ញាបត្រនេះ ដោយសារតែយើងខ្ញុំយល់ឃើញថា ការរៀបចំសណ្តាប់ធ្នាប់ និងសោភ័ណភាពទីក្រុងពិតជាមានសារៈសំខាន់ណាស់ ដើម្បីឲ្យទីក្រុងមួយមាន របៀបរៀបរយ សន្តិសុខ ភាពស្រស់ស្អាត ស្របតាមស្តង់ដារទីក្រុងស្អាត។ ជាពិសេសគឺចង់បង្ហាញពីការរៀបចំសណ្តាប់ធ្នាប់ សោភ័ណភាព រួមទាំងការអភិវឌ្ឍរបស់ក្រុងសៀមរាបដល់សាធារណៈជនផងដែរ។

គោលបំណងសំខាន់មួយទៀតគឺ យើងខ្ញុំចង់ឲ្យសាធារណៈជន សិស្ស និស្សិតបានយល់ដឹងពីការរៀបចំ និងដំណោះស្រាយទៅលើបញ្ហាសណ្តាប់ធ្នាប់ សោភ័ណភាព និងបរិស្ថាន មិនថាតែនៅរាជធានី ក្រុង ស្រុក ខណ្ឌ ឃុំ សង្កាត់របស់ខ្លួនទេ គឺរួមទាំងប្រទេសជាតិទាំងមូលផងដែរ។

យើងខ្ញុំសង្ឃឹមថា សារណាមួយនេះនឹងក្លាយជាអត្ថបទដែលមានសារៈប្រយោជន៍សម្រាប់មិត្ត និស្សិត បញ្ញាវន្ត ដែលមានបំណងចង់សិក្សាស្វែងយល់អំពីការរៀបចំសណ្តាប់ធ្នាប់ និងសោភ័ណភាពទីក្រុងណាមួយ។ យើងខ្ញុំក៏សង្ឃឹមផងដែរថា សារណាបញ្ចប់ការសិក្សាមួយនេះនឹងក្លាយជាឯកសារមួយដែលចូលរួមចំណែក និងជម្រុញឲ្យរាជធានី ក្រុង ស្រុក ខណ្ឌ ឃុំ សង្កាត់ មានសណ្តាប់ធ្នាប់ របៀបរៀបរយ និងសោភ័ណភាពកាន់តែល្អប្រសើរ។

ជាចុងក្រោយ បើទោះបីជាយើងខ្ញុំបានខិតខំសិក្សាស្រាវជ្រាវ និងត្រួតពិនិត្យយ៉ាងហ្មត់ចត់យ៉ាងណាក៏ដោយ ក៏យើងខ្ញុំគិតថាសារណាមួយនេះនៅតែមានការខ្វះចន្លោះ ដូចនេះ យើងខ្ញុំរង់ចាំទទួលនូវការរិះគន់ពីសំណាក់សាស្ត្រាចារ្យ សិស្សនិស្សិត និងមិត្តអ្នកអានទាំងអស់ ដើម្បីកែលម្អសារណាមួយនេះឲ្យកាន់តែមានភាពល្អប្រសើរបន្ថែមទៀត។

# មាតិកា

**ទំព័រ**


**សេចក្តីផ្តើម** ............................................................ ១

## ជំពូកទី១
## ការរៀបចំសណ្តាប់ធ្នាប់ក្នុងក្រុងសៀមរាប

**១.១. ទិដ្ឋភាពទូទៅ** ............................................................ ៥

**១.១.១. ទីតាំងភូមិសាស្ត្រក្រុងសៀមរាប** ............................................................ ៥

**១.១.២. រចនាសម្ព័ន្ធគ្រប់គ្រងរដ្ឋបាលរបស់ក្រុងសៀមរាប** ............................................................ ៧

**១.១.៣. បុព្វហេតុដែលនាំឲ្យមានការរៀបចំ** ............................................................ ៨

១.១.៣.១. កំណើនប្រជាជន ............................................................ ៨

១.១.៣.២. ភាពក្រីក្រ ............................................................ ៩

១.១.៣.៣. កម្រិតជីវភាពនៃការរស់នៅ ............................................................ ១០

១.១.៣.៤. ការដាក់សម្ពាធបរិស្ថាន ............................................................ ១១

១.១.៣.៥. គមនាគមន៍ ............................................................ ១១

១.១.៣.៦. សន្តិសុខសណ្តាប់ធ្នាប់សាធារណៈ ............................................................ ១២

**១.២. បច្ចុប្បន្នភាព និងទិសដៅអនាគតនៃការរៀបចំក្រុងសៀមរាប** ............................................................ ១២

**១.២.១. បច្ចុប្បន្នភាពនៃការរៀបចំ** ............................................................ ១៣

១.២.១.១. ការអភិវឌ្ឍហេដ្ឋារចនាសម្ព័ន្ធ ............................................................ ១៣

១.២.១.២. ការអភិវឌ្ឍសំណង់នានា ............................................................ ១៤

ក. ការបង្កើតសំណង់លំនៅស្ថាន និងអគារថ្មីៗ ............................................................ ១៥

ខ. ការគ្រប់គ្រងសំណង់អគារចាស់ៗ ............................................................ ១៧

១.២.១.៣. ការរៀបចំរបៀបរៀបរយ ............................................................ ១៨

**១.២.២. ទិសដៅអនាគតនៃការរៀបចំ** ............................................................ ២២

១.២.២.១. ការអភិវឌ្ឍលើវិស័យហេដ្ឋារចនាសម្ព័ន្ធ ............................................................ ២២

១.២.២.២. ការអភិវឌ្ឍលើវិស័យទឹកស្អាត និងអនាម័យ ............................................................ ២៣

១.២.២.៣. ទិសដៅរៀបចំសន្តិសុខសណ្តាប់ធ្នាប់ ............................................................ ២៤

# ជំពូកទី២

# សោភ័ណភាព និងបរិស្ថានក្នុងក្រុងសៀមរាប


**២.១. សោភ័ណភាពក្នុងក្រុងសៀមរាប** ........ ២៥

**២.១.១. សោភ័ណភាពពេលថ្ងៃ** ........ ២៦

២.១.១.១. ការកសាងហេដ្ឋារចនាសម្ព័ន្ធនៅលើដី ........ ២៦

២.១.១.២. ការកសាងហេដ្ឋារចនាសម្ព័ន្ធនៅក្រោមដី ........ ២៧

**២.១.២. សោភ័ណភាពពេលយប់** ........ ២៨

២.១.២.១. ការដាក់បង្គោលភ្លើងបំភ្លឺតាមដងផ្លូវ និងអគារ ........ ២៨

២.១.២.២. ការដាក់ភ្លើងលម្អពេលរាត្រីតាមឧទ្យាន និងសួនច្បារសាធារណៈ ........ ២៨

**២.២. បរិស្ថានក្រុងសៀមរាប** ........ ២៩

**២.២.១. លក្ខណៈទូទៅ និងហេតុបង្កនាំឲ្យមានការបំពុលបរិស្ថាន** ........ ៣០

២.២.១.១. ការបំពុលទឹក ដី ខ្យល់ ........ ៣០

ក.ការបំពុលទឹក ........ ៣០

ខ. ការបំពុលដី ........ ៣២

គ. ការបំពុលខ្យល់ ........ ៣៣

២.២.១.២. ការបំពុលដោយសំណល់រឹង រាវ និងសំលេង ........ ៣៥

ក.ការបំពុលដោយសំណល់រឹង រាវ ........ ៣៥

ខ. ការបំពុលដោយសំលេង ........ ៣៧

**២.២.២. ស្ថានភាពបរិស្ថានក្នុងក្រុងសៀមរាប** ........ ៣៨

២.២.២.១. បញ្ហាសំណល់រឹង ........ ៣៩

២.២.២.២. បញ្ហាប្រព័ន្ធបង្ហូរទឹក និងប្រព័ន្ធបង្ហូរសំណល់រាវ ........ ៣៩

២.២.២.៣. ការរំខានដោយសំលេង ........ ៤០

២.២.២.៤. ការបំពុលខ្យល់ ........ ៤០

**២.២.៣. ដំណោះស្រាយពាក់ព័ន្ធនឹងការបំពុលបរិស្ថានក្នុងក្រុងសៀមរាប** ........ ៤១

២.២.៣.១. ដំណោះស្រាយពាក់ព័ន្ធនឹងបញ្ហាសំណល់រឹង ........ ៤១

២.២.៣.២. ដំណោះស្រាយពាក់ព័ន្ធនឹងបញ្ហាប្រព័ន្ធបង្ហូរទឹក និងប្រព័ន្ធបង្ហូរសំណល់រាវ ... ៤២

២.២.៣.៣. ដំណោះស្រាយពាក់ព័ន្ធនឹងការរំខានដោយសំលេង ........ ៤២

២.២.៣.៤. ដំណោះស្រាយពាក់ព័ន្ធនឹងការបំពុលខ្យល់ ........ ៤៣

**សេចក្តីសន្និដ្ឋាន** ......................................................................................................... ៩៤
**អនុសាសន៍** ......................................................................................................... ៩៥
**ឯកសារពិគ្រោះ**
**ឧបសម្ព័ន្ធ**

# សេចក្តីផ្តើម

# សេចក្តីផ្តើម

## ១. លំនាំបញ្ហានៃការស្រាវជ្រាវ

តាំងពីសម័យបុរាណមកម្ល៉េះ នៅគ្រប់បណ្តាប្រទេសទាំងអស់សុទ្ធតែមានការធ្វើការអភិវឌ្ឍទៅលើហេដ្ឋារចនាសម្ព័ន្ធ ការរៀបចំទីក្រុង និងប្រទេសរបស់ខ្លួនឲ្យសណ្តាប់ធ្នាប់ របៀបរៀបរយមានភាពស្រស់ស្អាត មានសន្តិសុខ និងមានបរិស្ថានល្អ គ្រាន់តែរបៀបនៃការរៀបចំ និងការអភិវឌ្ឍនោះខុសគ្នាទៅតាមស្ថានភាព ការគ្រប់គ្រង និងយុទ្ធសាស្ត្ររបស់អ្នកដឹកនាំនៃប្រទេសនីមួយៗតែប៉ុណ្ណោះ។ សម្រាប់ប្រទេសកម្ពុជា ការរៀបចំក្រុង និងការអភិវឌ្ឍហេដ្ឋារចនាសម្ព័ន្ធ កើតមានតាំងពីសម័យបុរាណកាលមកម្ល៉េះ ហើយក៏នៅតែបន្តរហូតមកដល់បច្ចុប្បន្នផងដែរ។

ប្រទេសកម្ពុជាបែងចែកជា២៥ខេត្តក្រុង ហើយក្រុង និងខេត្តនីមួយៗ គឺសុទ្ធសឹងតែមានការរៀបចំសណ្តាប់ធ្នាប់ សោភ័ណភាព និងបរិស្ថានខេត្ត និងក្រុងឲ្យបានល្អប្រសើរទៅតាម លទ្ធភាព និងស្ថានភាពរបស់ខេត្តនិងក្រុងរបស់ខ្លួន។ ក្នុងនោះផងដែរក្រុងសៀមរាបដែលជាក្រុងតែមួយគត់របស់ខេត្តសៀមរាប និងជាទីក្រុងទេសចរណ៍ប្រវត្តិសាស្ត្រមួយដ៏ល្បីល្បាញរបស់កម្ពុជា ដែលបានទាក់ទាញភ្ញៀវទេសចរទាំងជាតិ និងអន្តរជាតិជាច្រើនឲ្យមកទេសចរណ៍កំសាន្តនោះ ក៏បានខំយកចិត្តទុកដាក់អភិវឌ្ឍន៍ទៅលើហេដ្ឋារចនាសម្ព័ន្ធផ្សេងៗ និងធ្វើការរៀបចំ កែលម្អសណ្តាប់ធ្នាប់ សោភ័ណភាព សន្តិសុខសុវត្ថិភាព និងបរិស្ថានក្រុងរបស់ខ្លួន ក៏ដូចជាខិតខំរិះរកវិធីសាស្ត្រធ្វើយ៉ាងណារៀបចំទីក្រុងរបស់ខ្លួនឲ្យកាន់តែល្អប្រសើរ និងខិតខំរិះរកដំណោះស្រាយទាក់ទងទៅនឹងបញ្ហាប្រឈមផ្សេងៗដែលកើតមានឡើងដើម្បីឲ្យស្របតាមស្តង់ដារទីក្រុងស្អាត និងដើម្បីទាក់ទាញភ្ញៀវទេសចរជាតិ អន្តរជាតិមកពីគ្រប់ទិសទី ឲ្យមកទស្សនាកាន់តែច្រើនបន្ថែមទៀត។

## ២. ចំណោទបញ្ហានៃការស្រាវជ្រាវ

ក្រុងសៀមរាបគឺជាគោលដៅទេសចរណ៍ដ៏សំខាន់មួយក្នុងចំណោមតំបន់ទេសចរណ៍ជាច្រើនរបស់ប្រទេសកម្ពុជា ក៏ដូចជាតំបន់ទេសចរណ៍នៅក្នុងតំបន់អាស៊ីទាំងមូលផងដែរ ម្យ៉ាងទៀតក្រុងនេះក៏បានផ្តល់នូវថវិការដល់ជាតិយ៉ាងច្រើនផងដែរតាមរយៈវិស័យទេសចរណ៍ ជាពិសេសគឺរមណីយដ្ឋានអង្គរ។

ដូច្នេះហើយ ក្រុងសៀមរាបចាំបាច់ត្រូវតែយកចិត្តទុកដាក់ទៅលើការអភិវឌ្ឍនូវហេដ្ឋារចនាសម្ព័ន្ធ និងធ្វើការរៀបចំទៅលើសណ្តាប់ធ្នាប់ សោភ័ណភាព និងបរិស្ថាន ឲ្យបានល្អប្រសើរ ដើម្បីជាការទាក់ទាញដល់អ្នកទេសចរឲ្យមកទស្សនាកាន់តែច្រើនឡើង។ហេតុដូចនេះ ទើបមានសាធារណៈជនបានចោទជាសំនួរថា “**តើក្រុងសៀមរាបធ្វើការរៀបចំសណ្តាប់ធ្នាប់ សោភ័ណភាព និងបរិស្ថានយ៉ាងដូចម្តេច?**” និង “ **តើនៅពេលបច្ចុប្បន្ន ក្រុងនេះមានការអភិវឌ្ឍអ្វីខ្លះ?** ”

## ៣. គោលបំណងនៃការស្រាវជ្រាវ

ការស្រាវជ្រាវទៅលើប្រធានបទមួយនេះ គឺមានគោលបំណងចង់បង្ហាញពីស្ថានភាព របៀបនៃការរៀបចំ សណ្តាប់ធ្នាប់ សោភ័ណភាព និងបរិស្ថាននៅក្នុងក្រុងសៀមរាប ដែលជាទីក្រុងទេសចរណ៍មួយក្នុងប្រទេសកម្ពុជា និងដែលបានទាក់ទាញភ្ញៀវទេសចរជាច្រើនកុះករមកទស្សនានោះ ដល់សាធារណជនក៏ដូចជាសិស្ស និស្សិតសម្រាប់ជាការស្វែងយល់ និងសិក្សាបន្ថែមដើម្បីជាចំណេះដឹងសម្រាប់យកទៅអនុវត្តន៍នៅក្នុងទីក្រុង ឬខេត្តរបស់ខ្លួនក៏ដូចជាប្រទេសជាតិទាំងមូល។ ម្យ៉ាងទៀតយើងក៏មានគោលបំណងចង់ឲ្យការស្រាវជ្រាវនេះ ក្លាយជាឯកសារជំនួយស្មារតីបន្ថែមសម្រាប់ការស្រាវជ្រាវរបស់ប្អូនៗនិស្សិតជំនាន់ក្រោយផងដែរ។

## ៤. ទំហំ និងដែនកំណត់នៃការស្រាវជ្រាវ

ចំពោះការស្រាវជ្រាវនេះ យើងខ្ញុំធ្វើការពិពណ៌នាអំពី ការរៀបចំសណ្តាប់ធ្នាប់ និងសោភ័ណភាពតែនៅក្នុងក្រុងសៀមរាបតែប៉ុណ្ណោះពុំមានវិសាលភាពគ្របដណ្តប់ទូទាំងខេត្តសៀមរាបនោះទេ ហើយយើងខ្ញុំនឹងធ្វើការបកស្រាយតែទៅលើអ្វីដែលទាក់ទងនឹងសណ្តាប់ធ្នាប់ សោភ័ណភាព និងបរិស្ថានតែប៉ុណ្ណោះ។

## ៥. សារៈសំខាន់នៃការស្រាវជ្រាវ

ការសិក្សាស្រាវជ្រាវទៅលើប្រធានបទមួយនេះគឺពិតជាមានសារៈសំខាន់ណាស់ចំពោះយើងខ្ញុំ និងចំពោះសាធារណៈជនក៏ដូចជា សិស្ស និស្សិតសំរាប់ជាឯកសារជំនួយ និងសិក្សាបន្ថែមដើម្បីបានយល់ដឹងពីការរៀបចំ និងការដោះស្រាយទៅលើបញ្ហាសណ្តាប់ធ្នាប់ សោភ័ណភាព និងបរិស្ថាន មិនថាតែនៅក្នុងរាជធានី ក្រុង ស្រុក ខណ្ឌ ឃុំ សង្កាត់របស់ខ្លួនទេ គឺរួមទាំងប្រទេសជាតិទាំងមូលផងដែរ។

## ៦. វិធីសាស្ត្រនៃការស្រាវជ្រាវ

ដើម្បីធ្វើការស្រាវជ្រាវទាក់ទងនឹងប្រធានបទ« **ការរៀបចំសណ្តាប់ធ្នាប់ និងសោភ័ណភាពក្រុងសៀមរាប** » មួយនេះ យើងខ្ញុំបានធ្វើការសិក្សាស្រាវជ្រាវលើគ្រប់ឯកសារដែលពាក់ព័ន្ធដែលបានមកពីគេហទំព័រផ្សេងៗ និងឯកសារដែលបានមកពីការចុះស្រាវជ្រាវដោយផ្ទាល់នៅសាលាក្រុងសៀមរាប។

## ៧. រចនាសម្ព័ន្ធនៃការស្រាវជ្រាវ

ចំពោះសារណានេះយើងខ្ញុំធ្វើការបែងចែកជា **ពីរជំពូក** រួមមាន៖

**ជំពូកទី១ ៖ ការរៀបចំសណ្តាប់ធ្នាប់ក្នុងក្រុងសៀមរាប** ដែលនៅក្នុងជំពូកទី១នេះមានបែងចែកជាពីរផ្នែកដោយផ្នែកទី១បកស្រាយពីទិដ្ឋភាពទូទៅ និងផ្នែកទី២បកស្រាយពីបច្ចុប្បន្នភាព

និងទិសដៅអនាគតនៃការរៀបចំក្រុងសៀមរាប។

**ជំពូកទី២ ៖ សោភ័ណភាព និងបរិស្ថានក្នុងក្រុងសៀមរាប** ដែលនៅក្នុងជំពូកទី២នេះផងដែរក៏មានបែងចែកជាពីរផ្នែកដូចគ្នា ដោយផ្នែកទី១បកស្រាយពីសោភ័ណភាពក្នុងក្រុងសៀមរាប ផ្នែកទី២បកស្រាយពីបរិស្ថានក្នុងក្រុងសៀមរាប ។

# ជំពូកទី១

# ការរៀបចំសណ្ដាប់ធ្នាប់ក្នុងក្រុងសៀមរាប

# ជំពូកទី១
# ការរៀបចំសណ្តាប់ធ្នាប់ក្នុងក្រុងសៀមរាប

តាមការវិភាគអំពីស្ថានភាពនៃការរៀបចំសណ្តាប់ធ្នាប់នៅរយៈពេលប៉ុន្មានឆ្នាំចុងក្រោយនេះឃើញថា ការរៀបចំសណ្តាប់ធ្នាប់នៅក្នុងក្រុងសៀមរាបត្រូវបានសាលាក្រុងយកចិត្តទុកដាក់ជាខ្លាំង ដោយបង្កើតឲ្យមានរបៀបរៀបរយ សុខសុវត្ថិភាពជូនប្រជាពលរដ្ឋ ដាក់ភ្លើងសញ្ញាចរាចរណ៍នៅតាមដងផ្លូវ ជួសជុល និងពង្រីកផ្លូវក្នុងក្រុង ជាពិសេសផ្លូវសម្រាប់ថ្មើរជើង និងផ្លូវសម្រាប់អ្នកជិះកង់ និងការចុះទៅត្រួតពិនិត្យរកសារធាតុហាមឃាត់ដែលដាក់ក្នុងចំណីអាហារនៅតាមផ្សារនានាក្នុងក្រុងដើម្បីធានាបាននូវសុវត្ថិភាពម្ហូបអាហារជូនប្រជាពលរដ្ឋ និងរួមទាំងភ្ញៀវទេសចរដែលមកទស្សនាកំសាន្តជាដើម។

ចំពោះការងាររៀបចំសន្តិសុខ និងសណ្តាប់ធ្នាប់នេះ គឺជាការទទួលខុសត្រូវរបស់គណៈមេបញ្ជាការឯកភាពក្រុងដែលមាន លោកអភិបាលក្រុងជាប្រធានដឹកនាំលើ៖

- អធិការដ្ឋាននគរបាលក្រុងដែលមានកម្លាំងប៉ូលីសសរុប ២១៦នាក់ ស្រី១០នាក់ ក្នុងនោះកម្លាំងនគរបាលប៉ុស្តិ៍រដ្ឋបាលសង្កាត់ទាំង១៣ មានចំនួន១៥៥នាក់ ស្រី០៨នាក់។ ប៉ុស្តិ៍នគរបាលរដ្ឋបាលនីមួយៗមានកម្លាំងពី០៨ ទៅ ១៥នាក់ដែលមានចៅសង្កាត់ជាប្រធាន គណៈបញ្ជាការឯកភាពសង្កាត់។
- បញ្ជាការដ្ឋានកងរាជអាវុធហត្ថក្រុងមានកម្លាំង៣១នាក់បែងចែកទៅតាមឃ្លាំមើលបទល្មើសតាមសង្កាត់នីមួយៗ
- បញ្ជាការផ្នែកសឹករងក្រុងមានកម្លាំង០៧នាក់ នៅភូមិក្រសាំង សង្កាត់ជ្រាវ
- លេខាធិការដ្ឋានក្រុងអនុវត្តន៍គោលនយោបាយ ភូមិ ឃុំ មានសុវត្ថិភាព
- ក្រុមការងារសុវត្ថិភាពចរាចរណ៍ផ្លូវគោក។[1]

ប៉ុន្តែ ទោះជាសាលាក្រុងបានខិតខំយកចិត្តទុកដាក់យ៉ាងណាក្តី ក៏នៅតែមានបញ្ហាប្រឈមកើតមានផងដែរ ដូចជា៖

- ពុំទាន់កំណត់ព្រំដែនការងារឲ្យបានច្បាស់លាស់រវាងរដ្ឋបាលក្រុង ជាមួយអង្គភាព និងមន្ទីរពាក់ព័ន្ធនានាៗ
- មិនទាន់មានធនធានមនុស្សគ្រប់គ្រាន់សម្រាប់បំពេញការងារ
- ព្រំប្រទល់រវាងក្រុង និងស្រុកមួយចំនួនពុំទាន់បានកំណត់ច្បាស់លាស់

[1] ផែនការអភិវឌ្ឍ(២០១៥ - ២០១៩) របស់សាលាក្រុងសៀមរាប, ២០១៥, ៣១។

- ប្រជាពលរដ្ឋមួយចំនួនតូចមិនទាន់មានអត្តសញ្ញាណប័ណ្ណប្រើប្រាស់នៅឡើយ
- នៅតែមានករណី ឃាតកម្ម លួច ឆក់ ប្លន់កើតមានឡើង
- នៅតែមានករណីគ្រោះថ្នាក់ចរាចរណ៍កើតមានជារៀងរាល់ថ្ងៃ
- នៅតែមានការរំលោភផ្លូវភេទ និងការជួញដូរមនុស្ស
- នៅតែមានការចែកចាយ និងប្រើប្រាស់គ្រឿងញៀន
- នៅតែមានអំពើហិង្សាក្នុងគ្រួសារ និងការប្រព្រឹត្តល្បែងស៊ីសង[2]
- ផ្លូវមួយចំនួនតូច ពុំទាន់បានពង្រីកនៅឡើយ ទន្ទឹមនឹងនោះផ្លូវក៏ពុំទាន់មានគុណភាព
- ទីក្រុងមានការលិចលង់ជារៀងរាល់ឆ្នាំ នៅពេលមានភ្លៀងធ្លាក់ខ្លាំងម្តងៗ បង្កជាទឹកជំនន់ ដោយសារប្រព័ន្ធរំដោះទឹកមិនធានា និងមិនទាន់មានការកែលម្អ
- ប្រជាពលរដ្ឋនៅមិនទាន់មានសេវាអគ្គិសនី និងទឹកស្អាតប្រើប្រាស់គ្រប់គ្រាន់នៅឡើយ
- ទីផ្សារនៅតាមសង្កាត់មិនទាន់មានអនាម័យសមរម្យសម្រាប់បម្រើឲ្យសេវាទេសចរណ៍
- កណ្តាលក្រុងខ្វះចំណត ។[3]

បញ្ហាទាំងអស់នេះ ទាមទារឲ្យអាជ្ញាធរគ្រប់ជាន់ថ្នាក់ ក៏ដូចជាប្រជាពលរដ្ឋគួរគប្បីរួមគ្នាដោះស្រាយ ដើម្បីឲ្យទីក្រុងមានសណ្តាប់ធ្នាប់ និងសោភ័ណភាពល្អប្រសើរ។

## ១.១. ទិដ្ឋភាពទូទៅ

### ១.១.១. ទីតាំងភូមិសាស្ត្រក្រុងសៀមរាប

ខេត្តសៀមរាប ជាខេត្តមួយស្ថិតនៅតំបន់ពាយ័ព្យ នៃប្រទេសកម្ពុជា តាមបណ្តោយផ្លូវជាតិលេខ ៦ ដែលមានចំងាយប្រវែង ៣១៤ គីឡូម៉ែត្រ ពីទីក្រុងភ្នំពេញ ដែលមានព្រំប្រទល់ខាងកើតជាប់នឹងខេត្តកំពង់ធំ និងខេត្តព្រះវិហារ ខាងលិចជាប់នឹងខេត្តបន្ទាយមានជ័យ ខាងជើងជាប់នឹងខេត្តឧត្តរមានជ័យ និងខេត្តព្រះវិហារ និងខាងត្បូងជាប់នឹងខេត្តបាត់ដំបង និងបឹងទន្លេសាប។ ខេត្តសៀមរាបជាតំបន់ទេសចរណ៍ដ៏សំខាន់របស់ប្រទេសកម្ពុជា ដោយសារខេត្តនេះជាទីតាំងនៃប្រាសាទអង្គរវត្ត ដ៏ល្បីល្បាញនិង ប្រាសាទបុរាណដទៃទៀតជាច្រើន។[4]

ដោយឡែក ក្រុងសៀមរាបគឺជាទីប្រជុំជន និងជាក្រុងតែមួយគត់របស់ខេត្តសៀមរាបដែលមានព្រំប្រទល់ដូចខាងក្រោម៖

- ខាងកើតទល់នឹងស្រុកប្រាសាទបាគង

[2] ផែនការអភិវឌ្ឍ(២០១៥ - ២០១៩) របស់សាលាក្រុងសៀមរាប, ២០១៥, ៣១។
[3] ផែនការអភិវឌ្ឍ(២០១៥ - ២០១៩) របស់សាលាក្រុងសៀមរាប, ២០១៥, ២៦។
[4] https://km.wikipedia.org/wiki/ (ចូលទស្សនាចុងក្រោយថ្ងៃទី១៥ មិថុនា ២០១៩)។

- ខាងលិចទល់នឹងស្រុកពួក
- ខាងជើងទល់នឹងស្រុកអង្គរធំ និងស្រុកបន្ទាយស្រី
- ខាងត្បូងទល់នឹងបឹងទន្លេសាប

ក្រុងសៀមរាបចែកចេញជា១៣សង្កាត់ មាន១០៨ភូមិ មាន៩៨១ក្រុម មានផ្ទៃដីសរុប៨៧២៧៣ ហិកតា មានចំនួនប្រជាជនសរុប២៤០,៦០០នាក់ក្នុងនោះមានស្រីចំនួន១២៨,៨៥០នាក់ ។[5]

សង្កាត់ក្នុងក្រុងសៀមរាបៈ

| ក្រុងសៀមរាប | | |
|---|---|---|
| ល.រ | ឈ្មោះសង្កាត់ជាអក្សរខ្មែរ | ឈ្មោះសង្កាត់ជាអក្សរឡាតាំង |
| ១ | សង្កាត់ស្លក្រាម | Sla Kram |
| ២ | សង្កាត់ស្វាយដង្គុំ | Svay Dankum |
| ៣ | សង្កាត់គោកចក | Kok Chak |
| ៤ | សង្កាត់សាលាកំរើក | Sala Kamreuk |
| ៥ | សង្កាត់នគរធំ | Nokor Thum |
| ៦ | សង្កាត់ជ្រាវ | Chreav |
| ៧ | សង្កាត់ចុងឃ្នៀស | Chong Khnies |
| ៨ | សង្កាត់សំបួរ | Sngkat Sambuor |
| ៩ | សង្កាត់សៀមរាប | Siem Reab |
| ១០ | សង្កាត់ស្រង៉ែ | Srangae |
| ១១ | សង្កាត់អំពិល | Ampil |
| ១២ | សង្កាត់ក្របីរៀល | Krabei Riel |
| ១៣ | សង្កាត់ទឹកវិល | TuekVil |

[5] ផែនការអភិវឌ្ឍ(២០១៥ - ២០១៩) របស់សាលាក្រុងសៀមរាប, ២០១៥, ០១។

ក្រុងសៀមរាបត្រូវបានប្តូរមកជាក្រុងនៅឆ្នាំ២០០៨។ក្រុងនេះ  គឺផ្តុំឡើងដោយភូមិតូចៗនៅតាមបណ្តោយដងស្ទឹងសៀមរាប  ដោយភូមិទាំងនោះត្រូវបានអភិវឌ្ឍន៍ដោយរក្សានូវលក្ខណៈដើមគឺព័ទ្ធជុំវិញដោយវត្តអារាម។ កណ្តាលទីក្រុង គឺសំដៅលើផ្លូវស៊ីវត្ថា ផ្សារចាស់ និងផ្សាររាត្រីអង្គរ ។[6]

### ១.១.២. រចនាសម្ព័ន្ធគ្រប់គ្រងរដ្ឋបាលរបស់ក្រុងសៀមរាប




[6] របាយការណ៍ចុងក្រោយនៃការសិក្សាតាមដានស្តីពីផែនការមេរួមសម្រាប់ការអភិវឌ្ឍដោយនិរន្តរភាពរបស់ក្រុងសៀមរាប, ២០១០, ០៦។

ចំពោះការិយាល័យជុំវិញក្រុងមានចំនួន១៤ការិយាល័យដូចជា៖

- ការិយាល័យផែនការ
- ការិយាល័យសាធារណៈការ និងដឹកជញ្ជូន
- ការិយាល័យទេសចរណ៍
- ការិយាល័យកសិកម្ម
- ការិយាល័យធម្មការ និងសាសនា
- ការិយាល័យសង្គមកិច្ច
- ការិយាល័យដែនដីនគរូបនីយកម្មសំណង់ និងភូមិបាល
- ការិយាល័យព័ត៌មាន
- ការិយាល័យវប្បធម៌ និងវិចិត្រសិល្បៈ
- ការិយាល័យពាណិជ្ជកម្ម
- ការិយាល័យសុខាភិបាលស្រុកប្រតិបត្តិ
- ការិយាល័យអប់រំយុវជន និងកីឡា
- ការិយាល័យកិច្ចការនារី
- ការិយាល័យអភិវឌ្ឍន៍ជនបទ។[7]

### ១.១.៣. មូលហេតុដែលនាំឲ្យមានការរៀបចំ

ការរៀបចំក្រុង មិនមែនកើតឡើងដោយសារតែភាពចៃដន្យ ឬចេះតែធ្វើការរៀបចំតាមចិត្តនោះទេ។ ការជម្រុញឲ្យកើតមាននូវការរៀបចំ និងការកែប្រែ បណ្តាលមកពីមានភាពខ្វះចន្លោះ ឬមានការលេចចេញនូវបញ្ហាផ្សេងៗ ហើយភាពខ្វះចន្លោះ និងបញ្ហាទាំងអស់នោះ តម្រូវឲ្យធ្វើការកែប្រែ និងការរៀបចំជាចាំបាច់។

ចំពោះក្រុងសៀមរាប ដោយសារតែសង្កេតឃើញមានភាពខ្វះចន្លោះ និងបញ្ហាជាច្រើនកើតមានឡើងក្នុងក្រុងរបស់ខ្លួន ក្រុងនេះក៏បានយកចិត្តទុកដាក់ធ្វើការរៀបចំ តែលម្អដោយមានការគិតគូរយ៉ាងហ្មត់ចត់ ហើយបញ្ហាដែលនាំឲ្យមានការរៀបចំនោះរួមមាន៖

#### ១.១.៣.១. កំណើនប្រជាជន

ការកើនឡើងនូវចំនួនប្រជាជន គឺជាកត្តាសំខាន់មួយដែលជម្រុញឲ្យកើតមាននូវការរៀបចំក្រុង។ ជាទូទៅមាននូវសមាសភាពនៃកំណើនប្រជាជនក្នុងទីក្រុង៣សំខាន់ៗគឺ កំណើនប្រជាជន

[7] ផែនការអភិវឌ្ឍ(២០១៥ - ២០១៩) របស់សាលាក្រុងសៀមរាប, ២០១៥, ៣០។

ក្នុងក្រុងជាលក្ខណៈធម្មជាតិ កំណើនប្រជាជនដោយសារមានចំណាកស្រុកពីជនបទ និងកំណើនដោយសារតែការបែងចែកប្រភេទសណ្ឋានដីនៃក្រុងថ្មី ដែលពីមុនតំបន់នេះជាទីជនបទប៉ុណ្ណោះ។ កំណើនប្រជាជនក្នុងក្រុងជាលក្ខណៈធម្មជាតិបានធ្វើឲ្យមានការកើនឡើងយ៉ាងឆាប់រហ័សនៃចំនួនប្រជាជន ចំណែកកំណើនដោយសារការធ្វើចំណាកស្រុកពីជនបទ និងកំណើនដោយសារតែការបែងចែកប្រភេទសណ្ឋានដីនៃក្រុងថ្មី ដែលពីមុនមក តំបន់នេះជាតំបន់ជនបទ គឺគ្រាន់តែជាធាតុចូលបន្ទាប់បន្សំប៉ុណ្ណោះ។ [8] ប៉ុន្តែជាក់ស្តែងសម្រាប់ក្រុងសៀមរាប កំណើនប្រជាជនមានការកើនឡើងដោយសារការធ្វើចំណាកស្រុកពីជនបទ និងដោយសារតែការបែងចែកប្រភេទសណ្ឋានដីនៃក្រុងថ្មី។

ការចុះបញ្ជីឧទ្យានអង្គរជាសម្បត្តិបេតិកភណ្ឌពិភពលោកដោយ UNESCO ក្នុងឆ្នាំ ១៩៩២ បានបង្កើតនូវឱកាសមួយដើម្បីផ្លាស់ប្តូរពីរូបភាពនៃកន្លែងដែលអសន្តិសុខ និងស្ថេរភាពតាមរយៈសង្គ្រាមផ្ទៃក្នុងឲ្យទៅជាទិសដៅទេសចរណ៍វប្បធម៌ និងប្រវត្តិសាស្ត្រដែលគួរឲ្យចាប់អារម្មណ៍។ ទេសចរណ៍វប្បធម៌ និងប្រវត្តិសាស្ត្រក្នុងក្រុងសៀមរាប និងតំបន់អង្គរត្រូវបានផ្តួចផ្តើម និងធ្វើឲ្យប្រសើរឡើងដោយកំណើនភ្ញៀវទេសចរជាតិនិងអន្តរជាតិ។[9]ដោយសារតែទីក្រុងសៀមរាបមានការផ្លាស់ប្តូរបែបនេះ ទើបក្រុងនេះក្លាយជាទីក្រុងទេសចរណ៍ដ៏ពេញនិយមសម្រាប់ភ្ញៀវជាតិ និងអន្តរជាតិមកពីគ្រប់ទិសទីដែលធ្វើឲ្យកំណើនភ្ញៀវទេសចរកាន់តែមានការកើនឡើងពីមួយឆ្នាំទៅមួយឆ្នាំ។ កត្តានេះបានធ្វើឲ្យប្រជាពលរដ្ឋនៅជនបទ និងនៅតាមបណ្តាខេត្តផ្សេងៗចាប់ផ្តើមធ្វើចំណាកស្រុកមកកាន់ក្រុងសៀមរាប ដើម្បីមករកការងារធ្វើ រកប្រាក់ចំណូលពីវិស័យទេសចរណ៍ និងវិស័យដទៃទៀតដើម្បីផ្គត់ផ្គង់គ្រួសារនៅឯស្រុកកំណើត។ ប្រជាពលរដ្ឋទាំងនោះបានធ្វើការចាប់ដីតាំងទីលំនៅជាសំណង់បណ្តោះអាសន្នលើដីរដ្ឋដោយរស់នៅជាលក្ខណៈគ្រួសារ ហើយភាគច្រើនទីតាំងដែលប្រជាពលលរដ្ឋកាន់កាប់គឺស្ថិតនៅលើដីចំណីផ្លូវ ដីដែលស្ថិតក្នុងគម្រោងពង្រាង និងអភិវឌ្ឍន៍តាមដងស្ទឹង លើប្រលាយ និងដីតំបន់អប្បរាជាដើម។[10] ដោយសារមូលហេតុទាំងនេះហើយ ដែលតម្រូវឲ្យអាជ្ញាធរក្រុងសៀមរាបត្រូវធ្វើការរៀបចំឲ្យមានរបៀបរៀបរយល្អ។

**១.១.៣.២. ភាពក្រីក្រ**

ការកំណត់អំពីស្ថានភាពក្រីក្រ មានការលំបាកនៅក្នុងការកំណត់ណាស់ តែជាទូទៅភាពក្រីក្រសំដៅដល់ការដែលតម្រូវការរបស់មនុស្សមិនត្រូវបានបំពេញ។ជារួម នៅប្រទេសភាគច្រើនបាន

[8] អ៊ុន សកក្កដា, *នីតិនគរូបនីយវិទ្យា* (ភ្នំពេញ,២០១៩),០៦។

[9] របាយការណ៍ចុងក្រោយនៃការសិក្សាតាមដានស្តីពីផែនការមេរូមសម្រាប់ការអភិវឌ្ឍដោយនិរន្តរភាពរបស់ក្រុងសៀមរាប,២០១០,០៦។

[10] របាយការណ៍ស្តីអំពី ការស្រង់ទិន្នន័យទីតាំងសំណង់បណ្តោះអាសន្នរបស់ក្រុងសៀមរាប, ០៥។

កំណត់ពីភាពក្រីក្រតាមរយៈប្រាក់ចំណូលទាប ដែលពួកគេមិនអាចចាយវាយគ្រប់គ្រាន់ក្នុងជីវភាពរស់នៅប្រចាំថ្ងៃ។ ជាក់ស្ដែង តម្រូវការរូបកាយ ចំណីអាហារ សម្លៀកបំពាក់ លំនៅស្ថាន ការងារ ធនធានទឹក អគ្គិសនី និងអនាម័យសុខមាលភាពសង្គម មានការខ្វះខាតជាដើម។

ការសម្គាល់ពីភាពក្រីក្រត្រូវបានសង្កត់ធ្ងន់លើចំណូលទាប របស់បុគ្គលម្នាក់ៗ ពីព្រោះតែបញ្ហាផ្សេងៗដូចជាៈ ចំនួននៃករណីឧក្រិដ្ឋកម្ម អំពើហិង្សា ឬ អាយុសង្ឃឹមរស់ជាមធ្យម មិនអាចយកមកជំនួសដោយការវាស់ស្ទង់តាមរយៈប្រាក់ចំណូលនោះឡើយ ដែលជាធម្មតាអ្នកដែលទទួលបានប្រាក់ចំណូលក្រោមកម្រិតមធ្យមត្រូវបានគេសន្មតថាជាជនក្រីក្រ។ បើយើងធ្វើការប្រៀបធៀបរវាងភាពក្រីក្រនៅតាមជនបទ និងភាពក្រក្រីនៅទីក្រុងគឺឃើញថាមានលក្ខណៈខុសគ្នា ដោយមូលហេតុគឺដោយសារតែតាមធម្មតាការចំណាយនៅទីក្រុងគឺខ្ពស់ជាងតំបន់ជនបទដាច់ស្រយាលឆ្ងាយណាស់។ ស្របពេលជាមួយគ្នានេះ អ្នករស់នៅតាមជនបទ អាចមានឱកាសស្វែងរកការចិញ្ចឹមជីវិតតាមរយៈការទទួលអំណោយផ្សេងៗ និងភោគផលពីធម្មជាតិច្រើនជាងអ្នកនៅទីក្រុង។ តាមរយៈនេះគេអាចនិយាយបានថា អ្នកក្រនៅទីក្រុងក្រជាង និងមានស្ថានភាពលំបាកជាងអ្នកក្រនៅ ជនបទ។[11]

កត្តានៃភាពក្រីក្រនេះ ក៏បានធ្វើឲ្យកើតមាននូវបញ្ហាសណ្ដាប់ធ្នាប់និងរបៀបរៀបរយផងដែរ គឺដោយសារតែជីវភាពក្រីក្រ ប្រជាពលរដ្ឋភាគច្រើនគ្មានទីលំនៅសម្រាប់រស់នៅសមរម្យ ធ្វើឲ្យអ្នកខ្លះត្រូវដេក ឬសម្រាកនៅតាមចិញ្ចើមផ្លូវ និងសួនច្បារ ម្យ៉ាងទៀតដោយសារគ្មានអាហារហូបចុកគ្រប់គ្រាន់ ប្រជាពលរដ្ឋមួយចំនួនក៏ត្រូវដើរសុំទានគេដើម្បីបំពេញក្រពះផងដែរ។ បញ្ហាទាំងអស់នេះបានធ្វើឲ្យប៉ះពាល់យ៉ាងខ្លាំងដល់សណ្ដាប់ធ្នាប់ របៀបរៀបរយសាធារណៈដែលជាហេតុនាំឲ្យអាជ្ញាធរក្រុង ត្រូវយកចិត្តទុកដាក់ស្វែងរកដំណោះស្រាយ និងរៀបចំធ្វើយ៉ាងណាឲ្យមានលក្ខណៈល្អប្រសើរ។

### ១.១.៣.៣. កម្រិតជីវភាពនៃការរស់នៅ

ភាពខុសគ្នានៃស្ថានភាពជីវភាពគឺជាកត្តាចម្បងដែលត្រូវបានគិតគូរនៅពេលមានការពិភាក្សាជុំវិញការជម្រុញឲ្យមានការរៀបចំក្រុង។ កម្រិតជីវភាព និងប្រាក់បៀវត្សន៍ខ្ពស់នៅទីក្រុងជាកត្តាទាក់ទាញមនុស្សឲ្យមករស់នៅទីក្រុង។ ដរាបណាភាពខុសគ្នារវាងទីក្រុង និងជនបទនៅតែមានគម្លាតខ្ពស់ ប្រជាពលរដ្ឋដែលរស់នៅជនបទ នៅតែចង់ចូលមករស់នៅទីក្រុង។

ជាទូទៅកត្តាសេដ្ឋកិច្ចនិងអត្រានិកម្មភាពខ្ពស់ជាកត្តាជម្រុញធ្វើឲ្យមានការធ្វើចំណាកស្រុក ដោយសារតែពេលខ្លះ ការងារនៅជនបទនៅមានកម្រិត ដូច្នេះទោះបីជាទទួលបានប្រាក់ខែទាបក៏

[11] អ៊ុន សកក្កដា, *នីតិនគរូបនីយវិទ្យា* (ភ្នំពេញ,២០១៩),០៧។

ត្រូវតែបង្ខំចិត្តចំណាកស្រុកមកកាន់ទីក្រុងដែរ។ លើសពីនេះទៀត ដោយសារនៅទីក្រុងមានការប្រមូលផ្តុំដោយកត្តាសង្គម នយោបាយល្អប្រសើរ ខណៈពេលដែលសេវាសុខាភិបាល និងអប់រំមានភាពសម្បូរបែប ដែលរឹតតែធ្វើឲ្យអ្នករស់នៅមានអារម្មណ៍ថា មានសុវត្ថិភាពជាងកន្លែងណាៗទាំងអស់។ [12] ដូចនេះហើយ កត្តាកម្រិតជីវភាពនៃការរស់នៅរបស់ប្រជាពលរដ្ឋក៏ជាកត្តាសំខាន់មួយដែលតម្រូវឲ្យមានការរៀបចំក្រុងផងដែរ។

**១.១.៣.៤. ការដាក់សម្ពាធបរិស្ថាន**

សម្ពាធដ៏ធំបំផុតរបស់ប្រជាពលរដ្ឋនៅជនបទពាក់ព័ន្ធនឹងវិស័យបរិស្ថានគឺការកង្វះដីបង្កបង្កើនផលដើម្បីធ្វើកសិកម្ម។ករណីនេះកើតមានច្រើនដែលដីរបស់ពួកគេ ដែលទទួលបានពីដូនតាឪពុកម្តាយរបស់ខ្លួនត្រូវបានពួកគេចែកឲ្យកូនៗអស់។ ចំណែកផ្ទៃដីដែលនៅសល់មានទំហំតូច មិនសមល្មមសម្រាប់ធ្វើកសិកម្ម ឬបង្កបង្កើនផលដំណាំផ្សេងឡើយ ហើយពេលខ្លះស្ថានភាពដីនោះមានលក្ខណៈខ្សោះ និងគ្មានជីជាតិទៀត។ ប្រសិនបើក្រឡេកទៅមើលមួយជ្រុងទៀត ចំពោះប្រជាពលរដ្ឋក្រីក្រ នៅពេលដែលគាត់មានដីគ្រប់គ្រាន់ហើយ តែគាត់បែរជាកង្វះប្រព័ន្ធធារាសាស្ត្រដើម្បីស្រោចស្រព និងជីកសិកម្មសម្រាប់បង្កបង្កើនផលបានគ្រប់គ្រាន់ទៅវិញ។[13]

**១.១.៣.៥. គមនាគមន៍**

គមនាគមន៍គឺជាកត្តាសំខាន់មួយផងដែរ ដែលជម្រុញឲ្យមានការរៀបចំក្រុង។សណ្តាប់ធ្នាប់ និងរបៀបរៀបរយក្រុងក៏អាស្រ័យទៅលើកត្តាផ្លូវផងដែរ។ ការរីកចម្រើនផ្នែកកសិកម្ម ឧស្សាហកម្ម ពាណិជ្ជកម្ម និងទេសចរណ៍ គឺមានទំនាក់ទំនងយ៉ាងជិតស្និទ្ធទៅនឹងការរីកចម្រើនខាងគមនាគមន៍ ទាំងផ្លូវថ្នល់ ផ្លូវទឹក ផ្លូវដែក ដែលសុទ្ធសឹងតែជាសរសៃឈាមនៃសេដ្ឋកិច្ច។

គមនាគមន៍គឺជាលក្ខណៈវិនិច្ឆ័យមួយដែលអាចឲ្យយើងដឹងពីការអភិវឌ្ឍរបស់ទីក្រុងណាមួយ ឬប្រទេសណាមួយ។កាលណាទីក្រុងមួយមានគមនាគមន៍ ផ្លូវថ្នល់ខ្វាត់ខ្វែងដែលអាចសម្រួលដល់ការដឹកជញ្ជូន និងការធ្វើដំណើរផ្សេងៗបានយ៉ាងល្អប្រសើរ ដោយគ្មានការកកស្ទះ ឬជួបបញ្ហាផ្សេងៗនោះ នឹងធ្វើឲ្យក្រុងនោះមាននូវសណ្តាប់ធ្នាប់ និងរបៀបរៀបរយល្អប្រសើរ ព្រមទាំងជម្រុញឲ្យសេដ្ឋកិច្ចរបស់ក្រុងឬប្រទេសនោះមានការរីកចម្រើនផងដែរ។ផ្ទុយទៅវិញ ប្រសិនបើទីក្រុង ឬប្រទេសមួយខ្វះខាតនូវគមនាគមន៍ នឹងបង្កឲ្យមានការកកស្ទះ រាំងស្ទះដល់ការធ្វើដំណើរ ឬការដឹកជញ្ជូនផ្សេងៗ នាំឲ្យបាត់បង់សោភ័ណភាព និងសណ្តាប់ធ្នាប់ ព្រមទាំងជាឧបសគ្គដល់ការរីកចម្រើននៃសេដ្ឋកិច្ចផងដែរ។ ដូចនេះហើយ ការរៀបចំក្រុងគឺចាំបាច់ត្រូវគិតគូរទៅលើ ការអភិវឌ្ឍគមនាគមន៍ជាមុន។

[12] អ៊ុន សកក្កដា, *នីតិនគរូបនីយវិទ្យា* (ភ្នំពេញ,២០១៩), ០៩។

[13] អ៊ុន សកក្កដា, *នីតិនគរូបនីយវិទ្យា* (ភ្នំពេញ,២០១៩), ០៦។

### ១.១.៣.៦. សន្តិសុខសណ្តាប់ធ្នាប់សាធារណៈ

សន្តិសុខសណ្តាប់ធ្នាប់សាធារណៈក៏ជាមូលហេតុចម្បងមួយដែលនាំឲ្យមានការរៀបចំក្រុងផងដែរ។ ទីក្រុងដែលគ្មានសន្តិសុខសុវត្ថិភាព កើតមាននូវបទល្មើសផ្សេងៗដូចជាការ លួច ឆក់ ប្លន់ និង គ្រោះថ្នាក់ចរាចរណ៍ជាដើមនោះធ្វើឲ្យទីក្រុងនោះ បាត់បង់នូវរបៀបរៀបរយ រួមទាំងភាពទាក់ទាញ។ ដោយឡែក បញ្ហាទាំងអស់នេះកើតឡើងដោយសារកត្តាមួយចំនួនដូចជា៖

- ប្រជាពលរដ្ឋខ្វះការយល់ដឹងអំពីច្បាប់
- ការមិនគោរពច្បាប់ចរាចរណ៍
- ការលក់ដូរតាមចិញ្ចើមផ្លូវគ្មានសណ្តាប់ធ្នាប់
- ការចតយានយន្តគ្មានសណ្តាប់ធ្នាប់
- ការប្រព្រឹត្តល្បែងស៊ីសង និង
- ក្មេងទំនើង

កត្តាទាំងអស់នេះ សុទ្ធតែជាមូលហេតុដែលជម្រុញឲ្យមានការរៀបចំឲ្យមានរបៀបរៀបរយ សោភ័ណភាព និងប្រកបដោយសុវត្ថិភាព។

## ១.២. បច្ចុប្បន្នភាព និងទិសដៅអនាគតនៃការរៀបចំក្រុងសៀមរាប

ក្រុងសៀមរាបជាក្រុងតែមួយគត់របស់ខេត្តសៀមរាប ហើយក៏ជាទីក្រុងប្រវត្តិសាស្ត្រដ៏ល្បីល្បាញមួយរបស់ប្រទេសកម្ពុជា។ ម្យ៉ាងទៀត សម្រស់ទីក្រុងនេះបានទាក់ទាញភ្ញៀវទេសចរជាច្រើនមកពីបណ្តាប្រទេសនានាទូទាំងពិភពលោក មិនតែប៉ុណ្ណោះក៏បានផ្តល់នូវចំណូលជាតិជាច្រើនតាមរយៈវិស័យទេសចរណ៍នេះផងដែរ។ កាលពីសម័យអង្គរ បុព្វបុរសខ្មែរបានរៀបចំ កសាងហេដ្ឋារចនាសម្ព័ន្ធនានា រៀបចំសន្តិសុខសណ្តាប់ធ្នាប់ក្នុងក្រុងអង្គរបានយ៉ាងល្អប្រសើរធ្វើឲ្យប្រជាពលរដ្ឋរស់នៅប្រកបដោយភាពសុខសាន្ត សម្បូរសប្បាយ ហើយក្លាយជាសម័យកាលដែលរុងរឿងបំផុតនៅក្នុងប្រវត្តិសាស្ត្រខ្មែរ។ គំរូនេះ បានបន្តរហូតមកដល់បច្ចុប្បន្ន ដោយកូនខ្មែរជំនាន់ក្រោយបានខិតខំប្រឹងប្រែងដើរតាមគំរូដឹកនាំរបស់បុព្វបុរស ហើយព្យាយាមអភិវឌ្ឍន៍ក្រុង និងខេត្តរបស់ខ្លួនឲ្យបានល្អប្រសើរ។

ជាក់ស្តែងក្រុងសៀមរាប នាពេលបច្ចុប្បន្នក្រុងនេះបានខិតខំ យកចិត្តទុកដាក់កសាងនូវប្រព័ន្ធហេដ្ឋារចនាសម្ព័ន្ធគ្រប់ទីកន្លែង យកចិត្តទុកដាក់រៀបចំសន្តិសុខសណ្តាប់ធ្នាប់និងរបៀបរៀបរយសាធារណៈ ដើម្បីបំពេញតម្រូវការជូនប្រជាពលរដ្ឋ និងដើម្បីឲ្យប្រជាពលរដ្ឋរស់នៅប្រកបដោយសុខសុវត្ថិភាព។ ស្របពេលនឹងការរៀបចំអភិវឌ្ឍន៍ក្រុងក្នុងពេលបច្ចុប្បន្ននេះ ក្រុងសៀមរាបក៏មានផែនការ និងទិសដៅអភិវឌ្ឍន៍ជាបន្តបន្ទាប់ទៀតនៅពេលអនាគតដើម្បីធ្វើយ៉ាង

ណាឲ្យក្រុងកាន់តែមានភាពទាក់ទាញចំពោះអ្នកទេសចរទាំងជាតិ និងអន្តរជាតិឲ្យមកលេងកំសាន្ត និងក្លាយជាទីពេញចិត្តរបស់ប្រជាពលរដ្ឋដែលរស់នៅក្នុងក្រុងនេះផងដែរ។

### ១.២.១. បច្ចុប្បន្នភាពនៃការរៀបចំ

បច្ចុប្បន្ន ក្រុងសៀមរាបមានមានការរៀបចំ និងការអភិវឌ្ឍទៅលើវិស័យជាច្រើន ប៉ុន្តែនៅក្នុងខណៈនេះយើងខ្ញុំសូមលើកយកតែមួយចំនួនប៉ុណ្ណោះមកធ្វើការបកស្រាយ ដែលក្នុងនោះរួមមានការអភិវឌ្ឍទៅលើហេដ្ឋារចនាសម្ព័ន្ធ ការអភិវឌ្ឍសំណង់នានា និងការរៀបចំសណ្ដាប់ធ្នាប់របៀបរៀបរយក្នុងក្រុង។

#### ១.២.១.១. ការអភិវឌ្ឍហេដ្ឋារចនាសម្ព័ន្ធ

ហេដ្ឋារចនាសម្ព័ន្ធ បរិយាយអំពីទ្រព្យបង្កើតឡើងដែលអនុញ្ញាតឲ្យប្រទេសមួយដំណើរការដូចជា ស្ពាន ផ្លូវថ្នល់ ផ្លូវដែក កំពង់ផែ ព្រលានយន្តហោះ ប្រព័ន្ធគមនាគមន៍ អគ្គិសនី និងបណ្ដាញចែកចាយទឹកស្អាតជាដើម។[14]

ក្រុងសៀមរាបមានផ្លូវជាតិលេខ៦ជាគោលពីព្រំប្រទល់ស្រុកពួករហូតដល់ព្រំប្រទល់ស្រុកប្រាសាទបាគង ប្រមាណជា ១៨គីឡូម៉ែត្រ និងមានផ្លូវគមនាគមន៍ DBST ២០.៤ គីឡូម៉ែត្រ ផ្លូវម៉ាកាដាំ ១៣.៩គីឡូម៉ែត្រ ផ្លូវបេទីម ៥៥.២ គីឡូម៉ែត្រ ផ្លូវបេតុង ៥.៥គីឡូម៉ែត្រ ផ្លូវក្រាលគ្រួសក្រហម ២៥គីឡូម៉ែត្រ ផ្លូវដីស ១៨គីឡូម៉ែត្រ និងផ្លូវទឹកប្រវែង ៥គីឡូម៉ែត្រ ( ពីកំពង់ផែស្ទឹងជីងទៅដល់មាត់បឹងទន្លេសាប )។ ក្រោមដីមានបណ្ដាញលូប្រអប់បេតុង ប្រវែង១៩៩០ម៉ែត្រគុណនិង ២.៥ម៉ែត្រ និងលូមូលមានប្រវែង៧២៨០ម៉ែត្រ ទទួលទឹកខ្វក់បាន ៣០០០ម៉ែត្រគូប ក្នុងមួយថ្ងៃ (ជាជំនួយ AFD) និងលូប្រអប់បេតុងប្រវែង ២.២គីឡូម៉ែត្រ (ADB) ទទួលទឹកខ្វក់បាន២០០០ម៉ែត្រក្នុងមួយថ្ងៃ លូកាត់ផ្លូវប្រវែង២៧.៧៨គីឡូម៉ែត្រ ប្រព័ន្ធសំណង់រំដោះទឹកប្រវែង៩.៨៦គីឡូម៉ែត្រ ប្រព័ន្ធលូទឹកស្អុយចំនួន០២ខ្សែ (១ខ្សែជាជំនួយ ADB និង១ខ្សែទៀតជាជំនួយAFD) ។[15]

មិនតែប៉ុណ្ណោះ ដោយសារតែក្រុងសៀមរាបជាទីក្រុងទេសចរណ៍សម្រាប់ភ្ញៀវជាតិ និងអន្តរជាតិមកពីគ្រប់ទិសទី ហើយកំណើនភ្ញៀវទេសចរកាន់តែមានការកើនឡើង ហេតុដូចនេះហើយសាលាក្រុងសៀមរាបបានខិតខំកែលម្អ និងរៀបចំហេដ្ឋារចនាសម្ព័ន្ធ ជាច្រើនទៀតសម្រាប់បំពេញតម្រូវការជូនភ្ញៀវទេសចរ និងប្រជាពលរដ្ឋនៅក្នុងមូលដ្ឋាន។ សាលាក្រុងសៀមរាបបានខិតខំប្រឹងប្រែងកែលម្អហេដ្ឋារចនាសម្ព័ន្ធដូចជា ជួសជុល និងកែលម្អផ្លូវ កែលម្អស្ទឹងសៀមរាប និង

[14] https://opendevelopmentcambodia.net/km/topics/urban-administration-and-development/(ចូលទស្សនាចុងក្រោយថ្ងៃទី ០១ មិថុនា ២០១៩)។

[15] ផែនការអភិវឌ្ឍ(២០១៥ - ២០១៩) របស់សាលាក្រុងសៀមរាប, ២០១៥, ២៥។

ការអភិវឌ្ឍផ្សេងៗទៀតដើម្បីគួរជាទីទាក់ទាញភ្ញៀវទេសចរបន្ថែមទៀត។ សមិទ្ធផលទាំងអស់នោះរួមមាន៖

- សាងសង់ផ្លូវក្រាលកៅស៊ូ ចាប់ពីស្ពាននាគទៅស្ពានបច្ចេកទេស(ស្ពានខាងលិចស្ទឹងសៀមរាប) ស្ថិតក្នុងសង្កាត់ស្លក្រាម មានប្រវែង៧០០ម៉ែត្រ និង ទទឹង០៦ម៉ែត្រ។
- សាងសង់ផ្លូវក្រាលកៅស៊ូចាប់ពីភោជនីយដ្ឋានចិនខ្មៅទៅវត្តរាជបូព៌ស្ថិតក្នុងសង្កាត់ស្លក្រាម និងសង្កាត់សាលាកំរើកមានប្រវែង ៨៥០ម៉ែត្រ និង ទទឹង០៥ម៉ែត្រ។
- សាងសង់ផ្លូវបេតុងក្រោយវត្តរាជបូព៌ដល់ផ្លូវលោកតា ខៀវ ណឹយ ស្ថិតក្នុងសង្កាត់សាលាកំរើកមានប្រវែង ៩០០ម៉ែត្រ និង ទទឹង០៦ម៉ែត្រ។
- រៀបចំដាក់លូនៅផ្លូវសាលាមត្តេយ្យញូវយ៉កដែលស្ថិតក្នុងសង្កាត់ស្វាយដង្គំមានប្រវែង៦០០ម៉ែត្រ និង មុខកាត់០១ម៉ែត្រ។
- សាងសង់ផ្លូវក្រាលកៅស៊ូ និងសួនច្បារកណ្តាល ផ្លូវជាតិលេខ៦ចាប់ពីស្ពានព្រះរាជដំណាក់ដល់សណ្ឋាគារស្មាយលីង ដែលស្ថិតក្នុងសង្កាត់ស្លក្រាមមានប្រវែង១៥០០ម៉ែត្រ និងមានទទឹង១២ម៉ែត្រ។
- សាងសង់ផ្លូវក្រាលកៅស៊ូ៧មករា និងដាក់លូចាប់ពីរង្វង់មូលព្រះរាជដំណាក់ដល់ផ្លូវសម្តេចហ៊ុន សែនសន្តិភាព (ផ្លូវក្រវ៉ាត់ក្រុង) ស្ថិតក្នុងសង្កាត់សាលាកំរើក មានប្រវែង៣០០០ម៉ែត្រ និងទទឹង១៥ម៉ែត្រ។
- សាងសង់ផ្លូវក្រាលកៅស៊ូនៅផ្លូវលោកតា ខៀវ ណឹយ ស្ថិតក្នុងសង្កាត់ស្លក្រាម និង សង្កាត់សាលាកំរើក មានប្រវែង ១៥០០ម៉ែត្រ និង ទទឹង២០ម៉ែត្រ (មានសួនកណ្តាល០២)។[16]

### ១.២.១.២. ការអភិវឌ្ឍសំណង់នានា

ទីក្រុងសៀមរាបជាទីក្រុងបេតិកភណ្ឌមួយប្រកបដោយសំណង់អច្ឆរិយៈដែលបន្សល់ទុកពីសម័យបុរាណរួមមានប្រាសាទរាប់ពាន់ ដែលខ្លះមានអាយុកាលជាងមួយពាន់ឆ្នាំមកហើយ ហើយត្រូវបានមហាជនទូទៅហៅទីក្រុងនេះថា «ទឹកដីអច្ឆរិយៈនៃបេតិកភណ្ឌវប្បធម៌ និងប្រវត្តិសាស្ត្រ» ដ៏មានប្រជាប្រិយភាពអាចទាក់ទាញភ្ញៀវទេសចរពីគ្រប់ទិសទីមកទស្សនាកំសាន្ត។

ក្រោយពីប្រទេសកម្ពុជាបានបញ្ចប់សង្គ្រាមស៊ីវិលបណ្តាញហេដ្ឋារចនាសម្ព័ន្ធ រួមទាំងបណ្តុំសំណង់ភូមិស្ថាន អគារ សណ្ឋាគារ ផ្ទះសំណាក់ ភោជនីយដ្ឋាន ត្រូវបានសាងសង់នៅទីប្រជុំជនធំក្នុងប្រទេសជាពិសេសតំបន់ដែលមានចំនួនភ្ញៀវទេសចរកុះករដូចជាទីក្រុងអង្គរ។[17] ជាក់ស្តែងនៅពេលបច្ចុប្បន្ននេះ ក្រុងសៀមរាបមានសំណង់ជាច្រើនដូចជា៖

[16] របាយការណ៍បញ្ចប់អាណត្តិទី២របស់ក្រុមប្រឹក្សាក្រុងសៀមរាប(២០១៤-២០១៨), ២០១៩, ១៣។
[17] https://www.postkhmer.com/ (ចូលទស្សនាចុងក្រោយថ្ងៃទី២៦ ឧសភា ២០១៩)។

- ផ្សារទំនើបចំនួន០២កន្លែងគឺផ្សារឡាក់គីម៉លអង្គរ និងផ្សារជាប់ស្រ្ទីត
- ផ្សារធំចំនួន០៦កន្លែងរួមមាន ផ្សារលើធំថ្មី ផ្សារសាមគ្គី ផ្សារកណ្តាល ផ្សារចាស់ ផ្សារក្រោម និងផ្សារដើមក្រឡាញ់
- ផ្សារមធ្យម( លក់ពេញមួយថ្ងៃ )ចំនួន១៦កន្លែង មាន ផ្សារញ៉ែរ ផ្សារវត្តពោធិ៍លង្កា ផ្សារអង្គរថ្មី ផ្សារទឹកវិល ផ្សារភូមិភាគ ផ្សារកន្ទ្រក ផ្សារហ៊ុយឡេង ផ្សារយើង ផ្សារក្របីរៀល ផ្សារដីហ៊ុយ ផ្សារជ្រាវ ផ្សារខ្នារ ផ្សារប្រិមប្រិយ ផ្សារគោកធ្លក ផ្សារភ្នំក្រោម និង ផ្សារស្រះស្រង់
- ផ្សារខ្នាតតូចចំនួន១៩កន្លែង
- ផ្សាររាត្រីចំនួន៨កន្លែង
- សណ្ឋាគារលំដាប់ផ្កាយ៥ ចំនួន ១៣កន្លែង
- សណ្ឋាគារលំដាប់ផ្កាយ៤ ចំនួន ២៥កន្លែង
- សណ្ឋាគារលំដាប់ផ្កាយ៣ ចំនួន ០៧កន្លែង
- សណ្ឋាគារលំដាប់ផ្កាយ២ ចំនួន ០១កន្លែង
- អាជាតមិនចំនួន ០៩កន្លែង
- ផ្ទះសំណាក់ចំនួន ២៥៤កន្លែង
- ភោជនីយដ្ឋានចំនួន ១៩១កន្លែង។[18]

ប៉ុន្តែការគ្រប់គ្រងផ្នែកនគរូបនីយកម្ម សំណង់ចាស់ និងថ្មី មិនមានការថែរក្សាបានត្រឹមត្រូវល្អនៅឡើយទេ ។

**ក. ការបង្កើតសំណង់លំនៅស្ថាន និងអគារថ្មីៗ**

តំបន់តាំងទីលំនៅក្នុងក្រុង ដោយរាប់បញ្ចូលទាំងតំបន់ដែលមានប្រជាជនរស់នៅយ៉ាងច្រើន និងតំបន់ពង្រីកក្រុងនៃក្រុងសៀមរាប ត្រូវបានចាត់ចេញជា៧ប្រភេទនៃតំបន់តាំងទីលំនៅផ្អែកលើលក្ខណៈនៃដីដែលប្រើប្រាស់ ដង់ស៊ីតេការអភិវឌ្ឍ និងតំបន់ដូចដែលមានខាងក្រោមៈ

- តំបន់មជ្ឈមណ្ឌលពាណិជ្ជកម្មៈ តំបន់នេះត្រូវបានកំណត់ជាតំបន់កណ្តាលក្រុង ដែលមានមជ្ឈមណ្ឌលពាណិជ្ជកម្ម និងជំនួញជាមួយដីដែលមានផែនការប្រើប្រាស់ដោយរាប់បញ្ចូលទាំងមន្ត្រីរាជការក៏បានរស់នៅក្នុងតំបន់នេះដែរ។ បើទោះបីថា សាលាខេត្តបានផ្លាស់ប្តូរទីតាំងទីតាំងទៅតំបន់ភាគខាងកើតក្រៅក្រុងក៏ដោយ ក៏វាទាមទារនូវសេវាសំខាន់ៗដូចជា ធនាគារ ហាងលក់ទំនិញ ការិយាល័យប្រៃសណីយ៍ មន្ទីរពេទ្យនៅក្នុងតំបន់នោះផងដែរ។
- តំបន់មជ្ឈមណ្ឌលពាណិជ្ជកម្មបន្ទាប់បន្សំៈ តំបន់នេះត្រូវបានកំណត់ជាតំបន់ក្បែរតំបន់

[18] ផែនការអភិវឌ្ឍ(២០១៥ - ២០១៩) របស់សាលាក្រុងសៀមរាប, ២០១៥, ២៥។

មជ្ឈមណ្ឌលពាណិជ្ជកម្មដែលមានសកម្មភាពជំនួញនិងពាណិជ្ជកម្មដោយរាប់បញ្ចូលទាំងសកម្មភាពផ្នែកទេសចរណ៍ដែលនៅវាយប៉ាយជាមួយតំបន់តាំងទីលំនៅ។

- តំបន់ដែលនៅក្បែរតំបន់កណ្ដាលក្រុង ៖ តំបន់នេះមានទីតាំងនៅក្បែរតំបន់កណ្ដាលក្រុង។ វាជាតំបន់តាំងទីលំនៅ ដែលមានការរស់នៅភាគច្រើនដោយប្រជាជន មានជីវភាពកម្រិតទាប និងរស់នៅវាយប៉ាយ លើកលែងតែការរស់នៅប្រកបអាជីវកម្មនៅតាមផ្លូវក្នុងតំបន់នេះ។
- តំបន់របៀងក្រុង (ពាណិជ្ជកម្ម និងធុរកិច្ច) ៖ តំបន់នេះត្រូវបានបង្កើតឡើងនៅតាមបណ្ដោយផ្លូវរណប និងផ្លូវជាតិលេខ៦ និងផ្លូវខេត្តលេខ២៣ និង២៤ ដែលមានជំនួញ និងពាណិជ្ជកម្មដោយរាប់បញ្ចូលទាំងសណ្ឋាគារធំៗ ភោជនីយដ្ឋាន និងហាងផ្សេងៗជាដើម។
- តំបន់ក្រុង ខាងក្រៅផ្លូវវាងក្រុង ៖ តំបន់នេះត្រូវបានកំណត់ជាតំបន់ដែលមានការរស់នៅតិចតួចស្ថិតនៅខាងក្រៅផ្លូវវាងក្រុង ដែលជាតំបន់កសិកម្ម និងតំបន់ដែលមានការអភិវឌ្ឍផ្ទះសម្បែង សណ្ឋាគារ រោងចក្រ ស្ថាប័នអប់រំ ភោជនីយដ្ឋាន និងហាងផ្សេងៗ។
- តំបន់បុរីសណ្ឋាគាររបស់អាជ្ញាធរអប្សរា (តំបន់ទេសចរណ៍ និងវប្បធម៌) ៖ តំបន់នេះត្រូវបានរចនាដោយរាជរដ្ឋាភិបាល សម្រាប់ការអភិវឌ្ឍទេសចរណ៍ដោយរាប់បញ្ចូលទាំងសណ្ឋាគារ និងផ្នែកទេសចរណ៍ផ្សេងៗនាពេលអនាគត ។
- តំបន់សាលាខេត្តថ្មី ៖ តំបន់នេះត្រូវបានអភិវឌ្ឍន៍នៅឆ្នាំ២០១០។ វាជាតំបន់ដែលមានបណ្ដុំការិយាល័យរបស់សាលាខេត្ត និងមន្ទីររបស់ខេត្ត មានទីតាំងស្ថិតនៅក្នុងតំបន់២។

ម្យ៉ាងវិញទៀត ទីក្រុងសៀមរាប ត្រូវបានគេស្គាល់ថា ជាទីក្រុងតូចតែមានចំនួនសណ្ឋាគារ និងផ្ទះសំណាក់ច្រើនម៉ឺនបន្ទប់ដើម្បីឆ្លើយតបទៅនឹងចំនួនភ្ញៀវទេសចរចម្រុះជាតិសាសន៍ដែលនឹងទៅទស្សនាប្រាសាទអង្គរវត្ត ប៉ុន្តែនាអំឡុងទសវត្សរ៍ចុងក្រោយនេះទីក្រុងនេះក៏មានកំណើននៃការសាងសង់លំនៅឋានតូចធំ និងបុរី ជាច្រើនកន្លែង និងមានផ្ទះរហូតដល់រាប់ពាន់ខ្នងផងដែរ។[19]កាលពីប៉ុន្មានឆ្នាំមុននៅជាយក្រុងសៀមរាបមានតែបុរីសៀងណាំមួយគម្រោងប៉ុណ្ណោះ ប៉ុន្តែនៅអំឡុងឆ្នាំ២០១៧ ចំនួនបុរីនៅក្នុងក្រុងសៀមរាប បានឡើងដល់ចំនួន ៦ បុរីហើយ ក្នុងនោះមានបុរីសៀងណាំ១ បុរីសៀងណាំ២ បុរីPerfect Angkor បុរីប្រិមប្រិយ និងឌីព្រីមៀរអង្គរជាលេស(The Premier Angkor Palace) ជាដើម។ ក្នុងចំណោមបុរីទាំងនោះ ខ្លះមានគម្រោងសង់ស្ទើររាប់ពាន់ខ្នង ខ្លះទៀតមានផ្ទះរាប់រយល្វែង និងបុរីខ្លះទៀតមានត្រឹមផ្ទះរាប់សិបប៉ុណ្ណោះ។[20]

---

19 http://www.cvea.org.kh/km/35-real-estate-news-2/1667-more-boreys-emerge-in-siem-reap.html(ចូលទស្សនាចុងក្រោយថ្ងៃទី២៧ ឧសភា ២០១៩)។

20 http://www.cvea.org.kh/km/35-real-estate-news-2/1667-more-boreys-emerge-in-siem-reap.html(ចូលទស្សនាចុងក្រោយថ្ងៃទី២៧ ឧសភា ២០១៩)។

### ខ. ការគ្រប់គ្រងសំណង់អគារចាស់ៗ

ក្រុងសៀមរាបទោះបីជាសំបូរទៅដោយអគារថ្មីៗនិងទំនើបៗជាច្រើនសម្រាប់ការដាក់ជួលក៏ដោយក៏ប៉ុន្តែអគារចាស់ៗទ្រុឌទ្រោមដែលបង្កួតរាងអស់រាប់សិបឆ្នាំដែលនៅតែមានរចនាបទស្អាតៗក៏នៅតែជាទីពេញនិយមសម្រាប់ការជួលដើម្បីធ្វើអាជីវកម្មផងដែរ។ ប៉ុន្តែនៅពេលថ្មីៗនេះ ដោយសារតែមានករណីបាក់រលំអគារមួយកន្លែងដែលជាអគារចាស់សាងសង់តាំងពីសម័យអាណានិគមបារាំងដែលមានទីតាំងស្ថិតនៅជិតតំបន់ផាប់ស្រ្ទីតផ្សារចាស់ភូមិមណ្ឌល៣ សង្កាត់ស្វាយដង្គំ ក្រុងសៀមរាប ដែលបានបណ្តាលឲ្យមនុស្សចំនួន០១នាក់បានស្លាប់ និង០៥នាក់ទៀតរងរបួស។[21]

ហេតុដូច្នេះហើយ មន្ទីររៀបចំដែនដី នគរូបនីយកម្ម និងសំណង់ ព្រមទាំងអាជ្ញាធរក្រុងសៀមរាបបានបង្កើតឡើងនូវគណៈកម្មការមួយសម្រាប់គ្រប់គ្រងអគារដែលបានសាងសង់នៅសម័យបារាំងនោះដើម្បីដោះស្រាយបញ្ហាបាក់រលំអគារ និងធ្វើការគ្រប់គ្រងអគារដែលបានសាងសង់នៅសម័យបារាំងដែលមានវ័យចំណាស់ នៅតំបន់ផ្សារចាស់ និងផាប់ស្រ្ទីត ដើម្បីទប់ស្កាត់ការបង្កឲ្យមានគ្រោះថ្នាក់បាក់រលំអគារ។សំណង់អគារភាគច្រើននៅក្នុងតំបន់ផ្សារចាស់ និងផាប់ស្រ្ទីតក្នុងក្រុងសៀមរាប ខេត្តសៀមរាប ជាសំណង់មានវ័យចំណាស់ដែលបានសាងសង់ឡើងនៅក្នុងសម័យអាណានិគមបារាំងក្នុងចន្លោះឆ្នាំ១៩២០ដល់ឆ្នាំ១៩៧០ ហើយសំណង់ទាំងនេះក៏ត្រូវបានចុះទៅក្នុងបញ្ជីសម្បត្តិបេតិកភណ្ឌជាតិផងដែរ។ ការជួសជុលសំណង់អគារដែលមានវ័យចំណាស់ទាំងនេះ គឺចាំបាច់ត្រូវតែមានការពិនិត្យច្បាស់លាស់ពីមន្ត្រីជំនាញបច្ចេកទេសផ្នែកសំណង់ និងជាងជួសជុលក៏ត្រូវមានជំនាញច្បាស់លាស់ផងដែរ។[22]

អ្នកនាំពាក្យសាលាខេត្តសៀមរាបធ្លាប់បានបញ្ជាក់ថា“ដើម្បីធានាសុវត្ថិភាពដល់ប្រជាពលរដ្ឋ ដែលរស់នៅក្នុងអគារមានវ័យចំណាស់ក្នុងតំបន់ផ្សារចាស់ និងផាប់ស្រ្ទីតនេះ អាជ្ញាធរក្រុងសៀមរាបសហការជាមួយមន្ទីររៀបចំដែនដី ដើម្បីបង្កើតឲ្យមានគណៈកម្មការមួយសម្រាប់ដោះស្រាយបញ្ហាបាក់អគារ និងធ្វើការគ្រប់គ្រងអគារដែលបានសាងសង់នៅសម័យបារាំងដែលមានវ័យចំណាស់ នៅតំបន់ផ្សារចាស់ និងផាប់ស្រ្ទីតនេះ ដើម្បីទប់ស្កាត់ការបង្កឲ្យមានគ្រោះថ្នាក់បាក់រលំអគារនេះនៅថ្ងៃក្រោយទៀត”។[23]ជំហានដំបូងនៃការដោះស្រាយបញ្ហាបាក់រលំអគារនេះ អាជ្ញាធរបានឲ្យប្រជាពលរដ្ឋដែលមានផ្ទះជាប់អគារបាក់រលំនេះប្រមាណជា៤ល្វែងផ្អាកធ្វើអាជីវកម្មនិង

[21] https://tvsiemreap.com/?p=906(ចូលទស្សនាចុងក្រោយថ្ងៃទី២៦ ឧសភា ២០១៩)។

[22] https://tvsiemreap.com/?p=906(ចូលទស្សនាចុងក្រោយថ្ងៃទី២៦ ឧសភា ២០១៩)។

[23] https://tvsiemreap.com/?p=906(ចូលទស្សនាចុងក្រោយថ្ងៃទី២៦ ឧសភា ២០១៩)។

ចាកចេញពីផ្ទះបណ្តោះអាសន្នសិន ចៀសវាងមានគ្រោះថ្នាក់នៅពេលដែលគេសម្អាតអគារដែលបាក់រលំនេះ ហើយក្រុមហ៊ុនដែលមកធ្វើការសម្អាតអគារនេះម្ចាស់ហាងត្រូវរកក្រុមហ៊ុនដែលមានបទពិសោធន៍ ហើយមានបច្ចេកទេសច្បាស់លាស់ចំពោះការងារនេះ។ បន្ទាប់ពីការងារជំហានទី១រួចរាល់ ក្រុមការងារបានបន្តពិនិត្យមើលអគារដែលមានវ័យចំណាស់នៅតំបន់ផ្សារចាស់ និងជាប់ស្ទឹតនេះ ថាតើអគារណាដែលអាចបន្តស្នាក់នៅបាន និងអគារណាចាំបាច់ត្រូវជួសជុល និងពិនិត្យទៅលើការប្រើប្រាស់អគារលើតម្រូវការដូចជា អគារដែលបានសាងសង់នៅសម័យបារាំងទាំងនេះគឺសម្រាប់តែមនុស្សរស់នៅតែប៉ុណ្ណោះ។ ប៉ុន្តែឥឡូវគេបានយកមកធ្វើអាជីវកម្ម ដូចជានៅផ្នែកខាងលើបានកែឆ្នៃឲ្យទៅជាកន្លែងរាំច្រៀងដែលមានមនុស្សច្រើនលើសទម្ងន់ដែលអគារមិនអាចទ្រូបាន ។បញ្ហាទាំងនេះជាកត្តាចាំបាច់ដែលអាជ្ញាធរត្រូវធ្វើការណែនាំដល់ម្ចាស់អាជីវកម្មទាំងអស់ករណីម្ចាស់អាជីវកម្មណាមិនធ្វើតាមអាចឈានដល់បិទការធ្វើអាជីវកម្មផងដែរ។[24]

**១.២.១.៣.ការរៀបចំរបៀបរៀបរយ**

រដ្ឋបាលក្រុងសៀមរាបសង្កេតឃើញថាកន្លងមកមានបងប្អូនប្រជាពលរដ្ឋដែលជាម្ចាស់ទីតាំងអាជីវកម្ម និងអ្នកបើកបរយានយន្តគ្រប់ប្រភេទមួយចំនួនបានរំលោភបំពានយកដីចំណីផ្លូវចិញ្ចើមផ្លូវសាធារណៈ និងធ្វើសកម្មភាពផ្សេងៗ ទៀត ដើម្បីបម្រើផលប្រយោជន៍ឯកជនរបស់ខ្លួន ដូចជាការប្រើប្រាស់ធ្វើជាចំណតយានជំនិះ បើកបញ្ច្រាសទិស បង្កើតទីតាំងលក់ដូរឬជួល លើកស្លាកយីហោឬស្លាកផ្សព្វផ្សាយពាណិជ្ជកម្មនិងការតបណ្តាញអគ្គិសនីចេញពីទីតាំងអាជីវកម្មពុំមានបច្ចេកទេសត្រឹមត្រូវជាដើមដែលសកម្មភាពទាំងនោះបានធ្វើឲ្យប៉ះពាល់យ៉ាងធ្ងន់ធ្ងរដល់សណ្តាប់ធ្នាប់របៀបរៀបរយ បាត់បង់សោភ័ណភាព ប្រព័ន្ធចរាចរណ៍ គ្មានផ្លូវថ្មើរជើង បង្កឲ្យមានគ្រោះថ្នាក់ចរាចរណ៍និងគ្រោះអគ្គិភ័យជាយថាហេតុនិងជាការប្រព្រឹត្តផ្ទុយនឹងច្បាប់ស្តីពីចរាចរណ៍ផ្លូវគោក ច្បាប់ស្តីពីផ្លូវថ្នល់ និងលិខិតបទដ្ឋានគតិយុត្តពាក់ព័ន្ធ។ ដើម្បីពង្រឹងការគោរពនិងអនុវត្តន៍ច្បាប់ឲ្យមានប្រសិទ្ធភាពក៏ដូចជាការលើកកម្ពស់សោភ័ណភាពក្រុងសៀមរាបឲ្យសមជាទីក្រុងទេសចរណ៍វប្បធម៌ប្រវត្តិសាស្ត្រ រដ្ឋបាលក្រុងសៀមរាបបានធ្វើការចាត់វិធានការដូចខាងក្រោម៖

១. ការចតយានយន្តគ្រប់ប្រភេទ ត្រូវអនុវត្តន៍ឲ្យបានត្រឹមត្រូវតាមគំនូសសញ្ញាចរាចរណ៍លើផ្លូវរួមទាំងស្លាកសញ្ញាចរាចរណ៍ និងការចង្អុលបង្ហាញរបស់អាជ្ញាធរមានសមត្ថកិច្ចពាក់ព័ន្ធបានកំណត់។

២. ម្ចាស់អាជីវកម្មនិងបុគ្គលិក ត្រូវដាក់តាំងរបស់របរលក់ និងចតយានយន្តផ្ទាល់ខ្លួនក្នុងទីតាំងកម្មសិទ្ធិរបស់ខ្លួន មិនត្រូវចតរំលោភ ឬ ប្រើប្រាស់ដីចំណីផ្លូវសាធារណៈជាដាច់ខាត។

[24] https://tvsiemreap.com/?p=906(ចូលទស្សនាចុងក្រោយថ្ងៃទី២៦ ឧសភា ២០១៩)។

៣. ផ្លូវលេខ៧ដល់លេខ១១ និងកំណាត់ផ្លូវលេខ៨អនុញ្ញាតឲ្យបិទការធ្វើចរាចរណ៍យានយន្តចាប់ពីម៉ោង១៨:០០នាទី ដល់ម៉ោង២៣:០០នាទី ដើម្បីទុកឲ្យភ្ញៀវទេសចរជាតិ និងអន្តរជាតិធ្វើដំណើរដោយថ្មើរជើង។

៤. កម្លាំងសមត្ថកិច្ចសណ្តាប់ធ្នាប់ និងចរាចរណ៍ក្រុងព្រមទាំងសមត្ថកិច្ចពាក់ព័ន្ធត្រូវឈរជើងប្រចាំការ និងសម្របសម្រួលចរាចរណ៍ រៀបចំផ្លូវថ្មើរជើង សន្តិសុខ របៀបរៀបរយការដាក់តាំងលក់ និងអ្នកលក់ដូរចល័ត។

៥. អង្គភាពអគ្គិសនីក្រុង ត្រូវចាត់មន្ត្រីបច្ចេកទេសចុះត្រួតពិនិត្យ និងរៀបចំប្រព័ន្ធបណ្តាញខ្សែភ្លើងឡើងវិញ។

៦. រដ្ឋបាលក្រុងសៀមរាប សហការជាមួយមន្ទីរពាណិជ្ជកម្មខេត្ត មន្ទីរទេសចរណ៍ខេត្ត មន្ទីរសុខាភិបាលខេត្ត មន្ទីរវប្បធម៌ និងវិចិត្រសិល្បៈខេត្ត រៀបចំនិងគ្រប់គ្រងធ្វើអាជីវកម្ម ការលើកស្លាកយីហោ ការផ្សព្វផ្សាយពាណិជ្ជកម្ម និងគុណភាពចំណីអាហារ។

៧.មន្ទីរបរិស្ថានខេត្តនិងមន្ទីរសាធារណៈការនិងដឹកជញ្ជូនខេត្តត្រូវសហការគ្នាគ្រប់គ្រងកាកសំណល់រាវរឹងឲ្យបានល្អប្រសើរ។

៨. ការបំពងសំលេងត្រូវអនុវត្តន៍តាមស្តង់ដារបច្ចេកទេសកំណត់របស់ក្រសួងបរិស្ថាន។[25]

ម៉្យាងវិញទៀត យោងតាមសេចក្តីណែនាំរបស់សាលាខេត្តសៀមរាបស្តីពីការធ្វើចរាចរណ៍របស់យានយន្តគ្រប់ប្រភេទ និងការរៀបចំសណ្តាប់ធ្នាប់ របៀបរៀបរយសាធារណៈ និងបរិស្ថានអនាម័យ នៅក្នុងក្រុងសៀមរាបខេត្តសៀមរាបដោយបច្ចុប្បន្ននេះរដ្ឋបាលខេត្តបានសង្កេតឃើញថា នៅតាមបណ្តាផ្លូវ និងទីប្រជុំជនមួយចំនួនមានក្រុមហ៊ុនសេវាដឹកជញ្ជូន ឬក្រុមហ៊ុនទេសចរណ៍ និងបងប្អូនប្រជាពលរដ្ឋដែលកំពុងប្រកបមុខរបរសេវាដឹកជញ្ជូន ម្ចាស់សណ្ឋាគារ ភោជនីយដ្ឋាន គ្រឹះស្ថាន សហគ្រាស អាជីវកម្មដ្ឋានគ្រប់ប្រភេទ ប្រជាពលរដ្ឋ និងភ្ញៀវជាតិ អន្តរជាតិ បានប្រើប្រាស់ទីតាំងដីចំណីផ្លូវសម្រាប់ធ្វើជាចំណតចតយានយន្តក្នុងគោលបំណងដើម្បីបម្រើដល់ផលប្រយោជន៍អាជីវកម្មរបស់ខ្លួន។ ក្នុងនោះដែរក៏មានអាកប្បកិរិយាឥរិយាបទមិនសមរម្យ និងមានការប៉ះពាល់ដល់សាធារណៈជនទូទៅដែលក្នុងនាមជាអ្នកបម្រើសេវាជូនភ្ញៀវជាតិ អន្តរជាតិ ប្រជាពលរដ្ឋដែលបានទៅទទួលសេវាដឹកជញ្ជូនផ្សេងៗ ឬធ្វើដំណើរឆ្លងកាត់នៅតំបន់ទាំងនោះ ហើយនឹងអាចឈានដល់ការប្រើប្រាស់អំពើហិង្សាក្លាយជាបទល្មើសព្រហ្មទណ្ឌទៀតផង ហើយដែល

[25] សេចក្តីណែនាំស្តីពីការរៀបចំសណ្តាប់ធ្នាប់ របៀបរៀបរយ និងសុវត្ថិភាពនៅតំបន់ផាប់ស្ទ្រីត ក្រុងសៀមរាប ខេត្តសៀមរាប, លេខ០០៣ សណន, ០៣ កក្កដា ២០១៧។

សកម្មភាពខាងលើនេះបានបង្ក និងអនុវត្តន៍ផ្ទុយទៅនឹងគោលការណ៍ច្បាប់ លិខិតបទដ្ឋានគតិយុត្តជាធរមាន និងអាចឈានទៅការបាត់បង់ទ្រព្យសម្បត្តិ ការបង្កគ្រោះថ្នាក់ជាយថាហេតុផ្សេងៗ ឬអាចមានការកកស្ទះចរាចរណ៍ និងជះឥទ្ធិពលអវិជ្ជមានដល់សណ្តាប់ធ្នាប់ និងរបៀបរៀបរយសាធារណៈ ព្រមទាំងធ្វើឲ្យប៉ះពាល់ដល់កិត្តិយស សោភ័ណភាពរបស់ក្រុងសៀមរាប ក៏ដូចជាខេត្តសៀមរាប ដែលជាខេត្តទេសចរណ៍ប្រវត្តិសាស្ត្រផងដែរ។[26]

ដើម្បីរក្សាបាននូវសណ្តាប់ធ្នាប់ និងរបៀបរៀបរយសាធារណៈ ជាពិសេសដើម្បីធានាបាននូវសោភ័ណភាព បរិស្ថាន អនាម័យនៅតាមបណ្តាផ្លូវ និងទីប្រជុំជននានាឲ្យកាន់តែបានល្អប្រសើរ និងចៀសផុតពីការបង្កភាពអសកម្ម និងភាពអវិជ្ជមានណាមួយពាក់ព័ន្ធនឹងករណីខាងលើ រដ្ឋបាលខេត្តបានធ្វើការណែនាំនូវគោលការណ៍ដូចខាងក្រោម៖

១. ចំពោះរថយន្តដឹកជញ្ជូនទំនិញ រថយន្តសណ្តោងរ៉ឺម៉ក និងរថយន្តឈ្នួល ឬរថយន្តដឹកជញ្ជូនអ្នកដំណើរគ្រប់ប្រភេទត្រូវចូលចតចំណតចំនួន២ទីតាំង ដែលរដ្ឋបាលខេត្តបានកំណត់ចាប់ពីថ្ងៃទី៣០ ខែមេសា ឆ្នាំ២០១៩ រួមមាន៖

- ចំណតប៉ែកខាងកើតក្រុងស្ថិតក្នុងបុរីសៀងណាំ ភូមិខ្នា សង្កាត់ជ្រាវ ក្រុងសៀមរាប ខេត្តសៀមរាប
- ចំណតប៉ែកខាងលិចក្រុងស្ថិតនៅភូមិថ្នល់ សង្កាត់ស្រង៉ែ ក្រុងសៀមរាប ខេត្តសៀមរាប

២. រថយន្តដឹកជញ្ជូនទំនិញ រថយន្តសណ្តោងរ៉ឺម៉ក រថយន្តឈ្នួល និងរថយន្តដឹកជញ្ជូនអ្នកដំណើរគ្រប់ប្រភេទនិងយានយន្តដឹកជញ្ជូនសារធាតុស្អុយគ្រប់ប្រភេទមិនអនុញ្ញាតឲ្យធ្វើចរាចរណ៍ ឬចតនៅតាមបណ្តាផ្លូវជាតិលេខ៦ឬបណ្តាផ្លូវមួយចំនួនស្ថិតក្នុងភូមិសាស្ត្រក្រុងសៀមរាបឡើយ។ ចំពោះរថយន្តគ្រប់ប្រភេទដែលបានបញ្ជាក់ខាងលើនេះ ត្រូវធ្វើចរាចរណ៍ឆ្លងកាត់តាមផ្លូវវាងក្រុងសៀមរាប ចាប់ពីចំណុចផ្លូវវាងក្រុងប៉ែកខាងកើត ស្តុបចរាចរណ៍ផ្លូវជាតិលេខ៦( ស្តុបចុងកៅស៊ូ) ស្ថិតនៅភូមិខ្នា សង្កាត់ជ្រាវ ក្រុងសៀមរាប និងផ្លូវវាងក្រុងប៉ែកខាងលិចក្រុង ចំណុចផ្លូវបំបែកផ្លូវជាតិលេខ៦ ជិតទីតាំងស្នាក់ការគយ និងរដ្ឋាករខេត្តស្ថិតនៅភូមិសណ្តាន់ សង្កាត់ទឹកវិល ក្រុងសៀមរាប។

៣. ក្រុមហ៊ុន ឬអ្នកប្រកបមុខរបរសេវាដឹកជញ្ជូន ឬក្រុមហ៊ុនទេសចរណ៍ សណ្ឋាគារ ភោជនីយដ្ឋាន គ្រឹះស្ថាន សហគ្រាស អាជីវកម្មដ្ឋានគ្រប់ប្រភេទមិនអនុញ្ញាតឲ្យមានការរៀបចំ ឬ

[26] សេចក្តីណែនាំស្តីពីការធ្វើចរាចរណ៍របស់យានយន្តគ្រប់ប្រភេទ និងការរៀបចំសណ្តាប់ធ្នាប់ របៀបរៀបរយសាធារណៈ និងបរិស្ថាន អនាម័យ នៅក្នុងក្រុងសៀមរាប ខេត្តសៀមរាប, លេខ០០១ សណន, ០២ មេសា ២០១៩។

រំលោភយកទ្រូងផ្លូវ ចិញ្ចើមផ្លូវ និងចំណីផ្លូវ ធ្វើជាកម្មសិទ្ធិកន្លែងផ្ញើរថយន្ត ម៉ូតូ កង់ ម៉ូតូរ៉ឺម៉ក និងយានយន្តគ្រប់ប្រភេទ ដើម្បីបម្រើផលប្រយោជន៍របស់ខ្លួនដែលធ្វើឲ្យបាត់បង់នូវសណ្តាប់ធ្នាប់សាធារណៈ និងរបៀបរៀបរយសាធារណៈ។

៤. ចំពោះរថយន្តសម្រាប់បម្រើការដឹកជញ្ជូនដី ថ្ម ខ្សាច់ ទំនិញ ឬសម្ភារៈផ្សេងៗ និងសំរាម មិនអនុញ្ញាតឲ្យផ្ទុកហួសកម្រិត(ស្ថានភាពដើម) និងមានការគ្រប ឬគម្របគ្របឲ្យបានជិត និងត្រឹមត្រូវល្អប្រសើរ ដើម្បីធានាឲ្យមានលក្ខណៈបច្ចេកទេស មិនឲ្យហុយ ធ្លាក់ ជ្រុះ ស្រក់ទឹក....។ល។ នៅតាមដងផ្លូវឡើយ។

៥. ចំពោះក្រុមហ៊ុន ឬដេប៉ូផ្សេងៗ ឬក្រុមហ៊ុនទេសចរណ៍ដែលចាំបាច់ត្រូវធ្វើចរាចរណ៍ចូលក្នុងក្រុងសៀមរាបដូចជា៖ រថយន្តដឹកជញ្ជូនភ្ញៀវទេសចរ និងរថយន្តធ្វើអាជីវកម្មលាយស៊ីម៉ង់ត៍ ដឹកដី ថ្ម ខ្សាច់ និងគ្រឿងសំណង់ផ្សេងៗត្រូវស្នើសុំការអនុញ្ញាតពីរដ្ឋបាលខេត្ត ព្រមទាំងមានការត្រួតពិនិត្យលក្ខណៈបច្ចេកទេស ស្របតាមគោលការណ៍ច្បាប់ លិខិតបទដ្ឋានគតិយុត្ត និងរៀបចំការកំណត់ពេលវេលាសម្រាប់ធ្វើចរាចរណ៍។

៦. ចំពោះម្ចាស់ក្រុមហ៊ុនបម្រើសេវាដឹកជញ្ជូនទាំងអស់ត្រូវពិនិត្យលទ្ធភាពផ្លាស់ប្តូរទីតាំងស្នាក់ការលក់សំបុត្រ ឬការទទួល និងដឹកភ្ញៀវ ឲ្យមានទីតាំងស្នាក់ការរបស់ខ្លួនស្ថិតនៅក្នុង ឬជិតទីតាំងចំណតដែលបានកំណត់ខាងលើ ហើយមិនអនុញ្ញាតឲ្យមានការទទួល ឬដឹកជញ្ជូនភ្ញៀវក្រៅពីចំណុចដែលបានកំណត់ឡើយ។ ដោយឡែក ចំពោះទីស្នាក់ការដែលស្ថិតនៅក្រៅពីចំណតដែលបានកំណត់ អនុញ្ញាតត្រឹមតែការបម្រើលក់សំបុត្រតែប៉ុណ្ណោះ។

៧. ការចតយានយន្តគ្រប់ប្រភេទ ត្រូវអនុវត្តន៍ឲ្យបានត្រឹមត្រូវតាមគំនូសសញ្ញាចរាចរណ៍ ស្លាកសញ្ញាចរាចរណ៍ ឬការចង្អុលបង្ហាញរបស់អាជ្ញាធរមានសមត្ថកិច្ចពាក់ព័ន្ធ ព្រមទាំងការបើកបរល្បឿន ដោយគោរពច្បាប់ចរាចរណ៍ផ្លូវគោក និងលិខិតបទដ្ឋានគតិយុត្តជាធរមាន។

៨. ត្រូវសម្អាតបរិស្ថាន អនាម័យ និងវេចខ្ចប់កាកសំណល់រឹង រាវ គ្រប់ប្រភេទឲ្យបានត្រឹមត្រូវ និងស្អាតជាប្រចាំ ទាំងនៅក្នុង ឬក្រៅបរិវេណចំណត ដែលបានប្រកបមុខរបរ និងអាជីវកម្មរបស់ខ្លួន ព្រមទាំងការបញ្ចេញកាកសំណល់សំរាមឲ្យបានត្រឹមត្រូវ តាមពេលវេលាកំណត់ដើម្បីងាយស្រួលឲ្យក្រុមហ៊ុនប្រមូលសំរាមដឹកជញ្ជូន។

៩. ស្នងការនគរបាលខេត្ត រដ្ឋបាលក្រុង ស្រុក ឃុំ សង្កាត់ ត្រូវចុះពិនិត្យ ទៅលើការរៀបចំសណ្តាប់ធ្នាប់ របៀបរៀបរយសាធារណៈ សោភ័ណភាព និងអនាម័យ បរិស្ថានឲ្យបានស្អាតជាប្រចាំទៅតាមដែនដីសមត្ថកិច្ចរបស់ខ្លួន និងត្រូវរៀបចំផែនការសកម្មភាពដើម្បីអនុវត្តន៍ការងារ

តាមសមត្ថកិច្ចរៀងៗខ្លួនដោយស្របតាមគោលការណ៍ណែនាំ ច្បាប់ និងលិខិតបទដ្ឋានគតិយុត្តជាធរមាន។[27]

### ១.២.២. ទិសដៅអនាគតនៃការរៀបចំ

ជាទូទៅការធ្វើកិច្ចការអ្វីមួយ គឺចាំបាច់ត្រូវមានផែនការ ឬទិសដៅមួយច្បាស់លាស់ដើម្បីត្រៀមក្នុងការអនុវត្តការងារនោះឲ្យដំណើរការទៅបានល្អ។ ជាក់ស្តែងក្រុងសៀមរាបបានដាក់គោលដៅក្នុងការអភិវឌ្ឍក្រុងរបស់ខ្លួនសម្រាប់ពេលអនាគតខាងមុខទៅលើវិស័យជាច្រើនផងដែរ។

#### ១.២.២.១. ការអភិវឌ្ឍលើវិស័យហេដ្ឋារចនាសម្ព័ន្ធ

ក្នុងការអភិវឌ្ឍលើវិស័យហេដ្ឋារចនាសម្ព័ន្ធ ក្រុងសៀមរាបក៏មានទិសដៅអភិវឌ្ឍន៍សម្រាប់ថ្ងៃអនាគតផងដែរ ដែលទិសដៅទាំងនោះរួមមាន៖

- ការកែលម្អផ្លូវក្នុងតំបន់ផ្សារចាស់
- ការអភិវឌ្ឍឧទ្យានតូចៗនៅកែងផ្លូវក្នុងតំបន់ផ្សារចាស់
- ការរៀបចំនូវកាតព្វកិច្ចការងារសម្រាប់កែលម្អតំបន់ផ្សារចាស់ជាមួយសមាគមន៍ក្នុងតំបន់
- ការគ្រប់គ្រងចរាចរណ៍រួម(ចំណតសាធារណៈ តំបន់សម្រាប់តែដើរ និងការត្រួតពិនិត្យផ្លូវឯកទិស )
- ការអភិរក្សបេតិកភណ្ឌក្រុង និងដើមឈើចាស់ៗនៅតាមផ្លូវ
- ការកែលម្អផ្ទាំងព័ត៌មានបេតិកភណ្ឌក្រុង
- ការអភិរក្ស និងកែលម្អនៃតំបន់ដងស្ទឹងសៀមរាប
- ពង្រឹងយន្តការសម្របសម្រួលនិងសហប្រតិបត្តិការក្នុងចំណោម អាជ្ញាធរអភិវឌ្ឍន៍ក្រុង
- គម្រោងជួសជុលស្ពានបេតុងស្ថិតនៅភូមិគោកត្នោត សង្កាត់គោកចក
- គម្រោងជួសជុលទ្វារទឹកពាកន្លែងនៅភូមិចុងកៅស៊ូ សង្កាត់ស្លក្រាម
- គម្រោងស្តារប្រព័ន្ធបណ្តាញផ្លូវនៅតំបន់បេតិកភណ្ឌជនបទ
- គម្រោងជួសជុលផ្លូវក្រួសក្រហមមួយកន្លែង(ទំហំ ៦ម×៧២០ម)នៅភូមិអញ្ចាញ សង្កាត់នគរធំ
- គម្រោងជួសជុលផ្លូវបេតុងអាមេ ១ខ្សែ ប្រវែង៣២៦ម៉ែត្រ ទទឹង៥ម៉ែត្រ នៅភូមិទ្រាំង សង្កាត់ស្លក្រាម
- គម្រោងជួសជុលលូរំដោះទឹក ១ខ្សែ ប្រវែង ១២៧ម៉ែត្រ នៅភូមិតាវៀនសង្កាត់សាលាកំរើក

---

[27] សេចក្តីណែនាំស្តីពីការធ្វើចរាចរណ៍របស់យានយន្តគ្រប់ប្រភេទ និងការរៀបចំសណ្តាប់ធ្នាប់ របៀបរៀបរយសាធារណៈ និងបរិស្ថាន អនាម័យ នៅក្នុងក្រុងសៀមរាប ខេត្តសៀមរាប, លេខ០០១ សណន, ០២ មេសា ២០១៩។

- គម្រោងជួសជុលផ្លូវបេតុងអាមេ ៣ខ្សែ ទី១ស្ថិតក្នុងភូមិតាវៀន សង្កាត់សាលាកំរើក មានប្រវែង ១៩៤ម៉ែត្រ និងទទឹង៥ម៉ែត្រ ទី២ស្ថិតក្នុងភូមិធ្លកអណ្តូង សង្កាត់ស្លក្រាម មានប្រវែង១៨៨ម៉ែត្រ និងទទឹង៥ម៉ែត្រ និងទី៣ស្ថិតក្នុងភូមិថ្មី សង្កាត់ស្វាយដង្គំ មានប្រវែង១៣៧ម៉ែត្រ និងទទឹង៦ម៉ែត្រ
- ពង្រីកផ្លូវដែលតូចចង្អៀត
- ជួសជុលផ្លូវដែលមានការខូចខាត និងបង្កើតគណៈកម្មាការគ្រប់គ្រងផ្លូវ និងចំណីផ្លូវ
- រកដៃគូវិនិយោគចំណតយានយន្ត។[28]

### ១.២.២.២. ការអភិវឌ្ឍលើវិស័យទឹកស្អាត និងអនាម័យ

នៅឆ្នាំ២០១៧ ក្រុងសៀមរាបបានធ្វើពិធីបញ្ចុះបឋមសិលាបើកការដ្ឋានសាងសង់រោងចក្រផលិតទឹកស្អាត ដែលរោងចក្រនេះ អាចពង្រីកសមត្ថភាពផ្គត់ផ្គង់ទឹក បានដល់ ១៥០០០ម៉ែត្រគូបក្នុង១ថ្ងៃ។ ក្រៅពីគម្រោងបើកការដ្ឋាននេះរដ្ឋាករទឹកស្វយ័តបានធ្វើការវិនិយោគជាទ្រង់ទ្រាយធំលើការពង្រីកប្រព័ន្ធផ្គត់ផ្គង់ទឹកស្អាតតាមរយៈការកៀរគរនូវប្រភពទុនពីដៃគូអភិវឌ្ឍន៍នានានូវគម្រោងចំនួន ០២ បន្ថែមទៀតដែលនឹងចាប់ដំណើរការនាពេលខាងមុខរួមមាន៖

១. គម្រោងពង្រីកបណ្តាញចែកចាយទឹកស្អាតក្រោមឥណទានរបស់ធនាគារអភិវឌ្ឍន៍អាស៊ី (ADB) ប្រើប្រាស់បំពង់ទឹកប្រវែង ៨៤គីឡូម៉ែត្រ និងសម្ភារៈតភ្ជាប់ មានទឹកប្រាក់សរុប ៥លានដុល្លារ និងថវិការបស់រដ្ឋាករទឹកស្វយ័តផ្ទាល់មានទឹកប្រាក់សរុបប្រមាណ២លានដុល្លារសម្រាប់បម្រើការងារដំឡើងបណ្តាញចែកចាយដែលនឹងដំណើរការនៅត្រីមាសទី១ចាប់ដំណើការឆ្នាំ២០១៨ បញ្ចប់ត្រីមាសទី៤ ឆ្នាំ២០១៩។

២. គម្រោងពង្រីកសមត្ថភាពប្រព័ន្ធផ្គត់ផ្គង់ទឹកស្អាតសៀមរាប ដែលមានបណ្តាញចែកចាយ១៩០គីឡូម៉ែត្រ និងនាំប្រព័ន្ធចម្រោះទឹកដោយយកប្រភពទឹកពីបឹងទន្លេសាបក្រោមឥណទានរបស់JICAមានទឹកប្រាក់៩៣លានដុល្លារ ដែលបានដំណើរការសាងសង់នៅត្រីមាសទី៣ ឆ្នាំ២០១៨ និងបញ្ចប់នៅត្រីមាសទី២ ឆ្នាំ២០២១។

ដូចនេះនៅឆ្នាំ២០២១រដ្ឋាករទឹកស្វយ័តនឹងមានសមត្ថភាពអាចផលិតទឹកស្អាតបំពេញតម្រូវការទាំងស្រុងសម្រាប់ប្រជាពលរដ្ឋក្នុងក្រុងសៀមរាបដែលអាចផលិតបានចំនួនប្រមាណ៩ម៉ឺនម៉ែត្រគូបក្នុង១ថ្ងៃ ជាមួយបណ្តាញចែកចាយទឹក សរុបប្រមាណ ៩៥០គីឡូម៉ែត្រ។[29]

---

[28] របាយការណ៍បញ្ចប់អាណត្តិទី២របស់ក្រុមប្រឹក្សាក្រុងសៀមរាប(២០១៤-២០១៨), ២០១៩។

[29] https://kbn.news/archives/82184(ចូលទស្សនាចុងក្រោយ ថ្ងៃទី១០ មិថុនា ២០១៩)។

ម្យ៉ាងទៀតសាលាក្រុងសៀមរាបមានគម្រោងកែលម្អប្រព័ន្ធបង្ហូរទឹកក្នុងក្រុងសៀមរាប ដែលគម្រោងនេះផ្តោតសំខាន់ទៅលើ ប្រព័ន្ធបង្ហូរទឹកភ្លៀង ទឹកកខ្វក់ ក្នុងក្រុង ដើម្បីធ្វើការបញ្ចៀសនូវការលិចលង់ក្នុងក្រុង។ គម្រោងនេះ រយៈពេលខ្លីដល់ឆ្នាំ២០២០ និងរយៈពេលវែង២០៣០ ។នៅក្នុងគម្រោងនេះ មានការសាងសង់ប្រឡាយមេ ៧ខ្សែ ប្រវែង២៩គីឡូម៉ែត្រ និង ប្រព័ន្ធលូ ប្រឡាយក្នុងក្រុងប្រវែង ៩៣គីឡូម៉ែត្រ ។ ក្នុងនោះដែរក៏មានការសាងសង់ស្ថានីយ៍ចម្រោះនៅផ្នែកខាងកើតក្រុង ដែលមាន សមត្ថភាព១០ពាន់ម៉ែត្រគូប ក្នុងមួយថ្ងៃ និង បណ្តាញលូមេប្រវែង ៥ពាន់៨០០ម៉ែត្រ ។ ក្នុងគម្រោងនេះ នឹងធ្វើ ឲ្យបរិស្ថាននៅអមប្រឡាយ ត្រូវបានធ្វើការកែលម្អ ព្រមទាំងលើកកម្ពស់ជីវភាព និង សុខមាលភាព ប្រជាពលរដ្ឋ ទៀតផង។ ម្យ៉ាងទៀត តាមរយៈ គម្រោងនេះ នឹងមានការកែលម្អ ប្រព័ន្ធលូទឹកក្នុងក្រុង ឲ្យសមជាក្រុងទេសចរណ៍ប្រវត្តិសាស្ត្រ ក្នុងការធានាកាត់បន្ថយជាអតិបរិមានូវគ្រោះមហន្តរាយទឹកជំនន់។[30]

### ១.២.២.៣. ទិសដៅរៀបចំសន្តិសុខសណ្តាប់ធ្នាប់

ក្នុងការរៀបចំសន្តិសុខសណ្តាប់សាធារណៈ ក្រុងសៀមរាបក៏មានទិសដៅរៀបចំសម្រាប់ថ្ងៃអនាគតផងដែរ ហើយទិសដៅទាំងនោះរួមមាន៖

- តាមដាន និងត្រួតពិនិត្យ ពួកក្មេងទំនើង និងអ្នកប្រើប្រាស់គ្រឿងញៀន
- ត្រួតពិនិត្យអាវុធជាតិផ្ទុះនៅពេលយប់
- ត្រួតពិនិត្យអ្នកចំណាកស្រុក អ្នកទៅធ្វើជាពលករ និងអ្នកចំណូលស្រុក
- សហការជាមួយស្ថាប័នពាក់ព័ន្ធផ្សេងៗដើម្បីរៀបចំកែលម្អសោភ័ណភាព និងសណ្តាប់ធ្នាប់សាធារណៈក្នុងក្រុងឲ្យបានល្អប្រសើរជាងមុន
- ពង្រឹងកម្លាំងសមត្ថកិច្ច និងប៉ុស្តិ៍ប្រជាការពារតាមគោលដៅ
- ចែកខ្លឹមសារលក្ខណៈសម្បត្តិ៩យ៉ាងអំពី ភូមិ ឃុំ មានសុវត្ថិភាពជាប្រចាំ
- បង្កើនការគ្រប់គ្រងរដ្ឋបាលចំហ និងបន្តផ្តល់អត្តសញ្ញាណប័ណ្ណជូនប្រជាពលរដ្ឋ
- សហការជាមួយអាជ្ញាធរសង្កាត់ទាំង១៣ ចុះបង្ក្រាបការលេងល្បែងស៊ីសង
- សហការជាមួយមន្ទីរសង្គមកិច្ចធ្វើការប្រមូលជនអនាថាទៅដាក់នៅមណ្ឌល
- ដោះស្រាយទំនាស់ជូនប្រជាពលរដ្ឋ
- តាមដាន និងទប់ស្កាត់ការសាងសង់សំណង់ខុសច្បាប់
- រៀបចំស្ថិតិអំពីការតាំងទីលំនៅបណ្តោះអាសន្នក្នុងក្រុង។[31]

[30] https://thmeythmey.com/?page=detail&id=76708(ចូលទស្សនាចុងក្រោយ ថ្ងៃទី១០ មិថុនា ២០១៩)។

[31] ផែនការអភិវឌ្ឍ( ២០១៥ - ២០១៩ ) របស់សាលាក្រុងសៀមរាប, ២០១៥, ២៥។

# ជំពូកទី២

# សោភ័ណភាព និងបរិស្ថានក្រុងសៀមរាប

# ជំពូកទី២
# សោភ័ណភាព និងបរិស្ថានក្រុងសៀមរាប

សោភ័ណភាព និងបរិស្ថាន គឺពិតជាមានសារៈសំខាន់ណាស់សម្រាប់ក្រុង ខេត្ត ឬប្រទេសមួយ ដែលចាំបាច់ត្រូវធ្វើការរៀបចំឲ្យបានល្អប្រសើរ។ ចំពោះក្រុងសៀមរាប បានកំពុងយកចិត្តដាក់យ៉ាងខ្លាំងទៅលើការរៀបចំសោភ័ណភាព និងបរិស្ថានក្រុងទាំងមូល ដោយសារក្រុងនេះជាគោលដៅទេសចរណ៍ដ៏សំខាន់មួយរបស់អ្នកទេសចរទាំងនៅក្នុងស្រុក និងនៅក្រៅស្រុក ដូច្នេះហើយ ការរៀបចំសោភ័ណភាពឲ្យមានភាពស្រស់ស្អាត និងទាក់ទាញក៏ដូចជាការរៀបចំបរិស្ថានឲ្យបានល្អប្រសើរគឺជាកត្តាដែលត្រូវយកចិត្តទុកដាក់ជាចាំបាច់។

## ២.១. សោភ័ណភាពក្នុងក្រុងសៀមរាប

សោភ័ណភាព៖ គឺសំដៅទៅលើភាពប្រសើរក្រៃលែង ភាពល្អហ្មត់ហ្មង។[32] សោភ័ណភាពនេះផងដែរគឺជាកត្តាមួយដែលជួយជម្រុញឲ្យមានការរៀបចំក្រុងនិងការអភិវឌ្ឍផ្សេងៗឲ្យបានល្អប្រសើរ។គ្រប់ទីកន្លែងទាំងអស់គឺសុទ្ធតែទាមទារឲ្យមានភាពស្រស់ស្អាតឬភាពល្អហ្មត់ហ្មងដើម្បីបង្កើតឲ្យមានភាពទាក់ទាញនិងតម្រូវការផ្សេងៗពីមជ្ឈដ្ឋានជុំវិញ។

ទីក្រុងដែលត្រូវបានគេទទួលស្គាល់និងមានភាពល្បីល្បាញទូទាំងពិភពលោកគឺជាទីក្រុងដែលមានសោភ័ណភាពស្រស់បំព្រង មានទេសភាពអស្ចារ្យ និងមានការរៀបចំត្រឹមត្រូវ។ជាក់ស្តែងទីក្រុងទាំង១០ដែលត្រូវបានគេទទួលស្គាល់ថាជាទីក្រុងស្អាតជាងគេនៅលើពិភពលោកគឺមានដូចជា ទីក្រុង Sydney(ប្រទេស Australia) ទីក្រុង New York ( United States) ទីក្រុង Singapore (ប្រទេស Singapore ) ទីក្រុង Cape (ប្រទេសSouth of Africa) ទីក្រុង Rio De Janeiro (ប្រទេស Brazil ) ទីក្រុង Istanbul ( ប្រទេស Turkey ) ទីក្រុង Florence (ប្រទេស Italy) ទីក្រុង Budapest (ប្រទេស Hungary) ទីក្រុង Paris (ប្រទេសបារាំង) ទីក្រុង Venice (ប្រទេស Italy) ដែលទីក្រុងទាំងអស់នេះសុទ្ធសឹងតែជាទីក្រុងដែលមានសោភ័ណភាពល្អដូចជា មានសំណង់ស្ថាបត្យកម្មខ្ពស់ៗទំនើបៗ ទីផ្លានិងសួនច្បារចម្រុះពណ៌ រូបសំណាកសិល្បៈស្រស់ស្អាតតាមដងផ្លូវជាដើមដែលទាក់ទាញភ្ញៀវទេសចរជាតិនិងអន្តរជាតិទៅទស្សនាកំសាន្តយ៉ាងច្រើនកុះករ។ [33] ជាក់ស្តែងចំពោះក្រុងសៀមរាបវិញគឺជាក្រុងមួយដែលមានប្រជាប្រិយភាពខ្លាំងក្នុងការទាក់ទាញភ្ញៀវទេសចរជាតិនិងអន្តរជាតិឲ្យមកទស្សនាកំសាន្ត និងមករស់នៅផងដែរ។

---

[32] សម្តេចព្រះសង្ឃរាជ ជួន ណាត,វចនានុក្រមខ្មែរ។

[33] http://www.kohthmey.com/thread-72729-1-1.html (ចូលទស្សនាចុងក្រោយ ថ្ងៃទី២៥ ឧសភា ២០១៩ )។

ដោយសារតែក្រុងសៀមរាមជាក្រុងដែលមានការរៀបចំសោភ័ណភាពដូចជាសួនច្បារ ដងផ្លូវ ឲ្យមានលក្ខណៈស្រស់ស្អាត មានទេសភាពស្រស់បំព្រង មានការបង្កើតនូវសំណង់អគារថ្មីៗ និង ថែរក្សាអភិរក្សសំណង់ស្ថាបត្យកម្មចាស់ៗដែលបន្សល់ទុកពីសម័យបុរាណ។

ជាទូទៅ សោភ័ណភាពក្រុងត្រូវបានគេបែងចែកជាពីរផ្នែកគឺ សោភ័ណភាពពេលថ្ងៃ និង សោភ័ណភាពពេលយប់។ជាការពិតណាស់នៅក្នុងក្រុងសៀមរាបក៏មានការបែងចែកសោភ័ណភាពទីក្រុងជាពីរផ្នែកផងដែរដើម្បីងាយស្រួលក្នុងការ អភិវឌ្ឍន៍និងអភិរក្សក្រុង។

### ២.១.១. សោភ័ណភាពពេលថ្ងៃ

សោភ័ណភាពពេលថ្ងៃ គឺសំដៅទៅលើការកសាងនិងរៀបចំហេដ្ឋារចនាសម្ព័ន្ធផ្សេងៗដែលមានដូចជាស្ពាន ផ្លូវថ្នល់ សាលារៀន សួនច្បារ សំណង់អគារ ប្រព័ន្ធដឹកជញ្ជូន ប្រព័ន្ធលូ ផ្លាកសញ្ញាចរាចរណ៍ ប្រព័ន្ធសុវត្ថិភាពចរាចរណ៍ និង មធ្យោបាយប្រើប្រាស់ផ្សេងៗឲ្យមានសោភ័ណភាព និងសណ្តាប់ធ្នាប់ល្អ។

#### ២.១.១.១.ការកសាងហេដ្ឋារចនាសម្ព័ន្ធនៅលើដី

ការកសាងហេដ្ឋារចនាសម្ព័ន្ធនៅលើដីគឺ សំដៅទៅលើការកសាងសំណង់នានាដូចជា ផ្លូវថ្នល់ សាលារៀន មន្ទីរពេទ្យ អគារ បុរីតម្រៀបគ្នាជាជួរៗ ផ្លាកសញ្ញា និងភ្លើងសញ្ញាចរាចរណ៍ជាដើម។ ជាក់ស្តែងនៅក្រុងសៀមរាប រដ្ឋបាលក្រុងបានយកចិត្តទុកដាក់យ៉ាងខ្លាំងក្នុងការកសាងទៅលើហេដ្ឋារចនាសម្ព័ន្ធជាច្រើនសម្រាប់បំពេញតម្រូវការទាំងភ្ញៀវទេសចរនិងប្រជាពលរដ្ឋនៅក្នុងមូលដ្ឋាន។

នៅប៉ុន្មានឆ្នាំចុងក្រោយមកនេះសាលាក្រុងសៀមរាបបានរៀបចំកសាងនិងកែលម្អហេដ្ឋារចនាសម្ព័ន្ធជាច្រើនដូចជាកសាងអគារថ្មីៗនិងបន្ទប់ទឹកនៅតាមសាលារៀនបឋមសិក្សា និងអនុវិទ្យាល័យមួយចំនួនធំដែលក្នុងនោះរួមមាន សាលាបឋមសិក្សាហ៊ុន សែនអញ្ចាញ ទទួលបានអគារថ្មថ្មី១ខ្នង ២បន្ទប់និងបន្ទប់ទឹក១ខ្នង៥បន្ទប់។ អនុវិទ្យាល័យ ធ្លក អណ្តូងទទួលបានអគារថ្ម២ខ្នង ២ជាន់ ស្មើនឹង១២ បន្ទប់។ អនុវិទ្យាល័យពោធិបន្ទាយជ័យទទួលបានអគារថ្ម១ខ្នង ៥បន្ទប់ និង បន្ទប់ទឹក១ខ្នង៨ បន្ទប់។ ក្រៅពីនេះក៏មានការកសាងនូវមន្ទីរពេទ្យរដ្ឋ និងឯកជនផងដែរដូចជាមន្ទីរពហុព្យាបាលមាន ៥កន្លែង មន្ទីរសម្រាកព្យាបាលមាន ១៣កន្លែង បន្ទប់ពិគ្រោះជម្ងឺ៧៩កន្លែង បន្ទប់ពិគ្រោះស្ត្រីមានផ្ទៃពោះមាន ៧៩កន្លែង បន្ទប់ថែទាំជម្ងឺមាន ៥៥កន្លែង ឱសថស្ថាន និងឱសថស្ថានរងមាន ១៨៦កន្លែង និង មន្ទីរពិសោធន៍វេជ្ជសាស្ត្រ ៦កន្លែងផងដែរ។[34] លើសពីនេះទៀតគឺមានការកែលម្អតំបន់កណ្តាលក្រុងដូចជា កែលម្អផ្លូវថ្មើរជើងប្រមាណ៣គីឡូម៉ែត្រ (ផ្លូវស៊ីវត្ថា និងផ្លូវក្នុង

[34] របាយការណ៍ប្រចាំឆ្នាំស្តីពីការអនុវត្តការងាររបស់រដ្ឋបាលក្រុងសៀមរាប, ២០១៨, ៣៥។

តំបន់ផ្សារចាស់)និងកែលម្អផ្លូវថ្មើរជើងនៅតាមផ្លូវនានាប្រមាណ១០.៥គីឡូម៉ែត្រ កែលម្អស្ពានសល់ពីសម័យអាណានិគមបារាំង។ជាងនេះទៅទៀតគឺមានការកសាងបណ្តាញផ្លូវទៅកាន់តំបន់ផ្សេងៗទៀតដូចជា តំបន់បេតិកភណ្ឌជនបទ(ក្បាលស្ពាន បាកាន ព្រះវិហារ កោះកេរ្តិ៍ ភ្នំគូលែន) សាងសង់ផ្លូវសម្រាប់ជិះកង់នៅតំបន់អង្គរ និងកសាងបុរីរដ្ឋបាលដែលប្រមូលផ្តុំគ្នានៅតំបន់តែមួយហើយតំរៀបគ្នាជាជួរៗដែលបានផ្តល់ភាពងាយស្រួលសម្រាប់ប្រជាពលរដ្ឋទៅទទួលយកសេវាសាធារណៈផ្សេងៗនៅទីនោះ និងបង្កើតឲ្យមានភាពស្រស់ស្អាតទាក់ភ្នែក។[35]

ម្យ៉ាងវិញទៀតបន្ទាប់ពីធ្វើការសិក្សាផែនការមេរួចហើយ សណ្ឋាគារនិងផ្ទះសំណាក់បានបន្តអភិវឌ្ឍន៍យ៉ាងឆាប់រហ័ស ក្នុងនោះសណ្ឋាគារប្រហែល៣០កន្លែងដែលប្រមាណជាមួយភាគបួននៃសណ្ឋាគារចំនួន១២០កន្លែងដែលមានស្រាប់ ត្រូវបានអភិវឌ្ឍន៍ថ្មីជាចម្បងនៅតាមបណ្តោយផ្លូវជាតិលេខ៦និងតំបន់៣រវាងតំបន់កណ្តាលក្រុងនិងឧទ្យានអង្គរ។ផ្ទះសំណាក់ប្រហែល៥៥កន្លែងដែលប្រមាណជាមួយភាពបួននៃផ្ទះសំណាក់ចំនួន២២៧កន្លែងត្រូវបានអភិវឌ្ឍន៍ថ្មីនិងប្រមូលផ្តុំក្នុងតំបន់ជាយនៃតំបន់ពាណិជ្ជកម្មកណ្តាលក្នុងតំបន់កណ្តាលក្រុង។ក្រៅពីនេះភោជនីយដ្ឋានកំពុងមានការកើនឡើងពី៩០ទៅដល់១២០កន្លែងដែលចំនួនកើនឡើងបន្ថែមនេះស្មើនឹងមួយភាគបួននៃចំនួនភោជនីយដ្ឋានសរុបដែលមានស្រាប់។[36] លើសពីនេះទៀតគឺមានការកសាង សួនច្បារថ្មីៗនិងសាងសង់ឧបករណ៍ហាត់ប្រាណជាច្រើនប្រភេទតាមដងផ្លូវសាធារណៈដើម្បីលើកកម្ពស់សុខុមាលភាពប្រជាពលរដ្ឋ និង ផ្តល់ភាពសប្បាយរីករាយជូនភ្ញៀវទេសចរជាតិនិងអន្តរជាតិ។[37]

### ២.១.១.២. ការកសាងហេដ្ឋារចនាសម្ព័ន្ធនៅក្រោមដី

ការកសាងហេដ្ឋារចនាសម្ព័ន្ធនៅក្រោមដីគឺសំដៅទៅលើការកសាងប្រព័ន្ធលូ ការដាក់ខ្សែភ្លើង និងខ្សែកាបអុបទិចក្រោមដីជាដើម។ការកសាងហេដ្ឋារចនាសម្ព័ន្ធនៅក្រោមដីនេះក៏ជារឿងមួយសំខាន់ផងដែរក្នុងការអភិវឌ្ឍទីក្រុង ពីព្រោះថាប្រព័ន្ធលូ និងប្រព័ន្ធខ្សែភ្លើងត្រូវមានការកសាងនិង គ្រប់គ្រងឲ្យបានត្រឹមត្រូវ និងហ្មត់ចត់ដើម្បីចៀសវាងនូវបញ្ហាកើតមានឡើង។ជាក់ស្តែងនៅក្នុងក្រុងសៀមរាបកន្លងមកយើងឃើញថាមានបញ្ហាចំណោទខ្លាំងចំពោះបញ្ហាប្រព័ន្ធទឹកកខ្វក់និងបញ្ហាទឹកជំនន់ក្នុងក្រុងដោយសារនៅកង្វះខាតបណ្តាញលូខ្មែងនិងខ្មែងរងដើម្បីតភ្ជាប់ពីលំនៅស្ថានរបស់ប្រជាពលរដ្ឋទៅកាន់បណ្តាញលូមេបើទោះបីកន្លងមកមានការគាំទ្រពីសំណាក់ដៃគូ

[35] របាយការណ៍ចុងក្រោយនៃការសិក្សាតាមដានស្តីពី ផែនការមេរួមសម្រាប់ការអភិវឌ្ឍដោយនិរន្តរភាពរបស់ក្រុងសៀមរាប, ២០១០, ០៦។

[36] របាយការណ៍ចុងក្រោយនៃការសិក្សាតាមដានស្តីពី ផែនការមេរួមសម្រាប់ការអភិវឌ្ឍដោយនិរន្តរភាពរបស់ក្រុងសៀមរាប, ២០១០, ២៥។

[37] https://thmeythmey.com/?page=detail&id=77808#(ចូលទស្សនាចុងក្រោយ ថ្ងៃទី២៥ ឧសភា ២០១៩ )។

អភិវឌ្ឍន៍លើផ្នែកអនាម័យក្តីដូចជា ធនាគារអភិវឌ្ឍន៍អាស៊ី ធនាគារអាហារណានីហារណ និងទីភ្នាក់ងារអភិវឌ្ឍន៍នៃប្រទេសបារាំង។ដោយមើលឃើញពីបញ្ហានេះ សាលាក្រុងក៏បានខិតខំយកចិត្តទុកដាក់ធ្វើការសហការជាមួយនឹងដៃគូអភិវឌ្ឍន៍នានាក្នុងការសាងសង់បណ្តាញលូខ្វែងនិងខ្វែងរងទឹកកខ្វក់ ដែលតភ្ជាប់ពីផ្ទះប្រជាពលរដ្ឋទៅកាន់បណ្តាញលូមេដើម្បីប្រមូលទឹកកខ្វក់យកទៅច្រោះសម្អាតនៅស្ថានីយន៍ច្រោះសម្អាតទឹកសំណល់ មុននឹងបញ្ចេញទៅប្រភពទឹកសាធារណៈវិញដើម្បីធានាបាននូវសុខភាពសាធារណៈ បរិស្ថាន និង អនាម័យសាធារណៈ។[38]

ម្យ៉ាងវិញទៀតចំពោះប្រព័ន្ធខ្សែភ្លើងវិញយើងឃើញថាសាលាក្រុងបានសហការជាមួយអង្គភាពពាក់ព័ន្ធដោយចុះទៅត្រួតពិនិត្យលើការជីក និង ខួងដីដាក់ខ្សែកាប្លិ៍អុបទិចក្នុងក្រុងសៀមរាបសៀមរាបរបស់ក្រុមហ៊ុន ស៊ីហ្វក ដោយក្នុងនោះជីកបាន ៩៤កន្លែង និងខួងបានចំនួន៤៧កន្លែង។[39]

**២.១.២. សោភ័ណភាពពេលយប់**

សោភ័ណភាពពេលយប់ គឺសំដៅទៅលើការកសាងនិងរៀបចំបំពាក់នូវភ្លើងបំភ្លឺតាមដងផ្លូវតាមស្ពាន អគារសាធារណៈ ឬអគារឯកជននាពេលរាត្រី និងការបំពាក់ភ្លើងចម្រុះពណ៌នៅតាមកន្លែងកំសាន្តនានាដូចជានៅតាមសួនច្បារ កំសាន្តផ្សេងៗឲ្យមានលម្អណៈស្រស់ស្អាត។

**២.១.២.១. ការដាក់បង្គោលភ្លើងបំភ្លឺតាមដងផ្លូវ និងអគារ**

ការដាក់បង្គោលភ្លើងបំភ្លឺតាមដងផ្លូវ និង អគារវាពិតជាមានសារៈសំខាន់ណាស់ព្រោះវាផ្តល់នូវសុវត្ថិភាពដោយជួយបំភ្លឺផ្លូវឲ្យភ្លឺជូនដល់ប្រជាពលរដ្ឋក្នុងការធ្វើដំណើរពេលយប់ ចៀសវាងការមើលផ្លូវមិនឃើញបង្កឲ្យមានគ្រោះថ្នាក់ដល់ពួកគាត់។ សាលាក្រុងសៀមរាបក៏បានគិតគូរដល់ការដាក់បង្គោលភ្លើងបំភ្លឺតាមដងផ្លូវ និង អគារនាពេលរាត្រីផងដែរ ដែលក្នុងនោះយើងឃើញ មានបង្គោលភ្លើងបំភ្លឺផ្លូវនៅតាមស្ពាន ផ្លូវថ្នល់ អគារសាធារណៈ សណ្ឋាគារលំដាប់ផ្កាយប្រាំ អគារពាណិជ្ជកម្មផ្សេងៗជាដើម។ ជាក់ស្តែង នៅក្នុងឆ្នាំ២០១៤ អាជ្ញាធរក្រុងសៀមរាប បានរៀបចំបង្គោលភ្លើងបំភ្លឺផ្លូវ និងភ្លើងលម្អតាមទីសាធារណៈ ចំនួន ៦២០ដើម ហើយដោយមានបំពាក់គោមភ្លើង និងភ្លើងលម្អ (ស៊ុំផ្ទាំងដែក) មួយចំនួន រួមទាំងរៀបចំបំពាក់ភ្លើងហ្វាលម្អ នៅតាមរង្វង់មូលចំនួន ៥កន្លែង ផងដែរ។

**២.១.២.២. ការដាក់ភ្លើងលម្អពេលរាត្រីតាមឧទ្យាន និងសួនច្បារសាធារណៈ**

ការដាក់ភ្លើងលម្អពេលរាត្រីគឺជាការដាក់ភ្លើងចម្រុះពណ៌ផ្សេងៗនៅតាមឧទ្យាន តាមទីធ្លា ឬសួនច្បារសាធារណៈដើម្បីបង្កើនឲ្យមានភាពស្រស់ស្អាតនិងទាក់ទាញនៅក្នុងក្រុងទាំងមូល។ ក្រុង

---

[38] https://www.pdisiemreap.info/siem-reap-development-dirty-water-sector-has-lack-network/(ចូលទស្សនាចុងក្រោយ ថ្ងៃទី២៥ ឧសភា ២០១៩)។

[39] របាយការណ៍បញ្ចប់អាណត្តិទី២របស់ក្រុមប្រឹក្សាក្រុងសៀមរាប(២០១៤-២០១៨), ២០១៩, ០៨។

ប្រវត្តិសាស្ត្រសៀមរាបត្រូវបានរៀបចំភ្លើងលម្អដើម្បីធ្វើឲ្យមានសោភ័ណភាពកាន់តែស្រស់ត្រកាលក្នុងការទទួលស្វាគមន៍ភ្ញៀវទេសចរជាតិ អន្តរជាតិឲ្យមកទស្សនាកំសាន្ត។ ក្នុងនោះឃើញមានការបំពាក់ និងការតុបតែងភ្លើងលម្អនៅតាមដងផ្លូវសាធារណៈដងវិថីនានា ទីប្រជុំជន ដងស្ទឹងសៀមរាប សំខាន់នៅជុំវិញបរិវេណព្រះវិហារព្រះអង្គចេកព្រះអង្គចម និង សួនច្បារនៅមុខព្រះរាជដំណាក់ផងដែរ ។ ម្យ៉ាងទៀតក្រុមបច្ចេកទេស ការរៀបចំលម្អភ្លើង គឺត្រូវរៀបចំយ៉ាងណាដើម្បីរំលេចនូវសោភ័ណភាពសម្រស់បៃតងនៅតាមដងស្ទឹង និងរុក្ខវិថីនានាក្នុងក្រុង នាពេលរាត្រីឲ្យកាន់តែធ្វើការទាក់ទាញអារម្មណ៍ភ្ញៀវទេសចរជាតិ អន្តរជាតិ ចូលមកទស្សនាកំសាន្តជាពិសេសក្នុងឱកាសព្រឹត្តិការណ៍អង្គរសង្ក្រាន្តជាដើម។[40]

## ២.២. បរិស្ថានក្រុងសៀមរាប

បរិស្ថាន ក៏ជាកត្តាមួយក្នុងការជម្រុញឲ្យមានការរៀបចំឲ្យបានល្អផងដែរ។ បញ្ហាអំពីបរិស្ថានគឺប្រទេសនៅទូទាំងសាកលលោកទៅហើយដែលបានគិតគូរទៅលើបញ្ហានេះជាធំដូច្នេះក្នុងក្រុងសៀមរាម គឺជាក្រុងមួយក្នុងចំណោមស្រុកទាំង១២ នៃខេត្តសៀមរាបដែលសាលាក្រុងបានយកចិត្តទុកដាក់យ៉ាងខ្លាំងទៅលើបញ្ហាបរិស្ថានផងដែរ។

ការប្រមូលសំរាមជារៀងរាល់ថ្ងៃគឺធានាការពារបាននូវគុណភាពទឹក ដី ខ្យល់ និងការគ្រប់គ្រងសំរាម សំណល់រឹង ភាវត្រឹមត្រូវធ្វើឲ្យបរិស្ថានរស់នៅមានភាពល្អប្រសើរ។ សម្រាប់ក្រុងសៀមរាប ដែលជាក្រុងទេសចរណ៍លំដាប់ទីមួយរបស់កម្ពុជា បញ្ហាសំរាមនៅមិនទាន់ដោះស្រាយបាននៅឡើយ។ ផ្លូវសំខាន់ៗ ដែលមានភ្ញៀវទេសចរដើរកំសាន្ត ក៏មានគំនរសំរាម និងជះក្លិនស្អុយជាហូរហែនៅឡើយ។ ប្រជាពលរដ្ឋរស់នៅក្រុងសៀមរាបមិនតិចទេ ដែលបានដឹងនិងបានឮពីភាពកម្សោយ សេវាប្រមូលសំរាមរបស់ក្រុមហ៊ុន។ ជារឿយៗគេតែងឃើញ និងឮប្រជាពលរដ្ឋរិះគន់ចំពោះភាពយឺតយ៉ាវរបស់ឡានដឹកសំរាម គ្មានទីតាំងសម្រាប់ដាក់សំរាមឲ្យបានត្រឹមត្រូវ ដែលធ្វើឲ្យសំរាមចេះតែកើនឡើងពីមួយថ្ងៃទៅមួយថ្ងៃ និងមានក្លិនស្អុយពេញផ្លូវសាធារណៈ មុខផ្ទះប្រជាពលរដ្ឋ និងមុខកន្លែងលក់ដូររបស់ពួកគេ។ ម្យ៉ាងទៀត តាមសណ្ឋាគារ អាហារដ្ឋាន ឬភោជនីយដ្ឋានមួយចំនួន ទៀតក៏នៅមិនទាន់បានវេចខ្ចប់សំរាមបានត្រឹមត្រូវនៅឡើយ។ ចំណែកឯក្នុងប្រព័ន្ធលូមួយចំនួនវិញ ឃើញមានសំរាមជាច្រើនសន្ធឹកសន្ធាប់បានកកស្ទះជាប់ក្នុងលូ ហើយមិនអាចហូរបានដែលនៅក្នុងនោះគេពិនិត្យឃើញមានដូចជា ថង់ប្លាស្ទិក ដបទឹក និងប្រអប់ស្នោជាដើម។

[40] http://www.cen.com.kh/archives/34997.html/entertainment/(ចូលទស្សនាចុងក្រោយថ្ងៃទី២៨ ឧសភា ២០១៩) ។

ចំពោះមូលហេតុនៃបញ្ហានេះគឺបណ្តាលមកពីប្រជាពលរដ្ឋសាងសង់លំនៅស្ថានជាលក្ខណៈអនាធិបតេយ្យនៅលើទឹកហើយបោះសំរាមចូលទឹក ឬអ្នកលក់ដូរតាមរ៉ឺម៉កនិងរទេះរុញយកសំរាមទៅបោះចោលពាសវាលពាសកាល ដោយពុំបានគិតពិចារណាពីផលប៉ះពាល់។[41]

ទាំងនេះសុទ្ធតែជាមូលហេតុជម្រុញឲ្យមានការរៀបចំដើម្បីទទួលបានសោភ័ណភាព និងសណ្តាប់ធ្នាប់ល្អក្នុងក្រុង ស្រុក ខណ្ឌ ឬតំបន់នានាថែមទៀត។

### ២.២.១. លក្ខណៈទូទៅ និងហេតុបង្កនាំឲ្យមានការបំពុលបរិស្ថាន

កាលពីមុនបញ្ហាបរិស្ថានមិនសូវកើតមានឡើងដែលនាំឲ្យមានការព្រួយបារម្ភនោះទេ ព្រោះដោយសារចំនួនប្រជាជន និងការអភិវឌ្ឍប្រទេសនៅមានកម្រិត។ប៉ុន្តែ បច្ចុប្បន្នដោយសារកំណើនប្រជាជន និងការរីកចម្រើននៃសេដ្ឋកិច្ចយ៉ាងឆាប់រហ័សកំពុងបង្កឲ្យមានបញ្ហាការបំពុលបរិស្ថានកើតឡើង។ សកម្មភាពអភិវឌ្ឍន៍សេដ្ឋកិច្ច បានបង្កើតជាផលវិបាកផ្នែកបរិស្ថានសំខាន់ៗរួមមានទាំងការបំពុលខ្យល់ បំពុលទឹកដី សំលេង និងបញ្ហាសំណល់រឹង ជាដើម។[42]នៅពេលដែលស្រុកទេសមានការអភិវឌ្ឍ មនុស្សគ្រប់គ្នាតែងតែចង់ប្រើប្រាស់នូវរបស់ទាន់សម័យប្លែកៗដូចជា រថយន្ត ម៉ូតូ ទូរស័ព្ទ និងផលិតផលដែលផលិតឡើងថ្មីៗដូចជា ជីគីមីសម្រាប់កសិកម្ម ថ្នាំសម្លាប់សត្វល្អិត និងរបស់របរដែលផលិតឡើងពីប្លាស្ទិកជាដើម។អ្វីទាំងនេះហើយជាបញ្ហាដែលកំពុងតែកើតមាននៅពេលបច្ចុប្បន្នពីព្រោះថា ពេលដែលឧបករណ៍ទាំងអស់នោះខូច ពួកគេនឹងយកវាទៅបោះចោលដោយសារថាផលិតផលទាំងនោះជាប្រភេទសំណល់ដែលមិនរលាយ វាត្រូវស្ថិតនៅក្នុងបរិស្ថានហើយសមាសភាពរបស់វាអាចធ្វើឲ្យមានការបំពុលដល់បរិស្ថាន។

#### ២.២.១.១. ការបំពុលទឹក ដី ខ្យល់

ទាំងការបំពុលទឹក ដី ខ្យល់ គឺសុទ្ធតែកើតចេញពីការចោលសំរាមពាសវាលពាសកាលគ្មានសណ្តាប់ធ្នាប់ និងការបង្ហូរកាកសំណល់ចូលក្នុងស្ទឹង ឬ ទន្លេ ហើយបណ្តាលឲ្យមានការបំពុលដល់ទឹក ដី ឬបរិយាកាសទាំងមូល។

##### ក. ការបំពុលទឹក

ការបំពុលទឹក អាចត្រូវបានគេឲ្យនិយមន័យច្រើនយ៉ាងផ្សេងៗពីគ្នា។ ជាទូទៅការបពុលទឹកគឺជាការធ្វើឲ្យកង្វក់ដល់ទឹកនៅពេលដែលសារធាតុបំពុលនានាបានហូរចូលទៅក្នុងប្រភពទឹកដោយមិនបានឆ្លងកាត់ការធ្វើប្រព្រឹត្តកម្ម(ដកយកសារធាតុបំពុលចេញ) ការបំពុលទឹកភាគច្រើន គឺ

[41] https://thmeythmey.com/?page=detail&id=36375&fbclid=IwAR1kHKwD2Nt4wC2lendTJpsnGf8J9ei6rCzmjLeS-zIHL_zcKIe5ZhLJCpg (ចូលទស្សនាចុងក្រោយថ្ងៃទី២៨ ឧសភា ២០១៩) ។

[42] https://thmeythmey.com/?page=detail&id=36375&fbclid=IwAR1kHKwD2Nt4wC2lendTJpsnGf8J9ei6rCzmjLeS-zIHL_zcKIe5ZhLJCpg (ចូលទស្សនាចុងក្រោយថ្ងៃទី២៨ ឧសភា ២០១៩) ។

បណ្តាលមកពីសំណល់ពីរោងចក្រឧស្សាហកម្ម កសិកម្ម និងតាមផ្ទះ ដែលផ្តល់ផលប៉ះពាល់យ៉ាងខ្លាំងដល់សុខភាពមនុស្សនិង សត្វក៏ដូចជាគុណភាពបរិស្ថាននៃប្រភពទឹកទាំងមូល។ទឹកគឺពិតជាមានសារៈប្រយោជន៍ណាស់សម្រាប់ទ្រទ្រង់ជីវិតរស់នៅរបស់ មនុស្ស សត្វ និងរុក្ខជាតិ។[43]

ម្យ៉ាងទៀត ការបំពុលទឹកគឺជាសកម្មភាពទាំងឡាយណាដែលធ្វើឲ្យទឹកប្រើប្រាស់ខុសពីលក្ខណៈដើម ហើយការបំពុលទឹក អាចជះឥទ្ធិពលអាក្រក់ដល់សោភ័ណភាពបិស្ថានអាស្រ័យទៅតាមកម្រិតនៃការបំពុល ភាគច្រើនមាននៅតាមកន្លែងសំខាន់ៗមួយចំនួនដូចជា រមណីយដ្ឋាន ទីក្រុង ទីប្រជុំជន ទីកំសាន្ត ទីសាធារណៈជាដើម។[44]

ការបំពុលទឹក អាចកើតឡើងតាមរយៈមូលហេតុផ្សេងៗជាច្រើនដូចជាៈ

-កត្តាមនុស្សដែលទាក់ទងនឹងមុខរបរអាជីវកម្មដែលប្រជាពលរដ្ឋប្រកបជារៀងរាល់ថ្ងៃដូចជាវិស័យកសិកម្ម ការប្រើប្រាស់ជីគីមីបានបន្សល់ទុកនូវកាកសំណល់ ដោយសារការគ្រប់គ្រងមិនបានត្រឹមត្រូវតាមបច្ចេកទេស។ម្យ៉ាងវិញទៀតដោយសារតែការបង្ហូរកាកសំណល់ឬភាពកខ្វក់ចេញពីរោងចក្រក៏ដូចជាកសិដ្ឋានផ្សេងៗទើបណ្តាលឲ្យទឹកស្រះនៅតាមជនបទប្រែក្លាយជាកខ្វក់រួមទាំងមានក្លិនស្អុយមិនអាចប្រើប្រាស់បាន។[45]

- វិស័យទេសចរណ៍ ការធ្វើដំណើរកំសាន្តទោះទៅតាមទូក កប៉ាល់ ឬ កាណូត អ្នកដំណើរខ្លះក៏មានការបន្ទោរបង់តាមបង្គន់អនាម័យក្នុងយានជំនិះដែរ ប៉ុន្តែប្រសិនបើមិនបានរៀបចំឲ្យបានត្រឹមត្រូវនោះទេ លាមក និងកាកសំណល់ផ្សេងៗទៀតត្រូវធ្លាក់ទៅក្នុងទឹក និង បណ្តាលឲ្យកង្វក់ដល់ទឹក។[46]

- ការទុកដាក់សំរាមនៅក្នុងទីក្រុង ឬទីសាធារណៈ ការបោះចោលសំរាម ឬ កាកសំណល់ផ្សេងៗពាសវាលពាសកាលឬបោះ ចូលទៅក្នុងទឹកជាហេតុនាំឲ្យមានការបំពុលទឹក និង ប៉ះពាល់ដល់សុខភាពមនុស្ស។

សកម្មភាពមួយចំនួនអាចធ្វើឲ្យមានការបំពុលទឹកហើយក៏បានជះឥទ្ធិពលដល់មនុស្ស សត្វ និងរុក្ខជាតិ។ដូច្នេះវាបានឆ្លើយតបទៅវិញចំពោះការកង្វះនូវបច្ចេកវិទ្យាដែលសមស្របសម្រាប់សម្អាតកាកសំណល់រឹង ដែលបានកែច្នៃផលិតផលរួចក៏បានបង្ហូរចេញពីរោងចក្រទៅក្នុងប្រភពទឹក

[43]https://opendevelopmentcambodia.net/km/topics/waterpollution/?fbclid=IwAR0DCm4rhymUQs8WGxVFTmCn4yTdW10bGe7IYtGE-fgQha4ZiRpPJxnTnSw (ចូលទស្សនាចុងក្រោយថ្ងៃទី២៨ ឧសភា ២០១៩) ។

[44]https://www.healthcambodia.com/category/environment (ចូលទស្សនាចុងក្រោយថ្ងៃទី២៨ ឧសភា ២០១៩) ។

[45]https://www.healthcambodia.com/category/environment (ចូលទស្សនាចុងក្រោយថ្ងៃទី០២ មិថុនា ២០១៩) ។

[46]https://www.healthcambodia.com/category/environment (ចូលទស្សនាចុងក្រោយថ្ងៃទី០២ មិថុនា ២០១៩) ។

តាមរយៈរោងចក្របោកគក់និងរោងចក្រផលិតស្រាបៀរជាដើម ហើយសារធាតុពុលគីមីក៏ត្រូវបានបញ្ចេញជាមួយគ្នាទៅក្នុងទឹកនោះផងដែរ។

-ការបង្ហូរកាកសំណល់រាវចេញពីរងចក្រឧស្សាហកម្ម កាកសំណល់ទាំងនោះមានផលប៉ះពាល់ច្រើនដល់ការរស់នៅរបស់មនុស្ស សត្វ រុក្ខជាតិ និងការបាត់បង់សេដ្ឋកិច្ចជាតិ។ជាពិសេសសុខភាពរបស់មនុស្សតាមរយៈការបរិភោគមិនស្អាតនិងកង្វះអនាម័យដែលនាំមកនូវកាកសំណល់រាវ ហើយបានបង្កជាជម្ងឺផ្សេងៗអាចបណ្តាលឲ្យមានការបំពុលទឹកដែលបង្កឲ្យមនុស្សមានជម្ងឺផងដែរ។[47]

-ការបង្ហូរកាកសំណល់ចេញពីលំនៅស្ថាន តាមទីប្រជុំជននានា ឬពីផ្សារទៅក្នុងថ្លុកផ្សេងៗដែលបង្កើតឲ្យមានទឹកស្អុយជាប្រចាំ និងមានកាកសំណល់ដែលនៅតាមដងផ្លូវរាយប៉ាយ និងគ្មានសណ្តាប់ធ្នាប់ទើបនៅពេលដែលមានភ្លៀងធ្លាក់បាននាំមកនូវកាកសំណល់ទាំងនោះហូរចូលទៅក្នុងទន្លេ។[48]

**ខ.ការបំពុលដី**

ការបំពុលដីជាកត្តាមួយដ៏សំខាន់ដែលដើរតួក្នុងការបំពុលបរិស្ថាន។សព្វថ្ងៃ ការបំពុលដីគឺជាបញ្ហាដែលត្រូវបានគេព្រួយបារម្ភដោយសារតែបញ្ហានេះបានផ្តល់ផលប៉ះពាល់យ៉ាងខ្លាំងចំពោះបរិស្ថាន និងជីវិតមនុស្សនិងសត្វ។ មនុស្សយើងចាំបាច់ត្រូវការរស់នៅកន្លែងស្អាតដើម្បីឲ្យមានសុខភាពល្អ ដើម្បីឲ្យកន្លែងស្អាតគឺត្រូវការដីស្អាត។ ការបំពុលដីធ្វើឲ្យដីកខ្វក់ហើយធ្វើឲ្យខូចគុណភាពដី ថែមទាំងប៉ះពាល់ដល់ជីវិតសត្វនិងរុក្ខជាតិទៀតផង។

ម្យ៉ាងវិញទៀត នៅពេលដែលមានការបំពុលដី ជាតិគីមីនឹងបានជ្រាបចូលទៅក្នុងដីដែលធ្វើឲ្យប៉ះពាល់ដល់រុក្ខជាតិផ្សេងៗដូចជាស្មៅជាដើម ដូចនេះហើយនៅពេលដែលសត្វដែលស៊ីរុក្ខជាតិដូចជាសត្វគោដែលស៊ីស្មៅបានស៊ីស្មៅដែលមានជាតិពុលនោះវាក៏ទទួលរងគ្រោះដោយសារជាតិពុលនោះដែរ ហើយមនុស្សយើងតែងត្រូវការខ្យល់បរិសុទ្ធដើម្បីដកដង្ហើម ការបំពុលដីធ្វើឲ្យខូចគុណភាពខ្យល់គឺក្លិនដែលភាយចេញពីសំរាមដែលធ្វើឲ្យខ្យល់មិនបរិសុទ្ធ។មិនត្រឹមតែប៉ុណ្ណោះ ការបំពុលដីធ្វើឲ្យដីបាត់បង់ជីជាតិដែលធ្វើឲ្យដីនោះក្លាយជាដីឥតបានការ ដីដែលមិនអាចដាំដំណាំបានឡើយ មិនតែប៉ុណ្ណោះដីដែលបាត់បង់ជីជាតិហើយមិនអាចមានវិធានការណាមួយដែលធ្វើឲ្យដីនោះមានជីជាតិឡើងវិញឡើយ។

មូលហេតុនៃការបំពុលដីជាទូទៅឃើញមានកត្តាចំនួនបីយ៉ាងគឺៈ

[47]https://www.healthcambodia.com/category/environment (ចូលទស្សនាចុងក្រោយ ថ្ងៃទី០២ មិថុនា ២០១៩) ។
[48]https://www.healthcambodia.com/category/environment (ចូលទស្សនាចុងក្រោយ ថ្ងៃទី០២ មិថុនា ២០១៩) ។

-កត្តាកសិកម្ម

មូលហេតុនៃការបំពុលដីចំពោះវិស័យកសិកម្ម គឺភាគច្រើនទាក់ទងទៅនឹងការប្រើប្រាស់ថ្នាំសម្លាប់សត្វល្អិតដែលមានសារជាតិគីមី។នៅពេលដែលមានការប្រើប្រាស់ជីគីមី និង ថ្នាំសម្លាប់សត្វល្អិតហួសកម្រិតសម្រាប់ដាំដំណាំឬការប្រើប្រាស់ថ្នាំសម្លាប់សត្វល្អិតច្រើនហួសហេតុសារជាតិពុលទាំងនោះនឹងស្ថិតនៅក្នុងដីបង្កឲ្យមានការបំពុលនិងធ្វើឲ្យដីនោះពោរពេញទៅដោយជាតិពុល។[49]

-កត្តាមនុស្ស

នៅពេលដែលមនុស្សបោះសំរាមចោលទៅលើដីហៅថា(ពង្រាយសំរាម)ការពង្រាយសំរាមនៅលើដីបណ្តាលឲ្យដីក្លាយជាកខ្វក់។ នៅពេលដែលសត្វទៅរកចំណីក្នុងគំនរសំរាមទាំងនោះវាក៏ទៅជាឈឺ ហើយបើមនុស្សចាប់សត្វទាំងនោះមកបរិភោគ ឬប៉ះពាល់សត្វទាំងនោះវានឹងបណ្តាលឲ្យទៅជាឈឺផងដែរ។ នៅពេលកប់កាកសំណល់ដែលមិនរលាយទៅក្នុងដីច្រើន គឺបណ្តាលឲ្យមានការបំពុល ប្រភេទសំណល់ដែលមិនអាចរលាយបាន វាត្រូវចំណាយពេលយូរណាស់ទើបរលាយដូច្នេះ មនុស្សមិនអាចប្រើប្រាស់ដីដែលកប់កាកសំណល់នោះសម្រាប់ដាំដំណាំឬយកទៅធ្វើជាដីលំនៅស្ថានបានទេ។[50]

-កត្តាឧស្សាហកម្ម

កត្តានេះដែរភាគច្រើនគឺពាក់ព័ន្ធទៅនឹងរោងចក្រ ដែលបង្ហូរទឹកស្អុយទៅលើដី ឬទឹកបង្កឲ្យមានការបំពុល ជាពិសេសឧស្សាហកម្មធ្ងន់ធ្ងរជាច្រើនដូចជា រោងចក្រផលិតសារជាតិគីមីលោហៈធាតុ និង ក្រដាសជាដើម ផលិតផលទាំងអស់នេះគឺសុទ្ធតែប៉ះពាល់ទៅដល់បរិស្ថាន។[51]

**គ. ការបំពុលខ្យល់**

ការបំពុលខ្យល់ ជាការកំណត់ឡើងនូវវត្តមាននៃសារធាតុកខ្វក់មួយ ឬច្រើននៅក្នុង និងក្រៅបរិយាកាស និងការចូលផ្សំគ្នារវាងសារធាតុទាំងនោះ ទាំងបរិមាណ និងរយៈពេលសំដិលក្នុងបរិយាកាស ដែលបណ្តាលឲ្យមានគ្រោះថ្នាក់ដល់ជីវិតមនុស្ស សត្វ រុក្ខជាតិ ឬខូចខាតការរកស៊ី និងការរស់នៅដោយសុខដុមរមនា។ការបំពុលខ្យល់មានប្រភពមកពីការដុតឥន្ធនៈ តួយ៉ាងប្រេងឥន្ធនៈ ប្រេងម៉ាស៊ូត និងធ្យូងសម្រាប់ការដឹកជញ្ជូន ការប្រើប្រាស់តាមផ្ទះ និងការប្រើប្រាស់ក្នុងវិស័យឧស្សាហកម្ម និងថាមពល។ ការដុតឥន្ធនៈទាំងនេះបានបញ្ចេញផ្សែងពុលចូលទៅក្នុងបរិយាកាសដែលបង្កឲ្យមានផលប៉ះពាល់គួរឲ្យកត់សម្គាល់ទៅលើគុណភាពខ្យល់ និងសុខភាពរបស់មនុស្ស។

[49] www.youtube.com(ចូលទស្សនាចុងក្រោយថ្ងៃទី០៥ មិថុនា ២០១៩) ។

[50]www.youtube.com(ចូលទស្សនាចុងក្រោយថ្ងៃទី០៥ មិថុនា ២០១៩) ។

[51]www.youtube.com (ចូលទស្សនាចុងក្រោយថ្ងៃទី០៥ មិថុនា ២០១៩) ។

ការបំពុលខ្យល់បង្កឡើងពីប្រភពដូចជាៈ

- ប្រភពធម្មជាតិៈ ដំណើរប្រព្រឹត្តនៃធម្មជាតិជាច្រើនបានបញ្ជូនភាគល្អិតតូចៗ និងលំអងផ្កា បន្ទុះភ្នំភ្លើងបានព្រួសចេញនូវកំទេចធូលី និងផេះយ៉ាងច្រើនដែលពោរពេញទៅដោយឧស្ម័នពុលភាយទៅក្នុងបរិយាកាស ដែលបង្កឲ្យកង្វក់ខ្យល់។[52]
- ប្រភពមនុស្ស

- ការដុតកាកសំណល់

នៅក្នុងទីក្រុងនិងទីប្រជុំជនភាគច្រើនការប្រមូលសំរាមត្រូវបានដំណើរការដោយក្រុមហ៊ុនឯកជន។បើសិនប្រជាជនចង់ឲ្យឡានដឹកសំរាមយកទៅចាក់ចោលនៅកន្លែងផ្សេងៗ គេត្រូវតែបង់ប្រាក់ឲ្យក្រុមហ៊ុននោះ។ជាទូទៅក្រុមហ៊ុនឯកជនប្រមូលតែសំរាមនៅតាមភោជនីយដ្ឋាន ហាងទំនិញ ទីផ្សារនានាប៉ុណ្ណោះ។ ចំណែកឯអ្នកដែលមិនបានបង់ប្រាក់ថ្លៃប្រមូលសំរាមជាទូទៅគេដុតសំរាមរបស់ពួកគេនៅទីវាលទំនេរជិតផ្ទះ។ ការដុតសំរាម ក៏អាចបង្កទៅជាបញ្ហាធំផងដែរ នៅពេលដែលមនុស្សដុតសំរាមប្លាស្ទិកឬកញ្ចប់ប្រអប់បាយដែលធ្វើពីប្លាស្ទិកផ្សែងភាយឡើងទៅក្នុងបរិយាអាកាសនិងធ្វើឲ្យបរិយាកាសកខ្វក់ដោយសារធាតុគីមីផ្សេងៗ ថែមទាំងបណ្តាលឲ្យមានគ្រោះថ្នាក់ដល់ផ្លូវដង្ហើម។ ម្យ៉ាងវិញទៀតនៅពេលដែលសំរាមឆេះមិនអស់ វាបង្កឲ្យមានភ្លើងឆេះរើមៗ មានផ្សែងច្រើនឡើងទៅបរិយាកាសហើយផ្សែងពណ៌ខ្មៅដែលបញ្ចេញទៅក្នុងអាកាសគឺវាផ្សំឡើងពីភាគល្អិតតូចៗជាច្រើនលានដែលផ្សែងនោះជួនកាលអាចនៅក្នុងខ្យល់បានជាច្រើនម៉ោង។សរបញ្ជាក់ផងដែរនៅពេលផ្សែង និងឧស្ម័នគ្រោះថ្នាក់ផ្សេងៗបានភាយឡើងទៅក្នុងខ្យល់គឺវាអាចបណ្តាលឲ្យមានការបំពុលខ្យល់កើតឡើងនោះដែកមូលហេតុគឺបណ្តាលមកពីការដុតកាកសំណល់ផ្សេងៗ។

- ការកប់កាកសំណល់នៅក្នុងដី

នៅតាមទីក្រុង និង ទីប្រជុំជនភាគច្រើនមានរណ្តៅធំៗជាច្រើនកន្លែងសម្រាប់ទុកដាក់កាកសំណល់ដែលមនុស្សបង្កើតឡើង។ មនុស្សជាច្រើនយល់ថាការកប់កាកសំណល់ទៅក្នុងដីគឺជាវិធីគ្រប់គ្រងសំរាមដ៏ងាយមួយដោយពួកគេគិតថា គ្រាន់តែចាក់សំរាមឲ្យពេញរណ្តៅ ហើយកាយដីកប់ជាការស្រេច។ ផ្ទុយមកវិញវាមិនមែនជាវិធីល្អទេ ការកប់សំរាមទៅក្នុងដីមានផលប៉ះពាល់យ៉ាងធ្ងន់ធ្ងរដល់បរិស្ថាន។ទោះបីយកទៅកប់ដីក៏ដោយក៏វារលាយចូលទៅក្នុងដីតែក្រដាសប៉ុណ្ណោះ

---

[52]http://www.khsearch.com/qna/11276?fbclid=IwAR1g0V9I6Tqo_6g3LdQtkZ5_tCnuiS6irjaTxAqAqOJdTEAkBmQEQToZh0M(ចូលទស្សនាចុងក្រោយថ្ងៃទី៣០ មិថុនា ២០១៩) ។

ចំណែកប្លាស្ទិកគឺវាមិនរលាយឡើយ។ យ៉ាងណាមិញការគ្រប់គ្រងសំរាមមិនបានល្អវាអាចបង្កឲ្យមានក្លិនមិនល្អ និង មានដីហុយថែមទៀតផង។

ទីក្រុងនានាជុំវិញពិភពលោក នៅពេលដែលមានការសាយភាយខ្យល់ពុលកម្រិតខ្ពស់ អាចបង្កឲ្យកុមារមានផ្តុលជម្ងឺហឺត រលាកសួត ជម្ងឺផ្លូវដង្ហើម និងមានអាត្រាកំណើនទារកទាប។ ម្យ៉ាងទៀតការសាយភាយនៃសារធាតុគីមីងាយធ្វើឲ្យមនុស្សចាស់និងកុមាររងគ្រោះកើតជម្ងឺដែលបណ្តាលមកពីការបំពុល ហើយចំណែកឯអ្នកមានជម្ងឺបញ្ហាសួត ឬបេះដូងស្រាប់នោះប្រាកដជាគ្រោះថ្នាក់កាន់តែធ្ងន់ថែមទៀត បញ្ហានេះគឺដោយសារសកម្មភាពមនុស្សបញ្ចេញនូវខ្យល់ច្រើនប្រភេទដែលបង្កឲ្យមានជម្ងឺ។លើសពីនេះទៀត ក៏មានជម្ងឺជាច្រើនដែលបង្កឡើងដោយការបំពុលខ្យល់ តែមិនមានបង្ហាញរោគសញ្ញាអ្វីសោះ។ ជម្ងឺទាំងនោះមានដូចជា រលាកទងសួតរ៉ាំរ៉ៃ រោគហឺត មហារីក និងបេះដូងជាដើមដែលអាចកើតមានឡើងជាយថាហេតុចំពោះអ្នកដែលបានស្រូបយកខ្យល់ដែលមានជាតិពុល។ ខ្យល់ពុលទាំងនោះមានដូចជា អូហ្សូន កាបូនឌីអុកស៊ីត ស្ពាន់ធ័រឌីអុកស៊ីតជាដើម ហើយខ្យល់ទាំងនេះក៏បង្កឲ្យមានអន្តរាយដល់ឋានប្រពន្ធ័ធម្មជាតិផងដែរ។[53]

### ២.២.១.២. ការបំពុលដោយសំណល់រឹង រាវ និង សំលេង

សំណល់មិនថារឹង ឬរាវនោះទេគឺបណ្តាលមកពីការទុកដាក់ វេចខ្ចប់និងវែកញែកមិនបានត្រឹមត្រូវល្អរបស់មនុស្សដែលអាចបង្កឲ្យមានមេរោគនៅក្នុងសំរាមជាហេតុធ្វើឲ្យប៉ះពាល់ដល់ជីវិតមនុស្ស។ រីឯសំលេងក៏ជាបញ្ហាប៉ះពាល់មួយផងដែរកាលណាសំលេងលឺខ្លាំងហួសកម្រិត វាបណ្តាលឲ្យមានផលប៉ះពាល់ដល់ការសិក្សា ការបំពេញការងារផ្សេងៗ ក៏ដូចជាជីវភាពរស់នៅរបស់មនុស្សទាំងអស់គ្នា។

#### ក. ការបំពុលដោយសំណល់រឹង រាវ

សំណល់រឹងគឺសំដៅដល់វត្ថុរឹង សារធាតុរឹងឬរាវដែលលែងត្រូវការប្រើប្រាស់ បោះបង់ចោល ឬត្រូវឲ្យបោះបង់ចោល។ [54] សំណល់រាវ គឺសំដៅដល់វត្ថុរាវដែលបញ្ចេញពីប្រភពបំពុលហូរចូលទៅក្នុងតំបន់សាធារណៈឬ ហូរចូលទៅក្នុងបណ្តាញលូសាធារណៈទោះបីជាបានឬមិនបានធ្វើប្រតិកម្មក៏ដោយ។ [55] ទាំងសំណល់រឹង និង សំណល់រាវខាងលើនេះជាទូទៅគេធ្វើការបែងចែកជាច្រើនប្រភេទដូចជា៖

[53] http://www.khsearch.com/qna/10524?fbclid=IwAR2XyL7ZNZikqFJfHP0zfaHfDxr8dUfDjtS_4CvX77DkU35YZXzYWa0L3Y(ចូលទស្សនាចុងក្រោយថ្ងៃទី៣០ មិថុនា ២០១៩) ។

[54] https://www.healthcambodia.com/category/environment (ចូលទស្សនាចុងក្រោយថ្ងៃទី០២មិថុនា ២០១៩) ។

[55] https://www.healthcambodia.com/category/environment (ចូលទស្សនាចុងក្រោយថ្ងៃទី០២ មិថុនា ២០១៩) ។

- សំណល់ទីក្រុងសំដៅលើសំណល់ដែលបញ្ចេញពីលំនៅស្ថាន ក្នុងនោះរួមមាន សំណល់សរីរាង្គ ប្លាស្ទិច សំរាម និង មានប្រភេទសំរាមដែលបង្កឲ្យមានគ្រោះថ្នាក់។ អាចជាសំណល់ដែលសល់ពីភោជនីយដ្ឋាន ទីផ្សារ សណ្ឋាគារ សំណល់ រោងចក្រ មន្ទីរពេទ្យ។[56]

- សំណល់ឧស្សាហកម្មគឺជាសម្ភារៈដែលសល់ពីការផលិតមានលក្ខណៈប្រហាក់ប្រហែល និងសំណល់ទីក្រុងដែរ ប៉ុន្តែប្រភេទខ្លះផ្ទុកទៅដោយសារធាតុគីមី។[57] សំណល់រឹង ឬ រាវអាចកើតមានឡើងពីរោងចក្របានបោះកាកសំណល់ដោយការធ្វើប្រព្រឹត្តិកម្មទៅកាន់ប្រព័ន្ធលូបង្ហូរទឹកស្អុយឬដោយផ្ទាល់ទៅកាន់ស្រះផ្សេងៗ។

- សំណល់មន្ទីរពេទ្យ គឺជាសំណល់ដែលសល់ពីផ្នែកវេជ្ជសាស្រ្តដូចជា ស៊ីរ៉ាំង បង់រុំ និងសំណល់ផ្សេងៗជាច្រើនទៀតដែលសល់ពីការវះកាត់។[58]

- សំណល់ប្រកបដោយគ្រោះថ្នាក់ សំដៅដល់សារធាតុពុល ផ្ទុះ ឆេះ ឬ ធ្វើអុកស៊ីតកម្ម ព្រមទាំងសំណល់ផ្សេងៗជាច្រើនទៀតដែលសល់ពីការវះកាត់។

ផលប៉ះពាល់ដែលបង្កឡើងពីសំណល់រឹង រាវមានដូចជា៖

-ផលប៉ះពាល់ដល់មនុស្ស៖ មិនថាសំណល់រឹង ឬ រាវទេប្រសិនបើមិនមានការគ្រប់គ្រងឲ្យល្អវាធ្វើឲ្យប៉ះពាល់ដល់គុណភាពជីវិតរស់នៅប្រចាំថ្ងៃរបស់មនុស្ស ការចាក់ចោលសំរាមមិនបានត្រឹមត្រូវវាអាចបង្កើតជាប្រភពចម្លងដល់ការរីករាលដាលនៃជម្ងឺផ្សេងៗជាច្រើនប្រភេទដូចជាជម្ងឺគ្រុនពោះវៀន ជម្ងឺគ្រុនចាញ់។ [59] មិនតែប៉ុណ្ណោះសារធាតុគីមីផ្សេងៗទៀតដែលបានមកពីសំណល់ឧស្សាហកម្មនិងសំណល់ដទៃទៀតគឺវាអាចស្រូបចូលក្នុងខ្លួនរបស់មនុស្សតាមរយៈការដកដង្ហើមឬការបរិភោគឬការប៉ះពាល់វា។ មេរោគដែលបង្កដោយសំរាម គឺអាចមានគ្រោះថ្នាក់ដល់ជីវិតមនុស្សវាមិនត្រឹមតែអាចមានជម្ងឺរុំរ៉ៃ ឬជាមហារីកប៉ុណ្ណោះទេ វាអាចបណ្តោយឲ្យមនុស្សបាត់បង់ជីវិតបានថែមទៀតផង។

-ផលប៉ះពាល់ដល់បរិស្ថាន៖ ប្រសិនបើគ្រប់គ្រងសំរាមមិនបានល្អនោះទេវានឹងនាំឲ្យប៉ះពាល់ដល់បរិស្ថាន ដល់សុខភាពមនុស្សដោយផ្ទាល់និងដោយប្រយោល។ ដោយផ្ទាល់មានដូចជាការបរិភោគចំណីអាហារ ឬហូបទឹក ឬសារធាតុដែលបង្កឲ្យមានជម្ងឺ ឬដោយប្រយោលវិញគឺវាធ្វើឲ្យមានការបាត់បង់ធនធានទឹក ដី ខ្យល់ ដែលជាតម្រូវការដល់ការទ្រទ្រង់ការរស់នៅប្រចាំថ្ងៃរបស់មនុស្ស និង សត្វ។[60]

---

[56] https://www.healthcambodia.com/category/environment (ចូលទស្សនាចុងក្រោយថ្ងៃទី០២ មិថុនា ២០១៩) ។
[57] https://www.healthcambodia.com/category/environment (ចូលទស្សនាចុងក្រោយថ្ងៃទី០២ មិថុនា ២០១៩) ។
[58] https://www.healthcambodia.com/category/environment (ចូលទស្សនាចុងក្រោយថ្ងៃទី០២ មិថុនា ២០១៩) ។
[59] https://www.healthcambodia.com/category/environment (ចូលទស្សនាចុងក្រោយថ្ងៃទី០២ មិថុនា ២០១៩) ។
[60] https://www.healthcambodia.com/category/environment (ចូលទស្សនាចុងក្រោយថ្ងៃទី០២ មិថុនា ២០១៩) ។

-ផលប៉ះពាល់ដល់សេដ្ឋកិច្ច បើសិនជាមានការបំពុលដោយសំណល់សំរាមរឹងក្ដី ឬរាវក្ដីគឺធ្វើឲ្យមនុស្សមានជម្ងឺ ហើយធ្វើឲ្យប្រាក់ចំណូលថយចុះដោយការកើតឡើងនូវជម្ងឺផ្សេងៗណាមួយនាំឲ្យប៉ះពាល់ដល់ផលដំណាំកសិកម្មនិងវិស័យទេសចរណ៍ថែមទៀតផង។

**ខ ការបំពុលដោយសំលេង**

សូរសំលេងតែងតែកើតឡើងពីគ្រឿងម៉ាស៊ីន និងយានយន្តគ្រប់ប្រភេទ។ ម៉ូតូដែលដោះតំរងការពារសំលេងចេញ។ម៉ាស៊ីនភ្លើងដាក់កណ្ដាលវាលគ្មានបំពង់ការពារសំលេងត្រឹមត្រូវតាមលក្ខណៈបច្ចេកទេស ។ ការបំពងសំលេងដោយឧឃោសនស័ព្ទក្នុងពិធីផ្សេងៗ ពិសេសនៅទីក្រុង និងទីប្រជុំជន ។ ការបញ្ចាំងវីដេអូតាមហាងកាហ្វេ ខារ៉ាអូខេ ម៉ាញេ ទូរទស្សន៍ វិទ្យុគ្មានម៉ោងសំរាក ។ កត្តាទាំងអស់នេះហើយជាហេតុនាំឲ្យរំខានដោយសារសំលេង។[61]

មូលហេតុដែលបង្កឲ្យមានការបំពុលសំលេង គឺកើតមានឡើងតាមដោយកត្តាជាច្រើនដូចជា៖

- សំលេងចេញពីការដ្ឋាន ៖ នៅទីកន្លែងសាងសង់ ចំពោះសំលេងគឺភាគច្រើនចេញពីម៉ាស៊ីនធំៗដូចជា ម៉ាស៊ីនលាយស៊ីម៉ង់ត៍ ម៉ាស៊ីនភ្លើង ម៉ាស៊ីនឈូសឈើ ម៉ាស៊ីនកាត់ដែកជាដើម។ល។ សំលេងទាំងនេះគឺប៉ះពាល់ដល់មនុស្សដែលនៅក្បែរការដ្ឋាននោះហើយក៏អាចប៉ះពាល់ដល់សុខភាពផងដែរ។ ផលប៉ះពាល់ដល់សុខភាពមានដូចជាជម្ងឺបេះដូង ជម្ងឺលើសឈាមជាដើម។
- សំលេងចេញពីឧបករណ៍ប្រើប្រាស់ដែលមានលក្ខណៈបច្ចេកវិទ្យា៖ សំលេងនេះចេញមកពីម៉ាស៊ីនត្រជាក់ ម៉ាស៊ីនបោកខោអាវ ម៉ាស៊ីនបូមធូលី ទូរទស្សន៍ជាដើម។ល។ សំលេងទាំងនេះអាចធ្វើឲ្យគុណភាពការងារធ្លាក់ចុះ ពីព្រោះនៅពេលដែលមានសំលេងថ្លង់ខ្លាំងពេក វាបណ្ដាលឲ្យយើងបាត់បង់អារម្មណ៍ក្នុងការបំពេញការងារ។
- សំលេងចរាចរ ៖ សំលេងនេះគឺកើតឡើងចេញពីសំលេងរថយន្ត ម៉ូតូ ឡានក្រុង រថភ្លើងជាដើម។ល។នៅពេលដែលសំលេងទាំងនេះឮខ្លាំងពេកវាបង្កឲ្យប៉ះពាល់ធ្ងន់ធ្ងរដល់ក្រដាសត្រចៀក ហ៊ឹងត្រចៀក និងអាចបណ្ដាលឲ្យមានជម្ងឺថ្លង់។
- សំលេងដែលចេញពីកម្មវិធីបុណ្យផ្សេងៗដូចជា កម្មវិធីបុណ្យ ពិធីរៀបការ ពិធីជប់លាងផ្សេងៗជាដើម។ សំលេងទាំងនេះអាចរំខានដល់ជីវភាពរស់នៅរបស់ប្រជាពលរដ្ឋដែលមានផ្ទះក្បែរនោះ ធ្វើឲ្យអារម្មណ៍មួម៉ៅ។[62]

[61] http://www.khsearch.com/qna/14638?fbclid=IwAR36kYNVQChtMUSrxaqmcet1ouTq_JDM8bFfwIz78z_DN_hVR1Jc2HoDvs (ចូលទស្សនាចុងក្រោយថ្ងៃទី៣០ មិថុនា ២០១៩) ។

[62] http://www.khsearch.com/qna/14639?fbclid=IwAR1V71iNMbdkYcL0amc3dP2pHY6Uxka9dcv9ogTc0o5DiZL_Saa73rEwm9s(ចូលទស្សនាចុងក្រោយថ្ងៃទី២៦ មិថុនា ២០១៩) ។

កត្តាទាំងឡាយខាងលើ គឺជាបញ្ហាដែលកើតមានសព្វថ្ងៃនេះមិនថាជាប្រទេសអភិវឌ្ឍន៍ឬប្រទេសកំពុងអភិវឌ្ឍន៍នោះទេ។តួយ៉ាងការបំពុលសំលេងដូចលើកឡើងខាងលើវាជាបញ្ហាដ៏សំខាន់ដែលប្រទេសមួយចំនួនកំពុងយកចិត្តទុកដាក់។ មិនតែប៉ុណ្ណោះ សំលេងឧបរណ៍ប្រើប្រាស់នៅក្នុងផ្ទះក៏ចាត់ទុកជាបញ្ហាបង្កសំលេងដែរ។ ដោយឡែកបញ្ហាទាំងនេះចំពោះប្រទេសកម្ពុជាវិញគឺមានតិចតួចបំផុតដែលសំលេងទាំងអស់នោះមិនបានកើតជាបញ្ហាធំដុំនោះទេដោយសារបច្ចុប្បន្ននេះប្រជាពលរដ្ឋមានការយល់ដឹងច្រើនហើយសំលេងដែលសព្វថ្ងៃគេចាត់ទុកជាបញ្ហាដែលកម្ពុជាកំពុងជួបប្រទះ។

### ២.២.២. ស្ថានភាពបរិស្ថានក្នុងក្រុងសៀមរាប

ក្រុងសៀមរាបមានប្រាសាទអង្គរវត្ត ដែលជាទីតាំងបេតិកភណ្ឌពិភពលោក និងជាគោលដៅទេសចរណ៍ដ៏ពេញនិយមបំផុតមួយនៅក្នុងព្រះរាជាណាចក្រកម្ពុជា។ [63] ពីមួយឆ្នាំទៅមួយឆ្នាំចំនួនភ្ញៀវទេសចរកាន់តែមានការកើនឡើងឥតឈប់ឈរ ហើយលើសពីនេះទៅទៀត មិនត្រឹមតែកំណើនរបស់ភ្ញៀវទេសចរប៉ុណ្ណោះទេ ចំនួនប្រជាជននៅក្នុងក្រុងនេះក៏មានការកើនឡើងគួរឲ្យកត់សំគាល់ផងដែរ។ ការកើនឡើងនូវចំនួនភ្ញៀវទេសចរយ៉ាងគំហុកនេះបានពន្លឿននូវការពង្រីកក្រុងយ៉ាងឆាប់រហ័សក្នុងក្រុងសៀមរាប។ កំណើនប្រជាជនមានការកើនឡើងបែបនេះ ដោយសារតែការធ្វើចំណាកស្រុករបស់ប្រជាជនមកពីជនបទនិងបណ្តាខេត្តឬក្រុងដទៃបានសម្រុកចូលមករកការងារធ្វើនៅក្នុងក្រុងសៀមរាបទាក់ទងនឹងវិស័យទេសចរណ៍ក៏ដូចជាវិស័យផ្សេងៗទៀត។ ចំពោះការកើនឡើងនូវកំណើនប្រជាជនបែបនេះបានធ្វើឲ្យកើតមាននូវបញ្ហាជាច្រើន ដែលក្នុងនោះបញ្ហាដែលគួរឲ្យកត់សម្គាល់គឺ បញ្ហាបរិស្ថាន។

តាមរបាយការណ៍របស់មន្ទីរបរិស្ថានខេត្តសៀមរាបបានឲ្យដឹងថា ក្រុងសៀមរាប ក្នុង១ថ្ងៃមានសំរាមប្រមាណពី៣០០ទៅ៣៥០តោន ហើយសំរាមទាំងនេះ ក្រុមហ៊ុនប្រមូលសំរាមបានប្រមូល និងដឹកជញ្ជូនចេញបាន តែ៦០ ទៅ៧០% ប៉ុណ្ណោះ។ ចំណែកសំរាមដែលនៅសល់ ត្រូវប្រជាពលរដ្ឋយកទៅដុតកប់បោះចោល នៅតាមដងផ្លូវក្នុងប្រឡាយទឹក ដែលកំពុងតែធ្វើឲ្យមានហានិភ័យដល់បរិស្ថាន សុខភាព និងការរស់នៅរបស់ប្រជាពលរដ្ឋ។[64]

កន្លងមកនេះអាជ្ញាធរខេត្ត ក្រុង បានខិតខំធ្វើយុទ្ធនាការសម្អាតបរិស្ថាន និងផ្សព្វផ្សាយអប់រំឲ្យប្រជាពលរដ្ឋមានការយល់ដឹងពីបញ្ហាសំរាម និងឲ្យមានចូលរួមសម្អាតឲ្យបានជាប្រចាំ។ ប៉ុន្តែរហូតមកដល់ពេលនេះ ការចូលរួមរបស់ប្រជាពលរដ្ឋនៅមានកម្រិតនៅឡើយ ដោយប្រជាពលរដ្ឋ

---

[63] របាយការណ៍ចុងក្រោយស្តីពី ផែនការមេរួមសម្រាប់ការអភិវឌ្ឍដោយនិរន្តរភាពរបស់ក្រុងសៀមរាប, ២០១០, ០១។

[64] http://kleykley.sabay.com.kh/article/945205(ចូលទស្សនាចុងក្រោយថ្ងៃទី២៧ មិថុនា ២០១៩) ។

មួយចំនួននៅតែបោះចោលសំរាមតាមទីសាធារណៈពាសវាលពាសកាល ដោយមិនបានវេចខ្ចប់ឲ្យបានត្រឹមត្រូវ ហើយយកទៅដាក់ក្នុងធុងសំរាមតាមការណែនាំរបស់អាជ្ញាធរនោះទេ បញ្ហាទាំងនេះហើយធ្វើឲ្យសំរាមនៅតែជាបញ្ហាប្រឈម ធ្វើឲ្យប៉ះពាល់ដល់សោភ័ណភាពក្រុង។[65]

**២.២.២.១.បញ្ហាសំណល់រឹង**

សំរាមនៅក្រុងសៀមរាបត្រូវបានពង្រាយដោយសារៈ

- កង្វះខាតការយល់ដឹងពីបញ្ហាសំរាមរបស់ប្រជាជននិងកែប្រែជីវិតរស់នៅទៅជាជីវិត ចោលសំរាម
- អាជ្ញាធរទទួលខុសត្រូវពុំមានសមត្ថភាពគ្រប់គ្រាន់ក្នុងការគ្រប់គ្រងសំណល់រឹង
- អត្រានៃការប្រមូលសំណល់លំនៅស្ថាននៅមានកម្រិតទាបដោយសារកម្រៃនៃការប្រមូលសំរាមខ្ពស់
- មានការពឹងផ្អែកហួសហេតុលើផ្នែកឯកជនក្នុងការគ្រប់គ្រងសំរាម
- ប្រព័ន្ធហិរញ្ញវត្ថុទន់ខ្សោយសម្រាប់ការគ្រប់គ្រងសំរាម។

សំណល់រឹងត្រូវបានពង្រាយនៅទីសាធារណៈដែលបង្កផលប៉ះពាល់អវិជ្ជមានមួយចំនួនដូចជាៈ

- ធ្វើឲ្យកខ្វក់ដល់បរិស្ថាន ដូចជាការបំពុលទឹកក្រោមដី ស្ទះផ្លូវទឹក សត្វចង្រៃ និងក្លិនស្អុយ
- ប៉ះពាល់ដល់សោភ័ណភាពនិងហេដ្ឋារចនាសម្ព័ន្ធព្រមទាំងបង្កនូវផលប៉ះពាល់អវិជ្ជមានធ្ងន់ធ្ងរដល់ភ្ញៀវទេសចរ
- មានបញ្ហាសង្គមដូចជាកំណើនមនុស្សដើររើសសំរាមក្នុងក្រុងយ៉ាងអនាធិបតេយ្យអាចបង្កផលប៉ះពាល់អវិជ្ជមានធ្ងន់ធ្ងរលើបរិស្ថាននៅតាមតំបន់ជុំវិញកន្លែងចោលសំរាមនៅពេលអនាគត។[66]

**២.២.២.២.បញ្ហាប្រព័ន្ធបង្ហូរទឹក និង ប្រព័ន្ធបង្ហូរសំណល់រាវ**

នៅក្នុងក្រុងសៀមរាប បណ្តាផ្សារ ផ្ទះសំណាក់ សណ្ឋាគារ និង ភោជនីយដ្ឋានមួយចំនួន នៅតាមដងស្ទឹងសៀមរាប បាន ដាក់លូបង្ហូរទឹកស្អុយចូលទៅក្នុងស្ទឹង ទើបធ្វើឲ្យទឹកស្ទឹងនេះប្រែពណ៌ពីខៀវថ្លាមកជាខ្មៅ ថែមទាំងមានក្លិនស្អុយថែមទៀត ។[67] លើសពីនេះទៅទៀត នៅក្រុងសៀមរាបមានការលិចទឹកជាញឹមញាប់នៅតាមមណ្ឌលពាណិជ្ជកម្មនិងតំបន់ស្នាក់នៅរបស់ភ្ញៀវទេសចរ

[65] http://kampucheathmey.com/2016/archives/657741(ចូលទស្សនាចុងក្រោយថ្ងៃទី២៧ មិថុនា ២០១៩) ។
[66] http://open_jicareport.jica.go.jp/pdf/11825882_03.pdf(ចូលទស្សនាចុងក្រោយថ្ងៃទី២៨ មិថុនា ២០១៩)។
[67] https://kohsantepheapdaily.com.kh/article/822100.html(ចូលទស្សនាចុងក្រោយថ្ងៃទី២៨ មិថុនា ២០១៩)។

ដោយសារតែលូចំហពុំមានសមត្ថភាពគ្រប់គ្រាន់សម្រាប់បង្ហូរទឹកភ្លៀង និងលូចំហរស្ទះដោយសារសំរាមជាដើម។[68]

ការលិចទឹកបណ្តាលឲ្យមានបញ្ហាសុខភាពនិងអនាម័យដូចខាងក្រោមៈ

- ធ្វើឲ្យលិចផ្ទះ និងទ្រព្យសម្បត្តិដោយសារទឹកភ្លៀង និង សំណល់រាវនៅពេលភ្លៀងធ្លាក់ខ្លាំងៗ
- សំណល់ពីអាងប្រព្រឹត្តកម្មទឹកហូរផ្ទាល់ទៅលូបណ្តាលឲ្យមានភ្នាក់ងារនាំជម្ងឺ
- បញ្ហាសុខភាព និង សោភ័ណភាពដែលបណ្តាលមកពីកង្វះអនាម័យក្នុងតំបន់ដែលមានដង់ស៊ីតេខ្ពស់ និង តំបន់ដែលមានកម្រិតចំណូលទាប។[69]

### ២.២.២.៣.ការរំខានដោយសំលេង

ក្រុងសៀមរាបមានកន្លែងកំសាន្តពេលរាត្រីជាច្រើន ដូចជា ខ្លឹបកំសាន្ត ភោជនីយដ្ឋាន បារជាពិសេសគឺតំបន់ផាប់ស្ទ្រីតដែលជាបណ្តុំភ្ញៀវទេសចរកំសាន្តសប្បាយនៅពេលរាត្រីដ៏សំខាន់មួយរបស់ក្រុងសៀមរាប។ជារៀងរាល់ថ្ងៃ តំបន់ផាប់ស្ទ្រីត ព្រមទាំងបណ្តាភោជនីយដ្ឋាន និងក្លឹបកំសាន្តមួយចំនួន បានធ្វើការចាក់ឌីសស្កូ បំពងសំលេងរំខានដល់ប្រជាពលរដ្ឋ អ្នកជំងឺក្នុងមន្ទីរពេទ្យ និងព្រះសង្ឃក្នុងវត្ត នៅក្នុងពេលរាត្រី ដោយមិនបានគោរព ទៅតាមច្បាប់កំណត់ឡើយ។ បញ្ហានេះបានធ្វើឲ្យមានការប៉ះពាល់យ៉ាងធ្ងន់ធ្ងរដល់ការរស់នៅរបស់ប្រជាពលរដ្ឋដែលរស់នៅក្បែរទីតាំងនោះ។[70]

### ២.២.២.៤.ការបំពុលខ្យល់

វិស័យដឹកជញ្ជូនផ្តល់ផលប៉ះពាល់ខ្លាំងទៅលើគុណភាពខ្យល់ដោយសារកំណើននៃយានយន្ត និងការប្រើប្រាស់ប្រេងឥន្ធនៈ។ ការដឹកជញ្ជូនកាន់តែច្រើនមានន័យថា ប្រេងឥន្ធនៈកាន់តែច្រើនត្រូវបានប្រើប្រាស់ ហើយសារធាតុពុលកាន់តែច្រើនត្រូវបានបញ្ចេញទៅក្នុងបរិយាកាស។ រ៉ឺម៉កកង់បី ម៉ូតូ និងរថយន្តដឹកអ្នកដំណើររាប់រយគ្រឿងដែលកំពុងបន្តប្រតិបត្តិការនៅជុំវិញតំបន់ប្រាសាទអង្គរវត្ត បង្កជាការគម្រាមកំហែងដល់គុណភាពខ្យល់នៅទីនោះ។ សារព័ត៌មាន Global Postបានរាយការណ៍ថា គុណភាពខ្យល់នៅប្រាសាទអង្គរវត្ត ដែលជាតំបន់បេតិកភ័ណ្ឌពិភពលោកទទួលស្គាល់ដោយអង្គការ យូណេស្កូ បានក្លាយជាបញ្ហាគួរឲ្យព្រួយបារម្ភ។ ប្រាសាទអាចប្រឈមនឹងការខូតខាត ដែលបណ្តាលមកពីភ្លៀងអាស៊ីត។[71]

---

[68] http://open_jicareport.jica.go.jp/pdf/11825882_03.pdf(ចូលទស្សនាចុងក្រោយថ្ងៃទី២៨ មិថុនា ២០១៩)។

[69] http://open_jicareport.jica.go.jp/pdf/11825882_03.pdf(ចូលទស្សនាចុងក្រោយថ្ងៃទី២៨ មិថុនា ២០១៩)។

[70] http://grandnewsasia.com/detail/152802/(ចូលទស្សនាចុងក្រោយថ្ងៃទី២៩ មិថុនា ២០១៩) ។

[71] https://opendevelopmentcambodia.net/km/topics/air-pollution/ (ចូលទស្សនាចុងក្រោយថ្ងៃទី២៩ មិថុនា ២០១៩) ។

### ២.២.៣. ដំណោះស្រាយពាក់ព័ន្ធនឹងការបំពុលបរិស្ថានក្នុងក្រុងសៀមរាប

បន្ទាប់ពីដឹងពីមូលហេតុបង្ក និងផលប៉ះពាល់មួយចំនួនដូចរៀបរាប់ខាងលើ ក្នុងខណៈនេះនឹងធ្វើការឆ្លើយតបដោយការដោះស្រាយទៅលើបញ្ហាដែលកើតមានឡើងក្នុងក្រុងសៀមរាបដូចជា បញ្ហាសំណល់រឹង បញ្ហាប្រព័ន្ធបង្ហូរទឹក និងប្រព័ន្ធបង្ហូរសំណល់រាវ ការបំពុលដោយសំលេង និងការបំពុលខ្យល់ ថាតើគួរមានដំណោះស្រាយដូចម្ដេចខ្លះដើម្បីការពារ កាត់បន្ថយ ឬការលុបបំបាត់បញ្ហាទាំងនេះ។

#### ២.២.៣.១. ដំណោះស្រាយពាក់ព័ន្ធនឹងបញ្ហាសំណល់រឹង

ដើម្បីដោះស្រាយបញ្ហាសំរាមនៅក្នុងក្រុងសៀមរាបឲ្យកាន់តែមានប្រសិទ្ធភាពខ្ពស់អាជ្ញាធរក្រុងសៀមរាបកំពុងតែរៀបចំគម្រោង ផែនការថ្មីដោយចាប់ពីឆ្នាំ២០១៩នេះទៅអាជ្ញាធរគ្រោងដាក់ឲ្យក្រុមហ៊ុនចំនួនបីធ្វើការប្រមូល និងដឹកសំរាមចេញពីក្រុង និងមានការរៀបចំប្រព័ន្ធគ្រប់គ្រងទីលានចាក់សំរាមឲ្យបានល្អ។ ក្រុមហ៊ុនទាំងនោះ និងមានការបែងចែកតំបន់គ្នាប្រមូល និងដឹកជញ្ជូនសំរាមចេញ ដូចជា ក្រុមហ៊ុនមួយធ្វើការប្រមូលសំរាមនៅផ្នែកខាងលិចស្ទឹង មួយធ្វើការប្រមូលផ្នែកខាងកើតស្ទឹង និងមួយទៀតធ្វើការប្រមូលតាមទីសាធារណៈ ដើម្បីធ្វើយ៉ាងណាឲ្យការប្រមូលសំរាមចេញពីក្រុងសៀមរាបឲ្យបានលឿន។ ក្រៅពីនេះអាជ្ញាធរក្រុង និងធ្វើការពិភាក្សាជាមួយនឹងស្ថាប័នពាក់ព័ន្ធ ដែលមានមន្ទីរសេដ្ឋកិច្ច មន្ទីរបរិស្ថានក្នុងការរៀបចំសៀវភៅបន្ទុកថ្មី និងធ្វើកិច្ចសន្យាថ្មី ជាមួយក្រុមហ៊ុន សម្រាប់អនុវត្តចាប់ពីឆ្នាំ២០១៩នេះទៅ។[72]

លើសពីនេះទៀត រដ្ឋបាលក្រុងបានអនុវត្តន៍នូវយុត្តិសាស្ត្រមួយចំនួនក្នុងការដោះស្រាយបញ្ហាការគ្រប់គ្រងសំណល់រឹងដូចជា៖

- ពង្រឹងការយល់ដឹងរបស់ប្រជាជនទៅលើបញ្ហាបរិស្ថានដោយធ្វើការណែនាំឲ្យពួកគាត់យល់ដឹងពីការទុកដាក់ និងវេចខ្ចប់សំរាមឲ្យបានត្រឹមត្រូវ
- បង្កើតប្រព័ន្ធគ្រប់គ្រងសំណល់ដែលមានបច្ចេកទេសខ្ពស់ ដោយការបង្កើតឲ្យមានស្ថាប័នទទួលខុសត្រូវនៅក្នុង អាជ្ញាធរក្រុង និងអភិវឌ្ឍន៍សមត្ថភាពរបស់ពួកគេសម្រាប់ធ្វើផែនការ និងការគ្រប់គ្រង។
- បង្កើតប្រព័ន្ធហិរញ្ញវត្ថុសមស្របមួយសម្រាប់ការគ្រប់គ្រងសំណល់រឹងដោយការភ្ជាប់ទៅនឹងពន្ធ ឬដោយការភ្ជាប់កម្រៃ ជាមួយនឹងកម្រៃនៃការប្រើប្រាស់ផ្សេងៗទៀត។
- ពង្រឹងភាពជាដៃគូ រវាងរដ្ឋ និងឯកជន។[73]

---

[72] https://www.information.gov.kh/detailnews/265988 (ចូលទស្សនាចុងក្រោយថ្ងៃទី១៧ មិថុនា ២០១៩) ។

[73] http://open_jicareport.jica.go.jp/pdf/11825882_03.pdf(ចូលទស្សនាចុងក្រោយថ្ងៃទី២៨ មិថុនា ២០១៩)។

- ប្រែក្លាយសំណល់ទៅជាថាមពល តាមរយៈការផ្តល់មូលនិធិដោយសហភាពអឺរ៉ុប សម្រាប់ប្រើប្រាស់ក្នុងរោងកិនស្រូវ( បច្ចេកវិទ្យាដើម្បីបម្លែងថាមពលអគ្គិសនីអង្កាម)។[74]

**២.២.៣.២. ដំណោះស្រាយពាក់ព័ន្ធនឹងបញ្ហាប្រព័ន្ធបង្ហូរទឹក និង ប្រព័ន្ធបង្ហូរសំណល់រាវ**

ក្នុងការដោះស្រាយនូវបញ្ហាប្រព័ន្ធបង្ហូរទឹកចៀសវាងកើតមាននូវការលិចលង់នៅក្រុងបន្ទៀត និងប្រព័ន្ធបង្ហូរកាកសំណល់ កុំឲ្យប៉ះពាល់ដល់ទឹកស្ទឹងសៀមរាប ក្រុងសៀមរាបមានវិធានការដូចខាងក្រោម៖

- សហការជាមួយក្រសួងសាធារណការនិងដឹកជញ្ជូនជួយសិក្សាប្រព័ន្ធលូបង្ហូរទឹកកខ្វក់នៅតាមដងស្ទឹងសៀមរាប
- បង្កើតនាយកដ្ឋានសំណង់ប្រព័ន្ធចម្រោះទឹកខ្វក់ ក្នុងគោលបំណងធ្វើឲ្យប្រសើរឡើងនូវការគ្រប់គ្រងប្រព័ន្ធលូ និងប្រព្រឹត្តកម្មទឹកកខ្វក់ ប្រកបដោយប្រសិទ្ធភាព
- ការស្តារសមត្ថភាពនៃលូបច្ចុប្បន្ន
- ផ្តល់សមត្ថភាពប្រព័ន្ធលូបន្ថែម
- ធ្វើប្រតិកម្មទឹកភ្លៀងក្នុងក្រុងរួចនាំទៅកាន់អាងស្តុកទឹក
- បង្វែរទឹកភ្លៀងចេញពីតំបន់កណ្តាលក្រុងទៅស្ទឹងសៀមរាប
- បង្កើតកន្លែងស្តុកទឹកភ្លៀងដើម្បីសម្រួលដល់ការហូរខ្លាំង និងការពារតំបន់ខាងក្រោយស្ទឹង
- បង្កើតលូទឹកក្រោមដើម្បីបញ្ចេញទឹកភ្លៀង នៅតាមវិថីសម្តេចទេពវង្សនិងបង្វែរទឹកចេញពីប្រព័ន្ធទឹកកណ្តាលក្រុង
- បង្កើតនូវប្រព័ន្ធលូថ្មីនៅភាគខាងលិចដើម្បីបង្កើនសមត្ថភាពស្តុកទឹកភ្លៀង
- បង្កើតនូវកន្លែងស្តុកទឹកដើម្បីកាត់បន្ថយការហូរនៅពេលមានទឹកខ្លាំងនិងគ្រប់គ្រងល្បឿនហូរ
- បង្វែរទឹកពីប្រឡាយ មុននឹងទៅដល់ផ្លូវរង់ខាងក្រៅ
- បង្វែរទឹកដែលមានចំនួនច្រើនជ្រុលពីបំពង់ទឹកនៅតាមផ្លូវរង់ទៅដាក់អាងស្តុកទឹក។[75]

**២.២.២.៣. ដំណោះស្រាយពាក់ព័ន្ធនឹងការរំខានដោយសំលេង**

វិធានការដោះស្រាយចំពោះការរំខានដោយសំលេងនោះគឺ ត្រូវអប់រំដល់ប្រជាពលរដ្ឋឲ្យបានយល់ពីបញ្ហា ផលប៉ះពាល់ ហើយនិងធ្វើការផ្សព្វផ្សាយច្បាប់ដល់ប្រជាពលរដ្ឋជាដើម។ ចំពោះការបញ្ចេញសំលេងពីប្រភពយានយន្តនានា និងទីតាំងផលិតកម្មផ្សេងៗ ឬតាមផ្ទះដែលបង្កឲ្យមានការបំពុលសំលេងគឺត្រូវធ្វើការហាមឃាត់ឲ្យបាន។លើសពីនេះទៀតគប្បីកម្រិតស្តង់ដារនៃការ

[74] https://opendevelopmentcambodia.net/km/topics/solid-waste/(ចូលទស្សនាចុងក្រោយថ្ងៃទី២៨ មិថុនា ២០១៩)។
[75] http://open_jicareport.jica.go.jp/pdf/11825882_03.pdf(ចូលទស្សនាចុងក្រោយថ្ងៃទី២៨ មិថុនា ២០១៩)។

បញ្ចេញសំលេងពីប្រភពយានុ្ត ទីតាំងផលិតកម្ម និងកម្រិតស្តង់ដារសំលេងអតិបរិមាសម្រាប់ទីកន្លែងសាធារណៈ និងតំបន់លំនៅស្ថាន។[76] ម្យ៉ាងវិញទៀត ទាក់ទងនឹងការបញ្ចេញសំលេងរំខាននៅតំបន់ផាប់ស្ទ្រីត រដ្ឋបាលក្រុងសៀមរាបបានចេញសេចក្តីណែនាំចំពោះកម្រិតនៃការ ការបំពងសំលេងគឺ ត្រូវអនុវត្តន៍តាមស្តង់ដារបច្ចេកទេសកំណត់របស់ក្រសួងបរិស្ថាន។[77]

**២.២.២.៤. ដំណោះស្រាយពាក់ព័ន្ធនឹងការបំពុលខ្យល់**

មានបច្ចេកវិទ្យាគ្រប់គ្រងការបំពុលខ្យល់ផ្សេងៗជាច្រើន រួមទាំងផែនការយុត្តិសាស្ត្រនានាដើម្បីកាត់បន្ថយការបំពុលខ្យល់ពីមធ្យោបាយធ្វើដំណើរ និងគ្រឿងម៉ាស៊ីនចល័តមួយចំនួនរួមមានដូចជា បទបញ្ញត្តិតាមរយៈការលើកម្ពស់ការប្រើប្រាស់ប្រេងឥន្ធនៈឲ្យមានប្រសិទ្ធភាព ឬការប្រើប្រាស់រថយន្តដើរដោយអាគុយផង និងសាំងផង ឬ ក៏ប្តូរទៅប្រើប្រាស់អគ្គិសនីទាំងស្រុង ឬប្តូរទៅប្រើជីវៈឥន្ធនៈ ដូចជាអេតាណុល ឬជីវៈម៉ាស៊ូតជាដើម។

ដើម្បីកាត់បន្ថយការបំពុលខ្យល់ គឺត្រូវហាមឃាត់ជាដាច់ខាតនូវរាល់ការបញ្ចេញសារធាតុបំពុលទៅក្នុងបរិយាកាសណាដែលមិនឆ្លើយតបទៅនឹងកម្រិតកំណត់ស្តង់ដារ។[78]

[76] មាត្រា៧ នៃអនុក្រឹត្យស្តីពីការត្រួតពិនិត្យការបំពុលខ្យល់ និងការរំខានដោយសំលេងលេខ ៤២ អនក្រ.បក, ១០ ខែកក្កដា ឆ្នាំ២០០០។

[77] សេចក្តីណែនាំស្តីពី ការរៀបចំសណ្តាប់ធ្នាប់ របៀបរៀបរយ និងសុវត្ថិភាពនៅតំបន់ផាប់ស្ទ្រីត ក្រុងសៀមរាប ខេត្តសៀមរាប,លេខ០០៣ សណន, ០៣ កក្កដា ២០១៧។។

[78] មាត្រា៨ នៃអនុក្រឹត្យស្តីពីការត្រួតពិនិត្យការបំពុលខ្យល់ និងការរំខានដោយសំលេងលេខ ៤២ អនក្រ.បក, ១០ ខែកក្កដា ឆ្នាំ២០០០។

# សេចក្តីសន្និដ្ឋាន

# សេចក្តីសន្និដ្ឋាន

យោងតាមការបកស្រាយខាងលើឃើញថា ការរៀបចំសណ្តាប់ធ្នាប់ និងសោភ័ណភាពគឺពិតជាមានសារៈសំខាន់ណាស់ដើម្បីធ្វើឲ្យទីក្រុង ឬខេត្តមួយមានរបៀបរៀបរយ និងមានបរិស្ថានស្អាត។ តួយ៉ាង សម្រាប់ក្រុងសៀមរាបផ្ទាល់ បានរៀបចំផ្លូវថ្នល់ ស្ពាន សាលារៀន មន្ទីរពេទ្យ លូ សួនច្បារ បង្គោលភ្លើងបំភ្លឺផ្លូវជាច្រើនគួរឲ្យកត់សម្គាល់។ ម្យ៉ាងទៀត តាមរយៈការខិតខំប្រឹងប្រែងរបស់អភិបាលក្រុង និងអាជ្ញាធរពាក់ព័ន្ធនានានៅក្នុងការរៀបចំសន្តិសុខ សណ្តាប់ធ្នាប់ និងសោភ័ណភាពក្រុងសៀមរាប បានធ្វើឲ្យទីក្រុងទេសចរណ៍មួយនេះកាន់តែល្អប្រសើរឡើង ទាំងសន្តិសុខ សុវត្ថិភាព របៀបរៀបរយ និងសោភ័ណភាព។

ទោះបីជាអភិបាលក្រុង និងអាជ្ញាធរពាក់ព័ន្ធបានខិតខំប្រឹងប្រែង ធ្វើការរៀបចំសណ្តាប់ធ្នាប់ និងសោភ័ណភាពទីក្រុងក៏ពិតមែន ប៉ុន្តែនៅក្នុងនោះបញ្ហា និងចំនុចខ្វះខាតមួយចំនួនក៏នៅតែមានផងដែរ។ ជាក់ស្តែង នៅតែមានករណី ឃាតកម្ម លួច ឆក់ ប្លន់កើតមានឡើង ផ្លូវមួយចំនួនតូច ពុំទាន់បានពង្រីកនៅឡើយ ទន្ទឹមនឹងនោះផ្លូវក៏ពុំទាន់មានគុណភាព ទីក្រុងមានការលិចលង់ជារៀងរាល់ឆ្នាំ នៅពេលមានភ្លៀងធ្លាក់ខ្លាំងម្តងៗ បង្កជាទឹកជំនន់ដោយសារប្រព័ន្ធរំដោះទឹកមិនធានា និងមិនទាន់មានការកែលម្អ ចំពោះផ្សារនៅក្នុងក្រុងមិនទាន់មានអនាម័យសមរម្យសម្រាប់បម្រើឲ្យសេវាទេសចរណ៍ ហើយម្យ៉ាងទៀតកណ្តាលក្រុងខ្វះខាតចំណតយានយន្តដែលបណ្តាលឲ្យមានការកកស្ទះចរាចរណ៍ នៅពេលមានកម្មវិធីបុណ្យជាតិផ្សេងៗ។

សរុបមក ការរៀបចំសណ្តាប់ធ្នាប់ និងសោភ័ណភាពទីក្រុងគឺពិតជាមានសារៈសំខាន់ពិតប្រាកដមែន ។ ពីព្រោះថា ការរៀបចំក្រុង ជាបញ្ហាដែលពាក់ព័ន្ធជាមួយការរៀបចំ រូបរាង និងមុខងាររបស់តំបន់ជាយក្រុង ទីប្រជុំជន ឬក្រុងដែលមានស្រាប់ ឬ មិនទាន់មាន ឲ្យមានសោភ័ណភាព និងសណ្តាប់ធ្នាប់។ ការរៀបចំក្រុងដើម្បីឲ្យមានសោភ័ណភាព និងសណ្តាប់ធ្នាប់នេះ គឺទាមទារឲ្យមានការចូលរួមពីវិស័យពាក់ព័ន្ធជាច្រើន តួយ៉ាងដូចជា ការធ្វើផែនការ ការអភិវឌ្ឍស្ថាបត្យកម្ម វិស្វកម្មលើទេសភាព ច្បាប់ និងជាពិសេសហិរញ្ញវត្ថុជាដើម។ ម្យ៉ាងវិញទៀត ចំពោះការរៀបចំក្រុងនេះផងដែរ មិនមែនត្រឹមតែ អភិបាលក្រុង អាជ្ញាធរ ឬស្ថាប័នពាក់ព័ន្ធនោះទេដែលត្រូវយកចិត្តទុកដាក់ក្នុងការរៀបចំនេះ គឺប្រជាពលរដ្ឋក៏ត្រូវតែចូលរួមសហការ ដូចជា ការចូលរួមថែរក្សាការពារហេដ្ឋារចនាសម្ព័ន្ធ និងបរិស្ថានជុំវិញខ្លួនឲ្យកាន់តែល្អប្រសើរ គង់វង្ស ស្ថិតស្ថេរជាចីរកាល។

# អនុសាសន៍

# អនុសាសន៍

យោងតាមការបកស្រាយខាងលើឃើញថា ថ្វីត្បិតតែអភិបាល និងអាជ្ញាធរក្រុងសៀមរាប បានខិតខំប្រឹងប្រែងយកចិត្តទុកដាក់ក្នុងការរៀបចំ និងអភិវឌ្ឍន៍ក្រុងក៏ពិតមែន ប៉ុន្តែឃើញថាការរៀបចំ និងអភិវឌ្ឍន៍នេះបានជួបនូវបញ្ហាប្រឈម និងនៅមានចំណុចខ្វះខាតជាច្រើន ហើយមិនទាន់បានបំពេញតាមសេចក្តីត្រូវការរបស់ប្រជាពលរដ្ឋក៏ដូចជាភ្ញៀវទេសចរនៅឡើយ។បញ្ហានេះផងដែរជាបញ្ហាដែលប្រជាពលរដ្ឋ ចង់ឲ្យអាជ្ញាធរធ្វើការដោះស្រាយនិងកែលម្អ ជាពិសេសទាក់ទងទៅនឹងបញ្ហាសន្តិសុខ សណ្តាប់ធ្នាប់ និងបរិស្ថាន។ ដើម្បីដោះស្រាយនឹងបញ្ហាទាំងនេះ នាងខ្ញុំទាំងពីរសូមមានមតិយោបល់ និងសំណូមពរមួយចំនួនដូចតទៅ៖

- អាជ្ញាធរគ្រប់ជាន់ថ្នាក់ គួរតែយកចិត្តទុកដាក់ឲ្យបានខ្ពស់ ទៅលើបញ្ហាសន្តិសុខ សណ្តាប់ធ្នាប់ និងបង្កើនការបង្រ្កាប ក៏ដូចជាទប់ស្កាត់នូវបញ្ហាចោរកម្ម ល្បែងស៊ីសងគ្រប់ប្រភេទ ក្មេងទំនើង និងត្រួតពិនិត្យទៅលើបញ្ហាបរិស្ថាន ដើម្បីកុំឲ្យមានផលប៉ះពាល់ដល់ការរស់នៅរបស់ប្រជាពលរដ្ឋ ភ្ញៀវទេសចរ និងបរិយាកាសក្នុងក្រុង។

- អាជ្ញាធរក្រុងសៀមរាប គួរតែធ្វើការរៀបចំសោភ័ណភាពស្ទឹងសៀមរាបឲ្យបានស្អាត ដើម្បីជាការទាក់ទាញភ្ញៀវទេសចរក៏ដូចជាប្រជាពលរដ្ឋ អាចមកអង្គុយលេងកំសាន្តនៅតាមមាត់ស្ទឹងស្រូបយកខ្យល់អាកាស និងដើរហាត់ប្រាណប្រកបដោយផាសុកភាព។

- រាជរដ្ឋាភិបាលគួរតែផ្តល់នូវកញ្ចប់ថវិកាបន្ថែម សម្រាប់អ្នកវិទ្យាសាស្ត្រ និងអ្នកសិក្សាស្រាវជ្រាវ ដើម្បីរិះរកមធ្យោបាយ និងបច្ចេកវិទ្យាជួយដល់ការកាត់បន្ថយការបំពុលបរិស្ថានពីកត្តាផ្សេងៗ ជាពិសេសពីផ្សែងយានយន្ត និងគ្រឿងចក្រផ្សេងៗ។

- សូមសំណូមពរដល់រាជរដ្ឋាភិបាល សូមឲ្យផ្តល់កញ្ចប់ថវិកា ទៅដល់សាលាក្រុងឲ្យបានគ្រប់គ្រាន់ ដើម្បីយកទៅអភិវឌ្ឍន៍លើ ហេដ្ឋារចនាសម្ព័ន្ធដូចជា សាងសង់ផ្លូវ ស្ពានបន្ថែម កែលម្អផ្លូវពីផ្លូវក្រាលក្រួសក្រហមឲ្យទៅជាផ្លូវបេតុង ឬថ្នល់ក្រាលកៅស៊ូ ហើយក៏សូមសំណូមពរផងដែរ ចំពោះប្រព័ន្ធលូសាធារណៈ សូមមេត្តារៀបចំប្រព័ន្ធលូឲ្យបានត្រឹមត្រូវតាមស្តង់ដារដោយធ្វើការកែប្រែពីលូតូចទៅជាលូធំវិញដើម្បីចៀសវាងពីបញ្ហាកកស្ទះប្រព័ន្ធលូបង្ហូរទឹកដែលបង្កឲ្យមានការជន់លិចផ្លូវ និងពិបាកធ្វើដំណើរ។

- សូមសំណូមពរដល់រាជរដ្ឋាភិបាល ឲ្យមានការពង្រឹងច្បាប់បរិស្ថានបន្ថែមទាក់ទងនឹងការចោលសំរាម ដោយធ្វើការផាកពិន័យឲ្យធ្ងន់ធ្ងរបំពោះបុគ្គលណាដែលបោះចោលសំរាមមិនមានសណ្តាប់ធ្នាប់នៅតាមទីសាធារណៈ និងវេចខ្ចប់សំរាមមិនបានត្រឹមត្រូវ។

# ឯកសារពិគ្រោះ

// ឯកសារពិគ្រោះ

## ❖ លិខិតបទដ្ឋានគតិយុត្ត

• អនុក្រឹត្យស្តីពីការត្រួតពិនិត្យការបំពុលខ្យល់ និងការរំខានដោយសំលេង, លេខ ៤២ អនក្រ .បក, ១០ កក្កដា ២០០០

## ❖ សេចក្តីណែនាំ

• សេចក្តីណែនាំស្តីពីការរៀបចំសណ្តាប់ធ្នាប់ របៀបរៀបរយ និងសុវត្ថិភាពនៅតំបន់ផាប់ស្ទឹត ក្រុងសៀមរាប ខេត្តសៀមរាប, លេខ ០០៣ សណន, ០៣ កក្កដា ២០១៧។

• សេចក្តីណែនាំស្តីពីការធ្វើចរាចរណ៍របស់យានយន្តគ្រប់ប្រភេទ និងការរៀបចំសណ្តាប់ធ្នាប់ របៀបរៀបរយសាធារណៈ និងបរិស្ថាន អនាម័យ នៅក្នុងក្រុងសៀមរាប ខេត្តសៀមរាប, លេខ ០០១ សណន, ០២ មេសា ២០១៩។

## ❖ របាយការណ៍

• របាយការណ៍បញ្ចប់អាណត្តិទី២របស់ក្រុមប្រឹក្សាក្រុងសៀមរាប(២០១៤-២០១៨), ២០១៩។

• របាយការណ៍ប្រចាំឆ្នាំស្តីពីការអនុវត្តការងាររបស់រដ្ឋបាលក្រុងសៀមរាប, ២០១៨។

• របាយការណ៍ស្តីអំពី ការស្រង់ទិន្នន័យទីតាំងសំណង់បណ្តោះអាសន្នរបស់ក្រុងសៀមរាប, ២០១៤

• របាយការណ៍ចុងក្រោយនៃការសិក្សាតាមដានស្តីពី ផែនការមេរួមសម្រាប់ការអភិវឌ្ឍដោយនិរន្តរភាពរបស់ក្រុងសៀមរាប, ២០១០

## ❖ សៀវភៅ

• អ៊ុន សកក្កដា,រៀបរៀង.២០១៩.*នីតិនគរូបនីយវិទ្យា*.ភ្នំពេញ

• សៀវភៅផែនការអភិវឌ្ឍ(២០១៥-២០១៩)របស់សាលាក្រុងសៀមរាប

## ❖ គេហទំព័រ

- https://km.wikipedia.org/wiki/
- https://opendevelopmentcambodia.net/km/topics/urban-administration-and-development/
- https://www.postkhmer.com/
- http://www.cvea.org.kh/km/35-real-estate-news-2/1667-more-boreys-emerge-in-siem-reap.html
- https://tvsiemreap.com/?p=906
- https://kbn.news/archives/82184

- https://thmeythmey.com/?page=detail&id=76708
- http://www.kohthmey.com/thread-72729-1-1.html
- https://thmeythmey.com/?page=detail&id=77808#
- https://www.pdisiemreap.info/siem-reap-development-dirty-water-sector-has-lack-network/
- http://www.cen.com.kh/archives/34997.html/entertainment/
- www.healthcambodia.com
- www.youtube.com
- https://thmeythmey.com/?page=detail&id=36375&fbclid=IwAR1kHKwD2Nt4wC2lendTJpsnGf8J9ei6rCzmjLeS-zIHL_zcKIe5ZhLJCpg
- http://www.armyinstitute.epizy.com/
- http://www.khsearch.com/qna/14639?fbclid=IwAR1V71iNMbdkYcL0amc3dP2pHY6Uxka9dcv9ogTc0o5DiZL_Saa73rEwm9s
- http://kleykley.sabay.com.kh/article/945205
- http://kampucheathmey.com/2016/archives/657741
- http://open_jicareport.jica.go.jp/pdf/11825882_03.pdf
- https://kohsantepheapdaily.com.kh/article/822100.html
- http://grandnewsasia.com/detail/152802/
- https://opendevelopmentcambodia.net/km/topics/air-pollution/
- https://www.information.gov.kh/detailnews/265988
- https://opendevelopmentcambodia.net/km/topics/solid-waste/

# ឧបសម្ព័ន្ធ

# បញ្ជីឧបសម្ព័ន្ធ

ឧបសម្ព័ន្ធទី១ ៖ អនុក្រឹត្យលេខ៤២ អនក្រ.បក, ចុះថ្ងៃទី១០ ខែកក្កដា ឆ្នាំ២០០០ ស្តីពីការត្រួតពិនិត្យការបំពុលខ្យល់ និងការរំខានដោយសំលេង។

ឧបសម្ព័ន្ធទី២ ៖ សេចក្តីណែនាំលេខ០០៣ សណន, ចុះថ្ងៃទី០៣ ខែកក្កដា ឆ្នាំ២០១៧ ស្តីពីការរៀបចំសណ្តាប់ធ្នាប់ របៀបរៀបរយ និងសុវត្ថិភាពនៅតំបន់ផាប់ស្ទ្រីត ក្រុងសៀមរាប ខេត្តសៀមរាប ។

ឧបសម្ព័ន្ធទី៣ ៖ សេចក្តីណែនាំលេខ០០១ សណន, ចុះថ្ងៃទី០២ ខែមេសា ឆ្នាំ២០១៩ ស្តីពីការធ្វើចរាចរណ៍របស់យានយន្តគ្រប់ប្រភេទ និងការរៀបចំសណ្តាប់ធ្នាប់ របៀបរៀបរយសាធារណៈ និងបរិស្ថាន អនាម័យ នៅក្នុងក្រុងសៀមរាប ខេត្តសៀមរាប។

ឧបសម្ព័ន្ធទី៤ ៖ របាយការណ៍បញ្ចប់អាណត្តិទី២របស់ក្រុមប្រឹក្សាក្រុងសៀមរាប(២០១៤-២០១៨), ឆ្នាំ២០១៩។

ឧបសម្ព័ន្ធទី៥ ៖ របាយការណ៍ប្រចាំឆ្នាំស្តីពីការអនុវត្តការងាររបស់រដ្ឋបាលក្រុងសៀមរាប, ២០១៨។

ឧបសម្ព័ន្ធទី៦ ៖ របាយការណ៍ចុងក្រោយស្តីនៃការសិក្សាតាមដានស្តីពីផែនការមេរួមសម្រាប់ការអភិវឌ្ឍដោយនិរន្តរភាពរបស់ក្រុងសៀមរាប, ២០១០។

ឧបសម្ព័ន្ធទី៧ ៖ រូបភាព។

# ឧបសម្ព័ន្ធទី១៖
# អនុក្រឹត្យ
# ស្តីពី
# ការត្រួតពិនិត្យការបំពុលខ្យល់
# និង ការរំខានដោយសំលេង

ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

# អនុក្រឹត្យ

# ស្តីពី

# ការត្រួតពិនិត្យការបំពុលខ្យល់

# និងការរំខានដោយសំលេង

**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

**រាជរដ្ឋាភិបាលកម្ពុជា**

**លេខ ៖** ៤២ អនក្រ.បក

# អនុក្រឹត្យ

# ស្តីពី

# ការត្រួតពិនិត្យការបំពុលខ្យល់

# និងការរំខានដោយសំលេង

## រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១១៩៨-៧២ ចុះថ្ងៃទី ៣០ ខែ វិច្ឆិកា ឆ្នាំ ១៩៩៨ ស្តីពី ការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២ /នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ស្តីពី ការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៤/២១ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ ១៩៩៦ ដែលប្រកាសអោយប្រើច្បាប់ស្តីពីការបង្កើតក្រសួងបរិស្ថាន
- បានឃើញព្រះរាជក្រមលេខ នស/រកម/១២៩៦/៣៦ ចុះថ្ងៃទី ២៤ ខែ ធ្នូ ឆ្នាំ ១៩៩៦ ដែលប្រកាសអោយប្រើច្បាប់ស្តីពី កិច្ចការពារបរិស្ថាន និងការគ្រប់គ្រងធនធានធម្មជាតិ
- បានឃើញអនុក្រឹត្យលេខ ៥៧ អនក្រ.បក ចុះថ្ងៃទី ២៥ ខែ កញ្ញា ឆ្នាំ ១៩៩៧ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់ក្រសួងបរិស្ថាន
- បានការឯកភាពពីគណៈរដ្ឋមន្ត្រី ក្នុងសម័យប្រជុំពេញអង្គនាថ្ងៃទី ០៩ ខែ មិថុនា ឆ្នាំ ២០០០។

## សំរេច

## ជំពូកទី ១

## បទប្បញ្ញត្តិទូទៅ

**មាត្រា ១.-**

អនុក្រឹត្យនេះកំណត់ការត្រួតពិនិត្យការបំពុលខ្យល់ និងការរំខានដោយសំលេងដើម្បីទប់ស្កាត់ និងកាត់បន្ថយសារធាតុដែលបំពុលខ្យល់ និងសំលេងក្នុងបរិយាកាសសំដៅការពារគុណភាពបរិស្ថាន និងសុខភាពសាធារណៈ ។

**មាត្រា ២.-**

អនុក្រឹត្យនេះមានវិសាលភាពអនុវត្ត និងចាត់វិធានការចំពោះរាល់ប្រភពបំពុលចល័តនិងអចល័តទាំងឡាយដែលបង្កអោយមានការបំពុលខ្យល់ និងការរំខានដោយសំលេងនៅក្នុងបរិយាកាស ។

**មាត្រា ៣.-**

និយមន័យពាក្យបច្ចេកទេសដែលប្រើក្នុងអនុក្រឹត្យនេះត្រូវបានបកស្រាយដូចតទៅ :

ក -"ប្រភពបំពុល" ចែកចេញជាពីរគឺ :

-ប្រភពចល័ត : គឺជាប្រភពដែលស្ថិតនៅទីតាំងមិនអចិន្ត្រៃយ៍ជាអាទិ៍មាន : យន្តហោះ នាវាដឹកជញ្ជូន យានយន្ត គ្រឿងយន្ត និងគ្រឿងបំពងសំលេងគ្រប់ភេទ ។

-ប្រភពអចល័ត : គឺជាប្រភពដែលស្ថិតនៅលើទីតាំងអចិន្ត្រៃយ៍មួយកន្លែងជាអាទិ៍មាន : រោងចក្រ សហគ្រាស ឃ្លាំងស្តុកសំភារៈ ការដ្ឋានសំណង់ ឡដុតសំរាម គ្រឿងបំពងសំលេង សិប្បកម្ម និងកសិដ្ឋានគ្រប់ប្រភេទ ។

ខ-"សារធាតុបំពុល" គឺសំដៅទៅលើផ្សែង លំអងផ្សែង ធូលី ផេះ ភាគល្អិតនៃសំណង់ ឧស្ម័ន ចំហាយទឹកអ័ព្ទ ក្លិន និងសារធាតុវិទ្យុសកម្ម ។

គ-"សារធាតុឆេះ" គឺសំដៅទៅលើប្រេងឥន្ធនៈ ធ្យូងថ្ម ឧស្ម័នធម្មជាតិ អុស ធ្យូង ឬសារធាតុគីមីផ្សេងៗទៀត ដែលមានប្រតិកម្មចំហេះ

ឃ-"កំរិតកំណត់ស្តង់ដារ" គឺជាកំរិតកំណត់កំហាប់អតិបរមានៃសាធារបំពុល ដែលអាចអនុញ្ញាតអោយមាននៅក្នុងមជ្ឈដ្ឋានបរិស្ថាន ឬដែលអាចអនុញ្ញាតអោយបញ្ចេញពីប្រភពបំពុលចូលទៅក្នុងបរិស្ថាន ។

## ជំពូកទី ២

## បញ្ញត្តិលើការបញ្ចេញសារធាតុបំពុលខ្យល់ និងសំលេង

**មាត្រា ៤.-**

កំរិតកំណត់ស្តង់ដារគុណភាពខ្យល់ មានចែងនៅក្នុងតារាងឧបសម្ព័ន្ធ ១ និងកំរិតកំណត់ស្តង់ដារអតិបរមានៃសារធាតុប្រកបដោយគ្រោះថ្នាក់ ដែលអនុញ្ញាតអោយមាននៅក្នុងខ្យល់មានចែងនៅក្នុងឧបសម្ព័ន្ធ ២ ។

**មាត្រា ៥.-**

ក៏រិតកំណត់ស្តង់ដារអតិបរមានៃសារធាតុបំពុល ដែលអនុញ្ញាតបញ្ចេញពីប្រភពអចល័តចូលទៅក្នុងបរិយាកាស មានចែងនៅក្នុងតារាងឧបសម្ព័ន្ធ ៣ និងក៏រិតកំណត់ស្តង់ដារនៃការបញ្ចេញឧស្ម័នពីប្រភពអចល័ត មានចែងនៅក្នុងតារាងឧបសម្ព័ន្ធ ៤ ។

**មាត្រា ៦.-**

ក្នុងករណីចាំបាច់ ក៏រិតកំណត់ស្តង់ដារដូចមានចែងក្នុងមាត្រា៤ និងមាត្រា ៥ នៃអនុក្រឹត្យនេះ នឹងត្រូវពិនិត្យកែសំរួលរៀងរាល់ប្រាំឆ្នាំម្តងតាមសំណើរបស់ក្រសួងបរិស្ថាន ។

**មាត្រា ៧.-**

ក៏រិតកំណត់ស្តង់ដារបញ្ចេញសំលេងពីប្រភពយានយន្ត ទីតាំងផលិតកម្ម និងក៏រិតកំណត់ស្តង់ដារសំលេងអតិបរមាសំរាប់ទីកន្លែងសាធារណៈ និងតំបន់លំនៅដ្ឋាន មានចែងនៅក្នុងតារាងឧបសម្ព័ន្ធ ៥ ឧបសម្ព័ន្ធ៦ និងឧបសម្ព័ន្ធ ៧ ។

**មាត្រា ៨.-**

ហាមឃាត់ដាច់ខាតនូវការបញ្ចេញសារធាតុពុលទៅក្នុងបរិយាកាស ដែលមិនឆ្លើយតបទៅនឹងក៏រិតកំណត់ស្តង់ដារដូចមានចែងនៅក្នុងតារាងឧបសម្ព័ន្ធ ៣ និងឧបសម្ព័ន្ធ ៤ ។

**មាត្រា ៩.-**

ហាមឃាត់ដាច់ខាតនូវការបង្កអោយមានសំលេង ដែលមិនឆ្លើយតបទៅនឹងក៏រិតកំណត់ស្តង់ដារដូចមានចែងនៅក្នុងតារាងឧបសម្ព័ន្ធ ៥ ឧបសម្ព័ន្ធ ៦ និងឧបសម្ព័ន្ធ ៧ ។

**មាត្រា ១០.-**

ការនាំចូល និងផលិតនូវសារធាតុឆេះ ដែលមានជាតិស្ពាន់ធ័រ សំណ បង់សែន និងសារធាតុអ៊ីដ្រូកាប៊ួប្រហើរ ត្រូវឆ្លើយតបទៅនឹងក៏រិតកំណត់ស្តង់ដារដូចមានចែងនៅក្នុងឧសម្ព័ន្ធ ៨ ។

**មាត្រា ១១.-**

ហាមឃាត់ដាច់ខាតការនាំចូល ប្រើប្រាស់ ផលិតយានយន្ត និងគ្រឿងយន្តគ្រប់ប្រភេទក្នុងព្រះរាជាណាចក្រកម្ពុជាដែលយានយន្ត និងគ្រឿងយន្តទាំងនោះបានបញ្ចេញសារធាតុបំពុល និងសំលេងមិនឆ្លើយតបទៅនឹងក៏រិតកំណត់ស្តង់ដារដូចមានចែងនៅក្នុងតារាងឧបសម្ព័ន្ធ ៤ និងឧបសម្ព័ន្ធ ៥ ។

**មាត្រា ១២.-**

ហាមដាច់ខាតការបង្ហូរ ឬការធ្វើអោយលេចធ្លាយសារធាតុឆេះ ប្រេងឥន្ទនៈ ធាតុវិទ្យុសកម្ម ឬសារធាតុគីមីផ្សេងៗទៀតចូលក្នុងបរិយាកាស ទឹក និងដី ។

## ជំពូកទី ៣
## ការសុំអនុញ្ញាត

**មាត្រា ១៣.-**

ការបញ្ចេញសារធាតុបំពុល និងសំលេងចូលទៅក្នុងបរិយាកាសពីប្រភពអចល័ត ត្រូវសុំការអនុញ្ញាតពីក្រសួងបរិស្ថាន និងត្រូវផ្ញើសេចក្តីចំលងនៃពាក្យសុំនោះទៅក្រសួង ស្ថាប័នពាក់ព័ន្ធ ។

**មាត្រា ១៤.-**

ការសុំអនុញ្ញាតនាំចូលសារធាតុឆេះ ត្រូវមានភ្ជាប់នូវលទ្ធផលវិភាគ ដែលបញ្ជាក់ពីបរិមាណជាតិពុលស្ពាន់ធ័រ សំណបង់សែន ឬអ៊ីដ្រូកាបូប្រហើរពីប្រភពដើមនៃការនាំចូល ឬការផលិត ។

**មាត្រា ១៥.-**

ការសុំអនុញ្ញាតលើការបញ្ចេញសារធាតុបំពុល និងសំលេងដូចមានចែងក្នុងមាត្រា ១៣ នៃអនុក្រឹត្យនេះ នឹងត្រូវអនុវត្តទៅលើប្រភពបំពុលទាំងគំរោងថ្មី និងសកម្មភាពដែលមានស្រាប់ និងកំពុងដំណើរការ លើកលែងតែគំរោងដែលមានរបាយការណ៍វាយតំលៃហេតុប៉ះពាល់បរិស្ថានរួចហើយ ។

**មាត្រា ១៦.-**

ម្ចាស់កម្មសិទ្ធិ ឬអ្នកទទួលខុសត្រូវប្រភពបំពុលដូចមានចែងក្នុងមាត្រា ១៣ នៃអនុក្រឹត្យនេះ ត្រូវដាក់ពាក្យសុំការអនុញ្ញាតមកក្រសួងបរិស្ថាន :

- អោយបានមុន ៤០ថ្ងៃ នៃការចាប់ផ្តើមដំនើរការ សំរាប់គំរោងនៅភ្នំពេញ
- អោយបានមុន ៦០ថ្ងៃ នៃការចាប់ផ្តើមដំនើរការ សំរាប់គំរោងនៅតាមខេត្ត ក្រុង ។

## ជំពូកទី ៤
## ការត្រួតពិនិត្យប្រភពបំពុល

**មាត្រា ១៧.-**

ការត្រួតពិនិត្យនូវបរិមាណជាតិពុលក្នុងសារធាតុឆេះ ការបញ្ចេញសារធាតុបំពុលខ្យល់ និងសំលេងពីប្រភពអចល័តជាសមត្ថកិច្ចរបស់ក្រសួងបរិស្ថាន ។

**មាត្រា ១៨.-**

ការត្រួតពិនិត្យនូវការបញ្ចេញឧស្ម័ន និងសំលេងពីប្រភពចល័ត ជាសមត្ថកិច្ចរបស់ក្រសួងបរិស្ថាន ដោយមានកិច្ចសហការពីក្រសួងស្ថាប័នពាក់ព័ន្ធ ។ ចំពោះនីតិវិធីក្នុងការត្រួតពិនិត្យនេះត្រូវកំណត់ដោយប្រកាសរួមរបស់អន្តរក្រសួង ។

**មាត្រា ១៩.-**

ក្រសួងបរិស្ថានត្រូវរៀបចំគោលការណ៍ណែនាំបច្ចេកទេស ស្តីពីវិធីសាស្ត្រត្រួតពិនិត្យប្រភពបំពុល វិធីសាស្ត្រកំណត់ទីតាំងយកគំរូតាង និងវិធីសាស្ត្រវិភាគគុណភាពខ្យល់ និងសំលេង ។

**មាត្រា ២០.–**

ក្រសួងបរិស្ថានត្រូវចុះយកគំរូតាងនៅគ្រប់ចំណុចបញ្ចេញរបស់ប្រភពបំពុល ។ ម្ចាស់កម្មសិទ្ធិ ឬអ្នកទទួលខុសត្រូវប្រភពបំពុលត្រូវចូលរួមសហការ និងបង្កលក្ខណៈងាយស្រួលដល់មន្ត្រីបរិស្ថាន ដែលចុះយកគំរូតាងដើម្បីបំពេញការងារតាមលក្ខណៈបច្ចេកទេស ។

**មាត្រា ២១.–**

នៅពេលចុះត្រួតពិនិត្យ ឬធ្វើអធិការកិច្ចនៅតាមប្រភពបំពុល មន្ត្រីបរិស្ថានអាចធ្វើការវិភាគគំរូតាងនៅនឹងកន្លែង ឬយកមកធ្វើនៅមន្ទីរពិសោធន៍ក្រសួងបរិស្ថាន ។

**មាត្រា ២២.–**

ម្ចាស់កម្មសិទ្ធិ ឬអ្នកទទួលខុសត្រូវប្រភពបំពុលត្រូវបង់ថ្លៃសំរាប់វិភាគតាមបញ្ជីចំនួនទឹកប្រាក់ដែលបានកំនត់ជាមុនដោយក្រសួងបរិស្ថាន និងក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ។ ចំណូលនេះត្រូវបញ្ចូលទៅក្នុងថវិកាជាតិដើម្បីផ្តល់ជូនទៅគណនីមូលនិធិទាយជ្ជទានបរិស្ថាន ។

**មាត្រា ២៣.–**

ម្ចាស់កម្មសិទ្ធិ ឬអ្នកទទួលខុសត្រូវប្រភពបំពុល អាចសុំធ្វើការវិភាគគំរូតាងសារធាតុបំពុលរបស់ខ្លួននៅតាមមន្ទីរពិសោធន៍រដ្ឋ ឬឯកជនដទៃទៀត ដែលមានការទទួលស្គាល់ជាផ្លូវការ ហើយដែលមន្ទីរពិសោធន៍នោះអនុវត្តវិធីសាស្ត្រវិភាគដូចដែលបានអនុវត្តនៅក្នុងមន្ទីរពិសោធន៍របស់ក្រសួងបរិស្ថាន ។

**មាត្រា ២៤.–**

ម្ចាស់កម្មសិទ្ធិ ឬអ្នកទទួលខុសត្រូវប្រភពបំពុលទាំងអស់ត្រូវ :

- ទទួលខុសត្រូវក្នុងការដំឡើង ឬបំពាក់ឧបករណ៍ច្រោះសំអាតសារធាតុបំពុល និងឧបករណ៍សំរាប់កាត់បន្ថយសំលេង ដើម្បីឱ្យឆ្លើយតបទៅនឹងកំណត់កំរិតស្តង់ដារ
- ទទួលខុសត្រូវក្នុងការដំឡើងគ្រឿងបរិក្ខារវាស់ស្ទង់សារធាតុបំពុលដែលបញ្ចេញពីប្រភពបំពុលរបស់ខ្លួន និងត្រូវរក្សាលទ្ធផលទុកជាឯកសារ ហើយត្រូវផ្ញើរបាយការណ៍មកក្រសួងបរិស្ថានរៀងរាល់ ៣ខែ ម្តង ។
- ជ្រើសរើសអ្នកជំនាញបរិស្ថានចំនួនមួយរូប ជាអ្នកទទួលខុសត្រូវក្នុងកិច្ចសំរបសំរួលការងារបរិស្ថាន និងរៀបចំផែនការការពារបរិស្ថានក្នុងមូលដ្ឋានរបស់ខ្លួន ដែលក្រសួងបរិស្ថានអាចផ្តល់ការបណ្តុះបណ្តាលតាមសំណូមពររបស់ម្ចាស់កម្មសិទ្ធិ ។

**មាត្រា ២៥.–**

ក្នុងករណីដែលរកឃើញថាការបញ្ចេញសារធាតុបំពុលខ្យល់ និងសំលេងពីប្រភពណាមួយពុំបានឆ្លើយតបទៅ និងកំរិតកំណត់ស្តង់ដារដូចមានចែងក្នុងមាត្រា ៥ មាត្រា ៧ នៃអនុក្រឹត្យនេះក្រសួងបរិស្ថានត្រូវ :

ក-ចេញបញ្ជាជាលាយលក្ខណ៍អក្សរតំរូវអោយម្ចាស់កម្មសិទ្ធិ ឬអ្នកទទួលខុសត្រូវប្រភពបំពុលនោះធ្វើការកែប្រែសកម្មភាពល្មើសជាបន្ទាន់ក្នុងរយៈពេលជាក់លាក់មួយ

ខ-ចេញបញ្ជាជាលាយលក្ខណ៍អក្សរតំរូវឱ្យម្ចាស់កម្មសិទ្ធិ ឬអ្នកទទួលខុសត្រូវប្រភពបំពុលនោះផ្អាកសកម្មភាពរបស់ខ្លួនជាបណ្តោះអាសន្នរហូតដល់បទល្មើសនោះត្រូវបានកែប្រែ ប្រសិនបើសកម្មភាពល្មើសបង្កឱ្យមានគ្រោះថ្នាក់ដល់សុខភាពសាធារណៈ ឬប៉ះពាល់ដល់គុណភាពបរិស្ថាន ។

## ជំពូកទី ៥

## ការត្រួតពិនិត្យគុណភាពខ្យល់

**មាត្រា ២៦.-**

ក្រសួងបរិស្ថានត្រូវធ្វើការត្រួតពិនិត្យតាមដានជាប្រចាំពីស្ថានភាព និងគុណភាពខ្យល់នៅទូទាំងព្រះរាជាណាចក្រកម្ពុជាដើម្បីមានវិធានការទប់ស្កាត់ និងកាត់បន្ថយការបំពុលខ្យល់បានទាន់ពេលវេលា ។

**មាត្រា ២៧.-**

ក្រសួងបរិស្ថានត្រូវគ្រប់គ្រងទិន្នន័យលទ្ធផលវិភាគគុណភាពខ្យល់ និងវាយតំលៃពីស្ថានភាពគុណភាពខ្យល់ ព្រមទាំងធ្វើការផ្សព្វផ្សាយជាសាធារណៈពីស្ថានភាពគុណភាព និងការបំពុលខ្យល់នៅទូទាំងព្រះរាជាណាចក្រកម្ពុជា ។

**មាត្រា ២៨.-**

ក្នុងករណីរកឃើញថា តំបន់ណាមួយត្រូវទទួលរងការបំពុលខ្យល់ ដែលបង្កអោយមានការគំរាមកំហែងដល់អាយុជីវិតសាធារណៈ ឬគុណភាពបរិស្ថាន ក្រសួងបរិស្ថានត្រូវធ្វើការផ្សព្វផ្សាយជាសាធារណៈជាបន្ទាន់ពីបញ្ហាគ្រោះថ្នាក់ និងត្រូវស៊ើបអង្កេតរកប្រភពដែលបង្កអោយមានការបំពុល ព្រមទាំងចាត់វិធានការទប់ស្កាត់ប្រភពបំពុលទាំងនោះ ដើម្បីស្តារនូវគុណភាពខ្យល់អោយបានប្រសើរឡើងវិញ ។

## ជំពូកទី ៦

## នីតិវិធីនៃការធ្វើអធិការកិច្ច

**មាត្រា ២៩.-**

នៅពេលចុះធ្វើអធិការកិច្ចតាមប្រភពបំពុល មន្ត្រីអធិការកិច្ចនៃក្រសួងបរិស្ថានត្រូវអនុវត្តតាមនីតិវិធីដូចមានចែងខាង ក្រោម :

ក-បង្ហាញអត្តសញ្ញាណប័ណ្ណ និងលិខិតបញ្ជាបេសកកម្មរបស់ខ្លួននៅពេលចូលក្នុងបរិវេណ ឬកន្លែងប្រភពបំពុលដើម្បីធ្វើអធិការកិច្ចយកគំរូតាង ឬពិនិត្យកំណត់ត្រា ។

ខ-កំណត់ហេតុ និងរបាយការណ៍ដំបូងនៃការត្រួតពិនិត្យ ឬយកគំរូតាង ត្រូវធ្វើនៅនឹងកន្លែងដែលធ្វើអធិការកិច្ចដោយត្រូវមានសាក្សីចូលរួមក្នុងករណីចាំបាច់ ។

គ-មន្ត្រីអធិការកិច្ចអាចសាកសួរ និងតំរូវឱ្យម្ចាស់កម្មសិទ្ធិ ឬអ្នកទទួលខុសត្រូវប្រភពបំពុលផ្តល់ពត៌មាន ឬឯកសារនានាដែលពាក់ព័ន្ធសំរាប់ប្រើប្រាស់ក្នុងការធ្វើរបាយការណ៍ និងកំណត់ហេតុសំរាប់ប្រើជាវត្ថុតាង ។

ឃ-របាយការណ៍ ឬកំណត់ហេតុត្រូវផ្តល់មួយច្បាប់ដល់ម្ចាស់កម្មសិទ្ធិ ឬអ្នកទទួលខុសត្រូវប្រភពបំពុល មួយច្បាប់ជូនតំណាងក្រសួងពាក់ព័ន្ធ និងមួយច្បាប់ទៀតត្រូវរក្សាទុកនៅក្រសួងបរិស្ថាន ។

**មាត្រា ៣០.-**

ក្នុងករណីមានពាក្យបណ្តឹង ឬសេចក្តីរាយការណ៍ថា ប្រភពបំពុលណាមួយបានបញ្ចេញសារធាតុបំពុលខ្យល់ ឬសំលេង ឬរំញ័របង្កអោយមានគ្រោះថ្នាក់ដល់សុខភាព ឬទ្រព្យសម្បត្តិសាធារណៈ ក្រសួងបរិស្ថានដោយសហការជាមួយក្រសួងពាក់ព័ន្ធមានសិទ្ធិធ្វើអធិការកិច្ចនៅក្នុងបរិវេណប្រភពបំពុលនោះ និងយកគំរូតាងមកធ្វើការវិភាគ ។

**មាត្រា ៣១.-**

ក្នុងករណីមានឧបទ្ទវហេតុ ឬគ្រោះថ្នាក់ធ្ងន់ធ្ងរណាមួយនៃការបំពុលខ្យល់ ឬការរំខានដោយសំលេង ក្រសួងបរិស្ថានត្រូវចុះធ្វើអធិការកិច្ចជាបន្ទាន់លើបញ្ហាឧបទ្ទវហេតុ ឬគ្រោះថ្នាក់ធ្ងន់ធ្ងរនោះ និងត្រូវជូនពតិមានទៅស្ថាប័នពាក់ព័ន្ធ និងអាជ្ញាធរមូលដ្ឋាន ។

**មាត្រា ៣២.-**

ក្នុងករណីបទល្មើសជាក់ស្តែងដែលបង្កអោយមានការបំពុលខ្យល់ ឬការរំខានដោយសំលេង មន្ត្រីអធិការកិច្ចក្រសួងបរិស្ថានត្រូវ :

ក-ធ្វើកំណត់ហេតុ ប្រមូលឃាត់ទុកវត្ថុតាងនៃបទល្មើស និងធ្វើការពិន័យអន្តរការណ៍ប្រសិនបើបទល្មើសនោះមិនបង្កអោយមានការបំពុលធ្ងន់ធ្ងរ ឬប៉ះពាល់ទៅដល់សុខភាព ឬទ្រព្យសម្បត្តិសាធារណៈ និងគុណភាពបរិស្ថាន ។

ខ-ប្រមូល និងឃាត់ទុកវត្ថុតាងនៃបទល្មើសនោះដើម្បីធ្វើកំណត់ហេតុ និងបញ្ជូនសំណុំរឿងទៅស្ថាប័នមានសមត្ថកិច្ច ប្រសិនបើបទល្មើសនោះបានបង្កអោយមានការបំពុលធ្ងន់ធ្ងរ ឬប៉ះពាល់ដល់សុខភាព ឬទ្រព្យសម្បត្តិសាធារណៈ និងគុណភាពបរិស្ថាន ។

## ជំពូកទី ៧

## ទោសប្បញ្ញត្តិ

**មាត្រា ៣៣.-**

ការរំលោភល្មើសទៅ និងអនុក្រឹត្យនេះនឹងត្រូវទទួលពិន័យ និងផ្តន្ទាទោសដោយយោងទៅតាមមាត្រា ២០ មាត្រា ២១ មាត្រា ២២ មាត្រា ២៣ និងមាត្រា ២៥ ជំពូក ទី ៩ នៃច្បាប់ស្តីពីកិច្ចការពារបរិស្ថាន និងការគ្រប់គ្រងធនធានធម្មជាតិ ។

**មាត្រា ៣៤.-**

កំណត់ហេតុចោទប្រកាន់បទល្មើសចំពោះជនទាំងឡាយណាដែលបានប្រព្រឹត្តផ្ទុយ ឬពុំអនុវត្តតាមមាត្រាណាមួយនៃអនុក្រឹត្យនេះ ជាសមត្ថកិច្ចរបស់មន្ត្រីក្រសួងបរិស្ថាន ។ ក្រសួងបរិស្ថានត្រូវអនុវត្តវិធានការច្បាប់ចំពោះបទល្មើសទាំង

ឡាយនៅក្នុងអនុក្រឹត្យនេះ ។

**មាត្រា ៣៥.-**

មន្ត្រី ឬភ្នាក់ងារអធិការកិច្ចបរិស្ថានរូបណា ដែលមានការធ្វេសប្រហែសខ្វះការប្រុងប្រយ័ត្ន ឬមិនគោរពបទបញ្ជារបស់ក្រសួង ឬរួមគំនិតនឹងអ្នកប្រព្រឹត្តបទល្មើស ឬជួយសំរួលដល់អ្នកប្រព្រឹត្តបទល្មើសនេះ ត្រូវទទួលការផ្តន្ទាទោសផ្នែករដ្ឋបាល ឬនឹងត្រូវជាប់ពីបទចោទប្រកាន់ចំពោះមុខតុលាការ ។

## ជំពូកទី ៨

## អវសានប្បញ្ញត្តិ

**មាត្រា ៣៦.-**

បទញ្ញត្តិទាំងឡាយណាដែលផ្ទុយ និងអនុក្រឹត្យនេះត្រូវទុកជានិរាករណ៍ ។

**មាត្រា ៣៧.-**

រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីគ្រប់ក្រសួង និងស្ថាប័នពាក់ព័ន្ធត្រូវសហការជាមួយក្រសួងបរិស្ថាន ហើយត្រូវទទួលបន្ទុកអនុវត្តអនុក្រឹត្យនេះតាមភារកិច្ចរៀងៗខ្លួន ។

**មាត្រា ៣៨.-**

អនុក្រឹត្យនេះចូលជាធរមានគតិយុត្តចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

រាជធានីភ្នំពេញ.ថ្ងៃទី ១០ ខែ កក្កដា ឆ្នាំ ២០០០

**នាយករដ្ឋមន្ត្រី**

**ហត្ថលេខា និងត្រា**

**ហ៊ុន សែន**

បានជំរាបជូន

សម្តេចនាយករដ្ឋមន្ត្រីដើម្បីសូមចុះហត្ថលេខា

រដ្ឋមន្ត្រីក្រសួងបរិស្ថាន

**ហត្ថលេខា**

**ម៉ុក ម៉ារ៉េត**

ឧបសម្ព័ន្ធ នៃអនុក្រឹត្យលេខ ៤២ អនក្រ.បក

ចុះថ្ងៃទី ១០ ខែ កក្កដា ឆ្នាំ ២០០០

# តារាងឧបសម្ព័ន្ធ ១

## កំរិតកំណត់ស្តង់ដារគុណភាពខ្យល់

| ល.រ | ប៉ារ៉ាម៉ែត្រ | រយៈពេល១ម៉ោង ជាមធ្យម mg/m3 | រយៈពេល៨ម៉ោង ជាមធ្យម mg/$m^3$ | រយៈពេល២៤ម៉ោង ជាមធ្យម mg/$m^3$ | រយៈពេល ១ឆ្នាំ ជាមធ្យមmg/$m^3$ |
|---|---|---|---|---|---|
| 1 | កាបូនឌីអុកស៊ីត CO | 40 | 20 | | |
| 2 | អាសូតឌីអុកស៊ីត$NO_2$ | 0,3 | | 0,10 | |
| 3 | ស្ពាន់ធ័រឌីអុកស៊ីត$SO_2$ | 0,5 | | 0,30 | 0,10 |
| 4 | អូសូន $0_3$ | 0,2 | | | |
| 5 | សំណ Pb | | | 0,005 | |
| 6 | សារធាតុរឹងអណ្តែតក្នុងខ្យល់ TSP | | | 0,33 | 0,10 |

**កំណត់សំគាល់**

-កំរិតកំណត់ស្តង់ដារនេះអនុវត្តសំរាប់ធ្វើការវាយតំលៃគុណភាពខ្យល់ទូទៅ និងអង្កេតតាមដានស្ថានភាពនៃការបំពុលខ្យល់ ។

-វិធីសាស្ត្រនៃការវិភាគគុណភាពខ្យល់នឹងត្រូវកំណត់តាមគោលការណ៍ណែនាំរបស់ក្រសួងបរិស្ថាន

-TSP Total Suspended Particulate

ឧបសម្ព័ន្ធ នៃអនុក្រឹត្យលេខ ៤២ អនក្រ.បក

ចុះថ្ងៃទី ១០ ខែ កក្កដា ឆ្នាំ ២០០០

# តារាងឧបសម្ព័ន្ធ ២

## កំរិតកំណត់ស្តង់ដារអតិបរមានៃសារធាតុប្រកបដោយគ្រោះថ្នាក់ ដែលអនុញ្ញាតអោយមាននៅក្នុងខ្យល់

| ល.រ | ឈ្មោះសារធាតុគីមី | រូបមន្តគីមី | កំរិតអតិបរមា (mg/m$^3$) |
|---|---|---|---|
| 1 | អានីលីន | $C_6H_5NH_2$ | 0,03 |
| 2 | អាម៉ូញាក់ | $NH_3$ | 0,2 |
| 3 | អាស៊ីត អាសេទិច | $CH_3COOH$ | 0,2 |
| 4 | អាស៊ីតស៊ុលផួរិច | $H_2SO_4$ | 0,3 |
| 5 | អាស៊ីតនីទ្រិច | $HNO_3$ | 0,4 |
| 6 | បង់សែន | $C_6H_6$ | 1 |
| 7 | បង់ស៊ីឌីន | $NH_2C_6H_4C_6H_4NH_2$ | គ្មាន |
| 8 | កាបូនឌីស៊ុលហ្វិត | $CS_2$ | 0,02 |
| 9 | ក្លរ៉ូហ្វម | $CHCL_3$ | 0,01 |
| 10 | កាបូនតេត្រាក្លរិត | $CCL_4$ | 3 |
| 11 | ភាគល្អិតដែលមាន asbestor | | គ្មាន |
| 12 | ដេ ដេ តេ | $C_8H_{11}CL$ | 0,5 |
| 13 | ហ្វម៉ល់ដេអ៊ីត | HCOH | 0,012 |
| 14 | អ៊ីដ្រូសែន អាសេនិច | $AsH_3$ | 0,002 |
| 15 | អ៊ីដ្រូសែន ស៊ីអានីត | HCN | 0,01 |
| 16 | អ៊ីដ្រូសែន ភ្លុយអរិច | HF | 0,002 |
| 17 | អ៊ីដ្រូសែនស៊ុលហ្វិត | $H_2S$ | 0,001 |
| 18 | ផេណុល | $C_6H_5OH$ | 0,01 |
| 19 | ស៊ីរេន | $C_6H_5CHCH_2$ | 0,003 |
| 20 | តេត្រាក្លរូអេទីឡែន | $C_2Cl_4$ | 0,1 |
| 21 | សំណតេត្រាអេទិល | $Pb(C_2H_5)_4$ | 0,005 |
| 22 | ទ្រីក្លរូអេទីឡែន | $CLCHCCL_2$ | 0,2 |
| 23 | តូលុយអែន | $C_9H_5CH_3$ | 0,4 |
| 24 | វិនិក្លរូ | $CLCHCH_2$ | 0,05 |

| | | | |
|---|---|---|---|
| 25 | អាសេទិច ( សមាសធាតុអសរីរាង្គ) | As | 0,00001 |
| 26 | កាត់ម្ញូម( សមាសធាតុលោហ: និងអុកស៊ីត) | Cd | 0,003 |
| 27 | ក្រូម( លោហ: និងសមាសធាតុ) | Cr | 0,0015 |
| 28 | នីកែល ( លោហ: និងសមាសធាតុ) | Ni | 0,0001 |
| 29 | បារត( លោហ: និងសមាសធាតុ) | Hg | 0,0001 |
| 30 | ប្រេងសាំង | | 5 |

**កំណត់សំគាល់**

កំរិតកំណត់ស្តង់ដារនេះអនុវត្តដើម្បីត្រួតពិនិត្យសារធាតុប្រកបដោយគ្រោះថ្នាក់ ដែលអនុញ្ញាតអោយមាននៅក្នុងខ្យល់ ។

ឧបសម្ព័ន្ធ នៃអនុក្រឹត្យលេខ ៤២ អនក្រ.បក

ចុះថ្ងៃទី ១០ ខែ កក្កដា ឆ្នាំ ២០០០

## តារាងឧបសម្ព័ន្ធ ៣

## កំរិតកំណត់ស្តង់ដារអតិបរមានៃសារធាតុបំពុល ដែលអនុញ្ញាតបញ្ចេញ ពីប្រភពអចលត៍ ចូលទៅក្នុងបរិយាកាស

| ល.រ | ប៉ារ៉ាម៉ែត | កំរិតអតិបរមានៃការបញ្ចេញ |
|---|---|---|
| 1 | ភាគល្អិតនៅក្នុងផ្សែង បញ្ចេញពីប្រភព : | |
| | -ឡដុត | 400 mg/$m^3$ |
| | -រោងចក្រផលិតលោហធាតុ | 400 mg/$m^3$ |
| | -រោងចក្រស៊ីម៉ង់តិ៍ កំបោរ និងថ្មស្អុយ | 400 mg/$m^3$ |
| | -រោងចក្របេតុងអាស្វាល់ | 500 mg/$m^3$ |
| 2 | ធូលី ដែលមានភ្ជាប់ : | |
| | -សារធាតុ ស៊ីលីកាត $Si0_2$ | 100 mg/$m^3$ |
| | -សារធាតុ Asbetos | 27 µg/$m_3$ |
| | -សារធាតុគីមីអសរីរាង្គ : | |
| 3 | អាលុយមីញ៉ូម AL | (ធូលី) ៣00 mg/$m^3$ .(Al) 50 mg/$m^3$ |
| 4 | អាម៉ូញាក់ $NH_3$ | 100 mg/$m^3$ |
| 5 | អាង់ទីម៉ូន Sb | 25 mg/$m^3$ |
| 6 | អាសេនិច As | 20 mg/$m_3$ |
| 7 | បេរីល្យូម Be | 10 µg/$m_3$ |
| 8 | ក្លរ CL | 20 mg/$m_3$ |
| 9 | អ៊ីដ្រូសែនក្លរីត HCL | 200 mg/$m_3$ |
| 10 | អ៊ីដ្រូសែនភ្លុយអរីត HF | 10 mg/$m_3$ |
| 11 | អ៊ីដ្រូសែនស៊ុលភីត $H_2F$ | 2 mg/$m_3$ |
| 12 | កាត់ម៉្យូម Cd | 1 mg/$m_3$ |
| 13 | ទង់ដែង Cu | (ធូលី) ៣00mg/$m_3$ (Cu) 20 mg/$m_3$ |
| 14 | សំណ Pb | (ធូលី) ១00 mg/$m_3$ (Pb) 30 mg/$m_3$ |
| 15 | ស័ង្កសី Zn | 30 mg/$m_3$ |
| 16 | បារត Hg | 0,1 mg/$m_3$ |
| 17 | កាបូនម៉ូណូអុកស៊ីត Co | 1000 mg/$m_3$ |

| | | |
|---|---|---|
| 18 | ស្ពាន់ធ័រឌីអុកស៊ីត $SO_2$ | 500 $mg/m^3$ |
| 19 | អាសូតអុកស៊ីត( គ្រប់ប្រភេទ) NOx | 1000 $mg/m^3$ |
| 20 | អាសូតអុកស៊ីត( ចេញពីការផលិតអាស៊ីត)NOx | 2000 $mg/m^3$ |
| 21 | អាស៊ីតស៊ុលផួរិច $H_2SO_4$ | 35 $mg/m^3$ |
| 22 | អាស៊ីតនីទ្រិច $HNO_3$ | 70 $mg/m^3$ |
| 23 | ស្ពាន់ធ័រទ្រីអុកស៊ីត ($SO_3$) | 35 $mg/m^3$ |
| 24 | អាស៊ីតផូស្វ័រិច ($H_3PO_4$) | 3 $mg/m^3$ |
| | <u>សារធាតុគីមីសរីរាង្គ</u> : | |
| 25 | អាសេទីឡែនតេត្រាប្រូមីត $CHBr_2CHBr_2$ | 14 $mg/m^3$ |
| 26 | អាក្រូឡេអ៊ិន $CH_2CHCHO$ | 1,2 $mg/m^3$ |
| 27 | អានីលីន $C_6H_5NH_2$ | 19 $mg/m^3$ |
| 28 | បង់ស៊ីឌីន $NH_2C_6H_4C_6H_4NH_2$ | None |
| 29 | បង់សែន $C_6H_6$ | 80 $mg/m^3$ |
| 30 | ក្លរូបង់ស៊ីល $C_6H_5CH_2Cl$ | 5 $mg/m^3$ |
| 31 | ប៊ុយទីលឡាមីន $CH_3(CH_2)_2CH_2NH_2$ | 15 $mg/m^3$ |
| 32 | ក្រេសូល (O-,m-,P-) $CH_3C_6H_4OH$ | 22 $mg/m^3$ |
| 33 | ក្លរូបង់សែន $C_6H_5Cl$ | 350 $mg/m^3$ |
| 34 | ក្លរូហ្វម $CHCl_3$ | 240 $mg/m^3$ |
| 35 | ក្លរូពិគ្រីន $CCl_3NO_2$ | 0,7 $mg/m^3$ |
| 36 | O-ឌីក្លរូបង់សែន $C_6H_4Cl_2$ | 300 $mg/m^3$ |
| 37 | 1.1-ឌីក្លរូអេតាន $CHCl_2CH_3$ | 400 $mg/m^3$ |
| 38 | ឌីមេទីលស៊ុលហ្វាត $(CH_3)_2SO_4$ | 0,5 $mg/m^3$ |
| 39 | ឌីមេទីលអ៊ីដ្រាហ្ស៊ីន $(NH_3)_2NNH_2$ | 1 $mg/m^3$ |
| 40 | ឌីនីត្រូបង់សែន (O-,m-,P-) $C_6H_4(NO_2)_2$ | 1 $mg/m^3$ |
| 41 | អេទីឡែនឌីអាមីន $NH_2CH_2$-$CH_2NH_2$ | 30 $mg/m^3$ |
| 42 | អេទីឡែន ក្លរូអ៊ីឌ្រីន $CH_2ClCH_2OH$ | 16 $mg/m^3$ |
| 43 | អេទីឡែន អុកស៊ីត $CH_2OCH_2$ | 20 $mg/m^3$ |
| 44 | ហ្វ័រម៉ាល់ដេអ៊ីដ HCHO | 6 $mg/m^3$ |
| 45 | មេទីលអាគ្រីឡាត $CH_2CHCOOCH_3$ | 35 $mg/m^3$ |
| 46 | មេតាណុល $CH_3OH$ | 260 $mg/m^3$ |
| 47 | មេទីលប្រូមីត $CH_3Br$ | 80 $mg/m^3$ |

| | | |
|---|---|---|
| 48 | ម៉ូណូមេទីលអានីលីន $C_6H_5NHCH_3$ | 9 mg/m$^3$ |
| 49 | នីត្រូបង់សែន $C_6H_5NO_2$ | 5 mg/m$^3$ |
| 50 | នីត្រូគ្លីសេរីន $C_3H_5(NO_2)_3$ | 5 mg/m$^3$ |
| 51 | នីត្រូតូលូអែន $NO_2C_6H_4CH_3$ | 30 mg/m$^3$ |
| 52 | ផេណុល $C_6H_5OH$ | 19 mg/m$^3$ |
| 53 | ផេនីលអ៊ីដ្រាហ្ស៊ីន $C_6H_5NHNH_2$ | 22 mg/m$^3$ |
| 54 | ពីរីនឌីន $C_5H_5N$ | 30 mg/m$^3$ |
| 55 | ពីរ៉ែន $C_{16}H_{10}$ | 15 mg/m$^3$ |
| 56 | គ្វីណូន $C_6H_4O_2$ | 0,4 mg/m$^3$ |
| 57 | ស្ទីរ៉ែន $C_6H_5CHCH_2$ | 420 mg/m$^3$ |
| 58 | 1,1,2,2-តេត្រាក្លរូអេតាន $Cl_2HCCHCl_2$ | 35 mg/m$^3$ |
| 59 | តេត្រាក្លរូមេតាន $CCl_4$ | 65 mg/m$^3$ |
| 60 | តូលូអែន $C_6H_5CH_3$ | 750 mg/m$^3$ |
| 61 | តេត្រានីត្រូមេតាន $C(NO_2)_4$ | 8 mg/m$^3$ |
| 62 | តូលូអ៊ីឌីន $CH_3C_6H_4NH_2$ | 22 mg/m$^3$ |
| 63 | តូលូអែន 2.4- ឌីអ៊ីសូស៊ីអាណាត $CH_3C_6H_3(NCO)_2$ | 0,7 mg/m$^3$ |
| 64 | ទ្រីក្លរូអេទីឡែន $ClCHCCl_2$ | 110 mg/m$^3$ |
| 65 | ស៊ីលីឌីន $(CH_3)_2C_6H_3NH_2$ | 50 mg/m$^3$ |
| 66 | វីនីលក្លរីត $CH_2CHCl$ | 150 mg/m$^3$ |

**កំណត់សំគាល់**

កំរិតកំណត់ស្តង់ដារនេះអនុវត្តដើម្បីត្រួតពិនិត្យការបញ្ចេញសារធាតុបំពុលពីប្រភពអចល័តចូលទៅក្នុងបរិយាកាស ។

តារាងឧបសម្ព័ន្ធ នៃអនុក្រឹត្យលេខ ៤២ អនក្រ.បក

ចុះថ្ងៃទី ១០ ខែ កក្កដា ឆ្នាំ ២០០០

# តារាងឧបសម្ព័ន្ធ ៤

## កំរិតកំណត់ស្តង់ដារ នៃការបញ្ចេញឧស្ម័នពីប្រភពអចល័ត

| ល.រ | ប្រភេទយានយន្ត | ប្រភេទប្រេងឥន្ធនៈ | កំរិតនៃការបញ្ចេញ | | | | |
|---|---|---|---|---|---|---|---|
| | | | CO (%) | | HC(ppm) | | ផ្សែងខ្មៅ % |
| | | | ក | ខ | ក | ខ | |
| 1 | ទោចក្រយានយន្តដែលមានចំហេះ២វគ្គ | ប្រេងសាំង | 4,5 | 4 | 10.000 | 3000 | |
| 2 | ទោចក្រយានយន្តដែលមានចំហេះ៤វគ្គ | ប្រេងសាំង | 4,5 | 4 | 10.000 | 2400 | |
| 3 | យានយន្តគ្រប់ប្រភេទ | ប្រេងសាំង | 4,5 | 4 | 1200 | 800 | |
| 4 | យានយន្តគ្រប់ប្រភេទ | ប្រេងម៉ាស៊ូត | | | | | ៥០ |

**កំណត់សំគាល់**

កំរិតកំណត់ស្តង់ដារនេះអនុវត្តដើម្បីត្រួតពិនិត្យការបញ្ចេញឧស្ម័នពីប្រភពអចល័តចូលទៅក្នុងបរិយាកាស ។

ក-គឺសំដៅលើយានយន្តគ្រប់ប្រភេទដែលប្រើប្រាស់ហួសរយៈពេល ៥ឆ្នាំ គិតពីឆ្នាំដែលផលិត ។

ខ-គឺសំដៅទៅលើយានយន្តគ្រប់ប្រភេទដែលបាននាំចូលថ្មីក្នុងរយៈពេល ប្រាំឆ្នាំដំបូងគិតចាប់ពីឆ្នាំដែលផលិត ។

តារាងឧបសម្ព័ន្ធ នៃអនុក្រឹត្យលេខ ៤២ អនក្រ.បក
ចុះថ្ងៃទី ១០ ខែ កក្កដា ឆ្នាំ ២០០០

# តារាងឧបសម្ព័ន្ធ ៥

## កម្រិតកំណត់ស្តង់ដារអតិបរមា ដែលអនុញ្ញាតបញ្ចេញសំលេងនៅ លើផ្លូវសាធារណៈ ពីប្រភពយានយន្ត

| ល.រ | **ប្រភេទយានយន្ត** | កម្រិតអតិបរមា (dB (A)) |
|---|---|---|
| 1 | ទោចក្រយានយន្តចំណុះស៊ីឡាំង (cc)< 125 $Cm^3$ | 85 |
| 2 | ទោចក្រយានយន្តចំណុះស៊ីឡាំង (cc)≥ 125 $Cm^3$ | 90 |
| 3 | **ត្រីចក្រយានយន្ត** | 90 |
| 4 | រថយន្តធុនតូច រថយន្តដឹកអ្នកដំណើរ ១២ នាក់ | 80 |
| 5 | រថយន្តដឹកអ្នកដំណើរ ≥ ១២ នាក់ | 85 |
| 6 | រថយន្តដឹកទំនិញដែលផ្ទុកទំនិញ < 3,5 តោន | 85 |
| 7 | រថយន្តដឹកទំនិញដែលផ្ទុកទំនិញ > 3,5 តោន | 88 |
| 8 | រថយន្តដឹកទំនិញដែលមានកំលាំង ≥ 150 kw | 89 |
| 9 | គ្រឿងយន្តផ្សេងៗទៀតដែលមិនបានរៀបរាប់ខាងលើ | 91 |

**កំណត់សំគាល់**

កម្រិតកំណត់ស្តង់ដារនេះអនុវត្តសំរាប់ការត្រួតពិនិត្យកម្រិតបញ្ចេញសំលេងពីប្រភពយានយន្តគ្រប់ប្រភេទ ដែលកំពុងធ្វើចរាចរលើផ្លូវសាធារណៈ ។

តារាងឧបសម្ព័ន្ធ នៃអនុក្រឹត្យលេខ ៤២ អនក្រ.បក
ចុះថ្ងៃទី ១០ ខែ កក្កដា ឆ្នាំ ២០០០

# តារាងឧបសម្ព័ន្ធ ៦

## កំរិតកំណត់ស្តង់ដារសំលេងអតិបរមា ដែលអនុញ្ញាតនៅតំបន់សាធារណៈ និងតំបន់លំនៅដ្ឋាន (dB(A))

| ល.រ | ទីតាំង | អំឡុងពេល | | |
|---|---|---|---|---|
| | | ពីម៉ោង ៦ព្រឹកដល់ម៉ោង ១៨ល្ងាច | ពីម៉ោង ១៨ល្ងាចដល់ម៉ោង ២២យប់ | ពីម៉ោង២២យប់ដល់ម៉ោង ៦ព្រឹក |
| 1 | តំបន់ស្ងប់ស្ងៀម<br>-មន្ទីរពេទ្យ<br>-បណ្ណាល័យ<br>សាលារៀន<br>មតេយ្យសាលា | 45 | 40 | 35 |
| 2 | តំបន់លំនៅដ្ឋាន<br>-សណ្ឋាគារ ទីកន្លែង រដ្ឋបាល<br>-ភូមិគ្រឹះ ផ្ទះល្វែង | 60 | 50 | 45 |
| 3 | តំបន់ពាណិជ្ជកម្ម សេវាកម្ម និងចំរុះ | 70 | 65 | 50 |
| 4 | ឧស្សាហកម្មធន់ស្រាល លាយចំរុះនៅក្នុងតំបន់លំនៅដ្ឋាន | 75 | 70 | 50 |

**កំណត់សំគាល់**

កំរិតកំណត់ស្តង់ដារនេះអនុវត្តសំរាប់ការត្រួតពិនិត្យកំរិតសំលេងពីប្រភព ឬសកម្មភាពណាមួយ ដែលបញ្ចេញសំលេងចូលក្នុងតំបន់សាធារណៈ និងតំបន់លំនៅដ្ឋាន ។

តារាងឧបសម្ព័ន្ធ នៃអនុក្រឹត្យលេខ ៤២ អនក្រ.បក

ចុះថ្ងៃទី ១០ ខែ កក្កដា ឆ្នាំ ២០០០

# តារាងឧបសម្ព័ន្ធ ៧

# កំរិតកំណត់ស្តង់ដារសំរាប់ត្រួតពិនិត្យសំលេង

# ក្នុងទីតាំង រោងជាង រោងចក្រឧស្សាហកម្ម

| កំរិតសំលេង (dB(A)) | រយៈពេលអតិបរមា (ម៉ោង) | កំណត់បង្ហាញ |
|---|---|---|
| 75 | 32 | ត្រូវផ្តល់ឧបករណ៍ការពារត្រចៀកដល់អ្នកបំរើការដែលធ្វើការនៅកន្លែងមានសំលេងលើសពី 80dB (A) |
| 80 | 16 | |
| 85 | 8 | |
| 90 | 4 | |
| 95 | 2 | |
| 100 | 1 | |
| 105 | 0,5 | |
| 110 | 0,25 | |
| 115 | 0,125 | |

**កំណត់សំគាល់**

កំរិតកំណត់ស្តង់ដារនេះអនុវត្តសំរាប់ការត្រួតពិនិត្យកំរិតសំលេងនៅក្នុងទីតាំងរោងជាង រោងចក្រឧស្សាហកម្ម ។

ឧបសម្ព័ន្ធ នៃអនុក្រឹត្យលេខ ៤២ អនក្រ.បក

ចុះថ្ងៃទី ១០ ខែ កក្កដា ឆ្នាំ ២០០០

# តារាងឧបសម្ព័ន្ធ ៧

# កំរិតកំណត់ស្តង់ដារ ជាតិស្ពាន់ធ័រ សំណ បង់សែន

# និងអ៊ីដ្រូកាប៊ួប្រហើរ ដែលអនុញ្ញាតឱ្យមាននៅក្នុងប្រេងឥន្ធនៈ និងធ្យូងថ្ម

| ល.រ | សារធាតុចំហេះ | ស្ពាន់ធ័រ(S) | សណ(Pb) | បង់សែន | អ៊ីដ្រូកាប៊ួប្រហើរ |
|---|---|---|---|---|---|
| 1 | ប្រេងខ្មៅ | 1,0% | | | |
| 2 | ប្រេងម៉ាស៊ូត | 0,2% | | | |
| 3 | ប្រេងសាំង | | 0,15 ក្រាម/លីត្រ | 3,5% | 50% |
| 4 | ធ្យូងថ្ម | 1,5% | | | |

**កំណត់សំគាល់**

កំរិតកំណត់ស្តង់ដារនេះអនុវត្តសំរាប់ត្រួតពិនិត្យជាតិស្ពាន់ធ័រ សំណ បង់សែន និងអ៊ីដ្រូកាប៊ួប្រហើរ ដែលអនុញ្ញាត អោយមាននៅក្នុងប្រេងឥន្ធនៈ និងធ្យូងថ្ម ។

# ឧបសម្ព័ន្ធទី២៖
# សេចក្តីណែនាំ
# ស្តីពី
# ការរៀបចំសណ្តាប់ធ្នាប់
# របៀបរៀបរយ និងសុវត្ថិភាព
# នៅតំបន់ផាប់ស្ទ្រីត ក្រុងសៀមរាប

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

រដ្ឋបាលខេត្តសៀមរាប
លេខៈ ០០៣/២៧ សណន

# សេចក្តីណែនាំ
## ស្តីពី
## ការរៀបចំសណ្តាប់ធ្នាប់ របៀបរៀបរយ និងសុវត្ថិភាព នៅតំបន់ផ្សារចាស់ក្រុងសៀមរាប ខេត្តសៀមរាប

រដ្ឋបាលខេត្តសៀមរាប សង្កេតឃើញថា កន្លងមកមានបងប្អូនប្រជាពលរដ្ឋ ម្ចាស់ទីតាំងអាជីវកម្ម និង អ្នកបើកបរយានយន្តគ្រប់ប្រភេទមួយចំនួនបានរំលោភបំពានយកដីចំណីផ្លូវ ចិញ្ចើមផ្លូវសាធារណៈ និងធ្វើសកម្មភាពផ្សេងៗទៀត ដើម្បីបំរើផលប្រយោជន៍ឯកជនរបស់ខ្លួន ដូចជាការប្រើប្រាស់ធ្វើជាចំណតយានជំនិះ បើកបរបញ្ច្រាស់ទិស បង្កើតទីតាំងលក់ដូរ ឬដួល លើកស្លាកយីហោ ឬស្លាកផ្សព្វផ្សាយពាណិជ្ជកម្ម និងការតបណ្តាញអគ្គិសនីចេញពីទីតាំងអាជីវកម្មពុំមានបច្ចេកទេសត្រឹមត្រូវជាដើម ដែលសកម្មភាពទាំងនោះ បានធ្វើឲ្យប៉ះពាល់យ៉ាងធ្ងន់ធ្ងរ ដល់សណ្តាប់ធ្នាប់របៀបរៀបរយ បាត់បង់សោភ័ណភាព ប្រព័ន្ធចរាចរណ៍ គ្មានផ្លូវថ្មើរជើង បង្កឲ្យមានគ្រោះថ្នាក់ចរាចរណ៍ និងគ្រោះអគ្គីភ័យ ជាយថាហេតុ និងជាការប្រព្រឹត្តផ្ទុយនឹងច្បាប់ស្តីពីចរាចរណ៍ផ្លូវគោក ច្បាប់ស្តីពីផ្លូវថ្នល់ និងលិខិតបទដ្ឋានគតិយុត្តពាក់ព័ន្ធ ។

ក្នុងន័យនេះ ដើម្បីពង្រឹងការគោរព និងអនុវត្តច្បាប់ឲ្យមានប្រសិទ្ធភាព ក៏ដូចជាការលើកកម្ពស់សោភ័ណភាពទីក្រុងសៀមរាបឲ្យសក្តិសមជាទីក្រុងទេសចរណ៍វប្បធម៌ប្រវត្តិសាស្ត្រ រដ្ឋបាលខេត្តសៀមរាប សូមធ្វើការណែនាំដូចខាងក្រោម៖

១-ការចតយានយន្តគ្រប់ប្រភេទ ត្រូវអនុវត្តឲ្យបានត្រឹមត្រូវតាមគំនូសសញ្ញាចរាចរណ៍លើផ្លូវ ផ្លាកសញ្ញាចរាចរណ៍ និងការចង្អុលបង្ហាញរបស់អាជ្ញាធរមានសមត្ថកិច្ចពាក់ព័ន្ធបានកំណត់។

២-ម្ចាស់អាជីវកម្មដ្ឋាន និងបុគ្គលិក ត្រូវដាក់តាំងរបស់របរលក់ និងចតយានយន្តផ្ទាល់ខ្លួនក្នុងទីតាំងកម្មសិទ្ធិរបស់ខ្លួន មិនត្រូវចតរំលោភ ឬប្រើប្រាស់ដីចំណីផ្លូវសាធារណៈជាដាច់ខាត។

៣-ផ្លូវលេខ៧ ដល់លេខ១១ និងកំណាត់ផ្លូវលេខ៨ អនុញ្ញាតឲ្យបិទការធ្វើចរាចរណ៍យានយន្ត ចាប់ពីម៉ោង ១៨:០០នាទី ដល់ម៉ោង ២៣:០០នាទី ដើម្បីទុកឲ្យភ្ញៀវទេសចរជាតិ-អន្តរជាតិ ធ្វើដំណើរដោយថ្មើរជើង។

-ផ្លូវលេខ២ធ្នូ មិនអនុញ្ញាតឲ្យរថយន្តក្រុងចំណុះចាប់ពី២៥កៅអីឡើងទៅឈប់ចតឡើយ ។

៤-កម្លាំងសមត្ថកិច្ចសណ្តាប់ធ្នាប់ និងចរាចរណ៍ក្រុង ព្រមទាំងសមត្ថកិច្ចពាក់ព័ន្ធ ត្រូវឈរជើងប្រចាំការ និងសម្របសម្រួលចរាចរណ៍ រៀបចំផ្លូវថ្មើរជើង សន្តិសុខ របៀបរៀបរយការដាក់តាំងលក់ និងអ្នកលក់ដូរចល័ត ។

៥-អង្គភាពអគ្គិសនីសៀមរាប ចាត់មន្ត្រីបច្ចេកទេសចុះត្រួតពិនិត្យ និងរៀបចំប្រព័ន្ធបណ្តាញខ្សែភ្លើងឡើងវិញ ។

៦-រដ្ឋបាលក្រុងសៀមរាប សហការជាមួយមន្ទីរពាណិជ្ជកម្មខេត្ត មន្ទីរទេសចរណ៍ខេត្ត មន្ទីរសុខាភិបាលខេត្ត មន្ទីរវប្បធម៌ និងវិចិត្រសិល្បៈខេត្ត រៀបចំ និងគ្រប់គ្រងការធ្វើអាជីវកម្ម ការលើកស្លាកយីហោ ការផ្សព្វផ្សាយពាណិជ្ជកម្ម និងគុណភាពចំណីអាហារ។

៧-មន្ទីរបរិស្ថានខេត្ត និងមន្ទីរសាធារណការ និងដឹកជញ្ជូនខេត្ត ត្រូវសហការគ្នាគ្រប់គ្រងកាកសំណល់រាវ-រឹងឲ្យបានល្អប្រសើរ ។

៨-ការបំពងសម្លេង ត្រូវអនុវត្តតាមស្តង់ដារបច្ចេកទេសកំណត់របស់ក្រសួងបរិស្ថាន។

៩-ក្នុងករណីមានបាតុភាពអសកម្មភាពណាមួយកើតឡើងដូចជា មានការទារកំរៃក្រៅសេវាពីម្ចាស់អាជីវកម្មដោយមិនស្របច្បាប់ ការមិនផ្តល់កិច្ចសហការពីអង្គភាព ឬសមត្ថកិច្ច ពាក់ព័ន្ធជាដើម សូមធ្វើការទំនាក់ទំនង:

-សេនាធិការ ស្នងការដ្ឋាននគរបាលខេត្ត ទូរស័ព្ទលេខ: ០៩៥ ៤៤ ៤៤ ១៥

-លោក នាយកទីចាត់ការអន្តរវិស័យ សាលាខេត្ត ទូរស័ព្ទលេខ: ០១១ ៨៧ ៦៣ ៩៣

-បណ្តាញសង្គម Facebook

- ផេក ឯឧត្តម បណ្ឌិត អភិបាលខេត្ត "Khim Bunsong, Siem Reap Governor"
- ផេក របស់រដ្ឋបាលខេត្ត "Siem Reap Provincial Hall"

-ប្រអប់គណនេយ្យភាព ដែលមានដាក់នៅតាមមុខទីតាំងរដ្ឋបាលខេត្តសៀមរាប

ទទួលបានសេចក្តីណែនាំនេះ នាយករដ្ឋបាលសាលាខេត្ត ស្នងការនគរបាលខេត្ត មេបញ្ជាការកងរាជអាវុធហត្ថខេត្ត មន្ទីរ-អង្គភាពពាក់ព័ន្ធ រដ្ឋបាលក្រុងសៀមរាប ត្រូវអនុវត្តឲ្យបានម៉ឺងម៉ាត់ប្រកបដោយការទទួលខុសត្រូវខ្ពស់ ចាប់ពីថ្ងៃចុះហត្ថលេខានេះតទៅ ៕

ខេត្តសៀមរាប ថ្ងៃទី ០៧ ខែ កក្កដា ឆ្នាំ ២០១៧

**អភិបាលខេត្ត**

**ឃឹម_ប៊ុនសុង**

**កន្លែងទទួល៖**

- ក្រសួងមហាផ្ទៃ
- ក្រុមប្រឹក្សាខេត្ត
  "ដើម្បីគោរពជូនជ្រាប"
- ស្នងការដ្ឋាននគរបាលខេត្ត
- បញ្ជាការដ្ឋានកងរាជអាវុធហត្ថខេត្ត
- មន្ទីរបរិស្ថានខេត្ត
- មន្ទីរទេសចរណ៍ខេត្ត
- មន្ទីរវប្បធម៌ និងវិចិត្រសិល្បៈខេត្ត
- មន្ទីរពាណិជ្ជកម្មខេត្ត
- មន្ទីរសុខាភិបាលខេត្ត
- មន្ទីរសាធារណការ និងដឹកជញ្ជូនខេត្ត
- អង្គភាពអគ្គិសនីសៀមរាប
- រដ្ឋបាលក្រុងសៀមរាប
  "ដើម្បីអនុវត្ត"
- មន្ទីរព័ត៌មានខេត្ត
  "ដើម្បីផ្សព្វផ្សាយ "
- ឯកសារ កាលប្បវត្តិ

# ឧបសម្ព័ន្ធទី៣៖

# សេចក្តីណែនាំ

# ស្តីពី

# ការធ្វើចរាចរណ៍របស់យានយន្តគ្រប់ប្រភេទ និងការរៀបចំសណ្តាប់ធ្នាប់ របៀបរៀបរយសាធារណៈ និង បរិស្ថានអនាម័យនៅក្នុងក្រុងសៀមរាប

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

រដ្ឋបាលខេត្តសៀមរាប
លេខៈ ០០១/១៩ ណ.ខ

# សេចក្តីណែនាំ
## ស្តីពីការធ្វើចរាចរណ៍របស់យានយន្តគ្រប់ប្រភេទ និងការរៀបចំសណ្តាប់ធ្នាប់ របៀបរៀបរយសាធារណៈ និងបរិស្ថាន អនាម័យ នៅក្នុងក្រុងសៀមរាប ខេត្តសៀមរាប

រដ្ឋបាលខេត្ត មានកិត្តិយសសូមជម្រាបជូនដល់ឯកឧត្តម លោកជំទាវ លោកឧកញ៉ា លោក លោកស្រី ម្ចាស់ក្រុមហ៊ុន ឬអ្នកប្រកបមុខរបរសេវាដឹកជញ្ជូន ឬក្រុមហ៊ុនទេសចរណ៍ ម្ចាស់សណ្ឋាគារ ភោជនីយដ្ឋាន គ្រឹះស្ថាន សហគ្រាស អាជីវកម្មដ្ឋានគ្រប់ប្រភេទ ប្រជាពលរដ្ឋ និងភ្ញៀវជាតិ-អន្តរជាតិ ឱ្យបានជ្រាបថា៖ បច្ចុប្បន្ននេះ រដ្ឋបាលខេត្តសង្កេតឃើញថានៅតាមបណ្តាផ្លូវ និងទីប្រជុំជននានាមួយចំនួន មានក្រុមហ៊ុនសេវាដឹកជញ្ជូន ឬក្រុមហ៊ុនទេសចរណ៍ និងបងប្អូនដែលកំពុងប្រកបមុខរបរសេវាដឹកជញ្ជូន ម្ចាស់សណ្ឋាគារ ភោជនីយដ្ឋាន គ្រឹះស្ថាន សហគ្រាស អាជីវកម្មដ្ឋានគ្រប់ប្រភេទ ប្រជាពលរដ្ឋ និងភ្ញៀវជាតិ-អន្តរជាតិ បានប្រើប្រាស់ទីតាំងដីចំណីផ្លូវសម្រាប់ការចតចំណតយានយន្តក្នុងគោលបំណងដើម្បីបម្រើផលប្រយោជន៍អាជីវកម្មរបស់ខ្លួន។ ក្នុងនោះដែរ ក៏មានអាកប្បកិរិយាឥរិយាបទមិនសមរម្យ និងមានការប៉ះពាល់ដល់សាធារណជនទូទៅដែលក្នុងនាមជាអ្នកបម្រើសេវាជូនភ្ញៀវជាតិ-អន្តរជាតិ ប្រជាពលរដ្ឋ ដែលបានទៅទទួលយកសេវាដឹកជញ្ជូនផ្សេងៗ ឬធ្វើដំណើរឆ្លងកាត់នៅតំបន់ទាំងនោះ ហើយនឹងអាចឈានដល់ការប្រើប្រាស់អំពើហិង្សាក្លាយជាបទល្មើសព្រហ្មទណ្ឌទៀតផង ដែលសកម្មភាពខាងលើបានបង្ក និងអនុវត្តន៍ផ្ទុយទៅនឹងគោលការណ៍ច្បាប់ លិខិតបទដ្ឋានគតិយុត្តជាធរមាន និងអាចឈានទៅការបាត់បង់ទ្រព្យសម្បត្តិ ការបង្កគ្រោះថ្នាក់ជាយថាហេតុផ្សេងៗ ឬអាចមានការកកស្ទះចរាចរណ៍ និងជះឥទ្ធិពលអវិជ្ជមានដល់សណ្តាប់ធ្នាប់ របៀបរៀបរយសាធារណៈ ព្រមទាំងធ្វើឱ្យប៉ះពាល់កិត្តិយស សោភ័ណភាពខេត្តសៀមរាប ដែលជាខេត្តទេសចរណ៍ប្រវត្តិសាស្ត្រផងដែរ។

ក្នុងន័យនេះ ដើម្បីក្សាឲ្យបាននូវសណ្តាប់ធ្នាប់ និងរបៀបរៀបរយសាធារណៈ ជាពិសេសដើម្បីធានាបាននូវសោភ័ណភាព បរិស្ថាន អនាម័យនៅតាមបណ្តាផ្លូវ និងទីប្រជុំជននានាឲ្យកាន់តែបានល្អប្រសើរ និងចៀសផុតពីការបង្កអសកម្មភាពអវិជ្ជមានណាមួយពាក់ព័ន្ធនឹងករណីខាងលើ រដ្ឋបាលខេត្ត សូមធ្វើការណែនាំគោលការណ៍ដូចខាងក្រោម៖

១-ចំពោះរថយន្តដឹកជញ្ជូនទំនិញ រថយន្តសណ្តោងរ៉ឺម៉ក និងរថយន្តឈ្នួល ឬរថយន្តដឹកជញ្ជូនអ្នកដំណើរគ្រប់ប្រភេទ ត្រូវចូលចតចំណតចំនួន ២ ទីតាំង ដែលរដ្ឋបាលខេត្តបានកំណត់ ចាប់ពីថ្ងៃទី **៣០ ខែ មេសា ឆ្នាំ ២០១៩ រួមមាន៖**

-ចំណតប៉ែកខាងកើតក្រុង ស្ថិតនៅក្នុងបុរីសៀង ណាំ ភូមិខ្វាវ សង្កាត់ជ្រាវ ក្រុងសៀមរាប ខេត្តសៀមរាប

-ចំណតប៉ែកខាងលិចក្រុង ស្ថិតនៅភូមិថ្នល់ សង្កាត់ស្រង៉ែ ក្រុងសៀមរាប ខេត្តសៀមរាប



រដ្ឋបាលខេត្តសៀមរាប ផ្លូវ៦០ម៉ែត្រ ភូមិបឹងដូនប៉ា សង្កាត់ស្លក្រាម ក្រុងសៀមរាប ខេត្តសៀមរាប Siem Reap Provincial Hall, 60m Street, Boeng Donpa Village Sangkat Slorkram, Siem Reap Municipality, Siem Reap Province, E-mail: srphall@yahoo.com Tel:(855) 63 765 276, (855) 63 765 319, Fax: (855) 63 765 341

២-រថយន្តដឹកជញ្ជូនទំនិញ រថយន្តសណ្តោងម៉ែក រថយន្តឈ្នួល និងរថយន្តដឹកជញ្ជូនអ្នកដំណើរគ្រប់ប្រភេទ និងយានយន្តដឹកជញ្ជូនសារធាតុស្ងួតគ្រប់ប្រភេទ មិនអនុញ្ញាតឲ្យធ្វើចរាចរណ៍ ឬចត នៅតាមបណ្តាផ្លូវជាតិលេខ ៦ ឬបណ្តាផ្លូវមួយចំនួនស្ថិតនៅក្នុងភូមិសាស្ត្រក្រុងសៀមរាបឡើយ។ ចំពោះរថយន្តគ្រប់ប្រភេទដែលបានបញ្ជាក់ខាងលើនេះ ត្រូវធ្វើចរាចរណ៍ឆ្លងកាត់តាមផ្លូវវាងក្រុងសៀមរាប ចាប់ពីចំណុចផ្លូវវាងក្រុងបែកខាងកើត (ស្តុបចរាចរណ៍ផ្លូវជាតិលេខ៦ (ចុងកៅស៊ូ) ស្ថិតនៅភូមិខ្វា សង្កាត់ជ្រាវ ក្រុងសៀមរាប និងផ្លូវវាងក្រុងបែកខាងលិចក្រុងចំណុចផ្លូវបំបែកផ្លូវជាតិលេខ៦ ជិតទីតាំងស្នាក់ការគយ និងរដ្ឋាករខេត្ត ស្ថិតនៅភូមិសណ្តាន់ សង្កាត់ទឹកវិល ក្រុងសៀមរាប

៣-ក្រុមហ៊ុន ឬអ្នកប្រកបមុខរបរសេវាដឹកជញ្ជូន ឬក្រុមហ៊ុនទេសចរណ៍ សណ្ឋាគារ ភោជនីយដ្ឋាន គ្រឹះស្ថាន សហគ្រាស អាជីវកម្មដ្ឋានគ្រប់ប្រភេទ មិនអនុញ្ញាតឲ្យមានការរៀបចំ ឬលោភយកទ្រូងផ្លូវ ចិញ្ចើមផ្លូវ និងចំណីផ្លូវ ធ្វើជាកម្មសិទ្ធិកន្លែងផ្ញើរថយន្ត ម៉ូតូ កង់ ម៉ូតូម៉ែក និងយានយន្តគ្រប់ប្រភេទ ដើម្បីបម្រើផលប្រយោជន៍របស់ខ្លួន ដែលធ្វើបាត់បង់នូវសណ្តាប់ធ្នាប់សាធារណៈ របៀបរៀបរយសាធារណៈ

៤-ចំពោះរថយន្តសម្រាប់បម្រើការដឹកជញ្ជូនដី ថ្ម ខ្សាច់ ទំនិញ ឬសម្ភារៈផ្សេងៗ និងសំរាម មិនអនុញ្ញាតឲ្យផ្ទុកហួសកម្រិត (ស្ថានភាពដើម) និងមានការគ្រប ឬគម្របឲ្យបានជិតគត់ម៉ត់ល្អ និងត្រឹមត្រូវល្អប្រសើរ ដើម្បីធានាឲ្យមានលក្ខណៈបច្ចេកទេស មិនឲ្យហុយ ធ្លាក់ ជ្រុះ ស្រក់ទឹក.....។ល។ នៅតាមដងផ្លូវឡើយ។

៥-ចំពោះក្រុមហ៊ុន ឬដេប៉ូផ្សេងៗ ឬក្រុមហ៊ុនទេសចរណ៍ ដែលចាំបាច់ត្រូវធ្វើចរាចរណ៍ចូលក្នុងក្រុងសៀមរាបដូចជាៈ រថយន្តដឹកជញ្ជូនភ្ញៀវទេសចរណ៍ និងរថយន្តធ្វើអាជីវកម្មលាយស៊ីម៉ង់ត៍ ដឹកដី ថ្ម ខ្សាច់ និងគ្រឿងសំណង់ផ្សេងៗ ត្រូវស្នើសុំការអនុញ្ញាតពីរដ្ឋបាលខេត្ត ព្រមទាំងមានការត្រួតពិនិត្យលក្ខណៈបច្ចេកទេស ស្របតាមគោលការណ៍ច្បាប់ លិខិតបទដ្ឋានគតិយុត្ត និងរៀបចំការកំណត់ពេលវេលា សម្រាប់ធ្វើចរាចរណ៍

៦-ចំពោះម្ចាស់ក្រុមហ៊ុនបម្រើសេវាដឹកជញ្ជូនទាំងអស់ ត្រូវពិនិត្យលទ្ធភាពផ្លាស់ប្តូរទីតាំងស្នាក់ការលក់សំបុត្រ ឬការទទួល និងដឹកជញ្ជូនភ្ញៀវ ឲ្យមានទីតាំងស្នាក់ការរបស់ខ្លួនស្ថិតនៅក្នុង ឬជិតទីតាំងចំណតដែលបានកំណត់ខាងលើ ហើយមិនអនុញ្ញាតឲ្យមានការទទួល ឬដឹកជញ្ជូនភ្ញៀវ ក្រៅពីចំណតដែលបានកំណត់ឡើយ។ ដោយឡែក ចំពោះទីស្នាក់ការដែលឋិតនៅក្រៅពីចំណតបានកំណត់ អនុញ្ញាតត្រឹមតែការបម្រើលក់សំបុត្រតែប៉ុណ្ណោះ

៧-ការចេតយានយន្តគ្រប់ប្រភេទ ត្រូវអនុវត្តឲ្យបានត្រឹមត្រូវតាមគំនូសសញ្ញាចរាចរណ៍ ស្លាកសញ្ញាចរាចរណ៍ ឬការចង្អុលបង្ហាញរបស់អាជ្ញាធរមានសមត្ថកិច្ចពាក់ព័ន្ធ ព្រមទាំងការបើកបរល្បឿន ដោយគោរពច្បាប់ចរាចរណ៍ផ្លូវគោក និងលិខិតបទដ្ឋានគតិយុត្តជាធរមាន

៨-ត្រូវសម្អាតបរិស្ថាន អនាម័យ និងវេចខ្ចប់កាកសំណល់រឹង-រាវគ្រប់ប្រភេទឲ្យបានត្រឹមត្រូវ និងស្អាតជាប្រចាំ ទាំងនៅក្នុង ឬក្រៅបរិវេណចំណត ដែលបានប្រកបមុខរបរ និងអាជីវកម្មរបស់ខ្លួន ព្រមទាំងការបញ្ចេញកាកសំណល់សំរាមឲ្យបានត្រឹមត្រូវ តាមពេលវេលាកំណត់ ដើម្បីងាយស្រួលឲ្យក្រុមហ៊ុនប្រមូលសំរាមដឹកជញ្ជូន

៩-ស្នងការដ្ឋាននគរបាលខេត្ត រដ្ឋបាលក្រុង-ស្រុក ឃុំ-សង្កាត់ ត្រូវចុះពិនិត្យ និងការរៀបចំសណ្តាប់ធ្នាប់ របៀបរៀបរយសាធារណៈ សោភ័ណភាព និង អនាម័យ បរិស្ថាន ឲ្យបានស្អាតជាប្រចាំទៅតាមដែនដីសមត្ថកិច្ចរៀងៗខ្លួន និងត្រូវរៀបចំផែនការសកម្មភាពដើម្បីអនុវត្តន៍ការងារតាមសមត្ថកិច្ចរៀងៗខ្លួន ដោយស្របតាមគោលការណ៍ណែនាំ ច្បាប់ និងលិខិតបទដ្ឋានគតិយុត្តជាធរមាន។

ទទួលបានសេចក្តីណែនាំនេះ រដ្ឋបាលខេត្ត សង្ឃឹមយ៉ាងមុតមាំថា ឯកឧត្តម លោកជំទាវ លោកឧកញ៉ា លោក លោកស្រី ម្ចាស់ក្រុមហ៊ុន ឬអ្នកប្រកបមុខរបរសេវាដឹកជញ្ជូន ឬក្រុមហ៊ុនទេសចរណ៍ ម្ចាស់សណ្ឋាគារ ភោជនីយដ្ឋាន គ្រឹះស្ថាន សហគ្រាស អាជីវកម្មដ្ឋានគ្រប់ប្រភេទ ប្រជាពលរដ្ឋ និងភ្ញៀវជាតិ-អន្តរជាតិ ចូលរួមអនុវត្ត និងសហការជាមួយអាជ្ញាធរមានសមត្ថកិច្ចពាក់ព័ន្ធ ដោយស្មារតីទទួលខុសត្រូវខ្ពស់។

ថ្ងៃអង្គារ ១០កើត ខែពិសាខ ឆ្នាំច សំរឹទ្ធិស័ក ព.ស២៥៦២

ខេត្តសៀមរាប ថ្ងៃទី ០២ ខែឧសភា ឆ្នាំ២០១៩

**អភិបាលខេត្ត**

**ទៀ សីហា**

**កន្លែងទទួល៖**
- ក្រសួងមហាផ្ទៃ
- ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់
- ក្រសួងសាធារណការ និងដឹកជញ្ជូន
- ក្រសួងទេសចរណ៍
- ក្រសួងបរិស្ថាន
- ក្រុមប្រឹក្សាខេត្ត

**"ដើម្បីសូមគោរពជូនជ្រាប"**
- ស្នងការដ្ឋាននគរបាលខេត្ត
- បញ្ជាការដ្ឋានកងរាជអាវុធហត្ថខេត្ត
- មន្ទីរ-អង្គភាពជុំវិញខេត្ត
- រដ្ឋបាលក្រុង-ស្រុក

**"ដើម្បីសហការអនុវត្ត"**
- មន្ទីរព័ត៌មានខេត្ត

**"ដើម្បីផ្សព្វផ្សាយ"**
- ឯកសារ កាលប្បវត្តិ

# ឧបសម្ព័ន្ធទី៤៖
# របាយការណ៍បញ្ចប់អាណត្តិទី២
# របស់ក្រុមប្រឹក្សាក្រុងសៀមរាប

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

**ខេត្តសៀមរាប**
**រដ្ឋបាលក្រុងសៀមរាប**
លេខ៖ ក.ប.រ....................

# របាយការណ៍បញ្ចប់អាណត្តិទី២
# របស់ក្រុមប្រឹក្សាក្រុងសៀមរាប
# (២០១៤-២០១៨)

## ឆ្នាំ ២០១៩

# មាតិកា

**សេចក្តីផ្តើម** ........ ០១
**ផ្នែកទី១ ៖ ការងារគ្រប់គ្រងរដ្ឋបាលក្រុង** ........ ០២
១.១. ការងាររដ្ឋបាល ........
០៤
១.២. ការងារផែនការ និងការគាំទ្រសង្កាត់ ........ ០៤
១.៣. ការគ្រប់គ្រងធនធានមនុស្ស ........
០៥
១.៤. ការងារហិរញ្ញវត្ថុ ........ ០៦
១.៥. ការងារលទ្ធកម្ម ........ ០៦
១.៦. ការងារអភិវឌ្ឍន៍ក្រុង ........០៧
**ផ្នែកទី២៖ការងារការិយាល័យ អង្គភាពជំនាញ** ........ ១១
២.១. សេដ្ឋកិច្ច........ ១១
២.២. សង្គមកិច្ច ........១៣
២.៣. ការគ្រប់គ្រងដីធ្លី ធនធានធម្មជាតិ បរិស្ថាន ការប្រែប្រួលអាកាសធាតុ
និងគ្រោះមហន្តរាយ ........ ១៩
២.៤. រដ្ឋបាល និងសន្តិសុខសណ្តាប់ធ្នាប់សាធារណៈ ........ ២០
**ផ្នែកទី៣៖ ការងាររដ្ឋបាលសង្កាត់** ........២២
**ផ្នែកទី៤៖បញ្ហាប្រឈម និងមេរៀនបទពិសោធន៍** ........ ២៥
**សេចក្តីសន្និដ្ឋាន** ........ ២៦
**ឧបសម្ព័ន្ធ៖**
ឧបសម្ព័ន្ធទី១ ៖ គម្រោងវិនិយោគ........២៧
ឧបសម្ព័ន្ធទី២ ៖ ការអនុវត្តគម្រោងវិនិយោគ ........២៧
ឧបសម្ព័ន្ធទី៣ ៖ បញ្ជីទ្រព្យសម្បត្តិ ........ ២៨
ឧបសម្ព័ន្ធទី៤ ៖ ការអនុវត្តផែនការសកម្មភាព និងថវិកាផអ៣ ........ ២៩

# សេចក្តីផ្តើម

ក្រុងសៀមរាប ជាក្រុងមួយក្នុងចំណោមស្រុកទាំង ១២ នៃខេត្តសៀមរាប ដែលមានព្រំប្រទល់

- ខាងកើតទល់ ៖ ស្រុកប្រាសាទបាគង
- ខាងលិចទល់ ៖ ស្រុកពួក
- ខាងជើងទល់ ៖ ស្រុកអង្គរធំ និងស្រុកបន្ទាយស្រី
- ខាងត្បូងទល់ ៖ បឹងទន្លេសាប

ក្រុងសៀមរាបមាន៖

| ល.រ | ការបរិយាយ | សរុប | ឯកតា |
|---|---|---|---|
| ១ | ផ្ទៃដីសរុប | ៤២៤,៧៣ | គីឡូម៉ែតការេ |
| ២ | ចំនួនសង្កាត់ | ១២ | សង្កាត់ |
| ៣ | ចំនួនភូមិ | ៩៩ | ភូមិ |
| ៤ | ចំនួនគ្រួសារ | ៥០ ៥០៦ | គ្រួសារ |
| ៥ | ចំនួនប្រជាពលរដ្ឋសរុប | ២៦៨ ៣៨០ | នាក់ |
| ៦ | ចំនួនស្ត្រីសរុប | ១៣៩ ២១៧ | នាក់ |

របាយការណ៍បញ្ចប់អាណត្តិទី២ របស់ក្រុមប្រឹក្សាក្រុងសៀមរាប គឺជាការបរិយាយសង្ខេបអំពីសមិទ្ធផលការងារដែលរដ្ឋបាលក្រុងសៀមរាប សម្រេចបានក្នុងរយៈពេល៥ឆ្នាំ ចាប់ពីឆ្នាំ២០១៤ ដល់ឆ្នាំ២០១៨។ របាយការណ៍បញ្ចប់អាណត្តិទី២នេះ មាន៤ផ្នែកដែលក្នុងនោះ ៖

- **ផ្នែកទី១ ៖ ការគ្រប់គ្រងរដ្ឋបាលក្រុងសៀមរាប**

  ផ្នែកទី១នេះ បរិយាយអំពីលទ្ធផលការងារដែលរដ្ឋបាលក្រុងសម្រេចបានក្នុងអាណត្តិទី២ របស់ក្រុមប្រឹក្សាក្រុងសៀមរាប។
- **ផ្នែកទី២ ៖ ការងាររបស់ការិយាល័យ អង្គភាពជំនាញ**

  ផ្នែកទី២នេះ បរិយាយអំពីលទ្ធផលការងាររបស់ការិយាល័យ អង្គភាពជំនាញនានា ដែលមានទីតាំងនៅក្នុងដែនសមត្ថកិច្ចក្រុង សម្រេចបានក្នុងអាណត្តិទី២ របស់ក្រុមប្រឹក្សាក្រុង ។
- **ផ្នែកទី៣ ៖ ការងាររដ្ឋបាលសង្កាត់**

  ផ្នែកទី៣នេះ បរិយាយសង្ខេបលទ្ធផលការងារដែលរដ្ឋបាលសង្កាត់ សម្រេចបានក្នុងរយៈពេល៥ឆ្នាំ (២០១៤-២០១៨)។
- **ផ្នែកទី៤ ៖ បញ្ហាប្រឈម និងមេរៀនបទពិសោធន៍**

  ផ្នែកទី៤នេះ បរិយាយអំពីបញ្ហាប្រឈម និងមេរៀនបទពិសោធន៍របស់រដ្ឋបាលក្រុង ក្នុងការបំពេញ ការងារនៅក្នុងអាណត្តិទី២ របស់ក្រុមប្រឹក្សាក្រុង ។

# ផ្នែកទី១
# ការគ្រប់គ្រងរដ្ឋបាលក្រុងសៀមរាប

## ១.១.ការងាររដ្ឋបាល

### ១.១.១៖ ការងារលិខិតស្នាម និងឯកសារប្រជាពលរដ្ឋ

- ដីកាដែលបានដាក់ចេញចំនួន ១៣ច្បាប់
- សេចក្តីសម្រេចចំនួន ១៣១ច្បាប់ រៀបចំលិខិតរដ្ឋបាលដែលបានដាក់ចេញចំនួន ១៧ ៥០៩ច្បាប់។
- ទទួលលិខិតពីរដ្ឋបាលនានា ក្រសួង មន្ទីរជុំវិញខេត្ត អង្គការសង្គមស៊ីវិលបាន និងការិយាល័យជុំវិញក្រុងសរុបចំនួន ១៣ ០៩៧ច្បាប់។
- ចេញសៀវភៅស្នាក់នៅដល់ប្រជាពលរដ្ឋចំនួន ៧ ០០០ក្បាល។

**តារាងទី១៖ លិខិតស្នាម និងឯកសារប្រជាពលរដ្ឋ**

| ល.រ | ការបរិយាយ | ចំនួន | | | | | |
|---|---|---|---|---|---|---|---|
| | | ២០១៤ | ២០១៥ | ២០១៦ | ២០១៧ | ២០១៨ | សរុប |
| ១ | ដីកាដែលបានដាក់ចេញ | ៤ | ១ | ៣ | ០១ | ៤ | ១៣ |
| ២ | សេចក្តីសម្រេចដែលបានដាក់ចេញ | ៣២ | ៣១ | ៩ | ២៧ | ៣២ | ១៣១ |
| ៣ | លិខិតដែលបានដាក់ចេញ | ២ ៩៧៦ | ៣ ៣៥៩ | ៣ ៤៨៨ | ៣ ៤៧៦ | ៤ ២១០ | ១៧ ៥០៩ |
| ៤ | លិខិតដែលបានទទួល | ១ ៧១២ | ២ ៧៥៦ | ១ ៩៦៨ | ២ ៤៥៨ | ៤ ២០៣ | ១៣ ០៩៧ |
| ៥ | សៀវភៅស្នាក់នៅ | ៤ ៣៤៥ | ៩៧២ | ៦៩១ | ៥៥៤ | ៤៣៨ | ៧ ០០០ |

### ១.១.២.៖ ការគ្រប់គ្រងប្រជាពលរដ្ឋ

**តារាងទី២៖ ការគ្រប់គ្រងប្រជាពលរដ្ឋ**

| ល.រ | ការបរិយាយ | ចំនួន |
|---|---|---|
| ១ | សរុបគ្រួសារ | ៥៨ ៧៤៨ |
| ២ | គ្រួសារអចិន្ត្រៃយ៍ | ៥០ ៥០៦ |
| ៣ | គ្រួសារបណ្តោះអាសន្ន | ៨ ២៤២ |
| ៤ | ប្រជាពលរដ្ឋសរុប | ២៦៨ ៣៨០ |
| ៥ | ប្រជាពលរដ្ឋជាស្ត្រី | ១៣៩ ២១៧ |
| ៦ | ប្រជាពលរដ្ឋដែលមានអាយុ១៨ឆ្នាំឡើង | ១៩១ ៩៣៥ |
| ៧ | ប្រជាពលរដ្ឋចំណាកស្រុក | ៥៥៦ |

### ១.១.៣៖ ការងារអត្រានុកូលដ្ឋាន

- ចេញសេចក្តីចម្លងសំបុត្រកំណើតដល់ប្រជាពលរដ្ឋបានចំនួន ៣២ ៤៤៦សន្លឹក។
- ចេញសេចក្តីចម្លងសំបុត្របញ្ជាក់កំណើតដល់ប្រជាពលរដ្ឋបានចំនួន ១៥៨ ២០៤សន្លឹក។
- ចេញសេចក្តីចម្លងសំបុត្រអាពាហ៍ពិពាហ៍ដល់ប្រជាពលរដ្ឋបាន ១៦ ៣០៥សន្លឹក។
- ចេញសេចក្តីចម្លងសំបុត្រមរណភាពដល់ប្រជាពលរដ្ឋបាន ២ ៨៣០សន្លឹក។

**តារាងទី៣៖ ការចេញសេចក្តីចម្លងសំបុត្រអត្រានុកូលដ្ឋាន**

| ល.រ | ការបរិយាយ | ចំនួន |
|---|---|---|
| ១ | សេចក្តីចម្លងសំបុត្រកំណើត | ៣២ ៤៤៦ |
| ២ | សេចក្តីចម្លងសំបុត្របញ្ជាក់កំណើត | ១៥៨ ២០៤ |
| ៣ | សេចក្តីចម្លងសំបុត្រអាពាហ៍ពិពាហ៍ | ១៦ ៣០៥ |
| ៤ | សេចក្តីចម្លងសំបុត្រមរណភាព | ២ ៨៣០ |

**១.១.៤. ការផ្សព្វផ្សាយព័ត៌មាន ទំនាក់ទំនងសាធារណៈ និងសហប្រតិបត្តិការអន្តរជាតិ** (រួមទាំងការងារសមាគម អង្គការមិនមែនរដ្ឋាភិបាល និងការងារចងសម្ព័ន្ធមេត្រីភាព)

- ផ្សព្វផ្សាយព័ត៌មានដល់សាធារណៈជនបាន ១ ១៣៥លើក និងការទំនាក់ទំនងសាធារណៈជាមួយប្រជាពលរដ្ឋបានចំនួន ២៧៥ ៥៤០លើក។

**១.១.៥. ការងារគណៈអភិបាល**

**ក-រៀបចំកិច្ចប្រជុំរបស់គណៈអភិបាលបាន ៩៦ លើក**

**ខ-ការចូលរួមកិច្ចប្រជុំផ្សេងៗរបស់គណៈអភិបាលក្រុងរួមមាន ៥៩៣ លើក៖**

- លោក នួន ពុទ្ធារ៉ា អភិបាល នៃគណៈអភិបាលក្រុងចំនួន ៣៤លើក។
- លោក លេង ពលៈ អភិបាលរង នៃគណៈអភិបាលក្រុងបានចំនួន ៣១៧លើក។
- លោក ពៅ សារ៉ាវុធ អភិបាលរង នៃគណៈអភិបាលក្រុងបានចំនួន ៧៥លើក។
- លោកស្រី លឹម ផល្លីកា អភិបាលរង នៃគណៈអភិបាលក្រុងបានចំនួន ៩៨លើក។
- លោក បូ ម៉េងទ្រី អភិបាលរង នៃគណៈអភិបាលក្រុងបានចំនួន ៦៩លើក។

**តារាងទី៤៖ កិច្ចប្រជុំគណៈអភិបាល**

| ល.រ | ការបរិយាយ | ចំនួន | | | | | |
|---|---|---|---|---|---|---|---|
| | | ២០១៤ | ២០១៥ | ២០១៦ | ២០១៧ | ២០១៨ | សរុប |
| ១ | កិច្ចប្រជុំអឌ្ឍមាសរបស់គណៈអភិបាល | ៩ | ១២ | ១២ | ១២ | ១១ | ៥៨ |
| ២ | កិច្ចប្រជុំប្រចាំខែរបស់គណៈអភិបាល | ៩ | ១២ | ៧ | ៦ | ៤ | ៣៨ |

**១.១.៦. ការងារក្រុមប្រឹក្សា និងគណៈកម្មាធិការនានា**

- រៀបចំកិច្ចប្រជុំសាមញ្ញរបស់ក្រុមប្រឹក្សាក្រុងបាន ៦០ លើក
- រៀបចំកិច្ចប្រជុំវិសាមញ្ញរបស់ក្រុមប្រឹក្សាក្រុងបាន ១៨ លើក
- រៀបចំកិច្ចប្រជុំសម្ងាត់របស់ក្រុមប្រឹក្សាក្រុងបានចំនួន ០៦ លើក
- រៀបចំកិច្ចប្រជុំគណៈកម្មាធិការបច្ចេកទេសបាន ២៣ លើក
- គណៈកម្មាធិការពិគ្រោះយោបល់កិច្ចការស្ត្រី និងកុមារប្រជុំបាន ៥៧លើក

**តារាងទី៥៖ កិច្ចប្រជុំក្រុមប្រឹក្សា និងគណៈកម្មាធិការនានា**

| ល.រ | ការបរិយាយ | ចំនួន | | | | | |
|---|---|---|---|---|---|---|---|
| | | ២០១៤ | ២០១៥ | ២០១៦ | ២០១៧ | ២០១៨ | សរុប |
| ១ | កិច្ចប្រជុំសាមញ្ញរបស់ក្រុមប្រឹក្សា | ១២ | ១២ | ១២ | ១២ | ១២ | ៦០ |
| ២ | កិច្ចប្រជុំវិសាមញ្ញរបស់ក្រុមប្រឹក្សា | ៤ | ៦ | ២ | ២ | ៤ | ១៨ |

| | | | | | | | |
|---|---|---|---|---|---|---|---|
| ៣ | កិច្ចប្រជុំសម្ងាត់របស់ក្រុមប្រឹក្សា | ០ | ១ | ២ | ២ | ១ | ៦ |
| ៤ | កិច្ចប្រជុំគណៈកម្មាធិការសម្របសម្រួលបច្ចេកទេស | ២ | ៤ | ៧ | ៧ | ៣ | ២៣ |
| ៥ | កិច្ចប្រជុំគណៈកម្មាធិការពិគ្រោះយោបល់កិច្ចការស្ត្រី និងកុមារ | ៩ | ១២ | ១២ | ១២ | ១២ | ៥៧ |

### ១.១.៧. ការងាររៀបចំវេទិកា

**តារាងទី៦៖ ការរៀបចំវេទិកា**

| ល.រ | ការបរិយាយ | ចំនួន | | | | | |
|---|---|---|---|---|---|---|---|
| | | ២០១៤ | ២០១៥ | ២០១៦ | ២០១៧ | ២០១៨ | សរុប |
| ១ | ការរៀបចំវេទិកាសាធារណៈ | ៥ | ៧ | ១១ | ១ | ១ | ២៥ |
| ២ | ប្រជាពលរដ្ឋសរុបដែលបានចូលរួម | ២៦០៣ | ២១១២ | ១៧៣៥ | ៣៩៤ | ៦៧៩ | ៧៥២៣ |
| ៣ | ប្រជាពលរដ្ឋជាស្ត្រីដែលបានចូលរួម | ៧២២ | ៧៨៩ | ៤៤៨ | ១១៧ | ១៩៣ | ២២៦៩ |

## ១.២. ការងារផែនការ និងការគាំទ្រសង្កាត់

### ១.២.១. ការកសាង និងការអនុវត្តផែនការអភិវឌ្ឍន៍ និងកម្មវិធីវិនិយោគ

**តារាងទី៧៖ គម្រោងវិនិយោគ**

(ព័ត៌មានបន្ថែមមាននៅក្នុងឧបសម្ព័ន្ធទី១ និងទី២)

| ល.រ | ការបរិយាយ | ចំនួន | | | | | |
|---|---|---|---|---|---|---|---|
| | | ២០១៤ | ២០១៥ | ២០១៦ | ២០១៧ | ២០១៨ | សរុប |
| ១ | គម្រោងវិនិយោគដែលបានស្នើ | ៨៣ | ១០៤ | ១៧៤ | ៩២ | ៩៧ | |
| ២ | គម្រោងវិនិយោគដែលបានអនុវត្ត | ២៦ | ៨ | ៤៩ | ២៧ | ៤ | |
| ៣ | តម្លៃគម្រោងវិនិយោគដែលបានស្នើ (លានរៀល) | ៦៨៦៣៧៨២ | ៣៦៥៤ ៣ | ១ ១៤៥ | ១៨ ៩៥៦ | ២៣ ៧៧៣ | |
| ៤ | តម្លៃគម្រោងវិនិយោគដែលបានអនុវត្ត (លានរៀល) | ៦៨៦៣៧៨២ | ៣៦៥៤ ៣ | ១ ១៤៥ | ១៨ ៩៥៦ | ២៣ ៧៧៣ | |
| សរុប | | | | | | | |

### ១.២.២. ការគាំទ្រឃុំ សង្កាត់

- គាំទ្របច្ចេកទេសសដល់ការកសាងកម្មវិធីវិនិយោគសង្កាត់ប្រចាំឆ្នាំរៀងរាល់ឆ្នាំ
- គាំទ្របច្ចេកទេសដល់ការកសាងផែនការថវិកា ការកែតម្រូវ និងបិទបញ្ជីថវិកាសង្កាត់រៀងរាល់ឆ្នាំ
- គាំទ្របច្ចេកទេសដល់ការកសាងផែនការសកម្មភាព និងផែនការរបស់ គ.ក.ស.ក រៀងរាល់ឆ្នាំ
- សម្របសម្រួល និងជំរុញការអនុវត្តគម្រោងមូលនិធិសង្កាត់រៀងរាល់ឆ្នាំ
- ពិនិត្យ និងតាមដាន សហការគាំទ្រ និងសម្របសម្រួលដំណើរការការអនុវត្តគម្រោងសង្កាត់ដែលអនុវត្តដោយដៃគូរអភិវឌ្ឍន៍
- តាមដានពិនិត្យ និងវាយតម្លៃការអនុវត្តគម្រោងមូលនិធិសង្កាត់
- តាមដានពិនិត្យ និងវាយតម្លៃការអនុវត្តគម្រោងរបស់ដៃគូរអភិវឌ្ឍន៍ ក្នុងក្របខ័ណ្ឌកម្មវិធីវិនិយោគប្រចាំឆ្នាំរបស់សង្កាត់

## ១.៣. ការគ្រប់គ្រងធនធានមនុស្ស

### ១.៣.១. ការគ្រប់គ្រងបុគ្គលិក

- បានរៀបចំប្រកាស ស្តីពីការរៀបចំមុខតំណែងមន្ត្រីរាជការទូទៅក្នុងរចនាសម្ព័ន្ធថ្មី
- បានធ្វើឧទ្ទេសនាមចុះតាមមូលដ្ឋាន និងតាមបណ្តាខេត្តជូនសមាជិកក្រុមប្រឹក្សាក្រុង និងគណៈអភិបាលក្រុង មន្ត្រីរដ្ឋបាលក្រុងតាមការចាំបាច់ និងជាក់ស្តែង
- បានរៀបចំប្រវត្តិរូបមន្ត្រីរដ្ឋបាលក្រុងរៀងរាល់ឆ្នាំ និងបញ្ជូនទៅសាលាខេត្តសៀមរាប
- បានរៀបចំធ្វើបច្ចុប្បន្នភាពមន្ត្រីរដ្ឋបាលក្រុងរៀងរាល់ឆ្នាំ
- ធ្វើសំណើរសុំគ្រឿងឥស្សរយសជូនមន្ត្រីមានស្នាដៃរៀងរាល់១ឆ្នាំម្តង
- រៀបចំផ្លាស់ប្តូរសមាសភាពសមាជិកក្រុមប្រឹក្សាក្រុងបានចំនួន ០៣នាក់
- រៀបចំផ្លាស់ប្តូរសមាសភាពក្រុមប្រឹក្សាសង្កាត់បានចំនួន៥៩នាក់
- បានរៀបចំបែបបទដាក់ឲ្យមន្ត្រីរដ្ឋបាលក្រុងចូលនិវត្តន៍ចំនួន៥នាក់
- បានរៀបចំសំណើរតែងតាំងស្មៀនចំនួន ០៣សង្កាត់ មានសង្កាត់សំបួរ សង្កាត់ស្រង៉ែ និងសង្កាត់ចុងឃ្នៀស
- បានប្រមូលបញ្ជីឈ្មោះមន្ត្រីជំនួយការសង្កាត់ទាំង១២ ដើម្បីរក្សាទុកជាឯកសាររបស់រដ្ឋបាលក្រុង
- ចេញលិខិតបេសកម្មជូនសមាជិក សមាជិកាក្រុមប្រឹក្សា គណៈអភិបាលក្រុង ប្រធាន អនុប្រធាន មន្ត្រីការិយាល័យចំណុះ និងជុំវិញក្រុង ១៣២៤លើក ។

**តារាងទី៨៖ ស្ថិតិក្រុមប្រឹក្សា និងបុគ្គលិក**

| ល.រ | ការបរិយាយ | សរុប | ស្រី |
|---|---|---|---|
| ១ | ប្រធានក្រុមប្រឹក្សា | ១ | ០ |
| ២ | សមាជិកក្រុមប្រឹក្សា | ១២ | ២ |
| ៣ | សមាជិកក្រុមប្រឹក្សាដែលបានផ្លាស់ប្តូរក្នុងរយៈពេល៥ឆ្នាំ (២០១៤-២០១៨) | ៣ | ០ |
| ៤ | អភិបាល | ១ | ០ |
| ៥ | អភិបាលរង | ៤ | ១ |
| ៦ | នាយករដ្ឋបាល | ១ | ០ |
| ៧ | នាយករងរដ្ឋបាល | ២ | ០ |
| ៨ | ប្រធានការិយាល័យ និងអង្គភាព | ៦ | ១ |
| ៩ | អនុប្រធានការិយាល័យ និងអង្គភាព | ៥ | ១ |
| ១០ | មន្ត្រីការិយាល័យ | ៣៧ | ១៤ |
| ១១ | បុគ្គលិកកិច្ចសន្យា | ២៥ | ១៣ |

### ១.៣.២. ការកសាងសមត្ថភាព

- ក្រុមប្រឹក្សា គណៈអភិបាល និងមន្ត្រីចំណុះក្រុង បានចូលរួមវគ្គបណ្តុះបណ្តាលផ្សេងៗទាំងការបណ្តុះបណ្តាលដែលរៀបចំដោយរដ្ឋបាលក្រុង រដ្ឋបាលខេត្ត ក្រសួង និងអង្គការសង្គមស៊ីវិលនានាបានចំនួន ១៧២វគ្គ។

### តារាងទី៩៖ ការកសាងសមត្ថភាព

| ល.រ | ការបរិយាយ | ចំនួន | | | | | |
|---|---|---|---|---|---|---|---|
| | | ២០១៤ | ២០១៥ | ២០១៦ | ២០១៧ | ២០១៨ | សរុប |
| ១ | វគ្គសិក្សា | ៤៤ | ៤៥ | ៣៨ | ៣៥ | ១០ | ១៧២ |
| ២ | សិក្ខាកាមសរុបដែលបានចូលរួមវគ្គសិក្សា | ១៨៣ | ៤៣ | ១៦៤ | ៧០ | ៣៤ | ៤៩៤ |
| ៣ | សិក្ខាកាមជាស្ត្រីដែលបានចូលរួមវគ្គសិក្សា | ៤២ | ៨ | ៦១ | ១៧ | ១៥ | ១៤៣ |

## ១.៤. ការងារហិរញ្ញវត្ថុ

### ១.៤.១. ការអនុវត្តថវិកា

### តារាងទី១០៖ ចំណូល ចំណាយ

| ឆ្នាំ | ចំណូល (គិតលានរៀល) | | | ចំណាយ (គិតលានរៀល) | | |
|---|---|---|---|---|---|---|
| | អនុម័ត | ជាក់ស្តែង | % | អនុម័ត | ជាក់ស្តែង | % |
| ២០១៤ | ២៩៨១ | ២៤០២ | ៨០.៥៩ | ២៩៨១ | ២០៣១ | ៦៨.១៥ |
| ២០១៥ | ៣៨៣៦ | ៣៦២៣ | ៩៤.៤៥ | ៣៨៣៦ | ២៥២៩ | ៦៥.៩៥ |
| ២០១៦ | ៥៤៤២ | ៤៣២៦ | ៧៩.៤៩ | ៥៤៤២ | ៤២២៦ | ៧៧.៦៥ |
| ២០១៧ | ៦២០៥ | ៤៧១១ | ៧៥.៩៣ | ៦២០៥ | ៣៨៦២ | ៦២.២៤ |
| ២០១៨ | ៥២៤៦ | ៥៥៤៣ | ១០៥.៦៥ | ៥២៤៦ | ៤៩៤៨ | ៩៤.៣២ |
| **សរុប** | ២៣៧១០ | ២០៦០៥ | ៨៦.៩០ | ២៣៧១០ | ១៧៥៩៦ | ៧៤.២១ |

### ១.៤.២.ការគ្រប់គ្រងទ្រព្យសម្បត្តិ

### តារាងទី១១៖ ការគ្រប់គ្រងទ្រព្យសម្បត្តិ

| ល.រ | ការបរិយាយ | ចំនួន | | | | | |
|---|---|---|---|---|---|---|---|
| | | ២០១៤ | ២០១៥ | ២០១៦ | ២០១៧ | ២០១៨ | សរុប |
| ១ | ទ្រព្យសម្បត្តិដែលបានទិញ ឬទទួល(ថ្មី) | ០ | ០ | ០ | ១០៥៤០០០០ | ០ | ១០៥៤០០០០ |
| ២ | ទ្រព្យសម្បត្តិដែលបានកាត់ចេញ | ០ | ០ | ០ | ០ | ០ | ០ |
| ៣ | ទ្រព្យសម្បត្តិសរុប | ០ | ០ | ០ | ០ | ០ | ០ |

## ១.៥. ការងារលទ្ធកម្ម

- គម្រោងទិញម៉ាស៊ីនថតចម្លង និង ម៉ាស៊ីនត្រជាក់ 14960000 រៀល
- គម្រោងទិញគ្រឿងបន្លាស់ និង ជួសជុលរថយន្តFord 12720000 រៀល
- គម្រោងទិញគ្រឿងបរិភោគ និងឧបភោគ 10 287 000 រៀល
- គម្រោងទិញប្រេងឥន្ធនៈ 165 073 600 រៀល
- គម្រោងទិញសម្ភារការិយាល័យ 114 965 000 រៀល

- គម្រោងទិញសម្ភារបរិក្ខាសង្ហារិម 19 560 000 រៀល
- គម្រោងទិញសម្ភារបរិក្ខាបច្ចេកទេស 22 900 000 រៀល
- គម្រោងសេវាអនាម័យបរិស្ថាន 2 316 863 000 រៀល
- គម្រោងជួសជុលអគាររដ្ឋបាលក្រុង 157,500,000 រៀល
- គម្រោងជួសជុលស្ពានបេតុងភូមិគោកត្នោត សង្កាត់គោកចក 126,552,000 រៀល
- គម្រោងជួសជុលទ្វារទឹក៣កន្លែងនៅភូមិចុងកៅស៊ូ សង្កាត់ស្លក្រាម ក្រុងសៀមរាប 39,000,000 រៀល
- គម្រោងជួសជុលផ្លូវគ្រួសក្រហម១កន្លែង (ទំហំ ៦មx៧២០ម) នៅភូមិអញ្ចាញ សង្កាត់នគរធំ 60,000,000 រៀល
- គម្រោងជួសជុលផ្លូវបេតុងអាមេ១ខ្សែ ប្រវែង៣២៦ម ទទឹង៥ម នៅភូមិទ្រាំង សង្កាត់ស្លក្រាម 145,690,000 រៀល
- គម្រោងជួសជុលលូរំដោះទឹក១ខ្សែ ប្រវែង១២៧ម នៅភូមិតាវៀន សង្កាត់សាលាកំរើក 31,890,000 រៀល
- គម្រោងជួសជុលផ្លូវបេតុងអាមេ៣ខ្សែ (ទី១.ក្នុងភូមិតាវៀន សង្កាត់សាលាកំរើក ប្រវែង ១៩៤ម ទទឹង៥ម ទី២.ក្នុងភូមិធ្លកអណ្តូង សង្កាត់ស្លក្រាម ប្រវែង១៨៨ម ទទឹង៥ម ទី៣.ក្នុងភូមិថ្មី សង្កាត់ស្វាយដង្គំប្រវែង ១៣៧ម ទទឹង៦ម ចំណាយថវិកា 242,000,000 រៀល

## ១.៦. ការងារអភិវឌ្ឍន៍ក្រុង

## ១.៤-ការងារអភិវឌ្ឍន៍ក្រុង

### ១.៤.១. ការសម្របសម្រួលតាមវិស័យ

#### ក.ការរៀបចំប្លង់គោលប្រើប្រាស់ដីធ្លី និងផែនការប្រើប្រាស់ដី

- សហការជាមួយមន្ទីររៀបចំដែនដី នគរូបនីយកម្ម សំណង់ និងសុរិយោដីខេត្ត ចុះវាស់វែងដីប្រជាពលរដ្ឋនៅភូមិវត្តបូព៌ សង្កាត់សាលាកំរើក ( ភូមិគ្រូវិទ្យាល័យអង្គរ ) ដើម្បីត្រៀមចេញប័ណ្ណកម្មសិទ្ធិជូន ក្នុងនោះវាស់វែងបានចំនួន ១១៣ក្បាលដី និងបំពេញទិន្នន័យបានចំនួន ១១៣ក្បាលដី ។

#### ខ.ការសាងសង់សំណង់ និងជួសជុលសំណង់នានា

- សហការជាមួយសាលាខេត្ត មន្ទីររៀបចំដែនដី នគរូបនីយកម្ម សំណង់ និងសុរិយោដីខេត្ត នគរបាលសណ្តាប់ធ្នាប់ក្រុង ការិយាល័យរៀបចំដែនដី នគរូបនីយកម្ម សំណង់ និងភូមិបាលក្រុង សង្កាត់ ប៉ុស្តិ៍នគរបាល និងភូមិ ចុះទប់ស្កាត់សំណង់ខុសច្បាប់ក្នុងក្រុងសៀមរាប បានចំនួន ២៣០លើក ។

#### គ.ការងារលំនៅដ្ឋានបណ្តោះអាសន្នក្នុងក្រុង

- ចូលរួមជាមួយក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ខេត្ត មន្ទីររៀបចំដែនដី នគរូបនីយកម្ម សំណង់ និងសុរិយោដីខេត្ត ការិយាល័យពាក់ព័ន្ធ សង្កាត់ និងភូមិ ប្រជុំពិភាក្សាស្វែងរកដំណោះស្រាយបញ្ហាសំណង់បណ្តោះអាសន្ន និងបានចុះស្រង់ស្ថិតិប្រជាពលរដ្ឋរបស់នៅលើសំណង់បណ្តោះអាសន្នចំនួន ៣៩លើក។
- ចុះស្រង់ស្ថិតិប្រជាពលរដ្ឋសាងសង់លំនៅដ្ឋានលើដីអតីតប្រព័ន្ធក្រវ៉ាត់ក្រុង ក្នុងភូមិបឹងដូនប៉ា សង្កាត់ស្លក្រាម មានចំនួន ១៩សំណង់ ។
- សហការជាមួយសាលាខេត្ត អាជ្ញាធរអប្សរា មន្ទីររៀបចំដែនដី នគរូបនីយកម្ម សំណង់ និងសុរិយោដីខេត្ត អធិការដ្ឋាននគរបាលក្រុង មូលដ្ឋានកងរាជអាវុធហត្ថក្រុង ការិយាល័យសាធារណការ និងដឹកជញ្ជូនក្រុង សង្កាត់ និងភូមិ សរុបចំនួន ៩៥នាក់ ( កម្មករ ៣៥នាក់ ) ដោយទទួលបានការឯកភាពពីព្រះរាជអាជ្ញាអមសាលាដំបូងខេត្ត ធ្វើការរុះរើ និងដកហូតសម្ភារសំណង់ ចំនួន ២០សំណង់, របងថ្ម, ក្រាក់ឈើ និងដំណាំផ្សេងៗ ដែលប្រជាពលរដ្ឋបានសាងសង់ និងដាំដុះដោយខុសច្បាប់នៅលើផ្លូវសាធារណៈ។

- ចូលរួមសហការជាមួយក្រុមការងារចម្រុះចុះរុះរើសំណង់ខុសច្បាប់ក្នុងតំបន់១ និងតំបន់២ ដែលបានសាងសង់ក្នុងយុទ្ធនាការបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សាឃុំ-សង្កាត់ ក្នុងភូមិសាស្ត្រក្រុងសៀមរាប បានចំនួន ១៥៥សំណង់ ក្នុងនោះ ផ្ទះចំនួន ១៥៤ខ្នង និងរបងចំនួន ០៩ ។

**ឃ.ការងារសណ្តាប់ធ្នាប់សាធារណៈ**

- សហការជាមួយសាលាខេត្ត អាជ្ញាធរជាតិអប្សរា មន្ទីរអង្គភាពពាក់ព័ន្ធ នគរបាលសណ្តាប់ធ្នាប់ក្រុង សង្កាត់ ប៉ុស្តិ៍នគរបាល និងភូមិ ចុះរៀបចំសណ្តាប់ធ្នាប់ក្នុងក្រុងសៀមរាបបានចំនួន ៩៨លើក ។
- សហការជាមួយមន្ទីរបរិស្ថានខេត្ត ចុះត្រួតពិនិត្យ និងណែនាំអំពីការបញ្ចេញសំឡេងរំពងនៅតំបន់ផាប់ស្ទ្រីត ស្ថិតនៅភូមិមណ្ឌល១ សង្កាត់ស្វាយដង្គុំ ចំនួន ៤០លើក ។
- សហការជាមួយមន្ទីរបរិស្ថានខេត្ត អធិការដ្ឋាននគរបាលក្រុង ការិយាល័យវប្បធម៌ និងវិចិត្រសិល្បៈក្រុង ការិយាល័យរៀបចំដែនដី នគរូបនីយកម្ម សំណង់ និងភូមិបាលក្រុង សង្កាត់ និងភូមិ ចុះចែកសេចក្តីណែនាំលេខ ០០៣/១៧ ស.ណ.ន ចុះថ្ងៃទី០៧ ខែកញ្ញា ឆ្នាំ២០១៧ របស់រដ្ឋបាលក្រុងសៀមរាប ដល់បងប្អូនអាជីវករ ពាណិជ្ជករ ម្ចាស់យានជំនិះ និងប្រជាពលរដ្ឋ នៅតំបន់ផាប់ស្ទ្រីត ភូមិមណ្ឌល១ សង្កាត់ស្វាយដង្គុំ បានចំនួន ៤០០នាក់។

**ង.កិច្ចការកសិកម្ម រុក្ខាប្រម៉ាញ់ និងនេសាទ**

- សហការជាមួយ ក្រុមចម្រុះថ្នាក់ជាតិ ព្រះរាជអាជ្ញាអមសាលាដំបូងខេត្ត អធិការដ្ឋាននគរបាលក្រុង កងរាជអាវុធហត្ថក្រុង សង្កាត់ ប៉ុស្តិ៍នគរបាល និងភូមិ ចុះបង្ក្រាបបទល្មើសនេសាទក្នុងក្រុងសៀមរាប ចំនួន៤៥លើក។

**ច.កិច្ចការប្រៃសណីយ៍ និងទូរគមនាគមន៍**

- សហការជាមួយនគរបាលសណ្តាប់ធ្នាប់ក្រុង ចុះទប់ស្កាត់ការជីកកប់បណ្តាញខ្សែកាប្លិ៍ខុសច្បាប់ចំនួន០១លើក។
- ថ្ងៃទី០២-០៧ ខែកុម្ភៈ ឆ្នាំ២០១៧ សហការជាមួយសាលាខេត្ត និងក្រុមហ៊ុនខ្សែកាប្លិ៍ Mekong net, Y5 net, Smart, T-C, Metfone និងក្រុមហ៊ុន City link ចុះចងខ្សែកាប្លិ៍ដែលរញ៉េរញ៉ៃឲ្យមានសណ្តាប់ធ្នាប់ ចំនួន ០២លើក។
- សហការជាប្រចាំជាមួយសាលាខេត្ត មន្ទីរសាធារណការ និងដឹកជញ្ជូនខេត្ត មន្ទីរប្រៃសណីយ៍ និងទូរគមនា-គមន៍ខេត្ត អង្គភាពអគ្គិសនីសៀមរាប អង្គភាពរដ្ឋាករទឹកស្វយ័តសៀមរាប នគរបាលសណ្តាប់ធ្នាប់ក្រុង សង្កាត់ ប៉ុស្តិ៍ និងភូមិ ចុះត្រួតពិនិត្យ និងតាមដានការជីក និងខួងដាក់ខ្សែកាប្លិ៍អុបទិចក្នុងក្រុងសៀមរាប របស់ក្រុមហ៊ុន ស៊ីហ្វូក ជីកបាន ៩៤កន្លែង និងខួងបានចំនួន ៤៧កន្លែង ។

**ឆ.កិច្ចការរ៉ែ និងថាមពល**

- សហការជាមួយអង្គភាពអគ្គិសនីសៀមរាប សង្កាត់ និងភូមិ ចុះត្រួតពិនិត្យទីតាំង និងសម្របសម្រួលដាំបង្គោលតម្លើងត្រង់ស្វូអគ្គិសនី ចំនួន ១៥លើក ។
- សហការជាមួយរដ្ឋបាលខេត្ត មន្ទីរសាធារណការ និងដឹកជញ្ជូនខេត្ត និងអង្គភាពអគ្គិសនីសៀមរាប ពិនិត្យទីតាំងស្នើសុំសាងសង់បន្ទប់បែងចែកថាមពលអគ្គិសនី ចំនួន ០៦ទីតាំង ក្នុងក្រុងសៀមរាប ។

**ជ.ការងារធនធានទឹក និងឧតុនិយម**

- ចូលរួមប្រជុំពិភាក្សាករណីស្នើសុំកំណត់ព្រំប្រទល់ចុងទឹក និងឃ្លាំងទឹកទំនប់៧៨ នៅក្នុងភូមិសាស្ត្រសង្កាត់សៀមរាប សង្កាត់ស្វាយដង្គុំ និងសង្កាត់សំបួរ ។

**ឈ.កិច្ចការវប្បធម៌ និងវិចិត្រសិល្បៈ**

- សហការជាប្រចាំជាមួយសាលាខេត្ត មន្ទីរសាធារណការ និងដឹកជញ្ជូនខេត្ត មន្ទីរប្រៃសណីយ៍ និងទូរគមនាគមន៍ខេត្ត អង្គភាពអគ្គិសនីសៀមរាប អង្គភាពរដ្ឋាករទឹកស្វយ័តសៀមរាប នគរបាលសណ្តាប់ធ្នាប់ក្រុង សង្កាត់ ប៉ុស្តិ៍ និងភូមិ ចុះត្រួតពិនិត្យទីតាំងត្រូវជីកតម្លើងជើងប៉ាណូ ចំនួន ១៦លើក។

**៣.កិច្ចការសាធារណការ និងដឹកជញ្ជូន**

- សហការជាមួយការិយាល័យសាធារណការ និងដឹកជញ្ជូនក្រុង ចុះត្រួតពិនិត្យករណីប្រជាពលរដ្ឋភូមិត្រៀក និងភូមិក្រសាំងរលើង សង្កាត់សៀមរាប ស្នើសុំឲ្យអាជ្ញាធរខេត្តជួយសាងសង់ស្ពានឆ្លងកាត់ផ្លូវសាធារណៈ ចំនួន ១៣ទីតាំង ជំនួសស្ពានរបស់មន្ទីរសាធារណការ និងដឹកជញ្ជូនខេត្ត ដែលបានដាក់បណ្តោះអាសន្ន ក្រោយពីធ្វើការជីកស្តារប្រឡាយរំដោះទឹកជំនន់។
- សហការជាមួយសាលាខេត្ត មន្ទីរសាធារណការ និងដឹកជញ្ជូនខេត្ត សង្កាត់ និងភូមិ ចុះត្រួតពិនិត្យប្រឡាយ ចំនួន ០២ខ្សែ ដែលត្រូវស្តារបន្ត ដើម្បីរំដោះទឹកជំនន់នារដូវវស្សា រួមមានប្រឡាយរ៉បខាងលិចផ្លូវក្រវ៉ាត់ក្រុង ចាប់ពីផ្ទះតា ឆេង ផុន ដល់ព្រំប្រទល់សង្កាត់សៀមរាប និងប្រឡាយផ្សារក្រោម។
- សហការជាមួយមន្ទីរសាធារណការ និងដឹកជញ្ជូនខេត្ត សង្កាត់ ប៉ុស្តិ៍នគរបាល និងភូមិ ចុះទប់ស្កាត់សំណង់ខុសច្បាប់រំលោភលើផ្លូវសាធារណៈ ចំនួន០២លើក ។
- សហការជាមួយ រដ្ឋបាលខេត្ត មន្ទីរសាធារណការ និងដឹកជញ្ជូនខេត្ត មន្ទីររៀបចំដែនដី នគរូបនីយកម្ម សំណង់ និងសុរិយោដីខេត្ត អធិការដ្ឋាននគរបាលក្រុង ការិយាល័យរៀបចំដែនដី នគរូបនីយកម្ម សំណង់ និងភូមិបាលក្រុង សង្កាត់ និងភូមិ ចុះត្រួតពិនិត្យ និងដោះស្រាយបើកផ្លូវសាធារណៈ ០៣ខ្សែ ។

**ង.កិច្ចការសមាគម អង្គការមិនមែនរដ្ឋាភិបាល**

- រៀបចំកិច្ចប្រជុំពិភាក្សាការងារសមាគម-អង្គការមិនមែនរដ្ឋាភិបាល ដែលកំពុងប្រតិបត្តិការក្នុងក្រុងសៀមរាប នៅសាលប្រជុំរដ្ឋបាលក្រុង ចំនួន២៥លើក ។

**ច.ការងារសង្គមកិច្ច សាសនា និងសុខាភិបាល**

- ចូលរួមវគ្គបណ្តុះបណ្តាលស្តីពីការអនុវត្តបរិស្ថានគ្មានផ្សែងបារី និងបានចុះណែនាំដល់បណ្តាអាជីវកម្មដ្ឋានក្នុងក្រុងសៀមរាប ចំនួន ២០កន្លែង ឲ្យបញ្ឈប់ការដាក់តាំងលក់បារីដែលផ្ទុយនឹងច្បាប់ លិខិតបទដ្ឋានជាធរមាន ។

**ទ.ការងារបេតិកភ័ណ្ឌ រមណីយដ្ឋាន និងតំបន់ប្រវត្តិសាស្ត្រ**

- សហការជាមួយសាលាខេត្ត មន្ទីររៀបចំដែនដី នគរូបនីយកម្ម សំណង់ និងសុរិយោដីខេត្ត មន្ទីរធនធានទឹក និងឧតុនិយមខេត្ត ការិយាល័យវប្បធម៌ និងវិចិត្រសិល្បៈក្រុង និងភូមិ វាស់វែងកំណត់ដីបុរាណដ្ឋាន ចំនួន០៩ទីតាំង។

**១.៤.២ ការអនុវត្តមុខងារផ្សេងៗ ( មិនទាន់មានប្រតិភូកម្ម )**

**១. ការដោះស្រាយ និងសម្រុះសម្រួលទំនាស់**

- **រឿងដោះស្រាយរួចរាល់នៅរដ្ឋបាលក្រុង មាន ៧៣ករណី**
- **រឿងដែលបានបញ្ជូនទៅស្ថាប័នពាក់ព័ន្ធ មានចំនួន ៤៣ករណី ៖**

**តារាងទី១២ ៖ ការដោះស្រាយ និងការសម្រុះសម្រួលទំនាស់**

| ល.រ | ការបរិយាយ | ចំនួន | | | | | |
|---|---|---|---|---|---|---|---|
| | | ២០១៤ | ២០១៥ | ២០១៦ | ២០១៧ | ២០១៨ | សរុប |

| | | | | | | | |
|---|---|---|---|---|---|---|---|
| ១ | ករណីដែលបានដោះស្រាយឬសម្រុះសម្រួលរួច | ៩ | ១៧ | ២១ | ១៦ | ១០ | ៧៣ |
| ២ | ករណីដែលបានបញ្ជូនទៅស្ថាប័នពាក់ព័ន្ធ | ៥ | ៦ | ១៧ | ១៣ | ២ | ៤៣ |

### ១.៦.៤. កិច្ចការច្រកចេញចូលតែមួយ

**តារាងទី១៣ ៖ កិច្ចការច្រកចេញចូលតែមួយ**

| ល.រ | ការបរិយាយ | ចំនួន | | | | | |
|---|---|---|---|---|---|---|---|
| | | ២០១៤ | ២០១៥ | ២០១៦ | ២០១៧ | ២០១៨ | សរុប |
| ១ | សេវាសរុបដែលបានផ្តល់ចប់សព្វគ្រប់ | ៣២ ៨១៥ | ៤១ ០៨០ | ៥៤ ០៤៤ | ៥៤ ០៩៦ | ៦២ ០៥១ | ២៤៤ ០៨៦ |
| ២ | ប្រជាពលរដ្ឋសរុបដែលបានទទួលសេវា | ៣២ ៨១៥ | ៤០ ៨៧១ | ៥២ ៦៥៥ | ៥៣ ០៥៨ | ៦១ ២១១ | ២៤០ ៦១០ |
| ៣ | ប្រជាពលរដ្ឋជាស្ត្រីដែលបានទទួលសេវា | ១១ ៦២៥ | ១៥ ៨៨៩ | ១៨ ៣៥៣ | ២០ ៤២៨ | ២២ ៦៧១ | ៨៨ ៩៦៦ |
| ៤ | ចំណូលដែលទទួលបានពីការផ្តល់សេវា | ១ ១៥២ ១៥២ ៩៤០ | ១ ៤៦២ ៦២៧ ០០០ | ៩១០ ៩៣១ ០០០ | ៥២៦ ៨៣០ ០០០ | ៤២៩ ២៧៦ ០០០ | ៤ ៤៨១ ៨១៦ ៩៤០ |
| ៥ | ប្រាក់រង្វាន់ដែលបានបែងចែក | ៣១៨ ៩៧៨ ៧៧៩ | ៥២៦ ៨៦០ ៤០៨ | ៤៤០ ៤៧៩ ៦៣៦ | ៤៦៤ ២៤៣ ៥៤៨ | ៣ ៣៨៤ ១៩ ៦១៩ | ២ ០៨៨ ៩៨១ ៩៩០ |
| ៦ | ករណីបណ្តឹងដែលទទួលបានសរុប | ១៥៧ | ១៧២ | ១៨៣ | ២៤៣ | ១២២ | ៨៧៧ |
| ៧ | ករណីបណ្តឹងដែលបានដោះស្រាយរួចជាស្ថាពរ | ៨១ | ៦២ | ៣៤ | ៥២ | ៣៥ | ២៦៤ |

### ១.៦.៥. កិច្ចការសេវាសង្គម និងការបង្កើនសិទ្ធិអំណាចស្ត្រី

**តារាងទី១៤៖ ការអនុវត្តសកម្មភាពសេវាសង្គម និងការងាររបស់គ.ក.ស.ក**

| ល.រ | ការបរិយាយ | ចំនួន | | | | | |
|---|---|---|---|---|---|---|---|
| | | ២០១៤ | ២០១៥ | ២០១៦ | ២០១៧ | ២០១៨ | សរុប |
| ១ | កិច្ចប្រជុំប្រចាំខែរបស់ គ.ក.ស.ក | ១៥ | ១៤ | ១៤ | ១៤ | ១៤ | ៧១ |
| ២ | ថវិកាគាំទ្រសកម្មភាពសេវាសង្គម និងការងាររបស់គ.ក.ស.ក | ០ | ០ | ០ | ៨៦០$ | ០ | ៨៦០$ |
| ៣ | វគ្គបណ្តុះបណ្តាលដែល គ.ក.ស.កបានទទួល | ០ | ៣ | ០ | ០ | ០ | ៣ |

# ផ្នែកទី២
# ការងាររបស់ការិយាល័យ អង្គភាពជំនាញ

## ៣.១. សេដ្ឋកិច្ច

### ៣.១.១.ការិយាល័យទេសចរណ៍

- ចុះស្រង់ទិន្នន័យសេវាកម្មទេសចរណ៍ដែលបង្កើតថ្មីបាន ៩០៧កន្លែង។
- បានផ្សព្វផ្សាយច្បាប់ទេសចរណ៍ និងជំរុញអាជីវករបម្រើសេវាកម្មទេសចរណ៍ក្នុងក្រុង ឲ្យមកសុំច្បាប់ប្រកបអាជីវកម្ម ២ ១៨៣លើក ក្នុងនោះម្ចាស់អាជីវកម្មបានមកសុំច្បាប់ ១ ១៣៧សេវា។

### ៣.១.២.ការិយាល័យកសិកម្ម

**ក-ការងារក្សេត្រសាស្ត្រ**

**ក.១-ការងារបង្កបង្កើនផលស្រូវប្រាំង និងស្រូវវស្សា**

- ឆ្នាំ២០១៤ អនុវត្តសរុបបាន ១១ ៣៥០ ហ.ត ស្មើ ១០១.០៦% នៃផែនការ ១១ ២៣០ហ.ត ។
- ឆ្នាំ២០១៥ អនុវត្តសរុបបាន ១១ ២៤៥ ហ.ត ស្មើ ១០០.១៣% នៃផែនការ ១១២៣០ហ.ត ។
- ឆ្នាំ២០១៦ អនុវត្តសរុបបាន ១១ ៨៦០ ហ.ត ស្មើ ១០០.១២% នៃផែនការ ១១៨៤៥ ហ.ត ។
- ឆ្នាំ២០១៧ អនុវត្តសរុបបាន ៩ ៩៣៥ ហ.ត ស្មើ ១០០.១០% នៃផែនការ ៩ ៩២៥ ហ.ត ។
- ឆ្នាំ២០១៨ អនុវត្តសរុបបាន ៧ ៩២៥ ហ.ត ស្មើ ៧៧.០៥% នៃផែនការ ១០ ២៨៥ ហ.ត ។

**ក.២-អំពីដំណាំរួមផ្សំស្រូវប្រាំង និងស្រូវវស្សា**

- ឆ្នាំ២០១៤ អនុវត្តសរុបបាន ៧០៥ហ.ត ស្មើនឹង ១២៧.០២% នៃផែនការ ៥៥៥ហ.ត។
- ឆ្នាំ២០១៥ អនុវត្តសរុបបាន ៦១០ ហ.ត ស្មើនិង ១០៩.៩០% នៃផែនការ ៥៥៥ ហ.ត។
- ឆ្នាំ២០១៦ អនុវត្តសរុបបាន ៣៥០ ហ.ត ស្មើនិង ៦៣.០៦% នៃផែនការ ៥៥០ ហ.ត។
- ឆ្នាំ២០១៧ អនុវត្តសរុបបាន ៤៧៣ ហ.ត ស្មើនិង ៨៥.២២% នៃផែនការ ៥៥០ ហ.ត។
- ឆ្នាំ២០១៨ អនុវត្តសរុបបាន ៦៨០ ហ.ត ស្មើនិង ១០៣.០៣% នៃផែនការ ៦៦០ ហ.ត។

**ខ-ការងារផលិតកម្ម និងបសុព្យាបាល**

**ខ.១-អំពីការងារចាក់វ៉ាក់សាំង និងថ្នាំការពារជំងឺសត្វ**

- ឆ្នាំ២០១៤ ចាក់វ៉ាក់សាំងការពារជំងឺគោ បានចំនួន ៦ ៣២៦ ក្បាល ក្របី បានចំនួន ១ ៥៩៥ក្បាល ជ្រូក បានចំនួន ២ ៧៥៤ ក្បាល។
- ឆ្នាំ២០១៥ ចាក់វ៉ាក់សាំងការពារជំងឺគោ បានចំនួន ៦ ៥៤០ ក្បាល ក្របី បានចំនួន ១ ៦១០ ក្បាល ជ្រូក បានចំនួន ២ ៨០០ ក្បាល។
- ឆ្នាំ២០១៦ ចាក់វ៉ាក់សាំងការពារជំងឺ គោ បានចំនួន ៦៨២២ ក្របី បានចំនួន ២១៥៤ក្បាល ជ្រូក បានចំនួន ២៨៣៥ ក្បាល។
- ឆ្នាំ២០១៧ ចាក់វ៉ាក់សាំងការពារជំងឺ គោ បានចំនួន ៥១០៧ ក្របី បានចំនួន ២២៣៤ក្បាល ជ្រូក បានចំនួន ៣៣៦៧ ក្បាល។
- ឆ្នាំ២០១៨ ចាក់វ៉ាក់សាំងការពារជំងឺសារទឹកគោ បានចំនួន ១ ៤៥៥ ក្បាល ក្របី បានចំនួន ១៤០៥ ក្បាល ជ្រូក បានចំនួន ១ ៨០៤ ក្បាល។

ខ.២-អំពីការងារចុះជួយព្យាបាល និងបញ្ចុះព្រូនសត្វ

- ឆ្នាំ២០១៤ ជួយព្យាបាលសត្វឲ្យកសិករសរុបបាន ៩៦៤ក្បាល ក្នុងនោះមាន៖ គោចំនួន ២៤៦ក្បាល ក្របីចំនួន ២៣០ក្បាល និងជ្រូកចំនួន ៤៨៨ក្បាល។ បញ្ចុះព្រូនសត្វសរុបបាន ១ ២១៥ក្បាល ក្នុងនោះមាន៖ គោចំនួន ២៧២៣ក្បាល ក្របីចំនួន ២៤៥ក្បាល និងជ្រូកចំនួន ៦៩៨ក្បាល។
- ឆ្នាំ២០១៥ ជួយព្យាបាលសត្វឲ្យកសិករសរុបបាន ៩៦៥ ក្បាល ក្នុងនោះមាន៖ គោ ២៤៥ក្បាល ក្របី ២២០ ក្បាល ជ្រូក ៥០០ ក្បាល។ បញ្ចុះព្រូនសត្វសរុបបាន ១១៥៥ ក្បាល ក្នុងនោះមាន៖ គោ ២៦៥ ក្បាល ក្របី ២៤០ ក្បាល ជ្រូក ៦៥០ ក្បាល។
- ឆ្នាំ២០១៦ ជួយព្យាបាលសត្វឲ្យកសិករសរុបបាន ១ ៦៩២ ក្បាល ក្នុងនោះមាន៖ គោ ៧១៧ក្បាល ក្របី ៣៨៤ក្បាល ជ្រូក ៥៩១ ក្បាល។ បញ្ចុះព្រូនសត្វសរុបបាន ១៩០២ ក្បាល ក្នុងនោះមាន៖ គោ ៦៥៧ក្បាល ក្របី ១៥៣ ក្បាល ជ្រូក ១០៩២ ក្បាល។ ដាក់ស្តាមសិប្បនិម្មិត្តលើជ្រូក ៦៦២ក្បាល។ គ្រៀវគោបានចំនួន ៣២៣ក្បាល និងជ្រូក ១២៣៧ក្បាល។
- ឆ្នាំ២០១៧ ជួយព្យាបាលសត្វឲ្យកសិករសរុបបាន ៣៩០៤ ក្បាល ក្នុងនោះមាន៖ គោ ២២០៧ក្បាល ក្របី ៦៦៥ក្បាល ជ្រូក ១០៣២ក្បាល។ បញ្ចុះព្រូនសត្វសរុបបាន ៤១៨៦ក្បាល ក្នុងនោះ៖ គោចំនួន ១ ២៨៤ក្បាល ក្របីចំនួន ៨៨៩ក្បាល និងជ្រូកចំនួន ២០១ក្បាល។ ដាក់ស្តាមសិប្បនិម្មិត្តលើជ្រូក ៥៥១ក្បាល។ គ្រៀវគោបានចំនួន ៥៨៤ក្បាល ។
- ឆ្នាំ២០១៨ ជួយព្យាបាលសត្វឲ្យកសិករសរុបបាន ៣ ១៦៩ក្បាល ក្នុងនោះមាន៖ គោចំនួន ១៣១៣ក្បាល ក្របីចំនួន ៦៨៤ក្បាល និងជ្រូកចំនួន ១១៧២ក្បាល។ បញ្ចុះព្រូនសត្វសរុបបាន ៤២៤៥ក្បាល ក្នុងនោះមាន ៖ គោចំនួន ១៧៩៣ក្បាល ក្របីចំនួន ៧២៤ក្បាល និងជ្រូកចំនួន ១៧២៨ក្បាល។ ដាក់ស្តែមសិប្បនិម្មិតសត្វជ្រូកបានចំនួន ៥១៨ក្បាល គោបានចំនួន ២៨ក្បាល។ គ្រៀវសត្វគោចំនួន ៣៨០ក្បាល និងជ្រូកចំនួន ១៦១ក្បាល។

## ៣.១.៣-ការិយាល័យពាណិជ្ជកម្ម

- ជំរុញអាជីវករម្ចាស់អាជីវកម្មសេវាកម្មក្នុងសង្កាត់ទាំង១២ ឲ្យមកសុំច្បាប់អនុញ្ញាតប្រកបអាជីវកម្ម នៅការិយាល័យច្រកចេញចូលតែមួយបាន ១ ៥៩៥កន្លែង ក្នុងនោះអាជីវករ មកសុំច្បាប់ប្រកបអាជីវកម្ម(ពាណិជ្ជកម្ម នៅការិយាល័យច្រកចេញចូលតែមួយបាន ១ ៧៦៣ច្បាប់។
- បានចុះស្រង់ទិន្នន័យអាជីវកម្មតាមផ្សារនានាក្នុងក្រុងរួមមាន៖ ផ្សារចាស់បានចំនួន ៣០៣កន្លែង ផ្សារអង្គរអាតសិនធ័របានចំនួន ១១២កន្លែង ផ្សារញ៉ែបានចំនួន ៣៣កន្លែង ផ្សារក្រោមបានចំនួន ១០៦កន្លែង ផ្សារត្រីកោណបានចំនួន ២១កន្លែង ផ្សារអង្គរថ្មីបានចំនួន ៥១កន្លែង ផ្សារហ៊ុយ ឡេង ដោគជ័យបានចំនួន ៣១ កន្លែង ផ្សារលើបានចំនួន ៥៤១កន្លែង ផ្សារពោធិ៍លង្ការបានចំនួន ៥៦កន្លែង ផ្សារសាមគ្គីបានចំនួន ៦០ កន្លែង ផ្សារប្រិមប្រិយ៍បានចំនួន ៤០កន្លែង សរុបរួម ១៣៥៤កន្លែង។

## ៣.១.៤-ការិយាល័យសាធារណការ

### ១. សកម្មភាពមន្ត្រីការិយាល័យ

- បានចូលរួមប្រជុំឆ្លងរបាយការណ៍នៅសាលាក្រុងសៀមរាប ចំនួន ៤០លើក។
- បានចូលរួមប្រជុំសាមញ្ញ អាណត្តិទី០២ របស់ក្រុមប្រឹក្សាក្រុងសៀមរាប ចំនួន៥០លើក ។
- បានចូលរួមប្រជុំគណៈបញ្ជាការពារឯកភាពរដ្ឋបាលក្រុង ចំនួន៤១លើក។

- បានសហការជាមួយសាលាក្រុង និងអាជ្ញាធរពាក់ពន្ធ័ចុះត្រួតពិនិត្យ និងសិក្សាស្ពានដែលយកសសរបេតុងមកជំនួសចំនួន១៣ស្ពាន ដើម្បីសាងសង់ស្ពានថ្មីដែលស្ថិតនៅភូមិត្រៀក និងភូមិក្រសាំងរលើង សង្កាត់សៀមរាប ជាប់ផ្លូវជីក្រហមឆ្ពោះទៅភ្នំក្រោម។
- បានចូលរួមប្រជុំដោះស្រាយករណីបិទផ្លូវសាធារណៈបានចំនួន ២០លើក។
- បានចូលរួមវគ្គបំប៉នសមត្ថភាពពីវិស័យសាធារណការ និងដឹកជញ្ជូន នៅមន្ទីរសាធារណការ និងដឹកជញ្ជូនខេត្តសៀមរាប បានចំនួន ៥លើក។
- បានចុះចែកសេចក្តីជូនដំណឹងស្តីពីការអនុញ្ញាតឲ្យហាងលក់យានយន្ត ចុះបញ្ជីយានយន្តជូនអតិថិជនតាមប្រពន្ធ័អនឡាញ ។
- បន្តចុះស្រង់ស្ថិតិយានយន្ត ជលយានយន្ត យានដ្ឋានជួសជុល និងកន្លែងលក់យានយន្តប្រចាំឆ្នាំ។
- ចុះធ្វើកិច្ចសន្យាជាមួយអាជីវករលក់ដូរនៅលើដីចំណីផ្លូវបានចំនួន ៣១៦នាក់រួមមានៈ ផ្លូវជាតិលេខ០៦ (ចាប់ពីស្តុបកោះកេរ្តិ៍ ដល់ស្ពានថ្ម) បានចំនួន ១៨នាក់ ផ្លូវហ្សាជីហ្គោល បានចំនួន ៥១នាក់ តំបន់ផ្សារចាស់ និងផាប់ស្ទ្រីត បានចំនួន១២៩នាក់ (មិនចូលរួម០៦នាក់) ផ្លូវផ្សារដើមក្រឡាញ់បានចំនួន ៦៨នាក់ ផ្លូវស៊ីបវ៉ដ្ឋលបានចំនួន ០៥នាក់ ផ្លូវ៦០ម៉ែត្រ បានចំនួន០៥នាក់។

**ខ.ការអភិវឌ្ឍហេដ្ឋារចនាសម្ព័ន្ធ**

- សាងសង់ផ្លូវក្រាលកៅស៊ូចាប់ពីស្ពាននាគទៅស្ពានបច្ចេកទេស (ខាងលិចស្ទឹង) ស្ថិតក្នុងសង្កាត់ស្លក្រាមមានប្រវែង ៧០០ម៉ែត្រ ទទឹង ០៦ម៉ែត្រ សម្រេចបាន១០០%។
- សាងសង់ផ្លូវកេសរកូល សង្កាត់ស្វាយដង្គុំ មានប្រវែង ៤២០ម៉ែត្រ ទទឹង ០៥ម៉ែត្រសម្រេចបាន១០០%។
- សាងសង់ផ្លូវក្រាលកៅស៊ូ ចាប់ពីភោជនីយដ្ឋានចិនខ្មៅទៅវត្តរាជបូព៌ ស្ថិតក្នុងសង្កាត់ស្លក្រាម និងសាលាកំរើកមានប្រវែង ៨៥០ ម៉ែត្រ ទទឹង០៨ម៉ែត្រ លទ្ធផលសម្រេចបាន១០០%។
- សាងសង់ផ្លូវបេតុង និងប្រឡាយ ក្រោយវត្តរាជបូព៌ ដល់ផ្លូវ លោកតា **ខៀវ ណឹយ** ស្ថិតក្នុងសង្កាត់សាលាកំរើកមានប្រវែង ៩០០ ម៉ែត្រ ទទឹង០៦ម៉ែត្រ សម្រេចបាន១០០%។
- រៀបចំដាក់លូនៅផ្លូវសាលាមត្តេយ្យញូវយ៉ក នៅសង្កាត់ស្វាយដង្គុំ មានប្រវែង ៦០០ម៉ែត្រ មុខកាត់០១ម៉ែត្រសម្រេចបាន១០០%។
- សាងសង់ផ្លូវក្រាលកៅស៊ូ និងសួនច្បារកណ្តាលនៅផ្លូវជាតិលេខ៦ ចាប់ពីស្ពានព្រះរាជដំណាក់ដល់សណ្ឋាគារស្មាយលីង សង្កាត់ស្លក្រាម មានប្រវែង ១៥០០ម៉ែត្រ ទទឹង១២ម៉ែត្រ សម្រេចបាន១០០%។
- សាងសង់ផ្លូវក្រាលកៅស៊ូពាមកក និងដាក់លូចាប់ពីរង្វង់មូលវត្តដំណាក់ដល់ផ្លូវសម្តេចហ៊ុនសែនសន្តិភាព (ផ្លូវក្រវ៉ាត់ក្រុង) នៅសង្កាត់សាលាកំរើក ប្រវែង៣០០០ម៉ែត្រ ទទឹង១៥ម៉ែត្រ សម្រេចបាន១០០%។
- សាងសង់ផ្លូវក្រាលកៅស៊ូ នៅផ្លូវ លោកតា **ខៀវ ណឹយ** ស្ថិតក្នុងសង្កាត់ស្លក្រាម និងសង្កាត់សាលាកំរើក មានប្រវែង ១៥០០ម៉ែត្រ ទទឹង ២០ម៉ែត្រ (មានសួនកណ្តាល០២) លទ្ធផលសម្រេចបាន ១០០% ដាក់លូសងខាង (ខាងកើត១ម៉ែត្រ ខាងលិច០,៦ម៉ែត្រ សម្រេចបាន១០០%)។

## ៣.២.សង្គមកិច្ច

### ៣.២.១.ការិយាល័យវប្បធម៌

- ប្រជុំបូកសរុបរបាយការណ៍ប្រចាំឆ្នាំនៅមន្ទីរវប្បធម៌ និងវិចិត្រសិល្បៈខេត្ត បានចំនួន ៥លើក។
- ប្រជុំឆ្លងរបាយការណ៍របស់រដ្ឋបាលក្រុងសៀមរាប បានចំនួន ៥០លើក។

- ប្រជុំសាមញ្ញ និងវិសាមញ្ញ របស់ក្រុមប្រឹក្សាក្រុងសៀមរាប ចំនួន ៥៥លើក ប្រជុំ គ.ក.ស.ក ចំនួន ៤០លើក ប្រជុំគណៈបញ្ជាការឯកភាពរដ្ឋបាលក្រុង ចំនួន ៤២លើក។
- ប្រជុំការងារសណ្តាប់ធ្នាប់ក្រុងនៅសាលាក្រុង និងនៅតំបន់ផាប់ស្ទ្រីត ចំនួន ២៥លើក។
- ប្រជុំការងារចម្រុះចុះជំរុញអាជីវករ ឲ្យមកសុំច្បាប់អាជីវកម្មនៅតាមផ្សារ បានចំនួន ១០លើក។
- ចុះត្រួតពិនិត្យអគ្គារវិទ្ធ និងពិនិត្យទីតាំងស្នើសុំលើកស្លាកយីហោ សរុប ១២៥កន្លែង ក្នុង ០៤សង្កាត់។
- ចុះជំរុញអាជីករ ឲ្យមកសុំច្បាប់អាជីវកម្ម នៅផ្សារចាស់ចំនួន ៣០៣កន្លែង ផ្សារអាតសិនធ័រចំនួន ១១២កន្លែង ផ្សារអង្គរថ្មី ចំនួន៥១កន្លែង ផ្សារក្រោមចំនួន១០៦កន្លែង ផ្សារត្រីកោណចំនួន២១កន្លែង ផ្សារញ៉ែចំនួន ៣៣ កន្លែង ផ្សារហ៊ុយឡេងជោគជ័យចំនួន៣១កន្លែង សរុបចំនួន០៧ផ្សារ ស្មើនឹង៦៥៧កន្លែង។
- ចុះធ្វើកិច្ចសន្យាស្តីពីការលក់ដូរ លើកស្លាកយីហោ លើដីចំណីផ្លូវក្នុងក្រុង ចំនួន៣៨៩កន្លែង។
- ចុះកាត់ស្លាកយីហោ ផ្ទាំងពាណិជ្ជកម្មគ្មានច្បាប់អនុញ្ញាត និងដាក់លើដីចំណីផ្លូវតាមបណ្តោយផ្លូវសុខសាន្ត បានចំនួន១៥០ស្លាក។
- សហការជាមួយនគរបាលសណ្តាប់ធ្នាប់ក្រុង ក្រុមការងារសណ្តាប់ធ្នាប់ក្រុង កាត់ស្លាកយីហោ តាមបណ្តោយ ផ្លូវជាតិលេខ៦ តាមបណ្តោយផ្លូវទៅអង្គរវត្ត បានចំនួន៥៥ផ្ទាំង។
- ចុះរៀបចំសណ្តាប់ធ្នាប់អ្នកលក់ដូរតាមចិញ្ចើមផ្លូវនានាក្នុងក្រុងបានចំនួន៣៤៧កន្លែង។
- ចុះស្រាវជ្រាវនៅសង្កាត់នគរធំអំពីវប្បធម៌រូបិយ និងអរូបិយ បានចំនួន០៤លើក។
- ចុះជំរុញអាជីវករ ពាក់ព័ន្ធនឹងវិស័យវប្បធម៌ បានចំនួន ១៨លើក ស្មើនឹង ២៥០កន្លែង។
- សហការជាមួយប្រធានភូមិព្រៃធំ សង្កាត់ស្រង៉ែ ទប់ស្កាត់ក្រុមការងារអាជ្ញាធរអប្សរា ដើម្បីធ្វើការពិភាក្សា លើការងារចុះកំណត់ ស្រះ ត្រពាំង គោក តំបន់បុរាណដ្ឋាន ចំនួន៣៧កន្លែង ដែលប៉ះពាល់ជាមួយប្រជាពលរដ្ឋ។
- ចូលរួមវេទិកាសាធារណៈរបស់ក្រុមការងារថ្នាក់ជាតិ និងថ្នាក់ក្រុងចំនួន ១១លើក។
- បានចេញលិខិតអនុញ្ញាតក្នុងវិស័យវប្បធម៌ និងវិចិត្រសិល្បៈ នៅការិយាល័យច្រកចេញចូលតែមួយ បានចំនួន ៦៨៩ច្បាប់។

+ **ស្ថិតិវិស័យបេតិកភ័ណ្ឌក្នុងក្រុងសៀមរាប**

- ប្រាសាទក្នុងក្រុងសៀមរាបមាន ៥៣ប្រាសាទ ល្អបង្គួរ ១៩ប្រាសាទ
- គោកបុរាណមាន២គោក, គ្រឹះប្រាសាទមាន៤គ្រឹះ, ត្រពាំងមាន១៧៤ត្រពាំង, អូរបុរាណ១អូរ, ស្រះបុរាណ ៩ស្រះ, ស្ពានបុរាណមាន២ស្ពាន, ទួលបុរាណមាន៤៩ទួល, កញ្ចាន់មាន៦កញ្ចាន់, ភ្នំមាន២ភ្នំ,វាលមាន១ វាល, បុរាណដ្ឋានមាន២កន្លែង, បឹងបុរាណមាន១កន្លែង, បារាយណ៍មាន១កន្លែង។

+ **ស្ថិតិវិស័យសិល្បៈក្រុងសៀមរាប**

- របាំមាន២៨ក្រុម, ល្ខោនស្បែកធំមាន២ក្រុម, ល្ខោនស្បែកតូចមាន១ក្រុម, ភ្លេងពិនពាទ្យ១៧វង់, ភ្លេងមហោរី ១ក្រុម, ភ្លេងធម្មឹងមាន១ក្រុម, ភ្លេងប្រពៃណីមាន៩ក្រុម, ភ្លេងគ្រឹមមាន២ក្រុម, ឆៃយ៉ាំមាន៥ក្រុម, របាំត្រុដិ មាន៦ក្រុម។
- រោងភាពយន្តមាន៣កន្លែង, រោងមហោស្រពមាន៣កន្លែង, គ្រឿងបំពងសំលេងមាន១០៣គ្រឿង។

+ **ស្ថិតិវិស័យសូនរូបក្រុងសៀមរាប**

- សិប្បកម្មខ្នាតធំមាន២កន្លែង, សិប្បកម្មខ្នាតមធ្យមមាន៣៦កន្លែង, សិប្បកម្មខ្នាតតូច៨៩កន្លែង,
- ហាងលក់វត្ថុសិល្បៈខ្នាតធំមាន៩កន្លែង, ហាងលក់វត្ថុសិល្បៈខ្នាតមធ្យមមាន១១៧កន្លែង, ហាងលក់វត្ថុ
- សិល្បៈខ្នាតខ្នាតតូចមាន៤៤៥កន្លែង, សារមន្ទីរមាន៨កន្លែង។

### ៣.២.២.ការិយាល័យធម្មការនិងសាសនា

+ រៀបចំប្រលងធម្មវិន័យថ្នាក់ត្រី ថ្នាក់ទោ ថ្នាក់ឯក
    - ថ្នាក់ត្រី ប្រឡងជាប់ ៥៥៦អង្គ អវត្តមាន ៥៦អង្គ សរុប ៥០០អង្គ
    - ថ្នាក់ទោ ប្រឡងជាប់ ២៣៦អង្គ អវត្តមាន ០៩អង្គ សរុប ២២៧អង្គ
    - ថ្នាក់ឯក ប្រឡងជាប់ ១២៤អង្គ អវត្តមាន ០៥អង្គ សរុប ១១៩អង្គ

- រៀបចំប្រលងពុទ្ធិកបឋមសិក្សា សមណសិស្សសរុប ២៥២រូប ប្រឡងជាប់ ១៩០អង្គ អវត្តមាន ៣៣អង្គ ប្រឡងធ្លាក់ ២៩អង្គ ។
- រៀបចំការប្រឡងចូលរៀនពុទ្ធិកអនុវិទ្យាល័យ សមណៈសិស្សសរុប២៥៥អង្គ។
- រៀបចំការប្រឡងចូលរៀនពុទ្ធិកសិក្សាទុតិយភូមិ នៅពុទ្ធិកវិទ្យាល័យវត្តរាជបូព៌ សមណសិស្សសរុបចំនួន ៤០៥អង្គ។
- ចុះស្រង់ស្ថិតិគ្រូ សមណសិស្ស សាលាពុទ្ធិកបឋមសិក្សា និងធម្មវិន័យក្នុងក្រុងសៀមរាប។
- ស្ថិតិគ្រូសរុប២២រូប គ្រូក្របខ័ណ្ឌចំនួន០៦រូប គ្រូកិច្ចសន្យាចំនួន១៦រូប
- ស្ថិតិសាលាពុទ្ធិកបឋមសិក្សា១៥ សាលាធម្មវិន័យមាន០១។
- ស្ថិតិសមណសិស្សពុទ្ធិកបឋមសិក្សាសរុបចំនួន៣២៥អង្គ ធម្មវិន័យមានចំនួន០៨អង្គ។

### ៣.២.៣.ការិយាល័យសង្គមកិច្ច

- រៀបចំបៀវត្សប្រចាំខែ ជូនមុខសញ្ញាអតីតយុទ្ធជន ក្នុងនោះមានជនពិការចំនួន ៥៧៧នាក់, និវត្តន៍ជនចំនួន ៧៦២នាក់, ជនបាត់បង់សមត្ថភាពការងារចំនួន៣២នាក់, ជនពលីចំនួន ៣៧៩នាក់ ជនមរណៈចំនួន ១៨៧ នាក់។
- សហការជាមួយកម្លាំងប្រដាប់អាវុធមាន ផ្នែកសឹករងក្រុង អធិការដ្ឋាននគរបាលក្រុង បញ្ជាការដ្ឋានកងរាជអាវុធហត្ថក្រុង និងអាជ្ញាធរមូលដ្ឋាន ពិធីប្រគល់ប្រាក់មរណសង្គ្រោះចំនួន ១៣៦សព ស្មើនឹងទឹកប្រាក់ចំនួន ៥៤៤ ០០០ ០០០រៀល។
- រៀបចំសំណើសុំលិខិតផ្តល់សិទ្ធិបើកប្រាក់របបសន្តិសុខសង្គមប្រចាំខែជំនួស ជូនគ្រួសារ អតីតយុទ្ធជន ចំនួន ១១២នាក់ ក្នុងនោះមានជំងឺចំនួន ៤១នាក់ ទទួលមរណភាពចំនួន ១២៤នាក់។
- រៀបចំបែបបទមុខសញ្ញាអតីតយុទ្ធជន សុំចូលជាសមាជិកសមាគមអតីតយុទ្ធជនកម្ពុជាបាន ចំនួន ១៧៨នាក់ ស្រី ១៤នាក់។
- បានរៀបចំប័ណ្ណសមាជិក ប.ស.ស របស់អតីតយុទ្ធជន ខុសព័ត៌មានផ្សេងៗ ការិយាល័យ បេឡាអតីត យុទ្ធជនខេត្ត និងសាខាបេឡាអតីតយុទ្ធជនក្រុង ត្រូវចេញលិខិតបញ្ជាក់ជូន អតីតយុទ្ធជន ដើម្បីផ្លាស់ប្តូរ ឬបន្ថែម ព័ត៌មានផ្សេងៗ ក្នុងប័ណ្ណសមាជិក ប.ស.ស បានចំនួន ១១៩នាក់ ស្រី២១នាក់ និងសម្របសម្រួលអំពីការទទួលសេវាថែទាំសុខភាពជូនអតីតយុទ្ធជន។
- បើកប្រាក់គោលនយោបាយ ធានារ៉ាប់រងសង្គម ជូនគ្រួសារសេពនិវត្តជន ចំនួន ១២៤គ្រួសារ។

### ៣.២.៤.ការិយាល័យអប់រំយុវជននិងកីឡា

**ក/ ផ្នែកចំណេះទូទៅ និងមត្តេយ្យ**

- សាលាបឋមសិក្សា, មត្តេយ្យសិក្សា, អនុវិទ្យាល័យ, វិទ្យាល័យទាំងអស់បានរៀបចំការប្រលងឆមាសទី១ និង លើកទី២ ។

- បានចុះពិនិត្យ និងវាយតម្លៃការអនុវត្តកម្មវិធីសាលាកុមារមេត្រី (ក្រុមDTMT) នៅសាលាបឋមសិក្សាដែលជួបការលំបាក។
- មន្ត្រីការិយាល័យបានចុះជួយបញ្ច្រាបថ្នាក់ពន្លឿនតាមសាលាបឋមសិក្សា និងសហគមន៍ដែលឧបត្ថម្ភដោយអង្គការ PSE។
- មន្ត្រីការិយាល័យបានបើកវគ្គបណ្តុះបណ្តាលគ្រូកិច្ចសន្យាលើកទី១ទទួលបានជោគជ័យដល់គ្រូចំនួន៨៣នាក់។

**ខ/ ផ្នែកបុគ្គលិករដ្ឋបាលផែនការសម្ភារៈ និងគណនេយ្យ**

- គ្រប់សាលាទទួលបានការប្រើប្រាស់សៀវភៅសិក្សាគោលគ្រប់គ្រាន់ និងសម្រាប់ស្រាវជ្រាវដល់គ្រូ និងសិស្ស។
- បានរៀបចំការដំឡើងកាំប្រាក់លើកទី២ របស់មន្ត្រីអប់រំ។
- បានរៀបចំច្បាប់លំហែមាតុភាព ច្បាប់សម្រាក់រយៈពេលខ្លី និងវែង ច្បាប់គណៈកម្មាការបោះឆ្នោត ច្បាប់ផ្សេងៗ និងរៀបចំប្រាក់បៀវត្សរៀងរាល់ខែបានទៀងទាត់ និងទាន់ពេលវេលា។
- បូកសរុបសៀវភៅសិក្សាគោលចុងឆ្នាំ និងបានពិនិត្យលើការប្រមូលសៀវភៅទុកតាមសាលានានា។
- វាយតម្លៃ និងរៀបចំគ្រឿងឥស្សរិយសជូនមន្ត្រីអប់រំរួមមាន៖ មាស១៥គ្រឿង ប្រាក់២៣គ្រឿង សំរិទ្ធ៣៨គ្រឿង។

**គ/ ផ្នែកអប់រំក្រៅប្រព័ន្ធ**

- អធិការកិច្ចតាមថ្នាក់ ដើម្បីឲ្យដំណើរការរៀនសូត្របានល្អ ។
- ប្រជុំត្រួតពិនិត្យការអនុវត្តបំណិនជីវិតរបស់មណ្ឌលសិក្សាសហគមន៍។
- បើកគណនីជូនគ្រូអក្ខរកម្មថ្នាក់សមមូល។

## ៣.២.៥.ការិយាល័យផែនការ និងស្ថិតិ

- ចូលរួមកិច្ចប្រជុំសាមញ្ញ អាណត្តិទី២ របស់ក្រុមប្រឹក្សាក្រុងសៀមរាប នៅសាលប្រជុំរដ្ឋបាលក្រុងសៀមរាប ចំនួន៥០លើក។
- ចូលរួមប្រជុំគណៈកម្មាធិការពិគ្រោះយោបល់កិច្ចការស្ត្រី និងកុមារ ចំនួន៣៤លើក។
- បានចូលរួមកិច្ចប្រជុំស្តីពីការងារអត្រានុកូលដ្ឋាន និងការងារស្ថិតិប្រជាជន ក្នុងភូមិ-សង្កាត់ទាំង១២ក្នុងក្រុងសៀមរាប នៅសាលប្រជុំរដ្ឋបាលក្រុងសៀមរាប
- ការិយាល័យផែនការស្ថិតិក្រុងសៀមរាម បានចូលរួមប្រជុំនៅមន្ទីផែនការខេត្តសៀមរាប
- បានចូលរួមវគ្គបណ្តុះបណ្តាល ស្តីពីសេចក្តីណែនាំបច្ចេកទេស កសាងផែនការអភិវឌ្ឍន៏ឃុំ សង្កាត់ និងកម្មវិធីវិនិយោគបីឆ្នាំរំកិលឃុំ សង្កាត់ ក្រុង ស្រុក នៅមន្ទីរផែនការខេត្តសៀមរាប
- បានទៅមន្ទីរផែនការខេត្តសៀមរាប ដើម្បីយកទិន្នន័យគ្រួសារក្រីក្រប្រចាំឆ្នាំ
- ការិយាល័យផែនការស្ថិតិក្រុងសៀមរាប បានបញ្ជូនទិន្នន័យគ្រួសារក្រីក្រប្រចាំឆ្នាំ
- ប្រជុំស្តីពីកម្មវិធីការកសាងផែនការរយៈពេល៥ឆ្នាំ និងកម្មវិធីវិនិយោគ៣ឆ្នាំរំកិល ក្រុង-ស្រុក។
- ការិយាល័យផែនការក្រុង បានទទួលសៀវភៅទិន្នន័យភូមិសង្កាត់បានគ្រប់ចំនួនទាំង១២សង្កាត់ និងបានបញ្ជូនទៅមន្ទីរផែនការខេត្តសៀមរាបរួចរាល់

## ៣.២.៦.ការិយាល័យកិច្ចការនារី

- រៀបចំកិច្ចប្រជុំគណៈកម្មាធិការពិគ្រោះយោបល់កិច្ចការស្ត្រី និងកុមារ ចំនួន៦០លើក។
- ចូលរួមវគ្គបណ្តុះបណ្តាលស្តីពី នីតិវិធីគោលនយោបាយ ស្តីពីការថែទាំជំនួសចំពោះកុមារ ការប្រើប្រាស់គំរូបទដ្ឋាន និងការគ្រប់គ្រងករណី នៅសាលាខេត្តសៀមរាបចំនួន៥លើក។
- ចូលរួមប្រារព្ធពិធី ទិវាសិទ្ធិនារីអន្តរជាតិ៨មីនា ប្រចាំឆ្នាំ តាមបណ្តាសង្កាត់បានចំនួន១៥លើក។

- ចូលរួមកិច្ចប្រជុំប្រចាំខែរបស់គណៈកម្មាធិការទទួលបន្ទុកកិច្ចការនារី និងកុមារសង្កាត់ ចំនួន២៦លើក អ្នកចូលរួមសរុបចំនួន៤៤៣នាក់ ស្រី៣១៦នាក់។
- ចូលរួមសម្ពោធអាគារ និងគម្រោងស្តីពី ការចូលរួមលើកកម្ពស់ស្ត្រី និងក្មេងស្រីក្នុងវិស័យវប្បធម៌ សិល្បៈ និងបណ្តុះបណ្តាលវិជ្ជាជីវៈរបស់អង្គការរចនាស្ត្រី មានអ្នកចូលរួមសរុបចំនួន៣៣២នាក់ ក្នុងនោះសិស្សចំនួន២៥០នាក់។
- ចូលរួមវគ្គបណ្តុះបណ្តាលគ្រូបង្គោល ស្តីពីការលើកកម្ពស់សមធម៌សង្គម និងបិរយាបន្ននៅថ្នាក់ក្រោមជាតិ នៅមន្ទីរកិច្ចការនារីខេត្ត។
- ប្រជុំផ្សព្វផ្សាយ ស្តីពីនិតិវិធីសម្រុះសម្រួលវិវាទក្រៅប្រព័ន្ធតុលាការរបស់មណ្ឌលសេវាកម្មយុត្តិធម៌ក្រុង។
- បានសហការណ៍ជាមួយ គ.ក.ន.ក និងប៉ុស្តិ៍សង្កាត់ ចុះផ្សព្វផ្សាយ ស្តីពីច្បាប់ទប់ស្កាត់អំពើហឹង្សាក្នុងគ្រួសារ និងកិច្ចការពារជនរងគ្រោះ មានអ្នកចូលរួមចំនួន ១១០នាក់ ស្រី៦៣នាក់។
- បានចូលរួមប្រជុំដោះស្រាយវិវាទក្រៅប្រព័ន្ធតុលាការទាក់ទងនឹងការលែងលះ នៅសាលាសង្កាត់សៀមរាប មានសមាសភាពចូលរួមចំនួន០៨រូប ស្រី០៤រូប។
- បានរៀបចំកិច្ចប្រជុំដោះស្រាយវិវាទក្រៅប្រព័ន្ធតុលាការទាក់ទងនឹងការលែងលះ នៅសាលាក្រុងសៀមរាប មានសមាសភាពចូលរួមចំនួន០៨រូប ស្រី០៣រូប។
- ចូលរួមវគ្គបណ្តុះបណ្តាល ស្តីពីការរៀបចំផែនការស្ថិតិ ការត្រួតពិនិត្យ និងវាយតម្លៃឆ្លើយតបនឹងយេនឌ័រ នៅមន្ទីរកិច្ចការនារីខេត្ត។

### ៣.២.៧.ការិយាល័យព័ត៌មាន

**១. ការផ្សព្វផ្សាយសកម្មភាពក្រុមប្រឹក្សា**

- ផ្សព្វផ្សាយសេចក្តីជូនដំណឹង និងលទ្ធផលនៃកិច្ចប្រជុំសាមញ្ញបានចំនួន ១១៥លើក។
- ផ្សព្វផ្សាយពីកិច្ចប្រជុំសាមញ្ញ និងវិសាមញ្ញរបស់ក្រុមប្រឹក្សាក្រុងបាន ៧២លើក។
- ផ្សព្វផ្សាយវេទិកាពិគ្រោះយោបល់របស់ក្រុមប្រឹក្សាបានចំនួន ០៥លើក។

**២. ការផ្សព្វផ្សាយសកម្មភាពគណៈកម្មាធិការពិគ្រោះយោបល់កិច្ចការស្ត្រីនិងកុមារ**

- ផ្សព្វផ្សាយលទ្ធផលនៃកិច្ចប្រជុំសាមញ្ញ របស់ គ.ក.ស.ក បាន ៦០លើក។

**៣. ការផ្សព្វផ្សាយសកម្មភាពអភិវឌ្ឍន៍ក្រុង**

- ផ្សព្វផ្សាយសកម្មភាពអភិវឌ្ឍន៍ និងសេចក្តីជូនដំណឹងផ្សេងៗរបស់គណៈអភិបាលក្រុងបាន ៣៨២លើក។
- ផ្សព្វផ្សាយវេទិកាសាធារណៈរបស់ក្រុមការងារថ្នាក់ជាតិចុះមូលដ្ឋានក្រុងសៀមរាបចំនួន ០៣លើក។
- ផ្សព្វផ្សាយវេទិកាក្រុមការងារថ្នាក់ជាតិស្តីពីភូមិ ឃុំ មានសុវត្ថិភាពបានចំនួន ០៥លើក។

សកម្មភាពទាំងអស់ខាងលើនេះធ្វើការផ្សព្វផ្សាយតាមរយៈទូរទស្សន៍ខ្សែកាបអង្គរ និងវិទ្យុ FM ជាតិនគរភ្នំ។

### ៣.២.៨.ការិយាល័យសុខាភិបាល

**១.លើកកម្ពស់សុខុមាលភាព មាតា កុមារ និង ទារក**

| | |
|---|---|
| - ស្ត្រីមានផ្ទៃពោះបានមកពិនិត្យផ្ទៃពោះលើកទី១មានចំនួន | ៤០ ៥៦៥នាក់ |
| - ស្ត្រីមានផ្ទៃពោះបានមកពិនិត្យផ្ទៃពោះលើកទី២មានចំនួន | ៤១ ៧១០នាក់ |
| - ស្ត្រីក្នុងវ័យបន្តពូជបានមកទទួលមធ្យោបាយពន្យារកំណើតករណីថ្មីមានចំនួន | ២៤ ២២៤នាក់ |
| - ស្ត្រីមកសម្រាលកូននៅមណ្ឌលសុខភាពមានចំនួន | ៣ ៧៥៧នាក់ |
| - កុមារអាយុក្រោម១ឆ្នាំមកទទួលថ្នាំបង្ការជំងឺ១២មុខមានចំនួន | ៤៨ ១៦០នាក់ |

២.ការអប់រំផ្សព្វផ្សាយអំពីវិធីទប់ស្កាត់ និងបង្ការជំងឺឆ្លង-ជំងឺមិនឆ្លង៖
- នៅតាមមណ្ឌលសុខភាពចំនួន ១១ កន្លែង បានចំនួន ៦៧២ លើក
៣.ជំរុញការផ្តល់សេវាសុខាភិបាលនៅតាមមណ្ឌលសុខភាព៖
- ពិគ្រោះជំងឺក្រៅករណីថ្មីបាន ៥៦១ ៤៣៩ នាក់
- ពិគ្រោះជំងឺក្រៅករណីសរុបបាន ៥៧០ ៧៥៥ នាក់
៤.ការគ្រប់គ្រងស្ថិតិមន្ទីរពេទ្យរដ្ឋ ឯកជន ឱសថស្ថាន និង បុគ្គលិកសុខាភិបាលក្រុង
- មន្ទីរពហុព្យាបាលមាន ០៤ កន្លែង
- មន្ទីរសម្រាកព្យាបាលមាន ១៣ កន្លែង
- បន្ទប់ពិគ្រោះជំងឺមាន ៧៩ កន្លែង
- បន្ទប់ពិគ្រោះស្ត្រីមានផ្ទៃពោះមាន ១៥ កន្លែង
- បន្ទប់ថែទាំជំងឺមាន ៤៤ កន្លែង
- មន្ទីរសម្រាកព្យាបាលជំងឺមាត់-ធ្មេញមាន ០៤ កន្លែង
- បន្ទប់ពិគ្រោះព្យាបាលជំងឺមាត់-ធ្មេញមាន ៣៤ កន្លែង
- ឱសថស្ថាន-ឱសថស្ថានរងមាន ១៨៦ កន្លែង
- មន្ទីរពិសោធន៍វេជ្ជសាស្ត្រ ០៦ កន្លែង

## ៣.២.៩-ការិយាល័យអភិវឌ្ឍន៍ជនបទ ( មិនផ្តល់របាយការណ៍ )

## ៣.២.១០-ការងារកាកបាទក្រហម

ក-ការកសាងសមាជិកទ្រទ្រង់កាកបាទក្រហម និងការប្រមូលថវិកាទ្រទ្រង់
- បានកសាង និងប្រមូលថវិកាសមាជិកទ្រទ្រង់កាកបាទក្រហមកម្ពុជា សមាជិកចំនួន ៨ ៨០៥នាក់ ថវិកាបានចំនួន ៣៨ ៥៩៧ ០០០រៀល។

ខ-ការប្រមូលថវិកាហិបសប្បុរស តាមបណ្តាវត្តក្នុងក្រុង
- បានប្រមូលថវិកាសប្បុរសជនតាមវត្តនានាក្នុងក្រុង បានថវិកាសរុបចំនួន ២៣ ២៥៩ ៨០០ រៀល។
- បានទទួលអំណោយទេយ្យទានពីព្រះសង្ឃវត្តស្វាយរមេត វត្តព្រះឥន្ទកោសីយ៍ និងវត្តព្រៃធំ មានអង្ករចំនួន ២១៥០គ.ក្រ មី ១៥០កេស ត្រីខ ៦៧យួរ ទឹកស៊ីអ៊ីវ៤២យួរ ទឹកត្រី ២៤យួរ ទឹកសុទ្ធ ១១០កេស និងសម្ភារ។
- បានទទួលអង្ករ ២៣៥០គ.ក្រ ទឹកស៊ីអ៊ីវ ២០០ដប ទឹកត្រី ២០០ដប ពីសាលាក្រុងសៀមរាប។

គ-ការផ្តល់អំណោយសង្គ្រោះដល់ជនរងគ្រោះដោយសារគ្រោះមហន្តរាយផ្សេងៗ
បានផ្តល់អំណោយដល់គ្រួសារក្រីក្រ និងគ្រួសាររងគ្រោះផ្សេងៗ ជាថវិកា ស្បៀងអាហារ សម្ភារផ្សេងៗរួមមាន៖
- គ្រួសាររងគ្រោះដោយសារអគ្គីភ័យចំនួន ៩៣គ្រួសារ។
- គ្រួសាររងគ្រោះដោយសារខ្យល់ព្យុះ ខ្យល់កន្ត្រាក់ ៦៧០៣គ្រួសារ។
- លង់ទឹកស្លាប់ ១០នាក់
- រន្ទះបាញ់ ១២នាក់ ក្នុងនោះស្លាប់ ៤នាក់។
- ស្លាប់ដោយសារគ្រោះថ្នាក់ចរាចរណ៍ ១នាក់
- ក្មេងកំព្រា ២នាក់ ពិការជើង ៣នាក់
- គ្រួសារផ្ទុកមេរោគអេដស៍ ១៥គ្រួសារ។
- ចាស់ជរា គ្រួសារក្រីក្រ ១៥១គ្រួសារ។

ឃ-ការអប់រំផ្សព្វផ្សាយ

- អ្នកស្ម័គ្រចិត្តតាមបណ្តាសង្កាត់បានចុះអប់រំតាមសហគមន៍ឲ្យប្រុងប្រយ័ត្ន ពេលមានគ្រោះទឹកជំនន់ត្រូវហូបស្អាត ហើយត្រូវហូបទឹកដែលដាំពុះការពារជំងឺរាករូស និងត្រូវប្រយ័ត្នកូនចៅតូចៗកុំឲ្យលេងទឹកការពារលង់ទឹក។

**៣.៣.ការគ្រប់គ្រងដីធ្លី ធនធានធម្មជាតិ បរិស្ថាន ការប្រែប្រួលអាកាសធាតុ និងគ្រោះមហន្តរាយ**

**៣.៣.១-ការងាររៀបចំដែនដីនគរូបនីយកម្ម សំណង់និងភូមិបាល**

**២.៣.១-ការិយាល័យរៀបចំដែនដីនគរូបនីយកម្ម សំណង់ និង ភូមិបាលក្រុង**

**១.ស្ថានភាពមន្ត្រីរាជការរបស់ការិយាល័យ**

មន្ត្រីការិយាល័យរៀបចំដែនដី នគរូបនីយកម្ម សំណង់ និងភូមិបាលក្រុង សរុបទាំងអស់ចំនួន ១៦នាក់ ស្រី០៤នាក់ រួមមាន ប្រធានការិយាល័យ ០១រូប អនុប្រធានការិយាល័យ ០៤រូប ។

**២. ការងារភូមិបាល**

| | |
|---|---|
| - ទម្រង់បែបបទនៃការប្រមូលទិន្នន័យក្បាលដីដាច់ដោយដុំបាន | ២៦៤ ច្បាប់ |
| - ទម្រង់បែបបទនៃការប្រមូលទិន្នន័យក្បាលដីបំពេញបន្ថែមបាន | ៦២៩ ច្បាប់ |
| - បានចុះហត្ថលេខាលើបណ្ណសម្គាល់សិទ្ធិកាន់កាប់អចលនវត្ថុបាន | ៩៨ ច្បាប់ |
| - លិខិតលក់ផ្តាច់បាន | ១០ ០០៦ ច្បាប់ |
| - អំណោយផ្តាច់ | ៩៧៧ ច្បាប់ |
| - ចុះសម្រង់សៀវភៅគោលបញ្ជីដីធ្លី | ២ ៣៨៧ ច្បាប់ |
| - ចុះសម្រង់សៀវភៅអចលនវត្ថុ | ៩១៨ ច្បាប់ |

**៣. ការងារសំណង់ (PV)**

| | |
|---|---|
| - ការងារសំណង់( P.V) សរុប | ២៨០ ច្បាប់ |

**៤. ការងារនៅការិយាល័យច្រកចេញចូលតែមួយៈ**

| | |
|---|---|
| - សាងសង់លំនៅដ្ឋានចេញដោយការិយាល័យច្រកចេញចូលតែមួយ | ៨៧៨ ច្បាប់ |

**៣.៣.២-ការងារបរិស្ថាន**

- ចូលរួមកិច្ចប្រជុំស្តីពីគម្រោងអភិវឌ្ឍទីក្រុងបៃតងកម្ពុជាជំណាក់កាលទី២ ចំនួន ០៤លើក ។
- ចូលរួមទិវាបរិស្ថានជាតិ និងបរិស្ថានពិភពលោក ៥ មិថុនា នៅសាលាបឋមសិក្សាភូមិថ្មល់ ។
- សហការជាមួយមន្ទីរបរិស្ថានខេត្តជាប្រចាំ ចុះតាមដាន និងត្រួតពិនិត្យការអនុវត្តកញ្ចប់ថវិកាសេវាអនាម័យបរិស្ថានសម្រាប់ការគ្រប់គ្រងសំណល់រឹង-រាវក្នុងក្រុងសៀមរាប របស់ក្រុមហ៊ុន ចាន់ ម៉េងសុវណ្ណ ឧនស្ត្រាក់សិន ។
- ចូលរួមសិក្ខាសាលាបណ្តុះបណ្តាលស្តីពីការគ្រប់គ្រងសំណល់រឹង រាវ និងពិធីប្រគល់កូនឈើ ដាំកូនឈើ ក្នុងបរិវេណវិទ្យាល័យ ហ៊ុន សែន វត្តស្វាយ រៀបចំដោយ សាលាក្រុង និងមន្ទីរបរិស្ថានខេត្ត។
- ចូលរួមយុទ្ធនាការ "កម្ពុជាស្អាត" នៅមជ្ឈមណ្ឌលសហប្រតិបត្តិការកម្ពុជា-ជប៉ុន រាជធានីភ្នំពេញ ។
- សហការជាមួយសាលាខេត្ត និងអ្នកជំនាញសិក្សាគម្រោងនៃប្រទេសចិន ដែលវិនិយោគគម្រោងកែលម្អស្ទឹងសៀមរាប ពីស្ពានអង្គរ ដល់ចុងស្រុក ភូមិអារញ្ញ សង្កាត់សៀមរាប ។
- ចូលរួមសិក្ខាសាលាពិគ្រោះយោបល់ស្តីពីបច្ចុប្បន្នភាព "ស្តង់ដារទីក្រុងស្អាត" នៅសណ្ឋាគារភ្នំពេញ រាជធានីភ្នំពេញ រៀបចំដោយគណៈកម្មាធិការជាតិវាយតម្លៃទីក្រុងស្អាត ។
- ចូលរួមកិច្ចប្រជុំដើម្បីសិក្សាអំពីលទ្ធផលនៃការអនុវត្តការគ្រប់គ្រងសំរាម សំណល់រឹងទីប្រជុំជន និងបញ្ហាប្រឈមនានា នៅរដ្ឋបាលក្រុង ដឹកនាំដោយតំណាងក្រសួងមហាផ្ទៃ និង គ.ជ.អ.ប ។

- ចូលរួមវគ្គបណ្តុះបណ្តាលភាពជាអ្នកដឹកនាំកម្មវិធីត្រួតពិនិត្យថ្នាំជក់ នៅខេត្តកំពង់ឆ្នាំង ។
- ចូលរួមក្នុងកិច្ចប្រជុំផ្ទៀងផ្ទាត់ និងវាយតម្លៃ "ការប្រឡងប្រណាំងទីក្រុងស្អាតលើកទី២" និង វាយតម្លៃ "ចលនាប្រឡងប្រណាំងទីក្រុងទេសចរណ៍ស្អាតអាស៊ាន" របស់បេក្ខភាពក្រុងសៀមរាប។

## ៣.៣.៣.ការប្រែប្រួលអាកាសធាតុនិងគ្រោះមហន្តរាយ

## ៣.៤.រដ្ឋបាល និងសន្តិសុខសណ្តាប់ធ្នាប់សាធារណៈ

### ១.សភាពការណ៍សន្តិសុខសណ្តាប់សង្គម

ក.បទល្មើសឧក្រិដ្ឋះកើតឡើងចំនួន ៥៨លើក បង្ក្រាបបាន ៥៨លើក ឃាត់ខ្លួន ៥៨នាក់

ខ.បទល្មើសមជ្ឈឹមះកើតឡើងចំនួន ២៤៥លើក បង្ក្រាបបាន ២៤៥លើក ឃាត់ខ្លួន ២៤៥នាក់

គ-បទល្មើសគ្រឿងញៀនះ កើតឡើងចំនួន ៣៥៤លើក ឃាត់ខ្លួន ៥៧៤នាក់ ស្រី២០៥នាក់ ក្នុងនោះប្រើប្រាស់គ្រឿងញៀនចំនួន ៣០៩នាក់ ស្រី១៦៧នាក់ ដោយបានបញ្ជូនទៅតុលាការ បញ្ជូនទៅអប់រំនៅមណ្ឌលចំនួន ១៣៧នាក់ ស្រី២៨នាក់ និងអប់រំធ្វើកិច្ចសន្យាចំនួន៥៣នាក់ ស្រី១៣នាក់។

### ២.ការងារសណ្តាប់ធ្នាប់សាធារណៈ

- កម្លាំងសណ្តាប់ធ្នាប់ក្រុងបានសហការជាមួយប៉ុស្តិ៍ទាំង៤ ក្នុងក្រុងចុះរៀបចំសណ្តាប់ធ្នាប់តាមដងផ្លូវជាប្រចាំ។
- ធ្វើការណែនាំអ្នកលក់ដូរគ្មានសណ្តាប់ធ្នាប់បាន ៣៣១១កន្លែង អ្នករត់ឡានឈ្នួលបាន ១៩៧១គ្រឿង អ្នករត់រ៉ឺម៉កម៉ូតូបាន ១៨១៦គ្រឿង ដើម្បីឲ្យពួកគាត់ចូលចំណតជៀសវាងបង្កភាពអនាធិបតេយ្យតាមដងផ្លូវ។
- សហការជាមួយសន្តិសុខផ្សារលើចុះរៀបចំអ្នកលក់ដូរនៅជុំវិញផ្សារឲ្យមានសណ្តាប់ធ្នាប់និងអនាម័យល្អ។
- ចុះបាញ់លេខសម្គាល់តាមរទេះរុញចល័ត និងស្រង់បញ្ជីបានចំនួន ៤៩រទេះ ដោយបានធ្វើកិច្ចសន្យា។
- ចុះត្រួតពិនិត្យផ្ទះសំណាក់បានចំនួន ៣៣២១ផ្ទះ មានចំនួន ៩៦៨១បន្ទប់ ស្មើនឹង៨៩១៩គ្រួសារ មនុស្ស ២៩៦៨៨នាក់ ស្រី១៨៤០៧នាក់ អាយុ១៨ឆ្នាំឡើង ១៥០៦១នាក់ ស្រី៦៩៣៧នាក់។
- ចុះចែកបទបញ្ជារបស់រដ្ឋបាលក្រុងដល់អាជីវករ ស្តីពីការមិនឲ្យនាំចូល លក់ ទិញ រំសេវផាវ គ្រឿងផ្ទុះ ផ្សេងៗ ក្នុងពិធីចូលឆ្នាំចិន បានចំនួន ៦៨១សន្លឹក។

### ៣.គ្រោះថ្នាក់ផ្សេងៗ

- អគ្គីភ័យ១៩លើក ឆក់ខ្សែភ្លើង៨ករណី រន្ទះបាញ់១២ករណី ខ្យល់កន្ត្រាក់១៥ករណី អត្តឃាត ២៨ករណី ដេកស្លាប់ ២៤ករណី លង់ទឹកស្លាប់៩ករណី។

### ៤.ការងារអត្តសញ្ញាណប័ណ្ណ

- ផែនការមានចំនួន ១៩៩៧៨៩នាក់ ស្រី ១០២១៦៨នាក់ បានផ្តល់ឲ្យមានចំនួន ១៤១៦៤១នាក់ ស្រី ៧២៦៤០នាក់ នៅសល់ចំនួន ៥៨១៤៨នាក់ ស្រី ២៩៤២៨នាក់ (ក្នុងនោះមាន ព្រះសង្ឃ ចំណាកស្រុក ចាស់ជរា វិកលចរឹក ជាប់ពន្ធធនាគារ) ត្រូវផ្តល់បន្តចំនួន ៥៤០៨១នាក់ ស្រី ២៧៦២៨នាក់។

### ៥.លទ្ធផលបទល្មើសនេសាទ

- ចុះបង្ក្រាប និងដកហូតសម្ភារនេសាទខុសច្បាប់ ក្នុងតំបន់ភូមិសាស្ត្រសង្កាត់ចុងឃ្នៀស ដកហូតបាន កាណូតឈើចំនួន២៤គ្រឿង កាណូតស្នាច់ចំនួន០២គ្រឿង ទូកស្នាច់ចំនួន ០២គ្រឿង ទូកឈើសម្រាប់ដាក់មង អួន ចំនួន ០៨គ្រឿង សាច់អួន ចំនួន៩២វង់ ប្រវែង ៥៥០០០ម៉ែត្រ សាច់ម៉ាញ់ខុសច្បាប់ចំនួន១១វង់ ប្រវែង៩០០០ម៉ែត្រ មងបណ្តែតខុសច្បាប់ចំនួន១១វង់ ប្រវែង១៥០០ម៉ែត្រ ឃាត់ជនសង្ស័យជាជនជាតិវៀតណាមចំនួន០២នាក់ បញ្ជូនទៅទីបញ្ជាការដ្ឋានកងរាជអាវុធហត្ថខេត្ត។

- នគរបាលរដ្ឋបាលសង្កាត់ជ្រាវ ចុះបង្ក្រាបបទល្មើសនេសាទ នៅចំណុច ខាងលិចបឹងពារាំង រឹបអូសស្បៃមុង ចំនួន១០កន្លែង ប្រវែង១០០០ម៉ែត្រ បរចំនួន២កន្លែង ប្រវែង២០០ម៉ែត្រ បង្គោលចំរឹងចំនួន៣០០ដើម លែងត្រី ចំនួន២០គ.ក្រ។

**៦.ចលនាមហាជន**

- បានបំផុសចលនាប្រជាពលរដ្ឋទាំង ១២សង្កាត់ ចំនួន៩៩ភូមិ ឲ្យប្រជាពលរដ្ឋចូលរួម ការពារសន្តិសុខសុវត្ថិភាពល្អនៅ តាមមូលដ្ឋាន និងបានបង្កើតប៉ុស្តិ៍យាមតាមចំណុចគោលដៅសំខាន់ៗ។
- ប៉ុស្តិ៍ប្រជាការពារមាន១១១គោលដៅ ស្មើនឹង ៣៧១ក្រុម មនុស្សសរុប ២៥៤៦នាក់ លើ ៩៩ភូមិ ស្មើនឹង ១២សង្កាត់ ដាក់កម្លាំងចូលរួមសហការជាមួយប្រជាពលរដ្ឋជាប្រចាំ។
- ផ្សព្វផ្សាយគោលនយោបាយភូមិ ឃុំ មានសុវត្ថិភាព ដល់សហគមន៍ទាំង១២សង្កាត់បានចំនួន ២៣៦លើក អ្នកចូលរួមសរុប ១០៣៣៤នាក់ ស្រី៥៥៤៤នាក់។
- បើកវេទិកាសាធារណបានចំនួន ៦លើក អ្នកចូលរួមសរុប១៧០៣នាក់ ស្រី៩០០នាក់។

**៧-ការងារចរាចរ**

- ល្មើសអត់ពាក់មួកចំនួន ៩៧៥៩នាក់
- ល្មើសអត់កញ្ចក់ចំនួន ៥៦៨នាក់
- ល្មើសមិនគោរពស្លាកសញ្ញាចំនួន ១៦៧៨នាក់
- ចែកសៀវភៅច្បាប់ចរាចរណ៍ផ្លូវគោកចំនួន ៥០ក្បាល និងខិតប័ណ្ណសញ្ញាចរាច ចំនួន៧០ សន្លឹក

# ផ្នែកទី៣
# ការងាររដ្ឋបាលសង្កាត់

## ៣.១.ស្ថិតិក្រុមប្រឹក្សា សង្កាត់ និងបុគ្គលិក

| ល.រ | ការបរិយាយ | សរុប | ស្រី |
|---|---|---|---|
| ១ | សមាជិកក្រុមប្រឹក្សាសង្កាត់ | ៩៤ | ២១ |
| ២ | សមាជិកក្រុមប្រឹក្សាសង្កាត់ដែលបានផ្លាស់ប្តូរ | ៥៩ | ២០ |
| ៣ | ចៅសង្កាត់ | ១២ | ០ |
| ៤ | ជំទប់ទី១ ចៅសង្កាត់រងទី១ | ១២ | ០២ |

| | | | |
|---|---|---|---|
| ៥ | ជំទប់ទី២ ចៅសង្កាត់រងទី២ | ១២ | ០ |
| ៦ | ស្មៀនសង្កាត់ | ១២ | ០៤ |
| ៧ | បុគ្គលិកកិច្ចសន្យា | ៥៤ | ២១ |
| ៨ | មេភូមិ | ៩៩ | ០៧ |
| ៩ | អនុប្រធានភូមិ | ៩៩ | ០៩ |
| ១០ | សមាជិកភូមិ | ៩៩ | ៨៥ |
| ១១ | អ្នកទទួលបន្ទុកកិច្ចការនារីនិងកុមារដែលមិនមែនជាសមាជិកក្រុមប្រឹក្សាសង្កាត់ | ៦ | ៦ |
| ១២ | ជនបង្គោលតាមដានត្រួតពិនិត្យ និងវាយតម្លៃឃុំ សង្កាត់ | ១២ | ០៥ |

### ៣.២.ដីកា សេចក្តីសម្រេច និងលិខិត

| ល.រ | ការបរិយាយ | ចំនួន | | | | | |
|---|---|---|---|---|---|---|---|
| | | ២០១៤ | ២០១៥ | ២០១៦ | ២០១៧ | ២០១៨ | សរុប |
| ១ | ដីកាដែលបានដាក់ចេញ | ៥ | ៤ | ៣៥ | ០៤ | ១ | ៤៩ |
| ២ | សេចក្តីសម្រេចដែលបានដាក់ចេញ | ១៤៦ | ១៤០ | ១៤២ | ១០៨ | ៥២ | ៥៨៨ |
| ៣ | លិខិតរដ្ឋបាលដែលបានដាក់ចេញ | ១៨៧០៨ | ២០៥៩២ | ២៨៩២៦ | ១៤៨៥ | ៩១០១ | ៧៨៨១២ |
| ៤ | លិខិតដែលបានទទួល | ១៥១៥ | ១២៩៩ | ១៦៨៨ | ៨៥៩ | ៥៧៧ | ៥៩៣៨ |

### ៣.៣. កិច្ចប្រជុំក្រុមប្រឹក្សាឃុំសង្កាត់ និង គ.ក.ន.ក

| ល.រ | ការបរិយាយ | ចំនួន | | | | | |
|---|---|---|---|---|---|---|---|
| | | ២០១៤ | ២០១៥ | ២០១៦ | ២០១៧ | ២០១៨ | សរុប |
| ១ | កិច្ចប្រជុំសាមញ្ញរបស់ក្រុមប្រឹក្សា | ១៥៦ | ១៥៦ | ១៤៤ | ១៤៤ | ១៣៣ | ៧៣៣ |
| ២ | កិច្ចប្រជុំវិសាមញ្ញរបស់ក្រុមប្រឹក្សា | ១៤២ | ៨១ | ៨៤ | ៣៨ | ៥ | ៣៥០ |
| ៣ | កិច្ចប្រជុំសម្ងាត់របស់ក្រុមប្រឹក្សា | ១១ | ០ | ០ | ០ | ០ | ១១ |
| ៤ | កិច្ចប្រជុំ គ.ក.ន.ក | ១៦៥ | ១៥៦ | ១៣៩ | ១៤០ | ១៣៥ | ៧៣៥ |

### ៣.៤.ការអនុវត្តថវិកាឃុំ សង្កាត់

| ឆ្នាំ | ចំណូល (គិតលានរៀល) | | | ចំណាយ (គិតលានរៀល) | | |
|---|---|---|---|---|---|---|
| | អនុម័ត | ជាក់ស្តែង | % | អនុម័ត | ជាក់ស្តែង | % |
| ២០១៤ | ២ ១៦៣ | ២ ១៨៦ | ១០១ | ២ ១៦៣ | ១៤៩១ | ៦៩ |
| ២០១៥ | ៣ ៨១៥ | ៣ ៨១៥ | ១០០ | ៣ ៨១៥ | ១១០៣ | ២៩ |
| ២០១៦ | ៣ ៦០៩ | ១ ៣៤៦ | ៣៧.៣០ | ៣ ៦០៩ | ១ ២៩៧ | ៣៥.៩៣ |
| ២០១៧ | ៣ ៣០០ | ៣ ៣០០ | ១០០ | ៣ ៣០០ | ៣ ០៨៧ | ៩៣.៥៥ |
| ២០១៨ | ៣ ១០០ | ២ ៣០០ | ៧៤.១៩ | ៣ ១០០ | ៣ ០៣៧ | ៩៧.៩៦ |

| សរុប | ១៥ ៩៨៧ | ១២ ៩៤៧ | ៨០.៩៨ | ១៥ ៩៨៧ | ១០ ០១៥ | ៦២.៦៤ |
|---|---|---|---|---|---|---|

## ៣.៥. ការគ្រប់គ្រងទ្រព្យសម្បត្តិ

| ល.រ | ការបរិយាយ | ចំនួន | | | | | |
|---|---|---|---|---|---|---|---|
| | | ២០១៤ | ២០១៥ | ២០១៦ | ២០១៧ | ២០១៨ | សរុប |
| ១ | ទ្រព្យសម្បត្តិដែលបានទិញ ឬទទួល (ថ្មី) | ២០៥ | ១៨៨ | ១៧១ | ១៨៨ | ១៦៦ | ៩១៨ |
| ២ | ទ្រព្យសម្បត្តិដែលបានកាត់ចេញ | ១១ | ៦៩ | ១១ | ៦៩ | ៥៣ | ២១៣ |
| ៣ | ទ្រព្យសម្បត្តិសរុប | ៥៧០ | ១៨៨ | ៥៩៦ | ១៨៨ | ១៥៤ | ១ ៦៩៦ |

## ៣.៦.ការអភិវឌ្ឍសមត្ថភាព

| ល.រ | ការបរិយាយ | ចំនួន | | | | | |
|---|---|---|---|---|---|---|---|
| | | ២០១៤ | ២០១៥ | ២០១៦ | ២០១៧ | ២០១៨ | សរុប |
| ១ | វគ្គសិក្សា | ២០០ | ៣២ | ៣០៧ | ៣៦ | ៣៧ | ៦១២ |
| ២ | សិក្ខាកាមសរុបដែលបានចូលរួមវគ្គសិក្សា | ៧៨៤ | ១៦៦ | ៣៥៩ | ៥៦ | ៤៣ | ១ ៤០០ |
| ៣ | សិក្ខាកាមជាស្ត្រីដែលបានចូលរួមវគ្គសិក្សា | ៣២៥ | ៥៨ | ២២៣ | ១៧ | ១៤ | ៦៣៧ |

## ៣.៧.សកម្មភាពសេវាសង្គម

| ល.រ | ការបរិយាយ | ចំនួន | | | | | |
|---|---|---|---|---|---|---|---|
| | | ២០១៤ | ២០១៥ | ២០១៦ | ២០១៧ | ២០១៨ | សរុប |
| ១ | មត្តេយ្យសិក្សាសហគមន៍កំពុងដំណើរការដែលគាំទ្រពីឃុំ សង្កាត់ | ៤ | ២ | ៣ | ០ | ៥ | ១៤ |
| ២ | គ្រួសារងាយរងគ្រោះគាំទ្រពីឃុំ សង្កាត់សម្រាប់កែលម្អអនាម័យ(ការលាងដៃនឹងសាប៊ូ) | ០ | ០ | ០ | ០ | ០ | ០ |
| ៣ | គ្រួសារងាយរងគ្រោះគាំទ្រពីឃុំ សង្កាត់ដើម្បីទទួលបានទឹកស្អាតប្រើប្រាស់ | ២១ | ០ | ៤២៩ | ០ | ០ | ៤៥០ |
| ៤ | គ្រួសារងាយរងគ្រោះគាំទ្រពីឃុំ សង្កាត់ដើម្បីទទួលបានបង្គន់អនាម័យប្រើប្រាស់ | ០ | ០ | ០ | ០ | ០ | ០ |
| ៥ | គ្រួសារងាយរងគ្រោះដែលឃុំ សង្កាត់ចុះកំណត់អត្តសញ្ញាណ | ២០២៤ | ១៨៥៣ | ២៤៣២ | ៣០៩២ | ០ | ៩៤០១ |
| ៦ | ស្ត្រីរងគ្រោះដោយអំពើហិង្សាក្នុងគ្រួសារដែលទទួលការគាំទ្រពីឃុំ សង្កាត់ | ៤៤៧ | ០ | ០ | ០ | ០ | ៤៤៧ |

## ៣.៨. ការដោះស្រាយ និងការសម្រុះសម្រួលទំនាស់

| ល.រ | ការបរិយាយ | ចំនួន |
|---|---|---|

| | | ២០១៤ | ២០១៥ | ២០១៦ | ២០១៧ | ២០១៨ | សរុប |
|---|---|---|---|---|---|---|---|
| ១ | ករណីដែលបានដោះស្រាយឬសម្រុះសម្រួលរួច | ៣៧៦ | ២៣៤ | ២៩៧ | ១៩៣ | ៩៣ | ១១៩៣ |
| ២ | ករណីដែលបានបញ្ជូនទៅស្ថាប័នពាក់ព័ន្ធ | ២១ | ០ | ២០ | ១១ | ១១ | ៦៣ |

### ៣.៩. ការងារអត្រានុកូលដ្ឋាន

| ល.រ | ការបរិយាយ | ចំនួន | | | | | |
|---|---|---|---|---|---|---|---|
| | | ២០១៤ | ២០១៥ | ២០១៦ | ២០១៧ | ២០១៨ | សរុប |
| ១ | សំបុត្រកំណើត | ៣០៥២ | ២៧៤៩ | ៤២៤២ | ២១១៨ | ២០៨០ | ១៤២៤១ |
| ២ | សំបុត្របញ្ជាក់កំណើត | ៣៤៦៣ | ៤៨៤៧ | ៥៥២២ | ៣១០០ | ២៧១៩ | ១៩៦៥១ |
| ៣ | សេចក្តីចម្លងសំបុត្រកំណើត | ១៤៧៣ | ១៨៨១ | ៣២៦៤ | ១៧៦១ | ១៦១៥ | ៩៩៩៤ |
| ៤ | សេចក្តីចម្លងសំបុត្របញ្ជាក់កំណើត | ១៥៥៥ | ១៩៥២ | ៣២១៩ | ១៧៦២ | ១៥៣៣ | ១០០២១ |
| ៥ | សំបុត្រអាពាហ៍ពិពាហ៍ | ១៨៨៦ | ២២៥០ | ២២០៧ | ១១២២ | ១១៤២ | ៨៦០៧ |
| ៦ | សេចក្តីចម្លងសំបុត្រអាពាហ៍ពិពាហ៍ | ៩៨៦ | ២៧៩១ | ២៦៨១ | ១៣៨១ | ១២៧៥ | ៩១១៤ |
| ៧ | សំបុត្រមរណភាព | ៥៦៧ | ៤២៦ | ៦៤៣ | ៣៧៨ | ៣៧០ | ២៣៨៤ |
| ៨ | សេចក្តីចម្លងសំបុត្រមរណភាព | ៤៣១ | ៤៧៤ | ៩៨២ | ៥៦៧ | ៥៧០ | ៣០២៤ |

### ៣.១០.ការចុះឈ្មោះ និងការពិនិត្យបញ្ជីឈ្មោះអ្នកបោះឆ្នោត

| ល.រ | ការបរិយាយ | ចំនួន | | | | | |
|---|---|---|---|---|---|---|---|
| | | ២០១៤ | ២០១៥ | ២០១៦ | ២០១៧ | ២០១៨ | សរុប |
| ១ | ប្រជាពលរដ្ឋដែលបានចុះឈ្មោះថ្មី | ២ ៦៥៦ | ០ | ១២៧ ៥៤៩ | ១២៧ ៥៤៩ | ០ | ២៥៧ ៧៥៤ |
| ២ | ប្រជាពលរដ្ឋដែលត្រូវបានលុបឈ្មោះ | ៥៦៩ | ០ | ០ | ០ | ០ | ៥៦៩ |
| ៣ | ប្រជាពលរដ្ឋដែលមានឈ្មោះបោះឆ្នោត | ១៤០ ៨៣៣ | ០ | ០ | ០ | ០ | ១៤០ ៨៣៣ |

# ផ្នែកទី៤
# បញ្ហាប្រឈម និងមេរៀនបទពិសោធន៍

លទ្ធផលដែលក្រុងសៀមរាប សម្រេចបានលើគ្រប់វិស័យតាមរយៈរបាយការណ៍ប្រាំឆ្នាំនេះ អាស្រ័យ ដោយមានកិច្ចសហការយ៉ាងធំធេងពីអាជ្ញាធរ និងសមត្ថកិច្ចគ្រប់លំដាប់ថ្នាក់ ព្រមទាំងមានការចូលរួមយ៉ាងសស្រាក់សស្រាំពីប្រជាពលរដ្ឋ ក្រោមការចង្អុលណែនាំពីក្រុមប្រឹក្សាក្រុងសៀមរាប ស្របតាមគោលនយោបាយ របស់រាជរដ្ឋាភិបាល ធ្វើឲ្យក្រុងសៀមរាបរក្សាបានសណ្តាប់ធ្នាប់របៀបរៀបរយ និងសន្តិសុខ សុវត្ថិភាព ជូនភ្ញៀវ ទេសចរណ៍

ជាតិ-អន្តរជាតិ ដែលមកស្នាក់នៅកំសាន្ត ពិសេសបានបង្កលក្ខណៈងាយស្រួលជូនបងប្អូនប្រជា ពលរដ្ឋគ្រប់ស្រទាប់ជាន់ថ្នាក់ កសាងជីវភាពគ្រួសារមានការរីកចម្រើនជាលំដាប់។

លទ្ធផលសម្រេចបានក្នុងឆ្នាំកន្លងទៅនេះ បើប្រៀបធៀប នឹងផែនការឆ្នាំយើងសម្រេចបានប្រមាណ ៨៥%ផងដែរ នៅសល់១៥ភាគរយ ទៀតដែលមិនទាន់អនុវត្តបានដោយសារការអនុវត្តគម្រោងមួយចំនួនរបស់សង្កាត់ និងក្រុងនៅមានភាពយឺតយ៉ាវ។ ទោះបីជាការអនុវត្តផែនការឆ្នាំរបស់ក្រុង និងសង្កាត់ទទួលលទ្ធផលមិនបាន១០០% ប៉ុន្តែសមិទ្ធិផលមួយចំនួនធំដែលសម្រេចបានតាមរយៈការផ្តល់កញ្ចប់ថវិកាពីថ្នាក់ជាតិ និងការជួយឧបត្ថម្ភគាំទ្រពីដៃគូរអភិវឌ្ឍន៍នានាប្រកបដោយគណនេយ្យភាព និងតម្លាភាព បានចូលរួមចំណែកយ៉ាងសំខាន់ក្នុងការអនុវត្តគោលនយោបាយកាត់បន្ថយភាពក្រីក្ររបស់ប្រជាពលរដ្ឋនៅមូលដ្ឋាន។ ទន្ទឹមនោះ យើងសង្កេតឃើញថាមានបញ្ហាប្រឈមមួយចំនួនដូចខាងក្រោម៖

- ការរៀបចំនីតិវិធីនៃការអនុវត្តគម្រោងមូលនិធិសង្កាត់ មានភាពស្មុគស្មាញ
- បញ្ហាសណ្តាប់ធ្នាប់ បរិស្ថាននៅតាមដងផ្លូវ និងទីប្រជុំជន ទីផ្សារសំខាន់ៗមិនទាន់រៀបរយល្អ និងគ្មានទីតាំងសម្រាប់ចតយានយន្តបានសមរម្យ
- ប្រជាពលរដ្ឋមួយចំនួនមិនទាន់តួចស្ថិតលើដីសាធារណៈរបស់រដ្ឋ (ដងស្ទឹង ចំណីផ្លូវ និងប្រឡាយផ្សេងៗ)និងនៅតែមានសំណង់គ្មានច្បាប់អនុញ្ញាត
- នៅតែមានបទល្មើស លួច ឆក់ ប្លន់ គ្រោះថ្នាក់ចរាចរណ៍ និងបទល្មើសផ្សេងៗ
- នៅតែមានអំពើហឹង្សាក្នុងគ្រួសារ និងលេងល្បែងស៊ីសង
- នៅតែមានបទល្មើសនេសាទខុសច្បាប់ និងបទល្មើសព្រៃឈើ ព្រៃលិចទឹក។
- ប្រជាពលរដ្ឋមិនទាន់មានប័ណ្ណកម្មសិទ្ធដីធ្លីប្រើប្រាស់គ្រប់គ្រួសារ
- ការដឹកជញ្ជូនលើសទម្ងន់មិនទាន់ទប់ស្កាត់បានទាំងស្រុងធ្វើឱ្យផ្លូវខូចខាតជាបន្តបន្ទាប់

## សេចក្តីសន្និដ្ឋាន

ក្រុងសៀមរាប ជាក្រុងមួយដែលមានសក្តានុពលសេដ្ឋកិច្ច ដោយផ្អែកទៅលើធនធានធម្មជាតិ និងហេដ្ឋារចនាសម្ព័ន្ធរូបវន្តផ្សេងៗជាអាទិ៍ ផ្លូវជាតិ ផ្លូវលំជនបទ **និង**បឹងទន្លេសាប។ វិស័យមួយចំនួនត្រូវបានចាត់ចូលជាអាទិភាពចម្បង ដើម្បីរួមចំណែកសម្រេចទិសដៅបន្ទាន់របស់រាជរដ្ឋាភិបាល ដែលក្នុងនោះមាន៖ សន្តិសុខ សុវត្ថិភាពមូលដ្ឋាន កសិកម្ម អភិវឌ្ឍន៍ជនបទ អប់រំ សុខាភិបាល អនាម័យ បរិស្ថាន និងហេដ្ឋារចនាសម្ព័ន្ធមូលដ្ឋាន។

ផ្តើមចេញពីសក្តានុពលដូចបានរៀបរាប់សង្ខេបខាងលើនេះ គួបផ្សំនឹងកិច្ចខិតខំប្រឹងប្រែងលើគ្រប់វិស័យ ដោយប្រើប្រាស់គ្រប់វិធានការក្នុងរយៈពេល០១ឆ្នាំកន្លងមក ក្រុងសម្រេចបានស្នាដៃ និងសមិទ្ធផលធំៗគួរឱ្យកត់សម្គា

ល់។ សន្តិសុខ សុវត្ថិភាព មូលដ្ឋានជាលក្ខខណ្ឌចម្បងត្រូវបានធានា និងបង្កលក្ខណៈដល់ដំណើរការអភិវឌ្ឍមូលដ្ឋាន ដូចជា ការស្តារ ឬស្ថាបនាហេដ្ឋារចនាសម្ព័ន្ធ ទឹក ភ្លើង ផ្លូវ ស្ពាន លូ ប្រឡាយ សំដៅលើកកម្ពស់ជីវភាពរស់នៅរបស់ប្រជាពលរដ្ឋដើម្បីកាត់បន្ថយភាពក្រីក្រ។ ការពង្រឹងរបៀបរបបការងារ និងការរក្សាសាមគ្គីភាព ឯកភាព ការយោគយល់គ្នា បានធ្វើឲ្យយន្តការរដ្ឋបាលក្រុង ដំណើរការទៅកាន់តែប្រសើរ ទោះបីនៅមានសេសសល់ផ្នែកខ្លះដែលមិនបានអនុវត្តឲ្យមានប្រសិទ្ធភាព និងមានការផ្លាស់ប្តូរជាដុំកំភួនក៏ដោយ យើងត្រូវបន្តជំរុញការកែលម្អ ការរិះរកមធ្យោបាយល្អៗបន្ថែមទៀត ដើម្បីធានាបាននូវការទទួលខុសត្រូវតាមតួនាទី ភារកិច្ច ជំនាញឯកទេស និងប្រព័ន្ធគ្រប់គ្រងមួយដែលមានប្រសិទ្ធភាពជាងមុន។ តាមរយៈការខិតខំរបស់ប្រជាពលរដ្ឋ មន្ត្រី និងថ្នាក់ដឹកនាំគ្រប់លំដាប់ថ្នាក់ ទើបធ្វើឲ្យក្រុងសៀមរាប មានការរីកចម្រើន ជាបន្តបន្ទាប់។

របាយការណ៍បញ្ចប់អាណត្តិទី២ រយៈពេល៥ឆ្នាំ របស់ក្រុមប្រឹក្សាក្រុងសៀមរាប ត្រូវបានពិនិត្យ និងអនុម័តនៅក្នុងកិច្ចប្រជុំសាមញ្ញលើកទី៦០ អាណត្តិទី២ របស់ក្រុមប្រឹក្សាក្រុងសៀមរាប នាថ្ងៃព្រហស្បតិ៍ ១៣កើត ខែពិសាខ ឆ្នាំកុរ ឯកស័ក ព.ស ២៥៦៣ ត្រូវនឹងថ្ងៃទី១៦ ខែឧសភា ឆ្នាំ២០១៩។

ថ្ងៃ ................................ ខែពិសាខ ឆ្នាំកុរ ឯកស័ក ព.ស ២៥៦៣
ក្រុងសៀមរាប ថ្ងៃទី ...... ខែឧសភា ឆ្នាំ២០១៩

**អភិបាលក្រុង**

**ឧបសម្ព័ន្ធ៖**

- ឧបសម្ព័ន្ធទី១ ៖ គម្រោងវិនិយោគ
- ឧបសម្ព័ន្ធទី២ ៖ ការអនុវត្តគម្រោងវិនិយោគ
- ឧបសម្ព័ន្ធទី៣ ៖ បញ្ជីទ្រព្យសម្បត្តិ
- ឧបសម្ព័ន្ធទី៤ ៖ ការអនុវត្តផែនការសកម្មភាព និងថវិកា ផអ៣

## ឧបសម្ព័ន្ធទី១
## គម្រោងវិនិយោគ

| ល.រ | ផ្នែក | ២០១៤ | | ២០១៥ | | ២០១៦ | | ២០១៧ | | ២០១៨ | | សរុប | |
|---|---|---|---|---|---|---|---|---|---|---|---|---|---|
| | | ចំនួន | តម្លៃ | ចំនួន | តម្លៃ | ចំនួន | តម្លៃ | ចំនួន | តម្លៃ | ចំនួន | តម្លៃ | ចំនួន | តម្លៃ |
| ១ | សេដ្ឋកិច្ច | ១៧ | ៦ ៨៣៩ ២០៧ | ៤១ | ១០ ៣៩៨ | ៥១ | ២៩៦ | ៣១ | ១៧ ២៣៦ | ២៤ | ២១ ៦៦៤ | ១៦៤ | ៦ ៨៨៨ ៨០១ |
| ២ | សង្គមកិច្ច | ៣៩ | ២៤ ០១៧ | ៣៣ | ១៥ ២០០ | ៦៥ | ៤១៩ | ៣២ | ១ ៣៦២ | ៣៨ | ១ ៤៦២ | ២០៧ | ៤២ ៤៦០ |
| ៣ | គ្រប់គ្រងដីធ្លី ធនធានធម្មជាតិ បរិស្ថាន ការប្រែប្រួលអាកាសធាតុនិងគ្រោះមហន្តរាយ | ៨ | ២១៤ | ១០ | ៨ ៣៩៨ | ២១ | ៦៦ | ១១ | ១៨៥ | ១៣ | ២៦៣ | ៦៣ | ៩ ១២៦ |
| ៤ | រដ្ឋបាល សន្តិសុខ សណ្តាប់ធ្នាប់សាធារណៈ | ១៩ | ៣៤៣ | ២០ | ២ ៥៤៦ | ៣៧ | ៣៦៣ | ១៨ | ១៧៣ | ២២ | ៣៨៤ | ១១៦ | ៣ ៨០៩ |
| **សរុប** | | **៨៣** | **៦ ៨៦៣ ៧៨១** | **១០៤** | **៣៦ ៥៤២** | **១៧៤** | **១ ១៤៤** | **៩២** | **១៨ ៩៥៦** | **៩៧** | **២៣ ៧៧៣** | **៥៥០** | **៦ ៩៤៤ ១៩៦** |

**កំណត់សម្គាល់ ៖**ឯកតាតម្លៃ គិតជាលានរៀល

## ឧបសម្ព័ន្ធទី៣
## បញ្ជីទ្រព្យសម្បត្តិ

| ល.រ | ឈ្មោះសម្ភារនិងបរិក្ខា | ប្រភេទ | លេខសម្គាល់ | កាលបរិច្ឆេទ ទិញឬទទួល | តម្លៃដើម | ទីតាំង | ផ្សេងៗ |
|---|---|---|---|---|---|---|---|
| **តារាងសម្ភារ និងសង្ហារឹម ឆ្នាំ ២០១៤** | | | | | | | |
| ១ | Laptop dell Inspriron 3421 (៤គ្រឿង) | | | ២០១៤ | ១០ ០០០ ០០០ | រដ្ឋបាលក្រុង | |
| ២ | Desk top dell (៤គ្រឿង) | | | ២០១៤ | ១០ ០០០ ០០០ | រដ្ឋបាលក្រុង | |
| ៣ | ម៉ាស៊ីនព្រីន Printer Canon L B P 3300 (២គ្រឿង) | | | ២០១៤ | ១ ៩០០ ០០០ | រដ្ឋបាលក្រុង | |
| ៤ | ម៉ាស៊ីនថត Canon70d | | | ២០១៤ | ៥៦៥ ០០០ | រដ្ឋបាលក្រុង | |
| **តារាងសម្ភារ និងសង្ហារឹម ឆ្នាំ ២០១៥ (គ្មាន)** | | | | | | | |
| | | | | | | | |
| **តារាងសម្ភារ និងសង្ហារឹម ឆ្នាំ ២០១៦** | | | | | | | |
| ១ | ទូដាក់ឯកសារ leeco 304 ( ៣ទូ ) | | | ២០១៦ | ៨៨០ ០០០ | រដ្ឋបាលក្រុង | |
| ២ | កៅអីវិល CM-F63AS | | | ២០១៦ | ៤ ៥៦០ ០០០ | រដ្ឋបាលក្រុង | |
| ៣ | តុការិយាល័យ HS 1819 | | | ២០១៦ | ២ ១៦០ ០០០ | រដ្ឋបាលក្រុង | |
| ៤ | ម៉ាស៊ីនព្រីនធំ imsge CLASS MF22id | | | ២០១៦ | ១ ១៨០ ០០០ | រដ្ឋបាលក្រុង | |
| **តារាងសម្ភារ និងសង្ហារឹម ឆ្នាំ ២០១៧ (គ្មាន)** | | | | | | | |
| | | | | | | | |
| **តារាងសម្ភារ និងសង្ហារឹម ឆ្នាំ ២០១៨** | | | | | | | |
| ១ | ម៉ាស៊ីន Printer Epson L3150(WIFI) (២ គ្រឿង) | | | ២០១៨ | ២ ១០០ ០០០ | រដ្ឋបាលក្រុង | |

| | | | | | | | |
|---|---|---|---|---|---|---|---|
| ២ | ម៉ាស៊ីន Printer Hp M26nw (P.S.C.N.WIFI)(១៣គ្រឿង) | | | ២០១៨ | ១១ ០១១ ០០០ | រដ្ឋបាលក្រុង | |
| ៣ | ម៉ាស៊ីន Projector Acer X118 3600 Lumen (២គ្រឿង) | | | ២០១៨ | ៣ ៨៦៤ ០០០ | រដ្ឋបាលក្រុង | |
| ៤ | ផ្ទាំង Screen Projector 2.4m Have Remote (Apollo) (២គ្រឿង) | | | ២០១៨ | ២ ៤៩០ ០០០ | រដ្ឋបាលក្រុង | |

ឧបសម្ព័ន្ធទី៤

ការអនុវត្តផែនការសកម្មភាព និងថវិកា ផអ៣

| លេខកូដ | ឈ្មោះលទ្ធផលរំពឹងទុក | ថវិកា (ដុល្លារ) | | | យោបល់ |
|---|---|---|---|---|---|
| | | គ្រោង | ចំណាយ | %ចំណាយ | |
| **ឆ្នាំ២០១៥** | | | | | |
| ៣.៣.១.១៣ | បណ្តុះបណ្តាលរំលឹកស្តីពីតួនាទី ភារកិច្ច និងរបៀបរបប ការងាររដ្ឋបាលក្រុង និងច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាល រាជធានី ខេត្ត ក្រុង | បញ្ចប់ | ១០០% | ១០០$ | |
| ៣.៣.១.១៣ | បណ្តុះបណ្តាលនីតិវិធីជំនាញកិច្ចការរដ្ឋបាល | បញ្ចប់ | ១០០% | ៧០$ | |

| | | | | | |
|---|---|---|---|---|---|
| ៣.៣.១.១៣ | បណ្ដុះបណ្ដាលនីតិវិធីលទ្ធកម្ម | បញ្ចប់ | ១០០% | ១២៦$ | |
| ៣.៣.១.១៥ | ការពង្រឹងតួនាទី ភារកិច្ច របស់ គ.ក.ស.ក និង គ.ក.ន.ក | បញ្ចប់ | ១០០% | ៤១$ | |
| **ឆ្នាំ២០១៦** | | | | | |
| ៣.១.៦.១.១០ | ពង្រឹងការអនុវត្តមុខងាររបស់ គ.ក.ស.ក ក្រុង ស្រុក ខណ្ឌ ក្នុងការបញ្ជ្រាបបរិយាប័ន្ន និងសមធម៌សង្គមក្នុងផ្នែកផែនការ គម្រោង និងកម្មវិធីនានាក៏ដូចជាការសម្របសម្រួល និងស្វែងរកការគាំទ្ររបស់ក្រុង ស្រុក ខណ្ឌ និងស្ថាប័នពាក់ព័ន្ធនានាក្នុងការលើកកម្ពស់សេវាសង្គម | បញ្ចប់ | ១០០% | ១០០៨$ | |
| ៣.២.១.១.៩ | រៀបចំ និងអនុវត្តផែនការអភិវឌ្ឍន៍សមត្ថភាពជាក់លាក់របស់រដ្ឋបាលក្រុង ស្រុក ខណ្ឌ | បញ្ចប់ | ១០០% | ៥៥៨$ | |
| | វគ្គហ្វឹកហ្វឺនស្ដីពីការរៀបចំកម្មវិធីវិនិយោគបីឆ្នាំរំកិលក្រុង | បញ្ចប់ | ១០០% | ១៨៦$ | |
| | វគ្គហ្វឹកហ្វឺនស្ដីពីការអនុវត្តចំណូលចំណាយថវិកាក្រុង | បញ្ចប់ | ១០០% | ១៨៦$ | |
| | ការបណ្ដុះបណ្ដាលស្ដីពីសៀវភៅរដ្ឋបាលថ្នាក់ក្រោមជាតិនៅក្រុង | បញ្ចប់ | ១០០% | ១៣៤$ | |
| | វគ្គហ្វឹកហ្វឺនស្ដីពីការអនុវត្តកិច្ចការរដ្ឋបាលក្រុង | បញ្ចប់ | ១០០% | ៥២$ | |
| ៩.១.១.១.៣ | ទីប្រឹក្សា និងបុគ្គលិកកិច្ចសន្យាថ្នាក់ស្រុកត្រូវបានជ្រើសរើស និងគ្រប់គ្រងប្រកបដោយប្រសិទ្ធភាព | បញ្ចប់ | ១០០% | ៧៣២០$ | |
| ៩៣.៣.១.១. | គាំទ្រការចំណាយប្រតិបត្តិការជាប្រចាំសម្រាប់ថ្នាក់ក្រុង ស្រុក ខណ្ឌ | បញ្ចប់ | ១០០% | ៤៦២៦$ | |
| **ឆ្នាំ២០១៧** | | | | | |
| ៣១៣.១.៦.១. | ពង្រឹងការអនុវត្តមុខងាររបស់ គក ក្រុង ស្រុក ខណ្ឌ ក្នុងការបញ្ជ្រាប់បរិយាប័ន្ន និងសមធម៌.ស.ក.សង្គមក្នុងផ្នែកផែនការ គម្រោង និងកម្មវិធីនានាក៏ដូចជាការសម្របសម្រួល និងស្វែងរកការគាំទ្ររបស់ក្រុង ស្រុក ខណ្ឌ និងស្ថាប័នពាក់ព័ន្ធនានាក្នុងការលើកកម្ពស់សេវាសង្គម | | | ៨៦០ | |
| ៣១២.១.១.២. | រៀបចំ និងអនុវត្តផែនការអភិវឌ្ឍ សមត្ថភាពជាក់លាក់របស់រដ្ឋបាលក្រុង ស្រុក ខណ្ | | | ៥៦៣ | |
| ៩៣.១.១.១. | ទីប្រឹក្សានិងបុគ្គលិកកិច្ចសន្យាថ្នាក់ ស្រុក ក្រុង ត្រូវបានជ្រើសរើស និងគ្រប់គ្រងប្រកបដោយប្រសិទ្ធភាព | | | ៧៣២០ | |
| ៩៣.៣.១.១. | គាំទ្រការចំណាយប្រតិបត្តិការជាប្រចាំសម្រាប់ថ្នាក់ក្រុង ស្រុក ខណ្ឌ | | | ៦២៦០ | |
| **សរុប** | | | | | |

# ឧបសម្ព័ន្ធទី៥៖

# របាយការណ៍ប្រចាំឆ្នាំ

# ស្តីពីការអនុវត្តការងារ

# របស់រដ្ឋបាលក្រុងសៀមរាប

**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

**ខេត្តសៀមរាប**
**សាលាក្រុងសៀមរាប**
លេខ៖ …………….. របក

# របាយការណ៍ប្រចាំឆ្នាំ
# ស្តីពី
# ការអនុវត្តការងាររបស់រដ្ឋបាលក្រុងសៀមរាប

**ឆ្នាំ ២០១៨**

# សេចក្តីផ្តើម

ក្រុងសៀមរាប ជាក្រុងមួយក្នុងចំណោមស្រុកទាំង ១២ នៃខេត្តសៀមរាប ដែលមានព្រំប្រទល់

- ខាងកើតទល់ ៖ ស្រុកប្រាសាទបាគង
- ខាងលិចទល់ ៖ ស្រុកពួក
- ខាងជើងទល់ ៖ ស្រុកអង្គរធំ និងស្រុកបន្ទាយស្រី
- ខាងត្បូងទល់ ៖ បឹងទន្លេសាប

ក្រុងសៀមរាបមាន៖

| ល.រ | ការបរិយាយ | សរុប | ឯកតា |
|---|---|---|---|
| ១ | ផ្ទៃដីសរុប | ៤៧២,៧៣ | គីឡូម៉ែតការេ |
| ២ | ចំនួនសង្កាត់ | ១២ | សង្កាត់ |
| ៣ | ចំនួនភូមិ | ៩៩ | ភូមិ |
| ៤ | ចំនួនគ្រួសារ | ៥០ ៥០៦ | គ្រួសារ |
| ៥ | ចំនួនប្រជាពលរដ្ឋសរុប | ២៦៨ ៣៨០ | នាក់ |
| ៦ | ចំនួនស្ត្រីសរុប | ១៣៩ ២១៧ | នាក់ |

របាយការណ៍ប្រចាំឆ្នាំ២០១៨ ជាការបរិយាយអំពីសមិទ្ធផលការងារប្រចាំឆ្នាំទី០៤ នៃអាណត្តិទី០២ របស់រដ្ឋបាលក្រុងសៀមរាប ដើម្បីឆ្លើយតបនូវគោលនយោបាយផែនការអភិវឌ្ឍន៍០៥ឆ្នាំ របស់ក្រុងសៀមរាប (២០១៥-២០១៩) តាមរយៈការអនុវត្តកម្មវិធីវិនិយោគបីឆ្នាំរំកិល (២០១៩-២០២១)។ របាយការណ៍ប្រចាំឆ្នាំស្តីពីការអនុវត្តការងាររបស់រដ្ឋបាលក្រុងមាន ៦ផ្នែក ដែលក្នុងនោះ៖

- **ផ្នែកទី១ ៖ ការគ្រប់គ្រងរដ្ឋបាលក្រុង**

ផ្នែកទី១នេះ បរិយាយអំពីលទ្ធផលនៃការអនុវត្តការងាររដ្ឋបាល ផែនការនិងការគាំទ្រសង្កាត់ ការគ្រប់គ្រងធនធានមនុស្ស ការងារអន្តរវិស័យ និងការងារហិរញ្ញវត្ថុរបស់រដ្ឋបាលក្រុងសៀមរាប។

- **ផ្នែកទី២ ៖ ការងាររដ្ឋបាលសង្កាត់**

ផ្នែកទី២នេះ បរិយាយជាសង្ខេបអំពីលទ្ធផលនៃការអនុវត្តការងាររបស់រដ្ឋបាលសង្កាត់ និងបញ្ហាប្រឈមដែលសង្កាត់បានជួបប្រទះ ព្រមទាំងសំណើដំណោះស្រាយបញ្ហាប្រឈមទាំងនោះ។

- **ផ្នែកទី៣ ៖ ការងាររបស់ការិយាល័យ អង្គភាពជំនាញ**

ផ្នែកទី៣នេះ បរិយាយអំពីលទ្ធផលនៃការអនុវត្តការងាររបស់ការិយាល័យ អង្គភាពជំនាញនានា ដែលមានទីតាំងនៅក្នុងដែនសមត្ថកិច្ចក្រុង សៀមរាប។

- **ផ្នែកទី៤ ៖ បញ្ហាប្រឈម និងដំណោះស្រាយ**

ផ្នែកទី៤នេះ បរិយាយអំពីបញ្ហាប្រឈមនានាដែលរដ្ឋបាលក្រុងសៀមរាប និងការិយាល័យ អង្គភាពជំនាញបានជួបប្រទះ និងសំណើដំណោះស្រាយបញ្ហាប្រឈមទាំងនោះ។

- **ផ្នែកទី៥ ៖ ទិសដៅការងារឆ្នាំបន្ទាប់**

ផ្នែកទី៥នេះ បរិយាយអំពីសកម្មភាពជាអាទិភាព ដែលរដ្ឋបាលក្រុងសៀមរាប និងការិយាល័យ អង្គភាពជំនាញបានគ្រោងសម្រាប់អនុវត្តនៅឆ្នាំបន្ទាប់។

- **ផ្នែកទី៦ ៖ សេចក្តីសន្និដ្ឋាន**

ផ្នែកទី៦នេះ បរិយាយជាសង្ខេបអំពីការសន្និដ្ឋាននៃការអនុវត្តការងាររបស់ រដ្ឋបាលក្រុងសៀមរាប ដោយប្រៀបធៀបទៅនឹងផែនការប្រចាំឆ្នាំ ដែលបានគ្រោងទុក។

# ផ្នែកទី១
# ការគ្រប់គ្រងរដ្ឋបាលក្រុងសៀមរាប

## ១.១.ការងាររដ្ឋបាល

### ១.១.១. ការងារលិខិតស្នាម និងឯកសារប្រជាពលរដ្ឋ

តារាងទី១៖ ការងារលិខិតស្នាម និងឯកសារប្រជាពលរដ្ឋ

| ល.រ | ការបរិយាយ | ចំនួន |
|---|---|---|
| ១ | ដីកាដែលបានដាក់ចេញ | ៤ |
| ២ | សេចក្ដីសម្រេចដែលបានដាក់ចេញ | ៣២ |
| ៣ | លិខិតរដ្ឋបាលដែលបានដាក់ចេញ | ៤ ២១០ |
| ៤ | លិខិតដែលបានទទួល | ៤ ២០៣ |
| ៥ | សៀវភៅស្នាក់នៅ | ៤៣៨ |

### ១.១.២.ការគ្រប់គ្រងប្រជាពលរដ្ឋ

តារាងទី២៖ ការគ្រប់គ្រងប្រជាពលរដ្ឋ

| ល.រ | ការបរិយាយ | ចំនួន |
|---|---|---|
| ១ | សរុបគ្រួសារ | ៥៨ ៧៤៨ |
| ២ | គ្រួសារអចិន្ត្រៃយ៍ | ៥០ ៥០៦ |
| ៣ | គ្រួសារបណ្ដោះអាសន្ន | ៨ ២៤២ |
| ៤ | ប្រជាពលរដ្ឋសរុប | ២៦៨ ៣៨០ |
| ៥ | ប្រជាពលរដ្ឋជាស្ត្រី | ១៣៩ ២១៧ |
| ៦ | ប្រជាពលរដ្ឋដែលមានអាយុ១៨ឆ្នាំឡើង | ១៩១ ៩៣៥ |
| ៧ | ប្រជាពលរដ្ឋចំណាកស្រុក | ៥៥៦ |

### ១.១.៣-ការងារអត្រានុកូលដ្ឋាន

តារាងទី៣៖ ការចេញសេចក្ដីចម្លងសំបុត្រអត្រានុកូលដ្ឋាន

| ល.រ | ការបរិយាយ | ចំនួន |
|---|---|---|
| ១ | សេចក្ដីចម្លងសំបុត្រកំណើត | ១០ ០៦៦ |
| ២ | សេចក្ដីចម្លងសំបុត្របញ្ជាក់កំណើត | ៤០ ០៩៤ |
| ៣ | សេចក្ដីចម្លងសំបុត្រអាពាហ៍ពិពាហ៍ | ៥១៦៩ |
| ៤ | សេចក្ដីចម្លងសំបុត្រមរណភាព | ៧៩៨ |

### ១.១.៤-ការផ្សព្វផ្សាយព័ត៌មានទំនាក់ទំនងសាធារណៈនិងសហប្រតិបត្តិការអន្តរជាតិ (រួមទាំងការងារសមាគម អង្គការមិនមែនរដ្ឋាភិបាល និងការងារចងសម្ព័ន្ធមេត្រីភាព )

តារាងទី៤៖ ការផ្សព្វផ្សាយព័ត៌មាន និងទំនាក់ទំនងសាធារណៈ

| ល.រ | ការបរិយាយ | ចំនួន |
|---|---|---|
| ក). ការផ្សព្វផ្សាយព័ត៌មាន | | |
| ១ | វិទ្យុ | ១០៤ |
| ២ | ទូរទស្សន៍ | ១០៤ |

| | | |
|---|---|---|
| ៣ | បិទផ្សាយលើក្តារព័ត៌មានសាធារណៈ | ៧៥ |
| ៤ | ព្រឹត្តិបត្រព័ត៌មានទស្សនាវដ្តី សារព័ត៌មាន | ០ |
| ៥ | ផ្សេងៗ | ០ |
| **ខ). ទំនាក់ទំនងសាធារណៈ** | | |
| ១ | សាធារណជនមកទំនាក់ទំនងសាលាក្រុង | ៨៣ ៦៧៣ |
| ២ | គណៈប្រតិភូភ្ញៀវជាតិ អន្តរជាតិ | ១៥ |

**១.១.៥. ការងារគណៈអភិបាល**(រួមទាំងការអនុវត្តតួនាទីជាតំណាងក្រសួង ស្ថាប័ន)

**ក-រៀបចំកិច្ចប្រជុំរបស់គណៈអភិបាលបាន ១៥ លើក**

**ខ-ការចូលរួមកិច្ចប្រជុំផ្សេងៗរបស់គណៈអភិបាលក្រុងរួមមាន ២២៤លើករួមមានៈ**

- លោក នួន ពុទ្ធារ៉ា អភិបាល នៃគណៈអភិបាលក្រុងចំនួន០៥លើក។
- លោក លេង ពលៈ អភិបាលរង នៃគណៈអភិបាលក្រុងបានចំនួន ៦៨លើក។
- លោក ពៅ សារ៉ាវុធ អភិបាលរង នៃគណៈអភិបាលក្រុងបានចំនួន  ៥៦លើក។
- លោកស្រី លឹម ផល្លីកា អភិបាលរង នៃគណៈអភិបាលបានចំនួន ៥៨លើក។
- លោក បូ ម៉េងទ្រី អភិបាលរង នៃគណៈអភិបាលក្រុងបានចំនួន ៣៧លើក។

**តារាងទី៥៖ កិច្ចប្រជុំគណៈអភិបាល**

| ល.រ | ការបរិយាយ | ចំនួន |
|---|---|---|
| ១ | កិច្ចប្រជុំអឌ្ឍមាសរបស់គណៈអភិបាល | ១១ |
| ២ | កិច្ចប្រជុំប្រចាំខែ(អឌ្ឍមាសទី២)របស់គណៈអភិបាល | ៤ |

**១.១.៦.ការងារក្រុមប្រឹក្សា និងគណៈកម្មាធិការនានា**

**តារាងទី៦៖ កិច្ចប្រជុំក្រុមប្រឹក្សា និងគណៈកម្មាធិការនានា**

| ល.រ | ការបរិយាយ | ចំនួន |
|---|---|---|
| ១ | កិច្ចប្រជុំសាមញ្ញរបស់ក្រុមប្រឹក្សា | ១២ |
| ២ | កិច្ចប្រជុំវិសាមញ្ញរបស់ក្រុមប្រឹក្សា | ៤ |
| ៣ | កិច្ចប្រជុំសម្ងាត់របស់ក្រុមប្រឹក្សា | ១ |
| ៤ | កិច្ចប្រជុំគណៈកម្មាធិការសម្របសម្រួលបច្ចេកទេស | ៣ |
| ៥ | កិច្ចប្រជុំគណៈកម្មាធិការពិគ្រោះយោបល់កិច្ចការស្ត្រី និងកុមារ | ១០ |

**តារាងទី៧៖ ការរៀបចំវេទិកា**

| ល.រ | ឈ្មោះវេទិកា | អ្នកចូលរួម | |
|---|---|---|---|
| | | សរុប | ស្រី |
| ១ | វេទិកាផ្សព្វផ្សាយ និងពិគ្រោះយោបល់របស់ក្រុមប្រឹក្សាក្រុង | ៦៧៩ | ១៩៣ |
| **សរុបរួម** | | **៦៧៩** | **១៩៣** |

## ១.២.ការងារផែនការនិងការគាំទ្រសង្កាត់

### ១.២.១. ការកសាងផែនការអភិវឌ្ឍន៍ និងកម្មវិធីវិនិយោគក្រុង

**តារាងទី៨ ៖ គម្រោងវិនិយោគបីឆ្នាំរំកិលក្រុង**

| ល.រ | ផ្នែក | ចំនួនគម្រោង | តម្លៃគម្រោង (លានរៀល) |
|---|---|---|---|
| ១ | សេដ្ឋកិច្ច | ២៤ | ២១ ៦៦៤ |
| ២ | សង្គមកិច្ច | ៣៨ | ១ ៤៦២ |
| ៣ | គ្រប់គ្រងដីធ្លីធនធានធម្មជាតិបរិស្ថានការប្រែប្រួលអាកាសធាតុនិងគ្រោះមហន្តរាយ | ១៣ | ២៦៣ |
| ៤ | រដ្ឋបាល សន្តិសុខ សណ្តាប់ធ្នាប់សាធារណៈ | ២២ | ៣៨៤ |
| **សរុប** | | **៩៧** | **២៣ ៧៧៣** |

### ១.២.២ ការអនុវត្តគម្រោងវិនិយោគក្រុង

- ការអនុវត្តគម្រោងមូលនិធិក្រុងឆ្នាំ២០១៨ មានចំនួន ០៤គម្រោង ថវិកាចំណាយចំនួន ៤៧០,១៥៤,០០៦រៀល (កំពុងអនុវត្ត) រួមមាន៖

  ១. សង្កាត់សាលាកំរើក នៅភូមិតាវៀន សាងសង់ផ្លូវបេតុង១ខ្សែ ប្រវែង១៩៤ម៉ែត្រ ទទឹង៥ម៉ែត្រ

  ២. សង្កាត់ស្លក្រាម នៅភូមិធ្លកអណ្តូង សាងសង់ផ្លូវបេតុង១ខ្សែ ប្រវែង១៨៨ម៉ែត្រ ទទឹង៥ម៉ែត្រ

  ៣. សង្កាត់ស្វាយដង្គំ នៅភូមិថ្មី សាងសង់ផ្លូវបេតុង១ខ្សែ ប្រវែង ៣៣៧ម៉ែត្រ ទទឹង ៦ម៉ែត្រ

  ៤. សង្កាត់សាលាកំរើក នៅភូមិតាវៀន សាងសង់លូរំដោះទឹក១ខ្សែង ប្រវែង ១២០ម៉ែត្រ មុខកាត់០១ម៉ែត្រ

**តារាងទី៩ ៖ ការអនុវត្តគម្រោងវិនិយោគក្រុង**

| ល.រ | ផ្នែក | សរុប | ស្ថានភាពនៃការអនុវត្ត | | |
|---|---|---|---|---|---|
| | | | មិនទាន់ | កំពុង | បញ្ចប់ |
| ១ | សេដ្ឋកិច្ច | ៤ | ០ | ៤ | ០ |
| ២ | សង្គមកិច្ច | ០ | ០ | ០ | ០ |
| ៣ | គ្រប់គ្រងដីធ្លី ធនធានធម្មជាតិ បរិស្ថាន ការប្រែប្រួលអាកាសធាតុនិងគ្រោះមហន្តរាយ | ០ | ០ | ០ | ០ |
| ៤ | រដ្ឋបាល សន្តិសុខ សណ្តាប់ធ្នាប់សាធារណៈ | ០ | ១ | ០ | ០ |
| **សរុប** | | **៤** | **០** | **៤** | **០** |

### ១.២.៣ អនុវត្តផែនការសកម្មភាព និងថវិកាផអ៣

**តារាងទី១០ ៖ ការអនុវត្តផែនការសកម្មភាព និងថវិកា ផអ៣**

| លេខកូដ | ឈ្មោះសកម្មភាព | ស្ថានភាព | %សម្រេច | %ចំណាយ |
|---|---|---|---|---|
| 3.1.6.1.13 | ពង្រឹងការអនុវត្តមុខងាររបស់ គ.ក.ស.ក ក្រុង ស្រុក ខណ្ឌ ក្នុងការបញ្ជ្រាបបរិយាប័ន្ន និងសមធម៌សង្គមក្នុងផ្នែកផែនការ គម្រោង និងកម្មវិធីនានាក៏ដូចជាការសម្របសម្រួល និងស្វែងរកការគាំទ្ររបស់ក្រុង ស្រុក ខណ្ឌ និងស្ថាប័នពាក់ព័ន្ធនានាក្នុងការលើកកម្ពស់សេវាសង្គម | មិនទាន់អនុវត្ត | 0% | 0% |
| 3.2.1.1.12 | រៀបចំ និងអនុវត្តផែនការអភិវឌ្ឍសមត្ថភាពជាក់លាក់របស់រដ្ឋបាលក្រុង ស្រុក ខណ្ឌ | មិនទាន់អនុវត្ត | 0% | 0% |

| | | | | |
|---|---|---|---|---|
| | វគ្គរំលឹកឡើងវិញពីតួនាទីភារកិច្ច និងរបៀបរបបការងាររបស់ គ.ក.ស.ក | មិនទាន់អនុវត្ត | 0% | 0% |
| | វគ្គហ្វឹកហ្វឺនឡើងវិញ ស្តីពីការអនុវត្តកិច្ចការរដ្ឋបាល ក្រុង | មិនទាន់អនុវត្ត | 0% | 0% |
| | វគ្គបណ្តុះបណ្តាលរំលឹកឡើងវិញ ស្តីពីការរៀបចំផែនការអភិវឌ្ឍន៍៥ឆ្នាំ និងកម្មវិធីវិនិយោគ៣ឆ្នាំរំកិល | មិនទាន់អនុវត្ត | 0% | 0% |
| | បណ្តុះបណ្តាលស្តីពីនីតិវិធីការអនុវត្តការងារលទ្ធកម្មក្រុង | មិនទាន់អនុវត្ត | 0% | 0% |
| | វគ្គរំលឹកឡើងវិញស្តីពីប្រព័ន្ធគ្រប់គ្រងហិរញ្ញវត្ថុ | មិនទាន់អនុវត្ត | 0% | 0% |
| 9.1.1.1.3 | ទីប្រឹក្សា និងបុគ្គលិកកិច្ចសន្យាថ្នាក់ស្រុកត្រូវបានជ្រើសរើស និងគ្រប់គ្រងប្រកបដោយប្រសិទ្ធភាព | មិនទាន់អនុវត្ត | 0% | 0% |
| 9.1.1.3.3 | គាំទ្រការចំណាយប្រតិបត្តិការជាប្រចាំសម្រាប់ថ្នាក់ក្រុង ស្រុក ខណ្ឌ | មិនទាន់អនុវត្ត | 0% | 0% |
| **សរុបរួម** | | | 0% | 0% |

**១.២.៤ ការគាំទ្រសង្កាត់**

**ក. ការអនុវត្តគម្រោងមូលនិធិសង្កាត់ឆ្នាំ២០១៨**

- **ចំនួន ០៨សង្កាត់ អនុវត្តបាន ១០០% រួមមាន៖**

**១. សង្កាត់សាលាកំរើក នៅភូមិតារៀន** សាងសង់ផ្លូវបេតុង១ខ្សែ ប្រវែង ២៩៧ម៉ែត្រ ទទឹង ៥ម៉ែត្រ ចំណាយថវិកាអស់ចំនួន ៨៥,៩៩៧,០៥៩លានរៀល និងលូរំដោះទឹក១ខ្សែ ប្រវែង ៥៧០ម៉ែត្រ មុខកាត់ 0.៦០ម៉ែត្រ ចំណាយថវិកាអស់ចំនួន ៧២,៥០០,០០០ រៀល។

**២. សង្កាត់សៀមរាប នៅភូមិប្រឡាយ** សាងសង់ផ្លូវបេតុង១ខ្សែ ប្រវែង ៥៤០ម៉ែត្រ ទទឹង ៥ម៉ែត្រ ចំណាយថវិកាអស់ចំនួន ១៦៩,២៩៧,០១៨ រៀល។

**៣. សង្កាត់គោកចក នៅភូមិត្រពាំងសេះ** សាងសង់ផ្លូវបេតុង១ខ្សែ ប្រវែង ៣១៦ម៉ែត្រ ទទឹង ៦ម៉ែត្រ ចំណាយថវិកាអស់ចំនួន ១៥២,៤០០,០០០ រៀល។

**៤. សង្កាត់ស្វាយដង្គំ នៅភូមិតាកុល** សាងសង់ផ្លូវបេតុង២ខ្សែ ប្រវែង ៤០៨ម៉ែត្រ ទទឹង ៦ម៉ែត្រ ចំណាយថវិកាអស់ចំនួន ១៥៥,៧៨១,៨១៨ រៀល។

**៥. សង្កាត់ស្រង៉ែ នៅភូមិស្រង៉ែ** សាងសង់ផ្លូវបេតុង១ខ្សែ ប្រវែង ២៩២ម៉ែត្រ ទទឹង ៤ម៉ែត្រ ចំណាយថវិកាអស់ចំនួន ៧៣,៣៧៨,២៣៨ រៀល។

**៦. សង្កាត់នគរធំ នៅភូមិអញ្ចាញ** ជួសជុលផ្លូវដីសក្រាលគ្រួសក្រហម២ខ្សែ ប្រវែង ១៤៣០ម៉ែត្រ ទទឹង ៥ម៉ែត្រ ចំណាយថវិកាអស់ចំនួន ៧២,៤០០,០០០ រៀល។

**៧. សង្កាត់ស្លក្រាម នៅភូមិទ្រាំង** សាងសង់ផ្លូវបេតុង១ខ្សែ ប្រវែង ៥៧៧ម៉ែត្រ ទទឹង ៥ម៉ែត្រ ចំណាយថវិកាអស់ចំនួន ១៨៤,៣៣៦,៩៨០ រៀល។

**៨. សង្កាត់ទឹកវិល នៅភូមិប្រៃយ៍ចាស់ និងភូមិសណ្តាន់** សាងសង់ផ្លូវដីសក្រាលគ្រួសក្រហម៣ខ្សែ ប្រវែង ២០៩៥ម៉ែត្រ ទទឹង ៥ម៉ែត្រ ចំណាយថវិកាអស់ចំនួន ៧៩,៦១០,០០០ រៀល។

- **ចំនួន ០១សង្កាត់ អនុវត្តបាន ២៥% គឺ៖**

៩. **សង្កាត់ក្របីរៀល នៅភូមិប្រម៉ា ភូមិរកា និងភូមិបឹង** ជួសជុលផ្លូវដីសក្រាលគ្រួសក្រហម២ខ្សែ ប្រវែង ២៣៩០ ម៉ែត្រ ទទឹង ៥ម៉ែត្រ គាំទ្រដោយមូលនិធិសង្កាត់ ចំណាយថវិកាចំនួន ១០១,៧០២,៥០០ រៀល។

➢ **ចំនួន ០៣សង្កាត់ មិនទាន់បានអនុវត្ត** (ដោយសារកិច្ចសន្យាមិនទាន់ដល់ថ្ងៃអនុវត្ត) **រួមមាន៖**

១០. **សង្កាត់សំបួរ នៅភូមិជ្រៃ** ជួសជុលផ្លូវដីស ១ខ្សែ ប្រវែង ២៦៤៥ម៉ែត្រ ទទឹង ៤ម៉ែត្រ ចំណាយថវិកាអស់ចំនួន ៩០,៤៥៩,០០០ រៀល។

១១. **សង្កាត់ចុងឃ្នៀស នៅភូមិទី១ ភូមិទី៤ និងភូមិទី៥** ជួសជុលផ្លូវដីស ៣ខ្សែ ប្រវែង ៨៥៦ម៉ែត្រ ទទឹង ៤ម៉ែត្រ និងលូ ៥កន្លែង ចំណាយថវិកាអស់ចំនួន ១១៨,៧១៩,៦២៦ រៀល។

១២. **សង្កាត់ជ្រាវ នៅភូមិជ្រាវ** ជួសជុលផ្លូវដីសក្រាលគ្រួសក្រហម១ខ្សែ ប្រវែង ១៣១៧ម៉ែត្រ ទទឹង ៥ម៉ែត្រ ចំណាយថវិកាអស់ចំនួន ៨៣,០៩១,០០០ រៀល។

**ខ. ការកសាងកម្មវិធីវិនិយោគ និងផែនការអភិវឌ្ឍន៍**

- ចំនួន ១២សង្កាត់ បានធ្វើដល់ជំហានទី២ និងបានចូលរួមកម្មវិធីសមាហរណកម្មកម្មវិនិយោគបីឆ្នាំរំកិលក្រុងសង្កាត់កាលពីថ្ងៃទី០៥ ខែធ្នូ ឆ្នាំ២០១៨។

**គ. ការរៀបចំគ្រោង កែសម្រួល និងបិទបញ្ជីថវិការបស់សង្កាត់**

- គ្រប់សង្កាត់កំពុងគ្រោងចំណូលចំណាយថវិកាឆ្នាំ២០១៩
- សង្កាត់កំពុងទូទាត់បុរេប្រទានជុំទី៤ ឆ្នាំ២០១៨បានចំនួន ១០សង្កាត់
- សង្កាត់មិនទាន់បើក បុរេប្រទាន ឆ្នាំ២០១៨មានចំនួន២សង្កាត់គឺ ៖ សង្កាត់សំបួរ និងសង្កាត់ស្វាយដង្គំ

**ឃ. ការគាំទ្រកិច្ចប្រជុំរបស់ក្រុមប្រឹក្សាសង្កាត់**

- ក្នុងខែនេះមិនបានចុះតាមដាន (ខ្វះមន្ត្រី)

## ១.៣.ការគ្រប់គ្រងធនធានមនុស្ស

### ១.៣.១.ការគ្រប់គ្រងបុគ្គលិក

ចេញលិខិតបេសកកម្មជូនសមាជិក សមាជិកាក្រុមប្រឹក្សា គណៈអភិបាលក្រុង ប្រធាន អនុប្រធាន មន្ត្រីការិយាល័យចំណុះ និងជុំវិញក្រុង ២៣១លើក ។

**តារាងទី១១៖ ស្ថិតិក្រុមប្រឹក្សា និងបុគ្គលិក**

| ល.រ | ការបរិយាយ | សរុប | ស្រី |
|---|---|---|---|
| ១ | ប្រធានក្រុមប្រឹក្សា | ១ | ០ |
| ២ | សមាជិកក្រុមប្រឹក្សា | ១២ | ២ |
| ៣ | សមាជិកក្រុមប្រឹក្សាដែលបានផ្លាស់ប្តូរ | ០ | ០ |
| ៤ | អភិបាល | ១ | ០ |
| ៥ | អភិបាលរង | ៤ | ១ |
| ៦ | នាយករដ្ឋបាល | ១ | ០ |
| ៧ | នាយករងរដ្ឋបាល | ២ | ០ |
| ៨ | ប្រធានការិយាល័យ និងអង្គភាព | ៥ | ១ |
| ៩ | អនុប្រធានការិយាល័យ និងអង្គភាព | ៥ | ១ |
| ១០ | មន្ត្រីការិយាល័យ | ៣៩ | ១៣ |
| ១១ | បុគ្គលិកកិច្ចសន្យា | ២៤ | ១០ |

### ១.៣.២. ការកសាងសមត្ថភាព (មិនទាន់បានអនុវត្ត)

តារាងទី១២៖ ការកសាងសមត្ថភាព

| ល.រ | ឈ្មោះវគ្គសិក្សា | ចំនួនថ្ងៃ | អ្នកចូលរួម | | រៀបចំដោយ |
|---|---|---|---|---|---|
| | | | សរុប | ស្រី | |
| | | | | | |
| | | | | | |

## ១.៤-ការងាររអភិវឌ្ឍន៍ក្រុង

### ១.៤.១. ការសម្របសម្រួលតាមវិស័យ

**ក.ការរៀបចំប្លង់គោលប្រើប្រាស់ដីធ្លី និងផែនការប្រើប្រាស់ដី**

- ចូលរួមប្រជុំគណៈកម្មការរដ្ឋបាល កំណត់ផ្លូវ អូរ ប្រឡាយក្នុងក្រុងសៀមរាប ចំនួន ៩២ខ្សែ ។
- ចូលរួមសិក្ខាសាលាពិគ្រោះយោបល់ពិនិត្យ និងផ្ទៀងផ្ទាត់ទិន្នន័យសម្រាប់ការកសាងផែនការរៀបចំដែនដីក្នុងខេត្តសៀមរាប ចំនួន ០១លើក ។

**ខ.ការសាងសង់សំណង់ និងជួសជុលសំណង់នានា**

- ចូលរួមសន្និបាតបូកសរុបការងារប្រចាំឆ្នាំ២០១៧ និងលើកទិសដៅការងារឆ្នាំ២០១៨ របស់មន្ទីររៀបចំដែនដី នគរូបនីយកម្ម សំណង់ និងសុរិយោដីខេត្តសៀមរាប ។
- ចូលរួមកិច្ចប្រជុំពិភាក្សាការងារគ្រប់គ្រងដីបុរី និងការពុះដីឡូត៍លក់ក្នុងក្រុងសៀមរាប និងប្រជុំពង្រាងកំណត់ជួរតម្រង់ គម្លាតព្រំ កម្ពស់អគារ ប្លង់សាងសង់ក្នុងក្រុងសៀមរាប ចំនួន ០២លើក ។
- សហការជាមួយរដ្ឋបាលខេត្ត មន្ទីររៀបចំដែនដី នគរូបនីយកម្ម សំណង់ និងសុរិយោដីខេត្ត ការិយាល័យរៀបចំដែនដី នគរូបនីយកម្ម សំណង់ និងភូមិបាលក្រុង សង្កាត់ និងភូមិ ចុះត្រួតពិនិត្យ និងទប់ស្កាត់សំណង់ក្នុងក្រុងសៀមរាប ចំនួន ២៥លើក ។
- ចូលរួមកិច្ចប្រជុំពាក់ព័ន្ធនឹងឯកសារគតិយុត្តសាងសង់ ជួសជុល ការប្រកបអាជីវកម្មលើវិស័យសំណង់ និងសុវត្ថិភាពក្នុងការដ្ឋានសាងសង់ ចំនួន ០៣លើក ។

**គ.ការងារសំណង់បណ្តោះអាសន្នក្នុងក្រុង**

- ចូលរួមប្រជុំបូកសរុបរបាយការណ៍ស្តីពីការរុះរើសំណល់ខុសច្បាប់នៅតំបន់១ និងតំបន់២ និងប្រជុំពិភាក្សាការចុះត្រួតពិនិត្យសំណង់តំបន់១ និងតំបន់២ ដំណាក់កាលទី២ នៅអាជ្ញាធរជាតិអប្សរា ចំនួន ០២លើក ។
- ចូលរួមកិច្ចប្រជុំពិភាក្សាគម្រោងអភិវឌ្ឍដោះស្រាយសំណង់បណ្តោះអាសន្នទាំង ០៥សហគមន៍ ក្នុងក្រុងសៀមរាប នៅបន្ទប់ប្រជុំរដ្ឋបាលក្រុង ។
- សហការចុះទប់ស្កាត់ និងអនុវត្តវិធានការរុះរើចំពោះករណីចូលកាន់កាប់ដីអាជ្ញាធរជាតិអប្សរាដោះស្រាយគោលនយោបាយរួច ចំនួន ០២លើក ។
- ចូលរួមប្រជុំ និងចុះត្រួតពិនិត្យទីតាំងស្នើសុំធ្វើទីទួលសុវត្ថិភាពសម្រាប់ប្រជាជនសង្កាត់ចុងឃ្នៀស ស្ថិតនៅភូមិទី៦ សង្កាត់ចុងឃ្នៀស ។
- សហការជាមួយក្រុមមេធាវីស្ត្រី និងមេភូមិ ចុះពិនិត្យស្ថានភាពសំណង់បណ្តោះអាសន្នក្នុងភូមិទក្សិណខាងត្បូង សង្កាត់គោកចក និងភូមិទ្រាំង ភូមិមណ្ឌល៣ ភូមិចុងកៅស៊ូ សង្កាត់ស្លក្រាម ចំនួន០១លើក ។
- ចូលរួមវេទិកាជាតិស្តីពី "លំនៅឋាន" ប្រចាំឆ្នាំលើកទី៣ ចំនួន ០១លើក ។

**ឃ.ការងារសណ្តាប់ធ្នាប់សាធារណៈ**

- ចូលរួមប្រជុំ និងចុះរៀបចំសណ្តាប់ធ្នាប់ក្នុងក្រុងសៀមរាប ចំនួន ៤២លើក ។

- សហការជាមួយក្រុមការងារចម្រុះចុះរៀបចំសណ្ដាប់ធ្នាប់ក្នុងក្រុងសៀមរាប ដោយបានចែកសេចក្ដីជូនដំណឹងបានចំនួន ២១០០សន្លឹក និងធ្វើកិច្ចសន្យាជាមួយអ្នកលក់ដូរ ចំនួន ១៤៧១កន្លែង ។

**ង.កិច្ចការកសិកម្ម រុក្ខាប្រម៉ាញ់ និងនេសាទ**

- សហការចុះពិនិត្យ ជីកយកអាចម៍ដី សម្អាតមែកឈើ វាយសាបថ្ម កាត់ដើមឈើងាប់ និងដាំកូនឈើ ចំនួន ០៦លើក ។
- ចូលរួមកិច្ចប្រជុំពិភាក្សាបញ្ហាគ្រប់គ្រងត្រពាំងហោលក្រាយ នៅបន្ទប់ប្រជុំរដ្ឋបាលស្រុកពួក ចំនួន០១លើក ។

**ច.កិច្ចការប្រៃសណីយ៍ និងទូរគមនាគមន៍**

- សហការចុះត្រួតពិនិត្យករណីស្នើសុំបើកអាជីវកម្មអ៊ីនធឺណេតកាហ្វេ ស្ថិតនៅភូមិវត្តបូព៌ សង្កាត់សាលាកំរើក ។
- ចូលរួមកិច្ចប្រជុំ ចុះពិនិត្យ និងចុះរៀបចំសណ្ដាប់ធ្នាប់បណ្ដាញខ្សែកាប្លិ៍អុបទិច ការរៀបចំសណ្ដាប់ធ្នាប់ការដំឡើងស្លាកយីហោ និងផ្ទាំងផ្សព្វផ្សាយពាណិជ្ជកម្ម ក្នុងក្រុងសៀមរាប ចំនួន ០៧លើក ។

**ឆ.កិច្ចការរ៉ែ និងថាមពល**

- ចូលរួមជាវាគ្មិន និងប្រជុំពិគ្រោះយោបល់អំពីការរៀបចំបណ្ដាញអគ្គិសនីនៅផ្សារលើធំ និងការកាត់បន្ថយតម្លៃលក់អគ្គិសនីក្នុងក្រុង ចំនួន ០៣លើក ។
- សហការចុះពិនិត្យ និងទប់ស្កាត់ការសាងសង់សំណង់ស្ថាននីយ៍ប្រេងឥន្ធនៈខុសច្បាប់ ចំនួន ០២លើក ។
- ចូលរួមប្រជុំពិនិត្យលើក្រុមហ៊ុនដឹកអាចម៍ដី និងដឹកអាចម៍ដីក្នុងក្រុង ចំនួន ០២លើក ។
- សហការចុះពិនិត្យរណ្ដៅជីកដី នៅក្នុងសង្កាត់ក្របីរៀល និងសង្កាត់សៀមរាប ចំនួន០២លើក ។
- ចូលរួមវគ្គបណ្ដុះបណ្ដាលស្ដីពីការធ្វើប្រតិភូកម្មមុខងារក្នុងការផ្ដល់សេវារដ្ឋបាលពាក់ព័ន្ធនឹងវិស័យរ៉ែនិងថាមពលជូនរដ្ឋបាលថ្នាក់ក្រោមជាតិ ចំនួន ០១លើក ។
- ចូលរួមប្រជុំ និងចុះពិនិត្យពាក់ព័ន្ធនឹងការសាងសង់គ្រឹះបង្គោលអគ្គិសនី ចំនួន ០៤លើក ។

**ជ.ការងារធនធានទឹក និងឧតុនិយម**

- ចូលរួមប្រជុំសិក្សារកទីតាំងធ្វើអាងចម្រោះទឹកស្អាត និងចុះណែនាំដល់អាជីវករផ្សាររាត្រីអង្គរយ៉ុងយូរុះរើរានតូបលើប្រឡាយសាធារណៈ ចំនួន ០២លើក ។
- សហការចុះត្រួតពិនិត្យករណីស្នើសុំបង្វែរប្រឡាយទឹក ស្ថិតនៅភូមិត្រៀក សង្កាត់សៀមរាប ។
- សហការជាមួយអង្គភាពរដ្ឋាករទឹកស្វយ័តសៀមរាប ជីកដាក់បំពង់មេនាំទឹកស្អាតទំហំ ៧០០ម.ម ប្រវែង ៦.៥គ.ម តាមបណ្ដោយផ្លូវជាតិលេខ៦ ចាប់ពីផ្សារទឹកវិលដល់ផ្លូវមិត្តភាពកម្ពុជា-កូរ៉េ ។
- ចូលរួមប្រជុំពិភាក្សាលើការគ្រប់គ្រងប្រព័ន្ធលូទឹកដើម្បីត្រៀមបង្ការទឹកជំនន់នារដូវវស្សា ។
- ចូលរួមកិច្ចប្រជុំពិភាក្សាការស្ដារអាងទឹកទំនប់៧៨ និងត្រពាំងចំនួន ៣កន្លែង ចំនួន ០៣លើក ។
- ចូលរួមសិក្ខាសាលាស្ដីពីការអភិវឌ្ឍទឹកស្អាត និងអនាម័យក្នុងទីប្រជុំជនប្រកបដោយចីរភាព ។

**ឈ.កិច្ចការវប្បធម៌ និងវិចិត្រសិល្បៈ**

- សហការចុះពិនិត្យ វាស់វែងត្រពាំងស្វាយ ត្រពាំងចក ចំនួន ០៦លើក ។
- សហការចុះពិនិត្យក្បាលដីរបស់ប្រជាពលរដ្ឋ ០៧គ្រួសារ ដែលពាក់ព័ន្ធនឹងតំបន់ប្រាសាទគោកប៉ាទ្រី និងកំណត់បុរាណដ្ឋានគោកប៉ាទ្រី ស្ថិតនៅភូមិគ្រួស សង្កាត់ស្វាយដង្គំ ចំនួន ០២លើក ។
- សហការចុះរុះរើស្លាកផ្សាយពាណិជ្ជកម្មខុសច្បាប់ចំនួន ០២លើក ។

**ញ.កិច្ចការសាធារណការ និងដឹកជញ្ជូន**

- ចូលរួមមន្ទីរសាធារណការ និងដឹកជញ្ជូនខេត្ត ការិយាល័យចរាចរណ៍ផ្លូវគោកនៃស្នងការដ្ឋាននគរបាលខេត្តរៀបចំយុទ្ធនាការរឹតបណ្ដឹងការពាក់មួកសុវត្ថិភាព ចំនួន ០២លើក ។

- សហការជាមួយរដ្ឋបាលខេត្ត ស្នងការដ្ឋាននគរបាលខេត្ត មន្ទីរសាធារណការ និងដឹកជញ្ជូនខេត្ត អធិការដ្ឋាននគរបាលក្រុង សង្កាត់ និងភូមិ ចុះពិនិត្យវាស់វែងយានយន្តកែច្នៃខុសបច្ចេកទេសចំនួន ០២លើក ។
- ចូលរួមប្រជុំ និងចុះត្រួតពិនិត្យផ្លូវ ប្រឡាយ ស្ពាន លូ បណ្តាញលូប្រមូលទឹកសំណល់ ចំនួន ៣៩លើក ។
- សហការចុះពិនិត្យ វាស់វែងកំណត់បើកផ្លូវ ចំនួន ០៥លើក ។
- សហការចុះជូនដំណឹង ចុះវាស់វែងក្រឡាផ្ទៃម៉ែត្រការ៉េការ៉ូឡា តាមរុក្ខវិថីពោធិកំបោរ ចំនួន ០៣លើក ។

**ដ.កិច្ចការច្បាប់ និងសិទ្ធិមនុស្ស**

- សហការជាមួយសង្កាត់ និងភូមិ ចុះពិនិត្យទីតាំងស្នើសុំបើកគ្រឹះស្ថានមីក្រូហិរញ្ញវត្ថុ អាជីវកម្មស្នូកឃ័រ ម៉ាស្សា ភោជនីយដ្ឋាន ០៤លើក ។

**ឋ.កិច្ចការសមាគម អង្គការមិនមែនរដ្ឋាភិបាល**

- ចូលរួមវេទិកាសន្ទនារវាងវេទិកាសង្គមស៊ីវិល ( វ.ស.ស ) ជាមួយអង្គការ សមាគម សហជីព និងសហគមន៍ ខេត្តសៀមរាប ចំនួន ០១លើក ។
- ចូលរួមកិច្ចប្រជុំករណីស្នើសុំលើកស្លាកគណបក្សហ្វុនស៊ិនប៉ិច និងគណបក្សសញ្ជាតិកម្ពុជា ក្នុងក្រុងសៀមរាប ចំនួន ០១លើក ។
- ចូលរួមប្រជុំ និងចុះពិនិត្យទីតាំងការស្នើសុំបើកមជ្ឈមណ្ឌលបណ្តុះបណ្តាល និងព្រះវិហារគ្រិស្ត ចំនួន០៦លើក ។

**ឌ.ការងារសង្គមកិច្ច សាសនា និងសុខាភិបាល**

- ចូលរួមកិច្ចប្រជុំស្តីពីយុទ្ធសាស្ត្រក្នុងការទប់ស្កាត់ការប្រើប្រាស់ផលិតផលថ្នាំជក់នៅកម្ពុជា និងការបង្កើតបណ្តាញសម្ពន្ធទីក្រុងគ្មានផ្សែងបារីក្នុងចំណោមរាជធានី ខេត្ត ចំនួន០៥ នៅទីស្តីការក្រសួងសុខាភិបាល រាជធានីភ្នំពេញ។
- ចូលរួមក្នុងពិធីបើកបវេសនកាលសាលាកម្រងពុទ្ធិកៈបឋមសិក្សាវត្តប្រាសាទត្រាំនាគ ។
- ចូលរួមអមដំណើរ លោកជំទាវ គួច ណាលីន ឃឹម ប៊ុនសុង ចែកអំណោយដល់ស្ត្រីក្រីក្រសង្កាត់គោកចក នៅវត្តប្រាសាទគោកចក ។

**ឍ.ការងារបម្រែបម្រួលអាកាសធាតុ និងធនធានធម្មជាតិ**

- សហការចុះស្រង់ទិន្នន័យប្រជាពលរដ្ឋទទួលរងផលប៉ះពាល់ដោយសារខ្យល់កន្ត្រាក់ ក្នុងសង្កាត់ទឹកវិល មានចំនួនសរុប ៩៤ខ្នងផ្ទះ ក្នុងនោះរលំចំនួន ៣៧ខ្នងផ្ទះ និងរបើកដំបូលចំនួន ៥៧ខ្នងផ្ទះ ។
- សហការចុះស្រង់ទិន្នន័យខ្នងផ្ទះដែលបានលិចលង់ដោយសារទឹកជំនន់ទន្លេសាប ស្ថិតនៅភូមិភ្នំក្រោម សង្កាត់សៀមរាប មានចំនួន ១៩ខ្នងផ្ទះ ។
- ចូលរួមសិក្ខាសាលាស្តីពីលំហាត់សាកល្បងឆ្លើយតបបន្ទាន់គ្រោះអាសន្ន ចំនួន ០១លើក ។

**ណ.ការងារបេតិកភ័ណ្ឌ រមណីយដ្ឋាន និងតំបន់ប្រវត្តិសាស្ត្រ**

- ចូលរួមកិច្ចប្រជុំពិភាក្សា និងចុះពិនិត្យបញ្ហាពាក់ព័ន្ធនឹងបុរាណដ្ឋាន ចំនួន ០៤លើក ។

**ត.ការងារទេសចរណ៍**

- ចូលរួមកិច្ចប្រជុំត្រៀមរៀបចំពិធីប្រគល់ទទួលពានរង្វាន់ប្រាសាទអង្គរវត្ត ជាសំណង់ប្រវត្តិសាស្ត្រដ៏អស្ចារ្យបំផុតលើពិភពលោកសម្រាប់ឆ្នាំ២០១៨ ចំនួន ០១លើក ។
- ចូលរួមសន្និបាតបូកសរុបការងារទេសចរណ៍រដ្ឋ និងឯកជន ចំនួន ០១លើក ។

**ថ. ការងារសហការដោះស្រាយ និងសម្រុះសម្រួលទំនាស់**

- ចូលរួមប្រជុំសម្របសម្រួលទំនាស់ និងចុះពិនិត្យទីតាំង ចំនួន ១១៩លើក ។

**ទ.ផ្សេងៗ**

-ចូលរួមកិច្ចប្រជុំក្រុមប្រឹក្សាក្រុង កិច្ចប្រជុំគណៈអភិបាល កិច្ចប្រជុំគណៈបញ្ជាការឯកភាពរដ្ឋបាលក្រុង និងកិច្ចប្រជុំគណៈកម្មការលទ្ធកម្ម ចំនួន ៤២លើក ។
- ចូលរួមជាវាគ្មិននៅស្ថាននីយ៍វិទ្យុជាតិនគរភ្នំ ចំនួន ០៤លើក ។
- ចូលរួមកិច្ចប្រជុំពិភាក្សាការងារចងក្រង ទុកដាក់ឯកសារ និងរបៀបរបបរដ្ឋបាល ជាមួយគណៈប្រតិភូក្រសួងមហាផ្ទៃ ចំនួន ០១លើក ។
- ចូលរួមកិច្ចប្រជុំការងារនៃការគ្រប់គ្រងមន្ត្រីការិយាល័យ និងការចេរាចរលិខិតក្នុងការិយាល័យអភិវឌ្ឍន៍ក្រុង ចំនួន ០១លើក ។
- ចូលរួមកិច្ចប្រជុំពិភាក្សាការងារជាមួយអង្គការ អេស អូ អេស សៀមរាប ចំនួន ០១លើក ។
- ចូលរួមសិក្ខាសាលាបូកសរុបលទ្ធផល ស្តីពីការពិពណ៌នាមុខតំណែងគ្រប់គ្រង និងមុខតំណែងវិជ្ជាជីវៈរបស់រដ្ឋបាលថ្នាក់ក្រោមជាតិ ចំនួន ០១លើក ។
- ចូលរួមទិវាមច្ឆាជាតិ នៅមុខប្រាសាទអង្គរវត្ត ចំនួន ០១លើក ។
- ចូលរួមកិច្ចប្រជុំពិភាក្សាការត្រៀមរត់ម៉ារ៉ាតុន ចំនួន ០១លើក ។
- ចូលរួមកិច្ចប្រជុំសំណេះសំណាលជាមួយមន្ត្រីរាជការចំណុះ និងជំនាញជុំវិញរដ្ឋបាលក្រុង ក្រោមអធិបតីភាព លោក សូរ ប្លាតុង អភិបាលក្រុង ចំនួន ០១លើក ។
- ចូលរួមពិធីសម្ពោធបើកអោយប្រើប្រាស់ផ្លូវគ្រួសក្រហមមួយខ្សែ ស្ថិតនៅភូមិទក្សិណខាងត្បូង សង្កាត់គោកចក ចំនួន ០១លើក ។
- ចូលរួមពិធីប្រកាសចែកវិញ្ញាបនបត្រសម្គាល់ម្ចាស់អចលនវត្ថុភូមិត្រពាំងសេះ ភូមិទក្សិណខាងត្បូង និងភូមិវាល ចំនួន ០១លើក ។
- ចូលរួមសម្ពោធអគារសិក្សាសាលាវេសហ្គេតអន្តរជាតិ និងចែកលិខិតសរសើរជូនដល់សិស្សឆ្នើមចំនួន០១លើក។
- ចូលរួមក្នុងពិធីប្រកាសបិទផ្សាយជាសាធារណៈនូវឯកសារវិនិច្ឆ័យនៅភូមិខ្នារ សង្កាត់ជ្រាវ ចំនួន ០១លើក។
- ចូលរួមប្រជុំរៀបចំការអញ្ជើញមកបំពេញទស្សនកិច្ច និងរៀបចំកម្មវិធីទិវាវប្បធម៌កូរ៉េ របស់អភិបាលក្រុងស៊ូវ៉ុន ចំនួន០១លើក ។
- ចូលរួមជួបសំណេះសំណាលគណៈប្រតិភូចិន ក្រុងហានចូវនៃប្រទេសចិន ចំនួន ០១លើក។
- ចូលរួមដង្ហែអដ្ឋិធាតុ ឯកឧត្តមសាស្ត្រាចារ្យ បេអាតរិចណឺ នៅមន្ទីរពេទ្យគន្ធបុប្ផា ចំនួន ០១លើក។

**១.៤.២ ការអនុវត្តមុខងារផ្សេងៗ ( មិនទាន់មានប្រតិភូកម្ម )**

**១.៤.៣ ការដោះស្រាយទំនាស់**

**ក. ការដោះស្រាយ និងសម្រុះសម្រួលទំនាស់ក្នុងដែនសមត្ថកិច្ចរដ្ឋបាលក្រុង**

ក្នុងរយៈពេលមួយឆ្នាំ២០១៨នេះ រដ្ឋបាលក្រុងសៀមរាបបានដោះស្រាយរឿងរួចរាល់ ចំនួន **០៣ករណី** បញ្ជូនទៅស្ថាប័នពាក់ព័ន្ធ ចំនួន **០៣ករណី** និងកំពុងដោះស្រាយ មានចំនួន **១២ករណី** ក្នុងនោះ ៖

➢ **រឿងដោះស្រាយរួចរាល់នៅរដ្ឋបាលក្រុង មាន ០៣ករណី**

១. ករណីឈ្មោះ **អេង ហេងលី** ប្តឹងឈ្មោះ **មៃ កក្កដា** រំលោភលើកិច្ចសន្យាលក់សិទ្ធិផ្តាច់មុខលើគំនូរនៅលើកែវពែង និងចាន ។

២. ករណីឈ្មោះ **ស្រែន លី** ប្តឹងឈ្មោះ **ចាន់ វណ្ណា** ជេរប្រមាថ និងប្រមាថសម្លាប់ នៅភូមិកក្រាញ់ សង្កាត់សៀមរាប។

៣. ករណីឈ្មោះ **ហេង សឿម** ប្តឹងឈ្មោះ **ធុំ វ៉ាន់ណារ៉ូ** ប្រពន្ធឈ្មោះ ស្រី ម៉ាច ជំពាក់ប្រាក់ចំនួន ៤០០០$ គេចវេសមិនព្រមសង ស្ថិតនៅភូមិវត្តស្វាយ សង្កាត់សាលាកំរើក ។

៤. ករណីឈ្មោះ **ជា អន** ស្នើសុំជួយសម្របសម្រួលដោះស្រាយករណីឈ្មោះ **ហ៊ិន គឹមសួង** ធ្វើកន្លែងស្តុកកាកសំណល់សំរាមនៅមុខផ្ទះ ដែលបង្កក្លិនស្អុយប៉ះពាល់សុខភាព ស្ថិតនៅភូមិបន្ទាយចាស់ សង្កាត់ស្លក្រាម ។
៥. ករណីឈ្មោះ **រឿង ហេង** ប្តឹងជំទាស់មិនឲ្យភ្ជាប់បណ្តាញអគ្គិសនីសម្រាប់ នៅភូមិរហាល សង្កាត់នគរធំ។
៦. ករណីឈ្មោះ ធុំ វណ្ណរ៉ូ ប្តឹងឈ្មោះ ផន ផល្លី ជំពាក់ប្រាក់ចំនួន ២៤៧០$ នៅភូមិស្ពានជ្រាវ សង្កាត់សៀមរាប។
៧. ករណីសណ្ឋាគារ អាណាន់តារា អង្គរ រីហ្សេត ស្នើសុំអន្តរាគមន៍ចំពោះការរំខានពីការប្រគុំតន្ត្រីរបស់ ក្រុមហ៊ុន Box Ville ស្ថិតនៅភូមិគ្រួស សង្កាត់ស្វាយដង្គំ ។
៨. ករណីប្រជាពលរដ្ឋចំនួន០៦គ្រួសារ ស្នើសុំសាងសង់ផ្លូវ០១ខ្សែ នៅភូមិត្រពាំងត្រែង សង្កាត់សាលាកំរើក។
៩. ករណីឈ្មោះ អ៊ុន អ៊ាម ប្តឹងទាមទារប្រាក់ចំនួន ៧០០$ ពីឈ្មោះ លុយ ស៊ីណាន ស្ថិតនៅភូមិសណ្តាន់ សង្កាត់ទឹកវិល ។
១០. ករណីឈ្មោះ នី វុទ្ធី ប្តឹងសុំឲ្យឈ្មោះ ណៃ ណម និងប្រពន្ធឈ្មោះ ធុន អ៊ុស សងប្រាក់បណ្ណាការចំនួន ៥៥៥០$ និងប្តឹងសុំផ្តាច់ទំនាក់ទំនងជាមួយនឹងឈ្មោះ ណៃ ណិត នៅភូមិគោកក្រសាំង សង្កាត់ស្វាយដង្គំ ។
១១. ករណីឈ្មោះ ជឿន សារី ស្នើសុំជួយអន្តរាគមន៍ទប់ស្កាត់ និងដោះស្រាយសំណងពាក់ព័ន្ធនឹងការធ្វើផ្លូវដីស ០១ខ្សែ ស្ថិតនៅភូមិស្ពានជ្រាវ សង្កាត់សៀមរាប ។
១២. ករណីឈ្មោះ ង៉ូវ ហ៊ួយម៉ាន់ ប្តឹងឈ្មោះ ធុយ ចិន្តា ជំពាក់ប្រាក់ចំនួន ៣០.០០០$ និងទាមទារសំណង ជំងឺចិត្តចំនួន ៥.០០០$ ស្ថិតនៅភូមិគ្រួស សង្កាត់ស្វាយដង្គំ ។
១៣. ករណីទំនាស់ច្រកចេញចូលរវាងឈ្មោះ ស្រី ភាស និងឈ្មោះ ល័យ វាសនា ស្ថិតនៅភូមិបន្ទាយចាស់ សង្កាត់ស្លក្រាម ។ ( ភាគីដកពាក្យបណ្តឹងទៅប្តឹងនៅតុលាការ និងបានដោះស្រាយចប់នៅតុលាការ )
១៤. ករណីឈ្មោះ វ៉េង ហុង ស្នើសុំអន្តរាគមន៍បញ្ឈប់ការលក់គ្រឿងកាឡៃក្នុងទីតាំងតូបលក់គ្រឿងក្រអូបរបស់អ្នកស្រី សារុន រស្មី ដែលបានជួលពី អ្នកស្រី ស៊ិន រ៉ាទី និងអ្នកស្រី ស៊ិន រ៉ាវី នៅផ្សារលើធំថ្មី ។ ( ភាគីចុងចម្លើយយល់ព្រមបញ្ឈប់ការលក់តាមការសម្របសម្រួលរបស់គណៈកម្មការផ្សារ ដោយស្នើសុំលក់បន្តរហូតដល់ចប់កិច្ចសន្យាជួលតូប ក្នុងខែធ្នូ ឆ្នាំ២០១៨ នេះ )
១៥. ករណីសំណើសុំជួយអន្តរាគមន៍ទប់ស្កាត់ និងរុះរើសំយាបផ្ទះរបស់ លី ណៃ ដែលសាងសង់រំលោភចូលដីកម្មសិទ្ធិរបស់ឈ្មោះ សោ ប៊ុនធី ស្ថិតនៅភូមិវត្តបូព៌ សង្កាត់សាលាកំរើក ។ ( ភាគីចុងចម្លើយយល់ព្រមរុះរើសំយាបចេញអស់ កាលពីថ្ងៃទី០៧ ខែកញ្ញា ឆ្នាំ២០១៨ )
១៦. ករណីម្ចាស់ផ្ទះសំណាក់ត្រូពិចខលប្រើស ប្តឹងម្ចាស់ផ្ទះសំណាក់ដោនថោន ដែលដាក់សំរាមលើផ្លូវសាធារណៈ និងមានក្លិនស្អុយ ស្ថិតនៅភូមិវត្តដំណាក់ សង្កាត់សាលាកំរើក ។
១៧. ករណីម្ចាស់សណ្ឋាគារស្រអែមសៀមរាប ប្តឹងភោជនីយដ្ឋានចំនួន ០៣ រួមមាន ភោជនីយដ្ឋានម្លប់ជ្រៃត្រជាក់ចិត្ត ភោជនីយដ្ឋានម្លប់ដូងសៀមរាប និងភោជនីយដ្ឋានស្នាដៃម៉ែក្មេក៥ អំពីការរំពងសំឡេងខ្លាំងធ្វើឲ្យរំខានដល់ការស្នាក់នៅក្នុងសណ្ឋាគារ ស្ថិតនៅភូមិសាលាកន្សែង សង្កាត់ស្វាយដង្គំ ។
១៨. ករណីឈ្មោះ ជា កឿន ស្នើសុំជួយបើកផ្លូវរទេះចាស់ទំហំ ៣មx២៥ម ស្ថិតនៅភូមិអារញ្ញ សង្កាត់សៀមរាប ។ (ក្រុមការងារចុះអនុវត្តរុះរើបើកផ្លូវរួចរាល់)
១៩. ករណីឈ្មោះ អ៊ុន ប៊ុនធី ស្នើសុំជួយអន្តរាគមន៍ឈ្មោះ វ៉េង ហ៊ាង បានសាងសង់សំណង់ផ្សេងៗនៅលើចំណីផ្លូវ និងប៉ះពាល់ដល់ក្បាលដីរបស់គាត់ ស្ថិតនៅភូមិកក្រាញ់ សង្កាត់សៀមរាប ។ (ក្រុមការងារចុះ អនុវត្តរុះរើតូបទាំង ០២កន្លែង ចេញពីលើដីចំណីផ្លូវសាធារណៈរួចរាល់)
២០. ករណីឈ្មោះ ហែម ធារី ប្តឹងឈ្មោះ មាស យី យកដាក់សម្ភារ ដាំដំណាំ និងធ្វើរោងភ្ជាប់នឹងបង្គោលភ្លើងនៅលើដីចំណីផ្លូវ បាំងផ្លូវចូល ស្ថិតនៅភូមិសណ្តាន់ សង្កាត់ទឹកវិល ។

- **រឿងដែលបានបញ្ជូនទៅស្ថាប័នពាក់ព័ន្ធ មានចំនួន ០៧ករណី ៖**
  1. ករណីសាងសង់សំណង់ប្រាសាទ និងកស្សិណទឹកប្រាសាទត្រាំនាគ ចូលដីរបស់លោក **ម៉ោ ឈុនស្រេង** ស្ថិតនៅភូមិធ្លកអណ្តូង សង្កាត់ស្លក្រាម ។
  2. ករណីឈ្មោះ **អ៊ឹម ពៅពន្លក** ស្នើសុំជួយអន្តរាគមន៍សាងសង់របង ស្ថិតនៅភូមិវិហារចិន សង្កាត់ស្វាយដង្គំ ដោយមានការជំទាស់ពីឈ្មោះ **ព្រំ សុវណ្ណរ័ត្នន៍** ។ ( បញ្ជូនទៅរដ្ឋបាលខេត្ត )
  3. ករណីឈ្មោះ វ៉ាន់ សំបូរ ស្នើសុំបើកផ្លូវចូលផ្ទះ នៅភូមិវិហារចិន សង្កាត់ស្វាយដង្គំ ។ ( បានណែនាំឲ្យម្ចាស់បណ្តឹងដាក់ពាក្យទៅតុលាការ )
  4. ករណីឈ្មោះ ឆុំ វណ្ណារ៉ូ ប្តឹងឈ្មោះ ផន ផល្លី ជំពាក់ប្រាក់ចំនួន ១៣០០$ នៅភូមិស្ពានជ្រាវ សង្កាត់សៀមរាប។ ( បានប្រជុំសម្របសម្រួល ចំនួន ០៣លើក ភាគីទាំងពីរស្ម័គ្រចិត្តបន្តការដោះស្រាយនៅស្ថាប័នផ្សេង )
  5. ករណីទំនាស់ដីធ្លីរវាងម្តាយឈ្មោះ **ទៀង ចំរើន** និងកូនបង្កើតឈ្មោះ **ភោគ សុភា** ស្ថិតនៅភូមិពោធិបន្ទាយជ័យ សង្កាត់សៀមរាប ។ (បានប្រជុំសម្របសម្រួល ចំនួន ០២លើក ភាគីម្តាយទាមទារដីចំនួន ៥០% នៃចំណែកដីទាំងមូល និង ៥០%ទៀត បែកចែកឲ្យកូនប្រុសស្រីចំនួន ០២នាក់ ដោយឡែកកូនប្រុសឈ្មោះ **ភោគ សុភា** ជំទាស់ ដោយយល់ព្រមបែងចែកឲ្យម្តាយចំនួន ៣០% ទុកសម្រាប់ខ្លួនចំនួន ៧០% ។ ភាគីទំនាស់ពុំស្រុះស្រួលគ្នា ដូចនេះរដ្ឋបាលក្រុងណែនាំឲ្យដាក់ពាក្យបណ្តឹងបន្ត)
  6. ករណីឈ្មោះ **ប៉ាន់ ជា , ឡាយ សំណាង** និង **ស្រី សុភា** ប្តឹងសុំជួយអន្តរាគមន៍ទប់ស្កាត់ និងដោះស្រាយចំពោះឈ្មោះ **មឿន ឡេង** ប្តីឈ្មោះ **លី ចាន់ផល** ប៉ុនប៉ងដណ្តើមទាមទារយកដី ស្ថិតនៅភូមិអញ្ចាញ សង្កាត់នគរធំ ។ (បានបញ្ជូនសំណុំរឿងទៅគណៈកម្មការសុរិយោដីក្រុងសៀមរាប ដើម្បីដោះស្រាយ )
  7. ករណីឈ្មោះ **លឹម វ៉ាន់នី** ប្តឹងសុំទាមទារដីមួយកន្លែងទំហំ ២០មx៤០ម ស្ថិតនៅភូមិអញ្ចាញ សង្កាត់នគរធំ ។ (បានបញ្ជូនសំណុំរឿងទៅគណៈកម្មការសុរិយោដីក្រុងសៀមរាប ដើម្បីដោះស្រាយ )
- **រឿងកំពុងដោះស្រាយ មានចំនួន ១២ករណី ៖**
  1. ករណីប្រជាពលរដ្ឋភូមិដកពោធិ៍ សង្កាត់ស្លក្រាម ប្តឹងសុំអន្តរាគមន៍ចំពោះម្ចាស់ផ្ទះទាំងអស់ដែលបានយកផ្លូវសាធារណៈដើម្បីជួលទៅឲ្យអាជីវករលក់ដូរតាមបណ្តោយផ្លូវខាងលិចផ្សារលើធំថ្មី។ ( បានចុះចែកសេចក្តីជូនដំណឹងឲ្យរុះរើសំយ៉ាប និងបញ្ឈប់ការជួលលក់ )
  2. ករណីសំណើសុំជួយអន្តរាគមន៍ទប់ស្កាត់ការបិទផ្លូវចេញចូលដោយឈ្មោះ **សុខ សារ៉េន** នៅភូមិស្វាយព្រៃ សង្កាត់ស្វាយដង្គំ ។ ( បានចុះទៅត្រួតពិនិត្យចំនួន ០១លើក )
  3. ករណីឈ្មោះ **ជឿន ជាន** ស្នើសុំជួយអន្តរាគមន៍បើកផ្លូវសាធារណៈចំនួន ០១ខ្សែ ស្ថិតនៅភូមិតាគុល សង្កាត់ស្វាយដង្គំ ។ ( បានចុះទៅពិនិត្យចំនួន ០២លើក និងប្រជុំសម្របសម្រួលចំនួន ០៣លើក ។ ក្បាលដីចំនួន ១៤ក្បាលដី ពាក់ព័ន្ធនឹងការបើកផ្លូវនេះ ក្នុងនោះក្បាលដីចំនួន ១៣ក្បាលដី បានឯកភាពបើកផ្លូវ ដោយឡែក ០១ក្បាលដីទៀត ពុំទាន់ឯកភាព )
  4. ករណីឈ្មោះ **ជឹម សម្បត្តិ , ឡោ គឹមឡឹង និង ជឹម ចាន់ធឿន** សុំអន្តរាគមន៍ឈ្មោះ **ដួង សុខា , ឡូ ម៉េង , វ៉ាន់ រ៉ាឌី និង យន់ ប៊ុនហឿន** សាងសង់របងរំលោភដីផ្លូវសាធារណៈ នៅភូមិធ្លកអណ្តូង សង្កាត់ស្លក្រាម។ ( បានចុះពិនិត្យ និងវាស់វែងចំនួន ០២លើក និងប្រជុំសម្របសម្រួល ចំនួន ០៤លើក ភាគីចុងចម្លើយ ដួង សុខា , វ៉ាន់ រ៉ាឌី និង យន់ ប៊ុនហឿន បានឯកភាពរុះរើរបងថ្មតាមជើងម៉ែត្ររបស់មន្ទីរ ដោយឡែកឈ្មោះ ឡូ ម៉េង មិនមកចូលរួមដោះស្រាយ រដ្ឋបាលក្រុងបានចេញសេចក្តីជូនដំណឹងដល់ក្បាលដីពាក់ព័ន្ធ ១៣ ក្បាលដី ឲ្យរុះរើរបងដែលចូលដីផ្លូវសាធារណៈ)

៥. ករណីឈ្មោះ **កែវ ស្រណោះ** ស្នើសុំបើកផ្លូវទំហំ ០៤មx២០ម ដែលឈ្មោះ **នូ សុជាតា** សាងសង់ផ្ទះលើដីផ្លូវគ្រោង ១៥ម៉ែត្រ នៅភូមិធ្លកអណ្តូង សង្កាត់ស្លក្រាម។ ( បានប្រជុំសម្របសម្រួល ចំនួន ០៥លើក ភាគីចុងចម្លើយស្នើសុំពិចារណាមួយរយៈពេល)

៦. ករណីឈ្មោះ **ហៀន ហន** សុំប្តឹងឈ្មោះ **ឡឹក វណ្ណនី** និងឈ្មោះ **វណ្ណ សិទ្ធិ** បានរស់នៅលើដីរបស់ ឈ្មោះ **ហៀន ហន** នៅភូមិត្រពាំងសេះ សង្កាត់គោកចក ។ (បានប្រជុំសម្របសម្រួល ចំនួន ០២លើក ភាគីដើមបណ្តឹងស្នើសុំទំហំដី ១,៥ម៉ែត្រ ដើម្បីទុកផ្លូវចេញចូល ដោយឡែកភាគីចុងបណ្តឹងអវត្តមានមិនបានមកចូលរួម ដូចនេះរង់ចាំអញ្ជើញមកដោះស្រាយម្តងទៀត )

៧. ករណីឈ្មោះ **សោម សារឿន** សុំប្តឹងឈ្មោះ **សូ ម៉ាន់លីស** បានធ្វើសំណង់ដែកកត់ផ្ទលើផ្លូវសាធារណៈ ប្រវែងទទឹង ០៦ម៉ែត្រ និងបណ្តោយ ៩០ម៉ែត្រ ស្ថិតនៅភូមិគ្រួស សង្កាត់ស្វាយដង្គំ ។ (បានប្រជុំសម្របសម្រួល ចំនួន ០១លើក ភាគីដើមបណ្តឹងស្នើសុំឲ្យរដ្ឋបាលក្រុង ចុះពិនិត្យបើកផ្លូវទៅតាមជើងម៉ែត្រដែលបានកំណត់ ដោយឡែកភាគីចុងបណ្តឹងមានគោលជំហរថាបើបើកផ្លូវ គឺត្រូវបើកទាំងអស់ )

៨. ករណីឈ្មោះ **ហែម ធារី** ស្នើសុំជួយអន្តរាគមន៍ឈ្មោះ **មាស យី** បានយកសម្ភារដាក់លើផ្លូវ ដាំដំណាំ និងធ្វើរោង លើផ្លូវសាធារណៈ ធ្វើឲ្យប៉ះពាល់ដល់ការធ្វើដំណើរ ស្ថិតនៅភូមិសណ្តាន់ សង្កាត់ទឹកវិល ។ (បានចុះពិនិត្យចំនួន ០១លើក ឈ្មោះ មាស យី ពុំព្រមរុះរើ)

៩. ករណីឈ្មោះ ដួង ពៅ ប្តឹងឈ្មោះ ម៉ៅ វុទ្ធី និងឈ្មោះ ង៉ាម រុំ ឲ្យរុះរើផ្ទះ និងចេញពីដីរបស់ឈ្មោះ ដួង ពៅ ស្ថិតនៅភូមិទ្រាំង សង្កាត់ស្លក្រាម ។

១០. ករណីឈ្មោះ ហា ម៉ុង អេ ជាម្ចាស់ភោជនីយដ្ឋាន ឌាបាក់រេសឺរេន ប្តឹងភោជនីយដ្ឋាន ប៊ិចឌាបាក់ ឲ្យរុះរើស្លាកយីហោឈ្មោះ ឌាបាក់រេសចឺរេន ជាភាសាកូរ៉េ ចេញពីទីតាំងភោជនីយដ្ឋាន ប៊ិចឌាបាក់ ស្ថិតនៅ ភូមិមណ្ឌល២ សង្កាត់ស្វាយដង្គំ ។

១១. ករណីឈ្មោះ ចាន់ សុខា , គឹម ច័ន្ទបូរ៉ាវី , ញឹក ចន្ទូ និង ញឹក ចាន់វត្តី ស្នើសុំជួយអន្តរាគមន៍លើករណីស្តុកធុងហ្គាសបន្ត របស់លោក លឹម គង់ (ហៅ សាន់ ហ្វាយ) នៅភូមិសាលាកន្សែង សង្កាត់ស្វាយដង្គំ។

១២. ករណីឈ្មោះ សុមន៍ សុវណ្ណ , ជុំ សំបូរ , ឡាច សុកឡុង និង គល់ ម៉ានីត ស្នើសុំពិនិត្យរកការពិត និងផ្តល់យុត្តិធម៌ដល់ពួកគាត់ ដែលរដ្ឋបាលសង្កាត់ស្លក្រាមបានចេញលិខិតឲ្យពួកគាត់រុះរើផ្ទះចេញ ដោយសម្អាងទៅលើអាជ្ញាធរអប្សរាបានដោះស្រាយគោលនយោបាយរួចរាល់ នៅភូមិធ្លកអណ្តូង សង្កាត់ស្លក្រាម ។

**តារាងទី១៣៖ ការសម្រុះសម្រួលទំនាស់**

| ល.រ | ការបរិយាយ | ចំនួន |
|---|---|---|
| ១ | ករណីដែលបានសម្រុះសម្រួលបញ្ចប់ដោយរដ្ឋបាលក្រុង | ១០ |
| ២ | ករណីដែលបញ្ជូនទៅស្ថាប័នពាក់ព័ន្ធ | ២ |
| សរុប | | ១២ |

### ១.៤.៤-កិច្ចការច្រកចេញចូលតែមួយ៖

**តារាងទី១៤ ៖ កិច្ចការច្រកចេញចូលតែមួយ( គិតជារៀល )**

| ល.រ | ការបរិយាយ | ចំនួន |
|---|---|---|
| ១ | សេវាសរុបដែលបានផ្តល់ចប់សព្វគ្រប់ | ៦២ ០៥១ |
| ២ | ប្រជាពលរដ្ឋសរុបដែលបានទទួលសេវា | ៦១ ២១១ |
| ៣ | ប្រជាពលរដ្ឋជាស្ត្រីដែលបានទទួលសេវា | ២២ ៦៧១ |

| | | |
|---|---|---|
| ៤ | ចំណូលដែលទទួលបានពីការផ្តល់សេវា | ៤២៩ ២៧៦ ០០០ |
| ៥ | ប្រាក់រង្វាន់ដែលបានបែងចែក | ៣៣៨ ៤១៩ ៦១៩ |
| ៦ | ករណីបណ្តឹងដែលទទួលបានសរុប | ១២២ |
| ៧ | ករណីបណ្តឹងដែលបានដោះស្រាយរួចជាស្ថាពរ | ៣៥ |

## ១.៤.៥-កិច្ចការសេវាសង្គម និងការបង្កើនសិទ្ធិអំណាចស្ត្រី

### តារាងទី១៥៖ ការអនុវត្តសកម្មភាពសេវាសង្គម និងការងាររបស់គ.ក.ស.ក

| ល.រ | សូចនាករ | ផែនការប្រចាំឆ្នាំ | លទ្ធផលសម្រេច | |
|---|---|---|---|---|
| | | | ជាក់ស្តែង | % |
| ១ | ចំនួនកិច្ចប្រជុំប្រចាំខែរបស់ គ.ក.ស.ក នៅថ្នាក់ក្រុង | 14 | 10 | 71.42% |
| ២ | ចំនួនថវិកាប្រចាំឆ្នាំសម្រាប់ចំណាយលើផ្នែកសេវាសង្គម | 0 | 0 | 0 |
| ៣ | ក្រុងបានចងក្រងទិន្នន័យអត្រានុកូលដ្ឋាន ដែលទទួលបានពីសង្កាត់ | 0 | 0 | 0 |
| ៤ | ចំនួនបេសកកម្មដែល គ.ក.ស.ក ក្រុង បានចុះគាំទ្រ និងផ្តល់សេវាសង្គម | 178 | 165 | 92.69% |
| ៥ | ចំនួនសង្កាត់ដែល គ.ក.ស.ក ក្រុងបានចុះគាំទ្រ | 12 | 12 | 100% |
| ៦ | ចំនួនវគ្គបណ្តុះបណ្តាលដែល គ.ក.ស.ក ក្រុង បានទទួល | 0 | 0 | 0 |

## ១.៥-ការងារហិរញ្ញវត្ថុ

### តារាងទី១៦ ៖ ការអនុវត្តចំណូល និងចំណាយ

| ជំពូក | ចំណាត់ថ្នាក់ | អនុម័ត | ជាក់ស្តែង | ភាគរយ |
|---|---|---|---|---|
| **ផ្នែកចំណូល** | | | | |
| ៧០ | ចំណូលសារពើពន្ធ | 0 | 0 | 0 |
| ៧២ | ផលទុននៃទ្រព្យសម្បត្តិរដ្ឋ | 0 | 0 | 0 |
| ៧៣ | ផលទុនលើការលក់-ជួលទ្រព្យសម្បត្តិនិងសេវា | 394 880 000 | 294 494 740 | 74.57% |
| ៧៤ | ផលពីការពិន័យ និងការដាក់ទណ្ឌកម្ម | | | |
| ៧៥ | ការឧបត្ថម្ភកធន | 4 851 810 000 | 5 248 509 834 | 108.18% |
| ៧៦ | ផលហិរញ្ញវត្ថុ | 0 | 0 | 0 |
| ៧៧ | ផលផ្សេងៗ និងផលពិសេស | 0 | 0 | 0 |
| ៧៨ | ការងារនៃរដ្ឋទេយ្យ | 0 | 0 | 0 |
| ០៨ | ចំណូលមូលនិធិបម្រុង | 0 | 0 | 0 |
| ១៣ | ឧបត្ថម្ភកធន-វិនិយោគ | 0 | 0 | 0 |
| **សរុបចំណូល** | | 5 246 690 000 | 5 543 004 574 | 105.65% |
| **ផ្នែកចំណាយ** | | | | |
| ៦០ | ការទិញ | 116 600 000 | 63 651 150 | 54.59% |
| ៦១ | សេវាខាងក្រៅ | 120 400 000 | 409 360 288 | 340% |
| ៦២ | អត្ថប្រយោជន៍សង្គម | 3 000 000 | 3 000 000 | 100% |
| ៦៣ | ពន្ធ និងអាករ | 0 | 0 | 0 |
| ៦៤ | បន្ទុកបុគ្គលិក | 1 354 600 000 | 869 807 670 | 64.21% |
| ៦៥ | ឧបត្ថម្ភកធននិងជំនួយសង្គម | 3 602 690 000 | 3 602 690 000 | 100% |

| ជំពូក | ចំណាត់ថ្នាក់ | អនុម័ត | ជាក់ស្តែង | ភាគរយ |
|---|---|---|---|---|
| ៦៦ | បន្ទុកហិរញ្ញវត្ថុ | | | |
| ៦៧ | បន្ទុកពិសេស | | | |
| ៦៨ | ទាយជ្ជទានឲ្យដល់រំលោះអចលកម្មរូបី | | | |
| ៦៩ | ចំណាយមិនបានគ្រោងទុក | 49 400 000 | 0 | 0 |
| ២០ | អចលកម្មអរូបី | 0 | 0 | 0 |
| ២១ | អចលកម្មរូបី | 0 | 0 | 0 |
| **សរុបចំណាយ** | | 5 246 690 000 | 4 948 509 108 | 94.32% |

### ១.៥.២.ការគ្រប់គ្រងទ្រព្យសម្បត្តិ

**តារាងទី១៧៖ ការគ្រប់គ្រងទ្រព្យសម្បត្ត**

| ល.រ | ការបរិយាយ | ចំនួន |
|---|---|---|
| ១ | ទ្រព្យសម្បត្តិ ដែលបានទិញ ឬទទួល (ថ្មី) | 0 |
| ២ | ទ្រព្យសម្បត្តិ ដែលបានកាត់ចេញ | 0 |
| ៣ | ទ្រព្យសម្បត្តិសរុប | 0 |

### ១.៦- <u>ការងារលទ្ធកម្ម</u>

**១. ស្ថានភាពទូទៅ**

សមាសភាពគណៈកម្មាធិការលទ្ធកម្ម និង អង្គភាពលទ្ធកម្ម

- សមាសភាពគណៈកម្មាធិការលទ្ធកម្ម មានចំនួន ៖ ០៨ នាក់ ស្រី ០២ នាក់
- សមាសភាពអង្គភាពលទ្ធកម្ម មានចំនួន ៖ ០៣ នាក់ ស្រី ០១ នាក់

**២. ការងារបុគ្គលិក**

១. លោក ប៊ូ រតនា ប្រធាន ២. កញ្ញា ពេញ មករា អនុប្រធាន ៣. លោក ទ្រី សុវណ្ណារ៉ា មន្ត្រី

**៣. លទ្ធផលការងារសម្រេចបាន**

- បានចុះកិច្ចសន្យារវាងរដ្ឋបាលក្រុងសៀមរាបជាមួយក្រុមហ៊ុន អ៊ែកជីវ ហ្គ្រីន ស៊ីធី ឯ.ក ស្តីពីការងារប្រមូលដឹកជញ្ជូនសំណល់រឹងរាវ ក្រុងសៀមរាប (សេវាអនាម័យបរិស្ថាន) ដែលមានទឹកប្រាក់នៃតម្លៃកិច្ចសន្យាចំនួន ៧៥៦,០០០,០០០ (ប្រាំពីររយហាសិបប្រាំមួយលាន រៀលគត់) ទាបជាងឥណទានជានាចំណាយចំនួន ៣៥,០០០,០០០ (សាមសិបប្រាំលាន រៀលគត់) ជូនរដ្ឋបាលក្រុងសៀមរាប។
- បានចុះប្រជុំចរចាថ្លៃរវាងរដ្ឋបាលក្រុងសៀមរាបជាមួយក្រុមហ៊ុន អ៊ែកជីវ ហ្គ្រីន ស៊ីធី ឯ.ក ស្តីពីការងារប្រមូលនិងដឹកជញ្ជូនសំណល់រឹងរាវ ក្រុងសៀមរាប (សេវាអនាម័យបរិស្ថានបន្ថែម) ជូនរដ្ឋបាលក្រុងសៀមរាប ដោយមានការចូលរួមពីគណៈកម្មាធិការលទ្ធកម្មក្រុង ផងដែរ។
- បានចុះកិច្ចសន្យារវាងរដ្ឋបាលក្រុងសៀមរាបជាមួយក្រុមហ៊ុន អ៊ែកជីវ ហ្គ្រីន ស៊ីធី ឯ.ក ស្តីពីការងារប្រមូលនិងដឹកជញ្ជូនសំណល់រឹងរាវ ក្រុងសៀមរាប (សេវាអនាម័យបរិស្ថានបន្ថែម) ដែលមានទឹកប្រាក់នៃតម្លៃកិច្ចសន្យាចំនួន 60,523,000 (ហុកសិបលាន ប្រាំរយម្ភៃបីពាន់ រៀលគត់ ) ទាបជាងឥណទានជានាចំណាយចំនួន ១,២១៧,០០០ (មួយលាន ពីររយដប់ប្រាំពីរពាន់ រៀលគត់) ជូនរដ្ឋបាលក្រុងសៀមរាប។
- ចុះកិច្ចសន្យារវាងរដ្ឋបាលក្រុងសៀមរាបជាមួយក្រុមហ៊ុន កម្ពុជាតេលា ស្តីពីកាផ្គត់ផ្គង់ទំនិញ (ប្រេងឥន្ទនៈ) ដែលមានទឹកប្រាក់នៃតម្លៃកិច្ចសន្យា ចំនួន៣៨.៩៣២.៥០០ (សាមសិបប្រាំបីលាន ប្រាំបួនរយសាមសិបពីរពាន់ ប្រាំរយរៀលគត់) ដែលទាបជាងឥណ ទានជានាចំណាយ ចំនួន ៦,០៦៧.៥០០ (ប្រាំមួយលាន

ហុកសិបប្រាំពីរពាន់ ប្រាំរយ រៀលគត់) និងបានចុះកិច្ចសន្យារវាងរដ្ឋបាលក្រុងសៀមរាបជាមួយក្រុមហ៊ុន សករាជខនស្ត្រាក់សិន ស្តីពីការផ្គត់ផ្គង់ទំនិញ (សម្ភារៈការិយាល័យ) មានទឹកប្រាក់នៃតម្លៃកិច្ចសន្យាចំនួន ២០,៩៣៧,០០០ (ម្ភៃលាន ប្រាំបួនរយសាមសិបប្រាំពីរពាន់ រៀលគត់) ដែលទាបជាងឥណទានជានាចំណាយ ចំនួន ៦៣,០០០ (ហុកសិបបីពាន់ រៀលគត់) ជូនរដ្ឋ បាលក្រុងសៀមរាប។

- បានដាក់ចេញនូវលិខិតស្នើសុំសន្យាចំណាយលើគម្រោងផ្លូវបេតុងអាមេ៣ខ្សែ នៅភូមិតាវៀន សង្កាត់សាលាកំរើក ភូមិធ្លកអណ្តូង សង្កាត់ស្លក្រាម និងភូមិថ្មី សង្កាត់ស្វាយដង្គំ ក្រុងសៀមរាប ដែលមានទឹកប្រាក់ជានាចំណាយសរុបចំនួន ២៤២,៣០៥,៨៨០ (ពីររយសែសិបពីរលាន បីរយប្រាំពាន់ ប្រាំបីរយប៉ែតសិប រៀលគត់)។
- បានរៀបចំឯកសារដេញថ្លៃប្រកួតប្រជែងជាសាធារណៈ ការងារជួសជុលនិងកែលំអផ្លូវបេតុងអាមេ០៣ខ្សែ។
- បានផ្ញើសំណើទៅមន្ទីរសេដ្ឋកិច្ចហិរញ្ញវត្ថុ អំពីករណីសុំផ្តល់ទិដ្ឋាការលើឯកសារដេញថ្លៃលើគម្រោងផ្លូវបេតុងអាមេរបស់រដ្ឋបាលក្រុងសៀមរាប។
- បានដាក់ចេញនូវលិខិតស្នើសុំសន្យាចំណាយ លើគម្រោងលូរំដោះទឹក១កន្លែង ប្រវែង១២៧ម៉ែត្រ មុខកាត់១ម៉ែត្រ ស្ថិតនៅភូមិតាវៀន សង្កាត់សាលាកំរើក ក្រុងសៀមរាប ដែលមានទឹកប្រាក់ជានាចំណាយ សរុបចំនួន ៣១,៩៩៨,៨២០ (សាមសិបមួយលាន ប្រាំបួនរយកៅសិបប្រាំបីពាន់ ប្រាំបីរយម្ភៃ រៀលគត់) ។
- បានស្នើសុំគោលការណ៍ទៅមន្ទីរសេដ្ឋកិច្ចនិងហិរញ្ញវត្ថុខេត្ត ដើម្បីធ្វើលទ្ធកម្មដោយឡែក ដោយចុះកិច្ចសន្យាផ្ទាល់ជាមួយក្រុមហ៊ុនសករាជ ខនស្ត្រាក់សិន លើគម្រោងផ្គត់ផ្គង់សម្ភារការិយាល័យ និងបរិក្ខារបច្ចេកទេសព័ត៌មានវិទ្យា ដែលមានទឹកប្រាក់ចំនួន ៣៣,១៥០,០០០ (សាមសិបបីលាន មួយរយហាសិបពាន់ រៀលគត់)
- បានចុះកិច្ចសន្យារវាងរដ្ឋបាលក្រុងសៀមរាបនិងក្រុមហ៊ុន ហ៊្សួរ ឆូយ លើគម្រោងផ្លូវបេតុងអាមេ ចំនួន៣ខ្សែ ក្នុងនោះរួមមាន៖

  ១. កំណាត់ផ្លូវទី១ ស្ថិតក្នុងភូមិតាវៀន សង្កាត់សាលាកំរើក (ប្រវែង១៩៤ម ទទឹង៥ម) ។

  ២. កំណាត់ផ្លូវទី២ ស្ថិតក្នុងធ្លកអណ្តូង សង្កាត់ស្លក្រាម (ប្រវែងប្រវែង១៨៨ម ទទឹង៥ម)។

  ៣. កំណាត់ផ្លូវទី៣ ស្ថិតក្នុងភូមិថ្មី សង្កាត់ស្វាយដង្គំ (ប្រវែង១៣៧ម ទទឹង៦ម) ដែលមានទឹកប្រាក់នៃតម្លៃកិច្ចសន្យា សរុបចំនួន ២៤២,០០,០០០ (ពីររយសែសិបពីរលាន រៀលគត់) ទាបជាងឥណទានជានាចំណាយ សរុបចំនួន ៣០៥,៨៨០ (បីរយប្រាំពាន់ ប្រាំបីរយប៉ែតសិប រៀលគត់)។
- បានចុះកិច្ចសន្យារវាងរដ្ឋបាលក្រុងសៀមរាបនិងក្រុមហ៊ុន អ៊ឹង លីសួរ មានទឹកប្រាក់នៃតម្លៃកិច្ចសន្យាសរុបចំនួន ៣១,៨៩០,០០០ (សាមសិបមួយលាន ប្រាំបីរយកៅសិបពាន់ រៀលគត់) ដែលទាបជាងឥណទានជានាចំណាយចំនួន១០៨,៨២០ (មួយរយប្រាំបីពាន់ ប្រាំបីរយម្ភៃ រៀលគត់)។

# ផ្នែកទី២
# ការងាររដ្ឋបាលសង្កាត់

## ២.១-ការងាររដ្ឋបាលសង្កាត់

- សង្កាត់ជ្រាវ សង្កាត់ចុងឃ្នៀស មិនបានផ្តល់របាយការណ៍មករដ្ឋបាលក្រុង។

### ២.១.១.ស្ថិតិក្រុមប្រឹក្សាសង្កាត់ និងបុគ្គលិក

| ល.រ | ការបរិយាយ | សរុប | ស្រី |
|---|---|---|---|
| ១ | សមាជិកក្រុមប្រឹក្សាឃុំ សង្កាត់ | ៨២ | ១៨ |
| ២ | សមាជិកក្រុមប្រឹក្សាឃុំ សង្កាត់ដែលបានផ្លាស់ប្តូរ | ០ | ០ |
| ៣ | មេឃុំ ចៅសង្កាត់ | ១២ | ០ |
| ៤ | ជំទប់ទី១ ចៅសង្កាត់រងទី១ | ១២ | ២ |
| ៥ | ជំទប់ទី២ ចៅសង្កាត់រងទី២ | ១២ | ០ |
| ៦ | ស្មៀនឃុំ សង្កាត់ | ១២ | ៤ |
| ៧ | បុគ្គលិកកិច្ចសន្យា | ៥៤ | ២១ |
| ៨ | មេភូមិ | ៩៩ | ៧ |
| ៩ | អនុប្រធានភូមិ | ៩៩ | ៩ |
| ១០ | សមាជិកភូមិ | ៩៩ | ៨៥ |
| ១១ | អ្នកទទួលបន្ទុកកិច្ចការនារីនិងកុមារដែលមិនមែនជាសមាជិកក្រុមប្រឹក្សាសង្កាត់ | ៦ | ៦ |
| ១២ | ជនបង្គោលតាមដានត្រួតពិនិត្យ និងវាយតម្លៃឃុំ សង្កាត់ | ១២ | ៥ |

### ២.១.២.ដីកា សេចក្តីសម្រេច និងលិខិត

| ល.រ | ការបរិយាយ | ចំនួន |
|---|---|---|
| ១ | ដីកាដែលបានដាក់ចេញ | ១ |
| ២ | សេចក្តីសម្រេចដែលបានដាក់ចេញ | ៥២ |
| ៣ | លិខិតរដ្ឋបាលដែលបានដាក់ចេញ | ៩ ១០១ |
| ៤ | លិខិតដែលបានទទួល | ៥៧៧ |

### ២.១.៣. កិច្ចប្រជុំក្រុមប្រឹក្សាសង្កាត់ និង គ.ក.ន.ក

| ល.រ | ការបរិយាយ | ចំនួន |
|---|---|---|
| ១ | កិច្ចប្រជុំសាមញ្ញរបស់ក្រុមប្រឹក្សា | ១៣៣ |
| ២ | កិច្ចប្រជុំវិសាមញ្ញរបស់ក្រុមប្រឹក្សា | ៥ |
| ៣ | កិច្ចប្រជុំសម្ងាត់របស់ក្រុមប្រឹក្សា | ០ |
| ៤ | កិច្ចប្រជុំ គ.ក.ន.ក | ១៣៥ |

### ២.១.៤. គម្រោងវិនិយោគដែលមានការសន្យាគាំទ្រដោយថវិកាសង្កាត់

| ល.រ | ផ្នែក | ចំនួនគម្រោង | តម្លៃគម្រោង |
|---|---|---|---|
| ១ | សេដ្ឋកិច្ច | ១១ | ១ ៨៤៨ ៥៩១ ៣៦២ |
| ២ | សង្គមកិច្ច | ០ | ០ |
| ៣ | ធនធានធម្មជាតិ និងបរិស្ថាន | ០ | ០ |

| ល.រ | ផ្នែក | ចំនួនគម្រោង | តម្លៃគម្រោង |
|---|---|---|---|
| ៤ | សេវាកម្មរដ្ឋបាល និងសន្តិសុខ | ០ | ០ |
| ៥ | យេនឌ័រ | ០ | ០ |
| សរុប | | ១១ | ១ ៨៤៨ ៥៩១ ៣៦២ |

២.១.៥. ការអនុវត្តគម្រោងសង្កាត់ (មិនមានតួលេខគ្រប់សង្កាត់)

| ល.រ | ផ្នែក | សរុប | ស្ថានភាពនៃការអនុវត្ត | | |
|---|---|---|---|---|---|
| | | | មិនទាន់ | កំពុង | បញ្ចប់ |
| ១ | សេដ្ឋកិច្ច | ២០ | ០៨ | ០២ | ១០ |
| ២ | សង្គមកិច្ច | ៣៧ | ២០ | ១៤ | ០៣ |
| ៣ | ធនធានធម្មជាតិ និងបរិស្ថាន | ២១ | ១៤ | ០៧ | ០ |
| ៤ | សេវាកម្មរដ្ឋបាល និងសន្តិសុខ | ២២ | ០៨ | ១១ | ០៣ |
| ៥ | យេនឌ័រ | ២២ | ១១ | ០៥ | ០៦ |
| សរុប | | ១២២ | ៦១ | ៣៩ | ២២ |

២.១.៦.ការអនុវត្តថវិកាសង្កាត់(មិនមានតួលេខគ្រប់សង្កាត់)

| ល.រ | ការបរិយាយ | អនុម័ត | ជាក់ស្តែង | ភាគរយ |
|---|---|---|---|---|
| ១ | ចំណូលសរុប | ៣ ៣០០ ៦៣០ ០០០ | ៣ ៣០០ ៦៣០ ០០០ | ១០០% |
| ២ | ចំណាយសរុប | ៣ ៣០០ ៦៣០ ០០០ | ៣ ០៨៧ ៩៣២ ៨០០ | ៩៣.៥៥% |

២.១.៧.ការគ្រប់គ្រងទ្រព្យសម្បត្តិសង្កាត់

| ល.រ | ការបរិយាយ | ចំនួន |
|---|---|---|
| ១ | ទ្រព្យសម្បត្តិឃុំ សង្កាត់ ដែលបានទិញ ឬទទួល (ថ្មី) | ១៨៨ |
| ២ | ទ្រព្យសម្បត្តិឃុំ សង្កាត់ដែលបានកាត់ចេញ | ៦៩ |
| ៣ | ទ្រព្យសម្បត្តិឃុំ សង្កាត់សរុប | ១៨៨ |

២.១.៨.ការអភិវឌ្ឍសមត្ថភាព

| ល.រ | ការបរិយាយ | ចំនួន |
|---|---|---|
| ១ | វគ្គសិក្សា | ៣៦ |
| ២ | សិក្ខាកាមសរុបដែលបានចូលរួមវគ្គសិក្សា | ៥៦ |
| ៣ | សិក្ខាកាមជាស្រ្តីដែលបានចូលរួមវគ្គសិក្សា | ១៧ |

២.១.៩.សកម្មភាពសេវាសង្គម

| ល.រ | ការបរិយាយ | ចំនួន |
|---|---|---|
| ១ | មត្តេយ្យសិក្សាសហគមន៍កំពុងដំណើរការដែលគាំទ្រពីឃុំ សង្កាត់ | ៥ |
| ២ | គ្រួសារងាយរងគ្រោះគាំទ្រពីឃុំ សង្កាត់សម្រាប់កែលម្អអនាម័យ (ការលាងដៃនឹងសាប៊ូ) | ០ |
| ៣ | គ្រួសារងាយរងគ្រោះគាំទ្រពីឃុំ សង្កាត់ដើម្បីទទួលបានទឹកស្អាតប្រើប្រាស់ | ០ |
| ៤ | គ្រួសារងាយរងគ្រោះគាំទ្រពីឃុំ សង្កាត់ដើម្បីទទួលបានបង្គន់អនាម័យប្រើប្រាស់ | ០ |
| ៥ | គ្រួសារងាយរងគ្រោះដែលឃុំ សង្កាត់ចុះកំណត់អត្តសញ្ញាណ | ០ |

| ល.រ | ការបរិយាយ | ចំនួន |
|---|---|---|
| ៦ | ស្ត្រីរងគ្រោះដោយអំពើហិង្សាក្នុងគ្រួសារដែលទទួលការគាំទ្រពីឃុំ សង្កាត់ | 0 |

២.១.១០.ការសម្រុះសម្រួលទំនាស់

| ល.រ | ការបរិយាយ | ចំនួន |
|---|---|---|
| ១ | ករណីដែលបានសម្រុះសម្រួលបញ្ចប់ដោយឃុំ សង្កាត់ | ៩៣ |
| ២ | ករណីដែលបានបញ្ជូនទៅស្ថាប័នពាក់ព័ន្ធ | ១១ |

២.១.១១. ការងារអត្រានុកូលដ្ឋាន

| ល.រ | ការបរិយាយ | ចំនួន |
|---|---|---|
| ១ | សំបុត្រកំណើត | ២០៨០ |
| ២ | សំបុត្របញ្ជាក់កំណើត | ២៧១៩ |
| ៣ | សេចក្តីចម្លងសំបុត្រកំណើត | ១៦១៥ |
| ៤ | សេចក្តីចម្លងសំបុត្របញ្ជាក់កំណើត | ១៥៣៣ |
| ៥ | សំបុត្រអាពាហ៍ពិពាហ៍ | ១១៤២ |
| ៦ | សេចក្តីចម្លងសំបុត្រអាពាហ៍ពិពាហ៍ | ១២៧៥ |
| ៧ | សំបុត្រមរណភាព | ៣៧០ |
| ៨ | សេចក្តីចម្លងសំបុត្រមរណភាព | ៥៧០ |

២.១.១២.ការចុះឈ្មោះ និងការពិនិត្យបញ្ជីឈ្មោះអ្នកបោះឆ្នោត (មិនមានតួលេខគ្រប់សង្កាត់)

| ល.រ | ការបរិយាយ | ចំនួន |
|---|---|---|
| ១ | ប្រជាពលរដ្ឋដែលបានចុះឈ្មោះថ្មី | |
| ២ | ប្រជាពលរដ្ឋដែលត្រូវបានលុបឈ្មោះចេញពីបញ្ជីឈ្មោះអ្នកបោះឆ្នោត | |
| ៣ | ប្រជាពលរដ្ឋសរុបដែលមានឈ្មោះបោះឆ្នោត (ចាស់ និងថ្មី) | |

## ២.២-បញ្ហាប្រឈមដែលរដ្ឋបាលសង្កាត់បានជួបប្រទះ

| ល.រ | បញ្ហាប្រឈមសំខាន់ៗ | សំណើដំណោះស្រាយ |
|---|---|---|
| **១.សង្កាត់ស្លក្រាម** | | |
| ១ | មិនទាន់កំណត់ព្រំប្រទល់រដ្ឋបាលឲ្យបានច្បាស់លាស់រវាងសង្កាត់ស្លក្រាម ក្រុងសៀមរាប និងឃុំកណ្តែក ស្រុកប្រាសាទបាគង | ស្នើសុំខេត្ត ក្រុង ជួយដោះស្រាយ |
| ២ | មិនទាន់មានដីសម្បទានសង្គមកិច្ចដោះស្រាយផ្តល់ជូនប្រជាពលរដ្ឋ ដែលរស់នៅលើដីសាធារណៈ | ស្នើសុំរដ្ឋបាលខេត្តជួយដោះស្រាយ |
| ៣ | ប្រជាពលរដ្ឋនៅតែបោះចោលសំរាមតាមទីសាធារណៈ | បន្តការផ្សព្វផ្សាយនិងណែនាំដល់ប្រជាពលរដ្ឋ |
| ៤ | ប្រជាពលរដ្ឋរស់នៅតាមដងស្ទឹងសៀមរាប ពុំទាន់មានប្រព័ន្ធលូរំដោះទឹក(ភូមិបឹងដូនប៉ា ភូមិទ្រាំង ភូមិមណ្ឌល៣) | ស្នើសុំរដ្ឋបាលខេត្តជួយដោះស្រាយ |
| ៥ | ពុំទាន់មានបណ្តាញទឹកស្អាតប្រើប្រាស់ឲ្យបានគ្រប់គ្រួសារ | ស្នើសុំអង្គភាពរដ្ឋាករទឹកស្វយ័តជួយដោះស្រាយ |
| ៦ | ផ្លូវក្នុងសង្កាត់ទទួលរងការខូចខាតច្រើន | ស្នើឲ្យមន្ទីរសាធារណការ និងដឹកជញ្ជូនជួសជុល |
| **២.សង្កាត់ស្វាយដង្គំ** | | |

| ល.រ | បញ្ហាប្រឈមសំខាន់ៗ | សំណើដំណោះស្រាយ |
|---|---|---|
| ១ | ប្រជាពលរដ្ឋដែលបានធ្វើកិច្ចសន្យាបើកផ្លូវរួចហើយតែមិនអនុវត្តតាមកិច្ចសន្យា | ស្នើរដ្ឋបាលក្រុង និងអាជ្ញាធរពាក់ព័ន្ធចុះដោះស្រាយ |
| ២ | ការយកសំរាមមកដាក់តាមផ្លូវ និងដឹកជញ្ជូនមិនទាន់ពេលវេលា | ចុះអប់រំ និងសូមឲ្យសាលាក្រុងពន្លឿនការដឹកសំរាមឲ្យទាន់ពេលវេលា |
| ៣ | នៅមានការលក់ដូរលើដីចំណីផ្លូវនានាក្នុងសង្កាត់ | ស្នើរដ្ឋបាលក្រុង និងអាជ្ញាធរពាក់ព័ន្ធចុះដោះស្រាយ |
| ៤ | សំណង់សង់មុនការអនុញ្ញាតច្បាប់ | សហការជាមួយអាជ្ញាធរពាក់ព័ន្ធចុះណែនាំ |
| **៣.សង្កាត់គោកចក** | | |
| ១ | បញ្ហាសណ្តាប់ធ្នាប់ កាកសំណល់រឹងនៅតែជាបញ្ហា | សហការជាមួយក្រុមហ៊ុនដឹកជញ្ជូនសំរាមក្នុងការដឹកឲ្យទាន់ពេលវេលា |
| ២ | នៅមានអាជីវករលក់ដូរលើដីចំណីផ្លូវទោះបីមានការណែនាំយ៉ាងណាក៏ដោយ | សហការជាមួយរដ្ឋបាលក្រុង និងប៉ុស្តិ៍ ធ្វើសេចក្តីជូនដំណឹង និងរៀបចំសណ្តាប់ធ្នាប់ជាប្រចាំ |
| ៣ | ប្រព័ន្ធលូរំដោះទឹកចាស់ស្ទះដោយសារការដាក់លូតាមផ្ទះរបស់ប្រជាពលរដ្ឋគ្មានបច្ចេកទេស | សហការជាមួយមន្ទីរសាធារណការក្នុងការចុះពិនិត្យ |
| ៤ | កង្វះទឹកស្អាតប្រើប្រាស់ | សហការជាមួយរដ្ឋាករទឹកក្នុងការតបណ្តាញទឹកស្អាតជូនប្រជាពលរដ្ឋ |
| **៤.សង្កាត់សាលាកំរើក** | | |
| ១ | មិនទាន់ទប់ស្កាត់បាននូវអំពើចោរកម្ម ចោរលួច គ្រឿងញៀន ល្បែងស៊ីសង អំពើហិង្សាក្នុងគ្រួសារ និងអំពើហិង្សាផ្សេងៗ ក្មេងទំនើង | សហការជាមួយសាលាខេត្ត សាលាក្រុង អធិការនគរបាលក្រុង ខេត្ត និងប៉ូលិសប៉ុស្តិ៍ ប្រជាការពារភូមិជួយមានវិធានការទប់ទល់ជាមួយក្មេងទំនើងទាំងនោះ |
| ២ | បញ្ហាកាកសំណល់រឹង គ្មានសណ្តាប់ធ្នាប់ និងការទុកដាក់គ្មានរបៀបរៀបរយ | សហការជាមួយរដ្ឋបាលក្រុង មន្ទីរបរិស្ថាន ដើម្បីរៀបចំឲ្យបានជាប្រចាំ |
| ៣ | បញ្ហាសណ្តាប់ធ្នាប់ និងការលក់ដូរលើដីចំណីផ្លូវនៅតែមាន | សហការជាមួយរដ្ឋបាលក្រុង ប៉ុស្តិ៍ ជូនដំណឹង និងចុះរៀបចំដល់អ្នកលក់ដូរទាំងនោះ |
| ៤ | ផ្លូវក្នុងភូមិតារៀនខូចដោយសារទឹកលិច ខ្វះប្រព័ន្ធមេរំដោះទឹក | ស្នើឲ្យរដ្ឋបាលក្រុង មន្ទីរសាធារណការ រៀបចំប្រព័ន្ធលូមេរំដោះទឹក |
| ៥ | ការដាក់ភ្លើងបំភ្លឺតាមដងផ្លូវសំខាន់មិនទាន់គ្រប់កន្លែង | ស្នើឲ្យអគ្គិសនីខេត្ត សាលាខេត្ត ដោះស្រាយ |
| **៥.សង្កាត់ជ្រាវ** | | |
| ១ | ការងារបរិស្ថាននិងអនាម័យនៅមិនទាន់ល្អប្រសើរ | បន្តការផ្សព្វផ្សាយដល់ប្រជាពលរដ្ឋគ្រប់ភូមិឲ្យចេះសម្អាតបរិស្ថានបានល្អប្រសើរនៅតាមផ្ទះ |
| ២ | ការងារភូមិ-ឃុំមានសុវត្ថិភាពនៅមិនទាន់ផ្សព្វផ្សាយបានគ្រប់ភូមិ | បន្តការផ្សព្វផ្សាយដល់ប្រជាពលរដ្ឋគ្រប់ភូមិ |
| **៦.សង្កាត់សៀមរាប** | | |
| ១ | ការងារបរិស្ថាននិងអនាម័យនៅមិនទាន់ល្អប្រសើរ (ផ្សារកក្រាញ់ ផ្លូវវាំងក្រុង ផ្លូវ៦៣ភ្នំក្រោម) | ភាគីបរិស្ថានបានចុះធ្វើការសម្របសម្រួល |

| ល.រ | បញ្ហាប្រឈមសំខាន់ៗ | សំណើដំណោះស្រាយ |
| --- | --- | --- |
| ២ | សណ្តាប់ធ្នាប់ និងការលក់ដូរលើដីចំណីផ្លូវនៅតែមាន | សហការជាមួយរដ្ឋបាលក្រុង ប៉ុស្តិ៍ ជូនដំណឹង និងចុះរៀបចំដល់អ្នកលក់ដូរទាំងនោះ |
| ៣ | ពលរដ្ឋមួយចំនួនធំមិនទាន់មានទឹកស្អាតប្រើប្រាស់ | សហការជាមួយរដ្ឋបាលក្រុង រដ្ឋាករទឹក ពិនិត្យបណ្តាញទឹកស្អាតជូនប្រជាពលរដ្ឋ |
| **៧.សង្កាត់ចុងឃ្លៀស (គ្មាន)** | | |
| **៨.សង្កាត់សំបួរ** | | |
| ១ | អគ្គិសនីនៅមិនទាន់មានប្រើប្រាស់គ្រប់គ្រាន់ | សុំឲ្យអាជ្ញាធរអគ្គិសនីផ្តល់ឲ្យបានគ្រប់ |
| ២ | ឡានដឹកដីធ្វើឲ្យខូចផ្លូវ និងជីករណ្តៅជ្រៅ បានធ្វើកិច្ចសន្យាហើយប៉ុន្តែខាងឡានមិនទាន់អនុវត្ត | សុំឲ្យរដ្ឋបាលក្រុងជួយអន្តរាគមន៍ |
| ៣ | ប្រជាពលរដ្ឋសុំឲ្យធ្វើការចុះប័ណ្ណកម្មសិទ្ធិដីស្រែប្រាំង | សុំឲ្យភូមិបាលក្រុងជួយដោះស្រាយ |
| ៤ | ពុំទាន់មានបង្គោលអគ្គិសនីត្រឹមត្រូវ សម្រាប់ធានានូវសុវត្ថិភាព | សុំឲ្យអគ្គិសនីខេត្តជួយដោះស្រាយ |
| ៥ | អគ្គិសនីនៅមិនទាន់មានប្រើប្រាស់គ្រប់គ្រាន់ | សុំឲ្យអាជ្ញាធរអគ្គិសនីផ្តល់ឲ្យបានគ្រប់ |
| ៦ | ឡានដឹកដីធ្វើឲ្យខូចផ្លូវ និងជីករណ្តៅជ្រៅ បានធ្វើកិច្ចសន្យាហើយប៉ុន្តែខាងឡានមិនទាន់អនុវត្ត | សុំឲ្យរដ្ឋបាលក្រុងជួយអន្តរាគមន៍ |
| **៩.សង្កាត់ស្រះចៃ (គ្មាន)** | | |
| ១ | នៅមានការចោលសំរាមតាមផ្លូវ | សូមរដ្ឋបាលក្រុងជួយទប់ស្កាត់ |
| ២ | ការផ្សព្វផ្សាយភូមិ ឃុំមានសុវត្ថិភាពនៅមិនទាន់បានគ្រប់ប្រជាពលរដ្ឋ | សូមអធិការនគរបាលក្រុងផ្សព្វផ្សាយឲ្យបានទូលំទូលាយ |
| ៣ | នៅតែមានការប្រើប្រាស់គ្រឿងញៀន | ធ្វើការផ្សព្វផ្សាយ និងទប់ស្កាត់ |
| ៤ | នៅតែមានល្បែងស៊ីសង | សូមរឹងបណ្តឹងច្បាប់ |
| ៥ | នៅតែមានការនេសាទខុសច្បាប់ | ផ្សព្វផ្សាយច្បាប់ជលផល និងពិន័យអ្នកប្រព្រឹត្តខុសច្បាប់ |
| **១០.សង្កាត់នគរធំ** | | |
| ១ | ប្រជាពលរដ្ឋរស់នៅលើប្រឡាយចំនួន៦៧គ្រួសារ | សុំឲ្យរដ្ឋបាលក្រុងជួយដោះស្រាយ |
| **១១.សង្កាត់ទឹកវិល** | | |
| ១ | ការផ្សព្វផ្សាយភូមិ ឃុំ មានសុវត្ថិភាពនៅមិនទាន់គ្រប់គ្រួសារ | ផ្សព្វផ្សាយឲ្យបានស៊ីជម្រៅ និងពង្រឹងប្រជាការពារ |
| ២ | ទំនាស់ដីឃ្លាំងទឹកស្រែប្រាំងរវាងឃុំកែវពណ៌ និងសង្កាត់ទឹកវិលមិនទាន់បានដោះស្រាយ | សូមឲ្យរដ្ឋបាលក្រុងជួយដោះស្រាយ |
| ៣ | ការងារបរិស្ថាននិងអនាម័យនៅមិនទាន់ល្អប្រសើរ | បន្តការផ្សព្វផ្សាយដល់ប្រជាពលរដ្ឋគ្រប់ភូមិឲ្យចេះសម្អាតបរិស្ថានបានល្អប្រសើរ |
| **១២.សង្កាត់ក្របីរៀល** | | |
| ១ | ផ្លូវក្រាលកៅស៊ូដោយមន្ទីរអភិវឌ្ឍន៍ជនបទរងការខូចខាត | ស្នើឲ្យរដ្ឋបាលក្រុងចាត់វិធានការណ៍ |
| ២ | សាលាបឋមសិក្សាក្របីរៀលចាស់ទ្រុឌទ្រោម | ស្នើមន្ទីរអប់រំ យុវជន និងកីឡាសាងសង់អគារថ្មី |

# ផ្នែកទី៣
# ការងាររបស់ការិយាល័យ អង្គភាពជំនាញ

## ៣.១. សេដ្ឋកិច្ច

### ៣.១.១.ការិយាល័យទេសចរណ៍

**ក/ រចនាសម្ព័ន្ធការិយាល័យ៖**

១. លោក សុខ សោម ប្រធានការិយាល័យ ២. លោក ផយ ភា អនុប្រធានការិយាល័យ ៣. លោក ថោង ស៊្មីគ្រ អនុប្រធានការិយាល័យ(ប្រចាំការនៅការិ.ច្រកចេញចូលតែមួយ) ៤. ថេង រិន មន្ត្រី ៥. អ្នកស្រី វ៉ន ជាវ៉ា មន្ត្រី។

**ខ/ លទ្ធផលការងារសម្រេចបាន៖**

- ចុះស្រង់ទិន្នន័យសេវាកម្មទេសចរណ៍ដែលបង្កើតថ្មីបាន ៨៩៤កន្លែង។
- បានចុះផ្សព្វផ្សាយច្បាប់ទេសចរណ៍ និងជំរុញអាជីវករបម្រើសេវាកម្មទេសចរណ៍ក្នុងក្រុង (ផុតសុពលភាពនិងបង្កើតថ្មី)ឲ្យមកសុំច្បាប់ប្រកបអាជីវកម្ម ១ ០៦៩លើក ក្នុងនោះម្ចាស់អាជីវកម្មបានមកសុំច្បាប់ ១១៩២សេវា។

### ៣.១.២.ការិយាល័យកសិកម្ម

**ក.ការងារក្សេត្រសាស្ត្រ**

**ក.១. អំពីការងារបង្កបង្កើនផលរដូវវស្សាឆ្នាំ២០១៨ (ផែនការ ៥ ៧៧០ ហ.ត)**

- ប្រមូលផលស្រាលសរុបបាន ៣ ៣៩៥ ហត ស្មើនឹង ៩០% ក្នុងនោះទិន្នផលជាមធ្យមបាន ២.២០ តោន/ហ.ត
- តម្លៃស្រូវ៖ ស្រូវក្រអូបស្ងួត ១២០០ ទៅ១៣០០ រៀល/គីឡូក្រាម
- ការងារចុះអង្កេតស្ទង់ទិន្នផលស្រូវ៖ បាន ១៤សំណាក ក្នុងនោះមួយសំណាកទទួលបានទិន្នផលចន្លោះពី ៨០០ក្រាម ទៅ ១៦០០ក្រាម (ទិន្នផល ១.៨២ ទៅ ៣.៦៤ ត/ហត)

**ក.២. អំពីដំណាំរួមផ្សំ រដូវវស្សា (ផែនការ ៣៣០ ហ.ត)**

- អនុវត្តបានចំនួន ៣៣៥ ហត ស្មើនិង ១០១.៥២% នៃផែនការ (បញ្ចប់)ក្នុងនោះមាន៖ បន្លែគ្រប់មុខ ២៥៥ ហ.ត ពោត ៤៥ ហ.ត ដំឡូងមី ០៥ ហ.ត អំពៅ ៣០ហ.ត

**ក.៣. អំពីការងារបង្កបង្កើនផលរដូវប្រាំងឆ្នាំ២០១៨** (ផែនការ ៤ ៥១៥ ហ.ត)

- សរុបបាន ៤ ៥៣០ ហ.ត ស្មើនិង ១០០.៣៣% ក្នុងនោះមាន៖ ភ្ជួរដោស់បានចំនួន ៤ ៥៣៥ ហ.ត ភ្ជួរដោយគ្រឿងយន្ត ៤ ៥៣៥ហ.ត សំណាប ២០ ហត ព្រោះស្រូវប្រដេញទឹកបាន ១ ៣១៥ហត ស្ទូង ៨០ ហត ព្រោះស្រូវប្រាំងនោមបាន ៣ ១៣៥ ហត។
- **ការប្រមូលផលស្រូវប្រាំង៖** ប្រមូលផលសរុបបាន ១ ១៣០ហត ស្មើនិង ២៤.៩៤% នៃផ្ទៃដីអនុវត្តបាន ៤ ៥៣០ ហត ក្នុងនោះ៖ ស្រូវប្រដេញទឹកប្រមូលផលបាន៖ ១០៨០ ហត ទិន្នផល ៣,១៥ ត/ហត ស្រូវប្រាំងនោមប្រមូលផលបានៈ ៥០ ហត ទិន្នផល ៣,៨០ ត/ហត (តម្លៃផលស្រូវចម្រុះសើមដែលកសិករ លក់បានតម្លៃ ៨០០ ទៅ ៩០០រៀល/គីឡូក្រាម)។

**ក.៤. អំពីដំណាំរួមផ្សំ រដូវប្រាំង** (ផែនការ ៣៣០ ហ.ត)

- អនុវត្តបានចំនួន ៣៤៥ ហត ស្មើនិង ១០៤.៥៥% រួមមាន៖ បន្លែគ្រប់មុខ ២៧៥ ហ.ត ពោត ៣៥ ហ.ត ដំឡូងជ្វា ១០ហ.ត ដំឡូងមី ០៥ហ.ត អំពៅ ២០ ហ.ត។

**ខ-ការងារផលិតកម្ម និងបសុព្យាបាល**

**ខ.១-អំពីការងារចាក់វ៉ាក់សាំង និងថ្នាំការពារជំងឺសត្វ**

- ចាក់វ៉ាក់សាំងការពារជំងឺសារទឹកគោ បានចំនួន **១ ៤៥៥** ក្បាល។ ចាក់វ៉ាក់សាំងការពារជំងឺសារទឹកក្របី បានចំនួន **១៤០៥** ក្បាល។ ចាក់វ៉ាក់សាំងការពារជំងឺសារទឹកជ្រូក បានចំនួន **១ ៨០៤** ក្បាល។

**ខ.២-អំពីការងារចុះជួយព្យាបាល និងបញ្ចុះព្រូនសត្វ**

- ជួយព្យាបាលសត្វឲ្យកសិករសរុបបាន **៣ ១៦៩**ក្បាល ក្នុងនោះមាន៖ គោចំនួន ១៣១៣ក្បាល ក្របីចំនួន ៦៨៤ក្បាល និងជ្រូកចំនួន ១១៧២ក្បាល
- បញ្ចុះព្រូនសត្វសរុបបាន ៤២៤៥ក្បាល ក្នុងនោះមាន៖ គោចំនួន ១៧៩៣ក្បាល ក្របីចំនួន ៧២៤ក្បាល និងជ្រូកចំនួន ១៧២៨ក្បាល
- ដាក់ស្ពែមសិប្បនិម្មិតសត្វជ្រូកបានចំនួន ៥១៨ក្បាល។
- ដាក់ស្ពែមសិប្បនិម្មិតសត្វគោបានចំនួន ២៨ក្បាល។
- ក្រៀវសត្វគោឲ្យកសិករសរុបបាន ៣៨០ក្បាល។
- ក្រៀវសត្វជ្រូកកសិករសរុបបាន ១៦១ក្បាល។

**ខ.៣-ការងារសម្របសម្រួលជាមួយភ្នាក់ងារសុខភាពសត្វភូមិ**

- សម្របសម្រួលជាមួយភ្នាក់ងារសុខភាពសត្វភូមិចំនួន ០៨នាក់ ដោយបានចែកនូវវ៉ាក់សាំង និងថ្នាំមួយចំនួនសម្រាប់ធ្វើការពារ និងការព្យាបាលជម្ងឺសត្វនៅក្នុងភូមិគោលដៅ។

**ខ.៤ ការងារ ឃ្លាំមើលជម្ងឺសត្វទូទៅ**

- ការឃ្លាំងមើលជម្ងឺសត្វទូទៅពុំមានអ្វីគួរឲ្យកត់សំគាល់ឡើយ។

**ខ.៥ ការងារនីតិកម្មកសិកម្ម:**

- ចូលរួមផ្តល់យោបល់លក្ខណៈបច្ចេកទេសក្នុងការចុះបញ្ជីអាជីវកម្ម លិខិតអនុញ្ញាតធ្វើអាជីវកម្ម លក់ដុំរាយសម្ភារកសិកម្មបានចំនួន៖
  - ចុះបញ្ជី លិខិតអនុញ្ញាតធ្វើអាជីវកម្ម លក់ដុំរាយសំភារៈកសិកម្មថ្មីបានចំនួន០៣នាក់។
  - ចុះបញ្ជី លិខិតអនុញ្ញាតធ្វើអាជីវកម្ម លក់ដុំរាយសំភារៈកសិកម្មបន្តបានចំនួន ២២នាក់។

**ខ.៦ ការងារគ្រឿងយន្តកសិកម្ម:**

- សហការជាមួយអាជ្ញាធរតាមភូមិសង្កាត់ក្នុងការស្រង់បច្ចុប្បន្នភាពនៃការប្រើប្រាស់គ្រឿងយន្តកសិកម្ម និងឧបករណ៍កសិកម្មក្នុងក្រុងសៀមរាបបន្ត ។

**ខ.៧ ការងារផ្សព្វផ្សាយកសិកម្ម:**

- ចូលរួមស្រង់ទិន្នន័យទាក់ទងនឹងការងារផ្សព្វផ្សាយតាមបណ្តាអង្គការ ដែលកំពុងដំណើរការក្នុងក្រុងសៀមរាប
- ចូលរួមពង្រឹងសមត្ថភាពក្រុមផលិតក្នុងការកត់ត្រាទិន្នន័យជាំដុះ វិភាគសេដ្ឋកិច្ច និងបច្ចេកដាំដុះដំណាំ ការអនុវត្តកសិកម្មល្អ (GAP)។

**ខ.៨ កិច្ចសហការជាមួយអាជ្ញាធរ និងការិយាល័យពាក់ព័ន្ធ**

- សហការជាមួយអាជ្ញាធរ ភូមិអារញ្ញ សង្កាត់សៀមរាប និងអាជ្ញាធរភូមិជ្រាវ សង្កាត់ជ្រាវ ដើម្បីចុះស្ទង់ទិន្នផលស្រូវប្រាំងចំនួន ២៤សំណាក។
- សហការជាមួយអាជ្ញាធរ ភូមិអារញ្ញ សង្កាត់សៀមរាប និងអាជ្ញាធរភូមិជ្រាវ សង្កាត់ជ្រាវ ដើម្បីចុះស្ទង់ទិន្នផលស្រូវស្រាលបាន ៣២ សំណាក ទិន្នផលចន្លោះពី ៩០០ក្រាម ទៅ ១៦០០ក្រាម (ទិន្នផល ២.០ ទៅ ៣.៦៤ ត/ហត) និងស្រូវកណ្តាលបាន ១៦ សំណាក ទិន្នផលចន្លោះពី ១០០០ក្រាម ទៅ ១៦០០ក្រាម (ទិន្នផល ២.២០ ទៅ ៣.៦៤ ត/ហត)។

- សហការជាមួយអាជ្ញាធរភូមិឃុំគ្រប់សង្កាត់តាមដានបង្កបង្កើនផលស្រូវវស្សាប្រាំង និងការស្ទាក់ទឹកទុក
- សហការជាមួយអាជ្ញាធរភូមិឃុំគ្រប់សង្កាត់ស្រង់គ្រឿងយន្តកសិកម្ម និងឧបករណ៍កសិកម្ម ។
- សហការជាមួយអាជ្ញាធរភូមិ និងសង្កាត់ តាមដានជម្ងឺសត្វទូទៅ
- តាមដានសភាពលូតលាស់ដំណាំស្រូវ និងតាមដានសត្វល្អិត និងជម្ងឺដំណាំរួមផ្សំគ្រប់ប្រភេទ។
- សហការជាមួយភ្នាក់ងារសុខភាពសត្វភូមិក្នុងការចុះតាមដានស្ថានភាពការចិញ្ចឹមសត្វនិង ការធ្វើវ៉ាក់សាំង
- សហការជាមួយប្រជាកសិករ និងអាជ្ញាធរមូលដ្ឋានភូមិសង្កាត់ក្នុងការចុះអង្កេតទិន្នផលស្រូវនៅ សង្កាត់ទឹកវិល និងសង្កាត់សំបួរចំនួន៤៨ សំណាក។
- ចូលរួមផ្តល់សំបកការ៉ុងចំនួន ៣៤៣០ការ៉ុង និងថ្នាំកំចាត់កណ្តុរចំនួន ២៧ គីឡូក្រាម ដល់ចំនួន ០៦សង្កាត់ រួមមាន៖ សង្កាត់ជ្រាវ សង្កាត់ក្របីរៀល សង្កាត់សៀមរាប សំបកដើម្បីបិទទំនប់ដែលបានបាក់ខូចក្នុង រដូវវស្សា និងទប់ទឹកទុកសម្រាប់ធ្វើស្រែប្រាំង។

**គ- កិច្ចសហការជាមួយដៃគូអភិវឌ្ឍន៍ និង អង្គការក្រៅរដ្ឋបាលកិបាល**

**គ.១ គម្រោងជម្រុញផលិតកម្មស្បៀង (គម្រោងBFP)**

- ភូមិគោលដៅនៅ ភូមិ ស្រះស្រង់ខាងជើង សង្កាត់នគរធំ កសិករទទួលផល០៦គ្រួសារ មានផ្ទៃដីដាំដុះសរុប ចំនួន ៤ហិតា ដែលបានដាំដំណាំដូចជា ត្រសក់ស្រូវ ត្រសក់ទ្រើង និងសណ្តែកគួរ និងដំណាំពោត ក្នុងនោះ ក្នុងមួយមុខដំណាំទទួលផលបាន ៥ តោន/ហិតា និងមានតម្លៃ ពី១៥០០រៀល ទៅ៣០០០រៀលក្នុងមួយ គីឡូក្រាម។

**គ.២ អង្គការIRRI**

- ធ្វើស្រែបង្ហាញពូជស្រូវខារ១៥ នៅភូមិក្រសាំង សង្កាត់ក្របីរៀលជាមួយកសិករ១គ្រួសារ លើផ្ទៃដី០១ហិកតា ទទួលបានទិន្នផល ៣.៦ ត/ហត ។
- ធ្វើស្រែបង្ហាញពូជស្រូវ ផ្ការំដួលនៅភូមិទឹកថ្លា សង្កាត់ទឹកវិលជាមួយកសិករ ១គ្រួសារលើផ្ទៃដី០.២៥ ហិកតា ទទួលបានទិន្នផល ២.៩ ត/ហត ។

## ៣.១.៣-ការិយាល័យពាណិជ្ជកម្ម

អាជីវករមកសុំច្បាប់ប្រកបអាជីវកម្ម នៅការិយាល័យច្រកចេញចូលតែមួយបាន ៨៤០សេវា (ការជំរុញអាជីវករ ម្ចាស់អាជីវកម្មសេវាកម្មក្នុងសង្កាត់ទាំង១២ ឲ្យមកសុំច្បាប់អនុញ្ញាតប្រកបអាជីវកម្មមិនបានអនុវត្តទេ ដោយសារ លោក ខាន់ សុខុម ប្រធានការិយាល័យពាណិជ្ជកម្មក្រុងបានចូលនិវត្តន៍)។

## ៣.១.៤-ការិយាល័យសាធារណការ

### ១. សកម្មភាពមន្ត្រីការិយាល័យ

- បានចូលរួមប្រជុំគណៈបញ្ជាការឯកភាពរដ្ឋបាលក្រុងចំនួន៨លើក។
- បានចូលរួមប្រជុំសាមញ្ញរបស់ក្រុមប្រឹក្សាក្រុងសៀមរាបបានចំនួន១១លើក។
- ចូលរួមជាមួយមន្ទីរសាធារណការ និងដឹកជញ្ជូនខេត្ត ការិយាល័យចរាចរណ៍ផ្លូវគោកនៃស្នងការដ្ឋាននគរបាលខេត្ត រៀបចំយុទ្ធនាការរឹតបណ្តឹងការពាក់មួកសុវត្ថិភាព ចំនួន០២លើក។
- សហការជាមួយរដ្ឋបាលខេត្ត ស្នងការដ្ឋាននគរបាលខេត្ត មន្ទីរសាធារណការ និងដឹកជញ្ជូនខេត្ត អធិការដ្ឋាន នគរបាលក្រុង សង្កាត់ និងភូមិ ចុះពិនិត្យវាស់វែងយានយន្តកែច្នៃខុសបច្ចេកទេសចំនួន០២លើក។
- ចូលរួមប្រជុំ និងចុះត្រួតពិនិត្យផ្លូវ ប្រឡាយ ស្ពាន លូ ចំនួន ២៤លើក។
- ចូលរួមកិច្ចប្រជុំរៀបចំសណ្តាប់ធ្នាប់ក្នុងក្រុង ០៥លើក ។

-បានចូលរួមសហការជាមួយសណ្តាប់ធ្នាប់ក្រុងចុះសណ្តាប់ធ្នាប់ជាប្រចាំ។

## ៣.២.សង្គមកិច្ច

### ៣.២.១.ការិយាល័យវប្បធម៌ និងវិចិត្រសិល្បៈ

- ប្រជុំនៅមន្ទីរវប្បធម៌ និងវិចិត្រសិល្បៈខេត្តបានចំនួន ៨លើក។
- ប្រជុំសាមញ្ញ និងវិសាមញ្ញ របស់ក្រុមប្រឹក្សាក្រុងសៀមរាប ចំនួន ១១។
- ប្រជុំគណៈបញ្ជាការឯកភាពរដ្ឋបាលក្រុង ចំនួន ០៧លើក។
- ប្រជុំនៅសាលាខេត្តស្តីពីការចុះកាត់ស្លាយីហោ លើ៤ម៉ែត្រការ៉េ និងផ្សព្វផ្សាយអាជីវករ និងអាជីវកម្មដ្ឋានមកដាក់ពាក្យស្នើសុំច្បាប់ នៅច្រកចេញចូលតែមួយសាលាខេត្តនិងក្រោម៤ម៉ែត្រការ៉េឲ្យមកសុំច្បាប់នៅច្រកចេញតែមួយនៅសាលាក្រុងបានចំនួន ៦លើក។
- ចូលរួមប្រជុំសាមញ្ញរបស់ គកសក ក្រុង អណត្តិទី២ បានចំនួន ១១លើក។
- ចូលរួមចូលប្រជុំការងារសណ្តាប់ធ្នាប់ក្រុងបានចំនួន ៧លើក។
- ចូលរួមប្រជុំដោះស្រាយបញ្ហាដី៨១គ្រួសារនៅភូមិភ្នំក្រោម សង្កាត់សៀមរាប ក្រុងសៀមរាប បានចំនួន ២លើក
- ចុះការងារសណ្តាប់ធ្នាប់លទ្ធផលសម្រេចបាន ក្រុមការងារយើងចែកសេចក្តីជូនដំណឹងបាន៨២០សន្លឹក និងធ្វើកិច្ចសន្យាបាន ៣៧៤កន្លែង។
- ចុះធ្វើកិច្ចសន្យា និងអនុវត្តកិច្ចសន្យាតាមផ្លូវស៊ីវត្ថា ផ្លូវសុខសាន្តចាស់ ផ្លូវផ្សាររាត្រី កាត់ស្លាយីហោ និងផ្ទាំងផ្សព្វផ្សាយពាណិជ្ជកម្ម ដកហូតស្លាចល័តដែលដាក់លើកចំណីផ្លូវគ្មានច្បាប់អនុញ្ញាត ទាំងតូចទាំងធំសរុបបានចំនួន ៥១ផ្ទាំង។
- ចុះវាស់ព្រំគូទឹកប្រាសាទប៉ាទ្រី សហការជាមួយសាលាខេត្ត សុរិយោដីខេត្ត មន្ទីរវប្បធម៌ និងវិចិត្រសិល្បៈខេត្ត សាលាក្រុងសៀមរាប និងអាជ្ញាធរមូលដ្ឋានដែលពាក់ព័ន្ធបាន១លើក។
- ចុះសហការជាមួយមន្ទីរវប្បធម៌ និងវិចិត្រសិល្បៈខេត្ត សង្កាត់ជ្រាវ ក្រុមបប្រឹក្សាសង្កាត់ មេភូមិខ្នារ និងអាជ្ញាធរមូលដ្ឋានពាក់ព័ន្ធ បានចុះទៅទប់ស្កាត់ ការដាក់ដីលុបគូទឹក ទួលគោកគ្រឹះពីសំណាក់បុរសឈ្មោះ កៅ គីរ៉ុជ (អះអាងថាជាម្ចាស់ដី) ហើយក្រុមការងារបានធ្វើកិច្ចសន្យាជាមួយលោក កៅ គីរ៉ុជ បញ្ឈប់ការដាក់ដី និងរំលោភបំពានបន្តទៀតដែលមានទីតាំងនៅភូមិខ្នារ សង្កាត់ជ្រាវ ក្រុងសៀមរាបបានចំនួន១លើក។
- ចុះសហការជាមួយកងកម្លាំងចម្រុះរបស់ខេត្ត មន្ទីរវប្បធម៌ សុរិយោដីខេត្ត សាលាក្រុងសៀមរាប និងអាជ្ញាធរមូលដ្ឋានចុះផ្ទៀងផ្ទាត់ក្បាលដីរបស់ឈ្មោះ ងួន សុភាព និងប្រពន្ធឈ្មោះជាង ប៉ាវ ស្ថិតនៅភូមិសាលាកន្សែង សង្កាត់ស្វាយដង្គុំ ដែលជាប់ពាក់ព័ន្ធនឹងទួលបុរាណដ្ឋាន ទួលគោកត្របែក (ជាលទ្ធផលក្រុមការងារបានធ្វើរបាយការណ៍ ជូនថ្នាក់លើបន្ត)។
- ចុះត្រួតពិនិត្យទីតាំងស្នើសុំប្រគុំតន្ត្រី បានចំនួន ១៥ លើក។
- ចុះត្រួតពិនិត្យទីតាំងស្នើសុំផ្សព្វផ្សាយ ចងបដា និងផ្សព្វផ្សាយផលិតផលផ្សេងៗបានចំនួន ៣៤លើក។
- ចុះត្រួតពិនិត្យទីតាំងសុំរាំវង់បានចំនួន ៥លើក។
- ចុះចែកសេចក្តីជូនដំណឹងសាលាក្រុង សាលាខេត្ត នៅតំបន់ផាប់ស្រ្ទីតចំនួន ២២៧ សន្លឹក។
- ចុះត្រួតពិនិត្យទីតាំងស្នើសុំលើស្លាយីហោបានចំនួន ២៣ កន្លែង (ជាលទ្ធផលអនុញ្ញាតបានចំនួន ១២ កន្លែង និងមិនអនុញ្ញាតបាន ៣កន្លែង)ក្នុងនោះជាតំបន់អាជ្ញាធរអប្សរាគ្រប់គ្រងមួយកន្លែង ដែលមិនអនុញ្ញាត។
- ចុះជំរុញអាជីវកម្មអ៊ុតសក់នៅក្នុងភូមិស្ទឹងថ្មី និងភូមិថ្មី ក្នុងសង្កាត់ស្វាយដង្គុំ ឲ្យមកសុំច្បាប់នៅច្រកចេញចូលតែមួយបានចំនួន៣០កន្លែង (ជាលទ្ធផលម្ចាស់មិនបានមកសុំច្បាប់)។
- ចុះស្រង់ទិន្នន័យស្លាយីហោដែលដាក់ភាសាបរទេសសុទ្ធក្នុងសង្កាត់ស្វាយដង្គុំបានចំនួន៥៦កន្លែង។

- ចុះជួបម្ចាស់ដីដែលពាក់ព័ន្ធ នឹងគោកត្រពាំងអ្នកតាស្វាយក្នុងភូមិទក្សិណត្បូងសង្កាត់គោកចកសម្របសម្រួល ដើម្បីផ្អាកសម្មភាពដែលមានការប៉ះពាល់ដល់ដីក្នុងតំបន់ការពារបុរាណដ្ឋានបាន១លើក (ជាលទ្ធផលផ្អាកបណ្តោះអាសន្នចាំការដោះស្រាយពីថ្នាក់លើ)។
- ចុះសហការជាមួយអាជ្ញាធរអប្សរា មន្ទីរវប្បធម៌ខេត្ត ប៉ូលីសបេតិកណ្ឌ ទប់ស្កាត់ការធ្វើរបងរំលោភចូលក្នុងដីត្រពាំងអ្នកតាស្វាយ ក្នុងតំបន់អភិរក្ស ក្នុងភូមិទក្សិត្បូង សង្កាត់គោកចក ក្រុងសៀមរាប (ជាលទ្ធផលផ្អាត បណ្តោះអាសន្ន ដើម្បីរកវិធីដោះស្រាយទៅថ្នាក់លើបន្តទៀត)។
- ចេញច្បាប់អនុញ្ញាតលើវិស័យវប្បធម៌នៅច្រកចេញចូលតែមួយបានចំនួន ១០៤ ច្បាប់។

## ៣.២.២.ការិយាល័យធម្មការ និងសាសនា

**ផ្នែកសាសនា**

- ប្រជាពលរដ្ឋក្នុងប្រទេសកម្ពុជាមានជំនឿផ្នែកសាសនាដូចតទៅ៖ ១. ពុទ្ធសាសនា ២. សាសនាឥស្លាម ៣. សាសនាគ្រីស្ទ ៤. ពុទ្ធសាសនាមហាយាន

**សកម្មភាពរបស់មន្ត្រីការិយាល័យ**

- ចូលរួមសិក្ខាសាលាសមាហរណកម្ម កម្មវិធីវិនិយោគបីឆ្នាំរំកិលក្រុង សង្កាត់(២០១៨-២០២០) ៣លើក។
- ចូលរួមប្រជុំសាមញ្ញ របស់គណៈកម្មការពិគ្រោះយោបល់ ស្ត្រីនិងកុមារចំនួន១១លើក ។
- ចូលរួមប្រជុំសាមញ្ញ របស់ក្រុមប្រឹក្សាក្រុងចំនួន១១លើក។
- ពិនិត្យទីតាំងសាសនាគ្រីស្ទនិងដកស្លាកសញ្ញាសាសនាគ្រីស្ទតាមដើមឈើ និងបង្គោលភ្លើងបានចំនួន១០លើក។
- ចូលរួមពិធីទទួលទេវតាអង្គសេង្រ្កាន្ត ពិធីស្រង់ព្រះក្នុងថ្ងៃចូលឆ្នាំប្រពៃណីខ្មែរ នៅមន្ទីរធម្មការនិងសាសនា។
- ចូលរួមផ្សព្វផ្សាយអំពីការប៉ះពាល់នៃការប្រើប្រាស់គ្រឿងញៀនតាមបណ្តាវត្ត និងតាមសាសនាផ្សេងៗបានចំនួន០៥លើក។
- រៀបចំប្រឡងចូលពុទ្ធិកអនុវិទ្យាល័យរាជបូណ៌សមណៈសិស្សសរុប១៧៥ រូប។
- ចូលរួមទប់ស្កាត់ការអែអង្គាសបិណ្ឌបាត្រគ្មានសណ្តាប់ធ្នាប់ចំនួន០២លើក។
- ចូលរួមប្រជុំសាលាអនុគណក្រុងដោះស្រាយអធិករណ៍ចំនួន១៤លើក។
- ចូលរួមប្រជុំនៅសាលាគណខេត្តចំនួន០៧លើក។
- ចូលរួមប្រជុំនៅមន្ទីរធម្មការ និងសាសនាខេត្តចំនួន០៨លើក។
- ចូលរួមបោះឆ្នោត អាចារ្យ គណៈកម្មការបានចំនួន ០៣លើក។
- ចូលរួមប្រជុំរៀបចំរចនាសម្ព័ន្ធសង្ឃបាន ០៣លើក។
- ចូលរួមបិទ បើកកម្មវិធីធ្វើធុត្តុង ឆ្ពោះទៅកាន់ការរំលត់ទុក្ខនៅវត្តប្រាសាទ៧ល្វេង។
- ចូលរួមបើកបវេសនកាលឆ្នាំសិក្សា២០១៨-២០១៩ នៅវត្តប្រាសាទត្រាំនាគ។
- ចូលរួមផ្សព្វផ្សាយអនុសំវច្ចរៈទូទាំងប្រទេសនៅវត្តព្រះព្រហ្មរ័ត្នបាន០១លើក។
- ចូលរួមទិវាក្រុងសៀមរាបគ្មានផ្សែងបារីចំនួន០៤លើក។
- អញ្ជើញតំណាងក្រុមជុំនុំសាក្សីព្រះយេហូវ៉ាមកអប់រំនែនាំការហាមបរិស័ទរបស់ខ្លួនមិនឲ្យគោរពទង់ជាតិ។
- **ផ្សព្វផ្សាយលិខិត្ត៣៣៨/១៨ អពសជ** របស់អគ្គាធិការដ្ឋានពុទ្ធិកសិក្សាជាតិស្តីពីការអនុញ្ញាតឲ្យរៀបចំប្រឡងសូត្រ បាតិមោក្ខ សម្តែងព្រះធម៌ទេសនា និងសូត្រធម៌បទដល់បណ្តាវត្តក្នុងក្រុងសៀមរាប។
- **ផ្សព្វផ្សាយលិខិត្តលេខ ៣០០/១៨ មធសខ** ស្នើជម្រុញឲ្យមានសកម្មភាពអប់រំផ្សព្វផ្សាយ ពីបញ្ហាគ្រឿងញៀនក្នុងឱកាសបុណ្យកាន់បិណ្ឌ និងភ្ជុំបិណ្ឌប្រពៃណីជាតិខ្មែរក្នុងក្រុង មានអ្នកចូលរួមសរុប៖ **ព្រះសង្ឃសរុប ១៤១០ អង្គ ពុទ្ធបរិស័ទ ១៨០២៨ នាក់។**

- ស្រង់ថវិកាចំណូលពីការកាន់បិណ្ឌ និងភ្ជុំបិណ្ឌតាមបណ្តាវត្តក្នុងក្រុងសរុបៈ**៦៩១៧០០០០០រៀល។**
- ផ្សព្វផ្សាយតាមបណ្តាវត្ត និងសាសនាផ្សេងៗ ទូងស្គរ វាយគង ទះប៉ោត គោះត្រដោក អបអរសាទរ ល្ខោនខោលចូលក្នុងបញ្ជីបេតិកណ្ឌវប្បធម៌អរូបីនៃមនុស្សជាតិ នាថ្ងៃទី២៨/១១/២០១៨។
- ស្រង់ទិន្នន័យអបអរសាទរតាមបណ្តាវត្ត និងសាសនាផ្សេងៗ **ល្ខោនខោល ចូលបេតិកភណ្ឌពិភពលោក** ចំនួនសរុប ព្រះសង្ឃមាន ៩១៣ អង្គ,បរិស័ទមាន ១៧២ រូប។
- ស្រង់បច្ច័យកឋិនទានតាមបណ្តាវត្តសរុប **១,០៨១,៥០០០,០០០រៀល ,និង ៣៩,២៣៣$ ។**
- ស្រង់ស្ថិតិព្រះសង្ឃ អាចារ្យ គណៈកម្មការ តាជី ដូនជី សិស្ស ក្មេងវត្ត ប្រចាំឆ្នាំ២០១៨ ក្នុងនោះព្រះសង្ឃសរុប១៤២៦ ភិក្ខុ៦១០រូប សាមណេរ៨១៦រូប អាចារ្យ១០៧នាក់ គណៈកម្មការ២០២នាក់ តាជី៧០នាក់ ដូនជី១៩៥នាក់ សិស្ស២៥៨នាក់ ក្មេង៩៥នាក់។
- ស្រង់ស្ថិតិពហិរសាសនាប្រចាំឆ្នាំ២០១៨ ក្នុងនោះ ៖
  + សាសនាឥស្លាម មាន វិហារ១ ,ស៊ូរ៉ាវ ០៧ ,សាសនិកសរុប **៣៧៨៥** រូប។
  + សាសនាគ្រិស្ទ មានវិហារ ០៣ ស្នាក់ការ ៣៤ អង្គការ ០១ សមាគម ០៩ បរិស័ទសរុប **៣៥៨០** រូប។
  + ពុទ្ធសាសនាមហាយាន មានវិហារ ០១ ស្នាក់ការ០២ បរិស័ទមាន២៨៣ រូប។

### ៣.២.៣.ការិយាល័យសង្គមកិច្ច

**១. រចនាសម្ព័ន្ធការិយាល័យ៖**

១. លោកស្រី ស៊ិន រចនា ប្រធានការិយាល័យ ២. លោក នួន ប៊ុន អនុប្រធានការិយាល័យ ៣. លោកស្រី យឹង ខេមរិន្ទ្រ មន្ត្រី ៤. លោក ងិន ច័ន្ទតុលា មន្ត្រី

**២. លទ្ធផលការងារសម្រេចបាន**

**២.១ ការងារសង្គមកិច្ច**

- ចូលរួមវគ្គបណ្តុះបណ្តាលស្តីវិស័យសង្គមកិច្ច នៅទីស្តីការក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា។
- ចូលរួមវគ្គបណ្តុះបណ្តាលស្តីពី ការប្រើប្រាស់ប្រព័ន្ធបច្ចេកវិទ្យា (ឌីជីថល) សម្រាប់ធ្វើអធិការកិច្ចមណ្ឌលថែទាំកុមារ ចំនួន០២លើក, អ្នកសម្របសម្រួលរបស់មន្ត្រីសង្គមកិច្ច និង អង្គការសង្គមស៊ីវិលលើឧបករណ៍បណ្តុះបណ្តាលកំណត់គោលដៅ(កម្រិត២) ស្តីពីការចិញ្ចឹមកូនបែបវិជ្ជមាន ចំនួន០២លើក, ស្តីពីសៀវភៅណែនាំធ្វើឲ្យប្រសើរ ឡើងនូវការថែទាំ កុមារនៅតាមគ្រួសារ។
- សហការជាមួយអាជ្ញាធរមូលដ្ឋានចុះស្វែងរកជនចាស់ជរាគ្មានទីពឹងសុំទាននៅផ្សារក្រោម បច្ចុប្បន្នលោកយាយ ត្រូវបានសប្បុរសជនស្វែងរកជំនួយ មានជំរកស្នាក់នៅបណ្តោះអាសន្ន ស្ថិតនៅជិតផ្សារក្រោម ចំនួន០២លើក។
- ចូលរួមកិច្ចប្រជុំលើការងារការពារកុមារក្នុងខេត្តសៀមរាបស្តីពី ស្ថានភាពកុមារដែលរស់នៅក្នុងមណ្ឌលថែទាំ និងផែនការប្រតិបត្តិខេត្ត ដើម្បីសមាហរណកម្មកុមារ៣០ភាគរយចេញពីមណ្ឌលថែទាំទៅក្នុងគ្រួសារ និងសហគមន៍ប្រកបដោយសុវត្ថិភាព ចំនួន០២លើក។
- អញ្ជើញបងប្អូនជនពិការចូលរួមក្នុងទិវាជនពិការកម្ពុជាលើកទី១៩ និងទិវាជនពិការអន្តរជាតិលើកទី៣៥ នៅមន្ទីរសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា នៃមណ្ឌលរដ្ឋបាល មន្ទីរខេត្តសៀមរាប។
- ចូលរួមពិធីអបអរសាទរខួបអនុស្សាវរីយ៍លើកទី២៤ ទិវាអន្តរជាតិស្តីពីគ្រួសារ ១៥ ឧសភា ក្រោមប្រធានបទ "គ្រួសារល្អមានតួនាទីសំខាន់ក្នុងការ លើកកម្ពស់សីលធម៌សង្គម និងការអភិវឌ្ឍប្រទេសជាតិ" ។

- ចូលរួមអបអរសាទរខួបលើកទី១១ ទិវាអតីតយុទ្ធជនកម្ពុជា ២១ មិថុនា ឆ្នាំ២០១៨ នៅសាលមហោស្រប កោះពេជ្រ ក្រោមអធិបតីភាពដ៏ខ្ពង់ខ្ពស់សម្តេច អគ្គមហាសេនាបតីតេជោ **ហ៊ុន សែន** នាយករដ្ឋមន្ត្រី នៃ ព្រះរាជាណាចក្រកម្ពុជា និងជាប្រធានសមាគមអតីតយុទ្ធជនកម្ពុជា។
- ចូលរួមប្រជុំការងារសមាគមអតីតយុទ្ធជនកម្ពុជាខេត្ត ដើម្បីត្រួតពិនិត្យការងារសមាគម និងដីសម្បទានសង្គមកិច្ចក្នុងភូមិសាស្ត្រខេត្តសៀមរាប ក្រោមអធិបតីភាពដ៏ខ្ពង់ខ្ពស់ ឯកឧត្តម នាយឧត្តមសេនីយ៍បណ្ឌិត **គន់ គីម** អនុប្រធានកម្មាធិការកណ្តាល និងជាអគ្គលេខាធិការសមាគមអតីតយុទ្ធជនកម្ពុជា នៅទីបញ្ជាការដ្ឋានតំបន់ប្រត្តិបត្តិការសឹករងខេត្តសៀមរាប។
- ចូលរួមកិច្ចប្រជុំសាមញ្ញ អាណត្តិទី២ របស់ក្រុម ប្រឹក្សាក្រុងសៀមរាប នៅសាលប្រជុំសាលាក្រុងសៀមរាប ចំនួន០៧លើក។
- ចូលរួមកិច្ចប្រជុំសារមេញ្ញរបស់គណៈកម្មាធិការពិគ្រោះយោបល់កិច្ចការស្ត្រី និងកុមារក្រុងសៀមរាប នៅសាលប្រជុំសាលាក្រុង ចំនួន ០៥លើក។
- ចូលរួមកម្មវិធីកិច្ចប្រជុំផ្សព្វផ្សាយពង្រឹងការអនុវត្តតួនាទីភារកិច្ច ដល់គណកម្មាធិការពិគ្រោះយោបល់កិច្ចការស្ត្រី និងកុមារក្រុង-ស្រុក និងគណកម្មាធិការទទួលបន្ទុកកិច្ចការនារី និងកុមារ ឃុំ-សង្កាត់ ចំនួន ០២លើក។
- ចូលរួមប្រជុំស្តីពីសមិទ្ធផលការងារក្រុងសៀមរាប រយៈពេល៥ឆ្នាំ ចាប់ពីឆ្នាំ ២០១៤-២០១៨។
- រៀបចំកិច្ចប្រជុំរៀបចំបង្កើតសមាគមមនុស្សចាស់ សរុបចំនួន ៧សង្កាត់ មានសង្កាត់នគរធំ សង្កាត់ជ្រាវ សង្កាត់ទឹកវិល សង្កាត់សំបួរ សង្កាត់សៀមរាប សង្កាត់ចុងឃ្នៀស និងសង្កាត់ក្របីរៀល។
- ចូលរួមកិច្ចប្រជុំធ្វើផែនការសមាហរណកម្មកុមារជាមួយមណ្ឌល ថែទាំកុមារក្នុងក្រុងសៀមរាប០១លើក ការគ្រប់គ្រងករណីកុមារ និងបង្រួបបង្រួម កុមារទៅគ្រួសារវិញ ចំនួន ០១លើក។
- ចូលរួមអបអរសាទរ ខួបលើកទី១០៧ ទិវាអន្តរជាតិនារី៨មីនា ឆ្នាំ២០១៨ ក្រោមប្រធានបទ "ស្ត្រីរួមគ្នារក្សាសន្តិភាពដើម្បីអភិវឌ្ឍជាតិ" នៅក្រុងសៀមរាប។
- ចូលរួមកិច្ចប្រជុំពិនិត្យកែតម្រូវសេចក្តីព្រៀងសៀវភៅកម្មវិធីវិនិយោគបីឆ្នាំរំកិល ២០១៩-២០២១ របស់រដ្ឋបាលក្រុងសៀមរាប ។
- ចូលរួមសិក្ខាសាលាសមាហរណកម្មកម្មវិធីវិនិយោគបីឆ្នាំរំកិល ឆ្នាំ(២០១៨-២០២០) ក្រុង-សង្កាត់ នៅថ្នាក់ក្រុង សិក្ខាសាលាផ្សព្វផ្សាយដាក់ឲ្យអនុវត្តរបបគោលនយោបាយ ចំពោះជនពិការក្រីក្រនៅតាមសហគមន៍។
- ចូលរួមពិធីចែកកង់ដល់កុមារក្រីក្រតាមសហគមន៍ ចំនួន៣០គ្រឿង នៅអង្គការអរុណរះកម្ពុជា។
- ចូលរួមពិធីចែកអំណោយដល់គ្រួសារទីទ័លក្រ និងជនរងគ្រោះដោយគ្រោះមហន្តរាយ និងគ្រោះអគ្គីភ័យ ចំនួន៦១គ្រួសារ មកពី៣សង្កាត់ មាន សង្កាត់ស្លក្រាម សង្កាត់សៀមរាប និងសង្កាត់នគរធំ ទីតាំងនៅសាលាសង្កាត់ស្លក្រាម។
- សហការជាមួយអាជ្ញាធរមូលដ្ឋាន ចុះតាមដានកុមារដែលបានសមាហរណកម្មទៅក្នុងគ្រួសារ របស់ពួកគេវិញ ចំនួន៣លើក មានកុមារ០៣នាក់ ។
- សហការជាមួយអង្គការដៃគូ និងអាជ្ញាធរមូលដ្ឋានចុះតាមដានកុមារប្រឈមមុខនឹងការរំលោភបំពាន ធ្វើការនៅពេលយប់ មានកុមារីចំនួន១១នាក់ ។
- សហការជាមួយកិច្ចការនារីសង្កាត់ និងអង្គការដៃគូចុះមកផ្ទះគ្រួសាររបស់កុមាររងគ្រោះដោយការជួញដូរ និងរំលោភបំពានផ្លូវភេទ មានកុមារី០៨នាក់ ដើម្បីធ្វើការប៉ាន់ប្រមាណគ្រួសារ បច្ចុប្បន្នពួកគេទាំងអស់កំពុងស្នាក់នៅមណ្ឌលសុវត្ថិភាពរបស់អង្គការដៃគូ ដើម្បីរៀនជំនាញវិជ្ជាជីវៈ។

- សហការជាមួយអង្គការកម្ពុជាដើម្បីជួយស្ត្រីមានវិបត្តិ និងអាជ្ញាធរមូលដ្ឋាន ចុះទៅជួបជនរងគ្រោះដោយសារអំពើហិង្សាក្នុងគ្រួសារ ចំនួន០៩លើក មានស្ត្រីរងគ្រោះចំនួន២៨នាក់ អង្គការបានជួយដល់ស្ត្រីរងគ្រោះដើម្បីដាក់ពាក្យបណ្ដឹងសុំលែងលះ និងសុំអាហារកាតព្វកិច្ចចិញ្ចឹមកូនទៅតុលាការហើយ បច្ចុប្បន្នកំពុងរង់ចាំសាលក្រមពីតុលាការ។
- សហការជាមួយអង្គការដៃគូ និងអាជ្ញាធរមូលដ្ឋានរៀបចំទុកដាក់កុមារតាមការថែទាំជំនួស នៅមណ្ឌលថែទាំជំនួសរបស់អង្គការមិនមែន រដ្ឋាភិបាល មានកុមារសរុប ១០នាក់ (ប្រុស០៥នាក់ ស្រី០៥នាក់) ដោយសារគ្រួសារក្រីក្រ គ្មានអ្នកមើលថែទាំ គ្មានជម្រកត្រឹមត្រូវ ខ្វះចំណីអាហារ ប្រឈមនឹងគ្រោះថ្នាក់ និងតម្រូវការការរៀនសូត្រ។
- សហការជាមួយអង្គការដៃគូ និងអាជ្ញាធរមូលដ្ឋាន សមាហរណកម្មកុមារសរុបចំនួន ២៦នាក់ (ស្រី១០នាក់ ប្រុស១៦នាក់) ចាកចេញពីការថែទាំជំនួសរបស់អង្គការមិនមែនរដ្ឋាភិបាលទៅរស់នៅជាមួយឪពុកម្ដាយបង្កើត និងសាច់ញាតិវិញ ។
- សហការជាមួយអង្គការដៃគូ និងអាជ្ញាធរមូលដ្ឋាន សមាហរណកម្មយុវជន ១៧នាក់ (ស្រី០៧នាក់ ប្រុស១០នាក់) ចាកចេញពីការថែទាំជំនួស របស់អង្គការមិនមែនរដ្ឋាភិបាល ទៅរស់នៅជាមួយឪពុកម្ដាយបង្កើត និងសាច់ញាតិវិញ ហើយពួកគាត់មានជំនាញវិជ្ជាជីវៈអាច ចិញ្ចឹមជីវិតដោយខ្លួនឯងបាន។
- សមាហរណកម្មយុវតី ០២នាក់ ករណី រំលោភបំពានផ្លូវភេទ ០១ករណី ករណីជួញដូរ ០១ករណី ចាកចេញពីការថែទាំជំនួសរបស់អង្គការARM ទៅរស់នៅដោយឯករាជ្យ ដោយគាត់មានការងារធ្វើ ទទួលបានប្រាក់ខែសមរម្យ។
- សហការជាមួយអង្គការដៃគូ និងអាជ្ញាធរមូលដ្ឋានបិទករណី មានកុមារសរុប ០៧នាក់(ស្រី០៣នាក់ ប្រុស០៤នាក់) និងយុវជនសរុប ០៣នាក់ (ស្រី០២នាក់ ប្រុស០១នាក់) ហើយសុខភាពផ្លូវចិត្ត ផ្លូវកាយរបស់កុមារ និងគ្រួសារបានល្អប្រសើរឡើងវិញ និងមានមុខរបរចិញ្ចឹមជីវិតបាន ដោយអង្គការបានឧបត្ថម្ភជាសម្ភារៈ ដើម្បីបង្កើតមុខរបរដល់ពួកគាត់។
- សហការជាមួយអាជ្ញាធរមូលដ្ឋាន និងអង្គការដៃគូចុះដោះស្រាយករណីកុមារត្រូវគេបោះបង់ចោលចំនួន០២ករណី មានកុមារ ០២នាក់ ។
- សហការជាមួយមន្ត្រីមន្ទីរសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទាខេត្ត បង្វែរកុមារ០៤នាក់ (ស្រី០២នាក់ ប្រុស ០២នាក់) ចេញពីអង្គការផ្ទះសុវត្ថិភាពមកមជ្ឈមណ្ឌលកុមារកំព្រាខេត្ត ដោយសារអង្គការអស់ជំនួយ។

**២.២.ការងារអតីតយុទ្ធជន**

- ចូលរួមវគ្គបណ្ដុះបណ្ដាលស្ដីពីវិស័យសង្គមកិច្ច នៅទីស្ដីការក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា
- ចូលរួមវគ្គបណ្ដុះបណ្ដាលស្ដីពី ការប្រើប្រាស់ប្រព័ន្ធបច្ចេកវិទ្យា (ឌីជីថល) សម្រាប់ធ្វើអធិការកិច្ចមណ្ឌលថែទាំកុមារ ចំនួន ០២លើក អ្នកសម្របសម្រួលរបស់មន្ត្រីសង្គមកិច្ច និងអង្គការសង្គមស៊ីវិលលើឧបករណ៍បណ្ដុះបណ្ដាលកំណត់គោលដៅ(កម្រិត២) ស្ដីពីការចិញ្ចឹមកូនបែបវិជ្ជមាន ចំនួន០២លើក ស្ដីពីសៀវភៅណែនាំធ្វើឲ្យប្រសើរឡើងនូវការថែទាំកុមារនៅតាមគ្រួសារ។
- ចូលរួមពិធីបើកអង្គរសង្ក្រាន ក្រោមអធិបតីភាពដ៏ខ្ពង់ខ្ពស់ សម្ដេចអគ្គសេនាបតីតេជោ **ហ៊ុន សែន** នាយក រដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា នៅបរិវេណមុខប្រាសាទបាយ័ន។
- សហការជាមួយអាជ្ញាធរមូលដ្ឋានចុះស្វែងរកជនចាស់ជរាគ្មានទីពឹងសុំទាននៅផ្សារក្រោម បច្ចុប្បន្នលោកយាយត្រូវបាន សប្បុរសជនស្វែងរកជំនួយ មានជំរកស្នាក់នៅបណ្ដោះអាសន្ន ស្ថិតនៅជិតផ្សារក្រោម ចំនួន០២លើក។

- សហការជាមួយ គ.ក.ន.ក សង្កាត់នគរធំ និងអនុភូមិអារក្សស្វាយ ចុះទៅដល់ផ្ទះជនពិការ និងទីទ័លក្រ ចំនួន ០២គ្រួសារ ស្ថិតនៅភូមិអារក្សស្វាយ សង្កាត់នគរធំ ក្រុងសៀមរាប ដើម្បីសួរសុខទុក្ខ និងយកឈ្មោះពួកគាត់ដើម្បីដាក់ទៅមន្ទីរស្នើសុំជំនួយ។
- ចូលរួមកិច្ចប្រជុំលើការងារ ការពារកុមារក្នុងខេត្តសៀមរាបស្តីពីស្ថានភាពកុមារដែលរស់នៅក្នុងមណ្ឌលថែទាំ និងផែនការប្រតិបត្តិខេត្ត ដើម្បីសមាហរណកម្មកុមារ៣០ភាគរយចេញពីមណ្ឌលថែទាំទៅក្នុងគ្រួសារ និងសហគមន៍ប្រកបដោយសុវត្ថិភាព ចំនួន០២លើក។
- អញ្ជើញបងប្អូនជនពិការ ចូលរួមក្នុងពិធីទិវាជនពិការកម្ពុជាលើកទី១៩ និងទិវាជនពិការ អន្តរជាតិលើកទី៣៥ នៅមន្ទីរសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា មន្ទីរខេត្តសៀមរាប។
- ចូលរួមអបអរសាទរខួបលើកទី១១ ទិវាអតីតយុទ្ធជនកម្ពុជា ២១ មិថុនា ឆ្នាំ២០១៨ នៅសាលមហោស្រប កោះពេជ្រ ក្រោមអធិបតីភាពដ៏ខ្ពង់ខ្ពស់សម្តេច អគ្គមហាសេនាបតីតេជោ **ហ៊ុន សែន** នាយករដ្ឋមន្ត្រី នៃ ព្រះរាជាណាចក្រកម្ពុជា និងជាប្រធានសមាគមអតីតយុទ្ធជនកម្ពុជា។
- ចូលរួមប្រជុំការងារសមាគមអតីតយុទ្ធជនកម្ពុជាខេត្ត ដើម្បីត្រួតពិនិត្យការងារសមាគម និងដីសម្បទានសង្គមកិច្ចក្នុងភូមិសាស្ត្រខេត្តសៀមរាប ក្រោមអធិបតីភាពដ៏ខ្ពង់ខ្ពស់ ឯកឧត្តម នាយឧត្តមសេនីយ៍បណ្ឌិត **គន់ គីម** អនុប្រធានកម្មាធិការកណ្តាល និងជាអគ្គលេខាធិការសមាគមអតីតយុទ្ធជនកម្ពុជា នៅទីបញ្ជាការដ្ឋានតំបន់ប្រត្តិបត្តិការសឹករងខេត្តសៀមរាប។
- ចូលរួមកិច្ចប្រជុំសាមញ្ញ អាណត្តិទី២ របស់ក្រុម ប្រឹក្សាក្រុងសៀមរាប នៅសាលប្រជុំ សាលាក្រុងសៀមរាប ចំនួន០៧លើក។
- ចូលរួមប្រជុំប្រចាំត្រីមាសរបស់គណៈកម្មាធិការទទួលបន្ទុកកិច្ចការស្ត្រី និងកុមារក្រុង ចំនួន ០២លើក ។
- ចូលរួមកិច្ចប្រជុំសារមេញ្ញរបស់គណៈកម្មាធិការពិគ្រោះយោបល់កិច្ចការស្ត្រី និងកុមារក្រុងសៀមរាប នៅសាលប្រជុំសាលាក្រុង ចំនួន ០៥លើក។
- ចូលរួមកម្មវិធីកិច្ចប្រជុំផ្សព្វផ្សាយពង្រឹងការអនុវត្តតួនាទីភារកិច្ចដល់គណកម្មាធិការពិគ្រោះ យោបល់កិច្ចការស្ត្រី និងកុមារក្រុង-ស្រុក និងគណកម្មាធិការទទួលបន្ទុកកិច្ចការនារី និងកុមារ ឃុំ-សង្កាត់ ចំនួន ០២លើក។
- រៀបចំកិច្ចប្រជុំរៀបចំបង្កើតសមាគមមនុស្សចាស់ សរុបចំនួន ៧សង្កាត់ មានសង្កាត់នគរធំ សង្កាត់ជ្រាវ សង្កាត់ទឹកវិល សង្កាត់សំបួរ សង្កាត់សៀមរាប សង្កាត់ចុងឃ្នៀស និងសង្កាត់ក្របីរៀល។
- ចូលរួមកិច្ចប្រជុំគណៈកម្មការអនុវត្តគម្រោងទីក្រុងគ្មានផ្សែងបារីក្រុងសៀមរាប ចំនួន០២លើក ការផ្សព្វផ្សាយច្បាប់ស្តីពីការគ្រប់គ្រងអ្នកប្រកបវិជ្ជាជីវៈវិស័យសុខាភិបាល ស្តីពីការសម្រេចដាក់ឲ្យប្រើប្រាស់នូវប្លង់គោលប្រើប្រាស់ដីក្រុងសៀមរាប ចក្ខុវិស័យឆ្នាំ២០៣៥ នៅសាលប្រជុំសាលាក្រុងសៀមរាប។
- ចូលរួមពិធីប្រកាស រដ្ឋបាលក្រុងសៀមរាប ជាកន្លែងធ្វើការគ្មានផ្សែងថ្នាំជក់ ។
- ចូលរួមកិច្ចប្រជុំធ្វើផែនការសមាហរណកម្មកុមារជាមួយមណ្ឌល ថែទាំកុមារក្នុងក្រុងសៀមរាប០១លើក ការគ្រប់គ្រងករណីកុមារ និងបង្រួបបង្រួមកុមារទៅគ្រួសារវិញ ចំនួន ០១លើក។
- ចូលរួមសិក្ខាសាលាស្តីពី សមាហរណកម្មកម្មវិធីវិនិយោគបីឆ្នាំរំកិល ឆ្នាំ(២០១៨-២០២០) ក្រុង-សង្កាត់ នៅថ្នាក់ក្រុង សិក្ខាសាលាផ្សព្វផ្សាយដាក់ឲ្យអនុវត្តរបបគោលនយោបាយ ចំពោះជនពិការក្រីក្រនៅតាមសហគមន៍។
- ចូលរួមពិធីចែកកង់ដល់កុមារក្រីក្រតាមសហគមន៍ ចំនួន៣០គ្រឿង នៅអង្គការអរុណរះកម្ពុជា

- ចូលរួមពិធីចែកអំណោយដល់គ្រួសារទីទ័លក្រ និងជន រងគ្រោះដោយគ្រោះមហន្តរាយ និងគ្រោះអគ្គីភ័យ ចំនួន៦១គ្រួសារ មកពី៣សង្កាត់ មាន សង្កាត់ស្លក្រាម សង្កាត់សៀមរាប និងសង្កាត់នគរធំ ទីតាំងនៅសាលាសង្កាត់ស្លក្រាម។
- សហការជាមួយអាជ្ញាធរមូលដ្ឋាន ចុះតាមដានកុមារដែលបានសមាហរណកម្មទៅក្នុងគ្រួសាររបស់ពួកគេវិញ ចំនួន៣លើក មានកុមារ ០៣នាក់ ។
- សហការជាមួយអាជ្ញាធរមូលដ្ឋាន និងអង្គការមេត្រីអន្តរជាតិ(នៅភ្នំពេញ) យកកុមារី០៣នាក់ មកសួរសុខទុក្ខគ្រួសារ ។
- សហការជាមួយអង្គការដៃគូ និងអាជ្ញាធរមូលដ្ឋានចុះតាមដានកុមារប្រឈមមុខនឹងការរំលោភបំពានធ្វើការនៅពេលយប់មានកុមារីចំនួន១១នាក់ ។
- សហការជាមួយកិច្ចការនារីសង្កាត់ និងអង្គការដៃគូចុះមកផ្ទះគ្រួសាររបស់កុមាររងគ្រោះដោយការជួញដូរ និងរំលោភបំពានផ្លូវភេទ មានកុមារី០៨នាក់ ដើម្បីធ្វើការប៉ាន់ប្រមាណគ្រួសារបច្ចុប្បន្នពួកគេទាំងអស់កំពុងស្នាក់នៅមណ្ឌលសុវត្ថិភាពរបស់អង្គការដៃគូ ដើម្បីរៀនជំនាញវិជ្ជាជីវៈ។
- សហការជាមួយអង្គការកម្ពុជាដើម្បីជួយស្ត្រីមានវិបត្តិ និងអាជ្ញាធរមូលដ្ឋានចុះទៅជួបជន រងគ្រោះដោយសារអំពើហិង្សាក្នុងគ្រួសាចំនួន០៩លើក មានស្ត្រីរងគ្រោះចំនួន២៨នាក់ អង្គការបានជួយដល់ស្ត្រីរងគ្រោះដើម្បីដាក់ពាក្យបណ្តឹងសុំលែងលះ និងសុំអាហារកាតព្វកិច្ចចិញ្ចឹមកូនទៅតុលាការហើយ បច្ចុប្បន្នកំពុងរង់ចាំសាលក្រមពីតុលាការ។
- សហការជាមួយអង្គការដៃគូ និងអាជ្ញាធរមូលដ្ឋានរៀបចំទុកដាក់កុមារតាមការថែទាំជំនួស នៅមណ្ឌលថែទាំជំនួសរបស់អង្គការមិនមែនរដ្ឋាភិបាល មានកុមារសរុប ១០នាក់ (ប្រុស០៥នាក់ ស្រី០៥នាក់) ដោយសារគ្រួសារក្រីក្រគ្មានអ្នកមើលថែទាំ គ្មានជម្រកត្រឹមត្រូវ ខ្វះចំណីអាហារ ប្រឈមនឹងគ្រោះថ្នាក់ និងតម្រូវការការរៀនសូត្រ។
- សហការជាមួយអង្គការដៃគូ និងអាជ្ញាធរមូលដ្ឋាន សមាហរណកម្មកុមារសរុបចំនួន ២៦នាក់ (ស្រី១០នាក់ ប្រុស១៦នាក់) ចាកចេញពីការថែទាំជំនួសរបស់អង្គការមិនមែនរដ្ឋាភិបាល ទៅរស់នៅជាមួយឪពុកម្តាយបង្កើត និងសាច់ញាតិវិញ ។
- សហការជាមួយអង្គការដៃគូ និងអាជ្ញាធរមូលដ្ឋាន សមាហរណកម្មយុវជន ១៧នាក់ (ស្រី០៧នាក់ ប្រុស១០នាក់) ចាកចេញពីការថែទាំជំនួសរបស់អង្គការមិនមែនរដ្ឋាភិបាល ទៅរស់នៅជាមួយឪពុកម្តាយបង្កើត និងសាច់ញាតិវិញ ហើយពួកគាត់មានជំនាញវិជ្ជាជីវៈអាចចិញ្ចឹមជីវិតដោយខ្លួនឯងបាន។
- សមាហរណកម្មយុវតី ០២នាក់ ករណី រំលោភបំពានផ្លូវភេទ០១ករណី ករណីជួញដូរ ០១ករណី ចាកចេញពីការថែទាំជំនួសរបស់អង្គការARM ទៅរស់នៅដោយឯករាជ្យដោយគាត់មានការងារធ្វើទទួលបានប្រាក់ខែសមរម្យ។
- សហការជាមួយអង្គការដៃគូ និងអាជ្ញាធរមូលដ្ឋាន បិទករណី មានកុមារសរុប ០៧នាក់(ស្រី០៣នាក់ ប្រុស០៤នាក់) និងយុវជនសរុប ០៣នាក់ (ស្រី០២នាក់ ប្រុស០១នាក់) ហើយសុខភាពផ្លូវចិត្តផ្លូវកាយរបស់កុមារ និងគ្រួសារបានល្អប្រសើរឡើងវិញ និងមានមុខរបរចិញ្ចឹមជីវិតបាន ដោយអង្គការបានឧបត្ថម្ភជាសម្ភារៈ ដើម្បីបង្កើតមុខរបរដល់ពួកគាត់។
- សហការជាមួយអាជ្ញាធរមូលដ្ឋាន និងអង្គការដៃគូចុះដោះស្រាយករណីកុមារត្រូវគេបោះបង់ ចោលចំនួន ០២ករណី មានកុមារ ០២នាក់ ។

- សហការជាមួយមន្រ្តីមន្ទីរសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទាខេត្ត បង្វែរកុមារ ០៤នាក់ (ស្រី០២នាក់ ប្រុស ០២នាក់) ចេញពីអង្គការផ្ទះសុវត្ថិភាពមកមជ្ឈមណ្ឌលកុមារកំព្រាខេត្ត ដោយសារអង្គការអស់ជំនួយ។

**២.២.ការងារអតីតយុទ្ធជន**

- រៀបចំបៀវត្សប្រចាំខែ មករា-មិថុនា ជូនមុខសញ្ញាអតីតយុទ្ធជន ក្នុងនោះមានជនពិការចំនួន **៦០៥**នាក់, និវត្តន៍ជនចំនួន **៧៨១**នាក់, ជនបាត់បង់សមត្ថភាពការងារចំនួន**៣១**នាក់, ជនពលីចំនួន **៣៩៤**នាក់ ជនមរណៈចំនួន **១៦៩**នាក់។
- សហការជាមួយកម្លាំងប្រដាប់អាវុធមាន ផ្នែកសឹករងក្រុង អធិការដ្ឋាននគរបាលក្រុង បញ្ជាការដ្ឋានកងរាជអាវុធហត្ថក្រុង និងអាជ្ញាធរមូលដ្ឋាន ពិធីប្រគល់ប្រាក់មរណៈសង្គ្រោះចំនួន **៤,០០០,០០០**(**បួនលាន**)រៀល ជូនគ្រួសារសព ជាសមាជិកសមាគម អតីតយុទ្ធជនកម្ពុជាចំនួន **២៥** គ្រួសារ ។
- លុបឈ្មោះមុខសញ្ញាអតីតយុទ្ធជន ទទួលមរណៈភាពចំនួន ២៣នាក់ និងរៀបចំធ្វើសំណើសុំផ្តល់ប្រាក់ធានារ៉ាប់រងសង្គម ប្រាក់បូជាសព ប្រាក់ឧបត្ថម្ភមួយលើក និងសុំទទួលស្គាល់ជាជនពលី ០៨នាក់ និងជនមរណៈ ចំនួន ១៥នាក់។
- លុបកូន និងបន្ទុកមុខសញ្ញាអតីតយុទ្ធជនចំនួន៣៨នាក់ ក្នុងនោះមាន កូនចំនួន៣៤នាក់ បន្ទុកចំនួន០៤នាក់។
- ចូលរួមពិធីបើកប្រាក់ធានារ៉ាបរងសង្គម ប្រាក់បូជាសព និងប្រាក់ ឧបត្ថម្ភមួយលើក ចំនួន ២៩នាក់ ដោយឡែកក្រុងសៀមរាបចំនួន ០៤នាក់ ជូនគ្រួសារអតីត យុទ្ធជននៅគេហដ្ឋាន ក្នុងក្រុងសៀមរាប។
- រៀបចំសំណើសុំលិខិតផ្តល់សិទ្ធិបើកប្រាក់របបសន្តិសុខសង្គមប្រចាំខែជំនួស ជូនគ្រួសារ អតីតយុទ្ធជន ចំនួន ១០០នាក់ ក្នុងនោះមានជម្ងឺចំនួន ៧៨នាក់ ទទួលមរណភាពចំនួន ២២នាក់។
- ការិយាល័យសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទាក្រុង បានរៀបចំពិធីបើកប្រាក់ធានារ៉ាប់រងសង្គម ជូនគ្រួសារសពអតីត យុទ្ធជន ជានិវត្តជនចំនួន ០៤ គ្រួសារ ។
- ចំពោះអតីតយុទ្ធជន និងគ្រួសារអតីតយុទ្ធជនថ្មី ដែលផ្ទេរមកពីអន្តរក្រសួង ទើបទទួលបាន ប្រកាសផ្តល់របប និងមុខសញ្ញាដែលអវត្តមានយុរមិនបង្ហាញមុខធ្វើបច្ចុប្បន្នភាពតាមកាលកំណត់បេឡាជាតិអតីតយុទ្ធជន បានចាត់ក្រុមការងារចុះធ្វើបច្ចុប្បន្នភាព នៅមន្ទីរសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា នៃមណ្ឌលរដ្ឋបាលមន្ទីរខេត្តសៀមរាប។ វត្តមានអតីតយុទ្ធជន និងគ្រួសារអតីតយុទ្ធជនចំនួន ៤១នាក់ ក្នុងនោះមាន និវត្តជន ចំនួន ០៤នាក់ និងគ្រួសារជនពលីមរណៈ ចំនួន២៦នាក់។
- រៀបចំបែបបទមុខសញ្ញាអតីតយុទ្ធជនសុំចូលជាសមាជិកសមាគមអតីតយុទ្ធជនកម្ពុជាបាន ចំនួន ៣២នាក់ ស្រី០៣នាក់។
- រៀបចំបែបបទសមាជិកសមាគមអតីតយុទ្ធកម្ពុជា (ពួកចាស់) បានចំនួន ៣២នាក់ ស្រី១៧នាក់។
- បានរៀបចំប័ណ្ណសមាជិក ប.ស.ស របស់អតីតយុទ្ធជនខុសព័ត៌មានផ្សេងៗ ការិយាល័យបេឡាអតីតយុទ្ធជនខេត្ត និងសាខាបេឡាអតីតយុទ្ធជនក្រុង ត្រូវចេញលិខិតបញ្ជាក់ជូន អតីតយុទ្ធជនដើម្បីផ្លាស់ប្តូរ ឬបន្ថែមព័ត៌មានផ្សេងៗក្នុងប័ណ្ណសមាជិក ប.ស.ស បានចំនួន ១៧នាក់ ស្រី០នាក់ និងសម្របសម្រួលអំពីការទទួលសេវាថែទាំសុខភាពជូនអតីតយុទ្ធជន ។

**២.៣.ការងារយុវនីតិសម្បទា**

- ចូលរួមប្រជុំដោះស្រាយនៅអង្គការកល្យាណមិត្ត ចំនួន ០៣លើក ករណីកុមាររត់ចេញពី មណ្ឌលដើរលេងនៅពេលយប់បានធ្វើកិច្ចសន្យាកែប្រែខ្លួនឈប់ប្រព្រឹតទៅទៀតហើយបន្តស្នាក់នៅ មណ្ឌលបន្ត។

- ដើម្បីសមាហរណកម្ម យុវជន០១នាក់ ភេទប្រុស អាយុ៣៤ឆ្នាំ ចេញពីពន្ធនាគារមកជួបជុំ គ្រួសារវិញ (ករណីជួញដូរ រក្សាទុក និងចាត់ចែងដោយខុសច្បាប់នូវសារធាតុញៀន) គាត់បានធ្វើការប្តេជ្ញាចិត្តឈប់ប្រព្រឹត្តតទៅទៀត និងមានផែនការច្បាស់លាស់ក្នុងការធ្វើឲ្យជីវភាព គ្រួសារមានភាពល្អប្រសើរឡើង ។

### ៣.២.៤.ការិយាល័យអប់រំយុវជននិងកីឡា

**ក/ ផ្នែកចំណេះទូទៅ និងមត្តេយ្យ**

- ធ្វើរបាយការណ៍បូកសរុបប្រចាំឆ្នាំសិក្សា២០១៦-២០១៧ និងលើកទិសដៅបន្តសម្រាប់ឆ្នាំសិក្សា២០១៧-២០១៨ ដាក់ជូនអង្គសន្និបាតបូកសរុបប្រចាំឆ្នាំដើម្បីលើកទិសដៅអនុវត្តផែនការបន្តសម្រាប់ឆ្នាំសិក្សាថ្មី។
- ប្រជុំធ្វើគម្រោងថវិកា S.I.F សម្រាប់ឆ្នាំសិក្សា២០១៧-២០១៨។
- ប្រជុំបូកសរុបរបាយការណ៍ប្រចាំឆមាសទី១ ឆ្នាំសិក្សា២០១៧-២០១៨។
- បញ្ចូលរបាយការណ៍បវរនកាលឆ្នាំសិក្សា២០១៨-២០១៩ នៃ សាលាបឋមសិក្សា និងមធ្យមសិក្សាទាំងអស់ក្នុងក្រុងសៀមរាប។
- ប្រមូលរបាយការណ៍សិស្សអាហាររូបករណ៍លើកទី១ សម្រាប់សាលាបឋមសិក្សា និងមធ្យមសិក្សាក្នុងឆ្នាំសិក្សា២០១៨-២០១៩។
- ចូលរួមប្រជុំផ្សព្វផ្សាយការប្រើប្រាស់សៀវភៅភាសាខ្មែរថ្នាក់ទី១ និងផ្តោតទៅលើការប្រើប្រាស់សម្ភារៈ។
- ប្រមូលរបាយការណ៍ពីសាលាដែលមានកុំព្យូទ័រសម្រាប់ឲ្យសិស្សរៀន។
- ប្រជុំផ្សព្វផ្សាយការងារបច្ចេកទេសដល់គ្រូមត្តេយ្យទាំងអស់ក្នុងក្រុងសៀមរាប។
- ប្រមូលរបាយការណ៍សិក្សាពូកែប្រចាំឆ្នាំ។

**ខ/ ផ្នែកបុគ្គលិករដ្ឋបាលផែនការសម្ភារៈ និងគណនេយ្យ**

- បានទទួលសៀវភៅគោលសម្រាប់ឆ្នាំសិក្សា២០១៧-២០១៨ របស់ក្រសួងអប់រំយុវជន និងកីឡាចំនួន ១២២ ២០៦ក្បាល បានចែកជូនទៅតាមគ្រឹះស្ថានសិក្សាទាំងអស់ក្នុងក្រុងសៀមរាប។
- ធ្វើផែនការតម្រូវការសៀវភៅសិក្សាគោលបន្ថែមសម្រាប់ឆ្នាំសិក្សាបន្តបន្ទាប់។
- ធ្វើរបាយការណ៍ពីសមិទ្ធផលការងារវិស័យអប់រំក្នុងក្រុងសៀមរាបរយៈពេល៥ឆ្នាំ ២០១៤-២០១៨។
- បានបើកប្រាក់អាហាររូបករណ៍សិស្សនៅតាមគ្រឹះស្ថានសិក្សាទាំងមធ្យមនិងបឋមបានទៀងទាត់។
- ប្រមូលPre-Pri ចុងឆ្នាំសិក្សា២០១៧-២០១៨។
- ធ្វើបញ្ជីរាយនាមសិស្សអាហាររូបករណ៍បឋមសិក្សាសម្រាប់ឆ្នាំ២០១៨-២០១៩។
- រៀបចំបញ្ជីតារាងប្រាក់បៀវត្សប្រចាំខែបានទៀងទាត់។
- ធ្វើសំណើសុំតម្លើងថ្នាក់ជូនមន្ត្រីអប់រំប្រចាំឆ្នាំ២០១៨។
- ទទួលតារាងបញ្ជីវត្តមានប្រចាំខែពីគ្រប់សាលាទាំងអស់ក្នុងក្រុងសៀមរាប។
- តារាងប្រៀបធៀបសិស្ស និងគ្រូសម្រាប់ឆ្នាំសិក្សា២០១៨-២០១៩។
- ធ្វើការប៉ាន់ស្មានតម្រូវការគ្រូបង្រៀនសម្រាប់ឆ្នាំសិក្សា២០១៨-២០១៩។
- ប្រជុំបង្កើតគណៈកម្មការជ្រើសរើសគ្រូជាប់កិច្ចសន្យាសម្រាប់ឆ្នាំសិក្សា២០១៨-២០១៩។
- គណៈកម្មការប្រជុំវាយតម្លៃគ្រូជាប់កិច្ចសន្យានៅតាមសាលាបឋមសិក្សាក្នុងក្រុងសៀមរាប។
- បានរៀបចំច្បាប់លំហែមាតុភាព ច្បាប់សម្រាករយៈពេលខ្លី និងរៀបចំប្រាក់បៀវត្សប្រចាំខែបានទៀងទាត់ ទាន់ពេលវេលា។

**គ/ ផ្នែកអប់រំក្រៅប្រព័ន្ធ**

-បើកថ្នាក់អក្ខរកម្មវិជ្ជាជីវៈ និងប្រមូលអន្ទរៈជននៅតាមសមាគមន៍ឲ្យចូលរៀនឡើងវិញ។

- បូកសរុបកម្មវិធីចូលរៀនឡើងវិញទូទាំងក្រុងសៀមរាប។
- បូកសរុបកម្មវិធីអក្ខរកម្មទូទាំងក្រុងសៀមរាប។
- បើកថ្នាក់អក្ខរកម្មសមមូលបឋមសិក្សាចំនួន៣ថ្នាក់។
- របាយការណ៍មជ្ឈមណ្ឌលសិក្សាសហគមន៍២កន្លែង។

**ឃ/ ផ្នែកយុវជន និងកីឡា**

- បានរៀបចំការប្រកួតកីឡាសិស្សប្រចាំឆ្នាំសិក្សា២០១៧-២០១៨។
- ចុះជួយការងារសាលកុមារមេត្រី និងកាយរិទ្ធិប្អូន។
- ផ្ញើបញ្ជីរាយនាមសមាជិកកាយរិទ្ធថ្មីសម្រាប់ឆ្នាំសិក្សា២០១៨-២០១៩។

**ង/ លទ្ធផលការងារសម្រេចបាន**

- អនុវិទ្យាល័យ ធ្លកអណ្ដូងបានអំណោយអគារថ្ម២ខ្នង ២ ជាន់ ស្មើនិង១២បន្ទប់ ជាអំណោយរបស់ប្រជាពលរដ្ឋជប៉ុន។
- បឋមសិក្សាហ៊ុន សែន អញ្ចាញទទួលបានអំណោយអគារថ្មថ្មី១ខ្នង ២បន្ទប់ និងបន្ទប់ទឹក១ខ្នង៥បន្ទប់ ជាអំណោយរបស់ធនាគារកូរ៉េ។
- អនុវិទ្យាល័យពោធិបន្ទាយជ័យទទួលអគារថ្ម ១ខ្នង ៥បន្ទប់ និងបន្ទប់ទឹក ១ខ្នង ៨បន្ទប់ ថវិកាសរុប ១៣០ ០០០ ដុល្លាជាអំណោយរបស់មូលនិធិឡាយអិនក្លិប អន្តរជាតិ និងប្រជាជនជប៉ុនតំបន់ ៣៣៣ស៊ី។
- អុនវិទ្យាល័យពោធិបន្ទាយជ័យទទួលអគារថ្ម១ខ្នង ២ជាន់ ៨បន្ទប់ ថវិកាសរុប ១០០ ០០០ ដុល្លា ជាអំណោយរបស់សមាគន៍ព្រះសង្ឃវត្តពោធិជ័យ។

## ៣.២.៥.ការិយាល័យផែនការ និងស្ថិតិ

- បានចូលរួមប្រជុំស្ដីពីការណែនាំផ្សេងៗដល់មន្ត្រីនានានៅសាលក្រុង ការិយាល័យជំនាញនិងចំណុះ នៅសាលប្រជុំរដ្ឋបាលក្រុងសៀមរាប ចំនួន២លើក។
- ការិយាល័យផែនការបានចូលរួមសមាហរណកម្ម កម្មវិធីវិនិយោគបីឆ្នាំរំកិលក្រុង ២០១៨-២០២០ នៅសាលប្រជុំក្រុងសៀមរាប។
- បានចូលរួមកិច្ចប្រជុំសាមញ្ញ អាណត្តិទី២ របស់គណៈកម្មាធិការពិគ្រោះយោបល់កិច្ចការស្ត្រី និងកុមារក្រុងសៀមរាប (គ.ក.ស.ក) នៅសាលប្រជុំក្រុងសៀមរាប ចំនួន១១លើក។
- បានចូលរួមកិច្ចប្រជុំសាមញ្ញ អាណត្តិទី២ របស់ក្រុមប្រឹក្សាក្រុង នៅសាលប្រជុំរដ្ឋបាលក្រុងសៀមរាប ចំនួន ១២លើក។
- ចូលរួមប្រជុំគណៈបញ្ជាការឯកភាពក្រុងសៀមរាបនៅសាលប្រជុំរដ្ឋបាលក្រុងសៀមរាបចំនួន៦លើក។
- បានចូលរួមប្រជុំជាមួយ GGGI គម្រោងវិនិយោគហេដ្ឋារចនាសម្ព័ន្ធក្រុងសៀមរាបនៅសាលប្រជុំក្រុងសៀមរាប
- បានចូលរួមទិវាសម្អាតបរិស្ថានក្រុងសៀមរាប ចំនួន៥លើក។
- បានចូលរួមសិក្ខាសិលាស្ដីពី ការចូលរួមចំណែកស្រឡាញ់បរិស្ថានយើង នៅសាលប្រជុំរដ្ឋបាលក្រុងសៀមរាប
- បានចូលរួមប្រជុំគណៈកម្មកាអនុវត្តគម្រោងគ្មានផ្សែងបារី នៅសាលក្រុងសៀមរាប ចំនួន៣លើក។
- ការិយាល័យផែនការស្ថិតិក្រុងសៀមរាប បានចូលរួមប្រជុំស្ដីពីការអនុវត្តការងារនិងរបាយការណ៍បូកសរុបប្រចាំឆ្នាំ២០១៨ និងការលើកទិលដៅការងារឆ្នាំ២០១៨ និងធ្វើការផ្សព្វផ្សាយពីខ្លឹមសារទិវាសិទ្ធិនារីអន្តរជាតិ០៨មិនាឆ្នាំ២០១៨ នៅមន្ទីរផែនការខេត្តសៀមរាប។
- បានចូលរួមប្រជុំគណៈអភិបាលក្រុងសៀមរាប ស្ដីពីការពង្រឹងសមត្ថភាពការងារ ការអនុវត្តតួនាទីនិងភារកិច្ច និងការលើកផែនការសកម្មភាពការងារសម្រាប់ព្រឹត្តិការណ៍អង្គរសង្ក្រាន នៅសាលប្រជុំក្រុងសៀមរាប។

- បានចូលរួមប្រជុំស្តីពី កិច្ចសហការការពារសន្តិសុខ សុវត្ថិភាព និងសណ្តាប់ធ្នាប់សាធារណៈ សម្រាប់ដំណើរការបោះឆ្នោតជ្រើសរើស តំណាងរាស្ត្រនីតិកាលទី៦ឆ្នាំ២០១៨ នៅថ្ងៃអាទិត្យទី២៩ ខែកក្កដា ឆ្នាំ២០១៩។
- បានចូលរួមប្រជុំគណៈកម្មការសម្របសម្រួលការងារអាហារូបត្ថម្ភខេត្ត ដើម្បីផ្សព្វផ្សាយពង្រឹងការអនុវត្តខ្លឹមសារប្រការលេខ ៤៨ កជអជ ស្តីពីការផលិតប្រើប្រាស់ទឹកត្រី ទឹកស៊ីអីវមានជាតិដែក និងសារៈសំខាន់ នៃការប្រើប្រាស់ទឹកត្រី ទឹកស៊ីអីវមានជាតិដែក នៅសណ្ឋាគារ សេរីភាពខេត្តសៀមរាប។
- ការិយាល័យផែនការនិងស្ថិតិក្រុងសៀមរាបបានចូលរួមទិវាមច្ឆជាតិលើកទី១៦ នៅកសិណអង្គរ ភូមិត្រពាំងសេះ សង្កាត់គោកចក ក្រុងសៀមរាប ខេត្តសៀមរាប។
- បានចូលរួមប្រជុំផ្សព្វផ្សាយសេចក្តីណែនាំស្តីពីការរៀបចំកសាងកម្មវិធីវិនិយោគបីឆ្នាំរំកិល នៅសាលាខេត្តសៀមរាប។
- បានចូលរួមប្រជុំឆ្លងសេចក្តីព្រាងកម្មវិធីវិនិយោគបីឆ្នាំរំកិលក្រុង២០១៩-២០២០ រដ្ឋបាលក្រុងសៀមរាប។
- ចូលរួមរៀនវគ្គបណ្តុះបណ្តាលស្តីពីអត្តសញ្ញាណកម្មគ្រួសារក្រីក្រជុំទី១២ ឆ្នាំ២០១៨ នៅសាលប្រជុំមន្ទីរផែនការខេត្តសៀមរាប។
- ជ្រើសរើសក្រុមតំណាងគណៈកម្មាធិការកសាងផែនការនិងថវិកា (គ.ផ.ថ) ថ្នាក់សង្កាត់ និងអ្នកសម្របសម្រួលក្រុមតំណាងភូមិ (ក.ត.ភ) និងការជ្រើសរើសសមាជិកក្រុមតំណាងភូមិ គ្រប់ភូមិ។
- ក្រុមការងារទទួលបន្ទុកអត្តសញ្ញាណកម្មគ្រួសារក្រីក្រ មកពីមន្ទីរផែនការខេត្តសៀមរាប សហការជាមួយការិយាល័យផែនការស្ថិតិក្រុងសៀមរាប ធ្វើការបើកវគ្គ បណ្តុះបណ្តាល អត្តសញ្ញាណកម្មគ្រួសារក្រីក្រជុំទី១២ ឆ្នាំ២០១៨ ទៅដល់ចៅសង្កាត់ ស្មៀន គ.ផ.ថ សង្កាត់ និង ក.ត.ភ គ្រប់សង្កាត់ទាំងអស់ក្នុងក្រុងសៀមរាប នៅសាលប្រជុំមន្ទីរផែនការខេត្តសៀមរាប និងសាលប្រជុំរដ្ឋបាលក្រុងសៀមរាប។
- ការិយាល័យផែនការស្ថិតិក្រុងសៀមរាប ចុះពិនិត្យមើលការបណ្តុះបណ្តាល អត្តសញ្ញាណកម្មគ្រួសារក្រីក្រជុំទី១២ ឆ្នាំ២០១៨ នៅតាមគ្រប់សង្កាត់ទាំងអស់ក្នុងក្រុងសៀមរាប។
- ចូលរួមប្រជុំស្តីពីពិធីប្រកាសតែងតាំងលោកអភិបាលក្រុងសៀមរាបថ្មីនៅសាលប្រជុំរដ្ឋបាលក្រុងសៀមរាប។
- រៀបចំកម្មវិធីសិក្ខាសាលា សមាហរណកម្មកម្មវិធីវិនិយោគបីឆ្នាំរំកិលក្រុង សង្កាត់ ឆ្នាំ២០១៩-២០២១ នៅថ្នាក់ក្រុង ស្រុក ឆ្នាំ២០១៨ នៅសាលប្រជុំ រដ្ឋបាលក្រុងសៀមរាប។

### ៣.២.៦.ការិយាល័យកិច្ចការនារី

- បានរៀបចំកិច្ចប្រជុំរបស់គណៈកម្មាធិការពិគ្រោះយោបល់កិច្ចការស្ត្រី និងកុមារក្រុងសៀមរាប អាណត្តិទី២ ចំនួន១២លើក។
- បានចុះគាំទ្រសកម្មភាពរបស់គណៈកម្មាធិការទទួលបន្ទុកកិច្ចការនារី និងកុមារសង្កាត់ បានចំនួន១៧៨លើក ។
- បានរៀបកិច្ចប្រជុំគណៈកម្មាធិការទទួលបន្ទុកកិច្ចការនារី និងកុមារថ្នាក់ក្រុងប្រចាំត្រីមាសបានចំនួន០៦លើក។
- បានចូលរួមកិច្ចប្រជុំក្រុមប្រឹក្សាក្រុងសៀមរាប ចំនួន១១ លើក ។
- បានចូលរួមចុះផ្សព្វផ្សាយផ្សេងៗទាក់ទងយេនឌ័រ បានចំនួន ០៨លើក ។
- បានចូលរួមសិក្ខាសាលាផ្សេងៗ បានចំនួន១៤លើក ។
- បានសមាហរណកម្មក្មេងពីអង្គការនានាឲ្យទៅរស់នៅជាមួយគ្រួសារ និងពីគ្រួសារឲ្យទៅនៅអង្គការវិញ សរុបចំនួនបាន១៣១លើក។
- បានជួយស្ត្រីមានផ្ទៃពោះដែលមានស្ថានភាពក្រីក្រ បានចំនួន ២៣លើក ។
- បានចែកអំណោយទៅដល់កុមារក្រីក្រនៅតាមសាលារៀននានានៅក្នុងក្រុងសៀមរាបបានចំនួន៣៤លើក ។

- បានសហការរៀបចំកិច្ចប្រជុំបណ្ដាញចម្រុះថ្នាក់ក្រុង ដែលមានការឧបត្ថម្ភពីអង្គការកម្ពុជាដើម្បីជួយស្ត្រីមានវិបត្តិ(CWCC)បានចំនួន០៦លើក ។
- បានឧបត្ថម្ភទៅដល់គ្រួសារសេពដែលស្ថានភាពក្រីក្រនៅតាមសង្កាត់ក្នុង០១គ្រួសារទទួលបាន៣០ដុល្លា ដែលមានចំនួន ៨៣គ្រួសារ ដោយមានការឧបត្ថម្ភពីអង្គការSCC។
- បានរៀបចំដោះស្រាយវិវាទគ្រួសារក្រៅប្រព័ន្ធតុលាការថ្នាក់ក្រុងសៀមរាប ចំនួន០៩ករណី ដោយ០៦ករណីដោះស្រាយនឹងសម្របសម្រួលតាមនិតីវិធីបានរួចរាល់ ហើយចំនួន០៣ករណីកំពុងរៀបចំដំណើរការតាមនិតីវិធីដោះស្រាយ ។
- បានទទួលសំណុំរឿង ករណីដោះស្រាយវិវាទគ្រួសារក្រៅប្រព័ន្ធតុលាការ ចំនួន ៩ករណី ។
- បានសហការជាមួយកាកបាទក្រហមកម្ពុជា ថ្នាក់ក្រុងចុះចែកអំណោយដល់ជនរងគ្រោះផ្សេងៗ បានចំនួន០៦លើក ។
- បានចុះជួយដោះស្រាយវិវាទគ្រួសារក្រៅប្រព័ន្ធតុលារ នៅតាមសង្កាត់បានចំនួន ៤លើក ។
- បានចុះផ្សព្វផ្សាយអំពីករណីទាក់ទងនឹងហឹង្សាក្នុងគ្រួសារ នៅតាមសង្កាត់បានចំនួន ៣លើក ។
- បានចូលរួមសិក្ខាសាលាផ្សេងៗ ដែលទាក់ទង់ ពីយេនឌ័រ និងជនរងគ្រោះស្ត្រី និងកុមារ បានចំនួន ៤លើក។
- បានរៀបចំកម្មវិធី ទិវាសិទ្ធនារីអន្តរជាតិ ៨មីនាថ្នាក់ក្រុង នៅសាលប្រជុំធំខេត្តសៀមរាប បានចំនួន១លើកមានអ្នកចូលរួមចំនួន ៣៥០នាក់ ។
- បានចូលរួមប្រជុំ គណៈបញ្ជាការឯកភាពក្រុង បានចំនួន ១២លើក ។

### ៣.២.៧.ការិយាល័យព័ត៌មាន

**១. ការផ្សព្វផ្សាយសកម្មភាពក្រុមប្រឹក្សា**

- ផ្សព្វផ្សាយសេចក្ដីជូនដំណឹង និងលទ្ធផលនៃកិច្ចប្រជុំសាមញ្ញបានចំនួន ១១លើក។
- ផ្សព្វផ្សាយពីកិច្ចប្រជុំសាមញ្ញ និងវិសាមញ្ញរបស់ក្រុមប្រឹក្សាក្រុងបាន ១២លើក។

**២. ការផ្សព្វផ្សាយសកម្មភាពគណៈកម្មាធិការពិគ្រោះយោបល់កិច្ចការស្ត្រីនិងកុមារ**

- ផ្សព្វផ្សាយលទ្ធផលនៃកិច្ចប្រជុំសាមញ្ញ របស់ គ.ក.ស.ក បាន ១១លើក។

**៣. ការផ្សព្វផ្សាយសកម្មភាពអភិវឌ្ឍន៍ក្រុង**

- ផ្សព្វផ្សាយសកម្មភាពអភិវឌ្ឍន៍ និងសេចក្ដីជូនដំណឹងផ្សេងៗរបស់គណៈអភិបាលក្រុងបាន ៩២លើក។ សកម្មភាពទាំងអស់ខាងលើនេះធ្វើការផ្សព្វផ្សាយតាមរយៈទូរទស្សន៍ខ្សែកាបអង្គរ និងវិទ្យុ FM ជាតិនគរភ្នំ។

### ៣.២.៨.ការិយាល័យសុខាភិបាល

**១.លើកកម្ពស់សុខុមាលភាព មាតា កុមារ និង ទារក**

- ស្ត្រីមានផ្ទៃពោះបានមកពិនិត្យផ្ទៃពោះលើកទី១មានចំនួន ៧ ៩៤៤នាក់
- ស្ត្រីមានផ្ទៃពោះបានមកពិនិត្យផ្ទៃពោះលើកទី២មានចំនួន ៨ ៥៦២នាក់
- ស្ត្រីក្នុងវ័យបន្តពូជបានមកទទួលមធ្យោបាយពន្យារកំណើតករណីថ្មីមានចំនួន ៤ ៦៤០នាក់
- ស្ត្រីមកសម្រាលកូននៅមណ្ឌលសុខភាពមានចំនួន ៤៩៤នាក់
- កុមារអាយុក្រោម១ឆ្នាំមកទទួលថ្នាំបង្ការជំងឺ១២មុខមានចំនួន ៦ ០១៦នាក់

**២.ការអប់រំផ្សព្វផ្សាយអំពីវិធីទប់ស្កាត់ និងបង្ការជំងឺឆ្លង-ជំងឺមិនឆ្លង៖**

- នៅតាមមណ្ឌលសុខភាពចំនួន ១១ កន្លែង បានចំនួន ១៣២ លើក

**៣.ជំរុញការផ្ដល់សេវាសុខាភិបាលនៅតាមមណ្ឌលសុខភាព៖**

- ពិគ្រោះជំងឺក្រៅករណីថ្មីបាន ១៣៥ ០៨០នាក់

- ពិគ្រោះជំងឺក្រៅករណីសរុបបាន ១៣៧ ៦៦៩នាក់

**៤.ការគ្រប់គ្រងស្ថិតិមន្ទីរពេទ្យរដ្ឋ ឯកជន ឱសថស្ថាន និង បុគ្គលិកសុខាភិបាលក្រុង**

| | |
|---|---|
| - មន្ទីរពហុព្យាបាលមាន | ០៤ កន្លែង |
| - មន្ទីរសម្រាកព្យាបាលមាន | ១៣ កន្លែង |
| - បន្ទប់ពិគ្រោះជំងឺមាន | ៧៩ កន្លែង |
| - បន្ទប់ពិគ្រោះស្ត្រីមានផ្ទៃពោះមាន | ១៥ កន្លែង |
| - បន្ទប់ថែទាំជំងឺមាន | ៤៤ កន្លែង |
| - មន្ទីរសម្រាកព្យាបាលជំងឺមាត់-ធ្មេញមាន | ០៤ កន្លែង |
| - បន្ទប់ពិគ្រោះព្យាបាលជំងឺមាត់-ធ្មេញមាន | ៣៤ កន្លែង |
| - ឱសថស្ថាន-ឱសថស្ថានរងមាន | ១៨៦ កន្លែង |
| - មន្ទីរពិសោធន៍វេជ្ជសាស្ត្រ | ០៦ កន្លែង |

**៣.២.៩-ការិយាល័យអភិវឌ្ឍន៍ជនបទ (មិនផ្តល់របាយការណ៍)**

**៣.២.១០-ការងារកាកបាទក្រហម**

**ក-ការកសាងសមាជិកទ្រទ្រង់កាកបាទក្រហម និងការប្រមូលថវិកាទ្រទ្រង់**

- បានកសាង និងប្រមូលថវិកាសមាជិកទ្រទ្រង់កាកបាទក្រហមកម្ពុជា បានចំនួន១៣ការិយាល័យ គណៈអភិបាល ក្រុមប្រឹក្សា នាយករដ្ឋបាលសរុបបាន សមាជិកចំនួន ១០ ៩៦ នាក់ ថវិកាបាន ៤៦៨២០០០រៀល និង ១២ សង្កាត់ បានសមាជិកសរុប ៩២៧នាក់ ថវិកាបាន ៥២៧៣០០០រៀល សរុបទាំងអស់ការិយាល័យ និងសង្កាត់ សមាជិក បាន ២០២៣នាក់ ថវិកាបាន ៩៩៥០០០រៀល (ប្រាំបួនលាន ប្រាំបួនរយហាសិបប្រាំពាន់រៀលគត់)

**ខ-ការប្រមូលថវិកាហិបសប្បុរស តាមបណ្តាវត្តក្នុងក្រុង**

- បានទទួលអង្ករចំនួន១ ១៥០គ.ក្រ ទឹកស៊ីអ៊ីវចំនួន១០០ដប និងទឹកត្រីចំនួន១០០ដប ពីសាលាក្រុងសៀមរាប។
- បានទទួលថវិកាសប្បុរសពីសប្បុរសជនតាមបណ្តាសង្កាត់ក្នុងក្រុងបានចំនួន១ ៩០០ ០០០រៀល។
- បានប្រមូលថវិកាហិបសប្បុរសនៅតាមបណ្តាវត្តក្នុងក្រុង សប្បុរសជនតាមបណ្តាសង្កាត់ក្នុងក្រុងសរុបបាន ២៥៣៣៥០០រៀល (ពីរលាន ប្រាំរយ សាមសិបបីពាន់ ប្រាំរយរៀលគត់)

**គ-ការផ្តល់អំណោយសង្គ្រោះដល់ជនរងគ្រោះដោយសារគ្រោះមហន្តរាយផ្សេងៗ**

- ចូលរួមជាគណៈកម្មាធិការសាខាខេត្តចុះប្រគល់ផ្ទះ សាខាកាកបាទក្រហមកម្ពុជាខេត្តសៀមរាបដល់ គ្រួសារក្រីក្រ ចំនួន៤គ្រួសារគឺនៅសង្កាត់ស្រង៉ែ ភូមិព្រៃធំមួយគ្រួសារ និងភូមិស្រង៉ែមួយគ្រួសារ សង្កាត់សាលាកំរើក ភូមិវត្ត ដំណាក់មួយគ្រួសារ សង្កាត់ស្លក្រាម ភូមិធ្លកអណ្តូងមួយគ្រួសារនិងមានអំណោយសង្កាត់ផ្ទះមានស្បៀង គ្រឿង ឧបភោគបរិភោគ ឃីតមុង ភួយ សម្ភារៈផ្ទះបាយ និងថវិកា ២០០ ០០០រៀលសម្រាប់មួយគ្រួសារ។
- បានផ្តល់អំណោយមនុស្សធម៌ដល់គ្រួសាររងគ្រោះមហន្តរាយផ្សេងៗមាន៖ គ្រួសារក្រីក្រចាស់ជរាមានជំងឺឈឺ ស្លាប់ចំនួន៤នាក់ មួយគ្រួសារនៅភូមិវត្តដំណាក់សង្កាត់សាលាកំរើក មួយគ្រួសារនៅភូមិ៧ សង្កាត់ចុងឃ្នៀស មួយគ្រួសារនៅភូមមិវាល សង្កាត់សំបួរ និងមួយគ្រួសារទៀតនៅភូមិ ស្ទឹងថ្មី សង្កាត់ស្វាយដង្គំ អំណោយមាន ស្បៀង គ្រឿងឧបភោគបរិភោគ និងថវិកា ជាអំណោយរបស់អនុសាខាកាកបាទក្រហមក្រុង។
- គ្រួសាររងគ្រោះដោយសារអគ្គីភ័យប្រាំបួនគ្រួសារគឺសង្កាត់សាលាកំរើក ២គ្រួសារ រួមមាន៖ ភូមិវត្តដំណាក់ មួយគ្រួសារ ភូមិវត្តស្វាយមួយគ្រួសារ សង្កាត់ស្លក្រាម ពីរគ្រួសារ ភូមិបឹងដូនប៉ាមួយគ្រួសារ ភូមិធ្លកអណ្តូងមួយ គ្រួសារ សង្កាត់នគរធំ ភូមិរហាលមួយគ្រួសារ សង្កាត់គោកចក ភូមិគោកត្នោតមួយគ្រួសារ សង្កាត់ទឹកវិល ភូមិ ជ្រៃមួយគ្រួសារ សង្កាត់សៀមរាប ភូមិស្ពានជ្រាវមួយគ្រួសារ ក្នុងសង្កាត់ស្រង៉ែ ភូមិរកាធំមួយគ្រួសារ សរុប ៩

គ្រួសារក្នុងនោះមួយគ្រួសារក្នុងសង្កាត់ស្រង៉ែជាអំណោយរបស់សាខាខេត្ត អំណោយមាន អង្ករ សង្ក័សី តង់ ឃីតមុងភួយ សម្ភារផ្ទះបាយ គ្រឿងឧបភោគបរិភោគ និងថវិកា។

- គ្រួសាររងគ្រោះថ្នាក់ចរាចរណ៍មួយនាក់ក្នុងពេលធ្វើពលកម្មសំអាតក្រុងនៅ ភូមិប្រិយ៍ចាស់សង្កាត់ទឹកវិលមាន ថវិកា និងគ្រឿងឧបភោគបរិភោគជាអំណោយរបស់អនុសាខាក្រុង។
- គ្រួសាររងគ្រោះដោយរន្ទះបាញ់ស្លាប់មួយនាក់ នៅភូមិបឹងសង្កាត់ជ្រាវ និងមួយនាក់ទៀតជាប្រជាពលរដ្ឋមកពីខេត្តកំពង់ធំស្លាប់ដោយសាររន្ទះបាញ់នៅភូមិក្រសាំងរលើង សង្កាត់សៀមរាបជាអំណោយរបស់សាខាខេត្ត។
- គ្រួសាររងគ្រោះដោយសារកូនលង់ទឹកស្លាប់មួយនាក់ នៅភូមិបឹងដូនប៉ា សង្កាត់ស្លក្រាម អំណោយមាន អង្ករ គ្រឿងឧបភោគបរិភោគនិងថវិកា ជាអំណោយរបស់អនុសាខាក្រុង។
- គ្រួសាររងគ្រោះដោយសារខ្យល់កន្ត្រាក់រលំផ្ទះមានមួយគ្រួសារនៅភូមិក្រសាំងរលើងសង្កាត់សៀមរាប សង្កាត់ទឹកវិល ពីរគ្រួសារ ភូមិគោកដូងមួយគ្រួសារ ភូមិជ្រៃថ្មីមួយគ្រួសារ មួយគ្រួសារនៅភូមិខ្នារ សង្កាត់ក្របីរៀល។
- គ្រួសារភូមិវាល សង្កាត់ជ្រាវ សរុប៥គ្រួសារ អំណោយរបស់អនុសាខាក្រុង និងសង្កាត់ទឹកវិលមានរលំ១៥គ្រួសារ របើកដំបូល៣១គ្រួសារ សរុប៤៦គ្រួសារ គណៈកម្មាធិការអនុសាខាក្រុងចូលរួមជាគណៈកម្មាធិការសាខាខេត្ត នាំយកអំណោយទៅចែកជូនដល់គ្រួសាររងគ្រោះទាំង៤៦គ្រួសារមាន អង្ករ ឃីតមុង ភួយ កន្ទេល តង់ សង្ក័សី សម្ភារផ្ទះបាយ គ្រឿងឧបភោគបរិភោគជាអំណោយរបស់សាខាខេត្ត។
- សាខាខេត្តក៏បានផ្ដល់អំណោយមនុស្សធម៌របស់សាខាដល់គ្រួសារក្រីក្រចំនួន១០០គ្រួសារ នៅ៨ភូមិរបស់សង្កាត់គោកចក អំណោយមាន អង្ករ គ្រឿងឧបភោគបរិភោគ ឃីតមុង ភួយ ឃីតខោអាវ និងថវិកា។

**៣.៣.ការគ្រប់គ្រងដីធ្លី ធនធានធម្មជាតិ បរិស្ថាន ការប្រែប្រួលអាកាសធាតុ និងគ្រោះមហន្តរាយ**

**៣.៣.១-ការងាររៀបចំដែនដីនគរូបនីយកម្ម សំណង់និងភូមិបាល**

**២.៣.១-ការិយាល័យរៀបចំដែនដីនគរូបនីយកម្ម សំណង់ និង ភូមិបាលក្រុង**

**១.ស្ថានភាពមន្ត្រីរាជការរបស់ការិយាល័យ**

មន្ត្រីការិយាល័យរៀបចំដែនដី នគរូបនីយកម្ម សំណង់ និងភូមិបាលក្រុង សរុបទាំងអស់ចំនួន ១៦នាក់ ស្រី០៤នាក់ រួមមាន ប្រធានការិយាល័យ ០១រូប អនុប្រធានការិយាល័យ ០៤រូប ក្នុងនោះអនុប្រធានការិយាល័យ ០១រូប សាម៉ីខ្លួនស្នើសុំបម្រើការងារក្នុងច្រកចេញចូលតែមួយ របស់មន្ទីររៀបចំដែនដី នគរូបនីយកម្ម សំណង់ និងសុរិយោដីខេត្ត ជាតំណាងការិយាល័យរៀបចំដែនដី នគរូបនីយកម្ម សំណង់ និងភូមិបាលក្រុង។

**១. ការងារភូមិបាល**

| | |
|---|---|
| - ទម្រង់បែបបទនៃការប្រមូលទិន្នន័យក្បាលដីដាច់ដោយដុំបាន | ៥៧ ច្បាប់ |
| - ទម្រង់បែបបទនៃការប្រមូលទិន្នន័យក្បាលដីបំពេញបន្ថែមបាន | ២៥៥ ច្បាប់ |
| - បានចុះហត្ថលេខាលើប័ណ្ណសម្គាល់សិទ្ធិកាន់កាប់អចលនវត្ថុបាន | ០៣ ច្បាប់ |
| - លិខិតលក់ផ្ដាច់បាន | ៣ ៦២៧ ច្បាប់ |
| - អំណោយផ្ដាច់ | ៤៥១ ច្បាប់ |
| - ចុះសម្រង់សៀវភៅគោលបញ្ជីដីធ្លី | ១ ៧៥០ ច្បាប់ |
| - ចុះសម្រង់សៀវភៅអចលនវត្ថុ | ៨៣៨ ច្បាប់ |

**២. ការងារសំណង់ (PV)**

| | |
|---|---|
| - ការងារសំណង់( P.V) សរុប | ១៥១ ច្បាប់ |

**៣. ការងារនៅការិយាល័យច្រកចេញចូលតែមួយៈ**

| | |
|---|---|
| - សាងសង់លំនៅដ្ឋានចេញដោយការិយាល័យច្រកចេញចូលតែមួយសរុប | ៣៤៥ ច្បាប់ |

៤.ការងារគណៈកម្មការសុរិយោដី៖

| | |
|---|---|
| - ទទួលពាក្យបណ្តឹង | ០៤ ពាក្យបណ្តឹង |
| - ករណីដីទំនាស់កំពុងស៊ើបអង្កេត | ០២ ពាក្យបណ្តឹង |
| - បានសម្រុះសម្រួល | ០១ ពាក្យបណ្តឹង |
| - បញ្ជូនទៅសាលាខេត្ត | ០១ ពាក្យបណ្តឹង |

## ៣.៣.២-ការងារបរិស្ថាន

- ចូលរួមប្រជុំ សិក្ខាសាលា និងចុះសម្អាតបរិស្ថាន ចំនួន ៣៥លើក ។
- ចុះពិនិត្យការអនុវត្តសកម្មភាពការងារប្រមូលសំណល់រឹង រាវ ថៃសួន និងការផ្សព្វផ្សាយអំពីបរិស្ថាន (សេវាអនាម័យបរិស្ថាន) ឆ្នាំ២០១៨ ជូនរដ្ឋបាលក្រុងសៀមរាបរបស់ក្រុមហ៊ុន អ៊ើកជីវហ្គ្រីន ស៊ីធី ឯ.ក ។

## ៣.៣.៣.ការប្រែប្រួលអាកាសធាតុនិងគ្រោះមហន្តរាយ

## ៣.៤.រដ្ឋបាល និងសន្តិសុខសណ្តាប់ធ្នាប់សាធារណៈ

### ៣.៤១.សភាពការណ៍សន្តិសុខសណ្តាប់សង្គម

ក.បទល្មើសឧក្រិដ្ឋ៖កើតឡើងចំនួន ១៥លើក បង្ក្រាបបាន ១៥លើក ឃាត់ខ្លួន ១៧នាក់

ខ.បទល្មើសមជ្ឈឹម៖កើតឡើងចំនួន ៤១លើក បង្ក្រាបបាន ៤១លើក ឃាត់ខ្លួន ៤២នាក់

គ-បទល្មើសគ្រឿងញៀន៖ កើតឡើងចំនួន ៨៧លើក ឃាត់ខ្លួន ៨២៤នាក់ ស្រី១៥២នាក់ ក្នុងនោះប្រើប្រាស់គ្រឿងញៀនចំនួន ២៦២នាក់ ស្រី៤០នាក់ ដោយបានបញ្ជូនទៅតុលាការ១១១នាក់ស្រី៧១ បញ្ជូនទៅអប់រំនៅមណ្ឌលចំនួន១៥១នាក់ ស្រី៣១នាក់ និងអប់រំធ្វើកិច្ចសន្យាចំនួន២០០នាក់ ស្រី៧១នាក់។

### ៣.៤.២.ការងារសណ្តាប់ធ្នាប់សាធារណៈ

- កម្លាំងសណ្តាប់ធ្នាប់ក្រុងបានសហការជាមួយប៉ុស្តិ៍ទាំង៤ ក្នុងក្រុងចុះរៀបចំសណ្តាប់ធ្នាប់តាមដងផ្លូវជាប្រចាំ។
- ក្រុងសៀមរាបមាន១២សង្កាត់ ស្មើនឹង៩៩ភូមិ ៩៤៧ក្រុម ៣៨០៩៣ខ្នងផ្ទះ។
- ធ្វើការណែនាំអ្នកលក់ដូរគ្មានសណ្តាប់ធ្នាប់បាន ៦១៤២កន្លែង អ្នករត់ឡានឈ្នួលបាន ២៩៧៦គ្រឿង អ្នករត់ម៉ឺកម៉ូតូបាន ៣២៨៨គ្រឿង ដើម្បីឲ្យពួកគាត់ចូលចំណតជៀសវាងបង្កភាពអនាធិបតេយ្យតាមដងផ្លូវ។
- សហការជាមួយសន្តិសុខផ្សារលើចុះរៀបចំអ្នកលក់ដូរនៅជុំវិញផ្សារឲ្យមានសណ្តាប់ធ្នាប់និងអនាម័យល្អ។
- ចុះត្រួតពិនិត្យផ្ទះសំណាក់បានចំនួន ៤២១៧ផ្ទះ មានចំនួន ៤៩៥៨បន្ទប់ ស្មើនឹង១៨២៩គ្រួសារ មនុស្ស ៧៤៩៥នាក់ ស្រី៣៤៣៥នាក់ អាយុ១៨ឆ្នាំឡើង ៦២៦៧នាក់ ស្រី៤០៩៥នាក់។

### ៣.៤.៣.គ្រោះថ្នាក់ផ្សេងៗ

- កើតឡើង ៣៥លើករួមមាន៖ អគ្គីភ័យ១៣ករណី ឆក់ខ្សែភ្លើង២ករណី រន្ទះបាញ់៣ករណី ខ្យល់កន្ត្រាក់២ករណី អត្តឃាត៣ករណី ដេកស្លាប់ ៨ករណី លង់ទឹកស្លាប់២ករណី។

### ៣.៤.៣.ចលនាមហាជន

- បានបំផុសចលនាប្រជាពលរដ្ឋទាំង ១២សង្កាត់ ចំនួន៩៩ភូមិ ឲ្យប្រជាពលរដ្ឋចូលរួមការពារសន្តិសុខសុវត្ថិភាពល្អនៅតាមមូលដ្ឋាន និងបានបង្កើតប៉ុស្តិ៍យាមតាមចំណុចគោលដៅសំខាន់ៗ។
- ប៉ុស្តិ៍ប្រជាការពារមាន១១១គោលដៅ ស្មើនឹង ៣៧១ក្រុម មនុស្សសរុប ២៥៤៦នាក់ លើ ៩៩ភូមិ ស្មើនឹង ១២សង្កាត់ ដាក់កម្លាំងចូលរួមសហការជាមួយប្រជាពលរដ្ឋជាប្រចាំ។
- ផ្សព្វផ្សាយគោលនយោបាយភូមិ ឃុំ មានសុវត្ថិភាព ដល់សហគមន៍ទាំង១២សង្កាត់បានចំនួន ៥២៨លើក ទាំង៩៩ភូមិ អ្នកចូលរួមសរុប ២២៦៤៧៤នាក់ ស្រី១១៤៣៥នាក់។

# ផ្នែកទី៤
# បញ្ហាប្រឈម និងដំណោះស្រាយ

## ៣.១.រដ្ឋបាលក្រុង

| ល.រ | បញ្ហាប្រឈមសំខាន់ៗ | សំណើដំណោះស្រាយ |
|---|---|---|
| **ក). ការងាររដ្ឋបាល(គ្មាន)** | | |
| **ខ). ការងារផែនការ និងការគាំទ្រសង្កាត់(គ្មាន)** | | |
| **គ). ការគ្រប់គ្រងធនធានមនុស្ស(គ្មាន)** | | |
| **ឃ). ការងារអភិវឌ្ឍន៍ក្រុង** | | |
| ១ | ការគ្រប់គ្រងសំរាមរបស់ប្រជាពលរដ្ឋនៅ ពុំទាន់បានល្អ | គួរបង្កើតដីកាស្តីពីគ្រប់គ្រងសំរាម និងកំណត់តម្លៃអតិបរមានៃការដឹកជញ្ជូនសំរាម |
| ២ | សំណង់ខុសច្បាប់ ដូចជាសំណង់លើដីចំណីផ្លូវ និងប្រឡាយសាធារណៈ មានការកើនឡើង | គួរអាជ្ញាធរសង្កាត់ ភូមិ នីមួយៗពង្រឹងយន្តការណែនាំ និងទប់ស្កាត់ |
| **ង). ការងារហិរញ្ញវត្ថុ(គ្មាន)** | | |
| **ច). ការងារលទ្ធកម្ម(គ្មាន)** | | |
| **ឆ).ការិយាល័យច្រកចេញចូលតែមួយ** | | |
| ១ | វិស័យមួយចំនួននៅតែមានសេវាតិចដូចជា៖ ឧស្សាហកម្មរ៉ែ និងថាមពល កសិកម្ម អប់រំ យុវជន និងកីឡា សុខាភិបាល | ស្នើការិយាល័យជំនាញចុះជំរុញ ស្រង់ស្ថិតិ និងធ្វើបច្ចុប្បន្នភាព |
| **ជ).ការិយាល័យប្រជាពលរដ្ឋ** | | |
| ១ | ប្រជាពលរដ្ឋមិនហ៊ានប្តឹង តវ៉ា មកអ្នកផ្តល់សេវាទោះបីមានការផ្សព្វផ្សាយជាច្រើនលើកក៏ដោយ | បន្តផ្សព្វផ្សាយពីតួនាទី ភារកិច្ចរបស់ការិយាល័យប្រជាពលរដ្ឋបន្ថែមទៀត |

## ៣.២. ការិយាល័យ អង្គភាពជំនាញ

| ល.រ | បញ្ហាប្រឈមសំខាន់ៗ | សំណើដំណោះស្រាយ |
|---|---|---|
| **ក). ការិយាល័យទេសចរណ៍** | | |
| ១ | អាជីវករដែលធ្វើអាជីវកម្មទេសចរណ៍មិនមកសុំច្បាប់ប្រកបអាជីវកម្ម បានគ្រប់កន្លែង | បង្កើតក្រុមការងារចុះជំរុញឲ្យម្ចាស់ទាំងអស់មកសុំច្បាប់អាជីវកម្ម |
| **ខ). ការិយាល័យអប់រំ យុវជន និងកីឡា** | | |
| **គ). ការិយាល័យធម្មការ និងសាសនា** | | |
| ១ | មានព្រះសង្ឃ តាជី យាយជី បិណ្ឌបាត្រគ្មានសណ្តាប់ធ្នាប់ និងសាសនាគ្រឹស្តមួយចំនួនលើកស្លាកសាសនាយេស៊ូតាមដើមឈើ និងបង្គួលភ្លើងនានាឥតមានសណ្តាប់ធ្នាប់ក្នុងក្រុង | សហការជាមួយមន្ត្រីសង្ឃ និងអាជ្ញាធមូលដ្ឋានដើម្បីទប់ស្កាត់ |
| **ឃ).ការិយាល័យកិច្ចការនារី (គ្មាន)** | | |
| **ង).ការិយាល័យវប្បធម៌ និងវិចិត្រសិល្បៈ** | | |
| ១ | ការលើកស្លាកសញ្ញាលើដីចំណីផ្លូវ នៅតាមផ្ទះ និងមិនបានសុំច្បាប់នៅតែមាន | អញ្ជើញម្ចាស់អាជីវកម្មមកសុំច្បាប់នៅការិយាល័យច្រកចេញចូលតែមួយ |

| | | |
|---|---|---|
| ២ | ការរំលោភយកដីស្រះ ត្រពាំង ទួលបុរាណដ្ឋាន អូរ ប្រឡាយ នៅតែមាន | សូមអាជ្ញាធរ និងអង្គភាពពាក់ព័ន្ធជួយទប់ស្កាត់ បោះបង្គោលកំណត់ព្រំឲ្យបានច្បាស់លាស់ |
| ៣ | ខ្វះមន្ត្រី | សូមលោកប្រធានមន្ទីរជួយផ្តល់មន្ត្រីចំនួន០១រូប |
| **ច).ការិយាល័យសាធារណការ** (គ្មាន) | | |
| **ឆ).ការិយាល័យពាណិជ្ជកម្ម** (គ្មាន) | | |
| **ជ).ការិយាល័យកសិកម្ម** | | |
| **ឈ).ការិយាល័យសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា**(គ្មាន) | | |
| **ញ).ការិយាល័យផែនការ និងស្ថិតិ** (គ្មាន) | | |
| ១ | ខ្វះសម្ភារសម្រាប់ប្រើប្រាស់ក្នុងការិយាល័យ | សុំឲ្យមន្ទីរជួយដោះស្រាយ |
| **ដ).ការិយាល័យអភិវឌ្ឍន៍ជនបទ** (**មិនបានផ្តល់របាយការណ៍**) | | |
| **ឋ).ការិយាល័យសុខាភិបាល** (គ្មាន) | | |
| **ឌ).ការិយាល័យព័ត៌មាន**(គ្មាន) | | |
| **ឍ).ការិយាល័យរៀបចំដែនដីនគរូបនីយកម្មសំណង់ និងភូមិបាល** | | |
| ១ | មិនទាន់មានប័ណ្ណកាន់កាប់សិទ្ធិដីគ្រប់សង្កាត់ | សុំពន្លឿនការចុះបញ្ជីមានលក្ខណៈជាប្រព័ន្ធ |
| ២ | ការសុំសេវារបស់ប្រជាពលរដ្ឋលើវិស័យសុរិយោដី និង សំណង់នៅមានកម្រិត | សុំបើកវគ្គ និងផ្សព្វផ្សាយ ឬធ្វើសិក្ខាសាលា |
| ៣ | ការធ្វើចរន្ត ការលេខាចារឹកមានភាពយឺតយ៉ាវ និងពុំមាន លេខរៀងតាមលំដាប់ នាំឲ្យការធ្វើលេខាចារឹកខ្លះមាន កំហុសដោយការខ្វះទំព័រ | ស្នើសុំមន្ទីររៀបចំដែនដី នគរូបនីយកម្ម សំណង់ និង សុរិយោដី បញ្ជូនសម្រង់តារាងផ្លាស់ប្តូរអចនវត្ថុ មក ការិយាល័យភូមិបាលក្រុង រយៈពេល១សប្តាហ៍ និង ដាក់លេខរៀងទំព័រសៀវភៅតាមលំដាប់ |
| ៤ | ទទួលព័ត៌មានពុំច្បាស់លាស់ពីដីកាសម្រេចរក្សាការពារ ឬ លិខិតផ្អកផ្តាក់ចុះបញ្ជីរបស់តុលាការ។ | ស្នើសុំមន្ត្រីច្រកចេញចូលតែមួយ របស់មន្ទីររៀបចំដែន ដី នគរូបនីយកម្ម សំណង់ និងសុរិយោដីខេត្តមុននិង បំពេញទម្រង់នៃពាក្យស្នើសុំសេវានានា សូមមេត្តាផ្ទៀង ផ្ទាត់ថាតើដីនោះមានដីកា សម្រេចរក្សាការពារ ឬ លិខិតផ្អកផ្តាក់ចុះបញ្ជីរបស់តុលាការដែលឬទេ |
| **ណ).ការងារសន្តិសុខសណ្តាប់ធ្នាប់សាធារណៈ** | | |
| ១ | ការចូលរួមសហការរបស់ប្រជាពលរដ្ឋនិងមន្ត្រីរាជការ មួយចំនួននៅមានកម្រិតលើការងារសន្តិសុខក្នុងមូលដ្ឋាន | ខិតខំរកមធ្យោបាយដើម្បីឲ្យប្រជាពលរដ្ឋនិងមន្ត្រី រាជការឲ្យមានការចូលរួមសហការបានល្អប្រសើរ |
| ២ | ចំពោះការចូលរួមយាមតាមគោលដៅពេលយប់របស់ ប្រជាការពារនៅមានការរអាក់រអួលខ្លះ | អាជ្ញាធរមូលដ្ឋានត្រូវខិតខំពង្រឹងការងារយាមពេល យប់របស់ប្រជាការពារឲ្យបានល្អប្រសើរជាងមុន |

## ផ្នែកទី៥
## ទិសដៅការងារឆ្នាំបន្ទាប់

### ៤.១.រដ្ឋបាលក្រុងសៀមរាប

| ល.រ | សកម្មភាពអាទិភាព | ត្រីមាស | | | |
|---|---|---|---|---|---|
| | | ១ | ២ | ៣ | ៤ |
| **ក). ការងារក្រុមប្រឹក្សា និងគណៈកម្មាធិការនានា** | | | | | |
| ១ | រៀបចំកិច្ចប្រជុំសាមញ្ញរបស់ក្រុមប្រឹក្សា និងគណៈកម្មាធិការនានាតាមប្រតិទិនដែលបានគ្រោងទុក និងរៀបចំកិច្ចប្រជុំវិសាមញ្ញតាមជាក់ស្តែង | ✓ | ✓ | ✓ | ✓ |
| ២ | ចូលរួមកិច្ចប្រជុំសាមញ្ញតាមការអញ្ជើញរបស់សង្កាត់ទាំង១២ | ✓ | ✓ | | |
| ៣ | ចូលរួមកិច្ចប្រជុំផ្សេងៗតាមការងារជាក់ស្តែង | ✓ | ✓ | ✓ | ✓ |
| ៤ | ធ្វើការដោះស្រាយវិវាទនៅមូលដ្ឋានដែលស្ថិតក្នុងដែនសមត្ថកិច្ច | ✓ | ✓ | ✓ | ✓ |
| ៥ | មកប្រចាំការនៅសាលាក្រុងតាមវេនប្រចាំការ | ✓ | ✓ | ✓ | ✓ |
| ៦ | រៀបចំវេទិកាផ្សព្វផ្សាយ និងពិគ្រោះយោបល់របស់ក្រុមប្រឹក្សាក្រុង | | ✓ | | |
| **ខ).ការងារគណៈអភិបាល** | | | | | |
| ១ | ពង្រឹងការអនុវត្តបទបញ្ជាផ្ទៃក្នុង | ✓ | ✓ | ✓ | ✓ |
| ២ | ជម្រុញការអនុវត្តមុខជំនាញតាមបណ្តាវិស័យឲ្យស្របតាមកម្មវិធីវិនិយោគបីឆ្នាំរំកិលនិងស្របតាមគោលនយោបាយរបស់រាជរដ្ឋាភិបាល | ✓ | ✓ | ✓ | ✓ |
| ៣ | រៀបចំកិច្ចប្រជុំអឌ្ឍមាសនិងប្រចាំខែឲ្យបានទៀងទាត់ និងគណៈបញ្ជាការឯកភាពរដ្ឋបាលក្រុង | ✓ | ✓ | ✓ | ✓ |
| ៤ | អនុវត្តការងារតាម ដីកា សេចក្តីសម្រេច ការណែនាំផ្សេងៗរបស់ក្រុមប្រឹក្សា | ✓ | ✓ | ✓ | ✓ |
| ៥ | ពង្រឹងការងារគណៈអភិបាលលើគម្រោងផែនការអភិវឌ្ឍន៍របស់សង្កាត់ទាំង១២ | ✓ | ✓ | ✓ | ✓ |
| **គ).ការិយាល័យរដ្ឋបាលនិងហិរញ្ញវត្ថុ** | | | | | |
| ១ | រៀបចំកិច្ចប្រជុំនានារបស់រដ្ឋបាលក្រុង | ✓ | ✓ | ✓ | ✓ |
| ២ | រៀបចំរបាយការណ៍ប្រចាំខែ ត្រីមាស ឆមាស ប្រចាំឆ្នាំ និងរៀបចំកំណត់ហេតុកិច្ចប្រជុំផ្សេងៗ | ✓ | ✓ | ✓ | ✓ |
| ៣ | ពិនិត្យនិងសម្រេចចេញសេចក្តីចម្លងអត្រានុកូលដ្ឋានជូនប្រជាពលរដ្ឋ | ✓ | ✓ | ✓ | ✓ |
| ៤ | គ្រប់គ្រងស្ថិតិប្រជាពលរដ្ឋក្នុងសង្កាត់ទាំង១២ | ✓ | ✓ | ✓ | ✓ |
| ៥ | លើកសំណើសុំផ្លាស់ប្តូរស្ថានភាពគ្រួសារមន្ត្រីទៅក្រុមប្រឹក្សាកំណែទម្រង់រដ្ឋបាលនិងទទួលតារាងបៀវត្សមន្ត្រីប្រចាំខែពីក្រុមប្រឹក្សាកំណែទម្រង់រដ្ឋបាល | ✓ | ✓ | ✓ | ✓ |
| ៦ | គ្រប់គ្រងស្ថានភាពមន្ត្រីរាជការក្របខណ្ឌក្រសួងមហាផ្ទៃដែលកំពុងបម្រើការងារនៅរដ្ឋបាលក្រុង | ✓ | ✓ | ✓ | ✓ |
| ៧ | គ្រប់គ្រងការងារចុះបញ្ជីអត្រានុកូលដ្ឋានរបស់ប្រជាពលរដ្ឋ | ✓ | ✓ | ✓ | ✓ |
| ៨ | រៀបចំទូទាត់រដ្ឋទេយ្យ | ✓ | ✓ | ✓ | ✓ |
| ៩ | រៀបចំរបាយការណ៍ហិរញ្ញវត្ថុជូនមន្ទីរសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ | ✓ | ✓ | ✓ | ✓ |

| | | | | | |
|---|---|---|---|---|---|
| ១០ | រៀបចំវិភាជន៍ថវិកាជូនសង្កាត់ទាំង១២ | ✓ | ✓ | ✓ | ✓ |
| ១១ | រៀបចំបង់ចំណូលប្រចាំខែជូនរតនាគារខេត្ត | ✓ | ✓ | ✓ | ✓ |
| ១២ | រៀបចំគ្រោងថវិកា និយ័តថវិកា និងបិទបញ្ជីថវិកា | ✓ | ✓ | ✓ | ✓ |
| ១៣ | រៀបចំទូទាត់ផ្សេងៗ | ✓ | ✓ | ✓ | ✓ |
| ១៤ | បញ្ចូលទិន្នន័យតាមដាន និងវាយតម្លៃផ្ទៃក្នុង | ✓ | ✓ | ✓ | ✓ |
| ១៥ | រៀបចំរបាយការណ៍វត្តមានមន្ត្រីរាជការ | ✓ | ✓ | ✓ | ✓ |
| **ឃ).ការិយាល័យផែនការនិងគាំទ្រសង្កាត់** | | | | | |
| ១ | ចុះគាំទ្រកិច្ចការដែលនៅសល់ពីក្រុមប្រឹក្សាអាណត្តិចាស់ទៅក្រុមប្រឹក្សាអាណត្តិថ្មី | ✓ | ✓ | ✓ | ✓ |
| ២ | ចុះគាំទ្រការរៀបចំផែនការអភិវឌ្ឍន៍៥ឆ្នាំ(២០១៥-២០២០)និងម្មវិធីវិនិយោគបីឆ្នាំរំកិលរបស់សង្កាត់ឆ្នាំ(២០១៩-២០២១) | ✓ | ✓ | ✓ | ✓ |
| ៣ | ចុះគាំទ្រជំរុញការអនុវត្ត ផែនការសកម្មភាព និងថវិកាស្តីពីការអភិវឌ្ឍផ្នែកសេវាសង្គមប្រចាំឆ្នាំ២០១៩ | ✓ | ✓ | ✓ | ✓ |
| ៤ | គាំទ្រកិច្ចប្រជុំក្រុមប្រឹក្សាសង្កាត់ប្រចាំខែតាមសង្កាត់ទាំង១២សង្កាត់ | ✓ | ✓ | ✓ | ✓ |
| ៥ | គាំទ្រកិច្ចប្រជុំប្រចាំខែរបស់ គ.ក.ន.ក | ✓ | ✓ | ✓ | |
| ៦ | តាមដានការអនុវត្តគម្រោងមូលនិធិសង្កាត់ ឆ្នាំ២០១៩ និងវាយតម្លៃអ្នកទទូលការទាំង១២សង្កាត់ | ✓ | ✓ | ✓ | ✓ |
| ៧ | គាំទ្រការអនុវត្តសកម្មភាពការងារ ផអ៣ ឆ្នាំ២០១៩ | ✓ | ✓ | ✓ | ✓ |
| **ង).ការិយាល័យអភិវឌ្ឍន៍ក្រុង** | | | | | |
| ១ | សហការជាមួយស្ថាប័នពាក់ព័ន្ធផ្សេងៗ ដើម្បីកែលម្អសោភណ័ភាព និងសណ្តាប់ធ្នាប់ក្រុងឲ្យកាន់តែល្អប្រសើរ | ✓ | ✓ | ✓ | ✓ |
| ២ | ដោះស្រាយទំនាស់ដល់ប្រជាពលរដ្ឋ | ✓ | ✓ | ✓ | ✓ |
| ៣ | ត្រួតពិនិត្យ តាមដាន ការប្រមូល និងបារប្រឡាយរបស់ក្រុមហ៊ុនជីអិម៣ ខនស្ត្រាក់សិន | ✓ | ✓ | ✓ | ✓ |
| ៤ | តាមដាន និងទប់ស្កាត់ការសាងសង់សំណង់ខុសច្បាប់ | ✓ | ✓ | ✓ | ✓ |
| ៥ | គ្រប់គ្រងការងារគ្រោះមហន្តរាយ | ✓ | ✓ | ✓ | ✓ |
| ៦ | វិភាគកំណើនប្រជាពលរដ្ឋ និងកំណើនសេដ្ឋកិច្ច | ✓ | ✓ | ✓ | ✓ |
| ៧ | រៀបចំស្ថិតិ ការតាំងលំនៅដ្ឋានបណ្តោះអាសន្នក្នុងក្រុង | ✓ | ✓ | ✓ | ✓ |
| ៨ | រៀបចំស្ថិតិ និងប្រជុំជាមួយអង្គការ សមាគម សហគមន៍ និងគណបក្សនយោបាយ | ✓ | ✓ | ✓ | ✓ |
| ៩ | រៀបចំប្លង់គោលប្រើប្រាស់ដីធ្លី និងផែនការប្រើប្រាស់ដីធ្លី | ✓ | ✓ | ✓ | ✓ |
| ១០ | រៀបចំ និងចងក្រងឯកសារពាក់ព័ន្ធទីក្រុងស្អាត | ✓ | ✓ | ✓ | ✓ |
| ១១ | បំពេញការងារចាំបាច់តាមការចាត់តាំងរបស់ថ្នាក់លើ | ✓ | ✓ | ✓ | ✓ |
| **ច).ការិយាល័យច្រកចេញចូលតែមួយ** | | | | | |
| ១ | ផ្តល់សេវាតាមការស្នើសុំជាក់ស្តែង | ✓ | ✓ | ✓ | ✓ |
| ២ | ផ្សព្វផ្សាយ និងជូនដំណឹងស្តីពីកម្រៃសេវា | ✓ | ✓ | ✓ | ✓ |
| ៣ | អនុវត្តការងារតាមផែនការសកម្មភាពទិសដៅឆ្នាំ២០១៩ | ✓ | ✓ | ✓ | ✓ |

| | | | | | |
|---|---|---|---|---|---|
| ៤ | ធានា និងថែរក្សាសុវត្ថិភាពទិន្នន័យក្នុងប្រព័ន្ធទិន្នន័យកុំព្យូទ័រ | ✓ | ✓ | ✓ | ✓ |
| ៥ | ស្រង់ស្ថិតិតាមវិស័យដែលពាក់ព័ន្ធនឹងការផ្តល់សេវា | ✓ | ✓ | ✓ | ✓ |
| **ឆ).ការិយាល័យប្រជាពលរដ្ឋ** | | | | | |
| ១ | បន្តការផ្សព្វផ្សាយដល់សង្កាត់ទាំង១២ ពីតួនាទីភារកិច្ចរបស់ការិយាល័យ | ✓ | ✓ | ✓ | ✓ |
| ២ | បន្តការដោះស្រាយបណ្តឹងរបស់ប្រជាពលរដ្ឋ | ✓ | ✓ | ✓ | ✓ |
| **ជ).អង្គភាពលទ្ធកម្ម** | | | | | |
| ១ | រៀបចំផែនការលទ្ធកម្មឆ្នាំ២០១៩ | ✓ | ✓ | | |
| ២ | រៀបចំផលិតឯកសារដេញថ្លៃ ពិគ្រោះថ្លៃ ស្ទង់តម្លៃ ឆ្នាំ២០១៩ | ✓ | ✓ | ✓ | ✓ |

## ៤.២.ការិយាល័យ អង្គភាពជំនាញ

| ល.រ | សកម្មភាពអាទិភាព | សប្តាហ៍ទី | | | |
|---|---|---|---|---|---|
| | | ១ | ២ | ៣ | ៤ |
| **ក). ការិយាល័យពាណិជ្ជកម្ម** | | | | | |
| ១ | បន្តចុះជម្រុញអាជីវករក្នុងសង្កាត់ទាំង១២ឲ្យមកសុំច្បាប់អនុញ្ញាត | ✓ | ✓ | ✓ | ✓ |
| ២ | បន្តចុះស្រង់ទិន្នន័យអាជីវកម្មនៅតាមទីផ្សារនិងតាមដងផ្លូវក្នុងសង្កាត់ទាំ១២ | ✓ | ✓ | ✓ | ✓ |
| **ខ). ការិយាល័យកសិកម្ម** | | | | | |
| ១ | ចុះតាមដានការចាប់ផ្តើមបង្កបង្កើនផលរដូវវស្សា និងដំណាំរួមផ្សំ | ✓ | ✓ | ✓ | ✓ |
| ២ | ចុះចាក់វ៉ាក់សាំងការពារជម្ងឺសារទឹកគោក្របីបន្ត | ✓ | ✓ | ✓ | ✓ |
| ៣ | ចុះតាមដានជម្ងឺសត្វគ្រប់ប្រភេទជាពិសេសជម្ងឺផ្តាសាយបក្សី | ✓ | ✓ | ✓ | ✓ |
| ៤ | បន្តកិច្ចសហការជាមួយការិយាល័យ មន្ទីរជំនាញ និងអាជ្ញាធរពាក់ព័ន្ធ | ✓ | ✓ | ✓ | ✓ |
| ៥ | ចុះតាមដានលើបញ្ហាដង្កូវបំផ្លាញដំណាំស្រូវ | ✓ | ✓ | ✓ | ✓ |
| ៦ | ចុះតាមដានជម្ងឺប្លាស់លើដំណាំស្រូវ | ✓ | ✓ | ✓ | ✓ |
| **គ).ការិយាល័យសាធារណការ** | | | | | |
| ១ | បន្តចុះស្រង់លទ្ធផលផ្លូវកំពុងសាងសង់និងសាងសង់រួច | ✓ | ✓ | ✓ | ✓ |
| ២ | បន្តចុះស្រង់ស្ថិតិយានយន្ត ជលយាន្ត យានដ្ឋានជួសជុលប្រចាំឆ្នាំ២០១៩ | ✓ | ✓ | ✓ | ✓ |
| ៣ | សហការជាមួយសាលាក្រុង និងអាជ្ញាធរដែនដី ដើម្បីការពារនិងទប់ស្កាត់ការរំលោភបំពានលើដីចំណីផ្លូវ | ✓ | ✓ | ✓ | ✓ |
| **ឃ).ការិយាល័យអប់រំ** | | | | | |
| **ក-ផ្នែកចំណេះទូទៅនិងមត្តេយ្យសិក្សា** | | | | | |
| ១ | បំប៉នសមត្ថភាពម៉ែតាមសាលាគោលដៅ | ✓ | ✓ | ✓ | ✓ |
| ២ | រៀបចំប្រឡងឆមាសលើកទី១និងទី២ | ✓ | ✓ | | |
| ៣ | ជម្រុញនិងតាមដានការអនុវត្តកម្មវិធីសិក្សាតាមសាលារដ្ឋនិងឯកជន | ✓ | ✓ | ✓ | ✓ |
| ៤ | ចុះជួយនិងជម្រុញការអនុវត្តកម្មវិធីសាលាកុមារមេត្រី | ✓ | ✓ | ✓ | ✓ |
| ៥ | អធិការកិច្ច | ✓ | ✓ | ✓ | ✓ |
| ៦ | បូកសរុបរបាយការណ៍ចុងឆ្នាំ | | ✓ | | ✓ |
| ៧ | រៀបចំឯកសារតេស្តដើមឆ្នាំនិងចុងឆ្នាំ | ✓ | | ✓ | |

| ល.រ | សកម្មភាពអាទិភាព | សប្តាហ៍ទី | | | |
|---|---|---|---|---|---|
| | | ១ | ២ | ៣ | ៤ |
| | **ខ-ផ្នែកបុគ្គលិក រដ្ឋបាល ផែនការ** | | | | |
| ១ | ប្រលងប្រណាំងគ្រូឆ្នើម សាលាល្អ | | ✓ | | |
| ២ | វាយតម្លៃមន្រ្តីឆ្នើមទទួលគ្រឿងឥស្សរិយយស | | ✓ | | |
| ៣ | ចុះពិនិត្យការគ្រប់គ្រងនិងប្រើប្រាស់សៀវភៅសិក្សាគោល | ✓ | ✓ | ✓ | |
| ៤ | ចុះពិនិត្យការប្រើប្រាស់ថវិកាPB | ✓ | ✓ | ✓ | ✓ |
| ៥ | ពិនិត្យសំណើសុំផ្លាស់ប្តូរកន្លែងបម្រើការងាររបស់គ្រូ | | | ✓ | |
| ៦ | រៀបចំផែនការអភិវឌ្ឍន៍ឆ្នាំ ២០១៩-២០២០ | | | ✓ | |
| ៧ | ពិនិត្យបែងចែកគ្រូផ្លាស់ចូល | | | ✓ | |
| ៨ | ការកសាងហេដ្ឋារចនាសម្ព័ន្ធ | ✓ | ✓ | ✓ | ✓ |
| | **គ-ផ្នែកអប់រំក្រៅប្រព័ន្ធ** | | | | |
| ១ | អធិការកិច្ចតាមថ្នាក់ | ✓ | ✓ | ✓ | ✓ |
| ២ | ប្រជុំត្រួតពិនិត្យការអនុវត្តន៍បំណិនជីវិតរបស់មណ្ឌលសិក្សាសហគមន៍ | ✓ | ✓ | ✓ | ✓ |
| ៣ | រៀបចំប្រឡងបញ្ចប់ឆ្នាំ | | | ✓ | |
| | **ឃ-ផ្នែកយុវជននិងកីឡា** | | | | |
| ១ | បង្កើតក្រុមកីឡាសិស្សនិងមហាជន | ✓ | | | |
| ២ | ពង្រីកក្រុមប្រឹក្សាកុមារនិងយុវជន បំផុសចលនាប្រឡងប្រណាំង៣ល្អ | ✓ | ✓ | ✓ | ✓ |
| **ខ).ការិយាល័យសង្គមកិច្ច** | | | | | |
| ១ | ស្វែងរកដៃគូរឧបត្ថម្ភដល់កុមារក្នុងសហគមន៍ | ✓ | ✓ | ✓ | ✓ |
| ២ | ពង្រឹងសកម្មភាពដោះស្រាយបញ្ហាជនអនាថា | ✓ | ✓ | ✓ | ✓ |
| ៣ | រៀបចំបៀវត្សប្រចាំខែជូនមុខសញ្ញាអតីតយុទ្ធជន | ✓ | ✓ | ✓ | ✓ |
| **ច).ការិយាល័យរៀបចំដែនដីនគរូបនីយកម្មសំណង់និងភូមិបាល** | | | | | |
| ១ | បន្តការចេញបណ្ណ័សម្គាល់សិទ្ធិកាន់កាប់អចលនវត្ថុជូនប្រជាពលរដ្ឋក្នុងក្រុង | ✓ | ✓ | ✓ | ✓ |
| ២ | បន្តការចេញលិខិតសាងសង់ជូនប្រជាពលរដ្ឋ | ✓ | ✓ | ✓ | ✓ |
| ៣ | បន្តការងារសម្រុះសម្រួលដោះស្រាយ ស្រាវជ្រាវនិងស៊ើបអង្កេតករណីដីទំនាស់ជូនប្រជាពលរដ្ឋ | ✓ | ✓ | ✓ | ✓ |
| **ឆ).ការិយាល័យធម្មការនិងសាសនា** | | | | | |
| ១ | រៀបចំប្រឡងធម្មវិន័យ និងពុទ្ធិកបឋមសិក្សា ឆ្នាំ២០១៩ | ✓ | ✓ | | |
| ២ | រៀបចំបោះឆ្នោតជ្រើសរើសអាចារ្យ គណៈកម្មការឲ្យបានគ្រប់វត្ត | ✓ | ✓ | ✓ | ✓ |
| ៣ | រៀបចំពិនិត្យនិងរាយការណ៍ពីការចុះបញ្ជីរបស់សាសនាផ្សេងៗ | | | ✓ | ✓ |
| ៤ | ចុះធ្វើបច្ចុប្បន្នភាពពាហិរសាសនាប្រចាំឆ្នាំ២០១៩ | | | ✓ | ✓ |
| **ជ).ការិយាល័យកិច្ចការនារី** | | | | | |
| ១ | រៀបចំកិច្ចប្រជុំសាមញ្ញ គ.ក.ស.ក ប្រចាំខែ ឆ្នាំ២០១៩ | | ✓ | | |
| ២ | ចុះតាមដានកិច្ចប្រជុំប្រចាំខែរបស់ គ.ក.ន.ក | | ✓ | ✓ | ✓ |

| ល.រ | សកម្មភាពអាទិភាព | សប្តាហ៍ទី | | | |
|---|---|---|---|---|---|
| | | ១ | ២ | ៣ | ៤ |
| ៣ | ចុះជំរុញការផ្សព្វផ្សាយ និងសម្របសម្រួលបញ្ហាកើតឡើងដល់ស្ត្រី និងកុមារក្នុងសហគមន៍ | | ✓ | ✓ | ✓ |
| **ឈ).ការិយាល័យព័ត៌មាន** | | | | | |
| ១ | ផ្តល់ព័ត៌មានស្តីពីសកម្មភាព និងលទ្ធផលនៃការអភិវឌ្ឍន៍ក្រុងជូនអ្នកសារព័ត៌មាននានា | ✓ | ✓ | ✓ | ✓ |
| ២ | ចុះយកព័ត៌មាន តាមដាននិងផ្សព្វផ្សាយព័ត៌មាន | ✓ | ✓ | ✓ | ✓ |
| **ញ).ការិយាល័យទេសចរណ៍** | | | | | |
| ១ | បន្តចុះស្រង់ទិន្នន័យនិងជម្រុញសេវាកម្មទេសចរណ៍ដែលបង្កើតថ្មីនិងផុតសុពលភាពឲ្យមកសុំច្បាប់អនុញ្ញាតិ | ✓ | ✓ | ✓ | ✓ |
| ២ | ចូលរួមសហការគ្រប់អាជ្ញាធរមូលដ្ឋាន និងស្ថាប័នអង្គភាពពាក់ព័ន្ធដើម្បីប្រមូលទិន្នន័យសេវាកម្មដែលក្រសួងបានផ្តល់ឲ្យ | ✓ | ✓ | ✓ | ✓ |
| ៣ | ខិតខំអនុវត្តផែនការការងារឲ្យកាន់តែមានប្រសិទ្ធភាព | ✓ | ✓ | ✓ | ✓ |
| **ដ).ការិយាល័យវប្បធម៌** | | | | | |
| ១ | សហការជាមួយមន្ទីរ អង្គភាពពាក់ព័ន្ធការងារវប្បធម៌ដើម្បីចុះជម្រុញអាជីវករឲ្យមកសុំច្បាប់អាជីវកម្ម | ✓ | ✓ | ✓ | ✓ |
| ២ | បន្តចុះកាត់ស្លាកសញ្ញាគ្មានច្បាប់អនុញ្ញាត | ✓ | ✓ | ✓ | ✓ |
| **ឋ).ការិយាល័យសុខាភិបាល** | | | | | |
| ១ | បន្តការលើកកម្ពស់សុខុមាលភាពមាតាកុមារនិងទារកតាមរយៈការផ្តល់សេវាសុខាភិបាល | ✓ | ✓ | ✓ | ✓ |
| ២ | បន្តការអប់រំផ្សព្វផ្សាយអំពីវិធីទប់ស្កាត់និងបង្ការជម្ងឺឆ្លង-ជម្ងឺមិនឆ្លង | ✓ | ✓ | ✓ | ✓ |
| ៣ | ជម្រុញការផ្តល់សេវាសុខាភិបាលនៅតាមមណ្ឌលសុខភាពសង្កាត់ទាំង១១ | ✓ | ✓ | ✓ | ✓ |
| ៤ | បន្តការធ្វើបច្ចុប្បន្នភាពមន្ទីរពេទ្យឯកជនឱសថស្ថាន បុគ្គលិកសុខាភិបាល | ✓ | ✓ | ✓ | ✓ |
| ៥ | សហការជាមួយអាជ្ញាធរសង្កាត់ទាំង១២ និងសាលាក្រុង ទប់ស្កាត់ការធ្វើសកម្មភាពរបស់សេវាឯកជនដែលគ្មានច្បាប់អនុញ្ញាត | ✓ | ✓ | ✓ | ✓ |
| **ឌ).ការិយាល័យផែនការនិងស្ថិតិ** | | | | | |
| ១ | បន្តការងារអត្តសញ្ញាណកម្មគ្រួសារក្រីក្រទាំង១២សង្កាត់ | ✓ | ✓ | | |
| ២ | ចុះតាមដានការស្រង់ទិន្នន័យតាមសង្កាត់ | ✓ | ✓ | ✓ | ✓ |
| ៣ | រៀបចំបណ្តុះបណ្តាលអំពីទិន្នន័យ | ✓ | ✓ | | |
| **ឍ).ការិយាល័យអភិវឌ្ឍន៍ជនបទ (គ្មានរបាយការណ៍)** | | | | | |
| **ន).ការងារកាកបាទក្រហម** | | | | | |
| ១ | បន្តការប្រមូលថវិកាទ្រទ្រង់កាកបាទក្រហមកម្ពុជាពីសង្កាត់ទាំង១២ | ✓ | ✓ | ✓ | ✓ |
| ២ | បន្តការពង្រីកសមាជិកថ្មីឲ្យគ្រប់សង្កាត់ | ✓ | ✓ | ✓ | ✓ |
| ៣ | ត្រៀមសង្គ្រោះពេលមានគ្រោះមហន្តរាយផ្សេងៗ | ✓ | ✓ | ✓ | ✓ |
| **ដ)ការងារសន្តិសុខសណ្តាប់ធ្នាប់សាធារណៈ** | | | | | |

| ល.រ | សកម្មភាពអាទិភាព | សប្ដាហ៍ទី | | | |
|---|---|---|---|---|---|
| | | ១ | ២ | ៣ | ៤ |
| ១ | តាមដាននិងត្រួតពិនិត្យក្មេងទំនើងអ្នកប្រើប្រាស់គ្រឿងញៀន | ✓ | ✓ | ✓ | ✓ |
| ២ | ត្រួតពិនិត្យអាវុធជាតិផ្ទុះនៅពេលយប់ ៤ ប៉ុស្តិ៍ | ✓ | ✓ | ✓ | ✓ |
| ៣ | ត្រួតពិនិត្យ អ្នកចំណាកស្រុក អ្នកទៅធ្វើជាពលករ និងអ្នកចំណូលស្រុក | ✓ | ✓ | ✓ | ✓ |
| ៤ | រៀបចំសណ្ដាប់ធ្នាប់សាធារណៈក្នុងក្រុងសៀមរាប | ✓ | ✓ | ✓ | ✓ |
| ៥ | ពង្រឹងកម្លាំងសមត្ថកិច្ច និងប៉ុស្តិ៍ប្រជាការពារតាមគោលដៅ | ✓ | ✓ | ✓ | ✓ |
| ៦ | ចែកខ្លឹមសារលក្ខណៈសម្បត្តិ៩យ៉ាងភូមិ-ឃុំមានសុវត្ថិភាពជាប្រចាំ | ✓ | ✓ | ✓ | ✓ |
| ៧ | បង្កើនការគ្រប់គ្រងរដ្ឋបាលចំហនិងបន្តផ្ដល់អត្តសញ្ញាណប័ណ្ណជូនប្រជាពលរដ្ឋ | ✓ | ✓ | ✓ | ✓ |
| ៨ | សហការជាមួយអាជ្ញាធរសង្កាត់ទាំង១២ ចុះបង្ក្រាបការលេងល្បែងស៊ីសង | ✓ | ✓ | ✓ | ✓ |
| ៩ | សហការជាមួយមន្ទីរសង្គមកិច្ចធ្វើការប្រមូលជនអនាថាទៅដាក់នៅមណ្ឌល | ✓ | ✓ | ✓ | ✓ |
| ១០ | ទប់ស្កាត់បទល្មើសនេសាទខុសច្បាប់គ្រប់ប្រភេទ | ✓ | ✓ | ✓ | ✓ |
| ១១ | បន្តអនុវត្តទិសដៅនិងផែនការរបស់លោកស្នងការ | ✓ | ✓ | ✓ | ✓ |

# ផ្នែកទី៦
# សេចក្តីសន្និដ្ឋាន

លទ្ធផលដែលក្រុងសៀមរាប សម្រេចបានលើគ្រប់វិស័យតាមរយៈរបាយការណ៍ឆ្នាំ២០១៨នេះ អាស្រ័យដោយមានកិច្ចសហការយ៉ាងជំផេងពីអាជ្ញាធរ និងសមត្ថកិច្ចគ្រប់លំដាប់ថ្នាក់ ព្រមទាំងមានការចូលរួមយ៉ាងសស្រាក់សស្រាំពីប្រជាពលរដ្ឋ ក្រោមការចង្អុលណែនាំពីក្រុមប្រឹក្សាក្រុងសៀមរាប ស្របតាមគោលនយោបាយរបស់រាជរដ្ឋាភិបាល ធ្វើឲ្យក្រុងសៀមរាបរក្សាបានសណ្តាប់ធ្នាប់របៀបរៀបរយ និងសន្តិសុខ សុវត្ថិភាព ជូនភ្ញៀវទេសចរណ៍ជាតិ-អន្តរជាតិ ដែលមកស្នាក់នៅកំសាន្ត ពិសេសបានបង្កលក្ខណៈងាយស្រួលជូនបងប្អូនប្រជា ពលរដ្ឋគ្រប់ស្រទាប់ជាន់ថ្នាក់ កសាងជីវភាពគ្រួសារមានការរីកចំរើនឈានទៅរកសម្បូរសប្បាយជាលំដាប់។

លទ្ធផលសម្រេចបានក្នុងឆ្នាំកន្លងទៅនេះ បើប្រៀបធៀប នឹងផែនការឆ្នាំយើងសម្រេចបានប្រមាណ ៨៥ភាគរយផងដែរ នៅសល់១៥ភាគរយ ទៀតដែលមិនទាន់អនុវត្តបានដោយសារការអនុវត្តគម្រោងមួយចំនួនរបស់សង្កាត់ និងក្រុងនៅមានភាពយឺតយ៉ាវ។

ទោះបីជាការអនុវត្តផែនការឆ្នាំរបស់ក្រុង និងសង្កាត់ទទួលលទ្ធផលមិនបាន១០០ភាគរយ ក៏ប៉ុន្តែសមិទ្ធិផលមួយចំនួនធំដែលសម្រេចបានតាមរយៈការផ្តល់កញ្ចប់ថវិកាពីថ្នាក់ជាតិ និងការជួយឧបត្ថម្ភគាំទ្រពីដៃគូរអភិវឌ្ឍន៍នានាប្រកបដោយគណនេយ្យភាព និងតម្លាភាព បានចូលរួមចំណែកយ៉ាងសំខាន់ក្នុងការអនុវត្តគោលនយោបាយកាត់បន្ថយភាពក្រីក្ររបស់ប្រជាពលរដ្ឋនៅមូលដ្ឋាន។ ទន្ទឹមនោះ យើងសង្កេតឃើញថាមានបញ្ហាប្រឈមមួយចំនួនដូចខាងក្រោម៖

- ការរៀបចំនីតិវិធីនៃការអនុវត្តគម្រោងមូលនិធិសង្កាត់ មានភាពស្មុគស្មាញ
- បញ្ហាសណ្តាប់ធ្នាប់ បរិស្ថាននៅតាមដងផ្លូវ និងទីប្រជុំជន ទីផ្សារសំខាន់ៗមិនទាន់រៀបរយល្អ និងគ្មានទីតាំងសម្រាប់ចតយានយន្តបានសមរម្យ
- ប្រជាពលរដ្ឋមិនទាន់មានប័ណ្ណកម្មសិទ្ធដីធ្លីប្រើប្រាស់គ្រប់គ្រួសារ
- ការដឹកជញ្ជូនលើសទម្ងន់មិនទាន់ទប់ស្កាត់បានទាំងស្រុងធ្វើឱ្យផ្លូវខូចខាតជាបន្តបន្ទាប់
- សំណង់បណ្តោះអាសន្នមួយចំនួនតូចស្ថិតលើដីសាធារណៈរបស់រដ្ឋ (ដងស្ទឹង ចំណីផ្លូវ និងប្រឡាយផ្សេងៗ) និងនៅតែមានសំណង់គ្មានច្បាប់អនុញ្ញាត
- នៅតែមានបទល្មើស លួច ឆក់ ប្លន់ គ្រោះថ្នាក់ចរាចរណ៍ និងបទល្មើសផ្សេងៗ
- នៅតែមានអំពើហឹង្សាក្នុងគ្រួសារ និងលេងល្បែងស៊ីសង
- នៅតែមានបទល្មើសនេសាទខុសច្បាប់ និងបទល្មើសព្រៃឈើ ព្រៃលិចទឹក។

របាយការណ៍ប្រចាំឆ្នាំ២០១៨នេះត្រូវបានពិនិត្យ និងអនុម័តក្នុងកិច្ចប្រជុំសាមញ្ញលើកទី៥៥ អាណត្តិទី២ របស់ក្រុមប្រឹក្សាក្រុង នាថ្ងៃព្រហស្បត្តិ៍ ១៣កើត ខែមិគសិត ឆ្នាំច សំរឹទ្ធិស័ក ព.ស ២៥៦២ ត្រូវនឹងថ្ងៃទី២០ ខែធ្នូ ឆ្នាំ ២០១៨។

ថ្ងៃ ............................. ខែ ......... ឆ្នាំច សំរឹទ្ធិស័ក ព.ស ២៥៦២

ក្រុងសៀមរាប ថ្ងៃទី........... ខែ ធ្នូ ឆ្នាំ ២០១៨

**អភិបាលក្រុង**

# ឧបសម្ព័ន្ធទី៦៖

# របាយការណ៍ចុងក្រោយ

# នៃការសិក្សាតាមដានស្តីពី

# ផែនការមេរួមសម្រាប់ការអភិវឌ្ឍ

# ដោយនិរន្តរភាព

# របស់ក្រុងសៀមរាប

ព្រះរាជាណាចក្រកម្ពុជា

សាលាខេត្តសៀមរាប

# ការសិក្សាតាមដានស្តីពី
# ផែនការមេរួមសម្រាប់ការអភិវឌ្ឍន៍ដោយនិរន្តរភាព
# ក្រុងសៀមរាប នៃព្រះរាជាណាចក្រកម្ពុជា
# របាយការណ៍ចុងក្រោយ

ខែ មិថុនា ឆ្នាំ២០១០

**ទីភ្នាក់ងារសហប្រតិបត្តិការអន្តរជាតិនៃប្រទេសជប៉ុន**

---

**PACET CORPORATION**
**NIPPON KOEI CO., LTD.**

អត្រាប្តូរប្រាក់ក្នុងខែ ឧសភា ឆ្នាំ២០១០

១ KHR= 0.0២២ JPY

១ USD= ៩៤.0៦ JPY

អារម្ភកថា

ដើម្បីឆ្លើយតបនឹងសំណូមពររបស់រាជរដ្ឋាភិបាលកម្ពុជា រដ្ឋាភិបាលជប៉ុនបានសំរេចធ្វើ "**ការសិក្សាផែនការមេរួមសំរាប់ការអភិវឌ្ឍន៍ប្រកបដោយនិរន្តភាពក្រុងសៀមរាប/អង្គរនៃ ព្រះរាជាណាចក្រកម្ពុជា**" ហើយបានផ្តល់ការទុកចិត្តដល់ទីភ្នាក់ងារសហប្រតិបត្តិការអន្តរជាតិនៃ ប្រទេសជប៉ុន (JICA) ឱ្យធ្វើការសិក្សាគំរោងនេះ។ ការសិក្សានេះត្រូវបានបញ្ចប់ក្នុងខែមិនា ឆ្នាំ២០០៦។

ជាផ្នែកមួយនៃកិច្ចសហប្រតិបត្តិការតាមដានចំពោះការសិក្សាខាងលើ  អង្គការ JICA បានធ្វើការសិក្សាតាមដានលើ ផែនការមេរួមសំរាប់ការអភិវឌ្ឍន៍ប្រកបដោយនិរន្តភាពនៃទីក្រុង សៀមរាប ក្នុងព្រះរាជាណាចក្រកម្ពុជា។ អង្គការ JICA បានចាត់បញ្ជូនក្រុមការងារដឹកនាំដោយ លោក Kanao ITOH នៃសហប្រតិបត្តិការ PACET មកកាន់កម្ពុជាចាប់ពីខែកុម្ភៈ ឆ្នាំ២០១០ ដល់ ខែឧសភា ឆ្នាំ២០១០។

ក្រុមការងារបានធ្វើការពិភាក្សាជាមួយនឹងមន្ត្រីពាក់ព័ន្ធនៃរាជរដ្ឋាភិបាលកម្ពុជា ហើយបានចុះអង្កេតផ្ទាល់នៅតាមទីតាំងគំរោង។ ក្រោយពីត្រលប់ទៅកាន់ប្រទេសជប៉ុនវិញ ក្រុមការងារបានសិក្សាបន្ថែម និងរៀបចំរបាយការណ៍ចុងក្រោយនេះឡើង។

ខ្ញុំសង្ឃឹមថារបាយការណ៍នេះនឹងរួមចំណែកដល់ការអភិវឌ្ឍន៍ប្រកបដោយនិរន្តភាពនៃទីក្រុង សៀមរាប និងជួយពង្រឹងទំនាក់ទំនងមិត្តភាពរវាងប្រទេសទាំងពីរឱ្យកាន់តែប្រសើរឡើង។

ជាចុងក្រោយ ខ្ញុំសូមថ្លែងអំណរគុណយ៉ាងជ្រាលជ្រៅដល់មន្ត្រីរដ្ឋាភិបាល និងអ្នកពាក់ព័ន្ធទាំងអស់ ចំពោះកិច្ចសហប្រតិបត្តិការយ៉ាងជិតស្និទ្ធសំរាប់ការសិក្សាមួយនេះ។

ខែមិថុនា ឆ្នាំ២០១០

Yasujiro SUZUKI
ប្រធានតំណាង
ទីភ្នាក់ងារសហប្រតិបត្តិការអន្តរជាតិ នៃ ប្រទេសជប៉ុន

លោក ស៊ូហ្ស៊ុគិ យ៉ាស៊ីជីរ៉ូ

ប្រធាន JICA កម្ពុជា

ទីភ្នាក់ងារសហប្រតិបត្តិការអន្តរជាតិ នៃប្រទេសជប៉ុន

ការិយាល័យនៅកម្ពុជា

ខែ មិថុនា ឆ្នាំ២០១០

លិខិតបញ្ជូនសារ

ជូនចំពោះ លោក ស៊ូហ្ស៊ុគិ

យើងខ្ញុំមានក្តីសោមនស្សរីករាយដាក់ជូនជាផ្លូវការនូវរបាយការណ៍ចុងក្រោយ មានចំណងជើងថា "ការសិក្សាតាមដានស្តីពីផែនការមេរួមសំរាប់ការអភិវឌ្ឍន៍ដោយនិរន្តរភាពក្រុងសៀមរាប នៃព្រះរាជាណាចក្រកម្ពុជា" ។

របាយការណ៍នេះ បានដកស្រង់នូវលទ្ធផលនៃការសិក្សា ដែលបានធ្វើឡើងក្នុងព្រះរាជាណាចក្រកម្ពុជា ចាប់ពី ខែ កុម្ភៈ ដល់ខែ ឧសភា ឆ្នាំ២០១០ ដោយក្រុមសិក្សាតាមដាន ដែលមានការចូលរួមដោយ PACET Corp. និង Nippon Koei Co., Ltd ក្រោមកិច្ចព្រមព្រៀងជាមួយទីភ្នាក់ងារសហប្រតិបត្តិការអន្តរជាតិ នៃប្រទេសជប៉ុន JICA ។

ក្នុងការសំរេចនូវការសិក្សាតាមដាននេះ យើងខ្ញុំបានទទួលនូវការចូលរួមជួយពីសំណាក់មន្ទីរ ស្ថាប័ន អង្គភាពជាច្រើន ជាពិសេស រដ្ឋបាលខេត្តសៀមរាប និងគណៈកម្មការបច្ចេកទេសអភិវឌ្ឍន៍ក្រុងសៀមរាប។ ហើយ យើងខ្ញុំក៏បានទទួលនូវការសហការពីភ្នាក់ងារដូចខាងក្រោមៈ

ក្រសួងសាធារណៈការ និងដឹកជញ្ជូន មន្ទីរសាធារណៈការ និងដឹកជញ្ជូនខេត្ត ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និង សំណង់ មន្ទីររៀបចំដែនដី នគរូបនីយកម្ម និងសំណង់ ក្រសួងទេសចរណ៍ មន្ទីរទេសចរណ៍ អាជ្ញាធរអប្សរា និងរដ្ឋបាលក្រុងសៀមរាប ។ល។ បន្ថែមពីលើនេះ យើងខ្ញុំសូមសំដែងនូវការដឹងគុណ និងវាយតំលៃខ្ពស់ចំពោះ ឯកឧត្តម លោកជំទាវ អស់លោក លោកស្រី ដែលបានចូលរួមជួយដល់ការសិក្សាតាមដាន និងជ្រើសរើសគំរោងដែលត្រឹមត្រូវ ។

លើសពីនេះទៅទៀត យើងខ្ញុំក៏សូមថ្លែងអំណរគុណចំពោះបុគ្គលិកទាំងអស់របស់ទីភ្នាក់ងារសហប្រតិបត្តិការអន្តរជាតិ នៃប្រទេសជប៉ុន និងស្ថានទូតនៃប្រទេសជប៉ុនប្រចាំនៅកម្ពុជា ផងដែរ ដែលបានចូលរួមផ្តល់នូវការគាំទ្រប្រកបដោយប្រសិទ្ធភាព ។

យើងខ្ញុំសង្ឃឹមថា របាយការណ៍នេះ នឹងចូលរួមចំណែកបង្កើតនូវវិធានការដ៏សមរម្យសំរាប់ការអភិវឌ្ឍន៍ទៅថ្ងៃខាងមុខរបស់ក្រុងសៀមរាប ។

ដោយសេចក្តីគោរពដ៏ខ្ពង់ខ្ពស់ពីខ្ញុំបាទ



កាណាអុ អ៊ិតុ

ប្រធានក្រុមសិក្សាតាមដាន JICA

ការសិក្សាតាមដានស្តីពីផែនការមេរួមសំរាប់ការអភិវឌ្ឍន៍ដោយនិរន្តរភាព

ក្រុងសៀមរាប នៃព្រះរាជាណាចក្រកម្ពុជា

# សេចក្តីសង្ខេប

## ១. សេចក្តីផ្តើម

ក្រុងសៀមរាបមានប្រាសាទអង្គរដែលជាទីតាំងបេតិកភណ្ឌពិភពលោក និងជាគោលដៅទេសចរណ៍ដ៏ពេញនិយមបំផុតមួយនៅក្នុងព្រះរាជាណាចក្រកម្ពុជា។ ទោះបីជាយ៉ាងណាក៏ដោយ ការកើនឡើងនូវចំនួនភ្ញៀវទេសចរយ៉ាងគំហុកនេះ បានពន្លឿននូវការពង្រីកក្រុងយ៉ាងឆាប់រហ័សក្នុងក្រុងសៀមរាប។ នៅក្នុងឆ្នាំ ២០០៨ ចំនួនប្រជាជននៅក្នុងក្រុងសៀមរាបមានត្រឹមចំនួន ១៧០០០០នាក់ប៉ុណ្ណោះ។ ក្នុងរយៈពេល១០ឆ្នាំចុងក្រោយនេះ ចំនួនប្រជាជននៅក្នុងក្រុងសៀមរាប បានកើនឡើង ៧០%។

រាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា និងទីភ្នាក់ងារសហប្រតិបត្តិការអន្តរជាតិនៃប្រទេសជប៉ុន JICA បានប្រមើរឃើញនូវការរីកដុះដាលក្រុងយ៉ាងឆាប់រហ័សនេះ។ ដោយផ្អែកលើកិច្ចព្រមព្រៀងរវាងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា និង ទីភ្នាក់ងារសហប្រតិបត្តិការអន្តរជាតិនៃប្រទេសជប៉ុន JICA ទីភ្នាក់ងារសហប្រតិបត្តិការអន្តរជាតិនៃប្រទេសជប៉ុន JICA បានធ្វើការសិក្សាស្តីពីផែនការមេរួមសំរាប់ការអភិវឌ្ឍន៍ដោយនិរន្តរភាពក្នុងក្រុងសៀមរាប (ការសិក្សាស្តីពីផែនការមេដែលមានទស្សនវិស័យដល់ឆ្នាំ២០២០) ចាប់ពីឆ្នាំ២០០៤ ដល់ ឆ្នាំ២០០៦។ ដើម្បីស្វែងយល់នូវទស្សនវិស័យនេះ គំរោង/កម្មវិធីចំនួន ៦៩ ត្រូវបានស្នើឡើង។ គំរោង/កម្មវិធីជាច្រើន និងសកម្មភាពមួយចំនួនត្រូវបានអនុវត្ត ទោះបីជាយ៉ាងណាក៏ដោយ គំរោង/កម្មវិធីក្នុងវិស័យគមនាគមន៍ និងផ្នែកអភិវឌ្ឍន៍ក្រុង មិនទាន់មានការវិវឌ្ឍន៍នៅឡើយ។

នៅក្នុងបរិបទនេះ ការសិក្សាតាមដានស្តីពីផែនការមេរួមសំរាប់ការអភិវឌ្ឍន៍ដោយនិរន្តរភាពក្រុងសៀមរាប ត្រូវបានធ្វើឡើង ក្នុងគោលបំណងស្វែងយល់នូវផែនការអភិវឌ្ឍន៍របស់ផែនការមេសំរាប់វិស័យគមនាគមន៍ និង ផ្នែកអភិវឌ្ឍន៍ក្រុង។

គោលបំណងនៃការសិក្សាតាមដានស្តីពីផែនការមេរួមសម្រាប់ការអភិវឌ្ឍន៍ប្រកបដោយនិរន្តរភាពក្រុងសៀមរាប នៃព្រះរាជាណាចក្រកម្ពុជា គឺដើម្បីៈ

- ពិនិត្យឡើងវិញពីការវិវត្តន៍នៃការសិក្សាផែនការមេ
- ពិនិត្យឡើងវិញនូវផែនការអភិវឌ្ឍន៍ក្នុងវិស័យគមនាគមន៍ និងផ្នែកអភិវឌ្ឍន៍ក្រុងរបស់ការសិក្សាផែនការមេ
- ធ្វើបច្ចុប្បន្នភាពនៃផែនការអភិវឌ្ឍន៍ ដោយរាប់បញ្ចូលទាំងគំរោងអាទិភាពនានា ។

តំបន់នៃការសិក្សាគ្របដណ្តប់លើដែនសមត្ថកិច្ចនៃក្រុងសៀមរាប។

- ក្រុងសៀមរាបត្រូវបានប្តូរមកជាក្រុងក្នុងឆ្នាំ ២០០៨ រួមមាន ១៣សង្កាត់ (ឃុំ)
- តំបន់កណ្តាលក្រុងផ្តោតលើតំបន់ផ្សារចាស់ និងតំបន់ជុំវិញក្រុង ហើយពង្រីកដល់តំបន់ដែលនៅជុំវិញនោះ
- និងគំរោងអាទិភាពនានា
- បណ្តាញផ្លូវមេស្ថិតក្នុងតំបន់ដដែលដូចមាននៅក្នុងការសិក្សាផែនការមេ ហើយពង្រីកដល់តំបន់ដែលនៅជុំវិញនោះ

ការសិក្សាតាមដានត្រូវបានចាប់ផ្តើមក្នុងខែ កុម្ភៈ ឆ្នាំ២០១០ ហើយត្រូវបញ្ចប់ក្នុងខែ មិថុនា ឆ្នាំ២០១០។ សមាសធាតុចំបងនៃការសិក្សាតាមដានគឺៈ ការវិភាគស្ថានភាពបច្ចុប្បន្ន ការត្រួតពិនិត្យឡើងវិញនូវការវិវត្តន៍នៃផែនការមេ ការត្រួតពិនិត្យឡើងវិញនូវគំរោងអាទិភាព និងការធ្វើរបាយការណ៍។

## ២. ស្ថានភាពអភិវឌ្ឍក្នុងពេលបច្ចុប្បន្នរបស់ក្រុងសៀមរាបបន្ទាប់ពីមានការសិក្សាផែនការមេ

### ២.១ ការផ្លាស់ប្តូរសេដ្ឋកិច្ចសង្គម និងផលប៉ះពាល់របស់វា (ផ្នែកទេសចរណ៍ និងផ្នែកដែលរងនូវផលប៉ះពាល់)

ទេសចរណ៍វប្បធម៌ និងប្រវត្តិសាស្ត្រក្នុងក្រុងសៀមរាប និងតំបន់អង្គរត្រូវបានផ្តួចផ្តើម និងធ្វើអោយប្រសើរឡើងដោយកំណើនភ្ញៀវទេសចរអន្តរជាតិ។ ចំនួនភ្ញៀវទេសចរអន្តរជាតិបានកើនឡើងយ៉ាងឆាប់រហ័សប្រមាណពីចំនួន ៨៣ ០០០ នាក់ ក្នុងឆ្នាំ១៩៩៩ រហូតដល់ចំនួន ៥៦០ ០០០ នាក់ ក្នុងឆ្នាំ២០០៤ (ស្មើនឹងចំនួន ៦.៧៥ដង ច្រើនជាងក្នុងឆ្នាំ១៩៩៩ ហើយដែលត្រូវនឹង៤៦%ប្រចាំឆ្នាំ)។ ក្នុងឆ្នាំ២០០៩ ចំនួនភ្ញៀវទេសចរអន្តរជាតិដែលបានចូលមកក្នុងតំបន់មានចំនួន ៩៩៨ ០០០។

សកម្មភាពទេសចរណ៍ក្នុងស្រុក ក្នុងក្រុងសសៀមរាប និងតំបន់អង្គរត្រូវបានចាប់ផ្តើមតាំងពីឆ្នាំ១៩៩៩។ នៅពេលនោះ រដ្ឋាភិបាលបានផ្សព្វផ្សាយ និងធ្វើអោយប្រសើរឡើងនូវទេសចរណ៍សហវត្សន៍តាមរយៈព្រឹត្តិការណ៍ជាច្រើនក្នុងក្រុងសៀមរាប។ ដោយសារតែមានកិច្ចខិតខំប្រឹងប្រែងរបស់រាជរដ្ឋាភិបាលបែបនេះ ចំនួនភ្ញៀវទេសចរក្នុងស្រុកបានកើនឡើងយ៉ាងឆាប់រហ័សពីចំនួន ២៣០ ៣៧៨ ក្នុងឆ្នាំ១៩៩៩ ដល់ចំនួន ១ ២៧៩ ៣៥៦ ក្នុងឆ្នាំ ២០០៩ (ត្រូវនឹង ៤០% នៃអត្រាកំណើនមធ្យមប្រចាំឆ្នាំក្នុងរយៈពេល ១៥ឆ្នាំចុងក្រោយនេះ)។

ចំនួនប្រជាជនក្នុង ១០ឃុំ ក្នុងក្រុងសៀមរាបបានកើនឡើងពីចំនួនប្រមាណ ៩៩ ០០០នាក់ក្នុងឆ្នាំ១៩៩៨ ដល់ចំនួន ១៩៨ ០០០នាក់ក្នុងឆ្នាំ ២០០៩ ដែលជាចំនួនទ្វេរដងនៃចំនួនប្រជាជនក្នុងឆ្នាំ១៩៩៨ និងស្មើនឹង ៦.៥% នៃអត្រាកំណើនប្រចាំឆ្នាំ។ អត្រាកំណើនប្រជាជនប្រចាំឆ្នាំ ៦.៥%នៃស្រុកសៀមរាបមានចំនួនប្រមាណ ៣.៨ដង នៃអត្រាកំណើនប្រជាជនជាតិប្រចាំឆ្នាំដែលមានចំនួន ១.៧% (ទិន្នន័យរបស់អង្គការសហប្រជាជាតិពីឆ្នាំ២០០៥ ដល់ឆ្នាំ ២០១០)។ កំណើនប្រជាជនភាគច្រើនបានតាំងទីលំនៅនៅក្នុងតំបន់កណ្តាលក្រុង ឬតំបន់ពង្រីកក្រុង

ឬតំបន់១ និង តំបន់២ នៃឧស្សានអង្គរ។ ដូចនេះ ដង់ស៊ីតេនៃចំនួនប្រជាជនមានកំរិតខ្ពស់នៅក្នុងតំបន់កណ្តាលក្រុង និងតំបន់ដែលស្ថិតនៅជុំវិញក្រុង។

ក្រុងសៀមរាបត្រូវបានកើតចេញពីស្រុកសៀមរាបដោយបន្ថែម ៣ឃុំទៀត ដូចជា ឃុំទឹកវិល (ស្ថិតនៅភាគខាងលិចនៃតំបន់១ តំបន់២ និងជាយក្រុង) ឃុំក្របីរាល (ស្ថិតនៅភាគនិរតី) និងឃុំអំពិល (ស្ថិតនៅភាគខាងកើតនៃតំបន់២)។ ចំនួនប្រជាជនទាំង ៣ឃុំ ក្នុងឆ្នាំ២០០៩ មានចំនួន ២៥ ៥៩៧។ ចំនួនប្រជាជនក្នុងក្រុងសរុបទាំង១៣ ឃុំ (សង្កាត់) មានចំនួន ២២៣ ៣៧៦ ក្នុងឆ្នាំ២០០៩។ ដោយពិចារណាទៅលើចំនួនភ្ញៀវទេសចរដែលមកបានដល់ និងចំនួនប្រជាជនក្នុងសៀមរាបដែលបានលើកឡើងខាងលើ ទិសដៅសេដ្ឋកិច្ចសង្គមត្រូវបានកែ សំរួល។ តារាង ១ បង្ហាញពីផលធៀបរបស់ទិសដៅសេដ្ឋកិច្ចសង្គមក្នុងផែនការមេ និងការសិក្សាតាមដាន។

**តារាង ១ ទិសដៅសេដ្ឋកិច្ចសង្គមដែលត្រូវបានកែសំរួល**

| ចំណងជើងនៃការសិក្សា | | ២០០៩ | ២០១២ | ២០២០ |
|---|---|---|---|---|
| ការសិក្សាផែនការមេ | ភ្ញៀវទេសចរអន្តរជាតិ | | ១ ៦៤៨ 000 | ២ 00៧ 000 |
| | ភ្ញៀវទេសចរក្នុងស្រុក | | ៥៧២ 000 | ៧៩៥ 000 |
| | ចំនួនប្រជាជន (១០ ឃុំ) | | ១៧១ 000 | ២១១ 000 |
| ការសិក្សាតាមដាន (ដែលត្រូវបានកែសំរួល) | ភ្ញៀវទេសចរអន្តរជាតិ | ៩៩៨ 000 | ១ ៦៥0 000 | ២ 000 000 |
| | ភ្ញៀវទេសចរក្នុងស្រុក | ១ ៣00 000 | ១ ៦២0 000 | ២ ៥00 000 |
| | ចំនួនប្រជាជន (១៣ ឃុំ) | ១៨៣ 000 | ២00 000 | ២៥១ 000 |

ប្រភព: ការសិក្សាផែនការមេ និងការសិក្សាតាមដាន

## ២.២ ការផ្លាស់ប្តូរ និងនិន្នាការនៃរចនាសម្ព័ន្ធ និងតំបន់ទីក្រុង

តំបន់ដែលបានធ្វើនគរូបនីយកម្មក្នុងឆ្នាំ២00៥ ដែលជាតំបន់កកកុញ ត្រូវបានពង្រីកជាចំបងនៅតាមបណ្តោយផ្លូវជាតិលេខ ៦ និង នៅក្នុង និងជុំវិញតំបន់ពាណិជ្ជកម្មកណ្តាល (CBD)។ ភាគច្រើននៃអាគារ/រចនាសម្ព័ន្ធថ្មីៗ ដែលត្រូវសាងសង់បន្ទាប់ពីឆ្នាំ ២00៥ រហូតដល់ឆ្នាំ ២00៨ គឺស្ថិតនៅជាយនៃតំបន់ពាណិជ្ជកម្មកណ្តាល (CBD) នៃឆ្នាំ២00៥ និងខាងក្នុងផ្លូវវាងក្រុង និងភាគខាងជើងផ្លូវជាតិលេខ៦។ ដូចនេះ វាមិនត្រូវបានគេទទួលស្គាល់ថាមានការពង្រីកតំបន់ក្រុងនៅក្នុងទីក្រុងទេ។ ទោះបីជាយ៉ាងណាក៏ដោយ ការអភិវឌ្ឍន៍ដែលមានទំហំធំមួយចំនួន ត្រូវបានគេអនុវត្តនៅក្នុង និងក្បែរទីក្រុង។

សណ្ឋាគារ និងផ្ទះសំណាក់ជាច្រើនត្រូវបានគេសាងសង់ និងបន្តសាងសង់យ៉ាងឆាប់រហ័សនៅតាមផ្លូវជាតិ

លេខ៦ និងតំបន់៣ រវាងតំបន់កណ្តាលក្រុង និងឧស្សាហកម្មអង្គរ និងនៅតំបន់ជាយតំបន់ពាណិជ្ជកម្មកណ្តាលក្នុងតំបន់កណ្តាលក្រុងបន្ទាប់ពីមានការរៀបចំផែនការមេ។ ដូចនេះ តំបន់តាំងទីលំនៅក្នុងតំបន់កណ្តាលក្រុងត្រូវបានផ្លាស់ប្តូរអោយទៅជាតំបន់ដែលមានការប្រើប្រាស់ឡូកឡំគ្នាយ៉ាងឆាប់រហ័សរវាងផ្នែកទេសចរណ៍ និងការរស់នៅ។ ចំនួនភោជនីយដ្ឋានក៏មានការកើនឡើងពី ៩០ ទៅ ១២០កន្លែងបន្ទាប់ពីមានផែនការមេ។ ភាគច្រើននៃភោជនីយដ្ឋានដែលមានការកើនឡើងត្រូវបានសាងសង់ក្នុងតំបន់ផ្សារចាស់ និងតាមផ្លូវស៊ីវុត្ថា និងផ្លូវជាតិលេខ៦។

## ៣. ការវិវត្តន៍នៃគំរោង/កម្មវិធីដែលបានស្នើឡើងរួច

មានគំរោង/កម្មវិធីចំនួន ៦៩ ត្រូវបានស្នើឡើងក្នុង ១១ផ្នែក នៅក្នុងផែនការមេ។ ក្នុងនោះ ការវិវត្តន៍នៃគំរោង/កម្មវិធីក្នុងវិស័យគមនាគមន៍ និងផ្នែករៀបចំក្រុងមានដូចខាងក្រោម:

### ៣.១ ការវិវត្តន៍នៃគំរោង/កម្មវិធីដែលបានស្នើឡើងរួចក្នុងផ្នែករៀបចំក្រុង

មានគំរោង/កម្មវិធីចំនួន ៥ ដែលបានស្នើឡើងរួចក្នុងផ្នែករៀបចំក្រុង។ តារាង ៣ បង្ហាញពីការវិវត្តន៍នៃគំរោង/កម្មវិធីដែលបានស្នើឡើងក្នុងផ្នែករៀបចំក្រុងក្នុងផែនការមេ។

**តារាង ២ ការវិវត្តន៍នៃគំរោង/កម្មវិធីដែលបានស្នើឡើងក្នុងផ្នែករៀបចំក្រុង**

| លេខសំគាល់គំរោង | ឈ្មោះ | ភ្នាក់ងារអនុវត្ត | ការវិវត្តន៍/កំណត់សំគាល់ | ស្ថានភាពការវិវត្តន៍ |
|---|---|---|---|---|
| U-1 | ការកែលំអតំបន់កណ្តាលក្រុង | សាលាខេត្ត អាជ្ញាធរអប្សរា និងមន្ទីរពាក់ព័ន្ធ | -គណៈកម្មការបច្ចេកទេសផ្នែកអភិវឌ្ឍន៍ក្រុងបានពិភាក្សាស្តីពីការអភិវឌ្ឍន៍តំបន់កណ្តាលក្រុង<br>-គណៈកម្មការបច្ចេកទេសផ្នែកអភិវឌ្ឍន៍ក្រុងនឹង ពិភាក្សា និងធ្វើផែនការអភិវឌ្ឍន៍ក្រុងជាការបរិយាយគំរោងប្រាក់កំចីនៃជំនួយអភិវឌ្ឍន៍ផ្លូវការ ODA Loan Project។<br>-អាជ្ញាធរអប្សរាមានផែនការមួយចំនួនដែលបានឧបត្ថម្ភដោយទីភ្នាក់ងារអភិវឌ្ឍន៍បារាំងAFD (ស្ថានឈើ ដើមឈើតាមផ្លូវ ។ល។)<br>-ផ្នែកជាច្រើននៃផ្លូវផ្លូវថ្មើរជើងក្នុងតំបន់ផ្សារ | △ |

| | | | | |
|---|---|---|---|---|
| | | | ចាស់ត្រូវបានកែលំអ ។ | |
| U-2 | ការកសាងសម្ថភាព<br>ផ្នែករៀបចំក្រុង | មន្ទីរ.ដ.ន.ស.ស<br>ឃុំ<br>អាជ្ញាធរអប្សរា<br>និងសាលាខេត្ត | -<br>ផែនការប្រើប្រាស់ដីធ្លីក្នុងក្រុងសៀមរាបត្រូវ បានរៀបចំរួចហើយដោយ ក្រុងសៀមរាប ដោយ ជំនួយ ពី DED ។<br>-ទីប្រឹក្សាមួយរូបផ្នែកគ្រប់គ្រងក្រុងរបស់ទីភ្នាក់ងារសហប្រតិបត្តិការអន្តរជាតិនៃប្រទេសជប៉ុនត្រូវបានបញ្ជូនមកខេត្តសៀមរាប ។<br>-មន្ត្រីជាន់ខ្ពស់ស្ម័គ្រចិត្តមួយរូបរបស់ទីភ្នាក់ងារសហប្រតិបត្តិការអន្តរជាតិនៃប្រទេសជប៉ុនផ្នែករៀបចំក្រុងត្រូវបានបញ្ជូនមកកាន់អាជ្ញាធរអប្សរា ។<br>-មន្ត្រីជាន់ខ្ពស់ស្ម័គ្រចិត្តមួយរូបរបស់ទីភ្នាក់ងារសហប្រតិបត្តិការអន្តរជាតិនៃប្រទេសជប៉ុនផ្នែកប្រព័ន្ធពតិមានភូមិសាស្រ្តត្រូវបានបញ្ជូនមកកាន់អាជ្ញាធរអប្សរា ។ | △ |
| U-3 | បញ្ជីសារពើភណ្ឌ<br>សំរាប់ស្ថាបត្យកម្ម<br>ប្រវត្តិសាស្រ្ត | អាជ្ញាធរអប្សរា/<br>សាលាខេត្ត | -អាជ្ញាធរអប្សរានឹងធ្វើការស្ទាបស្ទង់សារពើភណ្ឌមួយសំរាប់ស្ថាបត្យកម្មប្រវត្តិសាស្រ្តដោយមានជំនួយពីទីភ្នាក់ងារអភិវឌ្ឍន៍បារាំងAFD ។ | △ |
| U-4 | ការផ្សព្វផ្សាយស្តីពី<br>ការអភិវឌ្ឍន៍តំបន់<br>លំនៅដ្ឋាន | មន្ទីរ.ដ.ន.ស.ស<br>ឃុំ<br>និងផ្នែកឯកជន | -បុរីលំនៅដ្ឋានមួយចំនួនត្រូវបានអភិវឌ្ឍន៍ឡើង ប៉ុន្តែប្រជាជនក្នុងតំបន់មិនមានលទ្ធភាពទិញ ។ | △ |
| U-5 | ការអភិវឌ្ឍន៍តំបន់<br>ទេសចរ<br>និងវប្បធម៌ | អាជ្ញាធរអប្សរា<br>និងអ្នកវិនិយោគទុន<br>ឯកជន | -កន្លែងទេសចរមួយចំនួន ដូចជា មជ្ឈមណ្ឌលសន្និបាតសារៈមន្ទីរសីហនុ ។ល។ ត្រូវបានអភិវឌ្ឍន៍ឡើង ។<br>-ការទិញដីមកវិញបាននឹងកំពុងវិវត្តន៍ដោយអាជ្ញាធរ អប្សរា ។ | △ |

△:មានការវិវត្តន៍មួយចំនួន

ប្រភព: ការសិក្សាតាមដាន

កម្មវិធីនៃ " U-1 គំរោងកែលំអតំបន់កណ្តាលក្រុង " រួមមាន ៨សមាសធាតុ/គំរោង។ ការវិវត្តន៍នៃសមាសធាតុ/គំរោងទាំង ៨ នោះ មានដូចខាងក្រោម

**តារាង ៣ ការវិវត្តន៍នៃគំរោងកែលំអតំបន់កណ្តាលក្រុង**

| ល.រ | **ចំណងជើង** | **ការវិវត្តន៍/ កំណត់សំគាល់** |
|---|---|---|
| ១ | ការកែលំអផ្លូវថ្មើរជើង | ប្រមាណ ៣ គីឡូម៉ែត្រ(ផ្លូវស៊ីវុត្ថា និងផ្លូវក្នុងតំបន់ផ្សារចាស់) ត្រូវបានកែលំអរួចជាស្រេច។ ទោះបីជាយ៉ាងណាក៏ដោយ ផ្លូវទាំង នោះ មួយចំនួនមិនបានក្រាលកៅស៊ូនៅឡើយ និងតូចចង្អៀត។ |
| ២ | ជួរដើមឈើក្នុងតំបន់ផ្សារចាស់ | ប្រមាណ ២ គីឡូម៉ែត្រ (ផ្លូវស៊ីវុត្ថា និងផ្លូវក្នុងតំបន់ផ្សារចាស់) ច្រើនជាងពាក់កណ្តាលនៃជួរដើមឈើដែលបានស្នើឡើងត្រូវបានបំពេញ។ |
| ៣ | ការកែលំអអំពូលភ្លើង | អំពូលភ្លើងតាមផ្លូវនៅគ្រប់ផ្លូវដែលបានស្នើឡើងក្នុងផែនការមេត្រូវបាន ដំឡើង លើកលែងតែផ្លូវ ១។ |
| ៤ | ការកសាងសួនក្នុងក្រុង | គ្មានការវិវត្តន៍ |
| ៥ | ការអភិវឌ្ឍន៍ឡើងវិញនូវតំបន់មន្ទីរពេទ្យខេត្ត | គ្មានការវិវត្តន៍ |
| ៦ | ការអភិវឌ្ឍន៍ឡើងវិញនូវតំបន់កកកុញក្នុងតំបន់កណ្តាលក្រុង | គ្មានការវិវត្តន៍ |
| ៧ | ការកែលំអផ្លូវថ្មើរជើងនៅតាមផ្លូវនានា | ប្រមាណ ១០.៥គីឡូម៉ែត្រ(ភាគច្រើនក្នុងតំបន់ជុំវិញក្រុង)<br>ប្រមាណជា ៨០% នៃផ្លូវក្នុងក្រុងដែលបានស្នើឡើងត្រូវបានកែលំអ |
| ៨ | ការកសាងផ្លូវថ្មី | ប្រមាណ ១.១ គីឡូម៉ែត្រ (ស្ថិតនៅព្រំប្រទល់ភាគខាងកើត និងខាងត្បូងតំបន់ជុំវិញក្រុង) មិនទាន់ត្រូវបានអនុវត្តនៅឡើយ។ |

○: សាងសង់រួច, △: មានការវិវត្តន៍មួយចំនួន, ×: គ្មានការវិវត្តន៍

ប្រភព: ការសិក្សាតាមដាន

## ៣.២ ការវិវត្តន៍នៃគំរោង/កម្មវិធីដែលបានស្នើឡើងក្នុងវិស័យគមនាគមន៍

មានគំរោង/កម្មវិធីចំនួន ១០ ដែលបានស្នើឡើងក្នុងវិស័យគមនាគមន៍។ តារាង ២ បង្ហាញពីការវិវត្តន៍នៃគំរោង/កម្មវិធីដែលបានស្នើឡើងក្នុងវិស័យគមនាគមន៍ក្នុងផែនការមេះ

**តារាង ៤ ការវិវត្តន៍នៃគំរោង/កម្មវិធីដែលបានស្នើឡើងរួចក្នុងវិស័យគមនាគមន៍**

| លេខសំគាល់គំរោង | ឈ្មោះ | ភ្នាក់ងារអនុវត្ត | ការវិវត្តន៍/កំណត់សំគាល់ | ស្ថានភាពការវិវត្តន៍ |
|---|---|---|---|---|

| | | | | |
|---|---|---|---|---|
| TR-1 | គំរោងកែលំអស្ពាន សល់ពីសម័យបារាំង | ក្រសួង សាធារណៈការ និងដឹកជញ្ជូន | -ស្ពានថ្មីមួយត្រូវបានសាងសង់ឡើងមានប្រវែង ប្រម៉ាណ ២៧០ម៉ែត្រដែលមានទិសដៅបញ្រាសគ្នា នឹងស្ពានសល់ពីសម័យបារាំង និងត្រូវប្រើជាផ្លូវឯក ទិសពីទិសខាងលិចទៅទិសខាងកើត ។ ចំណែកស្ពាន សល់ពីសម័យបារាំងក៏ត្រូវប្រើប្រាស់ជាផ្លូវឯកទិសផង ដែរ ពីទិសខាងកើតទៅទិសខាងលិច ។ | ○ |
| TR-2 | បណ្តាញផ្លូវរណប (ជំហានទី ១) | មន្ទីរ សាធារណៈការ និងដឹកជញ្ជូន សាលាខេត្ត | -មានផ្នែកតិចតួចប៉ុណ្ណោះនៃផ្លូវដែលបានស្មើឡើងរួច ត្រូវបានក្រាលកៅស៊ូ ។ទោះបីយ៉ាងណាក៏ដោយ ផ្នែក ជាច្រើនគ្មានការវិវឌ្ឍន៍ឡើយ ។ | △ |
| TR-3 | បណ្តាញផ្លូវរណប (ជំហានទី ២) | ក្រសួង សាធារណៈការ និងដឹកជញ្ជូន | -ផ្លូវ ហ៊ុន សែន សន្តិភាពត្រូវបានកែលំអក្នុងខែមករា ឆ្នាំ ២០១០ ។<br>-ផ្លូវនេះត្រូវបានចាត់ថាជា"ផ្លូវបញ្ជៀសក្រុងសៀមរាប" ហើយរថយន្តធន់ធ្ងន់ត្រូវធ្វើចរាចរលើផ្លូវនេះជំនួសអោយ ការធ្វើចរាចរចូលទៅក្នុងក្រុងតាមផ្លូវជាតិលេខ៦ ។<br>-ផ្លូវបញ្ជៀសនេះជាផ្លូវបង់ប្រាក់ គឺយកប្រាក់តែពីរថយន្ត ធន់ធ្ងន់ប៉ុណ្ណោះ ហើយត្រូវបានដំណើរការដោយអាជ្ញាធរ អប្សរា ។ | ○ |
| TR-4 | បណ្តាញផ្លូវរណប (ជំហានទី ៣) | មន្ទីរ សាធារណៈការ និងដឹកជញ្ជូន សាលាខេត្ត | -ផ្នែកខ្លះនៃបណ្តាញផ្លូវរណបត្រូវបានសាងសង់បញ្ចប់ ។ ទោះជាយ៉ាងណាក៏ដោយ ផ្នែកជាច្រើននៃផ្លូវនេះមិនទាន់ ត្រូវបានបញ្ចប់នៅឡើយ ។ | △ |
| TR-5 | បណ្តាញផ្លូវរណប (ជំហានទី ៤) | សាលាខេត្ត | -ផ្នែកខ្លះនៃបណ្តាញផ្លូវរណបត្រូវបានសាងសង់បញ្ចប់ ។ ទោះជាយ៉ាងណាក៏ដោយ ផ្នែកជាច្រើននៃផ្លូវនេះមិនទាន់ ត្រូវបានបញ្ចប់នៅឡើយ ។ | △ |
| TR-6 | កែលំអស្ថាប័ន និង យុទ្ធនាការផ្សព្វ ផ្សាយសុវត្ថិភាព ចរាចរ | នគរបាល មន្ទីរ សាធារណៈការ និងដឹកជញ្ជូន សាលាខេត្ត | -មានផែនការសកម្មភាពចំនួន ៨ ។<br>-គ្មានសមិទ្ធផលណាមួយសំរេចបានគួរអោយកត់សំគាល់ | △ |

| | | | | |
|---|---|---|---|---|
| TR-7 | ស្ដារបណ្ដាញផ្លូវទៅកាន់តំបន់បេតិកភណ្ឌជនបទ | ក្រសួងសាធារណៈការនិងដឹកជញ្ជូន ក្រសួងអភិវឌ្ឍន៍ជនបទ | -ភាគច្រើននៃបណ្ដាញផ្លូវទៅកាន់តំបន់បេតិកភណ្ឌជនបទត្រូវបានកែលំអរួចហើយ ។<br>-ផ្នែកខ្លះនៃផ្លូវនេះស្ថិតក្នុងការសាងសង់ ឥឡូវនេះ ។ | △ |
| TR-8 | មធ្យោបាយដឹកជញ្ជូនសាធារណៈដែលមិនបំពុលពរិស្ថាន | អាជ្ញាធរអប្សរា | -រថយន្តអគ្គិសនីចំនួន ៥០ ត្រូវបានដាក់អោយដំណើរការក្នុងឧស្យានអង្គរ<br>-ការបង្កើនចំនួនរថយន្តអគ្គិសនីស្ថិតក្នុងផែនការនាយកដ្ឋានទេសចរ នៃអាជ្ញាធរអប្សរា ។ | △ |
| TR-9 | សាងសង់ផ្លូវសំរាប់ជិះកង់ | អាជ្ញាធរអប្សរា | -គ្មានការវិវឌ្ឍន៍ | × |
| TR-10 | លើកកំពស់សមត្ថភាពស្ថាប័នសំរាប់ថែទាំផ្លូវ | មន្ទីរសាធារណៈការនិងដឹកជញ្ជូន មន្ទីរអភិវឌ្ឍន៍ជនបទ | -មានផែនការសកម្មភាពចំនួន ៣ ។<br>-គ្មានសកម្មភាពណាមួយត្រូវបានអនុវត្ត ។ | × |

○: បានសាងសង់បញ្ចប់ △: មានការវិវត្តន៍មួយចំនួន ×: គ្មានការវិវត្តន៍

ប្រភព: ការសិក្សាតាមដាន

TR-1 និងTR-2 ត្រូវបានសាងសង់រួច ទោះបីយ៉ាងនេះក្ដី TR-9 និងTR-10 មិនទាន់ត្រូវបានគេអនុវត្តនៅឡើយ ។ គេឃើញមានការវិវត្តន៍មួយចំនួននៅក្នុងគំរោងដែលនៅសល់ទាំង៦ ។

## ៤. ផែនការអភិវឌ្ឍន៍នៃផ្នែកដែលត្រូវជ្រើសរើស

ផែនការកែលំអ/ អភិវឌ្ឍផ្នែកផ្លូវថ្នល់ និងផ្នែករៀបចំតំបន់កណ្ដាលក្រុងមានដូចខាងក្រោម:

### ៤.១ ផែនការកែលំអតំបន់កណ្ដាលក្រុង

តំបន់កណ្ដាលក្រុងក្នុងក្រុងសៀមរាប គឺជាតំបន់ដែលត្រូវរៀបចំក្នុងការសិក្សាតាមដាន។ ដើម្បីធ្វើការកែលំអតំបន់កណ្ដាលក្រុង កម្មវិធីចំនួន ៤ និងគំរោងចំនួនន ១៦ត្រូវបានស្នើឡើង។ ក្នុងចំណោមកម្មវិធី/ គំរោងទាំងនោះ មានគំរោងចំនួន ៩ និង កម្មវិធីចំនួន ៤ ត្រូវបានជ្រើសរើសជាគំរោងអាទិភាពក្នុងផ្នែករៀបចំក្រុង។ ក្នុងនោះ គំរោង ៣-១ ការអភិរក្សបេតិកភណ្ឌក្រុង និងដើមឈើចាស់ៗ និងគំរោង ៣-៣ ការអភិរក្ស និងការកែ

លំអតំបន់មាត់ស្ទឹងត្រូវបានអនុវត្តដោយ AFD ។

**តារាង ៥ គំរោង/កម្មវិធីអាទិភាពដែលត្រូវបានជ្រើសរើសក្នុងផ្នែករៀបចំក្រុង**

| កម្មវិធី | គំរោង |
|---|---|
| ការធ្វើអោយប្រសើរឡើងនូវភាពទាក់ទាញទេសចរណ៍ក្រុង និងមុនងារ | ១-១ ការកែលំអផ្លូវក្នុងតំបន់ផ្សារចាស់ជាមួយគំរោងសាកល្បងដែលឆ្លើយតបនាប់រហ័ស |
| | ១-២ ការអភិវឌ្ឍន៍ឧស្សានតូចៗនៅកែងផ្លូវក្នុងតំបន់ផ្សារចាស់ |
| | ១-៣ ការរៀបចំនូវកាតព្វកិច្ចការងារសំរាប់កែលំអតំបន់ផ្សារចាស់ជាមួយសមាគមន៍ក្នុងតំបន់ |
| ការពង្រឹងការគ្រប់គ្រងចល័តភាព | ២-១ ការគ្រប់គ្រងចរាចររួម( ចំណតសាធារណៈ តំបន់សំរាប់តែដើរ ការត្រួត ពិនិត្យផ្លូវឯកទិស ។ល ។) |
| ការអភិរក្ស និងប្រើប្រាស់បេតិកភណ្ឌក្រុង និងធម្មជាតិ | ៣-១ ការអភិរក្សបេតិកភណ្ឌក្រុង និងដើមឈើចាស់ៗនៅតាមផ្លូវ |
| | ៣-២ ការកែលំអផ្ទាំងពតិមានបេតិកភណ្ឌក្រុង |
| | ៣-៣ ការអភិរក្ស និងកែលំអនៃតំបន់ដងស្ទឹងសៀមរាប |
| ការធ្វើអោយប្រសើរឡើងនូវការគ្រប់គ្រងក្រុង និងសមត្ថភាពរបស់វា | ៤-១ ការអភិវឌ្ឍន៍សមត្ថភាពសំរាប់ការរៀបចំក្រុង និងការអនុវត្ត ( ត្រួតពិនិត្យ និងណែនាំ) |
| | ៤-២ ពង្រឹងយន្តការសំរបសំរួលនិងសហប្រតិបត្តិការក្នុងចំណោម អាជ្ញាធរអភិវឌ្ឍន៍ក្រុង |

ប្រភព: ការសិក្សាតាមដាន

## ៤.២ ផែនការអភិវឌ្ឍផ្លូវ

មានគំរោង/កម្មវិធីចំនួន ៩ ត្រូវបានស្នើឡើងក្នុងការសិក្សាតាមដាន។ ក្នុងចំណោមនោះ គំរោង/កម្មវិធីចំនួន ៤ ត្រូវបានជ្រើសរើសជាគំរោង/កម្មវិធីអាទិភាព។ តារាង ៥ បង្ហាញពីគំរោង/ កម្មវិធីអាទិភាពក្នុងវិស័យគមនាគមន៍។

**តារាង ៦ គំរោង/ កម្មវិធីអាទិភាពក្នុងវិស័យគមនាគមន៍**

| ល.រ | គំរោង/កម្មវិធីដែលបានស្នើឡើង |
|---|---|
| ១ | ការកែលំអបណ្តាញផ្លូវក្នុងក្រុងក្នុងផ្លូវជាតិលេខ៦ និងផ្លូវវាងក្រុង |
| ២ | ការកែលំអបណ្តាញផ្លូវក្នុងក្រុងខាងក្រៅផ្លូវវាងក្រុង |
| ៣ | ការកសាងបណ្តាញផ្លូវរណបនឹងផ្លូវជាតិលេខ៦ |
| ៤ | គំរោងស្តារប្រព័ន្ធបណ្តាញផ្លូវនៅតំបន់បេតិកភ័ណ្ឌជនបទ |

ប្រភព: ការសិក្សាតាមដាន

# ៥. សន្និដ្ឋាន និងអនុសាសន៍

## ៥.១ ការអនុវត្តន៍នូវគំរោង/កម្មវិធីអាទិភាព

តារាង ៧ បង្ហាញពីថ្លៃដើមប៉ាន់ស្មាន និងស្ថាប័នដែលទទួលខុសត្រូវ/អនុវត្តនៃគំរោង/កម្មវិធីអាទិភាពដែល

ត្រូវគេជ្រើសរើស ។

## តារាង ៧ គំរោង/កម្មវិធីអាទិភាពដែលបានជ្រើសរើសក្នុងផ្នែករៀបចំក្រុង

| គំរោង/កម្មវិធីអាទិភាព | | ស្ថាប័នទទួលខុសត្រូវ /អនុវត្ត | ថ្លៃដើម (,000 US$) |
|---|---|---|---|
| ផ្នែករៀបចំក្រុង | | | |
| ការធ្វើអោយប្រសើរឡើងនូវភាពទាក់ទាញទេសចរណ៏ក្រុង និង មុនងារ | ការកែលំអផ្លូវក្នុងតំបន់ផ្សារចាស់ជាមួយគំរោងសាកល្បងដែលឆ្លើយតបនាប់របស់ | DPWT (PG, PS, PPO) | ១ ៦៨០ |
| | ការអភិវឌ្ឍន៏ឧស្យានតូចៗនៅកែងផ្លូវក្នុងតំបន់ ផ្សារចាស់ | DPWT / DTC (PG, MG, LDs) | ៥០ |
| | ការរៀបចំនូវកាតព្វកិច្ចការងារសំរាប់កែលំអតំបន់ផ្សារចាស់ជាមួយសមាគមន៏ក្នុងតំបន់ | PG / MG (PS) | ១០ |
| ការពង្រឹងការគ្រប់គ្រងចល័តភាព | ការគ្រប់គ្រងចរាចរូម( ចំណតសាធារណៈ តំបន់សំរាប់តែដើរ ការត្រួតពិនិត្យផ្លូវឯកទិស ។ល ។) | DPWT / PPO (PG, MG, DH, PS) | ១ ១១០ |
| ការអភិរក្ស និងប្រើប្រាស់បេតិកភណ្ឌក្រុង និងធម្មជាតិ | ការអភិរក្សបេតិកភណ្ឌក្រុង និងដើមឈើចាស់ៗនៅតាមផ្លូវ | PG / APSARA | AFD |
| | ការកែលំអផ្ទាំងពតិមានបេតិកភណ្ឌក្រុង | DCA / APSARA | ៣១ |
| | ការអភិរក្ស និងកែលំអ នៃតំបន់ជងស្ទឹងសៀមរាប | APSARA | AFD |
| ការធ្វើអោយប្រសើរឡើងនូវការគ្រប់គ្រងក្រុង និងសមត្ថភាពរបស់វាក្នុងការប្រើប្រាស់ដីធ្លី និង ការធ្វើអោយរស់រានឡើងវិញ | ការអភិវឌ្ឍន៏សមត្ថភាពសំរាប់ការរៀបចំក្រុង និងការអនុវត្ត ( ត្រួតពិនិត្យ និងណែនាំ) | DLMUPC / MG (PG / APSARA) | ៥៤០ |
| | ពង្រឹងយន្តការសំរបសំរួលនិងសហប្រតិបត្តិការក្នុងចំណោមអាជ្ញាធរអភិវឌ្ឍន៏ក្រុង | PG (MG, LDs, APSARA) | ៣៧២ |
| | | Sub-total ផ្នែករៀបចំក្រុង | ៣ ៧៩៣ |
| វិស័យគមនាគមន៏ | | | |
| ការកែលំអបណ្តាញផ្លូវក្នុងក្រុងក្នុងផ្លូវជាតិលេខ៦ និងផ្លូវវាងក្រុង | | DPWT | ៥២ ៣០០ |
| ការកែលំអបណ្តាញផ្លូវក្នុងក្រុងខាងក្រៅផ្លូវវាងក្រុង | | DPWT | ២៣ ៦០០ |
| ការកសាងបណ្តាញផ្លូវរណបនឹងផ្លូវជាតិលេខ៦ | | DPWT | ១១ ៥០០ |
| គំរោងស្តារប្រព័ន្ធបណ្តាញផ្លូវនៅតំបន់បេតិកភ័ណ្ឌជនបទ | | DPWT | ៤០ ០០០ |
| | | Sub-total វិស័យគមនាគមន៏ | ១២៧ ៤០០ |
| | | **សរុប** | **១៣១ ១៩៣** |

កំណត់សម្គាល់ : PG = រដ្ឋបាលខេត្ត MG = រដ្ឋបាលក្រុង TC = គណៈកម្មការបច្ចេកទេស APSARA = អាជ្ញាធរអប្សរា

DLMUPC = មន្ទីររៀបចំដែនដី នគរូបនីយកម្ម និងសំណង់ DPWT = មន្ទីរសាធារណៈការ និងដឹកជញ្ជូន DCA = មន្ទីរវប្បធមិ និងសិល្បៈ

LG= រដ្ឋបាលក្នុងតំបន់ PPO = ស្នងការនគរបាលខេត្ត

ប្រភព: ការសិក្សាតាមដាន

គណៈកម្មការបច្ចេកទេសអភិវឌ្ឍន៍ក្រុង (UDTC) ដែលត្រូវបានបង្កើតឡើង ត្រូវបានស្នើឡើងដើម្បីលើកដំកើងជាគណៈកម្មការបច្ចេកទេសអភិវឌ្ឍន៍ទេសចរណ៍ និងក្រុង (UTDTC) ដោយស្ថិតនៅក្រោមគណៈកម្មការអភិវឌ្ឍន៍ខេត្ត (DC) ។

សំរាប់ការប្រតិបត្តិប្រកបដោយភាពរលូន និងសមស្របនៃការអភិវឌ្ឍន៍ក្រុង និងទេសចរណ៍ពហុវិស័យ ក្រុមការងារពិសេស ត្រូវបានស្នើអោយរៀបចំឡើងសម្រាប់កម្មវិធី និងគំរោងដែលបានស្នើឡើងនិមួយៗ ពីទីភ្នាក់ងារប្រតិបត្តិ និងទីភ្នាក់ងាររដ្ឋាភិបាលដែលពាក់ព័ន្ធជាមួយសមាជិករបស់គណៈកម្មការបច្ចេកទេសអភិវឌ្ឍន៍ទេសចរណ៍ និងក្រុង។

ធនធានហិរញ្ញវត្ថុចាំបាច់សំរាប់អនុវត្តគំរោងអាទិភាពគួរតែត្រូវបានធានាដោយការរួមបញ្ចូលគ្នានូវប្រាក់កំចី សំរាប់គំរោងអភិវឌ្ឍហេដ្ឋារចនាសម្ព័ន្ធ ផ្លូវថ្នល់ និងសំភារៈផ្សេងៗ និងជំនួយផ្នែកបច្ចេកទេសសំរាប់កម្មវិធីទន់ខ្សោយពីម្ចាស់ជំនួយដែលមានសក្តានុពល ស្ថិតក្រោមការដឹកនាំ និងភាពជាម្ចាស់របស់រដ្ឋបាលខេត្ត ជាមួយការទទួលខុសត្រូវរបស់ភ្នាក់ងារប្រតិបត្តិដែលពាក់ព័ន្ធនៅក្នុងតំបន់។ ប្រព័ន្ធប្រាក់កំចីវិស័យទេសចរណ៍នឹងក្លាយទៅជាមធ្យោបាយដ៏មានសក្តានុពលក្នុងការអនុវត្តនូវកម្មវិធីអភិវឌ្ឍសំភារៈ/ហេដ្ឋារចនាសម្ព័ន្ធវិស័យទេសចរណ៍ និងគំរោងដែលផ្តើមចេញពីទស្សនៈពីភាពដែលអាចធ្វើទៅបានផ្នែកសេដ្ឋកិច្ច និងហិរញ្ញវត្ថុ តាមរយៈការកែលំអ និងពង្រឹងប្រព័ន្ធប្រមូលថវិកា និងពន្ធដារ។ កម្មវិធីទន់ខ្សោយដែលបានស្នើឡើងស្តីពីការអភិវឌ្ឍន៍សមត្ថភាព និងការបង្កើតផែនការ ។ល។ នឹងត្រូវគ្របដណ្តប់ដោយគំរោងប្រាក់កំចី ឬជំនួយសហការផ្នែកបច្ចេកទេសរបស់ម្ចាស់ជំនួយដែលមានសក្តានុពល។

## ៥.២ បញ្ហាបន្ថែមនាពេលអនាគត

<u>ការផ្លាស់ប្តូរតំបន់រដ្ឋបាលខេត្តទៅកាន់តំបន់ ២</u>

ក្នុងផែនការមេ ការពង្រីកក្រុងសៀមរាបត្រូវបានបង្កើតឡើងយ៉ាងច្បាស់ទៅដល់ភាគអគ្នេយ៍ និងផ្នែកខាងត្បូងនៃតំបន់ពីផ្លូវជាតិលេខ ៦។ ការិយាល័យថ្មីរបស់រដ្ឋបាលខេត្ត មានទីតាំងស្ថិតក្នុងតំបន់ ២ ដែលជាតំបន់អភិរក្ស ហើយស្ថិតនៅភាគឥសាននៃដែនដីថ្មីរបស់ក្រុងសៀមរាប ហើយផ្លូវដែលអាចទៅដល់បានត្រូវបានកែលំអពីផ្លូវជាតិលេខ ៦ ក្នុងស្រុកប្រាសាទបាគង។ វាអាចបង្កើតនូវផលប៉ះពាល់សំរាប់ទិសដៅនគរូបនីយកម្មដែលបានកំណត់ក្នុងផែនការមេ និងតំបន់អភិរក្សរបស់ឧស្សានអង្គរ។ សកម្មភាពអភិវឌ្ឍន៍ក្រុងនាពេលអនាគត ត្រូវធ្វើការគ្រប់គ្រង និងត្រួតពិនិត្យឱ្យបានម៉ត់ចត់ ដើម្បីជៀសវាងប៉ះពាល់ដល់ការអភិរក្ស និងការការពារ តំបន់១ តំបន់២ និងតំបន់៣ នៃឧទ្យានអង្គរ ។

<u>ដែនដីនៃក្រុងសៀមរាប</u>

ក្រុងសៀមរាបដែលទើបបង្កើតថ្មីជាមួយដែនដីនៃសង្កាត់ចំនួន ១៣ ត្រូវបានគេស្នើឡើងដើម្បីអោយមានការត្រួតពិនិត្យឡើងវិញ ដើម្បីជៀសវាងនូវបញ្ហាមួយចំនួន ដូចខាងក្រោម :

-ដើម្បីអោយស៊ីគ្នាជាមួយតំបន់គ្របដណ្តប់នៃផែនការបែងចែកតំបន់នៅក្នុងតំបន់ភាគខាងកើតនៃទីក្រុង តំបន់នគរូបនីយកម្មនៃផែនការបែងចែកតំបន់កំពុងគ្របដណ្តប់ផុតពីដែនដីក្រុង និងគ្របដណ្តប់ដល់ឃុំជាប់នោះនៅក្នុងស្រុកប្រាសាទបាគង ។

# មាតិកា

**ជំពូក ១ សេចក្តីផ្តើម ---------------------------------------------------- ១-១**

១.១ ប្រវត្តិនៃការសិក្សាតាមដាន ---------------------------------------------១-១

១.២ គោលបំណងនៃការសិក្សា ------------------------------------------------១-២

១.៣ តំបន់នៃការសិក្សា -------------------------------------------------------១-២

១.៤ សេចក្តីសង្ខេបនៃការសិក្សា-------------------------------------------------១-៣

១.៤.១ កាលវិភាគនៃការសិក្សា ------------------------------------------------១-៣

១.៤.២ រចនាសម្ព័ន្ធចាត់តាំង----------------------------------------------------១-៤

១.៥ រចនាសម្ព័ន្ធនៃរបាយការណ៍--------------------------------------------------១-៥

**ជំពូក ២ ស្ថានភាពអភិវឌ្ឍន៍ក្នុងពេលបច្ចុប្បន្នរបស់ក្រុងសៀមរាបបន្ទាប់ពីមានផែនការមេ---------- ២-១**

២.១ ការផ្លាស់ប្តូរសេដ្ឋកិច្ចសង្គម និងផលប៉ះពាល់របស់វា ( ផ្នែកទេសចរ និងផ្នែកដែលរងនូវផលប៉ះពាល់) ------------------------------------------------- ២-១

២.១.១ ការកើនឡើងនូវភ្ញៀវទេសចរ ---------------------------------------------២-១

២.១.២ ការកើនឡើងនូវចំនួនប្រជាជន ------------------------------------------- ២-៩

២.១.៣ គោលដៅសេដ្ឋកិច្ចសង្គមដែលពាក់ព័ន្ធ------------------------------------- ២-១១

២.១.៤ សេណារីយ៉ូនាពេលអនាគតនៃក្របខ័ណ្ឌអភិវឌ្ឍន៍សេដ្ឋកិច្ចសង្គម------------------- ២-១៦

២.២ ការផ្លាស់ប្តូរ និងនិន្នាការនៃរចនាសម្ព័ន្ធ និងតំបន់ទីក្រុង --------------------------២-២៣

២.២.១ និន្នាការនៃការអភិវឌ្ឍន៍ទីក្រុង ------------------------------------------ ២-២៣

២.២.២ ផែនការប្រើប្រាស់ដីធ្លី និងការគ្រប់គ្រងកំណើនទីក្រុង ----------------------------២-២៦

២.២.៣ ផែនការ និងគម្រោងអភិវឌ្ឍន៍ផ្សេងៗ ----------------------------------------២-២៩

**ជំពូក ៣ ការវិវត្តន៍នៃគំរោង/កម្មវិធីដែលបានស្នើឡើងក្នុងផែនការមេ----------------------៣-១**

៣.១ ការអភិវឌ្ឍន៍ជាទូទៅនៃគំរោង/កម្មវិធីដែលបានស្នើឡើង------------------------------៣-១

៣.២ ការវិវត្តន៍នៃគំរោង/កម្មវិធីដែលបានស្នើឡើងក្នុងផ្នែករៀបចំក្រុង-------------------- ៣-៣

៣.៣ ការវិវត្តន៍នៃគំរោង/កម្មវិធីដែលបានស្នើឡើងក្នុងវិស័យគមនាគមន៍--------------------៣-៩

**ជំពូក ៤ ផែនការអភិវឌ្ឍន៍ផ្នែកដែលបានជ្រើសរើស------------------------------------ ៤-១**

៤.១ ផែនការកែលំអតំបន់កណ្តាលក្រុង ----------------------------------------------៤-១

៤.១.១ ការត្រួតពិនិត្យឡើងវិញនូវផែនការកែលំអតំបន់កណ្តាលក្រុង ----------------------៤-១
៤.១.២ ផែនការកែលំអសំរាប់តំបន់កណ្តាលក្រុង---------------------------------- ៤-៧
៤.១.៣ គំរោងអាទិភាពនៅក្នុងផ្នែកអភិវឌ្ឍន៍ក្រុង ---------------------------------- ៤-១៤
៤.២ ផែនការអភិវឌ្ឍន៍ផ្លូវថ្នល់ ------------------------------------------------------------៤-២៦
៤.២.១ ការត្រួតឡើងវិញនូវការអភិវឌ្ឍន៍ផ្លូវថ្នល់បន្ទាប់ពីមានការសិក្សាផែនការមេ--------------៤-២៦
៤.២.២ ផែនការអភិវឌ្ឍន៍ផ្លូវថ្នល់------------------------------------------------៤-៤០
៤.២.៣ គំរោងអាទិភាពក្នុងវិស័យដឹកជញ្ជូន-------------------------------------------៤-៥៣
**ជំពូក ៥ សេចក្តីសន្និដ្ឋាន និងអនុសាសន៍-----------------------------------------------៥-១**
៥.១ ការប្រតិបត្តិគម្រោងអាទិភាព --------------------------------------------------៥-១
៥.១.១ គំរោងអាទិភាព-------------------------------------------------------------៥-១
៥.១.២ ស្ថាប័នប្រតិបត្តិ-------------------------------------------------------------៥-៣
៥.១.៣ គំរោងសាកល្បង និងគំរោងបេក្ខភាពដទៃៗទៀត------------------------------៥-៥
៥.១.៤ ការរៀបចំធនធានហិរញ្ញវត្ថុ --------------------------------------------៥-៩
៥.២ បញ្ហាបន្ថែមនាពេលអនាគត---------------------------------------------------៥-១០
៥.២.១ ផ្លាស់ប្តូរតំបន់រដ្ឋបាលខេត្តទៅកាន់តំបន់-២------------------------------------៥-១០
៥.២.២ ដែនដីនៃក្រុងសៀមរាប---------------------------------------------------៥-១១

## ឧបសម្ព័ន្ធ

A: មការរាប់ចរាចរណ៍ដោយទីប្រឹក្សាផ្នែករៀបចំក្រុងរបស់ JICA
B: ការសំរេចលទ្ធផលនៃកម្មវិធី/គំរោងដែលបានស្នើឡើងដោយទីប្រឹក្សាផ្នែករៀបចំក្រុងរបស់ JICA
C: ទំរង់គំរោងនៃផែនការកែលំអតំបន់កណ្តាលក្រុង
D: វិស័យគមនាគមន៍
E: កំណត់ហេតុអង្គប្រជុំ

# តារាង


| | | |
|---|---|---|
| តារាង ១.១ | បញ្ជីកិច្ចប្រជុំ | ១-៤ |
| តារាង ២.១ | និន្នាការនៃការមកដល់របស់ភ្ញៀវទេសចរក្នុងស្រុក និងអន្តរជាតិមកកាន់ ក្រុងសៀមរាប និងតំបន់អង្គរក្នុងរយៈពេល ១៥ឆ្នាំចុងក្រោយ | ២-៣ |
| តារាង ២.២ | និន្នាការនៃលក្ខណៈរបស់ភ្ញៀវទេសចរអន្តរជាតិ | ២-៥ |
| តារាង ២.៣ | ការប្រែប្រួលតាមខែ និងរដូវរបស់ភ្ញៀវទេសចរអន្តរជាតិមកកាន់ ក្រុងសៀមរាប និងតំបន់អង្គរ | ២-៦ |
| តារាង ២.៤ | ចំនួនភ្ញៀវទេសចរអន្តរជាតិដែលបានមកដល់ប្រទេសកម្ពុជា និងព្រលានយន្តហោះអន្តរជាតិខេត្តសៀមរាប ពីតំបន់ដើម | ២-៧ |
| តារាង ២.៥ | កំណើនប្រជាជន និងកត្តាផ្សេងៗ | ២-១០ |
| តារាង ២.៦ | ការប៉ាន់ប្រមាណ (ទិសដៅ) ចំនួនភ្ញៀវទេសចរក្នុងផែនការមេ | ២-១៣ |
| តារាង ២.៧ | ការប៉ាន់ប្រមាណចំនួនប្រជាជន (ទិសដៅ) នៃផែនការមេ | ២-១៤ |
| តារាង ២.៨ | ទិសដៅនៃផែនការប្រើប្រាស់ដីធ្លីសំរាប់ស្រុកសៀមរាប | ២-១៤ |
| តារាង ២.៩ | ការប៉ាន់ស្មានចំនួនប្រជាជន (ទិសដៅ) នៃការផ្គត់ផ្គង់ទឹក | ២-១៦ |
| តារាង ២.១០ | ការប៉ាន់ស្មានចំនួនភ្ញៀវទេសចរ (ទិសដៅ) នៃការផ្គត់ផ្គង់ទឹក | ២-១៦ |
| តារាង ២.១១ | តំបន់គោលដៅនៃការផ្គត់ផ្គង់ទឹក | ២-១៦ |
| តារាង ២.១២ | ការប៉ាន់ស្មានចំនួនភ្ញៀវទេសចរក្នុងស្រុកមកកាន់តំបន់អង្គរ និងក្រុងសៀមរាប | ២-២០ |
| តារាង ២.១៣ | ទិសដៅចំនួនប្រជាជនដែលត្រូវបានត្រួតពិនិត្យឡើងវិញ | ២-២២ |
| តារាង ២.១៤ | ទិសដៅសេដ្ឋកិច្ចសង្គមដែលត្រូវបានកែសំរួល | ២-២៣ |
| តារាង ២.១៥ | ស្ថានភាពគម្រោងសម្រាប់ការអភិវឌ្ឍទ្រង់ទ្រាយធំ | ២-២៤ |
| តារាង ២.១៦ | ចំនួនភ្ញៀវទេសចរទៅកាន់ព្រះវិហារ | ២-៣០ |
| តារាង ៣.១ | ការវិវត្តន៍នៃគំរោង/កម្មវិធីដែលបានស្នើឡើងរួច | ៣-១ |
| តារាង ៣.២ | ការវិវត្តន៍នៃគំរោង/កម្មវិធីដែលបានស្នើឡើងរួចក្នុងផ្នែករៀបចំក្រុង | ៣-៣ |
| តារាង ៣.៣ | ការវិវត្តន៍នៃគំរោង/កម្មវិធីដែលបានស្នើឡើងរួចក្នុងវិស័យគមនាគមន៍ | ៣-៩ |
| តារាង ៤.១ | បញ្ហានាពេលបច្ចុប្បន្នស្តីពីការអភិវឌ្ឍនក្រុង | ៤-៦ |
| តារាង ៤.២ | គំរោងកែលំអដែលបានស្នើឡើងញដោយកម្មវិធីនីមួយៗ | ៤-១០ |
| តារាង ៤.៣ | គំរោង និងកម្មវិធីអាទិភាពដែលបានស្នើឡើង | ៤-១៦ |
| តារាង ៤.៤ | បញ្ជីគំរោងស្តារឡើងវិញបណ្តាញផ្លូវទៅកាន់តំបន់បេតិកភណ្ឌជនបទ | ៤-២៩ |
| តារាង ៤.៥ | បញ្ជីស្ថាប័ន និងផ្លូវដែលត្រូវទទួលខុសត្រូវ | ៤-៣១ |
| តារាង ៤.៦ | ការគិតជាឯកតានៃរថយន្តដឹកអ្នកដំណើរ PCU ដោយចំណាត់ថ្នាក់នៃយានយន | ៤-៣២ |

តារាង ៤.៧ សមត្ថភាពផ្លូវជាតិជាគោល ----------------------------------------------- ៤-៣៥
តារាង ៤.៨ តារាង ៤.៨ កត្តាកែសំរួលដោយបរិស្ថានចិញ្ចើមផ្លូវ ---------------------------------- ៤-៣៦
តារាង ៤.៩ កំរិតចរាចរណលើផ្លូវជាតិលេខ៦ ---------------------------------------------- ៤-៣៨
តារាង ៤.១០ តំរូវការចរាចរណនាពេលអនាគតលើផ្លូវជាតិលេខ៦ --------------------------------- ៤-៣៩
តារាង ៤.១១ ផែនការសកម្មភាពសុវត្ថិភាពផ្លូវ ------------------------------------------- ៤-៤៦
តារាង ៤.១២ បញ្ជីផ្លូវតំបន់ជនបទដែលត្រូវបានស្នើនៃគំរោង TR-5 ----------------------------- ៤-៤៨
តារាង ៤.១៣ កម្មវត្ថុដែលស្នើតាមទិន្នន័យសារពើរភ័ណ្ឌ --------------------------------------- ៤-៥២
តារាង ៤.១៤ ការប៉ាន់ស្មានថ្លៃដើមសាងសង់សំរាប់បណ្តាញផ្លូវទៅកាន់បេតិកភណ្ឌជនបទ -------------- ៤-៥៥
តារាង ៥.១ គំរោងអាទិភាពក្នុងការកែលំអតំបន់កណ្តាលក្រុង និងផ្នែកគមនាគមន៏ ------------------- ៥-២
តារាង ៥.២ គំរោងសាកល្បងដែលត្រូវបានស្នើឡើង ----------------------------------------- ៥-៥
តារាង ៥.៣ គំរោងបេក្ខភាពដទៃទៀតសំរាប់ការកែលំអតំបន់កណ្តាលក្រុង ------------------------- ៥-៧

# រូបភាព

រូបភាព ១.១ កាលវិភាគនៃការសិក្សា ------------------------------------------------ ១-៣
រូបភាព១.២ រចនាសម្ព័ន្ធចាត់តាំងសំរាប់ការសិក្សា ------------------------------------------ ១-៥
រូបភាព ២.១ និន្នាការនៃការមកដល់របស់ភ្ញៀវទេសចរក្នុងស្រុក និងអន្តរជាតិមកកាន់ ក្រុងសៀមរាប និងតំបន់អង្គរក្នុងរយៈពេល ១៥ឆ្នាំចុងក្រោយ ----------------------------------------- ២-៣
រូបភាព ២.២ ចំណែកនៃចំនួនភ្ញៀវទេសចរអន្តរជាតិមកកាន់ប្រទេសកម្ពុជា និងក្រុងសៀមរាបពីតំបន់ដើម ---- ២-៨
រូបភាព ២.៣ ចំនួនភ្ញៀវទេសចរអន្តរជាតិដែលមកពីប្រទេសដែលមានទីផ្សារទេសចរណ៍ខ្ពស់មកកាន់ព្រលានយន្តហោះអន្តរជាតិខេត្តសៀមរាប -------------------------------------------- ២-៨
រូបភាព ២.៤ កំណើនប្រជាជនក្នុង ១០ឃុំក្នុងស្រុកសៀមរាប ----------------------------------- ២-១០
រូបភាព ២.៥ ការប្រៀបធៀបនៃនិន្នាការកាលពីមុន និងទិសដៅនៃចំនួនភ្ញៀវទេសចរ អន្តរជាតិមកកាន់តំបន់សៀមរាប និងអង្គរ ------------------------------------------------ ២-១៨
រូបភាព ២.៦ ការប្រៀបធៀបនៃនិន្នាការកាលពីមុន និងទិសដៅក្នុងផែនការមេនៃចំនួនភ្ញៀវទេសចរក្នុងស្រុកមកកាន់តំបន់សៀមរាប និងអង្គរ ------------------------------------------- ២-១៩
រូបភាព ២.៧ ការប្រៀធៀបនិន្នាការកាលពីមុន និងទិសដៅនៃចំនួនប្រជាជនក្នុង ១០ឃុំនៃតំបន់ស្រុកសៀមរាប ----------------------------------------------------- ២-២១
រូបភាព ២.៨ ការប្រៀបធៀបនៃបណ្តាអាគារ/រចនាសម្ព័ន្ធ រវាងឆ្នាំ ២០០៥ និង ២០០៨ --------------- ២-២៤
រូបភាព ២.៩ ការប្រៀបធៀបតំបន់ក្រុងទាំងបី -------------------------------------------- ២-២៧

រូបភាព ២.១០ ការមកដល់របស់ភ្ញៀវទេសចរមកកាន់កម្ពុជាតាមច្រកប៉ោយប៉ែត--------------------២-៣០
រូបភាព ៣.១ ការកែលំអផ្លូវថ្មើជើង--------------------------------------------------៣-៥
រូបភាព ៣.២ ជួរដើមឈើ------------------------------------------------------------៣-៦
រូបភាព ៣.៣ ភ្លើងបំភ្លឺផ្លូវ------------------------------------------------------------៣-៧
រូបភាព ៣.៤ ការអភិវឌ្ឍន៍ និងកែលំអផ្លូវ--------------------------------------------៣.៨
រូបភាព ៣.៥ ទីតាំងស្ពានសម័យបារាំងទី២-------------------------------------------៣-១១
រូបភាព ៣.៦ ផ្លូវក្នុងដំណាក់កាលទី១ ដែលបានស្នើឡើង និងស្ថានភាពផ្លូវកៅស៊ូក្នុងពេលបច្ចុប្បន្ន----------៣-១១
រូបភាព ៣.៧ ផ្លូវ ហ៊ុន សែន សន្តិភាព (ដំណាក់កាលទី២)--------------------------------------៣-១២
រូបភាព ៣.៨ បណ្តាញផ្លូវដែលបានស្នើឡើងក្នុងដំណាក់កាលទី៣ (ឆ្វេង) និងដំណាក់កាលទី៤ (ស្តាំ)--------៣-១៤
រូបភាព ៤.១ ប្រភេទតំបន់ក្រុងក្នុងក្រុងសៀមរាប---------------------------------------------៤-២
រូបភាព ៤.២ ទីតាំងនៃតំបន់កណ្តាលក្រុង------------------------------------------------៤-៣
រូបភាព ៤.៣ ទស្សនវិស័យផ្ទៃរៀបចំក្រុង និងគោលដៅសំរាប់ការកែលំអតំបន់កណ្តាលក្រុង---------------៤-៥
រូបភាព ៤.៤ វិធីសាស្ត្រផ្នែករៀបចំដែលត្រូវបានចំរាញ់ដើម្បីធ្វើកែលំអតំបន់កណ្តាលក្រុង----------------៤-៧
រូបភាព ៤.៥ មុខងាររូបវ័ន្តសំរាប់ការកែលំអតំបន់កណ្តាលក្រុង---------------------------------៤-៨
រូបភាព ៤.៦ មូលបទនៃការកែលំអតំបន់កណ្តាលក្រុង រយៈពេលវែង----------------------------៤-១២
រូបភាព ៤.៧ ផែនការរូបវ័ន្តសំរាប់កែលំអតំបន់ផ្សារចាស់ (រយៈពេលវែង)------------------------៤-១៤
រូបភាព ៤.៨ រូបភាពនៃការកែលំអៈ ផ្នែកសាមញ្ញនៃផ្សារអ្នកថ្មើជើងក្នុងតំបន់ផ្សារចាស់ ---------------៤-១៨
រូបភាព ៤.៩ ក្រុមការងារសំរាប់កែលំអតំបន់ផ្សារចាស់ដែលបានស្នើឡើង--------------------------៤-២០
រូបភាព ៤.១០ សំណើសំរាប់ការគ្រប់គ្រងចរាចរណ៍ក្នុងតំបន់ផ្សារចាស់ -----------------------------៤-២១
រូបភាព ៤.១១ សំណើប្រព័ន្ធចំណតលើផ្លូវស៊ីវុត្ថា-------------------------------------------៤-២២
រូបភាព ៤.១២ សមាសធាតុដំណាក់កាលរយៈពេលមធ្យមក្នុងតំបន់ផ្សារចាស់ -----------------------៤-២៤
រូបភាព ៤.១៣ សមាសធាតុដំណាក់កាលរយៈពេលវែងក្នុងតំបន់ផ្សារចាស់-------------------------៤-២៥
រូបភាព ៤.១៤ ផ្លូវក្រាលកៅស៊ូត្រឹមខែ មេសា ឆ្នាំ ២០១០--------------------------------------៤-២៦
រូបភាព ៤.១៥ បណ្តាញផ្លូវឆ្នាំ ២០២០ ដែលបានស្នើឡើងដោយផែនការមេ-------------------------៤-២៧
រូបភាព ៤.១៦ ការពង្រីកតំបន់ក្រុងដោយដើរតាមលំនាំទស្សនៈទីក្រុងរណប-------------------------៤-២៧
រូបភាព ៤.១៧ លក្ខខណ្ឌបណ្តាញផ្លូវក្នុងតំបន់ត្រឹមខែ មិថុនា ឆ្នាំ២០០៥----------------------------៤-២៨
រូបភាព ៤.១៨ ស្ថានភាពស្តារឡើងវិញផ្លូវថ្នល់ក្នុងខេត្តត្រឹមខែ កុម្ភៈ ឆ្នាំ ២០១០----------------------៤-២៩
រូបភាព ៤.១៩ ផែនទីទីតាំងនៃស្ថានីយ៍ដែលបានធ្វើការស្ទាប់ស្ទង់ក្នុងឆ្នាំ២០១០-----------------------៤-៣២
រូបភាព ៤.២០ កំរិតចរាចរណ៍ក្នុង PCU នៅស្ថានីយ៍ធ្វើការស្ទាបស្ទង់ទី៤-------------------------៤-៣៣
រូបភាព ៤.២១ កំរិតចរាចរណ៍ក្នុង PCU នៅស្ថានីយ៍ធ្វើការស្ទាបស្ទង់ទី៥-------------------------៤-៣៣

រូបភាព ៤.២២ ករិតចរាចរណ៍ក្នុង PCU នៅស្ថានីយ៍ធ្វើការស្ទាបស្ទង់ទី១-------------------------៤-៣៤
រូបភាព ៤.២៣ ការបកស្រាយទ្រឹស្តីនៃទិន្នន័យពីការរាប់ ចរាចរណ៍នៅស្ថានីយ៍ទី១--------------------៤-៣៤
រូបភាព ៤.២៤ កំណាត់ផ្លូវជាតិលេខ៦----------------------------------------------------៤-៣៦
រូបភាព ៤.២៥ ករិតចរាចរណ៍ក្នុង PCU នៅស្ថានីយទី១២-------------------------------------៤-៣៧
រូបភាព ៤.២៦ ចំនុចរាប់ចរាចរណ៍ក្នុងផែនការមេ------------------------------------------៤-៣៧
រូបភាព ៤.២៧ ករិតចរាចរណ៍ក្នុង PCU នៅការរាប់ចំនុចទី១---------------------------------៤-៣៩
រូបភាព ៤.២៨ ករិតចរាចរណ៍ក្នុង PCU នៅការរាប់ចំនុចទី៣---------------------------------៤-៣៩
រូបភាព ៤.២៩ ការកែលំអបណ្តាញផ្លូវក្នុងក្រុងក្នុងផ្លូវជាតិលេខ៦ និងផ្លូវវាងក្រុង---------------------៤-៤៣
រូបភាព ៤.៣០ ការកែលំអបណ្តាញផ្លូវក្នុងក្រុងខាងក្រៅផ្លូវវាងក្រុង------------------------------៤-៤៤
រូបភាព ៤.៣១ TR-3 ការសាងសង់ផ្លូវវណបនឹងផ្លូវជាតិលេខ៦---------------------------------៤-៤៥
រូបភាព ៤.៣២ ផែនការអភិវឌ្ឍផ្លូវថ្នល់ (TR-1 TR-2 និង TR-3)-----------------------------៤-៤៦
រូបភាព ៤.៣៣ ទីតាំងផែនទីផ្លូវដែលបានស្នើនៃគំរោង TR-5----------------------------------៤-៤៩
រូបភាព ៤.៣៤ ផ្លូវដែលស្នើសំរាប់សេវាដឹកជញ្ជូនសាធារណៈ និងតំបន់រឹតបន្តឹងមិនឱ្យរថយន្តឯកជនចូល-----៤-៥១
រូបភាព ៥.១ អង្គការចាត់តាំងដែលបានស្នើឡើងសម្រាប់ការសម្របសម្រួល និងការប្រតិបត្តិ-----------៥-៤
រូបភាព ៥.២ ទីតាំងនៃគំរោងសាកល្បងដែលបានស្នើឡើង-----------------------------------៥-៧

# ជំពូក ១ សេចក្តីផ្តើម

## ១.១ ប្រវត្តិនៃការសិក្សាតាមដាន

ក្រុងសៀមរាបមានប្រាសាទអង្គរដែលជាទីតាំងបេតិកភណ្ឌពិភពលោក និងជាគោលដៅទេសចរណ៍ដ៏ពេញនិយមបំផុតមួយនៅក្នុងព្រះរាជាណាចក្រកម្ពុជា។ ទោះបីជាយ៉ាងណាក៏ដោយ ការកើនឡើងនូវចំនួនភ្ញៀវទេសចរយ៉ាងគំហុកនេះ បានពន្លឿននូវការពង្រីកក្រុងយ៉ាងឆាប់រហ័សក្នុងក្រុងសៀមរាប។ នៅក្នុងឆ្នាំ ២០០៨ ចំនួនប្រជាជននៅក្នុងខេត្តសៀមរាបមានត្រឹមតែចំនួន ៨៩០ ០០០នាក់ និងចំនួនប្រជាជននៅក្នុងក្រុងសៀមរាបមានត្រឹមតែចំនួន ១៧០០០០ នាក់ប៉ុណ្ណោះ។ ក្នុងរយៈពេល ១០ឆ្នាំចុងក្រោយនេះ ចំនួនប្រជាជននៅក្នុងក្រុងសៀមរាបបានកើនឡើង ៧០%។

រាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា និងទីភ្នាក់ងារសហប្រតិបត្តិការអន្តរជាតិនៃប្រទេសជប៉ុន JICA បានប្រមើរឃើញនូវការរីកដុះដាលក្រុងយ៉ាងឆាប់រហ័សនេះ ហើយបានទទួលស្គាល់នូវតំរូវការជាចាំបាច់នូវផែនការមេរួម ដើម្បីអភិវឌ្ឍសេដ្ឋកិច្ច ស្ថាបនាហេដ្ឋារចនាសម្ព័ន្ធ និងដើម្បីរក្សាគុណភាពនៃធនធានទេសចរណ៍ និងបរិស្ថានក្នុងក្រុងសៀមរាប។ ដោយផ្អែកលើ កិច្ចព្រមព្រៀងរវាងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា និងទីភ្នាក់ងារសហប្រតិបត្តិការអន្តរជាតិនៃប្រទេសជប៉ុន JICA ទីភ្នាក់ងារសហប្រតិបត្តិការអន្តរជាតិនៃប្រទេសជប៉ុន JICA បានធ្វើការសិក្សាស្តីពីផែនការមេរួមសំរាប់ការអភិវឌ្ឍន៍ដោយនិរន្តរភាពក្នុងក្រុងសៀមរាប នៃព្រះរាជាណាចក្រកម្ពុជា ចាប់ពីឆ្នាំ២០០៤ ដល់ ឆ្នាំ២០០៦។

ការសិក្សាផែនការមេបានកំណត់នូវទស្សនះវិស័យទៅថ្ងៃអនាគតសំរាប់ក្រុងសៀមរាបក្នុងឆ្នាំ២០២០ អោយទៅជាទីក្រុងទេសចរណ៍ស្អាត និងមានតែមួយផ្តោតលើភាពសុខដុមនៃប្រវត្តិសាស្ត្រ សិល្បៈ និងធម្មជាតិនៃខ្មែរ។ មានយុទ្ធសាស្ត្រចំនួន៦ ត្រូវបានបង្ហាញដើម្បីឈានទៅរកទស្សនះវិស័យនេះ ដូចជា (១) ផ្សព្វផ្សាយវិស័យទេសចរណ៍ផ្តោតលើទីផ្សារកំរិតខ្ពស់ (២) បង្កើនចំណូលក្នុងស្រុកពីវិស័យទេសចរណ៍ (៣) ធ្វើអោយទីក្រុងកាន់តែទាក់ទាញសំរាប់ភ្ញៀវទេសចរ (៤) ធ្វើអោយទីក្រុងកាន់តែមាននិរន្តរភាពក្នុងផ្នែកបរិស្ថាន (៥) ពង្រឹងហេដ្ឋារចនាសម្ព័ន្ធសំរាប់ភ្ញៀវទេសចរ និងប្រជាជន (៦) ពង្រឹង ហិរញ្ញវត្ថុ និងរដ្ឋបាលក្នុងស្រុក។ ដើម្បីស្វែងយល់នូវទស្សនះវិស័យនេះ មានគំរោង/កម្មវិធីចំនួន ៦៩ ផ្អែកលើយុទ្ធសាស្ត្រទាំង ៦ ខាងលើ ត្រូវបានស្នើឡើង។

ចាប់តាំងពីខែ ឧសភា ឆ្នាំ ២០០៨ ទីប្រឹក្សាផ្នែករៀបចំក្រុងមួយរូបរបស់ទីភ្នាក់ងារសហប្រតិបត្តិការអន្តរជាតិនៃប្រទេសជប៉ុន JICA ត្រូវបានបញ្ជូនមកដើម្បីពង្រឹងផ្នែករៀបចំក្រុង និងធ្វើការសំរបសំរួលសមត្ថភាព

ក្នុងខេត្តសៀមរាប ហើយក្នុងពេលបច្ចុប្បន្ននេះ កំពុងត្រូវបានអនុវត្តនូវសកម្មភាពជាច្រើនដូចជាការបង្កើតគណៈកម្មការបច្ចេកទេសផ្នែកអភិវឌ្ឍន៍ក្រុងសៀមរាប UDTC ជាដើម ។

រយៈពេលជិត ៤ឆ្នាំ បន្ទាប់ពីការសិក្សាផែនការមេត្រូវបានបញ្ចប់ មានគំរោង/កម្មវិធីជាច្រើន និងសកម្មភាពមួយចំនួនទៀតត្រូវបានគេអនុវត្តដូចជា ផ្នែកធនធានទឹក/ការផ្គត់ផ្គង់ទឹកស្អាត និងផ្នែកបង្ហូរទឹក/ទឹកសំអុយ ។ ទោះបីជាយ៉ាងណាក៏ដោយ គំរោង/កម្មវិធីក្នុងវិស័យគមនាគមន៍ និងផ្នែកអភិវឌ្ឍន៍ក្រុងពុំទាន់មានការវិវត្តន៍នៅឡើយ ។ ទោះបីថា ការកែលំអ/ការអភិវឌ្ឍន៍នូវបណ្តាញផ្លូវនៅក្នុងតំបន់ក្រុងត្រូវបានស្នើឡើងជាមួយយុទ្ធសាស្ត្រ (៥) " ពង្រឹងហេដ្ឋារចនាសម្ព័ន្ធសំរាប់ភ្ញៀវទេសចរ និងប្រជាជន " ក៏ដោយ ក៏ផែនការលំអិតពុំទាន់ត្រូវបានធ្វើឡើងនៅឡើយ ដូច្នេះហើយ ផែនការនោះ គឺពុំទាន់ត្រូវបានអនុវត្តនៅឡើយទេ ។ ទន្ទឹមនឹងនោះដែរ គំរោង/កម្មវិធីអភិវឌ្ឍន៍តំបន់កណ្តាលក្រុងដែលមានសារៈសំខាន់ដើម្បីសំរេចនូវយុទ្ធសាស្ត្រ (៣) " ធ្វើអោយទីក្រុងកាន់តែទាក់ទាញសំរាប់ភ្ញៀវទេសចរ " ពុំទាន់ត្រូវបានទទួលស្គាល់នៅឡើយ បើទោះបីថា បញ្ហានេះត្រូវបានពិភាក្សានៅក្នុងគណៈកម្មការបច្ចេកទេសផ្នែកអភិវឌ្ឍន៍ក្រុងសៀមរាប UDTC ក៏ដោយ ។

នៅក្នុងបរិបទនេះ ការសិក្សាតាមដានស្តីពីផែនការមេរួមសំរាប់ការអភិវឌ្ឍន៍ដោយនិរន្តរភាពក្រុងសៀមរាបត្រូវបានធ្វើឡើង ក្នុងគោលបំណងស្វែងយល់នូវផែនការអភិវឌ្ឍន៍របស់ផែនការមេសំរាប់វិស័យគមនាគមន៍ និងផ្នែកអភិវឌ្ឍន៍ក្រុង ។

## ១.២ គោលបំណងនៃការសិក្សា

គោលបំណងនៃការសិក្សាតាមដានស្តីពីផែនការមេរួមសម្រាប់ការអភិវឌ្ឍន៍ប្រកបដោយនិរន្តរភាពក្រុងសៀមរាប នៃព្រះរាជាណាចក្រកម្ពុជា គឺដើម្បីៈ

- ពិនិត្យឡើងវិញពីការវិវត្តន៍នៃការសិក្សាផែនការមេ
- ពិនិត្យឡើងវិញពីផែនការអភិវឌ្ឍន៍នៃវិស័យអភិវឌ្ឍន៍ក្រុង និងវិស័យគមនាគមន៍នៃការសិក្សាផែនការមេ និង
- ធ្វើបច្ចុប្បន្នភាពនៃផែនការអភិវឌ្ឍន៍ ដោយរាប់បញ្ចូលទាំងគំរោងអាទិភាពនានា ។

## ១.៣ តំបន់នៃការសិក្សា

តំបន់នៃការសិក្សាគ្របដណ្តប់លើដែនសមត្ថកិច្ចនៃក្រុងសៀមរាប ។

- ក្រុងសៀមរាបត្រូវបានប្តូរមកជាក្រុងក្នុងឆ្នាំ ២០០៨ រួមមាន ១៣សង្កាត់ (ឃុំ)
- តំបន់កណ្តាលក្រុងផ្តោតលើតំបន់ផ្សារចាស់ និងតំបន់ជុំវិញក្រុង ហើយពង្រីកដល់តំបន់ដែលនៅជុំវិញនោះក្នុងករណីចាំបាច់

- បណ្តាញផ្លូវមេស្ថិតក្នុងតំបន់ដដែលដូចមាននៅក្នុងការសិក្សាផែនការមេ ហើយពង្រីកដល់តំបន់ដែលនៅជុំវិញនោះក្នុងករណីចាំបាច់

## ១.៤ សេចក្តីសង្ខេបនៃការសិក្សា

### ១.៤.១ កាលវិភាគនៃការសិក្សា

ការសិក្សាតាមដានត្រូវបានចាប់ផ្តើមក្នុងខែ កុម្ភៈ ឆ្នាំ២០១០ ហើយត្រូវបញ្ចប់ក្នុងខែ ឧសភា ឆ្នាំ២០១០។ សមាសធាតុចំបងនៃការសិក្សាតាមដានគឺៈ ការវិភាគស្ថានភាពបច្ចុប្បន្ន ការត្រួតពិនិត្យឡើងវិញនូវការវិវត្តន៍នៃផែនការមេ ការត្រួតពិនិត្យឡើងវិញនូវគំរោងអាទិភាព និងការធ្វើរបាយការណ៍។ កិច្ចប្រជុំគណៈកម្មការបច្ចេកទេសផ្នែកអភិវឌ្ឍន៍ក្រុងសៀមរាប UDTC ចំនួន៣ និងកិច្ចប្រជុំផ្សព្វផ្សាយជាមួយមន្ទីរ និងស្ថាប័នពាក់ព័ន្ធចំនួន១ត្រូវបានប្រារព្ធឡើងដូចខាងក្រោមៈ

| ខែ | កុម្ភៈ | មិនា | មេសា | ឧសភា | មិថុនា |
|---|---|---|---|---|---|
| កិច្ចការងារ | ការវិភាគស្ថានភាពបច្ចុប្បន្ន<br>ការត្រួតពិនិត្យឡើងវិញនូវការវិវត្តន៍នៃផែនការមេ | ការធ្វើបច្ចុប្បន្នភាពនៃផែនការអភិវឌ្ឍន៍ | ការត្រួតពិនិត្យឡើងវិញនូវគំរោងអាទិភាព | របាយការណ៍ | |
| របាយការណ៍ | ▲ របាយការណ៍បឋម | | | ▲ DFR | ▲ FR |
| កិច្ចប្រជុំ | △ TC △ TC | | | □ SHM △ TC | |

ប្រភពៈ ការសិក្សាតាមដាន

TC: គណៈកម្មការបច្ចេកទេស SHM: កិច្ចប្រជុំផ្សព្វផ្សាយជាមួយស្ថាប័នអង្គភាពពាក់ព័ន្ធ
DFR: របាយការណ៍ព្រាងចុងក្រោយ FR: របាយការណ៍ចុងក្រោយ

**រូបភាព ១.១ កាលវិភាគនៃការសិក្សា**

## តារាង ១.១ បញ្ជីកិច្ចប្រជុំ

| | កាលបរិច្ឆេទ | ប្រធានបទ | អ្នកចូលរួម |
|---|---|---|---|
| គណៈ. លើកទី៥ | ថ្ងៃទី១១ខែកុម្ភៈ ឆ្នាំ ២០១០ | -កិច្ចពិភាក្សាលើរបាយការណ៍បឋម | សមាជិកគណៈកម្មការ បច្ចេកទេស និង ក្រុម សិក្សា JICA |
| គណៈ. លើកទី៦ | ថ្ងៃទី២៥ខែកុម្ភៈ ឆ្នាំ ២០១០ | -លទ្ធផលការស្ទាបស្ទង់ចរាចរណ៍<br>-របាយការណ៍លើការវិវត្តន៍ | |
| គណៈ. លើកទី៧ | ថ្ងៃទី១០ខែឧសភាឆ្នាំ២០១០ | -កិច្ចពិភាក្សាលើរបាយការណ៍ព្រាង ចុងក្រោយ | |
| កិច្ចប្រជុំផ្សព្វផ្សាយ ជាមួយមន្ទីរ និង ស្ថាប័នពាក់ព័ន្ធ | ថ្ងៃទី០៥ខែឧសភាឆ្នាំ២០១០ | -កិច្ចពិភាក្សា និងការផ្លាស់ប្តូរ យោបល់សំរាប់ការកែលំអតំបន់កណ្តាលក្រុង<br>-ការកសាងកិច្ចព្រមព្រៀងគ្នាជាមុនសំរាប់ ទិសដៅកែលំអទៅថ្ងៃអនាគត | សមាជិកគណៈកម្មការ បច្ចេកទេស ក្រុមសិក្សា JICA និងក្រុមប្រឹក្សាឃុំ ។ល ។ |

ប្រភព: ការសិក្សាតាមដាន

### ១.៤.២ រចនាសម្ព័ន្ធចាត់តាំង

អង្គភាពចាត់តាំងនៃការសិក្សាតាមដានមានរចនាសម្ព័ន្ធដូចខាងក្រោម ។ រដ្ឋបាលខេត្តសៀមរាបគឺជាសមភាគីសំរាប់ការសិក្សាតាមដាន ។ អាជ្ញាធរអប្សរា មន្ទីរសាធារណៈការ និងដឹកជញ្ជូនខេត្ត មន្ទីររៀបចំដែនដីនគររូបនីយកម្ម និងសំណង់ មន្ទីរទេសចរ រដ្ឋបាលក្រុងសៀមរាបគឺជាមន្ទីរអង្គភាពពាក់ព័ន្ធ ។

សំរាប់ការទំនាក់ទំនងក្នុងចំណោមមន្ទីរអង្គភាពពាក់ព័ន្ធ ក្រុមសិក្សាតាមដាន បានប្រើប្រាស់គណៈកម្មការបច្ចេកទេសផ្នែកអភិវឌ្ឍន៍ក្រុងសៀមរាប UDTC ដើម្បីពិភាក្សាស្តីពីការវិវត្តន៍នៃការសិក្សា ។ គណៈកម្មការបច្ចេកទេសផ្នែកអភិវឌ្ឍន៍ក្រុងសៀមរាប UDTC ត្រូវបានបង្កើតឡើងដោយមន្ត្រីមកពីស្ថាប័នចំនួន៨ ដូចជា រដ្ឋបាលខេត្តសៀមរាប អាជ្ញាធរអប្សរា មន្ទីរសាធារណៈការ និងដឹកជញ្ជូន មន្ទីររៀបចំដែនដី នគររូបនីយកម្ម និងសំណង់ មន្ទីរទេសចរ រដ្ឋបាលក្រុងសៀមរាប អាជ្ញាធររដ្ឋាករទឹកខេត្តសៀមរាប និងមន្ទីរឧស្សាហកម្ម រ៉ែ និងថាមពល ។




ប្រភព: ការសិក្សាតាមដាន

**រូបភាព១.២ រចនាសម្ព័ន្ធចាត់តាំងសំរាប់ការសិក្សា**

## ១.៥ រចនាសម្ព័ន្ធនៃរបាយការណ៍

របាយការណ៍ចុងក្រោយមាន ៥ជំពូក រួមមាន សេចក្ដីផ្ដើមក្នុងជំពូកទី១ ស្ថានភាពអភិវឌ្ឍន៍ក្នុងពេលបច្ចុប្បន្ននៃក្រុងសៀមរាបបន្ទាប់ពីផែនការមេត្រូវបានបង្ហាញក្នុងជំពូកទី២។ ក្នុងជំពូកទី៣ ការវិវត្តន៍នៃគំរោង/កម្មវិធីអាទិភាពនៃផែនការមេត្រូវបានត្រួតពិនិត្យឡើងវិញ និងពន្យល់។ ដោយផ្អែកលើការវិភាគលើស្ថានភាពបច្ចុប្បន្ន និងការវិវត្តន៍នៃគំរោង/កម្មវិធីនៃផែនការមេ ផែនការអភិវឌ្ឍន៍សំរាប់វិស័យគមនាគមន៍ និងផ្នែករៀបចំក្រុងត្រូវបានសិក្សា និងពិពណ៌នាក្នុងជំពូកទី៤។ ជំពូកទី៥ បានចងក្រងនូវការសន្និដ្ឋាន និងអនុសាសន៍សំរាប់ជំហានបន្ទាប់នៃផ្នែករៀបចំក្រុង និងបណ្ដាញផ្លូវដឹកជញ្ជូនសំរាប់ក្រុងសៀមរាប។

# ជំពូក ២ ស្ថានភាពអភិវឌ្ឍក្នុងពេលបច្ចុប្បន្នរបស់ក្រុងសៀមរាប បន្ទាប់ពីមានការសិក្សាផែនការមេ

ផែនការមេត្រូវបានបង្កើតប្រមាណជា ៤ឆ្នាំបានកន្លងផុតទៅហើយ ដោយក្នុងនោះរួមមានទាំងវិបត្តិសេដ្ឋកិច្ចពិភពលោកផងដែរ។ កំណើនសេដ្ឋកិច្ចសង្គមយ៉ាងឆាប់រហ័សដែលមានពីមុន បានត្រូវបន្ត និងកើនលើសទិសដៅនៃចំនួនភ្ញៀវទេសចរ និងចំនួនប្រជាជនក្នុងផែនការមេ។ ដោយឡែក ផែនការដែលបានស្នើឡើងក្នុងការអភិវឌ្ឍន៍ និងគ្រប់គ្រងក្រុងសៀមរាបអាចឈានដល់កំណើនសេដ្ឋកិច្ចសង្គមយ៉ាងឆាប់រហ័សបន្ទាប់ពីមានផែនការមេ។

## ២.១ ការផ្លាស់ប្តូរសេដ្ឋកិច្ចសង្គម និងផលប៉ះពាល់របស់វា (ផ្នែកទេសចរណ៍ និងផ្នែកដែលទទួលផលប៉ះពាល់)

### ២.១.១ ការកើនឡើងនូវភ្ញៀវទេសចរ

**(១) និន្នាការនៃការមកដល់របស់ភ្ញៀវទេសចរមកក្នុងក្រុងសៀមរាប និងតំបន់អង្គរ**

១) និន្នាការនៃការមកដល់របស់ភ្ញៀវទេសចរអន្តរជាតិ

ការចុះបញ្ជីឧស្សានអង្គរជាបេតិកភណ្ឌពិភពលោកដោយ UNESCO ក្នុងឆ្នាំ ១៩៩២ បានបង្កើតនូវឱកាសមួយដើម្បីផ្លាស់ប្តូរពីរូបភាពនៃកន្លែងដែលអសន្តិសុខ និងអស្ថេរភាពតាមរយៈសង្គ្រាមផ្ទៃក្នុងអោយទៅជាទិសដៅទេសចរវប្បធម៌ និងប្រវត្តិសាស្ត្រដែលគួរអោយចាប់អារម្មណ៍។ ទេសចរណ៍វប្បធម៌ និងប្រវត្តិសាស្ត្រក្នុងក្រុងសៀមរាប និងតំបន់អង្គរត្រូវបានផ្តួចផ្តើម និងធ្វើអោយប្រសើរឡើងដោយកំណើនភ្ញៀវទេសចរអន្តរជាតិ។ បន្ទាប់ពីឆ្នាំ ១៩៩៩ រហូតដល់ឆ្នាំ ២០០៤ ចំនួនភ្ញៀវទេសចរអន្តរជាតិបានកើនឡើងយ៉ាងឆាប់រហ័សប្រមាណពីចំនួន ៨៣ ០០០ នាក់ រហូតដល់ចំនួន ៥៦០ ០០០ នាក់ (ស្មើនឹងចំនួន ៦.៧៥ដង ច្រើនជាងក្នុងឆ្នាំ១៩៩៩ ហើយដែលត្រូវនឹង៤៦%ប្រចាំឆ្នាំ)។ និន្នាការនៃភ្ញៀវទេសចរអន្តរជាតិនេះបានស្ងប់ស្ងាត់ទៅវិញដោយជំងឺ SARS ដែលបានជះឥទ្ធិពលមកលើវិស័យទេសចរណ៍ក្នុងខេត្តសៀមរាប និងតំបន់អង្គរ។ ទោះបីជាយ៉ាងណាក៏ដោយ ចំនួនភ្ញៀវ ទេសចរអន្តរជាតិមកកាន់តំបន់នេះបានកើនឡើងវិញភ្លាមៗក្នុងឆ្នាំ ២០០៤។

បន្ទាប់ពីឆ្នាំ២០០៤ រហូតដល់ឆ្នាំ២០០៩ ការមកដល់របស់ភ្ញៀវទេសចរអន្តរជាតិមកក្នុងតំបន់បានបន្តកើនឡើងរហូតដល់ចំនួន ១.១ លាននាក់ ក្នុងឆ្នាំ២០០៧។ ទោះបីជាយ៉ាងណាក៏ដោយ វិបត្តិសេដ្ឋកិច្ចពិភពលោកចាប់ពីឆ្នាំ២០០៧ បានប៉ះពាល់យ៉ាងធ្ងន់ធ្ងរ និងបានកាត់បន្ថយនូវចំនួនមកដល់របស់ភ្ញៀវទេសចរអន្តរជាតិក្នុងទីផ្សារទេសចរណ៍ពិភពលោក។ ការមកដល់របស់ភ្ញៀវទេសចរអន្តរជាតិមកក្នុងតំបន់ក៏បានថយចុះពីចំនួន ១.១

លាននាក់ មកត្រឹមចំនួន ៩៥៨ ០០០ នាក់ ក្នុងឆ្នាំ២០០៩។ ប៉ុន្តែបាតុភូតនេះត្រូវបានផ្លាស់ប្តូរ និងវិលមកកាន់ស្ថានភាពដូចមុនពេលមានវិបត្តិសេដ្ឋកិច្ចវិញហើយ ដែលបង្ហាញថាភ្ញៀវទេសចរដែលមកកាន់ឧស្សានអង្គរក្នុងខែមករា ឆ្នាំ២០១០ បានកើនឡើង (ច្រើនជាងខែមករា ឆ្នាំ២០០៧)។ កំណើនជាមធ្យមប្រចាំឆ្នាំនៃភ្ញៀវទេសចរអន្តរជាតិមកកាន់តំបន់ក្នុងរយៈពេល ១៥ឆ្នាំចុងក្រោយនេះមានចំនួនប្រមាណជា ២៨%។ ក្នុងរយៈពេល ១០ឆ្នាំចុងក្រោយ ចាប់ពីឆ្នាំ១៩៩៩មក កំណើនជាមធ្យមប្រចាំឆ្នាំក៏មានចំនួន២៨% ផងដែរ។ ប៉ុន្តែក្នុងរយៈពេល ៥ឆ្នាំចុងក្រោយ ចាប់តាំងពីឆ្នាំ២០០៤ កំណើនជាមធ្យមប្រចាំឆ្នាំបានថយចុះជាបន្តបន្ទាប់មកត្រឹម ១២%។

បេតិកភណ្ឌវប្បធម៌ និងប្រវត្តិសាស្ត្រក្នុងខេត្តសៀមរាប និងតំបន់អង្គរអាចត្រូវបានចាត់ថ្នាក់ជាទិសដៅទេសចរណ៍វប្បធម៌ និងប្រវត្តិសាស្ត្រអន្តរជាតិកំពូលមួយក្នុងពិភពលោក។ ស្ថិតលើវិបត្តិ និងបញ្ហាទីផ្សារទេសចរណ៍អន្តរជាតិកាលពីមុន ទិសដៅទេសចរណ៍អន្តរជាតិនៃក្រុងសៀមរាប និងតំបន់អង្គរអាចដោះស្រាយ និងរើរួចពីភាពដុនដាបនៃចំនួនភ្ញៀវទេសចរ ក្នុងរយៈពេលដ៏ខ្លីដោយផ្អែកលើធនធានទេសចរណ៍វប្បធម៌ និងប្រវត្តិសាស្ត្រដែលមានតែមួយ។ ម្យ៉ាងវិញទៀត ការកើនឡើងនូវភ្ញៀវទេសចរក៏បានបង្កជាផលប៉ះពាល់អវិជ្ជមានចំពោះបរិស្ថានប្រវត្តិសាស្ត្រ និងបរិស្ថានសង្គមដែលទាមទារអោយមានវិធានការកាត់បន្ថយ កែលំអហេដ្ឋារចនាសម្ព័ន្ធ និងការគ្រប់គ្រងដើម្បីដោះស្រាយនូវផលប៉ះពាល់អវិជ្ជមាននេះ។

២) និន្នាការនៃការមកដល់របស់ភ្ញៀវទេសចរក្នុងស្រុក

សកម្មភាពទេសចរណ៍ក្នុងស្រុក ក្នុងក្រុងសសៀមរាប និងតំបន់អង្គរត្រូវបានចាប់ផ្តើមតាំងពីឆ្នាំ១៩៩៩។ នៅពេលនោះ រដ្ឋាភិបាលបានផ្សព្វផ្សាយ និងធ្វើអោយប្រសើរឡើងនូវទេសចរណ៍សហវត្សន៍តាមរយៈព្រឹត្តិការណ៍ជាច្រើនក្នុងក្រុងសៀមរាប។ បន្ទាប់ពីព្រឹត្តិការណ៍នោះមក ចំនួនភ្ញៀវទេសចរក្នុងស្រុកបានថយចុះពីចំនួន ២៣០ ០០០ នាក់ មកត្រឹមចំនួន ៨៤ ០០០ នាក់ ប៉ុន្តែវានៅតែច្រើនជាងឆ្នាំ១៩៩៨ ចំនួនជាង ៧ ដង។ បន្ទាប់ពីឆ្នាំ២០០០ ចំនួនភ្ញៀវទេសចរក្នុងស្រុកបានកើនឡើងជាលំដាប់រហូតដល់ឆ្នាំ២០០២ បន្ទាប់ពីឆ្នាំ២០០៣ ចំនួនភ្ញៀវទេសចរក្នុងស្រុកត្រូវបានជំរុញ និងកើនឡើងយ៉ាងគំហុក ដែលហេតុការណ៍នេះបណ្តាលមកពីការកើនឡើងនូវទីផ្សារក្នុងស្រុកផ្អែកលើការកើនឡើងចំណូលប្រចាំគ្រួសារកំរិតកណ្តាលនៃទីក្រុងធំៗក្នុងប្រទេស។

អត្រាកំណើនភ្ញៀវទេសចរក្នុងស្រុកជាមធ្យមប្រចាំឆ្នាំ គឺ៤០% ក្នុងរយៈពេល ១៥ឆ្នាំចុងក្រោយ (ឆ្នាំ១៩៩៤-ឆ្នាំ២០០៩) ១៩% ក្នុងរយៈពេល ១០ឆ្នាំចុងក្រោយ (ឆ្នាំ១៩៩៩- ឆ្នាំ២០០៩) និង ៣០% ក្នុងរយៈពេល ៥ឆ្នាំចុងក្រោយនេះ (ឆ្នាំ២០០៤- ឆ្នាំ២០០៩)។

បេតិកភណ្ឌវប្បធម៌ និងប្រវត្តិសាស្ត្រខ្មែរក្នុងខេត្តសៀមរាប និងតំបន់អង្គរត្រូវបានគេយល់ថាជាប្រភពដើម និង/ឬ ជាអត្តសញ្ញាណនៃប្រជាជន និងសង្គមកម្ពុជា។ បន្ទាប់ពីពេលនេះទៅ កំណើនសេដ្ឋកិច្ចស្តីពីស្ថេរភាពសង្គមនឹងជំរុញបន្ថែមនូវចំណូលប្រចាំគ្រួសារ និងបង្កើតអោយមានភ្ញៀវទេសចរក្នុងស្រុក។ ភាគច្រើននៃភ្ញៀវ

ទេសចរក្នុងស្រុកកំពុងទស្សនាទីកដីដើមរបស់ខ្មែរ ស្ថិតក្រោមលក្ខខណ្ឌនៃការអភិវឌ្ឍន៍ទេសចរក្នុងស្រុកក្នុងប្រទេសកម្ពុជា។

**តារាង ២.១ និន្នាការនៃការមកដល់របស់ភ្ញៀវទេសចរក្នុងស្រុក និងអន្តរជាតិមកកាន់ក្រុងសៀមរាប និងតំបន់អង្គរក្នុងរយៈពេល ១៥ឆ្នាំចុងក្រោយ**

| ឆ្នាំ | អន្តរជាតិ | អត្រាកំណើន | ក្នុងស្រុក | អត្រាកំណើន | សរុប | អត្រាកំណើន |
|---|---|---|---|---|---|---|
| ១៩៩៤ | ២៥ ២៩៤ | | - | | ២៥ ២៩៤ | |
| ១៩៩៥ | ៤៤ ៨៣៣ | ៧៧% | ១១ ៣៣៦ | - | ៥៦ ១៦៩ | ១២២% |
| ១៩៩៦ | ៥៥ ៥៦១ | ២៤% | ១១ ៧០៣ | ៣% | ៦៧ ២៦៤ | ២០% |
| ១៩៩៧ | ៣១ ៤៧២ | -៤៣% | ១១ ៩២៥ | ២% | ៤៣ ៣៩៧ | -៣៥% |
| ១៩៩៨ | ៣០ ២៥៥ | -៤% | ១១ ៥០៣ | -៤% | ៤១ ៧៥៨ | -៤% |
| ១៩៩៩ | ៨៣ ៦៤១ | ១៧៦% | ២៣០ ៣៧៨ | ១៩០៣% | ៣១៤ ០១៩ | ៦៥២% |
| ២០០០ | ១៩៤ ១៨០ | ១៣២% | ៨៣ ៩៤៨ | -៦៤% | ២៧៨ ១២៨ | -១១% |
| ២០០១ | ២៦៤ ០៥៧ | ៣៦% | ៨៩ ៩១២ | ៧% | ៣៥៣ ៩៦៩ | ២៧% |
| ២០០២ | ៤៣៨ ៣៧៤ | ៦៦% | ៩៣ ៩៤២ | ៤% | ៥៣២ ៣១៦ | ៥០% |
| ២០០៣ | ៤០២ ៦៧២ | -៨% | ១៣២ ៦៤៣ | ៤១% | ៥៣៥ ៣១៥ | ១% |
| ២០០៤ | ៥៦០ ៤៧៩ | ៣៩% | ៣៤៩ ១០៩ | ១៦៣% | ៩០៩ ៥៨៨ | ៧០% |
| ២០០៥ | ៦៨១ ៧៩៧ | ២២% | ៥០៩ ៥២០ | ៤៦% | ១ ១៩១ ៣១៧ | ៣១% |
| ២០០៦ | ៨៥៦ ១៥៧ | ២៦% | ៧៨២ ៨៩៥ | ៥៤% | ១ ៦៣៩ ០៥២ | ៣៨% |
| ២០០៧ | ១ ១០៤ ០៦៩ | ២៩% | ៨៩២ ២២៦ | ១៤% | ១ ៩៩៦ ២៩៥ | ២២% |
| ២០០៨ | ១ ០៥៩ ៨៧០ | -៤% | ១ ១៩៥ ២៦៤ | ៣៤% | ២ ២៥៥ ១៣៤ | ១៣% |
| ២០០៩ | ៩៩៨ ០៨៤ | -៦% | ១ ២៧៩ ៣៥៦ | ៧% | ២ ២៧៧ ៤៤០ | ១% |
| *១: ៩៤- | | ២៨% | | ៤០% | | ៣៥% |
| *២: ៩៩- | | ២៨% | | ១៩% | | ២២% |
| *៣:២០០៤- | | ១២% | | ៣០% | | ២០% |

*១:អត្រាកំណើនជាមធ្យមប្រចាំឆ្នាំ ១៩៩៤ ដល់ឆ្នាំ ២០០៩ *២: ១៩៩៩ ដល់ ២០០៩ *៣:២០០៤ ដល់ ២០០៩

ប្រភព: ទិន្នន័យស្ថិតិឆ្នាំ ២០០៩ មន្ទីរទេសចរណ៍ខេត្ត (ខែ មករា ឆ្នាំ ២០១០)




**រូបភាព ២.១ និន្នាការនៃការមកដល់របស់ភ្ញៀវទេសចរក្នុងស្រុក និងអន្តរជាតិមកកាន់ក្រុងសៀមរាប និងតំបន់អង្គរក្នុងរយៈពេល ១៥ឆ្នាំចុងក្រោយ**

## (២) លក្ខណៈ និងផលប៉ះពាល់នៃភ្ញៀវទេសចរអន្តរជាតិ

រយៈពេលជាមធ្យមនៃការស្នាក់នៅរបស់ភ្ញៀវទេសចរអន្តរជាតិមានចំនួន ៨ថ្ងៃ នៅក្នុងប្រទេសកម្ពុជា នៅក្នុងដំណាក់ដំបូងក្នុងឆ្នាំ ១៩៩៥។ វាបានធ្លាក់ចុះមកត្រឹម ៥.២ថ្ងៃក្នុងឆ្នាំ ១៩៩៨។ ទោះបីជាយ៉ាងណាក៏ដោយ វាត្រូវបានពន្យាពេលដល់ទៅចំនួន ៦.៦៥ថ្ងៃក្នុងឆ្នាំ ២០០៨ ដែលគេអាចនិយាយបានថា វាមិនមែនជាការស្នាក់នៅរយៈពេលខ្លីឡើយស្ថិតក្រោមលក្ខខណ្ឌនៃបំណែកខ្ពស់នៃក្រុមភ្ញៀវទេសចរ។

ចំនួនសរុបនៃចំនួនយប់នៃការស្នាក់នៅរបស់ភ្ញៀវទេសចរអន្តរជាតិក្នុងប្រទេសកម្ពុជាមានចំនួនប្រមាណ ១.៨លានក្នុងឆ្នាំ ១៩៩៥ ចំនួន ២លានក្នុងឆ្នាំ ១៩៩៩ ចំនួន៦.៦លានក្នុងឆ្នាំ ២០០៤ (ចំនួន ៣.៧ដងនៃឆ្នាំ ១៩៩៥) និងចំនួន ១៤លានក្នុងឆ្នាំ ២០០៩ (ចំនួន ៧.៨ដងនៃឆ្នាំ ១៩៩៥)។

អត្រាស្នាក់នៅនៃបន្ទប់សណ្ឋាគារក្នុងប្រទេសកម្ពុជាចាប់ផ្តើមពីចំនួន ៣៧% ក្នុងឆ្នាំ១៩៩៥។ វាគឺជាទូរលេខទាបបំផុតមួយដើម្បីអោយអាចរស់រានទៅបាន និងមានតុល្យភាពទីផ្សារ។ បន្ទាប់ពីឆ្នាំ១៩៩៧ អត្រាស្នាក់នៅនៃបន្ទប់សណ្ឋាគារត្រូវបានកើនឡើងជាលំដាប់ដល់ទៅចំនួន ៦៤%ក្នុងឆ្នាំ២០០៩ ដែលអាចនិយាយបានថាគឺជាទូរលេខសមហេតុផលមួយដើម្បីធ្វើអោយមានតុល្យភាព និងបង្កើតនូវប្រាក់ចំណេញ។ ដោយផ្អែកលើអត្រាស្នាក់នៅនៃបន្ទប់សណ្ឋាគារ ការប្រែប្រួលទៅតាមរដូវកាលនៃចំនួនភ្ញៀវទេសចរអន្តរជាតិត្រូវបានកាត់បន្ថយយ៉ាងយឺតៗ។ ក្នុងក្រុងសៀមរាប និងតំបន់អង្គរ សន្ទស្សន៍នៃចំនួនភ្ញៀវទេសចរសរុបក្នុង រយៈពេល ៤ខែកំពូលគឺមានប្រមាណជាមធ្យមចំនួន ១.២៨ ទៅ ១.៣០។ ហើយសន្ទស្សន៍នៃចំនួនភ្ញៀវទេសចរសរុបក្នុងរយៈពេល ៤ខែទាប គឺមានប្រមាណជាមធ្យម ០.៧០ ទៅ ០.៧៤ លើកលែងតែក្នុងឆ្នាំ ២០០៧ នៅក្នុងរយៈពេល ៣ឆ្នាំចុងក្រោយដែលនឹងត្រូវបង្ហាញក្នុងតារាងខាងក្រោម។

វិក្កយប័ត្រទេសចរណ៍របស់ភ្ញៀវទេសចរអន្តរជាតិត្រូវបានចាប់ផ្តើម និងរាប់ដែលមានតំលៃដល់ទៅ ១០០លានដុល្លារអាមេរិកក្នុងឆ្នាំ ១៩៩៥។ ការចំណាយជាមធ្យមរបស់ភ្ញៀវទេសចរត្រូវបានប៉ាន់ប្រមាណថាមានចំនួន ៤៥៥ដុល្លារអាមេរិកក្នុង ១នាក់/ការធ្វើដំណើរម្តង និង ៥៧ដុល្លារអាមេរិកក្នុង ១នាក់ ក្នុង ១ថ្ងៃ។ ការចំណាយជាមធ្យមរបស់ភ្ញៀវទេសចរក្នុងការធ្វើដំណើរម្តងៗ និងក្នុង ១ថ្ងៃបានប្រែប្រួល ប៉ុន្តែចំនួនសរុបនៃវិក្កយប័ត្រទេសចរណ៍បានកើនឡើង។ បន្ទាប់ពីឆ្នាំ ២០០៤ ការចំណាយរបស់ភ្ញៀវទេសចរ និងវិក្កយប័ត្រទេសចរណ៍បានកើនឡើងជាលំដាប់ដល់ចំនួន ១១២ដុល្លារអាមេរិកក្នុង ១ថ្ងៃ ៧២២ដុល្លារអាមេរិកក្នុងការធ្វើដំណើរម្តង និង១.៥៦ពាន់លានដុល្លារអាមេរិក (១៥.៦ដង ច្រើនជាងឆ្នាំ ១៩៩៥)។ ចំនួនវិក្កយប័ត្រទេសចរណ៍អាចត្រូវបានកំណត់ជាមាត្រដ្ឋានស្វ័យយ័តនៃទិសដៅទេសចរណ៍អន្តរជាតិតាមរយៈចំណូលពន្ធនៅពេលដែលវាមានលក្ខណៈជាប្រព័ន្ធ និងត្រូវបានគេប្រមូលយ៉ាងត្រឹមត្រូវ។

# តារាង ២.២ និន្នាការនៃលក្ខណៈរបស់ភ្ញៀវទេសចរអន្តរជាតិ

| ឆ្នាំ | ចំនួនភ្ញៀវទេសចរ | រយៈពេលមធ្យម នៃការស្នាក់នៅ | ចំនួនយប់ ភ្ញៀវទេសចរ | អត្រាស្នាក់នៅ បន្ទប់សណ្ឋាគារ | បន្ទប់សណ្ឋាគារ ដែលត្រូវប៉ាន់ ប្រមាណ | វិក្កតប័ត្រ ទេសចរណ៍ (គិតជាលាន ដុល្លារ) | ការចំណាយជាមធ្យមរបស់ ភ្ញៀវទេសចរ | |
|---|---|---|---|---|---|---|---|---|
| | | | | | | | ដុល្លារអាមេរិក/ ម្នាក់/ធ្វើដំណើរ | ដុល្លារអាមេរិក/ ម្នាក់/ ១ថ្ងៃ |
| ១៩៩៥ | ២១៩ ៦៨០ | ៨.០០ | ១ ៧៥៧ | ៣៧% | ៨ ០០០ | ១០០ | ៤៥៥ | ៥៧ |
| ១៩៩៦ | ២៦០ ៤៨៩ | ៧.៥០ | ១ ៩៥៤ | ៤០% | ៨ ០០០ | ១១៨ | ៤៥៣ | ៦០ |
| ១៩៩៧ | ២១៨ ៨៤៣ | ៦.៤០ | ១ ៤០១ | ៣០% | ៨ ០០០ | ១០៣ | ៤៧១ | ៧៤ |
| ១៩៩៨ | ២៨៩ ៥២៤ | ៥.២០ | ១ ៥០៦ | ៤០% | ៦ ០០០ | ១៦៦ | ៥៧៣ | ១១០ |
| ១៩៩៩ | ៣៦៧ ៧៤៣ | ៥.៥០ | ២ ០២៣ | ៤៤% | ៧ ០០០ | ១៩០ | ៥១៧ | ៩៤ |
| ២០០០ | ៤៦៦ ៣៦៥ | ៥.៥០ | ២ ៥៦៥ | ៤៥% | ៩ ០០០ | ២២៨ | ៤៨៩ | ៨៩ |
| ២០០១ | ៦០៤ ៩១៩ | ៥.៥០ | ៣ ៣២៧ | ៤៨% | ១១ ០០០ | ៣០៤ | ៥០៣ | ៩១ |
| ២០០២ | ៧៨៦ ៥២៤ | ៥.៨០ | ៤ ៥៦២ | ៥០% | ១៥ ០០០ | ៣៧៩ | ៤៨២ | ៨៣ |
| ២០០៣ | ៧០១ ០១៤ | ៥.៥០ | ៣ ៨៥៦ | ៥០% | ១២ ០០០ | ៣៤៧ | ៤៩៥ | ៩០ |
| ២០០៤ | ១ ០៥៥ ២០២ | ៦.៣០ | ៦ ៦៤៨ | ៥២% | ២១ ០០០ | ៥៧៨ | ៥៤៨ | ៨៧ |
| ២០០៥ | ១ ៤២១ ៦១៥ | ៦.៣០ | ៨ ៩៥៦ | ៥២% | ២៨ ០០០ | ៨៣២ | ៥៨៥ | ៩៣ |
| ២០០៦ | ១ ៧០០ ០៤១ | ៦.៥០ | ១១ ០៥០ | ៥៥% | ៣៣ ០០០ | ១ ០៤៩ | ៦១៧ | ៩៥ |
| ២០០៧ | ២ ០១៥ ១២៨ | ៦.៥០ | ១៣ ០៩៨ | ៥៥% | ៣៩ ០០០ | ១ ៤០០ | ៦៩៥ | ១០៧ |
| ២០០៨ | ២ ១២៥ ៤៦៥ | ៦.៦៥ | ១៤ ១៣៤ | ៦៣% | ៣៦ ០០០ | ១ ៥៩៥ | ៧៥០ | ១១៣ |
| ២០០៩ | ២ ១៦១ ៥៧៧ | ៦.៤៥ | ១៣ ៩៤២ | ៦៤% | ៣៥ ០០០ | ១ ៥៦១ | ៧២២ | ១១២ |

ប្រភព: ស្ថិតិទេសចរណ៍ របាយការណ៍ប្រចាំឆ្នាំ ២០០៩ ក្រសួងទេសចរណ៍

## តារាង ២.៣ ការប្រែប្រួលតាមខែ និងតាមរដូវរបស់ភ្ញៀវទេសចរអន្តរជាតិមកកាន់ក្រុងសៀមរាប និងតំបន់អង្គរ

| ខែ/រដូវ | ចំនួនភ្ញៀវទេសចរអន្តរជាតិតាមខែ/រដូវ | | | សន្ទស្សន៍នៃចំនួនភ្ញៀវទេសចរអន្តរជាតិតាមខែ/រដូវ | | |
|---|---|---|---|---|---|---|
| | ២០០៦ | ២០០៧ | ២០០៨ | ២០០៦ | ២០០៧ | ២០០៨ |
| មករា | ១២១ ៩៧៥ | ១៨៥ ១៦៣ | ៨៦ ២៧៩ | ១.៣៨ | ១.៩៨ | ១.២១ |
| កុម្ភៈ | ១២០ ៦៥៧ | ១១១ ៤៥៩ | ៨១ ៧៨៧ | ១.៣៧ | ១.១៩ | ១.១៥ |
| មិនា | ១១៣ ៧៥៨ | ១០៣ ១៩០ | ៧៣ ៧១៩ | ១.២៩ | ១.១១ | ១.០៣ |
| មេសា | ៩១ ១០៥ | ៨៥ ៧៦៩ | ៦៤ ៧៦៥ | ១.០៣ | ០.៩២ | ០.៩១ |
| ឧសភា | ៧២ ៤៤៧ | ៦៨ ២៩២ | ៤៥ ៥១៦ | ០.៨២ | ០.៧៣ | ០.៦៤ |
| មិថុនា | ៥៨ ៨៥២ | ៦១ ៥៧៣ | ៤៣ ២៩៤ | ០.៦៧ | ០.៦៦ | ០.៦១ |
| កក្កដា | ៦៥ ៨៩៦ | ៦២ ៩៧៦ | ៥៦ ៤២១ | ០.៧៥ | ០.៦៧ | ០.៧៩ |
| សីហា | ៧៨ ២៥៤ | ៦៩ ១៩៦ | ៧៤ ៣៦៥ | ០.៨៩ | ០.៧៤ | ១.០៤ |
| កញ្ញា | ៦៤ ៨៥៥ | ៥៦ ១៧០ | ៥៥ ៩៥៤ | ០.៧៣ | ០.៦០ | ០.៧៨ |
| តុលា | ៧៩ ២០០ | ៨៦ ៨៣៣ | ៧១ ០៨៦ | ០.៩០ | ០.៩៣ | ១.០០ |
| វិច្ឆិកា | ៩៥ ៩៨៤ | ១០៧ ៣៣០ | ៩៥ ០៥៨ | ១.០៩ | ១.១៥ | ១.៣៣ |
| ធ្នូ | ៩៦ ៨៨៧ | ១២២ ៦៣៥ | ១០៧ ៩១៣ | ១.១០ | ១.៣១ | ១.៥១ |
| សរុប | ១ ០៥៩ ៨៧០ | ១ ១២០ ៥៨៦ | ៨៥៦ ១៥៧ | | | |
| រដូវខ្ពស់ (៤ខែ) | ៤៥៣ ២៧៧ | ៥២៦ ៥៨៧ | ៣៧១ ០៣៧ | ១.២៨ | ១.៤១ | ១.៣០ |
| រដូវមធ្យម (៤ខែ) | ៣៤៤៥៤៣ | ៤៥២ ៦៥១ | ២៨៣ ៩៣៥ | ០.៩៨ | ១.២១ | ០.៩៩ |
| រដូវទាប (៤ខែ) | ២៦២០៥០ | ១៤១ ៣៤៨ | ២០១ ១៨៥ | ០.៧៤ | ០.៣៨ | ០.៧០ |

ប្រភព: ស្ថិតិទេសចរណ៍ របាយការណ៍ប្រចាំឆ្នាំ ២០០៩ ក្រសួងទេសចរណ៍

### (៣) ប្រភពភ្ញៀវទេសចរអន្តរជាតិ

តំបន់ទីផ្សារទេសចរណ៍ដ៏ធំសំរាប់ប្រទេសកម្ពុជាទាំងមូលមានប្រភពមកពីតំបន់អាស៊ីខាងកើតដែលបានចូលមកកាន់តំបន់អាស៊ីអគ្នេយ៍ផ្អែកលើទំនាក់ទំនងសេដ្ឋកិច្ចថ្មី។ ម្យ៉ាងវិញទៀត ទិសដៅទេសចរណ៍អន្តរជាតិនៃតំបន់អង្គរ និងក្រុងសៀមរាបបានរក្សានូវទីផ្សារយ៉ាងធំនៅក្នុងបណ្តាប្រទេសអាស៊ីខាងកើត ហើយក៏មានទីផ្សារផងដែរនៅក្នុងតំបន់អឺរ៉ុបខាងលិច អឺរ៉ុបខាងជើង និងអាមេរិក។ បើទោះបីជា ទិន្នន័យស្ថិតិនៃព្រលានយន្តហោះអន្តរជាតិខេត្តសៀមរាបមិនបានគ្របដណ្តប់ចំនួនភ្ញៀវទេសចរមកពីប្រទេសវៀតណាមដែលប្រើប្រាស់រថយន្តក្រុង និងមធ្យោបាយដឹកជញ្ជូនផ្លូវគោកដទៃទៀតក៏ដោយ ក៏ទីផ្សារទេសចរណ៍ក្នុងប្រទេសវៀតណាមបានកើនឡើង

យ៉ាងខ្លាំងក្នុងរយៈពេលមួយទៅពីរឆ្នាំចុងក្រោយនេះ ។

តំបន់ និងប្រទេសដែលជាទីផ្សារទេសចរណ៍ដ៏មានសក្តានុពលខ្លាំងបំផុតសំរាប់ក្រុងសៀមរាប និងតំបន់អង្គរត្រូវបានកំណត់ដូចខាងក្រោម ផ្អែកលើនិន្នាកានៃការមកដល់របស់ភ្ញៀវទេសចរ និងគោលការណ៍ណែនាំនៃការផ្លាស់ប្តូរយុទ្ធសាស្ត្រទីផ្សារ (ពីកំរិតទាប/មធ្យម អោយទៅជាកំរិតខ្ពស់) ក្នុងផែនការមេ ។

រយៈពេលខ្លី និងមធ្យម : បង្កើនទីផ្សារទេសចរណ៍កំរិតខ្ពស់ក្នុងតំបន់អ៊ឺរ៉ុបខាងលិច អ៊ឺរ៉ុបខាងជើង និងអាមេរិក ។ ប្រទេសជប៉ុន សហរដ្ឋអាមេរិក បារាំង អាល្លឺម៉ង់ អូស្ត្រាលី និងចក្រភពអង់គ្លេស ដែលជាប្រទេសដែលមានទីផ្សារទេសចរណ៍ខ្ពស់អាចនឹងជាប្រទេសសំរាប់យុទ្ធសាស្ត្រទីផ្សារ ។

រយៈពេលមធ្យម និងវែង : តំបន់អាស៊ីអគ្នេយ៍ និងអាស៊ីខាងកើត ។ ប្រទេសកូរ៉េខាងត្បូង តៃវ៉ាន់ ចិន ម៉ាឡេស៊ី ថៃ នឹងអាចជាទីផ្សារដែលមានសក្តានុពលបំផុតផ្អែកលើការអភិវឌ្ឍន៍ផ្នែកសេដ្ឋកិច្ច និងសង្គម ។

**តារាង២.៤ ចំនួនភ្ញៀវទេសចរអន្តរជាតិដែលបានមកដល់ប្រទេសកម្ពុជា និងព្រលានយន្តហោះអន្តរជាតិខេត្តសៀមរាបពីតំបន់ដើម**

| តំបន់ដើម | ២០០៨*[១] | ចំណែក(%) | ២០០៩*[២] | ចំណែក(%) | ២០០៩ SRIA | ចំណែក(%) |
|---|---|---|---|---|---|---|
| អាស៊ីអគ្នេយ៍ | ៥៥២ ៤៦១ | ២៦ | ៦៩២ ៨១៩ | ៣២ | ៥២ ៣០៣ | ៩ |
| ជប៉ុន | ១៦៣ ៨០៦ | ៨ | ១៤៦ ២៨៦ | ៧ | ១០៩ ២០៣ | ១៩ |
| កូរ៉េខាងត្បូង | ២៦៦ ៥២៥ | ១៣ | ១៩៧ ៧២៥ | ៩ | ១២០ ០២០ | ២១ |
| ចិន | ១២៩ ៦២៦ | ៦ | ១២៨ ២១០ | ៦ | ៣៣ ២៥៦ | ៦ |
| អាស៊ីខាងកើតសរុប | ៦៤៦ ៤៣២ | ៣១ | ៥៤៨ ៤២២ | ២៦ | ២៩១ ៧៩៤ | ៥១ |
| អាស៊ីខាងត្បូង | ១៥ ៤៥២ | ១ | ១៥ ៩៧៥ | ១ | ៤ ១៧៥ | ១ |
| អូសេអានី | ៩៩ ០៨៧ | ៥ | ៩៨ ៦៧៨ | ៥ | ២៣ ៨៨៥ | ៤ |
| អ៊ឺរ៉ុបខាងជើង | ១៥៣ ៣៧៦ | ៧ | ១៥៣ ៣១១ | ៧ | ៣៨ ២៥៦ | ៧ |
| អ៊ឺរ៉ុបខាងលិច | ២១៥ ២២៧ | ១០ | ២២៦ ០៥៧ | ១១ | ៧៨ ៧៦០ | ១៤ |
| អ៊ឺរ៉ុបខាងកើត | ៣០ ២១៩ | ១ | ៣៤ ៥៩៧ | ២ | ១០ ៧៩៣ | ២ |
| អ៊ឺរ៉ុបខាងត្បូង | ៤៤ ៧៩៥ | ២ | ៤០ ១៩៥ | ២ | ១៧ ៥៨២ | ៣ |
| អាមេរិក | ២០៤ ៨៧៨ | ១០ | ២០១ ១៣០ | ៩ | ៦១ ៨៥០ | ១១ |
| អាហ្វ្រិក | ៤ ០៤០ | ០ | ៥ ៤០៣ | ០ | ៨០៦ | ០ |
| មជ្ឈិមបូព៌ា | ៧ ៣៧៥ | ០ | ៦ ៩២១ | ០ | ១ ៤០១ | ០ |
| ផ្សេងៗ | ១២៤ ០៣១ | ៦ | ១១៥ ៨៤២ | ៥ | - | - |

| | | | | | | |
|---|---|---|---|---|---|---|
| សរុប | ២០៩៧៣៧៣ | ១០០ | ២១៣៩១៦០ | ១០០ | ៥៨១ ៦០៥ | ១០០ |

ចំណាំ: ២០០៨*[១] និង ២០០៩*[២] គឺជាចំនួនភ្ញៀវទេសចរអន្តរជាតិប្រចាំឆ្នាំដែលបានមកកាន់ប្រទេសកម្ពុជា ឆ្នាំ ២០០៨ និង២០០៩

២០០៩ SRIA គឺជាចំនួនភ្ញៀវទេសចរអន្តរជាតិប្រចាំឆ្នាំដែលបានមកដល់ព្រលានយន្តហោះអន្តរជាតិសៀមរាប ឆ្នាំ២០០៩

ប្រភព: ស្ថិតិផ្នែកទេសចរណ៍ របាយការណ៍ប្រចាំឆ្នាំ ២០០៩ ក្រសួងទេសចរណ៍




**រូបភាព ២.២ ចំណែកនៃចំនួនភ្ញៀវទេសចរអន្តរជាតិមកកាន់ប្រទេសកម្ពុជា និងក្រុងសៀមរាបពីតំបន់ដើម**




**រូបភាព ២.៣ ចំនួនភ្ញៀវទេសចរអន្តរជាតិដែលមកពីប្រទេសដែលមានទីផ្សារទេសចរណ៍ខ្ពស់ទាំង១០ មកកាន់ព្រលានយន្តហោះអន្តរជាតិខេត្តសៀមរាប**

## ២.១.២ ការកើនឡើងនូវចំនួនប្រជាជន

### (១) កំណើនប្រជាជនយ៉ាងឆាប់រហ័សក្នុងក្រុងសៀមរាប និងតំបន់អង្គរ

យោងទៅលើសៀវភៅស្ថិតិក្រុងសៀមរាបក្នុងរយៈពេល១១ឆ្នាំចុងក្រោយនេះ ចំនួនប្រជាជនក្នុង ១០ឃុំក្នុងក្រុងសៀមរាបបានកើនឡើងពីចំនួនប្រមាណ ៩៩ ០០០នាក់ក្នុងឆ្នាំ១៩៩៨ ដល់ចំនួន ១៩៨ ០០០នាក់ក្នុងឆ្នាំ២០០៩ ដែលជាចំនួនទ្វេរដងនៃចំនួនប្រជាជនក្នុងឆ្នាំ១៩៩៨ និងស្មើនឹង ៦.៥% នៃអត្រាកំណើនប្រចាំឆ្នាំ។ អត្រាកំណើនប្រជាជនប្រចាំឆ្នាំ ៦.៥%នៃស្រុកសៀមរាបមានចំនួនប្រមាណ ៣.៨ដងនៃអត្រាកំណើនប្រជាជនជាតិប្រចាំឆ្នាំដែលមានចំនួន ១.៧%។ ការកើនឡើងនូវចំនួនប្រជាជនយ៉ាងឆាប់រហ័សក្នុងស្រុកសៀមរាបកើតឡើងដោយប្រជាជនចំណូលស្រុកដែលស្វែងការងារក្នុងវិស័យទេសចរណ៍។

ប្រមាណជាពាក់កណ្តាលនៃចំនួនកំណើនប្រជាជនកើតឡើងក្នុងឃុំ២ គឺឃុំ ស្លក្រាម និងឃុំ ស្វាយដង្គុំដែលស្ថិតនៅកណ្តាលក្រុងសៀមរាប។ អត្រាកំណើនប្រជាជនជាមធ្យមប្រចាំឆ្នាំរបស់ឃុំទាំង ២នេះមានកំរិតខ្ពស់បំផុតដែលមានអត្រាស្មើនឹង ២៤%ក្នុងឃុំ ស្លក្រាម និងស្មើនឹង ១៧%ក្នុងឃុំ ស្វាយដង្គុំ។ ចំនួនប្រជាជនប្រមាណជា ៣៣ ០០០នាក់ បានកើនឡើងក្នុងឃុំចំនួន ៣ គឺឃុំ គោកចក (ដែលជាតំបន់១ តំបន់២ និងតំបន់កណ្តាលក្រុង) ឃុំ សាលាកំរើក (ដែលជាតំបន់កណ្តាលក្រុង) និងឃុំ សៀមរាប (ដែលជាតំបន់ជាយក្រុងនៅតាមដងស្ទឹងសៀមរាប)។ ហើយចំនួនប្រជាជនប្រមាណជា ១៧ ០០០នាក់ បានកើនឡើងក្នុងឃុំចំនួន ៥ ដែលនឹងត្រូវបង្ហាញក្នុងរូបភាពខាងក្រោម។

កំណើនប្រជាជនភាគច្រើនបានតាំងទីលំនៅនៅក្នុងតំបន់កណ្តាលក្រុង ឬតំបន់ពង្រីកក្រុង ឬតំបន់១ និងតំបន់២ នៃឧស្សានអង្គរ។ ដូចនេះ ដង់ស៊ីតេនៃចំនួនប្រជាជនក្នុងតំបន់កណ្តាលក្រុង និងជុំវិញក្រុងមានកំរិតខ្ពស់។ម្យ៉ាងវិញទៀត គំរោងអភិវឌ្ឍន៍ខុនដូ និងតំបន់តាំងទីលំនៅត្រូវបានអនុវត្តក្នុងតំបន់ជាយក្រុង និងក្នុងក្រុង។ ផ្ទះជាច្រើនត្រូវបានលក់ក្នុងតំលៃខ្ពស់ ដូច្នេះមានផ្ទះសំបែងជាច្រើនមិនត្រូវបានប្រើប្រាស់រហូតមកទល់នឹងសព្វថ្ងៃ។

ក្រុងសៀមរាបត្រូវបានកើតចេញពីស្រុកសៀមរាបដោយបន្ថែម ៣ឃុំទៀត ដូចជា ឃុំទឹកវិល (ស្ថិតនៅភាគខាងលិចនៃតំបន់១ តំបន់២ និងជាយក្រុង) ឃុំក្របីរាល (ស្ថិតនៅភាគនិរតី) និងឃុំអំពិល (ស្ថិតនៅភាគខាងកើតនៃតំបន់២)។ ចំនួនប្រជាជនក្នុងឆ្នាំ២០០៩ ក្នុងឃុំទឹកវិលមានចំនួន ១១ ១៨៣នាក់ ឃុំក្របីរាលមានចំនួន ៧ ៦៤៧នាក់ និងឃុំអំពិលមានចំនួន ៦ ៧២៧នាក់ ដែលចំនួនសរុបប្រជាជនក្នុងឃុំទាំង៣នេះមានចំនួន ២៥ ៥៥៧។ ចំនួនប្រជាជនក្នុងក្រុងសរុបទាំង១៣ ឃុំ (សង្កាត់) មានចំនួន ២២៣ ៣៧៦ ក្នុងឆ្នាំ២០០៩។




**រូបភាព ២.៤ កំណើនប្រជាជនក្នុង ១០ឃុំក្នុងស្រុកសៀមរាប**

### (២) លក្ខណៈនៃទិន្នន័យចំនួនប្រជាជន

នៅក្នុងសៀវភៅទិន្នន័យស្រុក ស្ថិតិប្រជាជនបានរាប់បញ្ចូលនូវចំនួនប្រជាជន ២ប្រភេទដូចខាងក្រោម:

ក. ចំនួនប្រជាជនដែលស្នាក់នៅជាបណ្តោះអាសន្ន និង

ខ. គ្រួសារដែលរស់នៅលើដីសាធារណៈ (ការតាំងទីលំនៅខុសច្បាប់)

ដោយមិនរាប់បញ្ចូលនូវចំនួនប្រជាជនទាំង ២ប្រភេទខាងលើ ចំនួនប្រជាជទាំង ១០ឃុំត្រូវបានប៉ាន់ប្រមាណចំនួន ១៣១ ០០០នាក់ ក្នុងឆ្នាំ២០០៦ ចំនួន ១៤៤ ០០០នាក់ ក្នុងឆ្នាំ ២០០៧ ១៤៨ ០០០នាក់ ក្នុងឆ្នាំ ២០០៨ និងចំនួន ១៧៥ ០០០នាក់ ក្នុងឆ្នាំ២០០៩។ ចំនួនប្រជាជនក្នុងក្រុងសៀមរាបដោយរាប់បញ្ចូល ៣ឃុំទៀតមានចំនួនប្រមាណ ២០០ ០០០នាក់ ក្នុងឆ្នាំ២០០៩។

**តារាង ២.៥ កំណើនប្រជាជន និងកត្តាផ្សេងៗ**

| ល.រ | ឃុំ | ១៩៩៨ | ២០០០ | ២០០២ | ២០០៤ | ២០០៦ | ២០០៧ | ២០០៨ | ២០០៩*[១] |
|---|---|---|---|---|---|---|---|---|---|
| ១ | ស្លក្រាម (ឥសាន) | ២០៧៨៧ | ២៥៤៤៥ | ២៦០៧៩ | ២៧៩១០ | ៣៤៦២៤ | ៣៥៥៩៩ | ៣៦១១៦ | ៥៣២០៩ |
| ២ | ស្វាយដង្គុំ (និរតី) | ២០៥៣៣ | ២៥១៩២ | ២៤៥០៣ | ២៦២២៥ | ២៨៦៣៤ | ៣១៦១៨ | ៣១៥៥៦ | ៣៨១៦៦ |
| ៣ | គោកចក (តំបន់ ១ តំបន់២) | ១៤៤០១ | ១៦២០១ | ១៦២២៨ | ១៨០៦៨ | ១៨៩៤០ | ២៧០៥១ | ២៧៤៤៤ | ២៧៤៤៤ |
| ៤ | សាលាកំរើក (ត្បូង/ កំពង់ផែ) | ១២៥៦៦ | ១៥១១៨ | ១៤៩៦០ | ១៧៣១៩ | ១៩១៩១ | ២២២៦១ | ២៥៣៥៨ | ២៦៩៥៤ |
| ៥ | នគរធំ (តំបន់ ១ តំបន់២) | ៣៥៥៤ | ៣៧២២ | ៤២៥៧ | ៥៣៣២ | ៥៩៤២ | ៦៥៥២ | ៦៧០២ | ៦៤០៦ |
| ៦ | ជ្រាវ (ភាគអគ្នេយ៍នៃក្រុង) | ៣៥៦៧ | ៦៣៦៥ | ៧៤០២ | ៧៧៩០ | ៩២៨៥ | ៩៤១២ | ៩៥១៦ | ១០៥៣២ |
| ៧ | ចុងឃ្នាស | ៤៦៣០ | ៤៤០៦ | ៤៦៧៨ | ៦០៥៧ | ៥៨០៣ | ៥៨២៩ | ៦០៩៣ | ៦៦៦១ |
| ៨ | សំបួរ (ខាងក្រៅភាគនិរតី) | ២៥៣២ | ២៧២៩ | ២៧៩៦ | ៣១៦០ | ៣២៩៣ | ៣៤៧៤ | ៣៥៧៥ | ៣៨០៣ |
| ៩ | សៀមរាប (កណ្តាល) | ១២១៥៨ | ១៣៦៥៧ | ១៤៣៧៤ | ១៤៨២០ | ១៦៩១៥ | ១៧១៣១ | ១៧៥៦៤ | ១៨០៤៩ |

| | | | | | | | | | |
|---|---|---|---|---|---|---|---|---|---|
| ១០ | ស្រង៉ែ (ខាងក្រៅភាគនិរតី) | ៤៩៣១ | ៤៧៩៨ | ៤៨២២ | ៥១៦៥ | ៦៩០១ | ៦៣៩២ | ៦៤៨៥ | ៦៥៩៥ |
| ស្រុកសៀមរាប (១០ឃុំ) | | ៩៩២៥៩ | ១១៧៥៩៣ | ១២០០៩៩ | ១៣១៨៤៦ | ១៤៩៥២៨ | ១៦៥៣១៩ | ១៧០៤០៩ | ១៩៧៨១៩ |
| | អត្រាកំណើនប្រចាំឆ្នាំ | | ១៨% | ២% | ១០% | ១៣% | ១១% | ៣% | ១៦% |
| A | ការរស់នៅបណ្តោះអាសន្ន | - | - | - | - | ៨១៦៩ | ៦៧២៣ | ៨០៨០ | (៨០៨០) |
| B | គ្រួសារដែលតាំងទីលំនៅខុសច្បាប់ | - | - | - | - | ១៨១៣ | ២៥០១ | ២៥៥៥ | (២៥៥៥) |
| C | ចំនួនប្រជាជនដែលតាំងទីលំនៅខុសច្បាប់ | - | - | - | - | ១០២៩៨ | ១៤២០៦ | ១៤៥១២ | (១៤៥១២) |
| ចំនួនប្រជាជនដែលមិនរាប់បញ្ចូលនូវអ្នកដែលតាំងទីលំនៅបណ្តោះអាសន្ន/ខុសច្បាប់ | | - | - | - | - | ១៣១០៦១ | ១៤៤៣៩០ | ១៤៧៨១៧ | ១៧៥២២៧ |
| | អត្រាកំណើនប្រចាំឆ្នាំ | | | | | | ១០% | ២% | ១៩% |
| ១១ | ទឹកវិល (ថ្មី: តំបន់ ១ តំបន់២) | - | - | - | - | - | - | - | ១១១៨៣ |
| ១២ | ក្របីរាល (ថ្មី: ភាគនិរតី) | - | - | - | - | - | - | - | ៧៦៤៧ |
| ១៣ | អំពិល (ថ្មី: ភាគខាងកើត) | - | - | - | - | - | - | - | ៦៧២៧ |
| ក្រុងដែលមាន ១៣ឃុំ | | - | - | - | - | - | - | - | ២០០៧៨៤ |

២០០៩*[១]: ទិន្នន័យត្រូវបានផ្តល់ជូនដោយក្រុងសៀមរាប ប៉ុន្តែពុំមានទិន្នន័យអ្នកតាំងទីលំនៅបណ្តោះអាសន្ន/ខុសច្បាប់ទេ (ជាបណ្តោះអាសន្ន យើងបានប្រើប្រាស់ទូរលេខឆ្នាំ ២០០៨)។

ប្រភព: សៀវភៅស្ថិតិស្រុក ឆ្នាំ ២០០៩ (ទិន្នន័យបានគ្របដណ្តប់ពីឆ្នាំ១៩៩៨ ដល់ឆ្នាំ ២០០៨)

## ២.១.៣ ទិសដៅសេដ្ឋកិច្ចសង្គមដែលពាក់ព័ន្ធ

ទិសដៅសេដ្ឋកិច្ចសង្គមដែលត្រូវបានកំណត់ឡើងសំរាប់ការអភិវឌ្ឍន៍ស្រុក/ក្រុងសៀមរាប ដោយផែនការមេក្នុងឆ្នាំ២០០៦ ផែនការប្រើប្រាស់ដីធ្លីឆ្នាំ២០០៧ ដោយDED និងគំរោងពង្រីកការផ្គត់ផ្គង់ទឹកក្នុងក្រុងសៀមរាប ដោយ JICA (ស្ថិតក្នុងដំណើរការក្នុងពេលបច្ចុប្បន្ននេះ)។

ផែនការគ្រប់ជ្រុងជ្រោយនៃសេដ្ឋកិច្ចសង្គមត្រូវបានបង្កើតឡើងដោយផែនការមេ ផែនការប្រើប្រាស់ដីធ្លីរបស់ DED បានធ្វើបច្ចុប្បន្នភាពទិន្នន័យស្ថិតិនៃឆ្នាំគោលរបស់ខ្លួន គឺឆ្នាំ ២០០៦ ហើយបន្ទាប់មកទៀតបានធ្វើគំរោងចំនួនប្រជាជនផ្អែកលើសេណារីយ៉ូនៃផែនការមេ។ គំរោងទើបបង្កើតថ្មីរបស់ JICA ស្តីពីការពង្រីកការផ្គត់ផ្គង់ទឹកក៏បានកំពុងធ្វើបច្ចុប្បន្នភាពនូវទូរលេខឆ្នាំគោលនៃការមកដល់របស់ភ្ញៀវទេសចរ និងចំនួនប្រជាជនដែលត្រូវបានប៉ាន់ប្រមាណដោយសេណារីយ៉ូអភិវឌ្ឍន៍របស់ខ្លួន។

ខាងក្រោមនេះ គឺជាទំរង់នៃទិសដៅសេដ្ឋកិច្ចសង្គម និងសេណារីយ៉ូនៃផែនការទាំង ៣ខាងលើ។

### (១) ផែនការមេរួមសំរាប់ការអភិវឌ្ឍន៍ដោយនិរន្តរភាពក្រុងសៀមរាប (ផែនការមេ)

ដោយផ្អែកលើគោលការណ៍និរន្តរភាពបរិស្ថាន និងសេដ្ឋកិច្ច សេណារីយ៉ូអភិវឌ្ឍន៍ ២ត្រូវបានបង្កើតឡើងដូចខាងក្រោម:

សេណារីយ៉ូ កៈ ការប៉ាន់ប្រមាណនូវទំនោរកំណើន ដោយរក្សាទំនោរកំណើននៃទីផ្សារកំរិតទាប/ មធ្យម ជាមួយការបំរែបំរួលនៃចំនួនភ្ញៀវទេសចរ។

សេណារីយ៉ូ ខៈ ការកែសំរួលនូវការប៉ាន់ប្រមាណកំណើន ការកែប្រែទៅកាន់ទីផ្សារកំរិតខ្ពស់នៅក្នុងពិភពលោក និងការធ្លាក់ចុះនៃអត្រាកំណើន ជាមួយនឹងសមត្ថភាពនៃព្រលានយន្តហោះដែលមានស្រាប់ ការមកដល់របស់ភ្ញៀវទេសចរមកក្នុងគោលដៅទេសចរណ៍បែបវប្បធម៌ និងប្រវត្តិសាស្ត្រក្នុងបណ្តាប្រទេសអាស៊ីអគ្នេយ៍បានធ្វើអោយកើនឡើងនូវវិក្កយប័ត្រចំនួនភ្ញៀវទេសចរ។

១) ការប៉ាន់ប្រមាណចំនួនភ្ញៀវទេសចរ

សេណារីយ៉ូ កៈ ការប៉ាន់ប្រមាណនូវទំនោរកំណើន អត្រាកំណើននៃភ្ញៀវទេសចរជាតិ និងអន្តរជាតិត្រូវបានកំណត់ក្នុងការវិភាគទំនោរកំណើនកាលពីមុន។ អត្រាកំណើននៃភ្ញៀវទេសចរអន្តរជាតិត្រូវបានកំណត់ចំនួន ១៤.៩% ក្នុង១ឆ្នាំ ចាប់ពីឆ្នាំ២០០៤ ដល់ឆ្នាំ២០១២ ចំនួន ៨.៧% ចាប់ពីឆ្នាំ២០១២ ដល់ឆ្នាំ២០២០ និងចំនួន ១១.៨% ចាប់ពីឆ្នាំ២០០៤ ដល់ឆ្នាំ២០២០។ អត្រាកំណើននៃភ្ញៀវទេសចរជាតិត្រូវបានកំណត់ចំនួន ៩.៥% ក្នុង ១ឆ្នាំ ចាប់ពីឆ្នាំ២០០៤ ដល់ឆ្នាំ២០១២ ចំនួន ៦.១% ចាប់ពីឆ្នាំ២០១២ ដល់ឆ្នាំ២០២០ និងចំនួន ៧.៨% ចាប់ពីឆ្នាំ២០០៤ ដល់ឆ្នាំ២០២០។

សេណារីយ៉ូ ខៈ ការកែសំរួលនូវការប៉ាន់ប្រមាណកំណើន អត្រាកំណើននៃភ្ញៀវទេសចរជាតិ និងអន្តរជាតិត្រូវបានកំណត់ដូចលក្ខខណ្ឌខាងលើ។ អត្រាកំណើននៃភ្ញៀវទេសចរអន្តរជាតិត្រូវបានកំណត់ចំនួន ១៤.៤% ក្នុង ១ឆ្នាំ ចាប់ពីឆ្នាំ២០០៤ ដល់ឆ្នាំ២០១២ ចំនួន ២.៥% ចាប់ពីឆ្នាំ២០១២ ដល់ឆ្នាំ២០២០ និងចំនួន ៨.៣% ចាប់ពីឆ្នាំ២០០៤ ដល់ឆ្នាំ២០២០។ អត្រាកំណើននៃភ្ញៀវទេសចរជាតិត្រូវបានកំណត់ចំនួន ៨.៥% ក្នុង ១ឆ្នាំ ចាប់ពីឆ្នាំ២០០៤ ដល់ឆ្នាំ២០១២ ចំនួន ៤.២% ចាប់ពីឆ្នាំ២០១២ ដល់ឆ្នាំ២០២០ និងចំនួន ៦.៣% ចាប់ពី ឆ្នាំ២០០៤ ដល់ឆ្នាំ២០២០។

អត្រាកំណើន និងចំនួនភ្ញៀវទេសចរនៃសេណារីយ៉ូ ក និងសេណារីយ៉ូ ខ មិនមានការខុសគ្នាច្រើនទេ គិតត្រឹមឆ្នាំ ២០១២។ ទោះបីយ៉ាងនេះក្តី អត្រាកំណើន និងចំនួនភ្ញៀវទេសចរនៃសេណារីយ៉ូទាំង២ មានការខុសគ្នាដូចខាងក្រោម ចាប់ពីឆ្នាំ២០១២ ដល់ឆ្នាំ២០២០។ ជាចុងក្រោយសេណារីយ៉ូ ខៈ ការកែសំរួលនូវការប៉ាន់ប្រមាណកំណើនត្រូវបានជ្រើសរើសដើម្បីបង្កើតផែនការមេ។

## តារាង ២.៦ ការប៉ាន់ប្រមាណ (ទិសដៅ) ចំនួនភ្ញៀវទេសចរក្នុងផែនការមេ

| | ឆ្នាំគោល ២០០៤ | សេណារីយ៉ូ ក: ការប៉ាន់ប្រមាណទូរទំនោរកំណើន | | សេណារីយ៉ូ ខ: ការកែសំរួលទូវការប៉ាន់ប្រមាណកំណើន | |
|---|---|---|---|---|---|
| | | ២០១២ | ២០២០ | ២០១២ | ២០២០ |
| អន្តរជាតិ (000) | ៥៦១ | ១ ៧០៩ | ៣ ៣៤៣ | ១ ៦៤៨ | ២ ០០៧ |
| ប្រចាំឆ្នាំ | | ១៤.៩% | ៨.៧% (១១.៨%) | ១៤.៤% | ២.៥% (៨.៣%) |
| ជាតិ (000) | ២៩៧ | ៦១៤ | ៩៨៨ | ៥៧២ | ៧៩៥ |
| ប្រចាំឆ្នា | | ៩.៥% | ៦.១% (៧.៨%) | ៨.៥% | ៤.២% (៦.៣%) |
| សរុប (000) | ៨៥៨ | ២ ៣២៤ | ៤ ៣៣១ | ២ ២២០ | ២ ៨០២ |
| ប្រចាំឆ្នាំ | | ១៣.៣% | ៨.១% (១០.៦%) | ១២.៦% | ៣.០% (៧.៧%) |

ចំណាំ: ចំនួនប្រជាជនឆ្នាំ ២០២០ ( ): អត្រាកំណើនជាមធ្យមប្រចាំឆ្នាំចាប់ពីឆ្នាំ ២០០៤ ដល់ឆ្នាំ ២០២០។

ប្រភព: ផែនការមេរួមសំរាប់ការអភិវឌ្ឍន៍ដោយនិរន្តរភាពក្រុងសៀមរាប ឆ្នាំ ២០០៦

២) ការប៉ាន់ប្រមាណចំនួនប្រជាជន

ទិន្នន័យស្ថិតិនៃចំនួនប្រជាជន ចំនួន ១៥៥ 000ក្នុងស្រុកសៀមរាបក្នុងឆ្នាំ២០០៤ ត្រូវបានចែកចេញជាអ្នកស្នាក់នៅចំនួន ១៣៩ 000នាក់ (៩0%) និងអ្នកដំណើរដែលបំរើការក្នុងស្រុកសៀមរាបចំនួន ១៦ 000នាក់ (១0%)។ ការប៉ាន់ប្រមាណចំនួនអ្នកស្នាក់នៅ (ទិសដៅ)សំរាប់ស្រុកសៀមរាបត្រូវបានកំណត់ចំនួន ១៧១ 000 នាក់ ក្នុងឆ្នាំ២០១២ និងចំនួន ២១១ 000នាក់ ក្នុងឆ្នាំ២០២០ ផ្អែកលើគោលការណ៍ក្នុងការបង្កើតក្រុងរណប។ កំណើនប្រជាជនបន្ថែមដែលបានកើនឡើងដោយសេណារីយ៉ូអភិវឌ្ឍន៏ត្រូវបានចាត់ទុកថា ជាអ្នកដំណើរមកពីស្រុកក្រៅដែលបំរើការក្នុងស្រុកសៀមរាប និងតំបន់អង្គរ។ ទិសដៅអ្នកតាំងទីលំនៅក្នុងស្រុកសៀមរាបត្រូវបានកំណត់ថាមានកំណើនថេរ ចំនួន ២.៦% ប្រចាំឆ្នាំ ចាប់ពីឆ្នាំ២០០៤ ដល់ឆ្នាំ២០២០។ ទិសដៅអ្នកដំណើរសំរាប់ស្រុកសៀមរាបត្រូវបានកំណត់ ចំនួន៣ ទៅ ៥ដងនៃអត្រាកំណើនអ្នកតាំងទីលំនៅដូចខាងក្រោម។

កំណើនប្រជាជនសរុបក្នុងស្រុកសៀមរាបត្រូវបានប៉ាន់ប្រមាណចាប់ពីចំនួន ១៥៥ 000នាក់ ទៅចំនួន ២៧៦ 000នាក់ក្នុងឆ្នាំ២០០៤ (សេណារីយ៉ូ ខ) និងចំនួន ៣១១ 000នាក់ (សេណារីយ៉ូ ក)ក្នុងឆ្នាំ២០២០។ អត្រាកំណើនប៉ាន់ស្មានជាមធ្យមប្រចាំឆ្នាំ មានចំនួន ៤.៤៥% និង ៣.៦៧% នៃសេណារីយ៉ូទាំង២ ត្រូវបានកំណត់អោយទាបជាងអត្រាកំណើនប្រជាជនក្នុងក្រុងនៃប្រទេសកម្ពុជាពីឆ្នាំ២០០៥ ដល់ឆ្នាំ ២០១០ (កម្មវិធីអភិវឌ្ឍន៏របស់អង្គការសហប្រជាជាតិ)។

## តារាង ២.៧ ការប៉ាន់ប្រមាណចំនួនប្រជាជន (ទិសដៅ) នៃផែនការមេ

| | ឆ្នាំគោល ២០០៤ | សេណារីយ៉ូ ក: ការប៉ាន់ប្រមាណនូវទំនោរកំណើន | | សេណារីយ៉ូ ខ: ការកែសំរួលនូវការប៉ាន់ប្រមាណកំណើន | |
|---|---|---|---|---|---|
| | | ២០១២ | ២០២០ | ២០១២ | ២០២០ |
| អ្នកតាំងទីលំនៅ (000) | ១៣៩ | ១៧១ | ២១១ | ១៧១ | ២១១ |
| ប្រចាំឆ្នាំ | | ២.៦២% | ២.៦៦%(២.៦៤%) | ២.៦២% | ២.៦៦%(២.៦៤%) |
| អ្នកដំណើរ (000) | ១៦ | ៤៤ | ១០០ | ៣៩ | ៦៥ |
| ប្រចាំឆ្នាំ | | ១៣.៤៨% | ១០.៨១%(១២.១៤%) | ១១.៧៨% | ៦.៥៩%(៩.១៦%) |
| សរុប (000) | ១៥៥ | ២១៥ | ៣១១ | ២១០ | ២៧៦ |
| ប្រចាំឆ្នាំ | | ៤.១៧% | ៤.៧២% (៤.៤៥%) | ៣.៨៧% | ៣.៤៨%(៣.៦៧%) |

ប្រភព: ការសិក្សាផែនការមេ

### (២) ផែនការប្រើប្រាស់ដីធ្លីសំរាប់ស្រុកសៀមរាប ( DED )

ការសិក្សាផែនការសំរាប់ស្រុកសៀមរាបនេះត្រូវបានធ្វើឡើងជាគំរោងមួយក្នុងចំណោមគំរោងសាកល្បងចំនួន២នៃគំរោងរបស់ ASia Urbs ដែលផ្តោតលើការផ្សព្វផ្សាយវិមជ្ឈការ និងពង្រឹងអាជ្ញាធរស្រុកក្រោមសេចក្តីសំរេចរបស់រាជរដ្ឋភិបាលលេខ ៤៧។ ការសិក្សានេះត្រូវបានធ្វើឡើងជា ២រយៈពេល គឺពីឆ្នាំ២០០១ ដល់ឆ្នាំ២០០៤ និងពីឆ្នាំ២០០៤ ដល់ឆ្នាំ២០០៧ ដោយក្រុមផែនការមេស្រុកនៃស្រុកសៀមរាបដែលឧបត្ថម្ភដោយសេវាអភិវឌ្ឍន៍របស់អាល្លឺម៉ង់ ( DED ), មូលនិធិ Konrad Adenauer, Asia Urbs គំរោងទី៣ ( AUP3) និងក្រសួង២ គឺក្រសួងមហាផ្ទៃ និងក្រសួងរៀបចំដែនដី នគររូបនីយកម្ម និងសំណង់ក្នុងប្រទេសកម្ពុជា។

តំបន់ និងឆ្នាំគោលដៅ គឺ ១០ឃុំ និងឆ្នាំ២០២០ដូចផែនការមេ។ ទិន្នន័យចំនួនប្រជាជនឆ្នាំគោលត្រូវបានធ្វើបច្ចុប្បន្នភាពក្នុងឆ្នាំ២០០៦ ដោយទិន្នន័យស្ថិតិបន្ទាប់ពីការបង្កើតផែនការមេ។ ទិសដៅក៏ត្រូវបានកំណត់ដោយសេណារីយ៉ូ៣ផ្អែកលើផែនការមេដូចខាងក្រោម:

## តារាង ២.៨ ទិសដៅនៃផែនការប្រើប្រាស់ដីធ្លីសំរាប់ស្រុកសៀមរាប

| និន្នាការនៃកំណើនប្រជាជនក្នុងស្រុកសៀមរាប ពីឆ្នាំ១៩៩៨ ដល់ឆ្នាំ២០០៥ | | | ការប៉ាន់ប្រមាណចំនួនប្រជាជនឆ្នាំ២០២០ក្នុងស្រុកសៀមរាប ដោយសេណារីយ៉ូ | | |
|---|---|---|---|---|---|
| ចំនួនប្រជាជន ក្នុងឆ្នាំ១៩៩៨ | ចំនួនប្រជាជន ក្នុងឆ្នាំ២០០៦ | អត្រាកំណើន ប្រចាំឆ្នាំ | សេណារីយ៉ូ១: (២០០៦- ២០២០: ៣%) | សេណារីយ៉ូ២: (២០០៦- ២០១១: ៤%) (២០១២- ២០២០: ៣%) | សេណារីយ៉ូ៣: (២០០៦- ២០១១: ៤%) (២០១២- ២០២០: ៣.៥%) |
| ៩៩ ២៥៩ | ១៤៦ ៣៧៩ | ៥% | ២២១ ៤០០ | ២៣០ ១០០ | ២៤១ ៦០០ |

ប្រភព: ផែនការប្រើប្រាស់ដីធ្លីព្រាងចុងក្រោយសំរាប់ស្រុកសៀមរាប ថ្ងៃទី ០១ ខែតុលា ឆ្នាំ ២០០៧

## (៣) ការផ្គត់ផ្គង់ទឹក

ការសិក្សាត្រៀមមួយស្តីពីគំរោងពង្រីកការផ្គត់ផ្គង់ទឹកក្នុងក្រុងសៀមរាបកំពុងបន្តការងារ ដោយមានការចុះហត្ថលេខានៅថ្ងៃទី២៩ ខែ មករា ឆ្នាំ២០០៩ រវាងក្រសួងឧស្សាហកម្ម រ៉ែ និងថាមពល ភាគីខាងអាជ្ញាធររដ្ឋាករទឹកក្រុងសៀមរាប និងទីភ្នាក់ងារសហប្រតិបត្តិការអន្តរជាតិនៃប្រទេសជប៉ុន (JICA)។ ការសិក្សានេះបានចាប់ផ្តើមនៅខែ ឧសភា ឆ្នាំ២០០៩ និងត្រូវបញ្ចប់ត្រឹមពាក់កណ្តាលខែ កញ្ញា ឆ្នាំ២០១០។

គោលបំណងនៃការសិក្សានេះមានដូចខាងក្រោមៈ

- ដើម្បីជ្រើសរើសប្រភពទឹកថ្មីសំរាប់ប្រព័ន្ធផ្គត់ផ្គង់ទឹកប្រកបដោយប្រសិទ្ធិភាព និងនិរន្តរភាព
- ដើម្បីចុះធ្វើការស្ទាបស្ទង់អណ្តូងដែលមានស្រាប់ និងវាយតំលៃពីទិន្នផលសក្តានុពលនៃទឹកក្រោមដី
- ដើម្បីកំណត់គំរោងពង្រីកការផ្គត់ផ្គង់ទឹកជាបន្ទាន់មួយដើម្បីបំពេញនូវតំរូវការទឹកប៉ាន់ស្មានមួយសំរាប់ក្រុងសៀមរាបរហូតដល់ឆ្នាំគោលដៅដែលបានជ្រើសរើសក្នុងគំរោង
- ដើម្បីធ្វើការសិក្សាពីភាពអាចធ្វើទៅបានមួយសំរាប់គំរោងពង្រីកការផ្គត់ផ្គង់ទឹកដែលបានស្នើឡើងដើម្បីបង្ហាញថាគំរោងចាំបាច់ត្រូវអនុវត្តក្រោមហិរញ្ញទាននៃប្រាក់កំចី ODA របស់ប្រទេសជប៉ុន
- ដើម្បីបង្កើតផែនការអភិវឌ្ឍន៏ការផ្គត់ផ្គង់ទឹករយៈពេលវែងដល់ឆ្នាំ២០៣០ និង
- ដើម្បីបន្តផ្ទេរបច្ចេកវិទ្យាដល់សមភាគីកម្ពុជាក្នុងកំឡុងពេលនៃការសិក្សា។

តំបន់គោលដៅមិនត្រឹមតែគ្របដណ្តប់ក្រុងសៀមរាបដែលទើបបង្កើតថ្មី (១២ឃុំ ដោយមិនរាប់បញ្ចូលឃុំចុងឃ្នាស) ប៉ុណ្ណោះទេ ប៉ុន្តែវាបានគ្របដណ្តប់ឃុំនៅជាប់គ្នានោះមួយទៀតគឺឃុំ (កណ្តែក) ស្ថិតនៅភាគអគ្នេយ៏ដែលភាគខាងលិចនៃឃុំនេះត្រូវបានស្នើអោយទៅជាតំបន់ក្រុងទៅថ្ងៃអនាគតលើកលែងតំបន់១ និងតំបន់២នៃស្រុកបាគងនៃផែនការមេ។ ឆ្នាំ និងតំបន់គោលដៅត្រូវបានកំណត់មានចំនួន ១៣ឃុំ និងឆ្នាំ២០៣០ ផ្តើមចេញពីទស្សនៈតំបន់ផ្គត់ផ្គង់ទឹកនៅថ្ងៃអនាគត និងទស្សនៈវិស័យអភិវឌ្ឍន៏រយៈពេលវែងរបស់អាជ្ញាធររដ្ឋាករទឹកក្រុងសៀមរាប។

ទិសដៅនៃចំនួនប្រជាជនត្រូវបានកំណត់អោយសមស្របទៅនឹងការវិភាគខ្សែកោងអ៊ិចប៉ូណង់ស្យែលជាមួយនឹងទិន្នន័យដែលបានធ្វើបច្ចុប្បន្នភាពក្នុងឆ្នាំ២០០៩ ដូចបង្ហាញខាងក្រោមៈ

**តារាង ២.៩ ការប៉ាន់ស្មានចំនួនប្រជាជន (ទិសដៅ) នៃការផ្គត់ផ្គង់ទឹក**

| | ឆ្នាំ ២០១០ | ២០១៥ | ២០២០ | ២០២៥ | ២០៣០ |
|---|---|---|---|---|---|
| ចំនួនប្រជាជនដែលត្រូវបានប៉ាន់ប្រមាណ | ២០៥ | ២៤៤ | ២៨៣ | ៣២២ | ៣៦២ |
| អត្រាកំណើន | | ២០១១-២០១៥<br>៣.៨២% ដល់ ៣.៣៣% | ២០១៦-២០២០<br>៣.២៣% ដល់ ២.៨៦% | ២០២១-២០២៥<br>២.៧៩% ដល់ ២.៥១% | ២០២៦-២០៣០<br>២.៤៥% ដល់ ២.២៤% |

ប្រភព: របាយការណ៍ព្រាងចុងក្រោយនៃការសិក្សាត្រៀមស្តីពីគំរោងពង្រីកការផ្គត់ផ្គង់ទឹកឆ្នាំ ២០១០

ការប៉ាន់ស្មានចំនួនភ្ញៀវទេសចរ (ទិសដៅ) ត្រូវបានកំណត់ ដោយផ្អែកលើសេណារីយ៉ូ៣ ដែលមានអត្រាកំណើន ២% ៣% និង៤%ក្នុង១ឆ្នាំផ្អែកលើទំនោរកំណើនក្នុងតំបន់កាលពីមុន និងចំនួនភ្ញៀវទេសចរនៃទិសដៅទេសចរណ៍បែបវប្បធម៌ និងប្រវត្តិសាស្ត្រក្នុងបណ្តាប្រទេសអាស៊ីអគ្នេយ៍ដូចខាងក្រោម:

**តារាង ២.១០ ការប៉ាន់ស្មានចំនួនភ្ញៀវទេសចរ (ទិសដៅ) នៃការផ្គត់ផ្គង់ទឹក**

| ឆ្នាំ | ២០១០ | ២០១៥ | ២០២០ | ២០២៥ | ២០៣០ |
|---|---|---|---|---|---|
| សេណារីយ៉ូ ១ | កំណើន ២% | | | | |
| ចំនួនភ្ញៀវទេសចរដែលបានប៉ាន់ស្មាន | ២ ៣០០ | ២ ៥៣៩ | ២ ៨០៣ | ៣ ០៩៥ | ៣ ៤១៨ |
| អត្រាសំរាប់ឆ្នាំ ២០០៨* | ១.០២ | ១.១២ | ១.២៤ | ១.៣៧ | ១.៥១ |
| សេណារីយ៉ូ ២ | កំណើន ៣% | | | | |
| ចំនួនភ្ញៀវទេសចរដែលបានប៉ាន់ស្មាន | ២ ៣២២ | ២ ៦៩២ | ៣ ១២១ | ៣ ៦១៨ | ៤ ១៩៥ |
| អត្រាសំរាប់ឆ្នាំ ២០០៨ | ១.០៣ | ១.១៩ | ១.៣៨ | ១.៦០ | ១.៨៦ |
| សេណារីយ៉ូ ៣ | កំណើន ៤% | | | | |
| ចំនួនភ្ញៀវទេសចរដែលបានប៉ាន់ស្មាន | ២ ៣៤៥ | ២ ៨៥៣ | ៣ ៤៧១ | ៤ ២២៣ | ៥ ១៣៨ |
| អត្រាសំរាប់ឆ្នាំ ២០០៨ | ១.០៤ | ១.២៦ | ១.៥៣ | ១.៨៧ | ២.២៧ |

ប្រភព: របាយការណ៍ព្រាងចុងក្រោយនៃការសិក្សាត្រៀមស្តីពីគំរោងពង្រីកការផ្គត់ផ្គង់ទឹកឆ្នាំ ២០១០

**តារាង ២.១១ តំបន់គោលដៅនៃការផ្គត់ផ្គង់ទឹក**

| | ២០១៥ | ២០២០ | ២០២៥ | ២០៣០ |
|---|---|---|---|---|
| សំរាប់អ្នកតាំងទីលំនៅ | ៥៥% | ៨០% | ៨៥% | ៩០% |
| សំរាប់ភ្ញៀវទេសចរ | ៥៥% | ៨០% | ១០០% | ១០០% |

ប្រភព: របាយការណ៍ព្រាងចុងក្រោយនៃការសិក្សាត្រៀមស្តីពីគំរោងពង្រីកការផ្គត់ផ្គង់ទឹកឆ្នាំ ២០១០

## ២.១.៤ សេណារីយ៉ូនាពេលអនាគតនៃទិសដៅសេដ្ឋកិច្ចសង្គម

វាមានរយៈពេល ៤ឆ្នាំហើយចាប់តាំងពីផែនការមេត្រូវបានបង្កើតក្នុងឆ្នាំ២០០៦។ ផ្នែកនៃទិសដៅ

សេដ្ឋកិច្ចសង្គមដែលត្រូវបានជ្រើសរើសនៃ "សេណារីយ៉ូ ខ: ការកែសំរួលការប៉ាន់ប្រមាណកំណើន" ចាំបាច់ត្រូវធ្វើការកែសំរួល និងតំរូវទៅតាមនិន្នាការនៃការអភិវឌ្ឍន៍សេដ្ឋកិច្ចសង្គម និងការផ្លាស់ប្តូរប្រព័ន្ធរដ្ឋបាលដែលបានប្រែក្លាយចេញពីស្រុកទៅជាក្រុង និងតំបន់គ្របដណ្តប់របស់វាក្នុងរយៈពេល ៤ឆ្នាំចុងក្រោយនេះ។

ការប៉ាន់ស្មាន និងទិសដៅនៃចំនួនភ្ញៀវទេសចរអន្តរជាតិដែលបានចូលមកក្នុងតំបន់នៅតែមានសារៈប្រយោជន៍ និងប្រសិទ្ធិភាពក្រោមការប្រែប្រួលស្ថានភាពកាលពីមុន និងគោលការណ៍សំរាប់ការអភិវឌ្ឍន៍ទីផ្សារកេរ្តិ៍ខ្ពស់អន្តរជាតិ។ ទោះបីជាយ៉ាងណាក៏ដោយ ទិសដៅ និងការប៉ាន់ស្មានចំនួនភ្ញៀវទេសចរក្នុងស្រុកមានភាពខុសគ្នា ដែលទាមទារអោយមានការត្រួតពិនិត្យឡើងវិញផ្អែកលើសេណារីយ៉ូអភិវឌ្ឍន៍មួយ។ ទិសដៅ និងការប៉ាន់ស្មាននៃចំនួនប្រជាជនត្រូវបានកែសំរួលចំពោះតំបន់ក្រុងសៀមរាបដែលទើបបង្កើតថ្មី (ពីស្រុកដែលមាន ១០ឃុំ ទៅកាន់ក្រុងដែលមាន ១៣ សង្កាត់)។

**(១) ការត្រួតពិនិត្យឡើងវិញនៃទិសដៅទេសចរណ៍អន្តរជាតិ: ចំនួន ១.៦៥លាននាក់ ក្នុងឆ្នាំ២០១២ និង ២លាននាក់ ក្នុងឆ្នាំ២០២០**

ទិសដៅនៃចំនួនភ្ញៀវទេសចរអន្តរជាតិក្នុងឆ្នាំ២០១២ក្នុងផែនការមេត្រូវបានកំណត់ចំនួនប្រមាណជា ១.៦៥លាននាក់ ស្មើនឹង១៤.៤% ដែលជាអត្រាកំណើនខ្ពស់ប្រចាំឆ្នាំ។ ដោយផ្អែកលើអត្រាកំណើននេះ ចំនួនភ្ញៀវទេសចរអន្តរជាតិអាចត្រូវបានគេប៉ាន់ប្រមាណចំនួន ១.២៦លាននាក់ក្នុងឆ្នាំ២០១០។

យោងទៅតាមស្ថិតិវិស័យទេសចរណ៍ ចំនួនភ្ញៀវទេសចរអន្តរជាតិមកកាន់តំបន់សៀមរាប និងអង្គរមានចំនួន ១.១លាននាក់ក្នុងឆ្នាំ ២០០៧។ និន្នាការនៃកំណើនបន្ទាប់ពីឆ្នាំ២០០៤ បានកើនឡើងយ៉ាងលឿនមកទល់នឹងឆ្នាំ ២០០៧។ ដោយឡែក វិបត្តិសេដ្ឋកិច្ចពិភពលោកបន្ទាប់ពីឆ្នាំ២០០៨ បានជះឥទ្ធិពលយ៉ាងអាក្រក់ និងបានកាត់បន្ថយនូវទីផ្សារទេសចរណ៍ពិភពលោក ហើយវាក៏បានជះឥទ្ធិពល និងបង្អាក់នូវចំនួនភ្ញៀវទេសចរអន្តរជាតិមកកាន់តំបន់មកត្រឹម ១.៦លាននាក់ក្នុងឆ្នាំ២០០៨ និង ១លាននាក់ក្នុងឆ្នាំ២០០៩។ ទោះបីយ៉ាងនេះក្តី នៅចុងឆ្នាំ ២០០៩ និងដើមឆ្នាំ២០១០ ផលប៉ះពាល់នៃវិបត្តិសេដ្ឋកិច្ចពិភពលោកមកលើចំនួនភ្ញៀវទេសចរអន្តរជាតិមកកាន់តំបន់ត្រូវបានដោះស្រាយ និងបានវិលមកកាន់ចំនួនដូចមុនពេលមានវិបត្តិសេដ្ឋកិច្ចវិញហើយ។

ស្ថិតក្រោមកាលៈទេសៈនេះ សេណារីយ៉ូ ខៈការកែសំរួលការប៉ាន់ប្រមាណចំនួនភ្ញៀវទេសចរអន្តរជាតិអាចត្រូវបានវាយតំលៃថា នៅតែជាទិសដៅអភិវឌ្ឍន៍ដ៏មានតំលៃ។ និន្នាការនៃចំនួនភ្ញៀវទេសចរអន្តរជាតិស្តីពីកំណើនយ៉ាងឆាប់រហ័សកាលពីមុន និងវិបត្តិសេដ្ឋកិច្ច នៅតែស្ថិតនៅជាមួយសេណារីយ៉ូខ នៃផែនការមេឆ្នាំ២០០៦។ ដូច្នេះការកំណត់ទិសដៅចំនួនភ្ញៀវទេសចរអន្តរជាតិចំនួន ១.៦លាននាក់ក្នុងឆ្នាំ២០១២ និង ២លាននាក់ក្នុងឆ្នាំ២០២០ ត្រូវបានរក្សាក្រោមលក្ខខណ្ឌដែលមានយុទ្ធសាស្ត្រផ្សព្វផ្សាយយ៉ាងសកម្មចំពោះទីផ្សារកេរ្តិ៍ខ្ពស់ក្នុងពិភពលោក។




**រូបភាព ២.៥ ការប្រៀបធៀបនៃនិន្នាការកាលពីមុន និងទិសដៅនៃចំនួនភ្ញៀវទេសចរ អន្តរជាតិមកកាន់តំបន់សៀមរាប និងអង្គរ**

### (២) ការប៉ាន់ស្មាន (ទិសដៅ) នៃចំនួនភ្ញៀវទេសចរក្នុងស្រុក: ចំនួន ១.៦២លាននាក់ក្នុងឆ្នាំ២០១២ និង ២.៣៤ លាននាក់ក្នុងឆ្នាំ ២០២០

និន្នាការនៃការអភិវឌ្ឍន៍សេដ្ឋកិច្ចក្នុងប្រទេសកម្ពុជា ជាពិសេសក្នុងតំបន់ក្រុងសំខាន់ៗ បានបង្កើតចំណូលជូនប្រជាជនដែលមានជីវភាពកំរិតកណ្តាល ហើយស្ថានភាពបែបនេះបានបង្កើតអោយមានទីផ្សារទេសចរក្នុងស្រុកយ៉ាងឆាប់រហ័ស។ ភ្ញៀវទេសចរក្នុងស្រុកភាគច្រើនត្រូវបានផ្តោតលើតំបន់អង្គរ និងក្រុងសៀមរាប (ទិន្នន័យទេសចរមិនបានគ្របដណ្តប់ដល់ចំនួនភ្ញៀវទេសដែលទៅទស្សនាក្រុងភ្នំពេញ និងក្រុងសំខាន់ៗដទៃផ្សេងទៀតទេ)។ និន្នាការនៃចំនួនភ្ញៀវទេសចរក្នុងស្រុកមកកាន់តំបន់សៀមរាប និងអង្គរបានកើនឡើងយ៉ាងឆាប់រហ័សក្នុងកំរិត ៣០% ប្រចាំឆ្នាំក្នុងឆ្នាំ២០០៤ ហើយបានឈានដល់ប្រមាណ ១.២៨លាននាក់ក្នុងឆ្នាំ២០០៩ ដែលមានចំនួន ១លាននាក់ លើសចំនួនភ្ញៀវទេសចរអន្តរជាតិក្នុងឆ្នាំ២០០៩ និងមានចំនួន ០.៨លាននាក់ លើសទិសដៅចំនួនភ្ញៀវទេសចរក្នុងស្រុកក្នុងឆ្នាំ២០២០។ ទីផ្សារទេសចរណ៍ក្នុងស្រុកត្រូវបានផ្សព្វផ្សាយតាមរយៈកម្មវិធី ព្រឹត្តិការណ៍ផ្សេងៗ ដែលបានរៀបចំឡើងដោយរដ្ឋាភិបាល។ ហើយវាមិនត្រឹមតែបានចូលរួមចំណែកដល់ការអភិវឌ្ឍន៍សេដ្ឋកិច្ចប៉ុណ្ណោះទេ ប៉ុន្តែវាក៏បានពង្រឹងនូវការរួបរួមនៃសង្គមខ្មែរផងដែរ។ ទេសចរណ៍អង្គរត្រូវបានផ្សព្វផ្សាយសំរាប់ទីផ្សារទេសចរណ៍ក្នុងស្រុក ដែលគឺជា "ការទស្សនាទីតាំងនៃវប្បធម៌ខ្មែរ " និងទេសចរណ៍បែបសាសនាអាចនឹងបន្តរីកចំរើន និងឈានដល់កំរិតខ្ពស់មួយ។ ស្ថិតក្រោមលក្ខខណ្ឌបែបនេះ ការប៉ាន់ស្មាននូវចំនួនភ្ញៀវទេសចរក្នុងស្រុកទាមទារអោយមានការត្រួតពិនិត្យឡើងវិញសំរាប់ការអភិវឌ្ឍន៍ទេសចរណ៍ទៅថ្ងៃអនាគត

ក្នុងក្រុងសៀមរាប និង តំបន់អង្គរ ។




**រូបភាព ២.៦ ការប្រៀបធៀបនៃនិន្នាការកាលពីមុន និងទិសដៅក្នុងផែនការមេនៃចំនួន ភ្ញៀវទេសចរក្នុងស្រុកមកកាន់តំបន់សៀមរាប និងអង្គរ**

ស្ថិតក្នុងកាលៈទេសៈបែបនេះ ទីផ្សារទេសចរណ៍ក្នុងស្រុកនៃប្រទេសកម្ពុជាត្រូវបានគេយល់ឃើញថាស្ថិតក្នុងដំណាក់កាលចាប់ផ្តើមនៃការកើនឡើងខ្ពស់នៅឡើយ ។ ចំនួនភ្ញៀវទេសចរក្នុងស្រុកមកកាន់តំបន់អង្គរ និងក្រុងសៀមរាបបានបន្តកើនឡើងដល់អត្រា ៧% ប្រចាំឆ្នាំក្នុងឆ្នាំ២០០៩ បើទោះបីថា កំណើនផលិតផលជាតិសរុបក្នុងមនុស្សម្នាក់មិនមានការកើនឡើងក្នុងឆ្នាំ២០០៩ ក៏ដោយ ។ ការប៉ាន់ស្មានចំនួនភ្ញៀវទេសចរក្នុងស្រុកមកកាន់តំបន់អង្គរ និងក្រុងសៀមរាបអាចត្រូវបានកំណត់ផ្អែកលើចំនួនប្រជាជនក្នុងក្រុងនៅពេលអនាគត និងចំណូលក្នុងមនុស្សម្នាក់ៗក្នុងប្រទេសកម្ពុជា ។

១) ស្ថានភាពសេដ្ឋកិច្ចក្នុងពេលអនាគតក្នុងប្រទេសកម្ពុជា

ផ្អែកលើការព្យាករណ៍នៃកំណើនផលិតផលជាតិសរុបដែលបានរៀបចំដោយធនាគារពិភពលោក ធនាគារអភិវឌ្ឍន៍អាស៊ី និងអង្គការអន្តរជាតិផ្សេងៗទៀត កំណើនផលិតផលជាតិសរុបក្នុងប្រទេសកម្ពុជានឹងត្រូវប្រសើរឡើងវិញក្នុងឆ្នាំ២០១០ និងឈានដល់អត្រាកំណើនប្រមាណជា ៧% ក្នុងឆ្នាំ២០១១ ។ ផលិតផលជាតិសរុបក្នុងមនុស្សម្នាក់ក្នុងប្រទេសកម្ពុជា និងចំណូលក្នុងមនុស្សម្នាក់ៗដែលមានជីវភាពមធ្យមក្នុងក្រុងនឹងត្រូវប្រសើរឡើងវិញហើយបន្តដើរតាមលំនាំនិន្នាការកំណើនដូចមុនពេលមានវិបត្តិសេដ្ឋកិច្ច ។

២) ចំនួនប្រជាជនក្នុងក្រុងក្នុងពេលអនាគតក្នុងប្រទេសកម្ពុជា

អត្រានៃចំនួនប្រជាជនក្នុងក្រុងមានប្រមាណជា ២០% (ត្រូវនឹងចំនួនប្រមាណជា ២.៨លាននាក់នៃចំនួនប្រជាជនទូទាំងប្រទេស ១៤.២លាននាក់) ក្នុងឆ្នាំ២០០៩។ អត្រាកំណើនប្រជាជនក្នុងក្រុងត្រូវបានប៉ាន់ប្រមាណជា ៤.៦% ប្រចាំឆ្នាំ (ត្រូវនឹង១.៧៦៥% នៃចំនួនសរុបទូទាំងប្រទេស) ចាប់ពីឆ្នាំ២០០៥ ដល់ឆ្នាំ២០១០ ដោយធនាគារ និងអង្គការអន្តរជាតិ។ ចំនួនប្រជាជនក្នុងក្រុងក្នុងថ្ងៃអនាគតត្រូវបានប៉ាន់ប្រមាណជា ៣.២លាននាក់ក្នុងឆ្នាំ ២០១២ និង ៤.៦លាននាក់ក្នុងឆ្នាំ២០២០ផ្អែកលើអត្រាកំណើនខាងលើ។ ទោះបីជាយ៉ាងណាក៏ដោយ ចំនួនប្រជាជន ៤.៦លាននាក់ក្នុងឆ្នាំ២០២០ត្រូវនឹងអត្រា ២៦.៥%ដែលអាចនិយាយបានថាមានការកើនឡើងយ៉ាងឆាប់រហ័ស។ ការប៉ាន់ស្មាននូវចំនួនភ្ញៀវទេសចរក្នុងស្រុកមកកាន់តំបន់អង្គរ និងក្រុងសៀមរាបត្រូវបានកំណត់ផ្អែកលើសេណារីយ៉ូអភិវឌ្ឍន៍ខ្ពស់ និងមធ្យមដែលត្រូវបានប៉ាន់ស្មានជា ២ករណីនៃអត្រាចំនួនប្រជាជនក្នុងក្រុងនៃ ៤.៦% និង ៣.៨% សំរាប់រយៈពេលពីឆ្នាំ២០១២ ដល់ឆ្នាំ ២០២០។

ចំនួនភ្ញៀវទេសចរក្នុងស្រុកចំនួន ១.៣លាននាក់ក្នុងឆ្នាំ២០០៩ បានកើនលើសទិសដៅចំនួនភ្ញៀវទេសចរក្នុងស្រុកចំនួន ០.៩៩លាននាក់ក្នុងសេណារីយ៉ូ ក និងចំនួន ០.៨លាននាក់ក្នុង សេណារីយ៉ូ ខ ក្នុងឆ្នាំ២០២០ ក្នុងផែនការមេ។ ដូចនេះ គេបានស្នើអោយមានការត្រួតពិនិត្យឡើងវិញចំពោះភ្ញៀវទេសចរក្នុងស្រុកចំនួន ២.៧លាននាក់ ក្នុងកំណើនសេណារីយ៉ូខ្ពស់ និង ២.៥លាននាក់ក្នុងកំណើនសេណារីយ៉ូមធ្យម។

**តារាង ២.១២ ការប៉ាន់ស្មានចំនួនភ្ញៀវទេសចរក្នុងស្រុកមកកាន់តំបន់អង្គរ និងក្រុងសៀមរាប**

| | ២០០៩ | ២០១២ | ២០២០ | |
|---|---|---|---|---|
| | | | សេណារីយ៉ូខ្ពស់ | សេណារីយ៉ូមធ្យម |
| ចំនួនប្រជាជនទូទាំងប្រទេស (គិតជាលាននាក់) | ១៤.២ | ១៥.០ | ១៧.៣ | ១៧.៣ |
| ចំនួនប្រជាជនក្នុងក្រុង (គិតជាលាននាក់) | ២.៨ | ៣.២ | ៤.៦ | ៤.៣ |
| អត្រាចំនួនប្រជាជនក្នុងក្រុង | ១៩.៦% | ២១.៤% | ២៦.៥% | ២៥% |
| អត្រាកំណើនចំនួនប្រជាជនក្នុងក្រុងក្នុង ១ឆ្នាំ | ៤.៦% | ៤.៦% | ៤.៦% | ៣.៨% |
| ចំនួនភ្ញៀវទេសចរក្នុងស្រុកក្នុងប្រទេសកម្ពុជា (ក្រុងសៀមរាប) | (១.៣) | ១.៨ | ៤.២ | ៣.៩ |
| អត្រាការធ្វើដំណើររបស់ប្រជាជនក្នុងក្រុង | ៤៦.៤% | ៥៦.៨% | ៩០.៥% | ៩០.៥% |
| អត្រាកំណើនផលិតផលជាតិសរុបក្នុង ១ឆ្នាំ | | ៧% | ៦% | ៦% |
| ចំនួនភ្ញៀវទេសចរក្នុងស្រុកក្នុងក្រុងសៀមរាប (គិតជាលាននាក់) | ១.៣ | ១.៦២ | ២.៧ | ២.៥ |
| ចំណែកនៃចំនួនភ្ញៀវទេសចរក្នុងស្រុកក្នុងក្រុងសៀមរាប | (១០០%) | (៩០%) | (៦៥%) | (៦៥%% |
| អត្រាកំណើនប៉ាន់ស្មាននៃចំនួនភ្ញៀវទេសចរក្នុងស្រុក | | ៧.៦% | ៦.៦% | ៥.៥% |

ប្រភព: ការសិក្សាតាមដាន

**(៣) ការប៉ាន់ស្មាន (ទិសដៅ) ចំនួនប្រជាជនៈ ១៨៩ ០០០នាក់ ក្នុងឆ្នាំ២០១២ និង ២២៣ ០០០ ក្នុងឆ្នាំ២០២០**

បន្ទាប់ពីមានការបង្កើតនូវផែនការមេ កំណើនចំនួនប្រជាជនរបស់ស្រុកបានដើរតាមលំនាំនៃទិសដៅរបស់ផែនការមេនៃកំណើនសេណារីយ៉ូ ខ គឺរិតមធ្យម រហូតដល់ឆ្នាំ២០០៨។ ទោះបីជាយ៉ាងណាក៏ដោយ ចំនួនប្រជាជនប្រមាណ ២៧ ០០០នាក់ (១៩%) បានកើនឡើងក្នុងឆ្នាំ២០០៩ដែលអាចជាការកើនឡើងតាមបែបធម្មជាតិដោយកត្តាសង្គម និងប្រជាជនចំណូលមកពីស្រុកក្រៅ។ ប៉ុន្តែចំនួនប្រជាជនសរុបដោយមិនរាប់បញ្ចូលអ្នកស្នាក់នៅបណ្តោះអាសន្ន និងអ្នកដែលរស់នៅខុសច្បាប់លើដីសាធារណៈមានចំនួនប្រមាណ ១៧៥ ០០០នាក់ ដែលចំនួននេះពុំសូវមានការខុសគ្នាទៅនឹងចំនួនក្នុងទិសដៅនៃសេណារីយ៉ូ ខ ក្នុងឆ្នាំ២០១២ ដែលមានចំនួន ១៧១ ០០០នាក់នោះទេ។ ទិសដៅគោលនយោបាយនៃទស្សនៈ " ទីក្រុងរណប " នៅតែមានសុពលភាពដដែលស្ថិតក្រោមស្ថានភាពអភិវឌ្ឍន៍ក្រុងជាបណ្តើរៗដែលមានស្រាប់។




**រូបភាព ២.៧ ការប្រៀបធៀបនិន្នាការកាលពីមុន និងទិសដៅនៃចំនួនប្រជាជនក្នុង ១០ឃុំ នៃតំបន់ស្រុកសៀមរាប**

ទោះបីជាយ៉ាងណាក៏ដោយ តំបន់គ្របដណ្តប់នៃទិសដៅត្រូវបានផ្លាស់ប្តូរពីចំនួន១០ឃុំ ក្នុងស្រុកសៀមរាបទៅជាចំនួន១៣ឃុំ ក្នុងក្រុងសៀមរាបដែលទើបបង្កើតក្នុងឆ្នាំ២០០៨។ ដូចច្នេះ ចំនួនប្រជាជនក្នុង ៣ឃុំថ្មីនេះត្រូវបានបន្ថែមទៅក្នុងទិសដៅស្រុកនៃផែនការមេ។អ្នកតាំងទីលំនៅខុសច្បាប់លើដីសាធារណៈនឹងត្រូវមានផែនការប្តូរទីតាំងទៅកាន់ភូមិរន្ធតាឯក ដែលនៅក្រៅឧទ្យានអង្គរ និងក្រៅតំបន់ក្រុង ដែលគំរោងនេះត្រូវបានដំណើរការដោយរដ្ឋបាលខេត្ត និងអាជ្ញាធរអប្សរា។

ចំនួនប្រជាជនក្នុងថ្ងៃអនាគតដែលត្រូវបានប៉ាន់ស្មានក្នុងក្រុងសៀមរាប (ដែលមាន១៣ឃុំ) រួមមានអ្នកតាំងទីលំនៅ និងអ្នកស្នាក់នៅបណ្តោះអាសន្ន (អ្នកដំណើរមកពីស្រុកនៅជុំវិញក្រុង)។ ការប៉ាន់ស្មានអំពីចំនួន

អ្នកតាំងទីលំនៅ អ្នកដំណើរ និងចំនួនសរុបត្រូវបានកំណត់ជាបន្តបន្ទាប់គ្នា ចំនួន ១៨៩ ០០០នាក់ ១១ ០០០នាក់ និង ២០០ ០០០នាក់ ក្នុងឆ្នាំ២០១២ និងចំនួន ២៣៣ ០០០នាក់ ១៨ ០០០នាក់ និង ២៥១ ០០០នាក់ ក្នុងឆ្នាំ ២០២០។

**តារាង ២.១៣ ទិសដៅចំនួនប្រជាជនដែលត្រូវបានត្រួតពិនិត្យឡើងវិញ**

| | ២០០៩ ឆ្នាំគោល | ២០១២ | ២០២០ |
|---|---|---|---|
| ១. អ្នកតាំងទីលំនៅ (០០០) ក្នុងស្រុកៈ សេណារីយ៉ូ ខ នៃផែនការមេ | ១៥៨ (២.៦២%) | ១៧១ (២.៦២%) | ២១១(២.៦២%) |
| ២. អ្នកដំណើរ (០០០) ក្នុងស្រុកៈ សេណារីយ៉ូ ខ នៃផែនការមេ | ២៨ (១១.៨%) | ៣៩ (១១.៨%) | ៦៥ (៦.៥៩%) |
| ៣. ចំនួនសរុប (០០០)ក្នុងស្រុកៈ សេណារីយ៉ូ ខ នៃផែនការមេ | ១៨៦ (៣.៧%) | ២១០ (៣.៧%) | ២៧៦(៣.៤៨%) |
| ៤. អ្នកតាំងទីលំនៅ (០០០) ក្នុងក្រុង | ១៧៥ | ១៨៩ | ២៣៣ |
| ៥. អ្នកស្នាក់នៅបណ្តោះអាសន្ន (អ្នកដំណើរ) ក្នុងក្រុង | ៨ | ១១ | ១៨ |
| ៦. ចំនួនសរុបក្នុងក្រុង | ១៨៣ | ២០០ | ២៥១ |
| ៧. ការតាំងទីលំនៅឡើងវិញនៃអ្នករស់នៅខុសច្បាប់ (គំរោងភូមិរន្ធតាឯក) | ១៤.៥ | | |

ប្រភពៈ ការសិក្សាតាមដាន

## (៤) ទិសដៅសេដ្ឋកិច្ចសង្គមដែលត្រូវបានត្រួតពិនិត្យឡើងវិញ

ផ្អែកលើការប៉ាន់ស្មានខាងលើ ទិសដៅសេដ្ឋកិច្ចសង្គមនៃផែនការមេត្រូវបានស្នើអោយមានការកែសំរួលនូវចំនួនភ្ញៀវទេសចរអន្តរជាតិ ចំនួនភ្ញៀវទេសចរជាតិ និងចំនួនប្រជាជនក្នុងឆ្នាំ២០១២ និងឆ្នាំ២០២០ ដូចខាងក្រោម

ទិសដៅនៃចំនួនភ្ញៀវទេសចរអន្តរជាតិមិនចាំបាច់អោយមានការកែសំរួលទេ។ យុទ្ធសាស្រ្តទីផ្សាររបស់ផែនការមេក្នុងការផ្សព្វផ្សាយទីផ្សារកំរិតខ្ពស់នៅក្នុងពិភពលោកត្រូវបានស្នើអោយបន្ត និងអនុវត្តអោយបានត្រឹមត្រូវដើម្បីជំរុញ និងបង្កើនភ្ញៀវទេសចរ។

ទិសដៅនៃចំនួនភ្ញៀវទេសចរជាតិត្រូវបានស្នើអោយមានការកែប្រែពីចំនួនប្រមាណ ០.៨លាននាក់ ក្នុងផែនការមេអោយទៅជាចំនួន ២.៥លាននាក់ (ប្រមាណ ៣ដង) ក្នុងឆ្នាំ២០២០។ វិស័យទេសចរណ៍ក្នុងស្រុកដែលត្រូវបានផ្សព្វផ្សាយដោយរដ្ឋាភិបាល មិនត្រឹមតែបានផ្តល់ដល់ការអភិវឌ្ឍន៍សេដ្ឋកិច្ចជាតិប៉ុណ្ណោះទេ ប៉ុន្តែវាក៏បានផ្តោតលើការពង្រឹងនូវការរួបរួមសង្គម និងវប្បធម៌ខ្មែរ។ វាត្រូវបានស្នើអោយបន្តទៀត។

ទិសដៅចំនួនប្រជាជនស្រុកសៀមរាបក្នុងផែនការមេចាំបាច់ត្រូវមានការកែសំរួល និងតំរូវ ចំពោះដែនកំណត់ឃុំទាំង១៣ នៃក្រុងសៀមរាបដែលទើបបង្កើតថ្មីៗ។ ប្រជាជនចំនួន ៤០ ០០០នាក់ ក្នុងឃុំ៣ បន្ថែម ក្នុងឆ្នាំ២០២០ត្រូវបាន ស្នើអោយបន្ថែមទៅលើចំនួន ២១១ ០០០នាក់ នៃទិសដៅចំនួនប្រជាជនក្នុងផែនការមេ។ ទិសដៅចំនួនប្រជាជនក្នុងក្រុងសៀមរាបត្រូវបានស្នើឡើងចំនួន ២៥១ ០០០នាក់ក្នុងឆ្នាំ២០២០។ ចំនួនអ្នកដំណើរ

ដែលមកក្នុងក្រុងសៀមរាបពីស្រុកដែលនៅក្បែរ អ្នកស្នាក់នៅបណ្តោះអាសន្ន អ្នកតាំងទីលំនៅខុសច្បាប់លើដីសាធារណៈមិនត្រូវបានរាប់បញ្ចូលទេ ដែលនេះបានដើរតាមលំនាំនៃទិសដៅដែលបានកំណត់នៅក្នុងផែនការមេក្នុងឆ្នាំ២០០៦។

កម្មសិទ្ធនៃទិសដៅសេដ្ឋកិច្ចសង្គមដែលបានកែសំរួលត្រូវជារបស់រដ្ឋបាលខេត្ត។ វាចាំបាច់ត្រូវមានការធ្វើបច្ចុប្បន្នភាព កែសំរួល និងប្រើប្រាស់យ៉ាងប្រុងប្រយ័ត្នបំផុតដោយរដ្ឋបាលខេត្ត និងមន្ទីរអង្គភាពពាក់ព័ន្ធដទៃទៀត។

**តារាង ២.១៤ ទិសដៅសេដ្ឋកិច្ចសង្គមដែលត្រូវបានកែសំរួល**

| | | ២០០៩ | ២០១២ | ២០២០ |
|---|---|---|---|---|
| ទិសដៅផែនការមេ | ភ្ញៀវទេសចរអន្តរជាតិ | | ១ ៦៤៨ ០០០ | ២ ០០៧ ០០០ |
| | ភ្ញៀវទេសចរជាតិ | | ៥៧២ ០០០ | ៧៩៥ ០០០ |
| | ចំនួនប្រជាជន (១០ឃុំ) | | ១៧១ ០០០ | ២១១ ០០០ |
| ទិសដៅដែលបានកែសំរួល | ភ្ញៀវទេសចរអន្តរជាតិ | ៩៥៨ ០០០ | ១ ៦៥០ ០០០ | ២ ០០០ ០០០ |
| | ភ្ញៀវទេសចរជាតិ | ១ ៣០០ ០០០ | ១ ៦២០ ០០០ | ២ ៥០០ ០០០ |
| | ចំនួនប្រជាជន (១៣ឃុំ) | ១៨៣ ០០០ | ២០០ ០០០ | ២៥១ ០០០ |

ប្រភព: ការសិក្សាផែនការមេ និងការសិក្សាតាមដាន

# ២.២ ការផ្លាស់ប្តូរ និង និន្នាការនៃរចនាសម្ព័ន្ធ និងតំបន់ទីក្រុង

## ២.២.១ និន្នាការនៃការអភិវឌ្ឍន៍ទីក្រុង

### (១) ភាពកកកុញ និងតំបន់ទីក្រុងដែលមានការពង្រីកតិចតួច

រូបភាពខាងក្រោម បង្ហាញពីការប្រៀបធៀបនៃបណ្តាអគារ/រចនាសម្ព័ន្ធ រវាងខែមករា ឆ្នាំ ២០០៥ និងខែតុលា ឆ្នាំ ២០០៨ នៅក្នុងផែនទីប្រព័ន្ធព័ត៌មានភូមិសាស្រ្ត (GIS) ។ ផែនទីប្រព័ន្ធព័ត៌មានភូមិសាស្រ្តនេះ ត្រូវបានរៀបចំដោយការសិក្សាផែនការមេ នៅដើមឆ្នាំ ២០០៥ ។ នៅដើមឆ្នាំ ២០០៨ ផែនទីនេះ ត្រូវបានបន្តរៀបចំតាមរយៈការសិក្សាតាមដាន ដោយប្រើប្រាស់រូបភាពផ្កាយរណបដែលត្រូវបានថតក្នុងឆ្នាំ ២០០៨ ។ តំបន់ដែលបានធ្វើនគរូបនីយកម្មក្នុងឆ្នាំ ២០០៥ ដែលជាតំបន់កកកុញ ត្រូវបានពង្រីកជាចំបងនៅតាមបណ្តោយផ្លូវជាតិលេខ ៦ និងនៅក្នុង និងជុំវិញតំបន់ពាណិជ្ជកម្មកណ្តាល (CBD) ដែលជាចំណុចកណ្តាលនៃទីក្រុង ។ អាគារ/រចនាសម្ព័ន្ធថ្មីៗដែលត្រូវសាងសង់បន្ទាប់ពីឆ្នាំ ២០០៥ រហូតដល់ឆ្នាំ ២០០៨ គឺស្ថិតនៅត្រង់ជាយនៃតំបន់កកកុញនោះនៅដើមឆ្នាំ ២០០៥ ។ អាគារ/រចនាសម្ព័ន្ធថ្មីៗជាច្រើន គឺស្ថិតនៅខាងក្នុងផ្លូវក្រវ៉ាត់ក្រុង និងភាគខាងជើងនៃផ្លូវជាតិលេខ ៦ ។ ដូចនេះ គេពិបាកនឹងមើលឃើញថាមានការពង្រីក/ការរីករាលដាលគួរអោយកត់សម្គាល់ណាមួយនៃតំបន់ទីក្រុង។




**រូបភាព ២.៨ ការប្រៀបធៀបនៃបណ្តុំអាគារ/រចនាសម្ព័ន្ធ រវាងឆ្នាំ ២០០៥ និង ២០០៨**

**(២) ការអភិវឌ្ឍន៍ទ្រង់ទ្រាយធំ**

ទោះបីជាមិនមានការពង្រីក/ការរីករាលដាលគួរអោយកត់សម្គាល់ណាមួយនៃតំបន់ទីក្រុងក៏ដោយ ក៏មានការអភិវឌ្ឍទ្រង់ទ្រាយធំមួយចំនួននៅក្នុង និងជិតក្រុងសៀមរាបដែរ ។ តារាងខាងក្រោម បង្ហាញពីស្ថានភាពគម្រោងសម្រាប់ការអភិវឌ្ឍន៍ទ្រង់ទ្រាយធំ ដែលផ្តល់ដោយមន្ទីររៀបចំដែនដី នគរូបនីយកម្ម និងសំណង់ ។

**តារាង ២.១៥ ស្ថានភាពគំរោងសំរាប់ការអភិវឌ្ឍន៍ទ្រង់ទ្រាយធំ**

| ល.រ | ឈ្មោះគម្រោង | ផ្ទៃក្រឡា (ហិចតា) | ទីតាំង | | | ផែនការអភិវឌ្ឍន៍ | | |
|---|---|---|---|---|---|---|---|---|
| | | | ក្រុង | ឃុំ/ សង្កាត់ | ភូមិ | ឆ្នាំគោលដៅបញ្ចប់គម្រោង | ចំនួនប្រជាជនដែលមានស្រាប់ | អគារសំខាន់ៗ |
| ១ | បុរីប្រិមប្រិយ | ៤ | សៀមរាប | គោកចក | ត្រពាំងសេះ | ២០០៩ | ២៩៥ គ្រួសារ | ទីផ្សា សាលារៀន ផ្ទះ |
| ២ | បុរីសុខលាភ | ១៧ | សៀមរាប | សណ្តែក | គោកដូន | ២០១០ | | ហាងលក់ដូរ ផ្ទះ |
| ៣ | បុរីអង្គរ | ៥ | សៀមរាប | ស្វាយដង្គំ | គ្រួស | ២០១០ | | ហាងលក់ដូរ ផ្ទះ |
| | បុរីណាហ្គារា | ៥.៣ | សៀមរាប | ស្វាយដង្គំ | សាលាកន្សែង | ២០១០- | ៥០០ គ្រួសារ | ហាងលក់ដូរ ផ្ទះ |

| | | | | | | | | |
|---|---|---|---|---|---|---|---|---|
| ៤ | | | | | | ២០១១ | | |
| ៥ | បុរីសៀងណាំ | ៥២ | សៀមរាប | ជ្រាវ | ភូមិខ្វារ | ២០០៨-២០១០ | | សាកលវិទ្យាល័យ ទីផ្សា សណ្ឋាគារ ផ្ទះសំណាក់ |
| ៦ | លានវាយកូនហ្គោល (ខារ៉ាអូខេ និងសណ្ឋាគារ) | ២០០ | ប្រាសាទបាគង | បាគង | លលៃ | ២០១០ | សមាជិក ៣០ ក្រុម | ម៉ូតែល រមនីយដ្ឋាន សណ្ឋាគារ ភោជនីយដ្ឋាន |
| ៧ | លានវាយកូនហ្គោល (ភូគាត្រា) | ១៥០ | ពួក | ល្វា | ដូនទ្រ | ២០០៩ | ២៥ ក្រុម | រមនីយដ្ឋាន ភោជនីយដ្ឋាន |
| ៨ | លានវាយកូនហ្គោល (អង្គរហ្វូលីដេ) | ១៧០ | សៀមរាប | ស្រង៉ែ | រការ | ២០០៩ | ៣០ ក្រុម | រមនីយដ្ឋាន ភោជនីយដ្ឋាន |

សម្គាល់: សណ្ឋាគារ មជ្ឈមណ្ឌលលក់ដូរ រោងចក្រ សាកលវិទ្យាល័យ មន្ទីរពេទ្យ សួនឧទ្យាន ។ល។
ប្រភព: មន្ទីររៀបចំដែនដី នគរូនីយកម្ម និងសំណង់

ក្រៅពីការអភិវឌ្ឍន៍ខាងលើ មានការអភិវឌ្ឍន៍សាលាខេត្តថ្មី។ រដ្ឋបាល និងបណ្តាមន្ទីរថ្នាក់ខេត្ត ត្រូវបានផ្លាស់ប្តូរទីតាំងក្នុងឆ្នាំ ២០១០ ទៅទីតាំងថ្មីដែលស្ថិតក្នុងសង្កាត់អំពិល និងក្នុងតំបន់អប្សរា II ផងដែរ ។ ផ្លូវប្រើប្រាស់ដែលចាប់ពីផ្លូវជាតិលេខ ៦ ដល់សាលាខេត្តថ្មី គឺស្ថិតនៅក្នុងតំបន់អប្សរា ១ និង ៣ ។

## (៣) សម្ភារៈបរិក្ខារសម្រាប់សេវាទេសចរណ៍

១) ការអភិវឌ្ឍន៍កន្លែងស្នាក់អាស្រ័យទេសចរណ៍

បន្ទាប់ពីការសិក្សាផែនការមេ សណ្ឋាគារ និងផ្ទះសំណាក់ បានបន្តអភិវឌ្ឍន៍យ៉ាងឆាប់រហ័ស ។ សណ្ឋាគារប្រហែល៣០កន្លែង ដែលប្រមាណជាមួយភាគបួននៃសណ្ឋាគារចំនួន ១២០កន្លែងដែលមានស្រាប់ ត្រូវបានអភិវឌ្ឍន៍ថ្មី ជាចំបងនៅតាមបណ្តោយផ្លូវជាតិលេខ ៦ និងតំបន់ ៣ រវាងតំបន់កណ្តាលក្រុង និងឧទ្យានអង្គរ ។ ផ្ទះសំណាក់ប្រហែល ៥៥កន្លែង ដែលប្រមាណជាមួយភាគបួននៃផ្ទះសំណាក់ចំនួន ២២៧កន្លែង ត្រូវបានអភិវឌ្ឍន៍ថ្មី និងប្រមូលផ្តុំក្នុងតំបន់ជាយនៃតំបន់ពាណិជ្ជកម្មកណ្តាលក្នុងតំបន់កណ្តាលក្រុង ។

ក្នុងកាលៈទេសៈមួយចំនួន តំបន់លំនៅដ្ឋានក្នុងតំបន់កណ្តាលក្រុង កំពុងផ្លាស់ប្តូរយ៉ាងឆាប់រហ័សទៅជាតំបន់ទេសចរណ៍ និងតំបន់ប្រើប្រាស់លំនៅដ្ឋានចម្រុះ ដែលត្រូវការជាចាំបាច់នូវកម្រិតសេវាផ្លូវថ្នល់ និងហេដ្ឋារចនាសម្ព័ន្ធអោយកាន់តែមានលក្ខណៈសមស្រប ។ ជាពិសេស ផ្លូវប្រើប្រាស់ដែលមិនក្រាលកៅស៊ូនៅក្នុងតំបន់ កំពុងបង្កអោយមានបរិស្ថានផ្លូវថ្នល់ដែលមានពោរពេញដោយធូលី ។ វានឹងធ្វើអោយបរិយាកាសទេសចរណ៍កាន់តែអាក្រក់

ឡើង ។

២) ភោជនីយដ្ឋាន និងអាគារលក់ដូរ

បន្ទាប់ពីការសិក្សាផែនការមេ ភោជនីយដ្ឋាន កំពុងកើនឡើងពី ៩០ ទៅដល់ ១២០កន្លែងដែលចំនួនកើនឡើងបន្ថែមនេះស្មើនឹងមួយភាគបួននៃចំនួនសរុបដែលមានស្រាប់ ។ ភោជនីយដ្ឋាន និងអាគារលក់ដូរកែលម្អថ្មី គឺជាចំបងកើនឡើងក្នុងតំបន់ផ្សាចាស់ និងតាមបណ្តោយផ្លូវស៊ីវត្ថា និងផ្លូវជាតិលេខ ៦ ។ ផ្នែកនៃផ្លូវថ្មើរជើង និងការក្រាលកៅស៊ូផ្លូវ ត្រូវបានកែលម្អនៅតាមកំណាត់ផ្លូវ និងតំបន់មួយចំនួន ប៉ុន្តែស្ថានភាពដែលមានស្រាប់នៃតំបន់ទេសចរណ៍ទាំងនោះ មិនអាចគ្រប់គ្រាន់នោះទេ ហើយរថយន្ត និងម៉ូតូកង់បីដែលចរាចរនៅលើផ្លូវថ្នល់ កំពុងបង្កើតស្ថានភាពដែលមិនមានផាសុកភាព និងសុវត្ថិភាព ។

ការបែងចែកនៃភោជនីយដ្ឋាន និងអាគារលក់ដូរ គឺត្រូវបានបែកខ្ញែកគ្នាក្នុងកម្រិតថេរមួយ ហើយបន្ទាប់ពីការអភិវឌ្ឍផ្ទះសំណាក់ក្នុងតំបន់កណ្តាលក្រុង ។

៣) ភាពទាក់ទាញភ្ញៀវទេសចរ

ជុំវិញផ្សារចាស់ ទីតាំងលក់ដូរពេលរាត្រីថ្មីនៃផ្សាររាត្រីព្រះច័ន្ទ និងផ្សាររាត្រីអង្គរ ត្រូវបានបន្តអភិវឌ្ឍន៍ និងទាក់ទាញភ្ញៀវទេសចរជាច្រើន ។ ទោះបីជាយ៉ាងនេះក្តី ការចូលទៅកាន់ទីតាំងទាំងនោះ មានការកកស្ទះដោយភ្ញៀវទេសចរ ឡាន និងម៉ូតូកង់បី ។

## ២.២.២ ផែនការប្រើប្រាស់ដីធ្លី និងការគ្រប់គ្រងកំណើនទីក្រុង

### (១). ផែនការចំនួនបី

មានផែនការចំនួនបីដែលពាក់ព័ន្ធនឹងការប្រើប្រាស់ដីធ្លី ដូចជា (១) ផែនការប្រើប្រាស់ដីធ្លីក្នុងឆ្នាំ ២០២០ ក្រោមផែនការមេរបស់ JICA (២០០៦) (២) ផែនការប្រើប្រាស់ដីធ្លីព្រាងចុងក្រោយដែលគាំទ្រដោយសេវាកម្មអភិវឌ្ឍន៍អាឡឺម៉ង់ DED (២០០៧) និង(៣) ផែនការព្រាងបែងចែកតំបន់ដែលកំណត់ដោយច្បាប់ (២០១០) ។

ផែនការប្រើប្រាស់ដីធ្លីព្រាងចុងក្រោយ (២០០៧) ត្រូវបានបង្កើតឡើងដោយរដ្ឋបាលស្រុកសៀមរាបដោយ សហការជាមួយ DED ។ ផែនការនេះត្រូវបានរៀបចំឡើងក្នុងក្របខ័ណ្ឌគម្រោងនគររូបនីយកម្មអាស៊ី (Asia Urbs Project) ដើម្បីលើកកម្ពស់វិមជ្ឈការ និងពង្រឹងអាជ្ញាធរស្រុក។ ដោយសាររដ្ឋបាលសៀមរាបស្ថិតនៅក្រោមក្រសួងមហាផ្ទៃ ផែនការប្រើប្រាស់ដីធ្លីព្រាងចុងក្រោយ គឺបច្ចុប្បន្ននេះស្ថិតនៅក្រោមដំណើរការអនុម័តក្នុងក្រសួងមហាផ្ទៃ។ ផែនការនេះ នឹងត្រូវប្រគល់ជូនក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ សម្រាប់ការអនុម័តចុងក្រោយបន្ទាប់ពីការអនុម័តដោយក្រសួងមហាផ្ទៃ។

ផែនការព្រាងបែងចែកតំបន់ដែលកំណត់ដោយច្បាប់ ត្រូវបានបង្កើតឡើងដោយមន្ទីររៀបចំដែនដី នគរូប-

នីយកម្ម និងសំណង់សៀមរាប ដោយសហការជាមួយអាជ្ញាធរអប្សរា ដើម្បីគ្រប់គ្រងកំណើនទីក្រុងអោយបានសមស្រប ដែលត្រូវបានពន្លឿន និងពង្រីក ។

រូបភាពខាងក្រោម បង្ហាញពីតំបន់ទីក្រុងក្នុងឆ្នាំ ២០២០នៃផែនការចំនួនបីខាងលើ ។ ដោយប្រៀបធៀបតំបន់ទាំងបី តំបន់ទីក្រុងនៃផែនការប្រើប្រាស់ដីធ្លីដែលរៀបចំដោយ DED លាតសន្ធឹងទៅទិសនិរតី ។ ទោះបីជាយ៉ាងនេះក្តី តំបន់ពីរផ្សេងទៀត លាតសន្ធឹងទៅទិសអាគ្នេយ៍ ។ ផែនការព្រាងបែងចែកតំបន់ដែលកំណត់ដោយច្បាប់ ហាក់បីដូចជាគោរពតាមគោលគំនិតផែនការមេរបស់ JICA ។ ដោយសារកំណើនប្រជាជន និង ភ្ញៀវទេសចរ កាន់តែខ្ពស់ជាងការរំពឹងទុកក្នុងផែនការមេរបស់ JICA ផែនការពង្រាងបែងចែកតំបន់ដែលកំណត់ដោយច្បាប់ បានពង្រីកតំបន់ក្រុងធំជាងតំបន់ក្រុងនៅក្នុងផែនការមេរបស់ JICA ។




**រូបភាព ២.៩ ការប្រៀបធៀបតំបន់ក្រុងទាំងបី**

យោងតាមបទសម្ភាសន៍ពីមន្ទីររៀបចំដែនដី នគរូបនីយកម្ម និងសំណង់ និងផែនការប្រើប្រាស់ដីធ្លីរបស់ DED នឹងត្រូវការពេលវេលាសម្រាប់ការសម្របសម្រួលជាមួយនឹងក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ ពីព្រោះ គោលគំនិតសម្រាប់តំបន់ក្រុងក្នុងឆ្នាំ ២០២០ ខុសគ្នាពីបណ្តាគោលគំនិតនៃផែនការមេរបស់ JICA ។

រហូតមកដល់ពេលនេះ ផែនការព្រាងបែងចែកតំបន់ដែលកំណត់ដោយច្បាប់ អាចត្រូវបានចាត់ទុកជាផែនការ

ដែលមានប្រសិទ្ធភាពបំផុត ពីព្រោះវា គឺជាការអនុវត្តចុងក្រោយបំផុត និងការប្រតិបត្តិច្បាប់ក្នុងពេលអនាគត ។

**(២). ការគ្រប់គ្រងកំណើនទីក្រុង**

ផែនការមេ បានណែនាំពីគោលគំនិតនៃ "ទីក្រុងរណប" ។ ទោះបីជាយ៉ាងនេះក្តី ការលំបាកមួយចំនួនត្រូវបានបង្ហាញ ។ ព្រំប្រទល់រដ្ឋបាលក្រុងសៀមរាប ត្រូវបានពង្រីកដោយបន្ថែមចំនួន៣សង្កាត់បន្ថែមទៀត។ ចំនួនប្រជាជន និងភ្ញៀវទេសចរ បានបន្តកើនឡើងយ៉ាងឆាប់រហ័ស ។ តំបន់ក្រុង កំពុងពង្រីក ហើយការអភិវឌ្ឍទ្រង់ទ្រាយធំមួយចំនួនដែលរួមមានការផ្លាស់ប្តូរទីតាំងនៃការិយាល័យរដ្ឋបាលខេត្ត កើតមានឡើងនៅខាងក្រៅនៃផ្លូវក្រវ៉ាត់ក្រុង ហើយផុតពីព្រំប្រទល់ក្រុង ។ ដើម្បីរក្សាកំណើនទីក្រុងអោយសមស្របទប់ទល់នឹងនគរូបនីយកម្មដែលគ្មានសណ្តាប់ធ្នាប់ដែលកើតឡើងយ៉ាងឆាប់រហ័ស ការកសាងសមត្ថភាពសម្រាប់អាជ្ញាធរមូលដ្ឋាន និងការគ្រប់គ្រងកំណើនទីក្រុង គឺមិនអាចខ្វះបាន ។

**(៣). ការផ្លាស់ប្តូរនៃការិយាល័យរដ្ឋបាលខេត្ត**

ការិយាល័យរដ្ឋបាលខេត្ត ត្រូវបានបន្តផ្លាស់ប្តូរពីចំនុចកណ្តាលក្រុងទៅតំបន់ខាងក្រៅ ។ ការិយាល័យរដ្ឋបាលក្រុងសៀមរាប ត្រូវបានផ្លាស់ប្តូរទៅជិតអាកាសយានដ្ឋានសៀមរាបក្នុងឆ្នាំ ២០០៨។ ការិយាល័យរដ្ឋបាលខេត្ត បានផ្លាស់ប្តូរពីតំបន់ពាណិជ្ជកម្មកណ្តាលទៅខាងក្រៅនៃតំបន់ក្រុងទាំងបីដែលបានលើកឡើងខាងលើ ។ តំបន់ផ្លាស់ប្តូរ ថ្មីៗ គឺស្ថិតក្នុងទីក្រុង និងខាងក្រៅនៃតំបន់ ២ ។

ដូចនេះ វាគឺជាការចាំបាច់ក្នុងការបង្កើតផែនការមួយជាបន្ទាន់សម្រាប់ការអភិវឌ្ឍ និងការអភិរក្សនៅជុំវិញតំបន់ផ្លាស់ប្តូរថ្មីរបស់រដ្ឋបាលខេត្ត និងផែនការមួយសម្រាប់ដីទំនេរបន្ទាប់ពីការផ្លាស់ប្តូរទីតាំងនោះ។ ជាពិសេសផែនការអភិវឌ្ឍន៍សម្រាប់ដីទំនេរ ត្រូវតែចាត់ចែងរៀបចំអោយបានសមស្របជាតំបន់កណ្តាលក្រុងមួយដែលមានភាពទាក់ទាញ ។

**(៤). ផែនការព្រាងបែងចែកតំបន់ដែលកំណត់ដោយច្បាប់**

ផែនការព្រាងបែងចែកតំបន់ដែលកំណត់ដោយច្បាប់ គឺបច្ចុប្បន្នស្ថិតនៅក្រោមដំណើរការអនុម័តដោយក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ ។ ផែនការនេះ ហាក់បីដូចជាច្បាប់រូបសាស្ត្រមួយ ដែលរួមមានគម្លាតអប្បបរមាពីអាគារ ផលធៀបក្រឡាផ្ទៃបាតអាគារ និងផលធៀបគម្របអាគារ ដោយយោងតាមព័ត៌មានមានកម្រិតដែលពាក់ព័ន្ធនឹងផែនការព្រាងបែងចែកតំបន់ដែលកំណត់ដោយច្បាប់ ពីព្រោះផែនការនេះ មិនទាន់ត្រូវបានលាតត្រដាងនៅឡើយរហូតមកដល់ពេលនេះ ។ ដូចនេះ គេចាំបាច់ត្រូវបង្កើតផែនការបែងចែកតំបន់ដែលចែងពីការគ្រប់គ្រងការប្រើប្រាស់ដីធ្លី និងគោលការណ៍ណែនាំលម្អិតស្តីពីការអភិវឌ្ឍន៍សម្រាប់ការគ្រប់គ្រងក្រុងអោយបានសមស្រប ។ វាគឺជាការចាំបាច់ផងដែរ ក្នុងការកសាងសមត្ថភាពមន្ត្រីរដ្ឋាភិបាលដែលទទួលខុសត្រូវលើ

ការគ្រប់គ្រងការប្រើប្រាស់ដីធ្លី ។

## ២.២.៣ ផែនការ និងគម្រោងអភិវឌ្ឍន៍ផ្សេងៗ

### (១). គម្រោងតាំងទីលំនៅឡើងវិញសម្រាប់គ្រួសារលើដីសាធារណៈ

រដ្ឋបាលខេត្ត និងអាជ្ញាធរអប្សរា បានបង្កើតគម្រោងមួយស្តីពី "ភូមិអេកូរុន្ធតាអែកសម្រាប់ការអភិវឌ្ឍប្រកបដោយចីរភាព" សម្រាប់ការផ្លាស់ប្តូរទីលំនៅខុសច្បាប់ចេញពីតំបន់១ តំបន់២ និងតំបន់៣នៃសួនឧទ្យានអង្គរ។ ទីតាំងគម្រោង គឺស្ថិតក្នុងតំបន់ខាងកើតជិត៧នៃតំបន់២នៃសួនឧទ្យានបុរាណវិទ្យា ។ សមត្ថភាពផ្ទុកនៃលំនៅដ្ឋានដែលបានគ្រោងទុក គឺសម្រាប់អ្នកស្រុក ៥000 នាក់ ។ ការអនុវត្តគម្រោង បានបន្តចាប់ផ្តើមនៅលើទីតាំងនោះ ។

### (២). គម្រោងជំនួយឥតសំណងរបស់ AFD សម្រាប់តំបន់កណ្តាលក្រុង

AFD កំពុងអនុវត្តនីកញ្ចប់គម្រោងជំនួយឥតសំណងដែលមានទឹកប្រាក់ ៥.៥ លានអឺរ៉ូ ដែលក្នុងនោះរួមមានការកែលម្អប្រព័ន្ធដោះទឹកភ្លៀងសម្រាប់ជ្រុងខាងកើតនៃក្រុងសៀមរាបពីស្ទឹង (៥ លាន) និងកញ្ចប់គម្រោងតូចៗចំនួនប្រាំសម្រាប់ការកែលម្អតំបន់កណ្តាលក្រុង (កន្លះលាន)ដែលរួមមានដូចខាងក្រោម:

- ការអភិរក្សបេតិកភ័ណ្ឌក្រុង (ការស៊ើបអង្កេត ការបង្កើតឃ្លាំងស្តុកទិន្នន័យ ការបង្កើតផែនការការស្តារឡើងវិញ/ការកែកុន/ និងការប្រើប្រាស់)
- ការកែលំអមាត់ស្ទឹងសៀមរាប (ទេសភាព ស្ពានអ្នកថ្មើរជើងលើស្ទឹងសៀមរាបដើម្បីតភ្ជាប់នឹងផ្សារចាស់ និងបេតិកភ័ណ្ឌក្រុង ក្តារពតិមានទេសចរណ៍)
- ការកែលំអតំបន់ផ្សារចាស់ (ការដាំដើមឈើ និងសកម្មភាពផ្សេងៗទៀត)
- ការអភិវឌ្ឍន៍ភូមិអេកូនៅតាមបណ្តោយដៃស្ទឹងសៀមរាបក្នុង និងជុំវិញតំបន់កណ្តាលក្រុង
- ការកែលំអផ្លូវថ្មល់ទៅកាន់តំបន់បេតិកភ័ណ្ឌក្រុង និងផ្លូវមាត់ស្ទឹងសៀមរាបថ្មីនៅលើច្រាំងខាងកើត

### (៣). ប្រាសាទព្រះវិហារ

ប្រាសាទព្រះវិហារ គឺជាប្រាសាទរបស់ខ្មែរដែលស្ថិតនៅលើកំពូលនៃភ្នំដងរែក ជិតព្រំប្រទល់ថៃ ។ ក្នុងខែកក្កដា ឆ្នាំ ២០០៨ ប្រាសាទព្រះវិហារត្រូវបានចុះបញ្ជីជាតំបន់បេតិកភ័ណ្ឌពិភពលោករបស់អង្គការយូនីស្កូ ។ ផ្លូវពីសៀមរាបទៅកាន់ប្រាសាទព្រះវិហារ គឺបច្ចុប្បន្នស្ថិតនៅក្រោមការសាងសង់ ដូច្នោះគេ នឹងអាចចូលទៅកាន់តំបន់បេតិកភ័ណ្ឌពិភពលោករបស់អង្គការយូនីស្កូចំនួនពីរក្នុងប្រទេសកម្ពុជាដោយងាយស្រួល ។

តារាងខាងក្រោម បង្ហាញពីចំនួនភ្ញៀវទេសចរទៅកាន់ប្រាសាទព្រះវិហារ។ កាលពីមុន វាមានការលំបាកណាស់ក្នុងការឡើងភ្នំដើម្បីទៅដល់ប្រាសាទនោះ ប៉ុន្តែពេលបច្ចុប្បន្នផ្លូវឡើងតាមភ្នំទៅកាន់ប្រាសាទនោះត្រូវបានអភិវឌ្ឍ និងក្រាលកៅស៊ូ ។ ដូចនេះ ចំនួនភ្ញៀវទេសចរ បានបន្តកើនឡើង ។ ក្នុងឆ្នាំ ២០០៩ ចំនួនភ្ញៀវទេសចរ

ត្រូវបាន ធ្លាក់ចុះ ដោយសារជម្លោះរវាងកម្ពុជា និងថៃ ។

ផែនការមេ បានស្នើឡើងនូវ "បណ្តាញទេសចរណ៍បេតិកភ័ណ្ឌខ្មែរ និងគម្រោងអភិវឌ្ឍន៍បរិក្ខារសម្រាប់ទេសចរណ៍" ដូច្នោះភ្ញៀវទេសចរដែលស្នាក់នៅក្នុងសៀមរាប អាចទស្សនាតំបន់បេតិកភ័ណ្ឌដែលនៅឆ្ងាយពីគ្នា ហើយបន្ទាប់មកពួកគេ អាចស្នាក់នៅកាន់តែយូរ និងធ្វើការចំណាយកាន់តែច្រើន ។ ប្រាសាទព្រះវិហារ មានសក្តានុពលដើម្បីបង្កើនល្បឿន "យុទ្ធសាស្ត្រទីផ្សារសម្រាប់អ្នកមាន" ។

## តារាង ២.១៦ ចំនួនភ្ញៀវទេសចរទៅកាន់ព្រះវិហារ

| | ២០០២ | ២០០៣ | ២០០៤ | ២០០៥ | ២០០៦ | ២០០៧ | ២០០៨ | ២០០៩ |
|---|---|---|---|---|---|---|---|---|
| អន្តរជាតិ | ១៦៨ | ៤៨.២៩៧ | ៦៧.៨៤៣ | ៨៨.៦១៥ | ១០៨.៦៩១ | ៩០.៦៩៣ | ៦២.២៥៨ | ៨.៤៥២ |
| ក្នុងស្រុក | ៧២៨ | ២.៨០០ | ៥.៥០៤ | ១៨.៨៧៦ | ២០.៣២៦ | ៣៧.៥៣០ | ៦៥.១៨២ | ៤០.៥២៥ |
| សរុបរង | ៨៩៦ | ៥១.០៩៧ | ៧៣.៣៤៧ | ១០៧.៤៩១ | ១២៩.០១៧ | ១២៨.២២៣ | ១២៧.៤៤០ | ៤៨.៩៧៧ |

ប្រភព: របាយការណ៍ប្រចាំឆ្នាំស្ថិតិទេសចរណ៍ ក្រសួងទេសចរណ៍

### (៤). ផ្លូវប៉ោយប៉ែត - សៀមរាប

កំណាត់ផ្លូវពីប៉ោយប៉ែតទៅសៀមរាប (១៤៥,៤ គម) (ផ្លូវជាតិលេខ៥ (ប៉ោយប៉ែត - សិរីសោភណ្ឌ) និង ផ្លូវជាតិលេខ៦ សិរីសោភណ្ឌ - សៀមរាប)) ត្រូវបានបន្តកែលម្អដោយក្រាលកៅស៊ូ ក្រោមមូលនិធិនៃកម្ចីរបស់ធនាគារអភិវឌ្ឍន៍អាស៊ី ។




ប្រភព: របាយការណ៍ប្រចាំឆ្នាំស្ថិតិទេសចរណ៍ ក្រសួងទេសចរណ៍

**រូបភាព ២.១០ ការមកដល់របស់ភ្ញៀវទេសចរមកកាន់កម្ពុជាតាមច្រកប៉ោយប៉ែត**

# ជំពូក ៣ ការវិវត្តន៍នៃគំរោង/កម្មវិធីដែលបានស្នើឡើងក្នុងផែនការមេ

## ៣.១ ការវិវត្តន៍ជាទូទៅនៃគំរោង/កម្មវិធីដែលបានស្នើឡើង

នៅក្នុងផែនការមេ មានគំរោង/កម្មវិធីចំនួន ៦៩ ត្រូវបានស្នើឡើងក្នុង ១១ ផ្នែក។ ការវិវត្តន៍ជាទូទៅនៃគំរោង/កម្មវិធីទាំង ៦៩ នោះត្រូវបានបញ្ជាក់ដោយផ្អែកលើការស្ទាបស្ទង់ដែលត្រូវបានធ្វើឡើងដោយទីប្រឹក្សាផ្នែកគ្រប់គ្រងក្រុងរបស់ទីភ្នាក់ងារសហប្រតិបត្តិការអន្តរជាតិនៃប្រទេសជប៉ុន។

ស្ថានភាពនៃការវិវត្តន៍សំរាប់គំរោង/កម្មវិធីក្នុង ៩ ផ្នែកដទៃផ្សេងទៀតលើកលែងវិស័យគមនាគមន៍ និងផ្នែករៀបចំក្រុងត្រូវបានសង្ខេបក្នុងតារាងខាងក្រោម:

**តារាង ៣.១ ការវិវត្តន៍នៃគំរោង/កម្មវិធីដែលបានស្នើឡើង**

| ល.រ | ផ្នែក | ចំនួនគំរោង/កម្មវិធី | | | |
|---|---|---|---|---|---|
| | | សរុប | ដែលបានបញ្ចប់ | កំពុងវិវត្តន៍ | គ្មានការវិវត្តន៍ |
| ១ | ទីក្រុង | ៥ | 0<br>0.0% | ៥<br>១00.0% | 0<br>0.0% |
| | | សូមមើលតារាង៣.២ | | | |
| ២ | ពរិស្ថាន | ៣ | 0<br>0.0% | ២<br>៦៦.៧% | ១<br>៣៣.៣% |
| | | គណៈកម្មការបច្ចេកទេសផ្នែកអភិវឌ្ឍន៍ក្រុងបានស្នើសុំសហប្រតិបត្តិការផ្នែកបច្ចេកទេសពីរដ្ឋាភិបាលប្រទេសជប៉ុននៅឆ្នាំ ២00៨។ ទោះបីជាយ៉ាងណាក៏ដោយ គំរោងនេះមិនត្រូវបានចាត់ទុកជាអទិភាពដោយភាគីខាងកម្ពុជាឡើយ។ ដូច្នេះ គំរោងនេះគ្មានការវិវឌ្ឍន៍អ្វីទេមកទល់នឹងពេលនេះ។ | | | |
| ៣ | ទេសចរ | ៦ | ១<br>១៦.៧% | ៤<br>៦៦.៧% | ១<br>១៦.៧% |
| | | រាល់គំរោងទាំងអស់លើកលែងតែគំរោងអភិវឌ្ឍន៍គុណភាពទេសចរភាពជាដៃគូរវាងឯកជន-រដ្ឋ ត្រូវបានបញ្ចប់ ឬស្ថិតក្នុងដំណើរការ។ | | | |
| ៤ | ការបង្កើតអោយមានផលិត-ផលកសិកម្មចំរុះ និងការផ្សព្វផ្សាយផលិតផលក្នុងស្រុក | ៤ | 0<br>0.0% | 0<br>0.0% | ៤<br>១00.0% |
| | | រាល់គំរោងទាំងអស់ដែលបានស្នើឡើងគ្មានការវិវត្តន៍ដោយសារតែមជ្ឈមណ្ឌល | | | |

| | | | | | |
|---|---|---|---|---|---|
| | | ផ្សព្វផ្សាយផលិតផលអង្ករមិនទាន់ត្រូវបានបង្កើតនៅឡើយ។ | | | |
| ៥ | គមនាគមន៍ | ១០ | ២<br>២០.០% | ៦<br>៦០.០% | ២<br>២០.០% |
| | | សូមមើលតារាង៣.៣ | | | |
| ៦ | ទឹក | ៧ | 0<br>0.0% | ៦<br>៨៥.៧% | ១<br>១៤.៣% |
| | | គំរោងភាគច្រើនស្ថិតក្នុងដំណើរការវិវត្តន៍ ជាពិសេស "គំរោងការសិក្សាត្រៀមស្តីពីការពង្រីកការផ្គត់ផ្គង់ទឹកក្នុងក្រុងសៀមរាប" ដែលកំពុងបន្ត និងរបាយការណ៍ចុងក្រោយនៃគំរោងនេះត្រូវដាក់ជូនត្រួតពិនិត្យ។ | | | |
| ៧ | កាកសំណល់រឹង | ៣ | 0<br>0.0% | 0<br>0.0% | ៣<br>១00.0% |
| | | រាល់គំរោងទាំងអស់គ្មានការវិវត្តន៍ | | | |
| ៨ | លូបង្ហូរទឹកសំអុយ/លូដោះទឹក | ៩ | 0<br>0.0% | ៥<br>៥៥.៦% | ៤<br>៤៤.៤% |
| | | គំរោងចំនួន ៥ ស្ថិតក្នុងការវិវត្តន៍ និងគំរោងចំនួន ៤ ទៀតគ្មានការវិវត្តន៍។ ទោះបីជាយ៉ាងណាក៏ដោយ គំរោងទាំង ៤ នេះ នឹងត្រូវចាប់ផ្តើមនៅក្រោយឆ្នាំ ២០១២។ | | | |
| ៩ | ថាមពល | ១០ | 0<br>0.0% | ៥<br>៥0.0% | ៥<br>៥0.0% |
| | | ខ្សែបញ្ជូនថាមពលមកពីប្រទេសថៃមិនទាន់បានសាងសង់នៅឡើយ។ | | | |
| ១០ | រដ្ឋបាលថ្នាក់មូលដ្ឋាន | ៥ | 0<br>0.0% | ៥<br>១00.0% | 0<br>0.0% |
| | | រាល់គំរោងទាំងអស់ស្ថិតក្នុងការវិវត្តន៍។ កម្មវិធីកែទំរង់វិមជ្ឈការ និងអំណាចមិនប្រមូលផ្តុំកំពុងបន្ត។ | | | |
| ១១ | ការផ្តល់អំណាចដល់សហគមន៍ | ៧ | 0<br>0.0% | ៤<br>៥៧.១% | ៣<br>៤២.៩% |
| | | គំរោងមួយចំនួនស្ថិតក្នុងដំណើរការវិវត្តន៍។ | | | |
| | សរុប | ៦៩ | ៣<br>៤.៣% | ៤២<br>៦0.៩% | ២៤<br>៣៤.៨% |

ជាងពាក់កណ្តាលនៃគំរោង/កម្មវិធីស្ថិតក្នុងដំណើរការវិវឌ្ឍន៍ (៦០.៩%)។ ទោះបីជាយ៉ាងណាក៏ដោយ មានគំរោងដែលគ្មានការវិវត្តន៍ចំនួន ៣៩.៨% ដោយហេតុផលថា គំរោង/កម្មវិធីមួយចំនួនមិនទាន់ត្រូវបានចាប់ផ្តើមនៅឡើយ ហើយត្រូវបានស្នើឡើងក្នុងផែនការរយៈពេលវែងដល់ទៅឆ្នាំ២០២០។

ហេតុផលសំខាន់ដែលធ្វើអោយគ្មានការវិវត្តន៍នោះគឺថា បុគ្គលិកភាគច្រើននៃមន្ទីរ/ស្ថាប័នដែលទទួលខុសត្រូវមិនបានដឹងអំពីផែនមេនៅពេលដែលទីប្រឹក្សាផ្នែកគ្រប់គ្រងក្រុងរបស់ទីភ្នាក់ងារសហប្រតិបត្តិការអន្តរជាតិនៃប្រទេសជប៉ុនត្រូវបានចាត់តាំងបន្ថែមពីលើនេះ ការផ្លាស់ប្តូរមន្ត្រីប្រតិបត្តិរបស់ខេត្តក៏បានជះឥទ្ធិពលដល់បុព្វហេតុនេះផងដែរ។

## ៣.២ ការវិវត្តន៍នៃគំរោង/កម្មវិធីដែលបានស្នើឡើងរួចក្នុងផ្នែករៀបចំក្រុង

មានគំរោង/កម្មវិធីចំនួន ៩ ដែលបានស្នើឡើងរួចក្នុងផ្នែករៀបចំក្រុង។ ការវិវត្តន៍នៃគំរោង/កម្មវិធីនីមួយៗមានដូចតទៅ:

**តារាង ៣.២ ការវិវត្តន៍នៃគំរោង/កម្មវិធីដែលបានស្នើឡើងក្នុងផ្នែករៀបចំក្រុង**

| លេខសំគាល់គំរោង | ឈ្មោះ | ភ្នាក់ងារអនុវត្ត | ការវិវត្តន៍/កំណត់សំគាល់ | ស្ថានភាពការវិវត្តន៍ |
|---|---|---|---|---|
| U-1 | ការអភិវឌ្ឍន៍តំបន់កណ្តាលក្រុង | សាលាខេត្ត អាជ្ញាធរអប្សរា និងមន្ទីរពាក់ព័ន្ធ | -គណៈកម្មការបច្ចេកទេសផ្នែកអភិវឌ្ឍន៍ក្រុងបានពិភាក្សាស្តីពីការអភិវឌ្ឍន៍តំបន់កណ្តាលក្រុង<br>-គណៈកម្មការបច្ចេកទេសផ្នែកអភិវឌ្ឍន៍ក្រុងនឹងពិភាក្សា និងធ្វើផែនការអភិវឌ្ឍន៍ក្រុងជាការបរិយាយគំរោងប្រាក់កំចី នៃជំនួយអភិវឌ្ឍន៍ផ្លូវការ ODA Loan Project។<br>-អាជ្ញាធរអប្សរាមានផែនការមួយចំនួនដែលបានឧបត្ថម្ភដោយទីភ្នាក់ងារ អភិវឌ្ឍន៍បារាំងAFD(ស្ពានឈើដើមឈើតាមផ្លូវ ។ល។)<br>-ផ្នែកជាច្រើននៃផ្លូវផ្លូវថ្មើរជើងក្នុងតំបន់ផ្សារចាស់ត្រូវបានកែលំអ។ | △ |
| U-2 | គារកសាងសម្ថភាពផ្នែករៀបចំក្រុង | មន្ទីរ.ដ.ន.ស.ស ឃុំ អាជ្ញាធរអប្សរា និងសាលាខេត្ត | -ផែនការប្រើប្រាស់ដីធ្លីក្នុងក្រុងសៀមរាបត្រូវបានរៀបចំរួចហើយដាយ ក្រុងសៀមរាប ដោយជំនួយពី DED។<br>-ទីប្រឹក្សាមួយរូបផ្នែកគ្រប់គ្រងក្រុងរបស់ទីភ្នាក់ងារសហប្រតិបត្តិការអន្តរជាតិនៃប្រទេសជប៉ុនត្រូវបានបញ្ជូនមកខេត្តសៀមរាប។<br>-មន្ត្រីជាន់ខ្ពស់ស្ម័គ្រចិត្តមួយរូបរបស់ទីភ្នាក់ងារសហប្រតិបត្តិការអន្តរជាតិនៃប្រទេសជប៉ុនផ្នែករៀបចំក្រុងត្រូវបានបញ្ជូនមកកាន់អាជ្ញាធរអប្សរា។<br>-មន្ត្រីជាន់ខ្ពស់ស្ម័គ្រចិត្តមួយរូបរបស់ទីភ្នាក់ងារ | △ |

| | | | | |
|---|---|---|---|---|
| | | | សហប្រតិបត្តិការអន្តរជាតិនៃប្រទេសជប៉ុនផ្នែកប្រព័ន្ធពត៌មានភូមិសាស្ត្រត្រូវបានបញ្ជូនមកកាន់អាជ្ញាធរអប្សរា។ | |
| U-3 | បញ្ជីសារពើភណ្ឌសំរាប់ស្ថាបត្យកម្មប្រវត្តិសាស្ត្រ | អាជ្ញាធរអប្សរា/សាលាខេត្ត | -អាជ្ញាធរអប្សរានឹងធ្វើការស្ទាបស្ទង់សារពើភណ្ឌមួយ សំរាប់ស្ថាបត្យកម្មប្រវត្តិសាស្ត្រដោយមានជំនួយពីទីភ្នាក់ងារអភិវឌ្ឍន៍បារាំងAFD។ | △ |
| U-4 | ការផ្សព្វផ្សាយស្តីពីការអភិវឌ្ឍន៍តំបន់លំនៅដ្ឋាន | មន្ទីរ.ដ.ន.ស.ស ឃុំ និងផ្នែកឯកជន | -បុរីលំនៅដ្ឋានមួយចំនួនត្រូវបានអភិវឌ្ឍន៍ឡើង ប៉ុន្តែប្រជាជនក្នុងតំបន់មិនមានលទ្ធភាពទិញ។ | △ |
| U-5 | ការអភិវឌ្ឍន៍តំបន់ទេសចរ និងវប្បធម៌ | អាជ្ញាធរអប្សរា និងអ្នកវិនិយោគទន់ឯកជន | -កន្លែងទេសចរមួយចំនួន ដូចជា មជ្ឈមណ្ឌលសន្និបាតសារៈមន្ទីរសីហនុ ។ល។ ត្រូវបានអភិវឌ្ឍន៍ឡើង។<br>-ការទិញដីមកវិញបាននឹងកំពុងវិវត្តន៍ដោយអាជ្ញាធរ អប្សរា។ | △ |

△:មានការវិវត្តន៍មួយចំនួន

ប្រភព: ការសិក្សាតាមដាន

ពត៌មានលំអិតពីការវិវត្តន៍នៃ" U-1 គំរោងកែលំអតំបន់កណ្តាលក្រុង" ត្រូវបានពិពណ៌នាដូចខាងក្រោម

U-1 គំរោងកែលំអតំបន់កណ្តាលក្រុង

មានសមាសធាតុចំនួន ៨ ដូចខាងក្រោម:

(១) ការកែលំអផ្លូវថ្មើរជើង: ប្រវែងប្រមាណជា ៣ គីឡូម៉ែត្រ (ផ្លូវស៊ីវុត្ថា និងផ្លូវក្នុងតំបន់ផ្សារចាស់)។ ផ្លូវថ្មើរជើងដែលបានស្នើឡើងក្នុងផែនការមេត្រូវបានកែលំអរួចស្រេចហើយ ដូចដែលបានបង្ហាញក្នុងរូបភាពខាងក្រោម។ បន្ថែមពីលើនោះ ក៏មានការកែលំអផ្លូវថ្មើរជើងមួយចំនួនទៀតនៅក្នុងតំបន់កណ្តាលក្រុងផងដែរ។ ទោះបីយ៉ាងនេះក្តី ផ្លូវថ្មើរជើងមួយចំនួនត្រូវបានធ្វើឡើង និង/ឬ មានទំហំតូចចង្អៀត។



ផ្លូវថ្មើរជើងនៅសងខាងផ្លូវ

ឧបសគ្គដែលមានទីធ្លាតូចចង្អៀតសំរាប់ផ្លូវថ្មើរជើងនៅសងខាងផ្លូវ (រារាំងដល់ផ្លូវថ្មើរជើង)

ផ្លូវថ្មើរជើងដែលនៅតែម្ខាងផ្លូវ

គំរោងអាទិភាពដែលបានស្នើឡើងសំរាប់ការអភិវឌ្ឍន៍ និងរៀបចំផ្លូវថ្មើរជើងក្នុងផែនការមេ

**រូបភាព ៣.១ ការកែលំអផ្លូវថ្មើរជើង**

(២) ការតំរង់ជួរដើមឈើក្នុងតំបន់ផ្សារចាស់: មានប្រវែងប្រមាណជា ២គីឡូម៉ែត្រ (ផ្លូវស៊ីវុត្ថា និងផ្លូវក្នុងតំបន់ផ្សារចាស់)។ ច្រើនជាងពាក់កណ្តាលនៃការតំរង់ជួរដើមឈើដែលបានស្នើត្រូវបានសាងសង់រួចបន្ថែមពីលើផ្លូវដែលមិនបានស្នើឡើងក្នុងផែនការមេ។ ស្ថានភាពបច្ចុប្បន្ននៃការតំរង់ជួរដើមឈើត្រូវបានបង្ហាញក្នុងរូបភាពដូចខាងក្រោម:



ដើមឈើនៅសងខាងផ្លូវ

នៅសងខាងផ្លូវ

គំរោងអាទិភាពដែលបានស្នើឡើងសំរាប់ការអភិវឌ្ឍន៍ និងតំរង់ជួរដើមឈើតាមផ្លូវក្នុងផែនការមេ

**រូបភាព ៣.២ ជួរដើមឈើ**

(៣) ការកែលំអភ្លើងបំភ្លឺតាមផ្លូវៈ ត្រូវបានកំណត់ដាក់ (ភាគច្រើននៅតាមដងស្ទឹងសៀមរាប) នៅតាមដងផ្លូវដែលបានស្នើឡើងក្នុងផែនការមេ ត្រូវបានសំរេចលើកលែងផ្លូវមួយ។ បន្ថែមពីលើនោះ ភ្លើងបំភ្លឺនៅតាមផ្សេងៗ ត្រូវបានបំពាក់ដូចបង្ហាញក្នុងរូបភាពខាងក្រោមៈ



ភ្លើងបំភ្លឺនៅសងខាងផ្លូវ

នៅតែម្ខាងផ្លូវ

គំរោងអាទិភាពដែលបានស្នើឡើងសំរាប់ការអភិវឌ្ឍន៍ និងរៀបចំភ្លើងបំភ្លឺតាមផ្លូវក្នុងផែនការមេ

**រូបភាព ៣.៣ ភ្លើងបំភ្លឺផ្លូវ**

（៤） ការកសាងសួនក្នុងក្រុង

（៥） ការអភិវឌ្ឍន៍ឡើងវិញនូវតំបន់មន្ទីរពេទ្យខេត្ត

（៦） ការអភិវឌ្ឍន៍ឡើងវិញនូវតំបន់កកកុញកណ្តាលក្រុង

ពុំមានការវិវត្តន៍ណាមួយទេក្នុងចំណោមសមាសធាតុទាំង ៣ខាងលើនេះ។

（៧） ការកែលំអផ្លូវថ្មើរជើងនៃផ្លូវក្នុងក្រុង៖ មានប្រវែងប្រមាណជា ១០.៥ គីឡូម៉ែត្រ（ភាគច្រើនស្ថិតក្នុងតំបន់ជិតក្រុង）។ ប្រមាណជា ៨០%នៃផ្លូវក្រុងដែលបានស្នើ មិនទាន់ត្រូវបានអនុវត្តនៅឡើយដូចដែលបានបង្ហាញនៅ

ក្នុងរូបភាពខាងក្រោម ។

(៨) ការសាងសង់ផ្លូវថ្មី: ប្រមាណ ១.១គីឡូម៉ែត្រ (ស្ថិតនៅភាគខាងកើត និងខាងត្បូងនៃព្រំប្រទល់តំបន់ជុំវិញក្រុង) ។ ការសាងសង់ផ្លូវថ្មីដែលបានស្នើក្នុងផែនការមេ ពុំទាន់ត្រូវបានអនុវត្តនៅឡើយដូចដែលបានបង្ហាញក្នុងរូបភាពខាងក្រោម:




បណ្តាញផ្លូវក្រាលកៅស៊ូដែលមានស្រាប់

តំរោងអាទិភាពដែលបានស្នើឡើងសំរាប់ការអភិវឌ្ឍន៍ និងក្រាលផ្លូវកៅស៊ូក្នុងផែនការមេ

**រូបភាព ៣.៤ ការអភិវឌ្ឍន៍ និងកែលំអផ្លូវ**

## ៣.៣ ការវិវត្តន៍នៃគំរោង/កម្មវិធីដែលបានស្នើឡើងក្នុងវិស័យគមនាគមន៍

មានគំរោង/កម្មវិធីចំនួន ១០ ដែលបានស្នើឡើងរួចក្នុងវិស័យគមនាគមន៍។ ការវិវត្តន៍នៃគំរោង/កម្មវិធីនីមួយៗមានដូចតទៅ:

**តារាង ៣.៣ ការវិវត្តន៍នៃគំរោង/កម្មវិធីដែលបានស្នើឡើងរួចក្នុងវិស័យគមនាគមន៍**

| លេខសំគាល់គំរោង | ឈ្មោះ | ភ្នាក់ងារអនុវត្ត | ការវិវត្តន៍/កំណត់សំគាល់ | ស្ថានភាពការវិវត្តន៍ |
|---|---|---|---|---|
| TR-1 | គំរោងកែលំអស្ពានសល់ពីសម័យបារាំង | ក្រសួងសាធារណៈការ និងដឹកជញ្ជូន | -ស្ពានថ្មីមួយត្រូវបានសាងសង់ឡើងមានប្រវែងប្រម៉ាណ ២៧០ម៉ែត្រដែលមានទិសដៅបញ្ច្រាសគ្នានឹងស្ពានសល់ពីសម័យបារាំង និងត្រូវប្រើជាផ្លូវឯកទិសពីទិសខាងលិចទៅទិសខាងកើត។ ចំណែកស្ពានសល់ពីសម័យបារាំងក៏ត្រូវប្រើប្រាស់ជាផ្លូវឯកទិសផងដែរ ពីទិសខាងកើតទៅទិសខាងលិច។ | ○ |
| TR-2 | បណ្តាញផ្លូវរណប (ជំហានទី ១) | មន្ទីរសាធារណៈការ និងដឹកជញ្ជូនសាលាខេត្ត | -មានផ្នែកតិចតួចប៉ុណ្ណោះនៃផ្លូវដែលបានស្នើឡើងរួចត្រូវបានក្រាលកៅស៊ូ។ទោះបីយ៉ាងណាក៏ដោយ ផ្នែកជាច្រើនគ្មានការវិវឌ្ឍន៍ឡើយ។ | △ |
| TR-3 | បណ្តាញផ្លូវរណប (ជំហានទី ២) | ក្រសួងសាធារណៈការ និងដឹកជញ្ជូន | -ផ្លូវ ហ៊ុន សែន សន្តិភាពត្រូវបានកែលំអក្នុងខែមករា ឆ្នាំ ២០១០។<br>-ផ្លូវនេះត្រូវបានចាត់ថាជា"ផ្លូវបញ្ចៀសក្រុងសៀមរាប" ហើយរថយន្តធន់ធ្ងន់ត្រូវធ្វើចរាចរលើផ្លូវនេះជំនួសអោយការធ្វើចរាចរចូលទៅក្នុងក្រុងតាមផ្លូវជាតិលេខ៦។<br>-ផ្លូវបញ្ចៀសនេះជាផ្លូវបង់ប្រាក់ គឺយកប្រាក់តែពីរថយន្តធន់ធ្ងន់ប៉ុណ្ណោះ ហើយត្រូវបានដំណើរការដោយអាជ្ញាធរអប្សរា។ | ○ |
| TR-4 | បណ្តាញផ្លូវរណប (ជំហានទី ៣) | មន្ទីរសាធារណៈការ និងដឹកជញ្ជូនសាលាខេត្ត | -ផ្នែកខ្លះនៃបណ្តាញផ្លូវរណបត្រូវបានសាងសង់បញ្ចប់។ ទោះជាយ៉ាងណាក៏ដោយ ផ្នែកជាច្រើននៃផ្លូវនេះមិនទាន់ត្រូវបានបញ្ចប់នៅឡើយ។ | △ |

| | | | | |
|---|---|---|---|---|
| TR-5 | បណ្តាញផ្លូវរណប (ជំហានទី ៤) | សាលាខេត្ត | -ផ្នែកខ្លះនៃបណ្តាញផ្លូវរណបត្រូវបានសាងសង់បញ្ចប់។ ទោះជាយ៉ាងណាក៏ដោយ ផ្នែកជាច្រើននៃផ្លូវនេះមិនទាន់ត្រូវបានបញ្ចប់នៅឡើយ។ | △ |
| TR-6 | កែលំអស្ថាប័ន និង យុទ្ធនាការផ្សព្វផ្សាយសុវត្ថិភាពចរាចរ | នគរបាល មន្ទីរសាធារណៈការ និងដឹកជញ្ជូន សាលាខេត្ត | -មានផែនការសកម្មភាពចំនួន ៨។<br>-គ្មានសមិទ្ធផលណាមួយសំរេចបានគួរអោយកត់សំគាល់ | △ |
| TR-7 | ស្តារបណ្តាញផ្លូវទៅកាន់តំបន់បេតិកភណ្ឌជនបទ | ក្រសួងសាធារណៈការ និងដឹកជញ្ជូន ក្រសួងអភិវឌ្ឍន៍ជនបទ | -ភាគច្រើននៃបណ្តាញផ្លូវទៅកាន់តំបន់បេតិកភណ្ឌជនបទត្រូវបានកែលំអរួចហើយ។<br>-ផ្នែកខ្លះនៃផ្លូវនេះស្ថិតក្នុងការសាងសង់ ឥឡូវនេះ។ | △ |
| TR-8 | មធ្យោបាយដឹកជញ្ជូនសាធារណៈដែលមិនបំពុលពរិស្ថាន | អាជ្ញាធរអប្សរា | -រថយន្តអគ្គីសនីចំនួន ៥០ ត្រូវបានដាក់អោយដំណើរការក្នុងឧស្សានអង្គរ<br>-ការបង្កើនចំនួនរថយន្តអគ្គីសនីស្ថិតក្នុងផែនការនាយកដ្ឋានទេសចរ នៃអាជ្ញាធរអប្សរា។ | △ |
| TR-9 | សាងសង់ផ្លូវសំរាប់ជិះកង់ | អាជ្ញាធរអប្សរា | -គ្មានការវិវឌ្ឍន៍ | × |
| TR-10 | លើកកំពស់សមត្ថភាពស្ថាប័នសំរាប់ថែទាំផ្លូវ | មន្ទីរសាធារណៈការ និងដឹកជញ្ជូន មន្ទីរអភិវឌ្ឍន៍ជនបទ | -មានផែនការសកម្មភាពចំនួន ៣។<br>-គ្មានសកម្មភាពណាមួយត្រូវបានអនុវត្ត។ | × |

○: បានសាងសង់បញ្ចប់ △: មានការវិវត្តន៍មួយចំនួន ×: គ្មានការវិវត្តន៍

ប្រភព: ការសិក្សាតាមដាន

ការវិវត្តន៍នៃគំរោង/កម្មវិធីនីមួយៗត្រូវបានពិពណ៌នាដូចខាងក្រោម

TR-1 គំរោងកែលំអស្ពានសល់ពីសម័យបារាំង

ស្ពានសម័យបារាំងទី២ ត្រូវបានសាងសង់ឡើងប្រវែងប្រមាណ ២៧០ម៉ែត្រ មានទិសដៅផ្ទុយពីស្ពានសម័យបារាំងទី១ ដូចដែលបានបង្ហាញក្នុងរូបភាព ៣.៥ ។ ស្ពានទាំង ២នេះ ត្រូវបានប្រើប្រាស់ជាស្ពានឯកទិសដូចគ្នា ។




ប្រភព: រូបភាពពីលំហអាកាសរបស់ប្រទេសជប៉ុន ថតកាលពីថ្ងៃទី ១០ខែ តុលា ឆ្នាំ២០០៨

**រូបភាព ៣.៥ ទីតាំងស្ពានសម័យបារាំងទី២**

TR-2 ការកសាងផ្លូវរណបនឹងផ្លូវជាតិលេខ៦ (ដំណាក់កាលទី១)

បន្ទាត់ពណ៌ក្រហមក្នុងផែនទីខាងឆ្វេងនៃរូបភាព ៣.៦ បានបង្ហាញពីផ្លូវរណបនឹងផ្លូវជាតិលេខ៦ ដែលបានស្នើដោយផែនការមេ ។ បន្ទាត់ពណ៌ខ្មៅក្នុងផែនទីខាងស្តាំបានបង្ហាញពីផ្លូវក្រាលកៅស៊ូត្រឹមខែ មេសា ឆ្នាំ២០១០ ។ ដូចដែលបានឃើញក្នុងរូបភាព ៣.៦ ផ្លូវរណបនឹងផ្លូវជាតិលេខ៦ មិនទាន់ត្រូវបានសាងសង់បញ្ចប់នៅឡើយ ។




ប្រភព: ការសិក្សាផែនការមេ




ប្រភព: ការសិក្សាតាមដាន

**រូបភាព ៣.៦ ផ្លូវក្នុងដំណាក់កាលទី១ ដែលបានស្នើឡើង និងស្ថានភាពផ្លូវកៅស៊ូក្នុងពេលបច្ចុប្បន្ន**

## TR-3 ការកែលំអផ្លូវ ហ៊ុន សែន សន្តិភាព (ដំណាក់កាលទី២)

ផ្លូវពណ៌ខៀវក្នុងរូបភាព ៣.៧ គឺជាផ្លូវ ហ៊ុន សែន សន្តិភាព (ផ្លូវវាងក្រុង) ។ ផ្លូវនេះត្រូវបានសាងសង់ឡើងក្នុងឆ្នាំ២០០២ ហើយវាគឺជាផ្លូវគ្រួសក្រហមនៅពេលធ្វើផែនការមេ ។ បន្ថែមពីលើនោះ ស្ពានមួយដែលឆ្លងកាត់ស្ទឹងសៀមរាបមិនទាន់ត្រូវបានសាងសង់នៅឡើយ ។




ប្រភព: ការសិក្សាផែនការមេ

**រូបភាព ៣.៧ ផ្លូវ ហ៊ុន សែន សន្តិភាព (ដំណាក់កាលទី២)**



**រូបថត ៣-១ រូបភាពពីចំហៀងស្ពានផ្លូវវាងឆ្លងកាត់ស្ទឹងសៀមរាប**

ក្នុងពេលបច្ចុប្បន្ន ផ្លូវវាងក្រុងត្រូវបានអ៊ុតកៅស៊ូ ហើយស្ពានឆ្លងកាត់ស្ទឹងសៀមរាបក៏ត្រូវបានសាងសង់រួច។ នៅពេលការសិក្សាតាមដានបានចាប់ផ្តើម ក្នុងខែកុម្ភៈ ឆ្នាំ២០១០ ស្ពាននេះត្រូវបានបើកបំរើជាសាធារណៈរួចទៅហើយ ។ ផ្លូវវាងក្រុងជាមួយផ្លូវយុទ្ធសាស្ត្រ ត្រូវបានចាត់ជាផ្លូវវាងបញ្ចៀសរថយន្តធន់ធ្ងន់មិនអោយចូលក្នុងក្រុងតាមផ្លូវជាតិ



**រូបថត ៣-២ ស្ពានត្រូវបានបើកបំរើជាសាធារណៈ**

តែពីរថយន្តធន់ធ្ងន់ប៉ុណ្ណោះ។ ផ្លូវបញ្ចៀសនេះត្រូវបានដំណើរការដោយអាជ្ញាធរអប្សរា។ រូបថត ៣-៣ បង្ហាញពីស្លាកសញ្ញាណែនាំនៃផ្លូវបញ្ចៀសដែលបានដំឡើងនៅ លើផ្លូវជាតិលេខ៦ ចំងាយប្រមាណ ២.៧គីឡូម៉ែត្រភាគខាងលិចពីផ្លូវទៅកាន់ព្រលានយន្តហោះ។ រូបថត ៣-៤ បង្ហាញពីខ្លោងទ្វារយកប្រាក់នៅលើផ្លូវយុទ្ធសាស្ត្រឆ្ពោះទៅកាន់ផ្លូវវាង។ មានខ្លោងទ្វារយកប្រាក់មួយទៀតនៅភាគខាងកើតនៃផ្លូវវាង។




**រូបថត ៣-៣ ស្លាកសញ្ញាណែនាំនៃផ្លូវបញ្ចៀសដែលបានដំឡើងនៅលើផ្លូវជាតិលេខ៦**




**រូបថត ៣-៤ ខ្លោងទ្វារយកប្រាក់ និងស្លាកសញ្ញាណែនាំ**

TR-4 ការសាងសង់បញ្ចប់នូវបណ្តាញផ្លូវក្នុងក្រុងដល់ឆ្នាំ២០១២ (ដំណាក់កាលទី៣)

TR-5 ការសាងសង់បញ្ចប់នូវបណ្តាញផ្លូវក្នុងក្រុងដល់ឆ្នាំ២០២០ (ដំណាក់កាលទី៤)

បណ្តាញផ្លូវរណបក្នុងដំណាក់កាលទី៣ និងដំណាក់កាលទី៤ ដែលបានស្នើឡើង មានពណ៌បៃតង និងពណ៌ទឹកក្រូចក្នុងរូបភាពបន្តបន្ទាប់គ្នានៃរូបភាព ៣.៨។ នៅពេលដែលមានការប្រៀបធៀបជាមួយលក្ខខណ្ឌនៃបណ្តាញផ្លូវក្នុងពេលបច្ចុប្បន្នដែលបានបង្ហាញក្នុងរូបភាព ៣.៦ គេបានសង្កេតឃើញថា សមិទ្ធិផលជាក់លាក់មួយនៃការកែលំអផ្លូវត្រូវបានសំរេច ដែលបណ្តាញផ្លូវទាំងនោះត្រូវបានស្នើឡើង/បញ្ចូលក្នុងដំណាក់កាលទី៣ និងដំណាក់កាលទី៤។

គេបានកត់សំគាល់ឃើញថា ផែនការកែលំអផ្លូវក្នុងផែនការមេត្រូវបានបង្កើតឡើងក្រោមទិសដៅសេដ្ឋកិច្ចសង្គមដែលបានកំណត់ក្នុងផែនការមេ។ គេបានយល់ឃើញថា គំរោង TR1 រហូតដល់ TR3 ដែលត្រូវបានស្នើឡើងត្រូវបានគេរំពឹងទុកថានឹងត្រូវគេអនុវត្តជាបន្ទាន់ ហើយ TR4 និង TR5 ត្រូវបានគេរំពឹងទុកថានឹងត្រូវបានគេទទួលស្គាល់ត្រឹមឆ្នាំ២០១២ និងឆ្នាំ២០២០ជាបន្តបន្ទាប់។







ប្រភព: ផែនការមេ JICA

ប្រភព: ផែនការមេ JICA

**រូបភាព ៣.៨ បណ្តាញផ្លូវដែលបានស្នើឡើងក្នុងដំណាក់កាលទី៣ (ឆ្វេង) និងដំណាក់កាលទី៤ (ស្តាំ)**

TR-6 ការកែលំអស្ថាប័ន និងយុទ្ធនាការសុវត្ថិភាពចរាចរ

ផែនការមេបានកំណត់ផែនការសកម្មភាពចំនួន ៨ក្នុងកម្មវិធី TR-6 ។

(i) ការប្រកាសផ្សាយជាសាធារណៈនូវសវនកម្មសុវត្ថិភាពចរាចរ និងតំបន់ដែលមានគ្រោះថ្នាក់

(ii) ការកែលំអបរិស្ថានផ្លូវ និងការរចនាផ្លូវ

(iii) ការអប់រំអំពីសុវត្ថិភាពចរាចរដល់កុមារតូចៗ

(iv) ការអនុវត្តច្បាប់

(v) ការត្រួតពិនិត្យបច្ចេកទេសយានយន្ត

(vi) ការបណ្តុះបណ្តាលអ្នកបើកបរ

(vii) ការកែលំអជំនួយបន្ទាន់ចំពោះជនរងគ្រោះពីគ្រោះថ្នាក់ចរាចរ

(viii) យុទ្ធនាការសុវត្ថិភាពចរាចរសាធារណៈ

គ្មានការសំរេចណាមួយគួរអោយកត់សំគាល់ឡើយ ។

TR-7 គំរោងស្តារបណ្តាញផ្លូវទៅកាន់តំបន់បេតិកភណ្ឌជនបទ

ដើម្បីផ្សព្វផ្សាយអោយភ្ញៀវទេសចរស្នាក់នៅអោយបានយូរ និងទាក់ទាញភ្ញៀវទេសចរកំរិតខ្ពស់អោយមកក្រុងសៀមរាប វាជារឿងសំខាន់មួយក្នុងការកែលំអបណ្តាញផ្លូវទៅកាន់បេតិកភណ្ឌជនបទ ។ ផ្លូវជនបទភាគច្រើនដែលមានក្នុងបញ្ជីក្នុងផែនការមេត្រូវបានកែលំអរួចរាល់ហើយ ហើយកំណាត់ផ្លូវមួយចំនួនកំពុងស្ថិតក្នុងការសាងសង់ ។

TR-8 ការណែនាំអោយមានការប្រើប្រាស់សេវាដឹកជញ្ជូនសាធារណៈដែលមិនបំពុលបរិស្ថាន ក្នុងឧស្សានអង្គរ

ផែនការមេបានស្នើអោយមានរថយន្តក្រុងសាធារណៈដែលមិនបំពុលបរិស្ថានក្នុងឧស្សានអង្គរ និងហាម

ឃាត់មិនអោយមានរថយន្តផ្ទាល់ខ្លួន ដោយរាប់បញ្ចូលទាំងរថយន្តក្រុងទេសចរណ៍ចូលក្នុងឧស្សានអង្គរ។ អាជ្ញាធរអប្សរាបានណែនាំអោយមានការប្រើប្រាស់រថយន្តអគ្គីសនី និងបានចាប់ផ្តើមក្នុងតំបន់អង្គរធំ។ ផ្តើមចេញពីទស្សនៈអភិរក្សបេតិកភណ្ឌក្នុងឧស្សានអង្គរ និងទស្សនៈការពារការកើនកំដៅពិភពលោក ការបំពាក់រថយន្តអគ្គីសនីខាងក្នុង និងខាងក្រៅឧស្សានអង្គរគួរត្រូវបានបន្តលើកទឹកចិត្ត។

ការហាមឃាត់មិនអោយមានរថយន្តផ្ទាល់ខ្លួន និងរថយន្តក្រុងទេសចរណ៍ចូលក្នុងឧស្សានអង្គរដោយទីភ្នាក់ងារទេសចរណ៍ពុំទាន់ត្រូវបានអនុវត្តនៅឡើយ។ ការហាមឃាត់មិនអោយមានរថយន្តផ្ទាល់ខ្លួន និងរថយន្តក្រុងទេសចរណ៍ចូលក្នុងឧស្សានអង្គរ នឹងមានបញ្ហាយ៉ាងច្រើនត្រូវដោះស្រាយពាក់ព័ន្ធទៅនឹងផលប្រយោជន៍ផ្នែកឯកជន ដូចជាចំណូលរបស់អ្នករត់ម៉ូតូកង់បី។ អាជ្ញាធរអប្សរាត្រូវបានគេរំពឹងថានឹងបង្ហាញផ្លូវដើម្បីអោយមានការព្រមព្រៀងពីស្ថាប័នអង្គភាព និងបុគ្គលពាក់ព័ន្ធជាមុនសិន។






**រូបថត ៣-៥ រថយន្តអគ្គីសនីដែលត្រូវបានបំពាក់ក្នុងតំបន់អង្គរធំ**

TR-9 ការកសាងផ្លូវអ្នកជិះកង់ក្នុងឧស្សានអង្គរ

ផែនការមេបានស្នើអោយមានការសាងសង់ផ្លូវអ្នកជិះកង់នៅតាមផ្លូវដែលមានស្រាប់ក្នុងឧស្សានអង្គរដើម្បីអោយមានសុវត្ថិភាព និងផាសុកភាពទេសចរណ៍ជិះកង់ដោយបែងចែកចរាចរណ៍ដោយកង់ចេញពីចរាចរណ៍ដោយរថយន្ត។ រហូតមកទល់នឹងពេលនេះ ផ្លូវអ្នកជិះកង់មិនទាន់ត្រូវបានសាងសង់នៅឡើយ។

TR-10 លើកកំពស់សមត្ថភាពស្ថាប័នសំរាប់ថែទាំផ្លូវអោយមានប្រសិទ្ធភា

ដើម្បីអោយមានប្រសិទ្ធភាពជាអតិបរិមានូវការថែទាំផ្លូវ ផែនការមេបានស្នើអោយមានការអនុវត្តនូវកម្មវិធីចំនួន ៣ ដូចខាងក្រោមៈ

(i) ការរៀបចំបញ្ជីសារពើភណ្ឌផ្លូវ

(ii) ការត្រួតពិនិត្យស្ថានភាពផ្លូវ

(iii) ការសំរបសំរួលគោលនយោបាយថែទាំផ្លូវរវាងមន្ទីរសាធារណៈការ និងដឹកជញ្ជូន និងមន្ទីរ

អភិវឌ្ឍន៍ជនបទ។

កម្មវិធីដែលបានស្នើឡើងត្រូវបានគេរំពឹងទុកថា មន្ទីរសាធារណៈការ និងដឹកជញ្ជូននឹងអនុវត្ត។ ទោះបីជាយ៉ាងណាក៏ដោយ អាស្រ័យដោយថវិការបស់មន្ទីរសាធារណៈការ និងដឹកជញ្ជូនមានកំណត់ កម្មវិធីទាំងនេះមិនទាន់ត្រូវបានអនុវត្តនៅឡើយ។

# ជំពូក ៤ ផែនការអភិវឌ្ឍន៍ផ្នែកដែលបានជ្រើសរើស

## ៤.១ ផែនការកែលំអតំបន់កណ្តាលក្រុង

### ៤.១.១ ការត្រួតពិនិត្យឡើងវិញនូវផែនការកែលំអតំបន់កណ្តាលក្រុង

**(១) រចនាសម្ព័ន្ធរូបវ័ន្តនៃតំបន់តាំងទីលំនៅក្រុងសៀមរាប**

តំបន់តាំងទីលំនៅក្នុងក្រុង ដោយរាប់បញ្ចូលទាំងតំបន់ដែលមានប្រជាជនរស់នៅយ៉ាងណែន និងតំបន់ពង្រីកក្រុងនៃក្រុងសៀមរាប ត្រូវបានចាត់ចេញជា៧ប្រភេទនៃតំបន់តាំងទីលំនៅផ្អែកលើគុណៈនៃដីដែលប្រើប្រាស់ដង់ស៊ីតេការអភិវឌ្ឍន៍ និងតំបន់ដូចដែលមានខាងក្រោម និងបង្ហាញក្នុងរូបភាព ៤.១។

- **តំបន់មជ្ឈមណ្ឌលពាណិជ្ជកម្ម:** តំបន់នេះត្រូវបានកំណត់ជាតំបន់កណ្តាលក្រុងដែលមានមជ្ឈមណ្ឌលពាណិជ្ជកម្ម និងជំនួញជាមួយដីដែលមានផែនការប្រើប្រាស់ដោយរាប់បញ្ចូលទាំងមន្ត្រីរាជការក៏បានរស់នៅក្នុងតំបន់នេះដែរ។ បើទោះបីថា សាលាខេត្តបានផ្លាស់ប្តូរទីតាំងទៅតំបន់ភាគខាងកើតក្រៅក្រុងក៏ដោយ ក៏វាទាមទារនូវសេវាសំខាន់ៗ ដូចជា ធនាគារ ហាងលក់ទំនិញ ការិយាល័យប្រៃសណីយ៍ មន្ទីរពេទ្យនៅក្នុងតំបន់នោះផងដែរ។
- **តំបន់មជ្ឈមណ្ឌលពាណិជ្ជកម្មបន្ទាប់បន្សំ:** តំបន់នេះត្រូវបានកំណត់ជាតំបន់ក្បែរតំបន់មជ្ឈមណ្ឌលពាណិជ្ជកម្មដែលមានសកម្មភាពជំនួញ និងពាណិជ្ជកម្មដោយរាប់បញ្ចូលទាំងសកម្មភាពផ្នែកទេសចរណ៍ដែលបាននៅរាយប៉ាយជាមួយនឹងតំបន់តាំងទីលំនៅ។
- **តំបន់ដែលនៅក្បែរតំបន់កណ្តាលក្រុង :** តំបន់នេះមានទីតាំងនៅក្បែរតំបន់កណ្តាលក្រុង។ វាជាតំបន់តាំងទីលំនៅ ដែលមានការរស់នៅភាគច្រើនដោយប្រជាជនមានជីវភាពក៏រិតទាប និងរស់នៅរាយប៉ាយ លើកលែងតែការរស់នៅប្រកបអាជីវកម្មនៅតាមផ្លូវក្នុងតំបន់នេះ។
- **តំបន់របៀងក្រុង (ពាណិជ្ជកម្ម និងធុរកិច្ច):** តំបន់នេះត្រូវបានបង្កើតឡើងនៅតាមបណ្តាញផ្លូវរណបនឹងផ្លូវជាតិលេខ៦ និងផ្លូវខេត្តលេខ ២៣ និង ២៤ ដែលមានជំនួញ និងពាណិជ្ជកម្មដោយរាប់បញ្ចូល ទាំងសណ្ឋាគារធំៗ ភោជនីយដ្ឋាន និងហាងផ្សេងៗ ជាដើម។
- **តំបន់ក្រុង ខាងក្រៅផ្លូវវាងក្រុង :** តំបន់នេះត្រូវបានកំណត់ជាតំបន់ក្រុងដែលមានការរស់នៅតិចតួចស្ថិតនៅខាងក្រៅផ្លូវវាងក្រុង ដែលជាតំបន់កសិកម្ម និងតំបន់ដែលមានការអភិវឌ្ឍន៍ផ្ទះសំបែងសណ្ឋាគារ រោងចក្រ ស្ថាប័នអប់រំ ភោជនីយដ្ឋាន និងហាងផ្សេងៗ។
- **តំបន់បុរីសណ្ឋាគាររបស់អាជ្ញាធរអប្សរា (តំបន់ទេសចរណ៍ និងវប្បធម៌):** តំបន់នេះត្រូវបានរចនាដោយរដ្ឋាភិបាល សំរាប់ការអភិវឌ្ឍន៍ទេសចរណ៍ដោយរាប់បញ្ចូលទាំងសណ្ឋាគារ និងផ្នែក

ទេសចរណ៍ផ្សេងៗ នាពេលអនាគត បើទោះបីថាការអភិវឌ្ឍន៍នោះមិនទាន់បានអនុវត្តនៅឡើយ លើកលែងតែសារៈមន្ទីរសីហនុ (AEON) ។

- **តំបន់សាលាខេត្តថ្មី** ៖ តំបន់នេះត្រូវបានអភិវឌ្ឍក្នុងពេលថ្មីៗ (ក្នុងឆ្នាំ២០១០) ។ វាជាតំបន់ដែលមានបណ្តុំការិយាល័យរបស់សាលាខេត្ត និងមន្ទីររបស់ខេត្ត មានទីតាំងស្ថិតនៅក្នុងតំបន់២ ។

តំបន់កណ្តាលក្រុងដែលជាតំបន់ត្រូវរៀបចំដោយការសិក្សាតាមដានគឺជាតំបន់ស្នូលរបស់ក្រុងសៀមរាប ដែលមានភ្ញៀវទេសចរយ៉ាងច្រើនមកទស្សនា ដើរទិញឥវ៉ាន់ បរិភោគ និងទាក់ទាញដោយផលិតផលទេសចរណ៍ដែលជាទិសដៅទេសចរណ៍របស់ក្រុង ។




ប្រភព៖ ការសិក្សាតាមដាន

**រូបភាព ៤.១ ប្រភេទតំបន់ក្រុងក្នុងក្រុងសៀមរាប**

**(២) តំបន់កណ្តាលក្រុងក្នុងក្រុងសៀមរាប**

យោងទៅតាមប្រភេទនៃតំបន់តាំងទីលំនៅក្នុងក្រុងកាលពីមុន អត្តសញ្ញាណនៃតំបន់កណ្តាលក្រុងរួមមានតំបន់មជ្ឈមណ្ឌលពាណិជ្ជកម្ម និងតំបន់មជ្ឈមណ្ឌលពាណិជ្ជកម្មបន្ទាប់បន្សំ ដែលនឹងត្រូវបង្ហាញដូចរូបភាពខាងក្រោម ។ ដូចនេះ តំបន់មជ្ឈមណ្ឌលពាណិជ្ជកម្ម/តំបន់ផ្សារចាស់ និងតំបន់ជុំវិញក្រុងក្នុងផែនការមេ ត្រូវបានស្នើអោយកំណត់ឡើងវិញជាតំបន់មជ្ឈមណ្ឌលពាណិជ្ជកម្ម/តំបន់ផ្សារចាស់ និងតំបន់មជ្ឈមណ្ឌលពាណិជ្ជកម្មបន្ទាប់បន្សំ ដែលប្តូរមកពីតំបន់ជុំវិញក្រុង ។

តំបន់មជ្ឈមណ្ឌលពាណិជ្ជកម្ម ខ័ណ្ឌដោយដោយផ្លូវសំខាន់បី គឺផ្លូវស៊ីវុត្ថា ផ្លូវប៉ូកំបោរ និងផ្លូវជាតិលេខ៦ ។ នៅតាមបណ្តោយផ្លូវទាំងនោះ មានសណ្ឋាគារលំដាប់ថ្កាយ៣-៤ ធំៗ ព្រះរាជដំណាក់ មន្ទីរពេទ្យធំៗ ចំនួន២ និងតំបន់ផ្សារចាស់ដែលមានភោជនីយដ្ឋាន កន្លែងលក់ភេសជ្ជៈ ហាងកាហ្វេ ផ្សារចាស់ និងផ្សារកណ្តាល ។ តំបន់មជ្ឈមណ្ឌលពាណិជ្ជកម្មបន្ទាប់បន្សំ ខ័ណ្ឌដោយផ្លូវជាច្រើនដែលមានផ្ទះសំណាក់ ភោជនីយដ្ឋាន និងកន្លែងលក់ភេសជ្ជៈដែលត្រូវបានអភិវឌ្ឍក្នុងតំបន់តាំងទីលំនៅ ។




ប្រភព: ការសិក្សាតាមដាន

**រូបភាព ៤.២ ទីតាំងនៃតំបន់កណ្តាលក្រុង**

## (៣) វិធីសាស្ត្រសំរាប់ការកែលំអតំបន់កណ្តាលក្រុង

១) ទស្សនវិស័យផ្តែករៀបចំក្រុងក្នុងផែនការមេដែលត្រូវរក្សា

ទស្សនវិស័យអភិវឌ្ឍន៍សម្រាប់ក្រុងសៀមរាបនៅក្នុងផែនការមេត្រូវបានគេកំណត់ជា ទីក្រុងទេសចរណ៍ *លួងក និងប្រកបដោយសោភ័ណភាព ដោយផ្តែកលើភាពចុះសម្រុងគ្នានៃប្រវត្តិសាស្ត្រ សិល្បៈ និង ធម្មជាតិ របស់ខ្មែរ* ។ ទោះបីជាការអភិវឌ្ឍនាពេលថ្មីៗនេះ នាំមកនូវការផ្លាស់ប្តូរមួយចំនួនដែលទាក់ទងទៅនឹងរចនាសម្ព័ន្ធក្រុង និងលក្ខខណ្ឌសេដ្ឋកិច្ច-សង្គមក៏ដោយ ក៏ទស្សនវិស័យនេះ អាចត្រូវបានគេពិចារណាថានៅតែមានតម្លៃ ដើម្បីតម្រង់តួនាទី និងមុខងារនៃក្រុងសៀមរាបអោយទៅជាទីក្រុងទេសចរណ៍ ជាមួយនិងបេតិកភណ្ឌពិភពលោក។ ដូចនេះហើយ ទស្សនវិស័យនេះ គួរតែត្រូវបានថែរក្សាទុកជាទិសដៅដ៏សំខាន់សម្រាប់ការអភិវឌ្ឍន៍។

២) គោលដៅសំរាប់ការកែលំអតំបន់កណ្តាលក្រុងដើម្បីសំរេចទស្សនវិស័យ

តំបន់កណ្តាលក្រុងដែលគឺជាតំបន់ស្នូលនៃក្រុងសៀមរាប បានដើរតួនាទីយ៉ាងសំខាន់ក្នុងការតំណាងអោយការអភិវឌ្ឍន៍ទស្សនវិស័យ ដែលបានលើកឡើងខាងលើ។ ទោះបីជាបែបនេះក្តី វាជាការចាំបាច់សំរាប់តំបន់កណ្តាលក្រុង ក្នុងការបង្កើតនូវគោលដៅអោយបានរឹងមាំដើម្បីសំរេចដោយទស្សនៈរួម និងច្បាស់លាស់របស់ស្ថាប័នអង្គភាពពាក់ព័ន្ធដែលទទួលខុសត្រូវនូវលក្ខខណ្ឌជាក់លាក់ណាមួយនៃតំបន់កណ្តាលក្រុងនេះ។

តំបន់កណ្តាលក្រុងមានមុខងារច្រើន និងជាទីកន្លែងដែលភ្ញៀវទេសចរស្នាក់នៅ និងជាទិសដៅទេសចរណ៍បេតិកភណ្ឌពិភពលោករង។ វារួមមានសកម្មភាពសេដ្ឋកិច្ចសង្គមនៃប្រជាជនដើម្បីធ្វើការងារ រស់នៅ និងជាមជ្ឈមណ្ឌលសេវាកម្មក្រុង។ បន្ថែមពីលើនោះ តំបន់កណ្តាលក្រុងក៏ពាក់ព័ន្ធក្នុងតំបន់ដែលត្រូវការពារទេសភាពវប្បធម៌ (តំបន់៣) សំរាប់បេតិកភណ្ឌពិភពលោកផងដែរ។

គោលដៅកែលំអសំរាប់តំបន់កណ្តាលក្រុងបានតំណាងអោយទស្សនវិស័យនៃក្រុងសៀមរាបដែលមានការទទួលខុសត្រូវនូវតួនាទី និងមុខងាររបស់ខ្លួន ដែលបានកំណត់ដូចខាងក្រោម:




ប្រភព: ការសិក្សាតាមដាន

**រូបភាព ៤.៣ ទស្សនវិស័យផ្នែករៀបចំក្រុង និងគោលដៅសំរាប់ការកែលំអតំបន់កណ្តាលក្រុង**

## (៤) បញ្ហាផ្នែករៀបចំក្រុងក្នុងពេលបច្ចុប្បន្ន និងវិធីសាស្ត្រកែលំអតំបន់កណ្តាលក្រុង

### ១) បញ្ហាផ្នែករៀបចំក្រុងក្នុងពេលបច្ចុប្បន្ន

ដូចដែលបានលើកឡើងក្នុងផ្នែកមុនសំរាប់ការអភិវឌ្ឍន៍ក្នុងពេលបច្ចុប្បន្ន និងការផ្លាស់ប្តូរក្នុងតំបន់ក្រុងសៀមរាប បញ្ហាអភិវឌ្ឍន៍ក្នុងក្រុងត្រូវបានផ្លាស់ប្តូរឆ្ពោះទៅកាន់ដំណាក់កាលបន្ទាប់នៃការអភិវឌ្ឍន៍ដើម្បីលៃលកជាមួយនឹងជីវភាពរស់នៅ ទេសចរណ៍ក្នុងក្រុង និងកំណើនភ្ញៀវទេសចរ និងចំនួនប្រជាជន ដែលការផ្តល់នូវហេដ្ឋារចនាសម្ព័ន្ធជាមូលដ្ឋានត្រូវបានវិវត្ត ដូចជាប្រព័ន្ធបង្ហូរទឹក និងផ្គត់ផ្គង់ទឹកស្អាតជាដើម ។

ដោយឡែក បណ្តាញផ្លូវក្នុងតំបន់ដោយរាប់បញ្ចូលទាំងផ្លូវតូចៗក្នុងតំបន់តាំងទីលំនៅ និងប្រព័ន្ធបង្ហូរទឹកនៅតែមិនល្អដដែលក្នុងតំបន់មជ្ឈមណ្ឌលពាណិជ្ជកម្មបន្ទាប់បន្សំ និងតំបន់តាំងទីលំនៅផ្សេងៗទៀតក្នុងក្រុង បើទោះបីថា គំរោងផ្នែកសុរិយោដី (LMAP) ដែលបានរឹបអូសយកដីដោយស្របច្បាប់ដើម្បីកែលំអផ្លូវតូចៗត្រូវបានអនុវត្តជាបណ្តើរៗយ៉ាងណាក៏ដោយ ។

តំបន់កណ្តាលក្រុងដែលមានភ្ញៀវទេសចរ និងប្រជាជនរីករាយនឹងសេវាកម្មក្នុងក្រុង និងភាពទាក់ទាញ

ផ្នែកទេសចរណ៍ដែលមានសារៈសំខាន់បំផុតសំរាប់វិស័យទេសចរណ៍ ទាមទារអោយមានការកែលំអអោយកាន់តែមានភាពទាក់ទាញ និងមានប្រសិទ្ធិភាពតាមរយៈនៃការផ្តល់អោយមាននូវហេដ្ឋារចនាសម្ព័ន្ធអោយបានគ្រប់គ្រាន់ ប្រព័ន្ធដឹកជញ្ជូន និងការគ្រប់គ្រងរបស់ខ្លួនជាមួយនឹងឧបសគ្គនានាសំរាប់ការអភិវឌ្ឍន៍ក្រុង ស្ថិតក្រោមការហាមឃាត់នៃតំបន់៣ ដែលជាតំបន់ការពារទេសភាពវប្បធម៌។

## តារាង ៤.១ បញ្ហានាពេលបច្ចុប្បន្នស្តីពីការអភិវឌ្ឍន៍ក្រុង

| បញ្ហានាពេលបច្ចុប្បន្នស្តីពីការអភិវឌ្ឍន៍ក្រុង | រចនាសម្ព័ន្ធតំបន់ក្រុង | | | | | | |
|---|---|---|---|---|---|---|---|
| | តំបន់កណ្តាលក្រុង | | តំបន់របៀងក្រុង (ពាណិជ្ជកម្ម និងធុរកិច្ច) | តំបន់សណ្ឋាគារអប្សរា *(ទីក្រុងវប្បធម៌ និងទេសចរណ៍)* | តំបន់ក្រុង (នៅខាងក្នុងផ្លូវវាងក្រុង) | តំបន់ក្រុង (នៅខាងក្រៅផ្លូវវាងក្រុង) | តំបន់សាលាខេត្តថ្មី |
| | តំបន់ពាណិជ្ជកម្មកណ្តាល | ជាយតំបន់ពាណិជ្ជកម្មកណ្តាល | | | | | |
| ១. ការអភិវឌ្ឍន៍លំនៅដ្ឋាន/ក្រុងដោយគ្មានផែនការបែងចែកតំបន់ | -- | ● | ● | -- | ● | ○ | -- |
| ២. ការអភិវឌ្ឍន៍ផ្ទះសំណាក់សម្រាប់ទីផ្សារទាប និងភ្ញៀវទេសចរក្នុងស្រុកដែលបង្កើនការលាយឡំគ្នាសម្រាប់ទេសចរណ៍ និងលំនៅដ្ឋាន | -- | ● | ○ | -- | △ | -- | -- |
| ៣. ការអភិវឌ្ឍន៍សមត្ថភាព និងសេវាកម្ម នៅមានកំរិត ឬមានការខ្វះខាត | -- | ○ | ○ | -- | ● | ○ | ○ |
| ៤. កំរិតនៃការកែលម្អ/អភិវឌ្ឍតំបន់ទេសចរណ៍នៅមានកំរិត | ● | ● | ● | ● | △ | △ | -- |
| ៥. កំរិតនៃការកែលម្អផ្លូវថ្នល់/ការគ្រប់គ្រងចរាចរមិនគ្រប់គ្រាន់ | ● | ● | ○ | ○ | △ | -- | -- |
| ៦. ហេដ្ឋារចនាសម្ព័ន្ធនិងបរិក្ខាសាធារណៈមិនគ្រប់គ្រាន់នៅក្នុងតំបន់តាំងទីលំនៅ | △ | ● | ○ | -- | ○ | ○ | ○ |
| ៧. ការពង្រឹងការអភិរក្សសម្រាប់ការខូចខាតនៃបរិស្ថានវប្បធម៌ និងធម្មជាតិ | ● | ● | ○ | ○ | ○ | ○ | ● |

កំណត់សម្គាល់ :

●= បញ្ហាបន្ទាន់ និងសំខាន់ ○ = ត្រូវពិចារណា ប៉ុន្តែមិនសូវបន្ទាន់

△= បញ្ហាតូចតាច ឬមិនសំខាន់ -- = មិនមានការប៉ះពាល់

ប្រភព: ការសិក្សាតាមដាន

២) បញ្ហា គោលដៅ និងកម្មវិធីសំរាប់ការកែលំអតំបន់កណ្តាលក្រុង

យោងទៅលើវិធីសាស្រ្តផ្នែករៀបចំក្រុងចំនួន ៣ របស់ផែនការមេកាលពីមុនដែលលើលឡើង ១) ការបង្កើតក្រុងរណប ២)ការអភិវឌ្ឍន៍ឡើងវិញនូវតំបន់ក្រុង និងការធ្វើសមាហរណកម្មតំបន់ផ្សារចាស់ និង ៣)ការអភិវឌ្ឍន៍បណ្តាញផ្លូវក្នុងក្រុង និងហេដ្ឋារចនាសម្ព័ន្ធ ការកែលំអតំបន់កណ្តាលក្រុងទាមទារអោយមានតួនាទី និងមុខងារកែលំអប្រកបដោយភាពប៉ិនប្រសព្វបន្ថែមទៀត ដើម្បីអោយសក្តិសមទៅនឹងលក្ខណៈ និងមុខងារចាំបាច់នៃតំបន់កណ្តាលក្រុង ដោយគិតគូពីបញ្ហាអភិវឌ្ឍក្រុងក្នុងពេលបច្ចុប្បន្ន ជាពិសេស បញ្ហាផ្នែកគមនាគមន៏ចរាចរណ៏ និងការ អភិរក្សបេតិកភណ្ឌក្រុង។ រូបភាពខាងក្រោមនេះ ពិពណ៌នាពីគោលដៅ និងកម្មវិធីសំរាប់កែលំអតំបន់កណ្តាលក្រុង។

រូបភាព ៤.៤ បង្ហាញពីបញ្ហាសំរាប់ផ្នែករៀបចំក្រុង និងកម្មវិធី និងគោលដៅសំរាប់ការកែលំអតំបន់កណ្តាលក្រុង ក្នុងក្រុងសៀមរាប ។




ប្រភព: ការសិក្សាតាមដាន

**រូបភាព ៤.៤ វិធីសាស្រ្តផ្នែករៀបចំដែលត្រូវបានចំរាញ់ដើម្បីធ្វើកែលំអតំបន់កណ្តាលក្រុង**

## ៤.១.២ ផែនការកែលំអសំរាប់តំបន់កណ្តាលក្រុង

### (១) ទស្សនៈអភិវឌ្ឍរូបវ័ន្តសំរាប់ការកែលំអតំបន់កណ្តាលក្រុង

តំបន់កណ្តាលក្រុងបានដើរតួនាទីយ៉ាងសំខាន់ក្នុងការបង្កើតនូវរចនាសម្ព័ន្ធក្រុងដែលជាសេវាកម្មក្រុងដែល

មានបេតិកភណ្ឌពិភពលោក និងជាគោលដៅទេសចរណ៍។ តំបន់កណ្តាលក្រុងក៏បានតភ្ជាប់ទៅនឹងគោលដៅទេសចរណ៍សំខាន់ៗនានា នៃតំបន់អង្គរដែលមានបេតិកភណ្ឌពិភពលោក តំបន់បឹងទន្លេសាប និងតំបន់ទេសចរណ៍ក្រុងផ្សេងៗទៀតនៅតាមផ្លូវជាតិលេខ៦។

ស្ថិតក្នុងបរិបទនៃមុខងាររូបវ័ន្ត តំបន់កណ្តាលក្រុងគួរត្រូវបានធ្វើអោយប្រសើរឡើងដោយតភ្ជាប់ទៅកាន់គោលដៅទេសចរណ៍សំខាន់ៗប្រកបដោយប្រសិទ្ធភាព។ ពាក្យថា "តភ្ជាប់" ពុំត្រឹមតែមានន័យថា ការតភ្ជាប់ប្រព័ន្ធដឹកជញ្ជូន និងផ្លូវថ្នល់ប៉ុណ្ណោះទេ ប៉ុន្តែវាក៏មានន័យដល់ការតភ្ជាប់ ដូចជាប្រព័ន្ធពត៌មាន ទំនាក់ទំនង សកម្មភាពវប្បធម៌ និងសង្គមក្នុងប្រទេសកម្ពុជាទៅនឹងពិភពលោក។ ខាងក្រោមនេះ គឺជារូបភាពដែលបង្ហាញពីទំនាក់ទំនងរូបវ័ន្តនៃតំបន់កណ្តាលក្រុង។




ប្រភព: ការសិក្សាតាមដាន

**រូបភាព ៤.៥ មុខងាររូបវ័ន្តសំរាប់ការកែលំអតំបន់កណ្តាលក្រុង**

## (២) កម្មវិធីសំរាប់កែលំអតំបន់កណ្តាលក្រុង

ដើម្បីសំរេចគោលដៅសំរាប់កែលំអតំបន់កណ្តាលក្រុង កម្មវិធីចំនួន ៤ ត្រូវបានបង្កើតដោយផ្អែកលើវិធីសាស្ត្រខាងលើ។ កម្មវិធីនីមួយៗត្រូវបានបង្កើតឡើងដោយគំរោងជាច្រើន។ តារាង ៤.២ ខាងក្រោម បង្ហាញពីគំរោង និងកម្មវិធីដែលបានស្នើឡើងសំរាប់ការកែលំអតំបន់កណ្តាលក្រុង។

<u>កម្មវិធីទី១: ការធ្វើអោយប្រសើរឡើងនូវភាពទាក់ទាញទេសចរណ៍ក្រុង និងមុខងារ</u>

តំបន់កណ្តាលក្រុងដែលជាគោលដៅទេសចរណ៍មួយ បានដើរតួនាទីយ៉ាងសំខាន់ក្នុងការបង្វែរសកម្មភាពទេសចរណ៍បែបប្រវត្តិសាស្ត្រ ពីតំបន់អង្គរដែលមានបេតិកភណ្ឌពិភពលោក។ ដោយគិតគូពិចារណាអំពីសមត្ថភាពផ្ទុករបស់បេតិកភណ្ឌពិភពលោក វាជារឿងមួយដែលមិនជៀសរួចសំរាប់ក្រុងសៀមរាបដែលត្រូវតែធ្វើអោយប្រសើរឡើងនូវភាពទាក់ទាញទេសចរណ៍ក្រុង ដោយការកែលំអបរិក្ខាសាធារណៈ តាមរយៈការផ្សព្វផ្សាយជា

សាធារណៈ និងភាពជាដៃគូឯកជន។ ជាងនេះទៅទៀត វានឹងចូលរួមចំណែកក្នុងការធ្វើអោយប្រសើរឡើងនូវសេដ្ឋកិច្ច និងឧស្សាហកម្មក្រុងស្រុក។

កម្មវិធីទី២: ពង្រឹងការគ្រប់គ្រងចល័តភាព

ការដឹកជញ្ជូន និងផ្លូវថ្នល់សមរម្យ និងមានផាសុកភាពគឺជារឿងមួយមិនអាចជៀសរួច មិនត្រឹមតែសំរាប់ភ្ញៀវទេសចរប៉ុណ្ណោះទេ គឺថែមទាំងសំរាប់ប្រជាជនផងដែរ ដែលមិនត្រឹមតែមានការគិតពិចារណាដល់គុណភាពនៃសេវាកម្មដឹកជញ្ជូនភ្ញៀវទេសចរប៉ុណ្ណោះទេ គឺថែមទាំងសេវាដឹកជញ្ជូនប្រកបដោយប្រសិទ្ធភាពសំរាប់សកម្មភាពសេដ្ឋកិច្ចសង្គមក្នុងស្រុកផងដែរ។ ជាការពិតណាស់ រាល់បែបផែននៃចរាចរណ៍របស់រថយន្តក្រុងទេសចរណ៍ រថយន្តក្រុងខ្នាតតូច ម៉ូតូឌុប ម៉ូតូកង់បី និងកង់ជាដើម ទាមទារអោយមានការគ្រប់គ្រង និងត្រួតពិនិត្យនូវចល័តភាពរបស់វាដើម្បីដំណើរការអោយមានប្រសិទ្ធភាព និងកាត់បន្ថយនូវផលប៉ះពាល់អវិជ្ជមានទៅលើប្រព័ន្ធដឹកជញ្ជូន និងបរិស្ថានក្នុងក្រុង។

កម្មវិធីទី៣: ការអភិរក្ស និងការប្រើប្រាស់បេតិកភណ្ឌក្រុង និងធម្មជាតិ

អាគារសល់ពីសម័យបារាំង ប្រាសាទ ស្ទឹងសៀមរាប និងដើមឈើធំៗ គឺមានតែមួយ និងជាទេសភាពដ៏មានតំលៃរបស់តំបន់កណ្តាលក្រុង។ វាមានសារៈសំខាន់ខ្លាំងណាស់សំរាប់តំបន់កណ្តាលក្រុងដើម្បីបង្ហាញពីចារិកលក្ខណៈ និងរូបភាពនៃទីក្រុងដែលបានដើរតួនាទីយ៉ាងសំខាន់ក្នុងការបង្កើតនូវអត្តសញ្ញាណ និងកិត្យានុភាពរបស់ក្រុង។ រដ្ឋបាលខេត្តគួរតែថែរក្សានូវបេតិកភណ្ឌក្រុងទាំងអស់នេះ និងអភិរក្សនូវទេសភាពក្រុងបែបប្រពៃណី និងប្រវត្តិសាស្ត្រ និងប្រើប្រាស់នូវសក្តានុពលនៃទ្រព្យសម្បត្តិទាំងនេះ។

កម្មវិធីទី៤: ការធ្វើអោយប្រសើរឡើងនូវការគ្រប់គ្រងក្រុង និងសមត្ថភាពរបស់វាក្នុងការធ្វើអោយរស់រានឡើងវិញ និងការប្រើប្រាស់ដីធ្លីប្រកបដោយប្រសិទ្ធភាព

តំបន់កណ្តាលក្រុង ពាក់ព័ន្ធដល់តំបន់៣ (ដែលជាតំបន់ការពារវប្បធម៌) ទាមទារអោយមានការរៀបចំអោយបានល្អ និងយកចិត្តទុកដាក់ តាមរយៈការប្រើប្រាស់ដីធ្លីក្នុងកំរិតខ្ពស់ ដើម្បីជៀសវាងការធ្លាក់ចុះនូវបរិស្ថានបែបប្រវត្តិសាស្ត្ររបស់តំបន់បេតិកភណ្ឌពិភពលោកអង្គរ។ ស្ថិតក្នុងស្ថានភាពនៃតំបន់កណ្តាលក្រុងបែបនេះ ជំនាញក្នុងការគ្រប់គ្រងក្រុង និងសមត្ថភាពរបស់មន្ត្រីរាជការជាមួយនឹងការណែនាំគឺជាការចាំបាច់មួយមិនអាចជៀសរួចដើម្បីធានាដល់ការកែលំអ ឬអភិវឌ្ឍន៍តំបន់កណ្តាលក្រុងនេះ។

## តារាង ៤.២ គំរោងកែលំអដែលបានស្នើឡើងញដោយកម្មវិធីនីមួយៗ

| កម្មវិធីដែលបានស្នើឡើង | គំរោងដែលបានស្នើឡើង | រយៈពេលខ្លី (៣ ឆ្នាំ) | រយៈពេលមធ្យម (៥ ឆ្នាំ) | រយៈពេលវែង (១០ ឆ្នាំ) | ភ្នាក់ងារទទួលខុសត្រូវ |
|---|---|---|---|---|---|
| ១. ការធ្វើអោយប្រសើរឡើងនូវភាពទាក់ទាញទេសចរក្រុង និងមុនងារ | ១-១ ការកែលំអផ្លូវក្នុងតំបន់ផ្សារចាស់ជាមួយគំរោងសាកល្បងដែលឆ្លើយតបឆាប់រហ័ស | | | | - |
| | ១-១-១ ការអភិវឌ្ឍន៍ផ្សារអ្នកថ្មើរជើង | | | | DPWT |
| | ១-១-២ គំរោងសាកល្បង | | | | DPWT/MG |
| | ១-២ ការអភិវឌ្ឍន៍ឧស្សានតូចៗនៅកែងផ្លូវក្នុងតំបន់ផ្សារចាស់ | | | | - |
| | ១-២-១ ការអភិវឌ្ឍន៍ឡើងវិញនូវសួនច្បារក្នុងតំបន់សាលាមត្តេយ្យ | | | | DTC |
| | ១-២-២ ការអភិវឌ្ឍន៍ទីធ្លា | | | | DPWT |
| | ១-៣ ការរៀបចំក្រុមការងារសំរាប់កែលំអតំបន់ផ្សារចាស់ជាមួយសមាគមក្នុងតំបន់ | | | | - |
| | ១-៣-១ ការបង្កើតក្រុមការងារសំរាប់កែលំអតំបន់ផ្សារចាស់ | | | | PG / MG |
| | ១-៣ ការគ្រប់គ្រង និងដំណើរការគណៈកម្មការអភិវឌ្ឍន៍ | | | | PG / MG |
| | ១-៤ ការបង្កើតបណ្តាញជូរពណ៌បៃតង | | | | DPWT |
| | ១-៥ បង្កើតបណ្តាញផ្លូវអ្នកថ្មើរជើង | | | | - |
| | ១-៥-១ ការរៀបចំផ្លូវអ្នកថ្មើរជើង តែម្ខាង | | | | DPWT/DLMUPC |
| | ១-៥-១ ការរៀបចំខ្សែភ្លើងក្រោមដី | | | | ក្រុមហ៊ុន អគ្គិសនី |
| | ១-៦ ការអភិវឌ្ឍន៍ទីធ្លា | | | | DPWT |
| ២.ការពង្រឹងការគ្រប់គ្រងចល័តភាព | ២-១ ការគ្រប់គ្រងចរាចររួម( ចំណតសាធារណៈ តំបន់សំរាប់តែដើរ ការត្រួតពិនិត្យផ្លូវឯកទិស ។ល។) | | | | - |
| | ២-១-១ ការសិក្សាស្តីពីការគ្រប់គ្រងចរាចរណ៍ | | | | DPWT / PPO |
| | ២-១-២ គំរោងសាងសង់ស្ថានីយ៍ឆ្លងកាត់រថយន្តក្រុងភ្ញៀវទេសចរ | | | | DPWT |
| | ២-១-៣ ការប្រតិបត្តិដំណើរការ និងការគ្រប់គ្រងចរាចរណ៍ | | | | DPWT / PPO |
| | ២-២ ប្រព័ន្ធរថយន្តក្រុងទេសចររួម ( ប្រព័ន្ធចរាចរណ៍) | | | | - |
| | ២-២-១ ការសិក្សាស្តីពីភាពអាចធ្វើទៅបានសំរាប់ការដាក់បង្ខាំង ឬការបង្កើតរថយន្តក្រុងភ្ញៀវទេសចរណ៍ | | | | ផ្នែកឯកជន |
| | ២-២-២ ការដំណើរការ និងការគ្រប់គ្រងរថយន្តក្រុងរួម | | | | ផ្នែកឯកជន |
| | ២-៣ ការបង្កើតបណ្តាញផ្លូវអ្នកជិះកង់ដែលមិនបំពុលបរិស្ថាន | | | | DPWT |
| | ២-៤ ការផ្សព្វផ្សាយនៃជំនួញចំណតឯកជន | | | | DPWT / PPO |
| ៣. ការអភិរក្ស និងប្រើប្រាស់បេតិកភណ្ឌក្រុង និងធម្មជាតិ | ៣-១ ការអភិរក្សបេតិកភណ្ឌក្រុង និងដើមឈើចាស់ៗនៅតាមផ្លូវ | | | | PG / APSARA |
| | ៣-២ ការកែលំអផ្ទាំងពតិមានបេតិកភណ្ឌក្រុង | | | | DCA / APSARA |
| | ៣-៣ ការអភិរក្ស និងកែលំអនៃតំបន់ដងស្ទឹងសៀមរាប | | | | APSARA |
| ៤. ការធ្វើអោយប្រសើរឡើងនូវការគ្រប់គ្រងក្រុង និងសម្ថភាពរបស់វា | ៤-១ ការអភិវឌ្ឍន៍សមត្ថភាពសំរាប់ការរៀបចំក្រុង និងការអនុវត្ត ( ត្រួតពិនិត្យ និងណែនាំ) | | | | - |
| | ៤-១-១ ការអភិវឌ្ឍន៍សមត្ថភាពដើម្បីអនុវត្តការគ្រប់គ្រងតំបន់ | | | | DLMUPC / MG |
| | ៤-១-២ ការអភិវឌ្ឍន៍ជំនាញរៀបចំក្រុង | | | | DLMUPC / MG |
| | ៤-២ ពង្រឹងយន្តការសំរបសំរួល និងសហប្រតិបត្តិការក្នុងចំណោមអាជ្ញាធរអភិវឌ្ឍន៍ក្រុង | | | | PG |
| | ៤-៣ សេចក្តីណែនាំការអភិរក្សទេសភាពក្រុងនៅក្នុងតំបន់កណ្តាលក្រុង | | | | PG |

ប្រភព: ការសិក្សាតាមដាន

## (៣) ផែនការកែលំអរូបវ័ន្តសំរាប់តំបន់កណ្តាលក្រុង

គំរោងដែលបានស្នើឡើងក្នុងកម្មវិធីនីមួយៗ ត្រូវបានកំណត់ជាផែនការកែលំអរយៈពេលវែង ក្នុងតំបន់កណ្តាលក្រុងជាមួយនឹងការអភិវឌ្ឍន៍ស្នូល ឬផ្ទាំងដូចជា ស្ថានីយ៍ប្តូររថយន្តក្រុង ទីធ្លាសាធារណៈ និងការតំរង់ ឬការអភិវឌ្ឍន៍បណ្តាញផ្លូវថ្មើជើង សសរបៃតង និងការអភិវឌ្ឍន៍ប្រកបដោយភាពឆ្លាតវៃនៃតំបន់ត្រួតពិនិត្យចរាចរណ៍ ឬការរចនាតំបន់សំរាប់តែដើរ ។

រូបភាព ៤.៦ បង្ហាញនូវផែនការកែលំអទៅថ្ងៃអនាគតដែលបានស្នើឡើងសំរាប់តំបន់កណ្តាលក្រុង ផ្អែកលើកម្មវិធីនីមួយៗដែលបានស្នើឡើងក្នុងផ្នែកមុន លើកលែងតែកម្មវិធីកែលំអក្នុងកម្មវិធីទី៤ ( ការធ្វើអោយ

ប្រសើរឡើងនូវការគ្រប់គ្រងក្រុង និងសមត្ថភាពរបស់វាក្នុងការធ្វើអោយរស់រានឡើងវិញ និងការប្រើប្រាស់ដីធ្លីប្រកបដោយប្រសិទ្ធភាព ) ។ ទោះបីជាយ៉ាងណាក៏ដោយ គេបានកត់សំគាល់ឃើញថា ការសិក្សាលំអិតបន្ថែមទៀតនឹងទាមទារអោយមានការអនុវត្តបន្ថែម ដូចផែនការដែលបានបង្ហាញ




ប្រភព: ការសិក្សាតាមដាន

**រូបភាព ៤.៦ មូលបទនៃការកែលំអតំបន់កណ្តាលក្រុង រយៈពេលវែង**

## (៤) ផែនការកែលំអរូបវ័ន្តសំរាប់តំបន់ផ្សារចាស់

យោងទៅលើគំរោងសំខាន់ៗសំរាប់តំបន់ផ្សារចាស់ ផែនការកែលំអរូបវ័ន្តត្រូវបានស្នើឡើងក្នុងរូបភាព ៤.៧។ ផែនការរូបវ័ន្តបានបង្ហាញទីតាំងរបស់សមាសធាតុគំរោងដែលពាក់ព័ន្ធ។

- គំរោង ១-១ (ការកែលំអផ្លូវក្នុងតំបន់ផ្សារចាស់ជាមួយគំរោងសាកល្បង): គោលបំណងនៃគំរោង នេះគឺផ្តោតទៅលើការបង្កើតតំបន់អ្នកថ្មើរជើងប្រកបដោយសុវត្ថិភាពសំរាប់សកម្មភាពភ្ញៀវទេសចរណ៍បែបទីក្រុងដែលជាច្រកទេសចរណ៍អន្តរជាតិមួយ។ វានឹងចូលរួមចំណែកធ្វើអោយប្រសើរឡើងនូវសកម្មភាពភ្ញៀវទេសចរ ហើយវាក៏អាចបង្កើតនូវឥទ្ធិពលវិជ្ជមានសំរាប់សេដ្ឋកិច្ច និងមុខជំនួញក្នុងតំបន់។
- គំរោង ១-២ (ការអភិវឌ្ឍន៍សួនតូចៗនៅកែងផ្លូវក្នុងតំបន់ផ្សារចាស់) : គោលបំណងនៃគំរោងនេះគឺផ្តល់នូវចំណតក្នុងតំបន់ផ្សារចាស់ និងបំពាក់នូវសំភារៈតាមផ្លូវសំរាប់ការសំរាក និងស្ថានីយ៍ឆ្លងកាត់រថយន្តក្រុង ជាមួយនឹងសេវារថយន្តក្រុងទេសចរណ៍រួម។
- ផ្នែកមួយនៃគំរោង ១-៤ (ការបង្កើតជួរពណ៌បៃតង) និងផ្នែកនៃគំរោង ១-៥ (ការបង្កើតបណ្តាញផ្លូវអ្នកថ្មើរជើង: គោលបំណងនៃគំរោងនេះ មិនត្រឹមតែផ្តល់នូវសោភណ្ឌភាពសល់ពីសម័យបារាំងប៉ុណ្ណោះទេ ប៉ុន្តែវាក៏បានផ្តល់នូវម្លប់ពណ៌បៃតង និងមានសុវត្ថិភាពសំរាប់ការសប្បាយនឹងទេសភាពក្រុង។
- ផ្នែកមួយនៃគំរោង ២-១ (ការគ្រប់គ្រងចរាចរណ៍ដែលត្រូវបានធ្វើសមាហរណ៍កម្ម) និងផ្នែកមួយនៃគំរោង ២-២ (ប្រព័ន្ធរថយន្តក្រុងរួម):គោលបំណងនៃគំរោងនេះ គឺផ្តោតលើការបង្កើតនូវសេវាដឹកជញ្ជូនដែលមានសណ្តាប់ធ្នាប់ ដែលត្រូវជៀសវាងនូវលក្ខខណ្ឌមិនមានសុវត្ថិភាពនៃការចតតាមផ្លូវ និងចតលើផ្លូវថ្មើរជើង ហើយនឹងសំលេងខ្លាំងៗរបស់ម៉ូតូកង់បី។
- ផ្នែកមួយនៃគំរោង៣-១(ការអភិរក្សបេតិកភណ្ឌក្រុង និងដើមឈើចាស់ៗ) ផ្នែកមួយនៃគំរោង៣-២ (ការកែលំអផ្ទាំងពត៌មានបេតិកភណ្ឌក្រុង) និងផ្នែកមួយនៃគំរោង ៣-៣ (ការអភិរក្ស និងកែលំអតំបន់មាត់ស្ទឹង): គោលបំណងនៃគំរោងនេះ គឺផ្តោតទៅលើការធ្វើអោយប្លែកពីគ្នានូវផលិតផលទេសចរណ៍។




ប្រភព: ការសិក្សាតាមដាន

**រូបភាព ៤.៧ ផែនការរូបវ័ន្តសំរាប់កែលំអតំបន់ផ្សារចាស់ (រយៈពេលវែង)**

## ៤.១.៣ គំរោងអាទិភាពនៅក្នុងផ្នែកអភិវឌ្ឍន៍ក្រុង

### (១) គំរោង និងកម្មវិធីដែលបានស្នើឡើងសម្រាប់ការកែលំអតំបន់កណ្តាលក្រុង

១) បញ្ជីកម្មវិធី និងគំរោងដែលបានស្នើឡើង

ដោយផ្អែកលើអភិក្រមកែលំអដែលបានរៀបរាប់រួចពីមុន គំរោង និងកម្មវិធីដែលបានស្នើឡើងត្រូវបានបង្កើតដោយគិតទៅលើផែនការអនុវត្តរបស់គំរោង និងកម្មវិធីទាំងនោះ ដែលរួមមានដំណាក់កាលកែលំអ (រយៈ

ពេលខ្លី មធ្យម និងរយៈពេលវែង) វិធានការណ៍ ឬគំរោងការគាំទ្រចាំបាច់ផ្សេងទៀត ដូចជាជំនួយបច្ចេកទេស មូលនិធិ របស់រដ្ឋាភិបាល ឬមូលនិធិខាងក្រៅ (ការគាំទ្រពីឯកជន ឬអន្តរជាតិ) ភាពជាដៃគូ សាធារណៈ ឯកជន (PPP) ។ កម្មវិធី និងគំរោងដែលបានស្នើឡើងហើយពាក់ព័ន្ធនឹងតំបន់កណ្តាលក្រុង ក៏ត្រូវបានបង្ហាញសំរាប់ការពិចារណា ជាពហុ-ប្រសិទ្ធភាព ឬប្រសិទ្ធភាពរួមគ្នាក្នុងចំណោមគំរោងទាំងនោះ។

**(២) ការជ្រើសរើសនូវគំរោង និងកម្មវិធីអាទិភាព**

គំរោង និងកម្មវិធីដែលបានស្នើឡើង គឺចាំបាច់ដើម្បីផ្តល់នូវលក្ខណៈអាទិភាពតាមបែបយុទ្ធសាស្ត្រដើម្បីទទួលបានគោលបំណងកែលំអ ក៏ដូចជាស្ថេរភាពនៃទិដ្ឋភាពសេដ្ឋកិច្ច ហិរញ្ញវត្ថុ ស្ថាប័ន និងបរិស្ថាន ដោយគិតទៅលើអតិបរមានៃផលប៉ះពាល់ពហុ-ឥទ្ធិពល ដោយសារតែធនធានមានកំរិត។ ជាពិសេស សមត្ថភាពខាងស្ថប័ន និងហិរញ្ញវត្ថុរបស់គំរោង និងកម្មវិធី គឺជាធាតុសំខាន់ ដើម្បីគ្រប់គ្រងសមត្ថភាពអនុវត្តរបស់គំរោង និងកម្មវិធី ។

១) លក្ខណៈវិនិច្ឆ័យសំរាប់ជ្រើសរើសគំរោង និងកម្មវិធីអាទិភាព

គំរោង និងកម្មវិធីដែលបានស្នើឡើង នៅក្នុងផ្នែកក្រុង មានទំនោរពាក់ព័ន្ធជាមួយអ្នកចូលរួមផ្សេងៗទៀត ដោយតំរូវឱ្យមានពេលវេលាគ្រប់គ្រាន់សម្រាប់ការបង្កើតការព្រមព្រៀងគ្នា ។ ដូចនេះ គំរោង និងកម្មវិធីទាំងនោះ ត្រូវបានអនុវត្តដោយយុទ្ធសាស្ត្រសន្សឹមៗសម្រាប់ការអនុវត្តគំរោងពីរយៈពេលខ្លី ទៅរយៈពេលពាក់កណ្តាល និងវែង។ ផ្ទុយមកវិញ ចំណោមគំរោង និងកម្មវិធីដែលបានស្នើឡើង អាទិភាពគួរតែផ្តល់ទៅអោយគំរោងដែលអាចពិចារណាបានដោយរាល់គំរោងតាមដំណាក់កាលរយៈពេលខ្លី មធ្យម និងរយៈពេលវែង ដោយផ្អែកលើលក្ខណៈវិនិច្ឆ័យសម្រាប់ការជ្រើសរើសដូចខាងក្រោម :

- **បន្ទាន់ :** កម្មវិធី និងគំរោងដែលបានស្នើឡើង គួរតែត្រូវបានពិចារណាជាបន្ទាន់ ដើម្បីចាត់វិធានការ ឬសកម្មភាពភ្លាមៗ ដើម្បីធ្វើការដោះស្រាយបញ្ហាសំខាន់ៗនៅក្នុងតំបន់កណ្តាលក្រុង ។
- **បរិវច្ឆភាព (រៀបចំរួច):** គំរោង និងកម្មវិធីត្រូវតែបានធ្វើការពិចារណាទៅលើស្ថេរភាពក្នុងលក្ខណៈជាកំរិតនៃការទទួលស្គាល់បញ្ហាក្នុងចំណោមអ្នកចូលរួមដែលពាក់ព័ន្ធ អង្គភាពទទួលខុសត្រូវច្បាស់លាស់ និងមូលនិធិ ដែលរួមមានការគាំទ្រអន្តរជាតិសំរាប់ការអនុវត្ត ។
- **ប្រសិទ្ធភាពការវិនិយោគ (ឥទ្ធិពលរួម):** ផលប៉ះពាល់សេដ្ឋកិច្ចលើវិស័យទេសចរ ឬផ្នែកឧស្សាហកម្មផ្សេងៗទៀតនិងពហុទំនាក់ទំនងក្នុងចំណោមគំរោងក៏ជាលក្ខណៈវិនិច្ឆ័យដ៏សំខាន់សម្រាប់ការជ្រើសរើស ដើម្បីធ្វើអោយមានផលប៉ះពាល់ ឬឥទ្ធិពលវិជ្ជមានជាអតិបរមាទៅលើអ្នកទទួលផល ដែលច្រើនជាងមុខ ដោយមូលនិធិដែលមានកំរិត។
- **ឥទ្ធិពលបរិស្ថាន និងសង្គម:** គំរោង និងកម្មវិធីនេះ ទាមទារអោយមានការពិចារណាយ៉ាងយកចិត្តទុកដាក់ក្នុងការជ្រើសរើស ថាតើគំរោង និងកម្មវិធីទាំងនោះមានផលប៉ះពាល់វិជ្ជមាន ឬអវិជ្ជមានមកលើ

បរិស្ថានសង្គម និងធម្មជាតិដែរ ឬអត់។

២) គំរោង និងកម្មវិធីអាទិភាពដែលបានស្នើឡើង

គំរោង និងកម្មវិធីអាទិភាពត្រូវបានជ្រើសរើសតាមរយៈការវាយតម្លៃដោយលក្ខណៈវិនិច្ឆ័យដែលបានរៀបរាប់រួចខាងលើ។ តារាង ៤.៣ បង្ហាញពីលទ្ធផលនៃការវាយតម្លៃរបស់គំរោង និងកម្មវិធីនីមួយៗ គំរោង និងកម្មវិធីអាទិភាពចំនួន ៦ ត្រូវបានជ្រើសរើស និងស្នើឡើង ដូចមានបង្ហាញខាងក្រោម :

១-១: ការកែលំអផ្លូវនៅក្នុងតំបន់ផ្សារចាស់ជាមួយនឹងគំរោងសាកល្បងគន្លឹះ
១-២: ការអភិវឌ្ឍន៍ឧទ្យានតូចៗនៅតាមកាច់ជ្រុងនៅក្នុងតំបន់ផ្សារចាស់
១-៣: ការរៀបចំក្រុមការងារសំរាប់កែលំអតំបន់ផ្សារចាស់ជាមួយនឹងសហគមន៍តំបន់ដែលបានរៀបចំរួច
២-១: ការគ្រប់គ្រងចរាចរចម្រុះសម្រាប់កណ្តាលក្រុង ដែលរួមមានការសិក្សា និងការអនុវត្ត (សួនច្បារសាធារណៈ តំបន់សំរាប់ធ្វើរជើង ការត្រួតពិនិត្យច្រកតែមួយ ។ល។)
៣-១: ការអភិរក្សតំបន់បេតិកភណ្ឌក្រុង និងដើមឈើចាស់នៅតាមផ្លូវ (ការស៊ើបអង្កេត ការបង្កើតកន្លែងស្តុកទិន្នន័យ ផែនការស្តារ/តំឡើងវិញ/ប្រើប្រាស់)
៣-២: ការកែលំអក្តារពតិមានពីបេតិកភណ្ឌក្រុង
៣-៣: ការអភិរក្ស និងការកែលំអតំបន់មាត់ស្ទឹង
៤-១: ការអភិវឌ្ឍសមត្ថភាពសម្រាប់ផ្នែកនគរូបនីយកម្ម និងការអនុវត្ត (សាលាក្រុង និងមន្ទីររៀបចំដែនដីនគរូបនីយកម្ម និងសំណង់)
៤-២: ការពង្រឹងការសម្របសម្រួល និងយន្តការសហប្រតិបត្តិការក្នុងចំណោមអាជ្ញាធរអភិវឌ្ឍន៍ និងនគរូបនីយកម្ម ទាក់ទងទៅនឹងក្រុងសៀមរាប

**តារាង ៤.៣ គំរោង និងកម្មវិធីអាទិភាពដែលបានស្នើឡើង**

| កម្មវិធី | គំរោង | ការវាយតម្លៃតាមលក្ខណៈវិនិច្ឆ័យ | | | | |
|---|---|---|---|---|---|---|
| | | បន្ទាន់ | រៀបចំរួច | ប្រសិទ្ធភាពរួម | ផលប៉ះពាល់អវិជ្ជមាន | ការវាយតម្លៃទូទៅ |
| ១.ការធ្វើអោយប្រសើរឡើងនូវ | ១-១ ការកែលំអផ្លូវក្នុងតំបន់ផ្សារចាស់ជាមួយគំរោង សាកល្បងដែលឆ្លើយតបឆាប់រហ័ស | ● | ○ | ● | -- | ●* |
| | ១-២ ការអភិវឌ្ឍន៍ឧស្សានតូចៗនៅកែងផ្លូវក្នុង តំបន់ផ្សារចាស់ | ● | ○ | ● | -- | ● |

| | | | | | | |
|---|---|---|---|---|---|---|
| ភាពទាក់ទាញទេសចរណ៍ក្រុង និងមុនងារ | ១-៣ ការរៀបចំក្រុមការងារសំរាប់កែលំអតំបន់ផ្សារចាស់ជាមួយសហគមន៍ក្នុងតំបន់ | ● | ○ | ● | -- | ● |
| | ១-៤ ការបង្កើតបណ្តាញសសរបៃតង | ○ | -- | ○ | -- | ○ |
| | ១-៥ បង្កើតបណ្តាញផ្លូវអ្នកថ្មើរជើង | ○ | ○ | ○ | -- | ○ |
| | ១-៦ ការអភិវឌ្ឍន៍ទីធ្លា | ○ | -- | -- | ○ | ○ |
| ២.ការពង្រឹងការគ្រប់គ្រងចល័តភាព | ២-១ ការគ្រប់គ្រងចរាចររួម( ចំណតសាធារណៈ តំបន់សំរាប់តែដើរ ការត្រួតពិនិត្យផ្លូវឯកទិស) | ● | ○ | ● | ○ | ● |
| | ២-២ ប្រព័ន្ធរថយន្តក្រុងទេសចររួម (ប្រព័ន្ធចរាចរណ៍) | ○ | -- | ○ | -- | ○ |
| | ២-៣ ការបង្កើតបណ្តាញផ្លូវអ្នកជិះកង់ដែល មិនបំពុល បរិស្ថាន | -- | ○ | -- | -- | -- |
| | ២-៤ ការផ្សព្វផ្សាយនៃជំនួញចំណតឯកជន | ○ | -- | -- | -- | -- |
| ៣.ការអភិរក្ស និងប្រើប្រាស់បេតិកភណ្ឌក្រុង និងធម្មជាតិ | ៣-១ ការអភិរក្សបេតិកភណ្ឌក្រុង និងដើមឈើ ចាស់ៗនៅតាមផ្លូវ | ● | ● | ○ | -- | ●* |
| | ៣-២ ការកែលំអផ្ទាំងពតិមានបេតិកភណ្ឌក្រុង | ● | -- | ● | -- | ●* |
| | ៣-៣ ការអភិរក្ស និងកែលំអនៃតំបន់ដងស្ទឹង សៀមរាប | ● | ● | -- | -- | ●* |
| ៤.ការធ្វើអោយប្រសើរឡើងនូវការគ្រប់គ្រងក្រុង និងសម្ថភាពរបស់វា | ៤-១ ការអភិវឌ្ឍន៍សម្ថភាពសំរាប់ការរៀបចំ ក្រុង និងការអនុវត្ត (ត្រួតពិនិត្យ និងណែនាំ) | ● | ○ | ● | -- | ● |
| | ៤-២ ពង្រឹងយន្តការសំរបសំរួល និង សហប្រតិបត្តិការក្នុងចំណោមអាជ្ញាធរអភិវឌ្ឍក្រុង | ● | ● | ● | -- | ● |
| | ៤-៣ សេចក្តីណែនាំការអភិរក្សទេសភាពក្រុងនៅក្នុងតំបន់កណ្តាលក្រុង | ○ | -- | ○ | -- | ○ |

កំណត់សម្គាល់ :

● = តម្លៃខ្ពស់ជាងគេ ○ = តម្លៃមធ្យម -- = តម្លៃទាប ឬផលប៉ះពាល់ទាប

* = គម្រោងរបស់រដ្ឋាភិបាលខេត្ត ដែលទទួលហិរញ្ញប្បទានពី AFD ( គាំទ្របច្ចេកទេស ដោយអប្សរា)

ប្រភព: ការសិក្សាតាមដាន

## (៣) គំរោង និងកម្មវិធីអាទិភាពដែលបានស្នើឡើង

### ១) គំរោងរយៈពេលខ្លី- មធ្យម

<u>១-១: ការកែលំអផ្លូវក្នុងតំបន់ផ្សារចាស់ជាមួយនឹងគំរោងសាកល្បងដែលផ្តល់លទ្ធផលឆាប់រហ័ស</u>

សមាសធាតុដ៏សំខាន់របស់គំរោង ១-១ គឺត្រូវកែលំអផ្លូវក្នុងតំបន់ផ្សារចាស់ដើម្បីធានាសុវត្ថិភាព

ផាសុកភាព និងការទាក់ទាញតាមរយៈការសាងសង់ផ្លូវថ្មើរជើង និងកំណត់ពីទំហំផ្លូវបើកបរសំរាប់យានយន្ត។

ទំហំនៃការកែលំអផ្លូវ គឺត្រូវគ្របដណ្តប់គ្រប់ផ្លូវក្នុងតំបន់ផ្សារចាស់ដែលទាមទារអោយត្រូវតែធ្វើការកែលំអផ្លូវជាបណ្តើរៗដោយផ្អែកលើមូលនិធិដែលមាន និងការសំរបសំរួលចាំបាច់ក្នុងចំណោមផ្នែកពាក់ព័ន្ធ ដូចជាការគ្រប់គ្រងចរាចរណ៍ ផ្នែកដឹកជញ្ជូនឯកជនដែលពាក់ព័ន្ធ (សមាគមទឹកង់បី) និងសេវាកម្មទេសចរណ៍ដទៃទៀត (ភោជនីយដ្ឋាន កន្លែងលក់ភេសជ្ជៈ ទីផ្សារ និងហាងលក់វត្ថុអនុស្សាវរីយ៍ ។ល។)

គោលដៅរយៈពេលវែងនៃគំរោង ១-១ ទាមទារអោយមានការអនុវត្តតាមដំណាក់កាលនៃរយៈពេលខ្លី និងរយៈពេលមធ្យមដើម្បីសំរេចនូវគោលដៅចុងក្រោយនៃការកែលំអផ្លូវថ្នល់។ ក្នុងដំណាក់កាលរយៈពេលខ្លី គេបានស្នើអោយមានការអនុវត្តនូវគំរោងសាកល្បងដើម្បីជំរុញអោយមានបរិយាកាសសហគមន៍ក្នុងតំបន់អោយបានសមស្របមួយក្នុងន័យ សហការ សំរបសំរួល និងលើកទឹកចិត្តដល់គំរោងតាមរយៈផ្នែកឯកជន និងផ្នែករដ្ឋដើម្បីឆ្ពោះទៅសំរេចនូវគំរោងក្នុងថ្ងៃអនាគត។ គំរោងសាកល្បងនេះត្រូវបានគេរំពឹងថាជាមូលដ្ឋាននៃគំរោងដែលបានស្នើឡើង "ក្រុមការងារកែលំអតំបន់ផ្សារចាស់" (សូមមើលគំរោង ១-៣) តាមរយៈនៃការផ្តល់ឱកាសអោយមានការពិភាក្សា និងកសាងការព្រមព្រៀង ក្នុងចំណោមស្ថាប័នពាក់ព័ន្ធ ដោយរាប់បញ្ចូលទាំងផ្នែកឯកជន និងផ្នែករដ្ឋ។ ទស្សនៈនៃគំរោងសាកល្បងត្រូវបាន ពិពណ៌នាក្នុងជំពូក ៥.១។

ក្នុងដំណាក់កាលរយៈពេលមធ្យម ការកសាងទីផ្សារអ្នកថ្មើរជើងដោយគំរោងសាកល្បងអាចត្រូវបានពង្រីកវិសាលភាពឆ្ពោះទៅកាន់គ្រប់ផ្លូវទាំងអស់ក្នុងតំបន់ផ្សារចាស់ដើម្បីអោយការកសាងផ្សារអ្នកថ្មើរជើង និងផ្លូវទាំងអស់នោះបញ្ចប់ក្នុងពេលដំណាលគ្នា បន្ទាប់ពីធ្វើការត្រួតពិនិត្យ និងវាយតំលៃផលប៉ះពាល់វិជ្ជមានរបស់គំរោងសាកល្បងទៅលើតំបន់ផ្សារចាស់។




ប្រភព: ការសិក្សាតាមដាន

**រូបភាព ៤.៨ រូបភាពនៃការកែលំអ: ផ្នែកសាមញ្ញនៃផ្សារអ្នកថ្មើជើងក្នុងតំបន់ផ្សារចាស់**

១-២ ការអភិវឌ្ឍន៍សួនច្បារតូចៗនៅផ្លូវកាច់ជ្រុងក្នុងតំបន់ផ្សារចាស់

តំបន់ផ្សារចាស់មានទីតាំងសក្តានុពល ២ដែលអាចអភិវឌ្ឍទៅជាចំណតបាន ដែលទីតាំងធំទី១ ប្រើប្រាស់ដោយសាលាមត្តេយ្យសហគ្រាស និងទីតាំងតូច១ ដែលជាទីសាធារណៈស្ថិតនៅខាងចុងតំបន់ផ្សារចាស់ក្បែរផ្លូវស៊ីវុត្ថា។ ចំណតត្រូវបានគេរំពឹងថា នឹងដើរតួនាទីជាច្រកចូលក្នុងតំបន់ផ្សារចាស់មួយយ៉ាងសំខាន់ ជាមួយនឹងសំរាកមួយចំនួនទៀតសំរាប់ភ្ញៀវទេសចរ និងអ្នកមកទស្សនាផ្សេងៗ ជាពិសេសតំបន់សាលាមត្តេយ្យសហគ្រាស ដែលឧបត្ថម្ភដោយមន្ទីរពាណិជ្ជកម្ម ដែលទាមទារអោយមានការខិតខំយ៉ាងស្វាហាប់ និងពេលវេលាជាក់លាក់មួយក្នុងការប្តូរទីតាំងទៅកាន់កន្លែងណាមួយដែលសមរម្យជាងនេះ និងមានបរិស្ថានស្ងប់ស្ងាត់ និងសុវត្ថិភាព។ ១) ការកសាងទីធ្លា (ការងារចាក់ដី និងក្រាលកៅស៊ូ សំភារៈផ្លូវ បង្គន់សាធារណៈ) ២) ការកសាងសួនឧស្សានលំហែកាយ (ការងារចាក់ដី និងក្រាលកៅស៊ូ សំភារៈផ្លូវ) ត្រូវបានស្នើឡើងជាគំរោងរយៈពេលខ្លី- មធ្យម។

១-៣ ការរៀបចំក្រុមការងារសំរាប់កែលំអតំបន់ផ្សារចាស់ជាមួយសហគមក្នុងតំបន់

គេរំពឹងទុកថាគំរោងសាកល្បង (សូមមើលជំពូក ៥.១) នេះអាចផ្តួចផ្តើមបង្កើតនូវអង្គការចាត់តាំងមួយសំរាប់ធ្វើការងារពាក់ព័ន្ធនឹងការកែលំអផ្លូវជាមួយស្ថាប័នអង្គភាពពាក់ព័ន្ធផ្នែកឯកជន និងផ្នែករដ្ឋ។ ប្រសិនបើទីតាំង/ឱកាសបែបនេះ ត្រូវបានគេបង្កើតដោយជោគជ័យ អង្គការចាត់តាំងផ្លូវការមួយសំរាប់បន្តសកម្មភាពផ្សព្វផ្សាយការកែលំអតំបន់ផ្សារចាស់នឹងត្រូវស្នើអោយបង្កើតឡើង។

គោលបំណងនៃអង្គការចាត់តាំង

អង្គការចាត់តាំងដែលបានស្នើឡើងមានគោលបំណងៈ

- ដើម្បីសំរេចអោយបាននូវគុណភាពសេវាកម្មខ្ពស់ និងបរិស្ថានទីក្រុងដែលទាក់ទាញសំរាប់អ្នកមកទស្សនា ដោយរាប់បញ្ចូលទាំងភ្ញៀវទេសចរ និងអ្នកតាំងទីលំនៅ តាមរយៈសកម្មភាពសហប្រតិបត្តិការ ដោយការបង្កើតភាពជាដៃគូផ្នែកឯកជន និងផ្នែករដ្ឋ។

- ដើម្បីជំរុញ និងផ្សព្វផ្សាយនូវគោលដៅទេសចរណ៍ដែលមានលក្ខណៈប្រកួតប្រជែងនៅតំបន់ផ្សារចាស់តាមរយៈសកម្មភាពដែលទាក់ទាញ និងមានតែមួយ (ឧ. យុទ្ធនាការ ព្រឹត្តិការណ៍ប្រចាំឆ្នាំ)ដើម្បីបង្កើនអ្នកមកទស្សនាជាបន្តបន្ទាប់។

- ដើម្បីជំរុញ និងលើកទឹកចិត្តអោយកាន់តែប្រសើរឡើងចំពោះជំនួញផ្នែកទេសចរណ៍ក្នុងចំណោមស្ថាប័នអង្គភាពពាក់ព័ន្ធតាមរយៈនៃការចែករំលែកនូវការទទួលខុសត្រូវ។

- ដើម្បីដើរតួនាទីសំរបសំរួល និងទទួលខុសត្រូវរវាងសកម្មភាពរបស់ផ្នែកឯកជន និងផ្នែករដ្ឋសំរាប់កែលំអតំបន់ផ្សារចាស់ ផ្តោតលើទេសភាពផ្លូវថ្នល់ ចរាចរណ៍ និងទីធ្លា។

- ដើម្បីអោយមានការព្រមព្រៀង និងអនុវត្តនូវសកម្មភាពផ្សេងៗសំរាប់ការកែលំអតំបន់ផ្សារចាស់អោយកាន់តែប្រសើរក្នុងចំណោមស្ថាប័នអង្គភាពពាក់ព័ន្ធ។

<u>អង្គការចាត់តាំងដែលត្រូវបានស្នើឡើង</u>

អង្គការចាត់តាំងដែលត្រូវបានស្នើឡើង "ក្រុមការងារសំរាប់កែលំអតំបន់ផ្សារចាស់ជាមួយសហគមន៍ក្នុងតំបន់ " រួមមានផ្នែកឯកជន និងផ្នែករដ្ឋ ដូចដែលបានបង្ហាញក្នុងរូបភាព ៤.៩។ អង្គការចាត់តាំងនេះ ក៏ត្រូវបានស្នើអោយស្ថិតនៅក្រោម "គណៈកម្មការបច្ចេកទេសសំរាប់ការអភិវឌ្ឍន៍ទេសចរណ៍ និងរៀបចំក្រុង " ក្នុងតួនាទីជាក់លាក់សំរាប់ការសំរបសំរួលនៃការអភិវឌ្ឍន៍ទេសចរណ៍ និងរៀបចំក្រុង (សូមអានជំពូកទី៥)។




ប្រភព: ការសិក្សាតាមដាន

**រូបភាព ៤.៩ ក្រុមការងារសំរាប់កែលំអតំបន់ផ្សារចាស់ដែលបានស្នើឡើង**

<u>២-១: ការគ្រប់គ្រងចរាចរណ៍រួម(ចំណតសាធារណៈ តំបន់អ្នកថ្មើរជើង ការគ្រប់គ្រងផ្លូវឯកទិស ។ល។)</u>

គំរោងនេះមានគោលដៅផ្តល់ការណែនាំ និងគ្រប់គ្រងលក្ខខណ្ឌចរាចរណ៍អោយបានសមរម្យសំរាប់ទាំងចល័តភាពភ្ញៀវទេសចរ និងសហគមន៍ក្នុងតំបន់កណ្តាលក្រុងជាមួយការកើនឡើងនូវចរាចរណ៍ក្នុងពេលបច្ចុប្បន្ន និងបញ្ហាបរិស្ថាននៃការដឹកជញ្ជូនមិនគ្រប់គ្រាន់ និងមិនមានសុវត្ថិភាព។ គំរោងរួមមានសមាសធាតុ ៣ គឺ ១) ការសិក្សា ពីការគ្រប់គ្រងចរាចរណ៍ជាមួយគំរោងសាកល្បង ២) គំរោងស្ថានីយ៍ឆ្លងកាត់រថយន្តក្រុងទេសចរណ៍ ៣) ដំណើរការ និងការគ្រប់គ្រងចរាចរណ៍នៃការប្រតិបត្តិការកម្មវិធីចរាចរណ៍។

រូបភាពខាងក្រោមបង្ហាញពីសំណើរសំរាប់ការគ្រប់គ្រងចរាចរណ៍ក្នុងតំបន់ផ្សារចាស់ដែលត្រូវបានស្នើ

អោយទៅជាតំបន់សំរាប់តែដើរ ហើយដែលរថយន្តឯកជនធន់តូច និងការដឹកជញ្ជូនភ្ញៀវទេសចរត្រូវបើកបរលើផ្លូវក្បែរនោះ គឺផ្លូវស៊ីវុត្ថា ផ្លូវប៉ូកំបោរ និងផ្លូវជាតិលេខ៦ ជាពិសេសផ្លូវស៊ីវុត្ថា និងផ្លូវជាតិលេខ៦ ដែលត្រូវបានស្នើអោយដំឡើងនូវប្រព័ន្ធចំណតតាមផ្លូវ សំរាប់រថយន្តឯកជនធន់តូច ហើយដែល រថយន្តដឹកភ្ញៀវទេសចរត្រូវបានស្នើអោយប្រើប្រាស់លើផ្លូវស្ថានីយ៍ឆ្លងកាត់របស់ភ្ញៀវទេសចរ។




ប្រភព: ការសិក្សាតាមដាន

**រូបភាព ៤.១០ សំណើសំរាប់ការគ្រប់គ្រងចរាចរណ៍ក្នុងតំបន់ផ្សារចាស់**

ផ្លូវស៊ីវុត្ថាដែលមានទំហំ ២២ម៉ែត្រ អាចជាផ្លូវដែលសក្តិសមបំផុតដែលគេអាចប្រើចិញ្ចើមផ្លូវនេះដើម្បីដំឡើងចំណត។ ក្នុងពេលបច្ចុប្បន្ននេះ ទទឹងផ្លូវថ្មើរជើងត្រូវបានប្រើជាកន្លែងចតបណ្តោះអាសន្ន ដែលការចតយានយន្តលើផ្លូវថ្មើរជើងនេះអាចបង្កជាឧបសគ្គសំរាប់ភ្ញៀវទេសចរ និងអ្នកមកទស្សនាធម្មតា ក្នុងការដើរប្រកបដោយសុវត្ថិភាព និងផាសុកភាព។ គេបានស្នើឡើងថា ទទឹងផ្លូវដែលមានទំហំ ៦ម៉ែត្រសំរាប់អ្នកថ្មើរជើង អាចត្រូវបានកាត់បន្ថយ ដូច្នេះ គេអាចធ្វើជាចំណតនៅលើចិញ្ចើមផ្លូវនោះបាន។ រូបភាព ៤.១១ បង្ហាញពីវិធីនៃការកែលំអដើម្បីដំឡើងនៅចំណតតាមផ្លូវ។




ប្រភព: ការសិក្សាតាមដាន

**រូបភាព ៤.១១ សំណើប្រព័ន្ធចំណតលើផ្លូវស៊ីវុត្ថា**

## ៣-១: ការអភិរក្សបេតិកភណ្ឌក្រុង និងដើមឈើចាស់ៗតាមដងផ្លូវ

គំរោងនេះមានគោលដៅតាមដានទូវគំរោងអាទិភាពរបស់ផែនការមេ ដើម្បីអភិរក្ស និងការពារបេតិកភណ្ឌធម្មជាតិ និងវប្បធម៌ក្រោមច្បាប់ និងបទបញ្ជាដែលពាក់ព័ន្ធ។ គំរោងនេះនឹងត្រូវបានអនុវត្តដោយរដ្ឋបាលខេត្ត ដោយមានការឧបត្ថម្ភមូលនិធិពី AFD ហើយដែលអាជ្ញាធរអប្សរានឹងរៀបចំការសិក្សា។ ទោះបីជាយ៉ាងណាក៏ដោយ វាត្រូវបានគេស្នើអោយបញ្ចូលបន្ថែមដោយគំរោងអភិរក្សដើមឈើចាស់ៗនៅតាមផ្លូវក្នុងតំបន់

កណ្តាលក្រុងដោយប្រើប្រាស់វិធីសាស្ត្រអនុវត្តស្រដៀងគ្នា (អត្តសញ្ញាណ បញ្ជីសារពើភណ្ឌ ការរចនា និងការពារដោយវិធានការជាក់លាក់)។

<u>៣-២: ការកែលំអផ្ទាំងពត៌មានបេតិកភណ្ឌក្រុង</u>

ភ្ជាប់ទៅនឹងគំរោង ៣-១ គំរោង ៣-២ គឺជាគំរោងគាំទ្រដែលត្រូវបានស្នើឡើង ដើម្បីផ្តល់ពត៌មានសំខាន់ៗ និងទាក់ទាញនៃបេតិកភណ្ឌទីក្រុងសម្រាប់ភ្ញៀវទេសចរ តាមរយៈការដាក់ក្តារពន្យល់ដែលមានការពិពណ៌នា និងវិចិត្ររូបចាំបាច់។

<u>៣-៣: ការអភិរក្ស និងការកែលម្អតំបន់មាត់ស្ទឹង</u>

ដើម្បីកែលំអតំបន់មាត់ស្ទឹងសៀមរាប តាមរយៈការកែកុនសោភណ្ឌភាព និងការផ្តល់ផ្លូវដែលមានបំពាក់ឧបករណ៍ផ្លូវចាំបាច់ រួមទាំងការសាងសង់ស្ពានថ្មើរជើងថ្មីមួយផង ។(គំរោងនេះ ដែលផ្តោតលើតំបន់ផ្សាចាស់ត្រូវបានផ្តល់មូលនិធិមួយផ្នែកដោយ AFD ហើយអាជ្ញាធរអប្សរានឹងរៀបចំការសិក្សា និងអនុវត្តគំរោងនេះក្នុងនាមជារដ្ឋបាលខេត្ត។

<u>៤-១: ការអភិវឌ្ឍន៍សមត្ថភាពសម្រាប់ការរៀបចំផែនការទីក្រុង និងការប្រតិបត្តិផែនការនោះ</u>

វាគឺជាឱកាសដ៏សំខាន់មួយសំរាប់រដ្ឋបាលគ្រប់គ្រងក្រុងសំរាប់អាជ្ញាធរពាក់ព័ន្ធរបស់ខេត្ត និងរដ្ឋបាលក្រុងដែលត្រូវបានពង្រឹង ដោយវិធានការអនុវត្តសមរម្យ និងការគ្រប់គ្រង ខណៈពេលដែលលក្ខខន្តិកៈនៃប្រព័ន្ធតំបន់ត្រូវបានដាក់ជូនក្រសួង រៀបចំដែនដី នគររូបនីយកម្ម និងសំណង់ ហើយបន្ទាប់មកទៀតរងចាំការអនុម័ត។ ១) ការអភិវឌ្ឍន៍សមត្ថភាពក្នុងការអនុវត្តការគ្រប់គ្រងប្រព័ន្ធតំបន់ និង ២) ការអភិវឌ្ឍន៍ជំនាញរៀបចំក្រុងត្រូវបានស្នើឡើងជាគំរោងអភិវឌ្ឍន៍សមត្ថភាព។

<u>៤-២: ពង្រឹងការសំរបសំរួល និងយន្តការសហប្រតិបត្តិការក្នុងចំណោមអាជ្ញាធររៀបចំក្រុង និងអភិវឌ្ឍន៍ក្នុងក្រុងសៀមរាប</u>

គំរោងនេះមានគោលដៅបង្កើតនូវយន្តការសំរបសំរួលផ្នែកអភិវឌ្ឍក្រុងអោយបានល្អ និងមានប្រសិទ្ធភាពក្នុងចំណោមអាជ្ញាធរ និងស្ថាប័នអង្គភាពពាក់ព័ន្ធ ដូចជាមន្ទីររៀបចំដែនដី នគរូបនីយកម្ម និងសំណង់ នាយកដ្ឋានអភិវឌ្ឍក្រុងរបស់ក្រុងសៀមរាប និងអាជ្ញាធរអប្សរា រដ្ឋាភិបាលខេត្ត (អភិបាលខេត្ត) ដើម្បីធ្វើការដោះស្រាយជាមួយនឹងការអភិវឌ្ឍន៍ និងការគ្រប់គ្រងក្រុងក្នុងការអនុវត្តចំរុះ និងមានលក្ខណៈសហការ។

ក្នុងផ្នែកនេះ គេបានស្នើថា គណៈកម្មការអភិវឌ្ឍន៍ក្រុង និងវិស័យទេសចរណ៍គួរតែត្រូវបានបង្កើតឡើងស្ថិតក្រោមគណៈកម្មការអភិវឌ្ឍន៍ដែលមានស្រាប់ ដែលពត៌មានលំអិតនៃយន្តការសំរបសំរួលត្រូវបានពិពណ៌នាក្នុងជំពូក ៥ (ស្ថាប័នអនុវត្ត)។

រូបភាពខាងក្រោមបង្ហាញពីវិធីសាស្ត្រធ្វើដោយសន្ទឹមៗសំរាប់ការកែលំអតំបន់ផ្សារចាស់ក្នុងរយៈពេលមធ្យម។




ប្រភព: ការសិក្សាតាមដាន

**រូបភាព ៤.១២ សមាសធាតុដំណាក់កាលរយៈពេលមធ្យមក្នុងតំបន់ផ្សារចាស់**

## ២) គំរោងរយៈពេលវែង

ក្នុងដំណាក់កាលវែង ដែលជាដំណាក់កាលចុងក្រោយ ស្ថានីយ៍ប្តូររថយន្តក្រុងរបស់ភ្ញៀវទេសចរ (គំរោង ២-១) ដែលស្ថិតនៅខាងក្នុងអចលនទ្រព្យរបស់មន្ទីរពេទ្យខេត្ត ត្រូវបានស្នើអោយអភិវឌ្ឍបន្ទាប់ពីការសាងសង់ផ្សារអ្នកថ្មើរជើងរួចរាល់ (គំរោង ១-១) និងអភិវឌ្ឍសួនច្បារតូចៗនៅកាច់ជ្រុងផ្លូវ (គំរោង ១-២) ដើម្បីបង្កើតនូវថ្នាំងដឹកជញ្ជូនទៅកាន់តំបន់ផ្សារចាស់ និងទិសដៅទេសចរដទៃៗទៀតក្នុងតំបន់កណ្តាលក្រុង។ ម្យ៉ាងវិញទៀត មានគំរោង ២បន្តបន្ទាប់គ្នាទៀត គឺ ១) គំរោង ៣-១ សំរាប់អភិរក្សបេតិកភណ្ឌក្រុងក្នុងកម្មវិធីដែលបានស្នើឡើង នៃ "៣: អភិរក្ស និងប្រើប្រាស់នូវបេតិកភណ្ឌក្រុង និងធម្មជាតិ" ២) គំរោង ៤-៣សំរាប់បង្កើតសេចក្តីណែនាំស្តីពីការអភិរក្សទេសភាពបែបប្រវត្តិសាស្ត្រក្នុងកម្មវិធីដែលបានស្នើឡើង នៃ "៤: ការធ្វើអោយ

ប្រសើរឡើងនូវការគ្រប់គ្រងក្រុង និងសមត្ថភាពរបស់វា ” ។




ប្រភព: ការសិក្សាតាមដាន

## រូបភាព ៤.១៣ សមាសធាតុដំណាក់កាលរយៈពេលវែងក្នុងតំបន់ផ្សារចាស់

# ៤.២ ផែនការអភិវឌ្ឍន៍ផ្លូវថ្នល់

## ៤.២.១ ការត្រួតពិនិត្យឡើងវិញនូវការអភិវឌ្ឍន៍ផ្លូវ

### (១) ការអភិវឌ្ឍន៍ផ្លូវថ្នល់ក្នុងក្រុងសៀមរាប

រូបភាព ៤.១៤ បង្ហាញអំពីផ្លូវក្រាលកៅស៊ូក្នុងពេលបច្ចុប្បន្នក្នុងក្រុងសៀមរាបត្រឹមខែ មេសា ឆ្នាំ ២០១០។ រូបភាព ៤.១៥ បង្ហាញអំពីផែនការអភិវឌ្ឍន៍ផ្លូវដែលបានស្នើឡើងរួចក្នុងផែនការមេ។ បន្ទាត់ពណ៌ក្រហមក្នុង រូបភាព ៤.១៥ បង្ហាញអំពីផ្លូវក្រាលកៅស៊ូដែលមានស្រាប់ក្នុងពេលធ្វើផែនការមេ។ ដោយប្រៀបធៀបផ្លូវក្រាលកៅស៊ូក្នុងពេលបច្ចុប្បន្នជាមួយផ្លូវក្រាលកៅស៊ូក្នុងពេលធ្វើផែនការមេ យើងទទួលស្គាល់ថាមានការវិវឌ្ឍន៍នៃការកែលំអផ្លូវ ពីផ្លូវដី/ផ្លូវគ្រួសក្រហម អោយទៅជាផ្លូវក្រាលកៅស៊ូ។ ទោះបីជាយ៉ាងណាក៏ដោយ គេអាចនិយាយបានថា ដំណាក់កាលនៃការកែលំអផ្លូវមានភាពយឺតយ៉ាវផ្អែកលើថវិកាមានកំណត់របស់មន្ទីរសាធារណៈការ និងដឹកជញ្ជូនខេត្ត។




ប្រភព: ការសិក្សាតាមដាន

**រូបភាព ៤.១៤ ផ្លូវក្រាលកៅស៊ូត្រឹមខែ មេសា ឆ្នាំ ២០១០**




ប្រភព: ការសិក្សាផែនការមេ

**រូបភាព ៤.១៥ បណ្តាញផ្លូវឆ្នាំ ២០២០ ដែលបានស្នើឡើងដោយផែនការមេ**

រូបភាព៤.១៦បង្ហាញពីទិសដៅពង្រីកក្រុងសៀមរាបក្នុងថ្ងៃអនាគតដែលបានស្នើដោយផែនការមេ។ ទិសដៅនេះ បង្ហាញថា តំបន់ភាគអគ្នេយ៍នៃក្រុងសៀមរាបជាតំបន់ពង្រីកក្រុង ហើយភាគខាងលិចជាដីកសិកម្ម ដែលត្រូវអភិរក្ស ដោយថា នៅទីនោះមានប្រព័ន្ធស្រោចស្រព្វប្រវត្តិសាស្ត្របន្សល់ទុក និងដីជាប្រភេទដីទំនាប។ បន្ថែមពីលើនោះ ការពង្រីកក្រុងពុំទាន់ត្រូវបានធ្វើការពង្រីកច្រើននៅឡើយ គឺស្ថិតនៅតែខាងក្នុងផ្លូវវាងក្រុងនៅឡើយ លើកលែងតែការអភិវឌ្ឍន៍ទំហំធំតិចតួចប៉ុណ្ណោះដែលស្ថិតនៅខាងក្រៅតំបន់ពង្រីកក្រុង។




ប្រភព: ការសិក្សាផែនការមេ

**រូបភាព ៤.១៦ ការពង្រីកតំបន់ក្រុងដោយដើរតាមលំនាំទស្សនៈទីក្រុងរណប**

### (២) ការអភិវឌ្ឍន៍ផ្លូវថ្នល់ក្នុងតំបន់

ខេត្តសៀមរាបមានព្រំប្រទល់ជាប់នឹងខេត្តចំនួនប្រាំ គឺ ខេត្តកំពង់ធំ ខេត្តព្រះវិហារ ខេត្តឧត្តរមានជ័យ ខេត្តបន្ទាយមានជ័យ និងខេត្តបាត់ដំបង។ បណ្តាញផ្លូវសំខាន់ៗក្នុងតំបន់រួមមាន ផ្លូវជាតិលេខ៦ ផ្លូវជាតិលេខ៥ ផ្លូវ២លេខចំនួន ៦ខ្សែ ឧទាហរណ៍ ដូចជាផ្លូវជាតិលេខ៥៦ ផ្លូវជាតិលេខ៦២ ផ្លូវជាតិលេខ៦៣ ផ្លូវជាតិលេខ៦៤ ផ្លូវជាតិលេខ៦៧ និង ផ្លូវជាតិលេខ៦៨។ ផ្លូវខេត្តបានដើរតួនាទីជាផ្លូវភ្ជាប់របស់បណ្តាញផ្លូវទាំងនេះ ពីទីរួមខេត្តទៅនឹងទីរួមស្រុកសំខាន់ៗ។

រូបភាព ៤.១៧ បង្ហាញពីលក្ខខណ្ឌនៃបណ្តាញផ្លូវសំខាន់នេះក្នុងកំឡុងពេលនៃផែនការមេ។

រូបភាព ៤.១៨ បង្ហាញពីពតិមានចុងក្រោយបំផុតដែលរៀបចំដោយមន្ទីរសាធារណៈការខេត្តសៀមរាប ពាក់ព័ន្ធទៅនឹងការស្តារឡើងវិញនូវផ្លូវក្នុងខេត្ត ដែលក្រុមសិក្សាតាមដានរបស់ JICA បានទទួលក្នុងខែកុម្ភៈ ឆ្នាំ២០១០។

ការកែលំអបណ្តាញផ្លូវធំៗ មានសារៈសំខាន់ខ្លាំងណាស់ដើម្បីធានាដល់ស្ថេរភាពផ្លូវទៅកាន់បេតិកភណ្ឌជនបទ ។ ការកែលំអបណ្តាញផ្លូវធំៗនេះ នឹងធ្វើអោយប្រសើរឡើងនូវទេសចរណ៍ដ៏សំខាន់របស់ខេត្តសៀមរាប។ លើសពីនេះទៅទៀត ការកែលំអនេះ នឹងធ្វើអោយប្រសើរឡើងដល់ជីវភាពប្រជាជននៅជនបទដោយផ្ទាល់ និងបញ្ចៀសប្រជាជនទាំងនោះមិនអោយចូលទៅក្នុងក្រុងសៀមរាបដើម្បីស្វែងរកការងារធ្វើតទៅទៀត។




Legend:
Paved Road
Asphalt
Concrete
DBST
Laterite/Gravel Road
Good/Fair Condition
Bad Condition
Archaeological
Temple

ប្រភព: ការសិក្សាផែនការមេ

**រូបភាព ៤.១៧ លក្ខខណ្ឌបណ្តាញផ្លូវក្នុងតំបន់ត្រឹមខែ មិថុនា ឆ្នាំ២០០៥**




ប្រភព: មន្ទីរសាធារណៈការ និងដឹកជញ្ជូនខេត្តសៀមរាប

## រូបភាព ៤.១៨ ស្ថានភាពស្តារឡើងវិញផ្លូវថ្នល់ក្នុងខេត្តត្រឹមខែ កុម្ភះ ឆ្នាំ ២០១០

ផែនការមេបានស្នើអោយមានការកែលំអផ្លូវទៅកាន់តំបន់បេតិកភណ្ឌជនបទចំនួន ៥។ ស្ថានភាពផ្លូវក្នុងផែនការមេកាលពីមុន និងស្ថានភាពផ្លូវក្នុងពេលបច្ចុប្បន្នត្រូវបានបង្ហាញក្នុងតារាង ៤.៤

## តារាង ៤.៤ បញ្ជីគំរោងស្តារឡើងវិញបណ្តាញផ្លូវទៅកាន់តំបន់បេតិកភណ្ឌជនបទ

| តំបន់បេតិកភណ្ឌជនបទ | លេខផ្លូវ | ប្រវែងប្រហាក់ប្រហែល (គីឡូម៉ែត្រ) | ស្ថានភាពផ្លូវក្នុងផែនការមេកាលពីមុន | ស្ថានភាពផ្លូវក្នុងពេលបច្ចុប្បន្ន |
|---|---|---|---|---|
| ក្បាលស្ពាន | ផ្លូវជាតិលេខ:៦៧ | ១០ | ផ្លូវគ្រួសក្រហម | ផ្លូវកៅស៊ូ |
| បាកាន | ផ្លូវជាតិលេខ:៦៤ | ៣០ | ផ្លូវដី | ផ្លូវកៅស៊ូ |
| | ផ្លូវខេត្តលេខ:២៦៤៤ | ៦៥ | ផ្លូវដី | ផ្លូវដី |
| ព្រះវិហារ | ផ្លូវជាតិលេខ:៦៧ | ១០៥ | ផ្លូវគ្រួសក្រហម | ផ្លូវកៅស៊ូ |
| | ផ្លូវខេត្តលេខ:២៧៤ | ៩៥ | ផ្លូវគ្រួសក្រហម | ផ្លូវកៅស៊ូ |
| | ផ្លូវជាតិលេខ:៦២ | ២០ | ផ្លូវគ្រួសក្រហម/ដី | ផ្លូវកៅស៊ូ |
| កោះកេរ្តិ៍ | ផ្លូវជាតិលេខ:៦៤ | ៦០ | ផ្លូវគ្រួសក្រហម | ផ្លូវកៅស៊ូ |
| | ផ្លូវខេត្តលេខ:២៦៤១D | ១០ | ផ្លូវគ្រួសក្រហម | ផ្លូវគ្រួសក្រហម |
| ភ្នំគូលេន | ផ្លូវខេត្តលេខ:២៦៤១ | ២៥ | ផ្លូវគ្រួសក្រហម/ដី | ផ្លូវគ្រួសក្រហម/ដី |

កំណត់សំគាល់: ផ្លូវកៅស៊ូមានន័យថាផ្លូវក្រាល AC/ DBST/Macadam

ប្រភព: ផែនការមេJICA

ភាគច្រើននៃផ្លូវក្នុងតារាង ៤.៤ ត្រូវបានកែលំអរួចហើយ។ បន្ថែមពីលើនេះ ផ្លូវដែលភ្ជាប់ទៅកាន់ខេត្តព្រះវិហារស្ថិតក្រោមការសាងសង់ចំងាយប្រម៉ាណ ១០ គីឡូម៉ែត្រពីស្រុកអន្លង់វែងទៅកាន់ជើងប្រាសាទព្រះវិហារ។

ផ្លូវដែលមិនទាន់កែលំអនៅឡើយក្នុងតារាង ៤.៤ គឺ ផ្លូវខេត្តលេខៈ២៦៤៤ ទៅកាន់បាកាន ផ្លូវខេត្តលេខៈ២៦៤១D ទៅកាន់កោះកេរ្តិ៍ និងផ្លូវខេត្តលេខៈ២៦៤១ ទៅកាន់ភ្នំគូលេន។




**រូបថត ៤-១ រូបភាពខ្លោងទ្វារយកប្រាក់នៃចុងផ្លូវខាងលិចនៃផ្លូវ BOT**

គេបានកត់សំគាល់ថា ផ្លូវ BOT ដោយក្រុមហ៊ុនវិនិយោគ **ខាំ សាម៉េត** ដែលបានបង្ហាញក្នុងរូបភាព ៤.១៨ គឺជាផ្លូវកៅស៊ូពីត្រពាំងព្រៃ ដែលគឺជាចំនុចភ្ជាប់រវាងផ្លូវ BOT និងផ្លូវជាតិលេខ៦៤ ទៅភាគខាងកើត។ ទោះបីជាយ៉ាងណាក៏ដោយកំណាត់ផ្លូវពីចុង ផ្លូវខាងលិចនៃផ្លូវ BOT ទៅកាន់ត្រពាំងព្រៃស្ថិតនៅជាផ្លូវគ្រួសក្រហម ដូចដែលបានបង្ហាញក្នុងរូបថត ៤-១។ ចរាចរណ៍ដែលសំខាន់គឺ ភ្ញៀវទេសចរមកពីខេត្តសៀមរាបទៅកាន់បឹងមាលា/ ប្រាសាទកោះកេរ្តិ៍ ដែលប្រើប្រាស់ផ្លូវជាតិលេខ៦ ផ្លូវជាតិលេខ៦៤ ផ្លូវ BOT (ផ្លូវជាតិលេខ៦៤)។ ដោយសារពុំទាន់មានចរាចរណ៍សំខាន់នៅកំណាត់ផ្លូវភាគខាងលិចនៃផ្លូវ BOT ក្រុមហ៊ុនវិនិយោគលើផ្លូវនេះមិនទាន់ចាក់កៅស៊ូ (ប៊ីទែរមីណ័រ) លើ កំណាត់ផ្លូវនេះនៅឡើយទេ។

## (៣) បញ្ហាវិស័យគមនាគមន៍

១) ពុំមានបរិស្ថាន និងហេដ្ឋារចនាសម្ព័ន្ធក្នុងក្រុងគ្រប់គ្រាន់

ផែនការមេបានលើកឡើងថា "ដោយយោងទៅតាមការស្ទាបស្ទង់លើភ្ញៀវទេសចរ ទីផ្សារក៏រិតខ្ពស់សំរាប់ភ្ញៀវទេសចរពុំទាន់មានការពេញចិត្តនៅឡើយស្តីអំពីសុវត្ថិភាព និងភាពស្អាតនៃទីក្រុង"។ ទោះបីជាផ្លូវក្នុងក្រុងមួយចំនួនត្រូវបានកែលំអអោយទៅជាផ្លូវដែលអាចបំរើបានរាល់ស្ថានភាពបរិយាកាស ចាប់តាំងពីផែនការមេត្រូវបានធ្វើឡើងក៏ដោយ ក៏ក្រុងសៀមរាបនៅតែមានផ្លូវគ្រួសក្រហមជាច្រើននៅឡើយ។ នៅក្នុងរដូវប្រាំងផ្លូវគ្រួសក្រហមបានហុយយ៉ាងខ្លាំង ហើយចំណែកនៅក្នុងរដូវវស្សា យានយន្តដែលបានបើកចូលមកក្នុងទីក្រុងបាននាំមកជាមួយភក់ដីក្រហមតាមកង់របស់វា។ ដើម្បីអោយទីក្រុងមានភាពស្រស់ស្អាត វាចាំបាច់ត្រូវលុបបំបាត់ផ្លូវគ្រួសក្រហមនៅក្នុងទីក្រុងជាមុនសិន។

២) បញ្ហាលើការគ្រប់គ្រងផ្លូវ

ផ្លូវក្នុង និងជុំវិញក្រុងសៀមរាបស្ថិតក្រោមការទទួលខុសត្រូវរបស់មន្ទីរសាធារណៈការ និងដឹកជញ្ជូន មន្ទីរអភិវឌ្ឍន៏ជនបទ អាជ្ញាធរខេត្ត និងអាជ្ញាធរអប្សរា។ ដែនកំណត់នៃផ្លូវដែលទទួលខុសត្រូវដោយមន្ទីរនីមួយៗមានដូចតទៅ:

**តារាង ៤.៥ បញ្ជីស្ថាប័ន និងផ្លូវដែលត្រូវទទួលខុសត្រូវ**

| ស្ថាប័ន | ប្រភេទផ្លូវ |
|---|---|
| មន្ទីរសាធារណៈការ និងដឹកជញ្ជូន | - ផ្លូវជាតិ<br>- ផ្លូវខេត្ត<br>- ផ្លូវជនបទដែលមានចរាចរប្រចាំថ្ងៃជាមធ្យមក្នុងមួយឆ្នាំៗច្រើនជាង ៥០<br>- ការគ្រប់គ្រងផ្លូវទីក្រុង |
| មន្ទីរអភិវឌ្ឍន៏ជនបទ | - ផ្លូវជនបទដែលមានចរាចរប្រចាំថ្ងៃជាមធ្យមក្នុងមួយឆ្នាំៗតិចជាង ៥០<br>- ផ្លូវបីលេខ: ភ្ជាប់ពីស្រុកទៅស្រុក<br>- ផ្លូវបីលេខរង ទី១: ភ្ជាប់ពីស្រុកទៅឃុំ<br>- ផ្លូវបីលេខរង ទី២: ភ្ជាប់ពីឃុំទៅឃុំ<br>- ផ្លូវបីលេខរង ទី៣: ភ្ជាប់ពីឃុំទៅភូមិ និង ពីភូមិទៅភូមិ |
| អាជ្ញាធរអប្សរា | - បណ្តាញផ្លូវនៅក្នុងតំបន់ឧស្យានអប្សរា<br>- ផ្លូវអប្សរាក្នុងក្រុងសៀមរាប |

ប្រភព: ការសិក្សាតាមដាន

ដោយផ្អែកលើបញ្ជីផ្លូវទទួលខុសត្រូវដែលបានបង្ហាញក្នុងតារាង ៤.៥ ផ្លូវដែលត្រូវយកមកសិក្សាដោយការសិក្សាតាមដានគឺជាផ្លូវដែលទទួលខុសត្រូវដោយមន្ទីរសាធារណៈការ និងដឹកជញ្ជូន។

មន្ទីរសាធារណៈការ និងដឹកជញ្ជូនចាំបាច់ត្រូវអនុវត្តអោយបានសមស្របនូវការថែរក្សាផ្លូវតាមរយៈកាល និងការកែលំអផ្លូវក្នុងក្រុងសៀមរាប និងបណ្តាញផ្លូវជនបទដែលអាចបញ្ចៀសនូវការលំបាកនៃផ្លូវទៅកាន់បេតិកភណ្ឌជនបទ។ ទោះបីជាយ៉ាងណាក៏ដោយ មន្ទីរសាធារណៈការ និងដឹកជញ្ជូន ពុំអាចអនុវត្តនូវកិច្ចការដែលបានរំពឹងទុកនេះបានឡើយដោយកង្វះថវិកា ធនធានមនុស្ស និងសំភារៈ។

ដើម្បីអោយសកម្មភាពថែរក្សាផ្លូវមានប្រសិទ្ធភាព វាជាការចាំបាច់ត្រូវមានការអនុវត្តនូវការត្រួតពិនិត្យជាប្រចាំនូវលក្ខខណ្ឌផ្លូវ ការបន្តធ្វើបច្ចុប្បន្នភាពនៃទិន្នន័យសំភារៈ និងការបង្កើតនូវកម្មវិធីអទិភាពសំរាប់ការថែរក្សា និងកែលំអផ្លូវ។ មន្ទីរសាធារណៈការ និងដឹកជញ្ជូនបានដឹងអំពីសារៈសំខាន់នៃសំរង់ស្ថិតិនៃបញ្ជីទ្រព្យសម្បត្តិផ្លូវ។ ទោះបីជាយ៉ាងណាក៏ដោយ យោងទៅតាមធនធាន និងថវិកាមានកំណត់ដែលបានលើកឡើង

ខាងលើ មន្ទីរសាធារណៈការ និងដឹកជញ្ជូនពុំអាចចាប់ផ្តើមសកម្មភាពដើម្បីបង្កើតនូវបញ្ជីទ្រព្យសម្បត្តិផ្លូវបានឡើយ។ បញ្ជីទ្រព្យសម្បត្តិផ្លូវគឺជាទិន្នន័យមូលដ្ឋានសំរាប់បង្កើតកម្មវិធីគ្រប់គ្រងផ្លូវដោយរាប់បញ្ចូលទាំងកម្មវិធីថែរក្សា កែលំអ និងសាងសង់ផ្លូវ។

៣) ការវិភាគសមត្ថភាពផ្លូវ

<u>ការធ្វើការស្ទាបស្ទង់ចរាចរណ៍ឆ្នាំ២០១០</u>

កាលពីខែ មករា ឆ្នាំ២០១០ លេខាធិការដ្ឋាននៃគណៈកម្មការបច្ចេកទេសផ្នែកអភិវឌ្ឍន៍ក្រុងបានធ្វើការស្ទាបស្ទង់ចរាចរណ៍ក្រោមការដឹកនាំរបស់ទីប្រឹក្សាផ្នែករៀបចំក្រុងនៃទីភ្នាក់ងារសហប្រតិបត្តិការអន្តរជាតិនៃប្រទេសជប៉ុន JICA។ ការស្ទាបស្ទង់នេះត្រូវបានអនុវត្តឡើងចាប់ពីថ្ងៃទី ១៦ រហូតដល់ថ្ងៃទី ១៩ ខែ មករា ឆ្នាំ២០១០ នៅចំនួន ១២ ស្ថានីយ៍ ដូចដែលបានបង្ហាញក្នុងរូបភាព ៤.១៩។




ប្រភព: របាយការណ៍ការស្ទាបស្ទង់ចរាចរណ៍ ក្រុងសៀមរាប ខែ កុម្ភៈ ឆ្នាំ២០១០

**រូបភាព ៤.១៩ ផែនទីទីតាំងនៃស្ថានីយ៍ដែលបានធ្វើការស្ទាបស្ទង់ក្នុងឆ្នាំ២០១០**

យានយន្តត្រូវបានចែកចេញជាបីចំណាត់ថ្នាក់ដូចខាងក្រោមក្នុងការធ្វើការស្ទាបស្ទង់ចរាចរណ៍:

រថយន្តធន់ធ្ងន់ : រថយន្តក្រុង រថយន្តដឹកទំនិញ រថយន្តសណ្តោងរ៉ឺម៉ក និងរថយន្តពិសេស

យានយន្តធន់ស្រាល : ម៉ូតូកង់បី រថយន្តតូច រថយន្តក្រុងខ្នាតតូច រថយន្ត pick- up ម៉ូតូរ៉ឺម៉ក ម៉ូតូ

ដើម្បីធ្វើការវិភាគពីសមត្ថភាពផ្លូវជាតិ ចំនួនយានយន្តត្រូវបានគិតជាឯកតានៃរថយន្តដឹកអ្នកដំណើរ PCU

**តារាង ៤.៦ ការគិតជាឯកតានៃរថយន្តដឹកអ្នកដំណើរ PCU ដោយចំណាត់ថ្នាក់នៃយានយន្ត**

| ចំណាត់ថ្នាក់នៃយានយន្ត | ចំនួនសមមូលនៃឯកតានៃរថយន្តដឹកអ្នកដំណើរ |
|---|---|
| រថយន្តធន់ធ្ងន់ | ២.៥ |

| | |
|---|---|
| យានយន្តធន់ស្រាល | ១.0 |
| ម៉ូតូ | 0.៣ |

ប្រភព: ទំព័រ III-៦-១៣ លេខ III របាយការណ៍ផ្នែក ការសិក្សាផែនការមេ

កំរិតចរាចរណ៍លើផ្លូវជាតិលេខ៦ត្រូវបានផ្តល់ដោយទិន្នន័យការរាប់ចរាចរណ៍នៅស្ថានីយ៍ទី៤ ទី១ និងទី៥។ កំរិតចរាចរណ៍នៃ PCU នៅស្ថានីយ៍នីមួយៗចាប់ពីម៉ោង ៦ព្រឹក ដល់ម៉ោង ៨យប់ ត្រូវបានផ្តល់ជូនដូចខាងក្រោម។ ប្រភពចំនួនដែលពាក់ព័ន្ធដល់ចំនួនយានយន្តដែលត្រូវបានធ្វើការស្ទាបស្ទង់ និង PCU នៅស្ថានីយ៍នីមួយៗ នឹងត្រូវលំអិតក្នុងទំព័របន្ថែម D-១។




កាលបរិច្ឆេទការស្ទាបស្ទង់: ថ្ងៃទី ១៦ ខែ មករា ឆ្នាំ ២០១០




កាលបរិច្ឆេទការស្ទាបស្ទង់: ថ្ងៃទី ១៩ ខែ មករា ឆ្នាំ ២០១០

កំណត់សំគាល់: "W to E" តំណាងអោយចរាចរណ៍ភាគខាងកើត ពីទិសខាងលិចទៅខាងកើត។ "E to W" តំណាងអោយចរាចរណ៍ភាគខាងលិច ពីទិសខាងកើតទៅខាងលិច។ Total បង្ហាញពីកំរិតចរាចរណ៍ទាំងពីរទិសដៅ។ រីឯអ័ក្សឈរគឺ PCU

**រូបភាព ៤.២០ កំរិតចរាចរណ៍ក្នុង PCU នៅស្ថានីយ៍ធ្វើការស្ទាបស្ទង់ទី៤**




កាលបរិច្ឆេទការស្ទាបស្ទង់: ថ្ងៃទី ១៦ ខែ មករា ឆ្នាំ ២០១០




កាលបរិច្ឆេទការស្ទាបស្ទង់: ថ្ងៃទី ១៩ ខែ មករា ឆ្នាំ ២០១០

**រូបភាព ៤.២១ កំរិតចរាចរណ៍ក្នុង PCU នៅស្ថានីយ៍ធ្វើការស្ទាបស្ទង់ទី៥**




កាលបរិច្ឆេទការស្ទាបស្ទង់: ថ្ងៃទី ១៦ ខែ មករា ឆ្នាំ ២០១០




កាលបរិច្ឆេទការស្ទាបស្ទង់: ថ្ងៃទី ១៩ ខែ មករា ឆ្នាំ ២០១០

**រូបភាព ៤.២២ កំរិតចរាចរណ៍ក្នុង PCU នៅស្ថានីយ៍ធ្វើការស្ទាបស្ទង់ទី១**

គេបានកត់សំគាល់ថា ការធ្វើការស្ទាបស្ទង់នៅស្ថានីយ៍ទី១ ដែលមានទីតាំងនៅរង្វង់មូលរវាងផ្លូវជាតិលេខ៦ និងផ្លូវស៊ីវុត្ថាត្រូវបានធ្វើឡើងជាបីទិសដៅ (បត់ឆ្វេង ឆ្លងកាត់ភ្លើងស្តុប និងបត់ស្តាំ)។ សំរាប់ជាការប្រៀបធៀប កំរិតចរាចរណ៍នៅលើផ្លូវជាតិលេខ៦ នៅភាគខាងលិចនៃរង្វង់មូល ត្រូវបានដកស្រង់ចេញពីទិន្នន័យដើមដូចខាងក្រោម:

កំរិតចរាចរណ៍ពីលិចទៅកើត = W1+W2+W3

កំរិតចរាចរណ៍ពីកើតទៅលិច = N1+E2+S3




**រូបភាព ៤.២៣ ការបកស្រាយទ្រឹស្តីនៃទិន្នន័យពីការរាប់ចរាចរណ៍នៅស្ថានីយ៍ទី១**

ការរាប់ចរាចរណ៍នៅស្ថានីយ៍ទី៤ មានទីតាំងរវាងព្រលានយន្តហោះអន្តរជាតិ និងតំបន់កណ្តាលក្រុងនៃក្រុងសៀមរាប។ ដូចច្នេះ ចរាចរណ៍នឹងរាប់បញ្ចូលទាំងភ្ញៀវទេសចរទៅ និងមកពីព្រលានយន្តហោះ ហើយក៏អាចរាប់បញ្ចូលទាំងភ្ញៀវទេសចរផ្លូវគោកមកពីប៉ោយប៉ែត ព្រំដែនប្រទេសកម្ពុជា និងថៃ។ កំរិតចរាចរណ៍នៅភាគខាងលិចនៃស្ថានីយទី១ (រង្វង់មូលរវាងផ្លូវជាតិលេខ៦ និងផ្លូវស៊ីវុត្ថា) បង្ហាញថាមានចំនួនស្មើរ ២ដងនៃកំរិតចរាចរណ៍នៅស្ថានីយទី៤។ ហេតុផលនៃកំរិតចរាចរណ៍ខ្ពស់នៅត្រង់រង្វង់មូលនេះ ឆ្លុះបញ្ចាំងអោយឃើញពីកំរិតខ្ពស់នៃចរាចរណ៍ចូលមកក្នុងទីក្រុង។

ការរាប់ចរាចរណ៍នៅស្ថានីយ៍ទី៥ ក៏បានបង្ហាញថាមានកំរិតខ្ពស់ជាងស្ថានីយ៍ទី៤ផងដែរ។ ការរាប់ចរាចរណ៍នៅស្ថានីយ៍ទី៥ មានទីតាំងនៅក្បែរផ្សារលើធំថ្មី។ ចរាចរណ៍ទៅ និងមកផ្សារ ចរាចរណ៍របស់ភ្ញៀវទេសចរវៀតណាម (តាមរយៈគមនាគមន៍ផ្លូវគោក) និងប្រជាជនក្នុងតំបន់ និងចរាចរណ៍ចូលក្នុងក្រុងដ៏មមាញឹកអាចជាហេតុផលដ៏សំខាន់ដែលបណ្តាលអោយមានកំរិតចរាចរណ៍ដ៏ខ្ពស់ត្រង់កន្លែងនេះ។

"សមត្ថភាពផ្លូវជាតិ" ដែលត្រូវបានបោះពុម្ពផ្សាយជាសាធារណៈដោយសមាគមផ្លូវថ្នល់នៃប្រទេសជប៉ុន បានកំណត់នូវសមត្ថភាពផ្លូវជាតិជាគោល ដូចដែលមានចុះក្នុងតារាង ៤.៧ ជាមួយនឹងលក្ខខណ្ឌដូចខាងក្រោម៖

- ទំហំទទឹងផ្លូវ ≥ ៣.៥ ម៉ែត្រ
- ខាងនៃផ្លូវត្រូវមានទំហំ ≥ ១.៧៥ ម៉ែត្រ
- ទ្រង់ទ្រាយនៃផ្លូវជាតិមិនបានកាត់បន្ថយនូវសមត្ថភាពផ្លូវជាតិទេ
- កំរិតចរាចរណ៍ត្រូវបានគិតតែអំពីរថយន្តដឹកអ្នកដំណើរតែប៉ុណ្ណោះ
- គ្មានការកំណត់ល្បឿនណាមួយដែលអាចកាត់បន្ថយនូវសមត្ថភាពផ្លូវជាតិទេ

**តារាង ៤.៧ សមត្ថភាពផ្លូវជាតិជាគោល**

| ប្រភេទផ្លូវជាតិ | សមត្ថភាពអតបរិមា |
|---|---|
| ផ្លូវជាតិដែលមានផ្លូវទៅ និងមកច្រើន | ២ ២០០ pcu/ម៉ោង/ ១ទិសដៅ |
| ផ្លូវជាតិដែលមានផ្លូវទៅ២ មក២ | ២ ៥០០ pcu/ម៉ោង/ ២ទិសដៅ |
| ផ្លូវជាតិដែលមានផ្លូវទៅ១ មក១ | ២ ២០០ pcu/ម៉ោង |

សមត្ថភាពផ្លូវជាតិអតិបរមានៃផ្លូវជាតិនីមួយៗមានកំរិតទាបជាងសមត្ថភាពជាគោល និងត្រូវបានប៉ាន់ស្មានដោយរូបមន្តដូចខាងក្រោម៖

$C_M = C_B \times \gamma_L \times \gamma_C \times \gamma_I \cdots$

ដែល $C_M$ : សមត្ថភាពផ្លូវជាតិអតិបរមា (pcu/ម៉ោង)

$C_B$ : សមត្ថភាពផ្លូវជាតិជាគោល (pcu/ម៉ោង)

$\gamma_L$ : កត្តាកែសំរួលដោយទទឹងផ្លូវ

$\gamma_C$ : កត្តាកែសំរួលដោយទំហំខាងនៃផ្លូវ

$\gamma_I$ : កត្តាកែសំរួលដោយបរិស្ថានចិញ្ចើមផ្លូវ

កំណាត់ផ្លូវជាតិលេខ៦ ត្រូវបានបកស្រាយក្នុងរូបភាព ៤.២៤។ ផ្លូវជាតិលេខ៦ ត្រូវបានចាត់ជាផ្លូវជាតិដែលមាន ២ខ្សែទៅ និង២ខ្សែមក។




ប្រភព: ការសិក្សាផែនការមេ

## រូបភាព ៤.២៤ កំណាត់ផ្លូវជាតិលេខ៦

ដោយផ្អែកលើកំណាត់ផ្លូវដែលបានបង្ហាញក្នុងរូបភាព ៤.២៤ ខាងលើ ការកែសំរួលដោយទំហំទទឹងផ្លូវ និងទំហំខាងនៃផ្លូវនឹងមិនចាំបាច់ទេ។ "សមត្ថភាពផ្លូវជាតិ " នៃសមាគមផ្លូវថ្នល់នៃប្រទេសជប៉ុន បានស្នើអោយមាននូវកត្តាកែសំរួលដោយបរិស្ថានចិញ្ចើមផ្លូវដូចខាងក្រោម:

## តារាង ៤.៨ កត្តាកែសំរួលដោយបរិស្ថានចិញ្ចើមផ្លូវ

| បរិស្ថានចិញ្ចើមផ្លូវ | កត្តាកែសំរួល |
|---|---|
| • ការចតនៅតាមចិញ្ចើមផ្លូវមិនប៉ះពាល់ដល់សមត្ថភាពចរាចរណ៍ទេ | |
| តំបន់ជនបទ | 0.៩៥ ~ ១.00 |
| តំបន់ជាយក្រុង | 0.៩0 ~ 0.៩៥ |
| តំបន់ក្រុង | 0.៨៥ ~ 0.៩0 |
| • ការចតនៅតាមចិញ្ចើមផ្លូវបានប៉ះពាល់ដល់សមត្ថភាពចរាចរណ៍ | |
| តំបន់ជនបទ | 0.៩0 ~ ១.00 |
| តំបន់ជាយក្រុង | 0.៨0 ~ 0.៩0 |
| តំបន់ក្រុង | 0.៧0 ~ 0.៨0 |

ឧបមាថា បរិស្ថានចិញ្ចើមផ្លូវនៃផ្លូវជាតិលេខ៦ ជាតំបន់ជាយក្រុងមានការប៉ះពាល់ដល់ការចតនៅតាមចិញ្ចើមផ្លូវ នោះសមត្ថភាពផ្លូវជាតិជាអតិបរិមាត្រូវបានប៉ាន់ស្មានដូចខាងក្រោម:

សមត្ថភាពអតិបរមានៃផ្លូវជាតិលេខ៦= ២ ៥00 × 0.៨0 ~ 0.៩0= ២ 000 ~ ២ ២៥0 pcu/ម៉ោង/ ២ទិសដៅ

កំរិតចរាចរណ៍ក្នុងពេលបច្ចុប្បន្នលើផ្លូវជាតិលេខ៦ មានស្ទើរតែពាក់កណ្តាលនៃសមត្ថភាពអតិបរិមានៃផ្លូវនេះ។

ការរាប់ចរាចរណ៍នៅស្ពានសល់ពីសម័យបារាំង (ផ្លូវមួយខ្សែដែលជាផ្លូវឯកទិស) ត្រូវបានធ្វើឡើងនៅស្ថានីយ៍ទី១២។ គេកត់សំគាល់ឃើញថា ស្ពានសល់ពីសម័យបារាំងទី២ ត្រូវបានសាងសង់រួចជាស្រេច ហើយស្ថិត

ក្រោមដំណើរការនៅពេលដែលមានការធ្វើការស្ទាបស្ទង់ចរាចរណ៍។ កំរិតចរាចរណ៍ដែលត្រូវបានធ្វើការស្ទាបស្ទង់ក្នុង PCU ត្រូវបានផ្តល់ក្នុងរូបភាព ៤.២៥។ ដោយប្រៀបធៀបទៅនឹងសមត្ថភាពផ្លូវជាតិជាគោលចំនួន ២ ២០០ pcu/ម៉ោង សំរាប់ផ្លូវជាតិដែលមានតែ ១ខ្សែ ចរាចរណ៍ដែលត្រូវបានគេអង្កេតបានបង្ហាញប្រមាណ ៥០% ទល់នឹងសមត្ថភាពផ្លូវជាតិ។ នៅពេលដែលបណ្តាញផ្លូវក្នុងក្រុងត្រូវបានអភិវឌ្ឍ/ កែលំអ ដូចដែលបានស្នើឡើងដោយការសិក្សាតាមដាន និងកំរិតចរាចរណ៍នៅស្ពានសល់ពីសម័យបារាំងត្រូវបានធ្វើអោយបែកខ្ញែក នោះគេពិចារណាឃើញថា ស្ពានសល់ពីសម័យបារាំង (ចាស់) នឹងមិនបង្កើតអោយមានចរាចរណ៍កកកុញទេ។




**រូបភាព ៤.២៥ កំរិតចរាចរណ៍ក្នុង PCU នៅស្ថានីយទី១២**

<u>ការស្ទាបស្ទង់ចរាចរណ៍ក្នុងឆ្នាំ២០០៤ ដោយផែនការមេ</u>

ការធ្វើការស្ទាបស្ទង់ពីការរាប់ចរាចរណ៍ត្រូវបានធ្វើឡើងនៅតាមផ្លូវជាតិលេខ៦ នៅថ្ងៃទី ១២ និង១៣ ខែធ្នូ ឆ្នាំ២០០៤ នៅរង្វង់មូលសំខាន់២ ក្នុងតំបន់ក្រុងសៀមរាប និង ២ចំនុចទៀតក្នុងតំបន់ជនបទ។ ទីតាំងនៃចំនុចធ្វើការរាប់ចរាចរណ៍នោះត្រូវបានបង្ហាញក្នុងរូបភាព ៤.២៦។




ប្រភព: ការសិក្សាផែនការមេ

**រូបភាព ៤.២៦ ចំនុចរាប់ចរាចរណ៍ក្នុងផែនការមេ**

ផែនការមេបានធ្វើរបាយការណ៍អំពីលទ្ធផលនៃការរាប់ចរាចរណ៍ ដូចដែលបានបង្ហាញក្នុងតារាង ៤.៩។

គេបានកត់សំគាល់ថា ការរាប់ចរាចរណ៍ត្រូវបានធ្វើឡើងចាប់ពីម៉ោង៥ព្រឹក រហូតដល់ម៉ោង ៩យប់ ហើយចរាចរណ៍ប្រចាំថ្ងៃត្រូវបានប៉ាន់ស្មានដោយបន្ថែម ១០%នៃកំរិតចរាចរណ៍ដែលបានរាប់។ បន្ថែមពីលើនោះ ថ្ងៃកំរិតចរាចរណ៍ដែលត្រូវបានគេធ្វើរបាយការណ៍ គឺជាកំរិតចរាចរណ៍សរុបនៃកន្លែងដែលបានរាប់ ឧទាហរណ៍ កំរិតចរាចរណ៍នៅត្រង់រង្វង់មូលផ្លូវបែកជាបួន និងកំរិតចរាចរណ៍នៃទិសដៅទាំង២ នៅកន្លែងរាប់ចរាចរណ៍នៅក្នុងតំបន់ជាយក្រុង។

## តារាង ៤.៩ កំរិតចរាចរណ៍លើផ្លូវជាតិលេខ៦

(PCU/ថ្ងៃ)

| ចំណាត់ថ្នាក់យានយន្ត | អត្រា PCU | តំបន់ក្រុង | | តំបន់ជាយក្រុង | |
|---|---|---|---|---|---|
| | | ការរាប់ចំនុចទី១ | ការរាប់ចំនុចទី២ | ការរាប់ចំនុចទី៣ | ការរាប់ចំនុចទី៤ |
| ម៉ូតូ | ០.៣ | ៩៨៩៦ | ៧៣៩២ | ៣២៦០ | ២៦២៥ |
| រថយន្តធន់ស្រាល | ១.០ | ១១៥៩៨ | ៥៦៧០ | ៣១៦៧ | ២១២៦ |
| រថយន្តធន់ធ្ងន់ | ២.៥ | ៧០១៨ | ៣៣២៨ | ២៦១៨ | ៩២៣ |
| សរុប | | ២៨៥១២ | ១៦៣៩០ | ៩០៤៥ | ៥៦៧៤ |

ប្រភព: ការសិក្សាផែនការមេ

ការរាប់ចរាចរណ៍ញចំនុចទី៤ លើផ្លូវជាតិលេខ៦ មានទីតាំងនៅភាគខាងលិចនៃផ្លូវទៅកាន់ព្រលានយន្តហោះ ហើយដែលស្ថានីយ៍រាប់ទី៤ មានទីតាំងនៅចន្លោះព្រលានយន្តហោះអន្តរជាតិ និងតំបន់កណ្តាលក្រុងនៃក្រុងសៀមរាប។ ដូចច្នេះ ការប្រៀបធៀបទិន្នន័យចរាចរណ៍នៃការរាប់ចំនុចទី៤ របស់ផែនការមេ និងស្ថានីយ៍ទី៤ ក្នុងឆ្នាំ២០១០ ពុំមានអត្ថន័យអ្វីទេ។ ដើម្បីត្រួតពិនិត្យនូវទំនោរកើនឡើង ឬថយចុះនៃកំរិតចរាចរណ៍លើផ្លូវជាតិលេខ៦ ទិន្នន័យនៃការរាប់ចរាចរណ៍នៅចំនុចទី១ និងចំនុចទី៣ ត្រូវបានគេយកមកវិភាគ។

ការរាប់ចំនុចទី១ គឺស្ថិតនៅរង្វង់មូលរវាងផ្លូវជាតិលេខ៦ និងផ្លូវស៊ីវុត្ថា។ ដូចច្នេះ ដើម្បីដឹងពីកំរិតចរាចរណ៍នៅលើកំណាត់ផ្លូវភាគខាងលិចនៃរង្វង់មូល ការកែសំរួលនូវទិន្នន័យនៃស្ថានីយ៍ទី១ ត្រូវបានយកមកប្រើ។ បើទោះបីថា វាមិនសូវច្បាស់ ទីតាំងនៃការរាប់ទី៣ អាចស្ថិតនៅជិតរង្វង់មូលរវាងផ្លូវជាតិលេខ៦ និងផ្លូវរវាងក្រុង ដែលស្ថិតនៅភាគខាងកើតនៃស្ថានីយ៍រាប់ទី៥។

រូបភាព ៤.២៧ និង ៤.២៨ បង្ហាញពីកំរិតចរាចរណ៍លើផ្លូវជាតិលេខ៦ ត្រង់ការរាប់ចំនុចទី១ និងទី៣ ក្នុង PCU។




កាលបរិច្ឆេទការស្ទាបស្ទង់: ថ្ងៃទី ១២ ខែ ធ្នូ ឆ្នាំ ២០០៤




កាលបរិច្ឆេទការស្ទាបស្ទង់: ថ្ងៃទី ១៣ ខែ ធ្នូ ឆ្នាំ ២០០៤

**រូបភាព ៤.២៧ កំរិតចរាចរណ៍ក្នុង PCU នៅការរាប់ចំនុចទី១**




កាលបរិច្ឆេទការស្ទាបស្ទង់: ថ្ងៃទី ១២ ខែ ធ្នូ ឆ្នាំ ២០០៤




កាលបរិច្ឆេទការស្ទាបស្ទង់: ថ្ងៃទី ១៣ ខែ ធ្នូ ឆ្នាំ ២០០៤

**រូបភាព ៤.២៨ កំរិតចរាចរណ៍ក្នុង PCU នៅការរាប់ចំនុចទី៣**

កំរិតចរាចរណ៍នៃការរាប់ចំនុចទី១ ក្នុងឆ្នាំ២០០៤ បានបង្ហាញថា មានកំរិតខ្ពស់ជាងការរាប់នៅឯស្ថានីយ៍ទី១ ក្នុងឆ្នាំ២០១០។ ដោយឡែក ការរាប់នៅឯស្ថនីយ៍ទី៥ ក្នុងឆ្នាំ២០១០បានបង្ហាញថាមានប្រមាណជា ២ដង នៃកំរិតចរាចរណ៍នៃការរាប់ចំនុចទី៣ ក្នុងឆ្នាំ២០០៤។

បើទោះបីថា ផែនការមេបានប៉ាន់ស្មាននូវតំរូវការចរាចរណ៍នាពេលអនាគតលើផ្លូវជាតិលេខ៦ ដូចដែលបានបង្ហាញក្នុងតារាង ៤.១០ យ៉ាងណាក៏ដោយ ក៏អត្រាកំណើនថេរក្នុងកំឡុងឆ្នាំ២០០៤ និងឆ្នាំ២០១០ មិនអាចធ្វើការប៉ាន់ស្មានបានឡើយ។

**តារាង ៤.១០ តំរូវការចរាចរណ៍នាពេលអនាគតលើផ្លូវជាតិលេខ៦**

<table>
<tr><th rowspan="3">ឆ្នាំ</th><th colspan="2">អត្រាកំណើន<br>(% ក្នុងមួយឆ្នាំ)</th><th colspan="4">កំរិតចរាចរណ៍<br>(យានយន្ត/ថ្ងៃ)</th></tr>
<tr><th rowspan="2">ក្រុង</th><th rowspan="2">ជាយក្រុង</th><th colspan="2">ក្រុង</th><th colspan="2">ជាយក្រុង</th></tr>
<tr><th>ការរាប់ ចំនុចទី១</th><th>ការរាប់ ចំនុចទី២</th><th>ការរាប់ ចំនុចទី៣</th><th>ការរាប់ ចំនុចទី៤</th></tr>
<tr><td>២០០៥</td><td>១៣.៥%</td><td>៩.៨%</td><td>៥២៨១១</td><td>៣៩៧៣៦</td><td>១៦៥៦៣</td><td>១២៣៥២</td></tr>
</table>

| | | | | | | |
|---|---|---|---|---|---|---|
| ២០១២ | ៤.១% | ៨.១% | ៩១៨៨៧ | ៦១០២៣ | ៣០៨០០ | ២២៩៦៨ |
| ២០២០ | ៣.១% | ៨.២% | ១១៨១៨០ | ៧៨៤៨៤ | ៩៧៥៦៨ | ៤២៩៣០ |

(PCU/ថ្ងៃ)

| ឆ្នាំ | ក្រុង | | ជាយក្រុង | |
|---|---|---|---|---|
| | ការរាប់ចំនុចទី១ | ការរាប់ចំនុចទី២ | ការរាប់ចំនុចទី៣ | ការរាប់ចំនុចទី៤ |
| ២០០៥ | ៣២៣៧៣ | ១៨៥៥២ | ៩៩៣៣ | ៦២៣២ |
| ២០១២ | ៥៥២៧៨ | ៣១៦៧៩ | ១៨៤៧១ | ១១៥៨៨ |
| ២០២០ | ៧១០៩៦ | ៤០៧៧៤ | ៣៤៥២៤ | ២១៦៥៩ |

ប្រភព: ការសិក្សាផែនការមេ

ដោយពិចារណាទៅលើសមត្ថភាពទទួលភ្ញៀវទេសចរក្នុងឧស្សាហនអង្គរ និងការអភិវឌ្ឍន៍/កែលំអបណ្តាញផ្លូវខាងក្នុង និងជុំវិញក្រុងសៀមរាប ដែលបានកំណត់កាលបរិច្ឆេទរួច គេបានវិនិច្ឆ័យថា កំណើនតំរូវការនៃកិរិតចរាចរណ៍ក្នុងតំបន់ឧស្សាហនអង្គរ នឹងមិនកើនលើសទេ ហើយការអភិវឌ្ឍន៍/កែលំអបណ្តាញផ្លូវដែលបានកំណត់កាលបរិច្ឆេទរួចនឹងអាចបំរើដល់តំរូវការនៃកិរិតចរាចរណ៍នាពេលអនាគត។

## ៤.២.២ ផែនការអភិវឌ្ឍន៍ផ្លូវថ្នល់ដែលត្រូវបានត្រួតពិនិត្យឡើងវិញ

### (១) ការត្រួតពិនិត្យឡើងវិញនូវមធ្យោបាយការងារសំរាប់ផែនការអភិវឌ្ឍផ្លូវដែលបានស្នើឡើង

ដោយផ្អែកទៅលើការពិចារណាដូចខាងក្រោម ផែនការអភិវឌ្ឍន៍ផ្លូវនៅក្នុងផែនការមេត្រូវបានត្រួតពិនិត្យឡើងវិញ និងស្នើឡើង

(i) នៅពេលដែលការបរិយាយនៅក្នុងគំរោង/កម្មវិធីនៃផែនការមេត្រូវបានស្វែងយល់ គំរោង/កម្មវិធីនៃផែនការមេនោះនឹងត្រូវដកចេញពីសំណើ។

(ii) នៅពេលមានការចាំបាច់ក្នុងការត្រួតពិនិត្យឡើងវិញ ឬបន្ថែមនូវគំរោង/កម្មវិធីដែលត្រូវកំណត់ដោយផ្អែកលើស្ថានភាពក្នុងពេលបច្ចុប្បន្ន លក្ខខណ្ឌនោះនឹងត្រូវបញ្ចូលទៅក្នុងសំណើ។

(iii) នៅពេលដែលគំរោង/កម្មវិធីនៃផែនការមេនៅតែចាំបាច់ដោយផ្អែកថាពុំមានការវិវឌ្ឍន៍ និងស្ថានភាពនៅដដែល គំរោង/កម្មវិធីនឹងត្រូវរក្សាទុកនៅក្នុងសំណើ។

គេអាចនិយាយបានថា តំបន់ក្រុង ក្នុងក្រុងសៀមរាបនៅមានកិរិតនៅឡើយស្ថិតក្នុងតំបន់ដែលហ៊ុំព័ទ្ធដោយផ្លូវជាតិលេខ៦ និងផ្លូវវាងក្រុង។ ក្នុងតំបន់នេះ ផ្លូវដីនៅមាននៅឡើយ ហើយភាគច្រើននៃសំភារៈក្រុងសំរាប់អ្នកតាំងទីលំនៅ/ភ្ញៀវទេសចរត្រូវបានសាងសង់តែនៅតាមផ្លូវក្រាលកៅស៊ូ (ផ្លូវដែលអាចបំរើបានរាល់

បរិយាកាសអាកាសធាតុ) ។

គេបានសង្កេតឃើញថា តំបន់ក្រុង ក្នុងក្រុងសៀមរាបបានពង្រីកទៅកាន់ភាគខាងកើត ខាងក្រៅផ្លូវវាង ក្រុង ដែលផែនការមេបានកំណត់ថាជាតំបន់ក្រុងទៅថ្ងៃអនាគត ។ ទោះបីជាយ៉ាងនេះក្តី ហេដ្ឋារចនាសម្ព័ន្ធចាំបាច់ សំរាប់ទ្រទ្រង់ការពង្រីកក្រុង ដូចជា ផ្លូវក្រាលកៅស៊ូ ខ្សែភ្លើង ប្រព័ន្ធបង្ហូរ និងផ្គត់ផ្គង់ទឹក ពុំទាន់ត្រូវបានផ្តល់ជូន អោយល្អនៅឡើយ ។ ដោយថាតំបន់អភិវឌ្ឍន៍ក្រុងថ្មីនេះពុំមានហេដ្ឋារចនាសម្ព័ន្ធគ្រប់គ្រាន់ គេឃើញមានផ្លូវក្រាល កៅស៊ូ ពីរ ទៅ បី ប៉ុណ្ណោះក្នុងតំបន់នេះ ។ ជាមួយគ្នានេះដែរ នៅផ្នែកខាងក្នុងផ្លូវវាងក្រុង គេឃើញមានតំបន់ទំនេរ ដែលគ្មានការប្រើប្រាស់នៅច្រើននៅឡើយ ។ បន្ថែមពីលើនេះ ដូចដែលបានបង្ហាញក្នុងរូបភាព ២.៨ អាគារថ្មី៧ភាគ ច្រើនដែលត្រូវបានសាងសង់បន្ទាប់ពីមានផែនការមេ មានទីតាំងនៅខាងក្នុងផ្លូវវាងក្រុង ។

ស្ថិតិបានបង្ហាញថា ចំនួនប្រជាជនក្នុងក្រុង និងចំនួនភ្ញៀវទេសចរមានការកើនឡើងថេរ ។ ក្រុងសៀមរាប ត្រូវដោះស្រាយបញ្ហាកំណើននេះដោយត្រូវអភិវឌ្ឍន៍ និងពង្រីកតំបន់ក្រុង ។ ទោះបីជាយ៉ាងណាក៏ដោយ ដោយ ពិចារណាទៅលើស្ថានភាពប្រើប្រាស់ដីធ្លីក្នុងពេលបច្ចុប្បន្ន គេអាចវិនិច្ឆ័យបានថា តំបន់ដែលស្ថិតនៅខាងក្នុងផ្លូវវាង ក្រុងនៅតែមានសក្តានុពលឆ្លើយតបទៅនឹងតំរូវការពង្រីកក្រុងទៅថ្ងៃអនាគតយ៉ាងហោចណាស់ក្នុងរយៈពេល៥ឆ្នាំ ទៀត ។ ដូច្នេះ ដើម្បីជំរុញអោយមានការពង្រីកក្រុងអោយបានសមរម្យនៅខាងក្នុងផ្លូវវាង វាជារឿងចាំបាច់ដែល ត្រូវកែលំអផ្លូវដីក្នុងពេលបច្ចុប្បន្ន អោយទៅជាផ្លូវក្រាលកៅស៊ូដែលអាចបំរើបានរាល់ស្ថានភាពបរិយាកាស ។

ការកែលំអពីផ្លូវដីអោយទៅជាផ្លូវក្រាលកៅស៊ូដែលអាចបំរើបានរាល់ស្ថានភាពបរិយាកាស ក៏នឹងចូលរួម ចំណែកធ្វើវិមជ្ឈការសំភារៈក្រុង និងបណ្តាញផ្លូវអោយមានតុល្យភាពបានល្អក្នុងតំបន់ខាងក្នុងផ្លូវវាងក្រុង ។

ការវិភាគលើទិន្នន័យនៃការរាប់ចរាចរណ៍បានបង្ហាញថា កំរិតចរាចរណ៍ក្នុងពេលបច្ចុប្បន្ន ស្ថិតក្នុងដែន សម្ថភាពនៃផ្លូវជាតិដែលមានស្រាប់ ។ ទិន្នន័យនៃការរាប់ចរាចរណ៍នៅក្បែរផ្សារលើធំថ្មី (ស្ថានីយ៍ទី៥) បានបង្ហាញ ថា មានកំរិតខ្ពស់ ។ ទោះបីជាយ៉ាងណាក៏ដោយ បន្ទាប់ពីមានការរាប់ចរាចរណ៍ក្នុងខែមករា ឆ្នាំ ២០១០ ក្រុង សៀមរាប បានបណ្តេញចេញនូវអ្នកលក់តាមចិញ្ចើមផ្លូវដែលបង្កអោយមានការកកស្ទះចរាចរណ៍នៅតាមផ្លូវជាតិ លេខ៦ ក្នុងតំបន់នោះ ។ ដោយផ្អែកលើការបោសសំអាតនេះ គេបានពិចារណាថា កំរិតចរាចរណ៍នៅស្ថនីយ៍ទី៥ មាន ការថយចុះពីកំរិតដែលត្រូវបានរាប់ ។

ការសិក្សាប្រៀបធៀបនៃទិន្នន័យការរាប់ចរាចរណ៍ត្រូវបានធ្វើឡើងរវាងផែនការមេកាលពីឆ្នាំ២០០៤ និង ទិន្នន័យការរាប់ចរាចរណ៍ក្នុងឆ្នាំ ២០១០ ។ ផែនការមេបានធ្វើការរាប់ចរាចរណ៍ចំនួន ៤ កន្លែងលើផ្លូវជាតិលេខ៦ ខណៈដែលទីតាំងនៃកន្លែងរាប់ចរាចរណ៍លើផ្លូវជាតិលេខ៦ នោះ ខុសគ្នាពីទីតាំងនៃការរាប់ចរាចរណ៍លើផ្លូវជាតិ លេខ៦ ក្នុងឆ្នាំ ២០១០ ។ ដោយផ្អែកលើ ភាពខុសគ្នានៃទីតាំងនៃការរាប់នេះ អត្ថន័យនៃការប្រៀបធៀបផ្តើម ចេញពីទស្សនៈនៃភាពត្រឹមត្រូវក្នុងន័យវិស្វកម្មមិនអាចវិនិច្ឆ័យបានទេ ។ ហើយការសិក្សប្រៀបធៀបនេះ ក៏មិន

អាចអោយគេទាញចេញជាលទ្ធផលដើម្បីព្យាករណ៍ពីអត្រាកំណើននៃតំរូវការចរាចរណ៍ទៅថ្ងៃអនាគតបានដែរ។ ទោះបីជាយ៉ាងណាក៏ដោយ ការសិក្សាអាចបង្ហាញដូចខាងក្រោមៈ

· ក៏រិតចរាចរណ៍លើផ្លូវជាតិលេខ៦ រវាងព្រលានយន្តហោះអន្តរជាតិ និងក្រុងសៀមរាបមានការថយចុះពីឆ្នាំ២០០៤ បើមិនដូច្នោះទេ គឺដោយសារមិនមានការកើនឡើងនូវភ្ញៀវទេសចរតាមរយៈជើងហោះហើរ។

· ដោយផ្អែកលើការស្តារឡើងវិញនូវផ្លូវជាតិលេខ៦ គេបានយល់ឃើញថា មានភ្ញៀវទេសចរធ្វើដំណើរតាមផ្លូវគោកពីព្រំដែនកម្ពុជា ថៃ។ ទោះបីជាយ៉ាងនេះក្តី តំរូវការចរាចរណ៍ពុំមានលក្ខណៈគួរអោយកត់សំគាល់ទេ ឬ ស្ទើរតែអាចចោលបាន។

· ក៏រិតចរាចរណ៍លើផ្លូវជាតិលេខ៦ នៅភាគខាងកើតស្ទឹងសៀមរាបមានការកើនឡើងពីឆ្នាំ ២០០៤។ ហេតុផលនោះអាចថាៈ

· តំបន់នោះ គឺជាតំបន់ពង្រីកក្រុងយ៉ាងគគុកញ និងបង្កើតអោយមានចរាចរណ៍ចូលមកក្នុងក្រុង។

· មានការកើនឡើងគួរអោយកត់សំគាល់នូវភ្ញៀវទេសចរណ៍តាមផ្លូវគោកដែលមកទស្សនាខេត្តសៀមរាបពីតំបន់ភាគខាងកើតនៃប្រទេស។

· ក្នុងរយៈពេលប៉ុន្មានឆ្នាំចុងក្រោយនេះ ភ្ញៀវទេសចរវៀតណាម ដែលធ្វើដំណើរតាមផ្លូវគោកមានការកើនឡើងគួរអោយកត់សំគាល់។

ពួកគេបានមកខេត្តសៀមរាបតាមផ្លូវពីភាគខាងកើតនៃផ្លូវជាតិលេខ៦។

ដូចនេះ តំរូវការចរាចរណ៍នៅថ្ងៃអនាគតនៃផ្លូវជាតិលេខ៦ នៅភាគខាងលិច នឹងមិនលើសពីសមត្ថភាពផ្លូវជាតិដែលមានស្រាប់ត្រឹមឆ្នាំ២០២០ឡើយ។ តំរូវការចរាចរណ៍ក្នុងពេលអនាគតនៃផ្លូវជាតិលេខ៦ នៅភាគខាងកើតនឹងមានការកើនឡើង។ ទោះបីជាយ៉ាងណាក៏ដោយ នៅពេលមានការកែលំអផ្លូវពីផ្លូវដីខាងក្នុងផ្លូវវាងក្រុងអោយទៅជាផ្លូវក្រាលកៅស៊ូ ត្រូវបានអនុវត្ត កំណើនចរាចរណ៍នឹងត្រូវរំដោះទៅក្នុងបណ្តាញផ្លូវក្នុងក្រុង។ ក៏រិតចរាចរណ៍លើផ្លូវជាតិលេខ៦ នឹងមិនលើសពីសម្ថភាពផ្លូវជាតិឡើយ ខណៈដែលមានចរាចរណ៍ឆ្លងកាត់ក្រុងសៀមរាបមានតែបន្តិចបន្តួច ហើយភាគច្រើននៃចរាចរណ៍លើផ្លូវជាតិលេខ៦ គឺធ្វើដំណើរទៅទីស្នាក់អាស្រ័យក្នុងតំបន់ក្រុង និងឧស្សាហបេតិកភណ្ឌ។ ដូច្នេះ គេអាចពិចារណាឃើញថា ការកែលំអបណ្តាញផ្លូវខាងក្នុងផ្លូវវាងក្រុងនឹងអាចរំដោះកំណើនចរាចរណ៍ក្នុងថ្ងៃអនាគតបាន។

ជាលទ្ធផល ទស្សនៈជាមូលដ្ឋានសំរាប់ការបង្កើតអោយមាន នូវការកែលំអ/អភិវឌ្ឍបណ្តាញផ្លូវត្រូវបានសង្ខេបដូចខាងក្រោមៈ

· ការកែលំអ/អភិវឌ្ឍបណ្តាញផ្លូវខាងក្នុងផ្លូវវាងក្រុង គឺជាអាទិភាពចំបងបំផុត

· ការកែលំអ/អភិវឌ្ឍបណ្តាញផ្លូវខាងក្រៅផ្លូវវាងក្រុង គឺជាអាទិភាពចំបងបន្ទាប់

· ការពង្រីកផ្លូវជាតិលេខ៦ អោយទៅផ្លូវដែលមាន៤ ខ្សែ មិនមានការចាំបាច់

· គំរោងផ្លូវរណបនឹងផ្លូវជាតិលេខ៦ គួរត្រូវបានស្នើជាផគំរោងអាទិភាពទី៣ ឯករាជ្យចេញពីការកែលំអ/ អភិវឌ្ឍន៍បណ្តាញផ្លូវខាងក្រៅផ្លូវវាងក្រុង។

## (២) ការអភិវឌ្ឍន៍/ កែលំអបណ្តាញផ្លូវនៅក្នុងតំបន់ក្រុង

TR-1 ការកែលំអបណ្តាញផ្លូវក្នុងក្រុងក្នុងផ្លូវជាតិលេខ៦ និងផ្លូវវាងក្រុង

ដោយផ្អែកលើទស្សនៈនៃការរៀបចំក្រុង ការកែលំអបណ្តាញផ្លូវសំខាន់ៗខាងក្នុងផ្លូវវាងក្រុងត្រូវបានស្នើឡើងដោយផែនការមេ ហើយរំពឹងថានឹងត្រូវបញ្ចប់មុនឆ្នាំ ២០១២។ ដោយផ្អែកលើការសិក្សាតាមដាន បានបង្ហាញអោយឃើញថា ផែនការសេដ្ឋកិច្ចសង្គមក្នុងដែលបានលើកឡើងស្ថិតក្រោមការវាយតំលៃស្មើរ។ រីឯផែនការសេដ្ឋកិច្ចពិតបានឈានដល់ផែនការក្នុងឆ្នាំ២០២០រួចទៅហើយ។ ទោះបីជាយ៉ាងណាក៏ដោយ ការកែលំអផ្លូវក្នុងក្រុង ក្នុងផ្លូវជាតិលេខ៦ និងផ្លូវវាងក្រុងគឺមិនទាន់មានការកែលំអនៅឡើយ។ ដូច្នេះវាត្រូវបានគេចាត់ទុកថាការកែលំអបណ្តាញផ្លូវខាងក្នុងផ្លូវវាងក្រុងគឺចាំបាច់ជាបន្ទាន់។ បន្ថែមពីលើនោះ ផ្តើមចេញពីទស្សនៈក្នុងការស្វែងយល់អំពីបរិស្ថានក្រុងដែលស្អាត និងមានសុវត្ថិភាព ការកែលំអផ្លូវគ្រួសក្រហមគឺជារឿងចាំបាច់។ បេក្ខភាពនៃផ្លូវគ្រួសក្រហមដែលត្រូវកែលំអត្រូវបានត្រួតពិនិត្យ និងពិចារណាយ៉ាងយកចិត្តទុកដាក់។

រូបភាព ៤.២៩ បង្ហាញបណ្តាញផ្លូវក្នុងក្រុងដែលត្រូវកែលំអអោយទៅជាផ្លូវបំរើបានគ្រប់ស្ថានភាពបរិយាកាស(ផ្លូវក្រាលកៅស៊ូ)។ ប្រវែងសរុបនៃផ្លូវដែលត្រូវកែលំអមានប្រមាណជា ៧០ គីឡូម៉ែត្រ។ ក្នុងគោលដៅអភិវឌ្ឍនៃបណ្តាញផ្លូវនេះ ការកែលំអរង្វង់មូល ការដំឡើងផ្លាកសញ្ញា អំពូលភ្លើងតាមដងផ្លូវ និងប្រព័ន្ធបង្ហូរទឹក ក៏នឹងត្រូវអនុវត្តផងដែរ។




**រូបភាព ៤.២៩ ការកែលំអបណ្តាញផ្លូវក្នុងក្រុងក្នុងផ្លូវជាតិលេខ៦ និងផ្លូវវាងក្រុង**

TR-2 ការកែលំអបណ្តាញផ្លូវក្នុងក្រុងខាងក្រៅផ្លូវវាងក្រុង

ផែនការមេបានស្នើអោយមានការផ្តល់ជូននូវបណ្តាញផ្លូវសំខាន់ៗក្នុងតំបន់ក្រុងក្នុងពេលអនាគត (ភាគខាងកើត និងភាគអគ្នេយ៍នៃទីក្រុង) រវាងឆ្នាំ២០១២ និង ឆ្នាំ២០២០។ ដោយផ្អែកលើហេតុផលដូចគ្នានៃការកើនឡើងយ៉ាងឆាប់រហ័សនៃកំណើនប្រជាជនក្នុងទីក្រុងដូចដែលបានលើកឡើងខាងលើការកែលំអបណ្តាញផ្លូវក្នុងក្រុងខាងក្រៅផ្លូវវាងក៏ទាមទារអោយមានការអនុវត្តក្នុងរយៈពេលវែងផងដែរ។

រូបភាព ៤.៣០ បង្ហាញបណ្តាញផ្លូវដែលបានស្នើឡើងដើម្បីអោយមានការកែលំអ ឬសាងសង់ថ្មីដោយ TR-2។ ប្រវែងសរុបនៃបណ្តាញផ្លូវដែលបានស្នើឡើងមានប្រវែងប្រហែល ៦០ គីឡូម៉ែត្រ។




**រូបភាព ៤.៣០ ការកែលំអបណ្តាញផ្លូវក្នុងក្រុងខាងក្រៅផ្លូវវាងក្រុង**

គេបានកត់សំគាល់ថា ការកសាងផ្លូវបញ្ចៀសត្រូវបានគេធ្វើផែនការរួចរាល់ហើយ ដោយឆ្លងកាត់ភាគខាងលិច និងខាងជើងនៃតំបន់ឧស្សាហកម្ម។ ការកសាងនឹងត្រូវចាប់ផ្តើមនៅក្នុងឆ្នាំ២០១០។ ការកសាងផ្លូវបញ្ចៀសក្រុងនេះរួមមាន ការកែលំអផ្លូវដែលមានស្រាប់ប្រវែង ១៦.៣ គីឡូម៉ែត្រ និងការកសាងផ្លូវថ្មីមានប្រវែង ៤.៦ គីឡូម៉ែត្រ ដូចដែលបានផ្តល់ជូនក្នុងទីតាំងផែនទី ក្នុងទំព័របន្ថែម D-៣

TR-3 ការកសាងបណ្តាញផ្លូវរណបនឹងផ្លូវជាតិលេខ៦

ចរាចរនៅលើផ្លូវជាតិលេខ៦ មិនទាន់កកកុញខ្លាំងនៅឡើយ។ ទោះបីជាយ៉ាងណាក៏ដោយ វាចាំបាច់ត្រូវ

មានការផ្តល់ជូននូវផ្លូវជំរើសដើម្បីរំដោះចរាចរក្នុងពេលអនាគតអោយបានជាមុន។ ផែនការមេបានស្នើអោយមានផ្លូវជំរើសចំនួន ២ ស្របទៅនឹងផ្លូវជាតិលេខ៦ ដោយស្ថិតនៅភាគខាងជើង និងភាគខាងត្បូង និងផ្លូវភ្ជាប់រវាងផ្លូវជាតិលេខ៦ និងផ្លូវស្របទាំងនេះ។ ដើម្បីពង្រឹងនូវបណ្តាញផ្លូវ និងស្វែងយល់អំពីការបែងចែកចរាចរណ៍អោយបានសមស្របនៅក្នុងទីក្រុង វាទាមទារចាំបាច់អោយមានការអនុវត្តនូវ TR-3 ក្នុងដំហានដំបូងអោយបានច្រើនតាមតែអាចធ្វើទៅបាន។

ទោះបីជាយ៉ាងណាក៏ដោយ ផ្លូវស្របទាំងនេះ ដែលស្ថិតនៅភាគខាងជើង និងខាងត្បូងផ្លូវជាតិលេខ៦ ត្រូវឆ្លងកាត់តំបន់ដែលមានសំណង់អគារ។ ការអនុវត្តការសាងសង់ផ្លូវទាំងនេះ ទាមទារអោយមានការប្តូរការតាំងទីលំនៅរបស់ប្រជាជន កំទេចអគារ និងផ្ទះសំបែងចោលជាច្រើន។ វាត្រូវបានគេប្រមើរមើលឃើញថា ការទទួលយកគំរោងផ្លូវស្របនេះ ចាំបាច់នូវដំណើរការប្រើរយៈពេលយ៉ាងយូរដើម្បីអោយមានការព្រមព្រៀងរវាងស្ថាប័នពាក់ព័ន្ធរបស់រដ្ឋាភិបាល និងគំរោងដែលប៉ះពាល់ដល់ប្រជាពលរដ្ឋ។

ដោយផ្អែកទៅលើសារៈសំខាន់នៃផ្លូវរណបទាំងនេះ និងការលំបាកជាច្រើនក្នុងការអនុវត្ត គេបានវិនិច្ឆ័យអោយស្នើនូវគំរោងឯករាជ្យ ដូចជា TR-3 បន្ថែមទៅលើ TR-1 និង TR-2។




ប្រភព: ការសិក្សាតាមដាន

**រូបភាព ៤.៣១ TR-3 ការសាងសង់ផ្លូវរណបនឹងផ្លូវជាតិលេខ៦**

ក្នុងលទ្ធផលចុងក្រោយរបស់ TR-1 TR-2 និង TR-3 ផែនការអភិវឌ្ឍផ្លូវថ្នល់ក្នុងឆ្នាំ ២០២០ ក្នុង

ក្រុងសៀមរាប ត្រូវបានបង្ហាញក្នុងរូបភាព ៤.៣២ ។




**រូបភាព ៤.៣២ ផែនការអភិវឌ្ឍផ្លូវថ្នល់ (TR-1 TR-2 និង TR-3)**

## (៣) ការអភិវឌ្ឍន៍/ កែលំអបណ្តាញផ្លូវនៅក្នុងតំបន់ក្រុង

TR-4ការកែលំអស្ថាប័ន និងយុទ្ធនាការសុវត្ថិភាពចរាចរ

ក្នុងឆ្នាំ ២០០៤ រដ្ឋាភិបាលព្រះរាជាណាចក្របានបង្កើតផែនការសកម្មភាពចំនួន ១៥ ដើម្បីបង្កើនលើសុវត្ថិភាពចរាចរ និងប្រឆាំងនឹងគ្រោះថ្នាក់ចរាចរ។ ផ្តើមចេញពីផែនការសកម្មភាពទាំងនេះ ផែនការមេបានស្នើអោយខេត្តសៀមរាប/ ក្រុងសៀមរាបអនុវត្តនូវផែនការសកម្មភាពចំនួន ៨ ដូចខាងក្រោម:

**តារាង ៤.១១ ផែនការសកម្មភាពសុវត្ថិភាពផ្លូវ**

| | | |
|---|---|---|
| (ក) | : | ការប្រកាសផ្សព្វផ្សាយជាសាធារណៈនូវសវនកម្មសុវត្ថិភាពចរាចរ និងតំបន់ដែលមានគ្រោះថ្នាក់ |
| (ខ) | : | ការកែលំអបរិស្ថានផ្លូវ និងការរចនាផ្លូវ |
| (គ) | : | ការអប់រំអំពីសុវត្ថិភាពចរាចរដល់កុមារតូចៗ |
| (ឃ) | : | ការអនុវត្តច្បាប់ |
| (ង) | : | ការត្រួតពិនិត្យបច្ចេកទេសយានយន្ត |
| (ច) | : | ការបណ្តុះបណ្តាលអ្នកបើកបរ |
| (ឆ) | : | ការកែលំអជំនួយបន្ទាន់ចំពោះជនរងគ្រោះពីគ្រោះថ្នាក់ចរាចរ |

(ជ) យុទ្ធនាការសុវត្ថិភាពចរាចរសាធារណៈ

ប្រភព: ការសិក្សាផែនការមេ

គេបានវិនិច្ឆ័យថា ផែនការសកម្មភាពសំរាប់សុវត្ថិភាពចរាចរទាំងនេះនៅតែទាមទារអោយមានការអនុវត្ត សំរាប់ការអភិវឌ្ឍន៍ដោយនិរន្តរភាពក្រុងសៀមរាប ។ តំរូវការនៃផែនការសកម្មភាពនីមួយៗមានដូចខាង ក្រោមៈ

(ក) ការផ្សព្វផ្សាយពីសុវត្ថិភាពចរាចរ និង ទីតាំងដែលងាយគ្រោះថ្នាក់

ការធ្វើឱ្យខូចផ្ទៃខាងលើផ្លូវគ្រលុក ទទឹងផ្លូវតូចចង្អៀត រឺការភ្ជាប់ផ្លូវមិនស៊ីសង្វាក់គ្នា និងទទឹងស្ពានតូចចង្អៀត គឺជាកត្តាដែលនាំឱ្យមានគ្រោះថ្នាក់ចរាចរ ទោះជាបីជាយ៉ាងណាក៏ដោយ បើយើងមានដាក់ផ្លាកសញ្ញាព្រមាន វានាំឱ្យមានការប្រុងប្រយ័ត្នពីអ្នកបើកបរក្នុងការការពារសុវត្ថិភាពចរាចរ ចំពោះទីតាំងដែលមិនមានសុវត្ថិភាព គ្រប់គ្រាន់ ។ ដូច្នេះ ការត្រួតពិនិត្យទីតាំងដែលងាយគ្រោះថ្នាក់ និងកត្តាផ្សេងៗទៀតដែលចាំបាច់ក្នុងការពង្រឹង សុវត្ថិភាពនៃការប្រើប្រាស់ផ្លូវថ្នល់ ។ លទ្ធផលនៃការត្រួតពិនិត្យ គួរតែត្រូវធ្វើការផ្សព្វផ្សាយឱ្យបានយល់ដឹង ដូច្នេះ អ្នកបើកបរ អាចយល់ដឹងពីទីតាំងដែលងាយគ្រោះថ្នាក់ និងកត្តាផ្សេងៗទៀត នាំងឱ្យពួកគេប្រុងប្រយ័ត្នពីសុវត្ថិភាពនៃការបើកបររបស់ខ្លួន ។

(ខ) ការកែលំអបរិស្ថាន និង ផ្លាកសញ្ញាតាមដងផ្លូវ

ផ្លូវសាធារណៈគួរតែរៀបចំដាក់ផ្លាកសញ្ញា ដើម្បីធានាសុវត្ថិភាពនៃការប្រើប្រាស់ផ្លូវ ។ ផ្លាកសញ្ញាផ្លូវ និងផ្លាកសំគាល់ ការដាក់ភ្លើងតាមដងផ្លូវ ។ល។ គួរតែត្រូវបានដំឡើងតាមទីតាំងសំខាន់ៗ ការចតលើផ្លូវ និងការចតមិនត្រូវផ្លូវ គួរតែត្រូវរៀបចំឱ្យមានសណ្តាប់ធ្នាប់សមរម្យ នៅតំបន់ដែលមានដង់ស៊ីតេខ្ពស់ ជាពិសេស គឺតំបន់ដែលមានការធ្វើជំនួញមមាញឹកគឺតំបន់កណ្តាលក្រុង ។ ការផ្តល់ឱ្យមានផ្លូវតូចៗពិសេស ត្រូវបានណែនាំក្នុងការអនុញ្ញាតិឱ្យការធ្វើចរាចរ ដោយម៉ូតូ កង់ និង អ្នកថ្មើរជើង ។

(គ) ការអប់រំសុវត្ថិភាពចរាចរលើដងផ្លូវសំរាប់កុមារ

ការអប់រំសុវត្ថិភាពចរាចរសំរាប់កុមារ គឺជាការសំខាន់ណាស់ ។ពួកគេអាចយល់ដឹងពីច្បាប់ចរាចរ រឺសេចក្តីណែនាំពីចរាចរតាមរយៈកម្មវិធីអប់រំ ចាប់តាំងពីកុមារភាព ។ ការអប់រំពីសុវត្ថិភាពចរាចរនេះ ត្រូវបានណែនាំធ្វើចាប់ថ្នាក់ទី១ នៅបឋមសិក្សា ដោយមានការចូលរួមពីលោកគ្រូ អ្នកគ្រូ និងអាណាព្យាបាល របស់ពួកគេផងដែរ ការងារនេះត្រូវបានរំពឹងថា អ្នកចូលរួមនឹងមានការយល់ដឹងច្បាស់ពីច្បាប់ចរាចរ ។

(ឃ) ការអនុវត្តន៍ច្បាប់

ដើម្បីកាត់បន្ថយគ្រោះថ្នាក់ចរាចរតាមដងផ្លូវ ការអនុវត្តន៍ ច្បាប់គួរតែ "បានឆាប់ ច្បាស់លាស់ និងឱ្យម៉ឺងម៉ាត់" ដើម្បីកែតម្រូវនូវអាកប្បកិរិយានៃការប្រើប្រាស់ផ្លូវ ។

(ង) ការត្រួតពិនិត្យបច្ចេកទេសយានយន្ត

ការត្រួតពិនិត្យបច្ចេកទេសយានយន្តតាមកាលកំណត់ គួរតែត្រូវបានអនុវត្ត ដោយយោងតាមច្បាប់

និងសេចក្តីណែនាំ ។ រថយន្តដែលមិនមានការត្រួតពិនិត្យបច្ចេកទេស អាចជួបបញ្ហាហ្វ្រាំងមិនស៊ី បែកកង់ បញ្ហាចង្កូត និងខូចភ្លើងស៊ីញ៉ូ នឹងបណ្តាលឱ្យមានគ្រោះថ្នាក់ចរាចរក្នុងពេលបើកបរ ។

(ច) ការបណ្តុះបណ្តាលអ្នកបើបបរ

ស្ថិតិនៃការគ្រោះថ្នាក់ចរាចរតាមដងផ្លូវបានបង្ហាញថា ភាគច្រើននៃគ្រោះថ្នាក់ចរាចរបណ្តាលមកពីការខុសឆ្គងរបស់អ្នកដែលខ្វះការប្រុងប្រយ័ត្ន ។ ការបណ្តុះបណ្តាលអ្នកបើកបរ ស្តីពីច្បាប់ចរាចរ សុវត្ថិភាពតាមដងផ្លូវ ការបើកបរប្រុងប្រយ័ត្នការពារខ្លួនឯង និងការបើកបរដែលមានការប្រុងប្រយ័ត្នខ្ពស់ គឺជាការងារអាទិភាព ។

(ឆ) ជំនួយបន្ទាន់សំរាប់អ្នករងគ្រោះដោយគ្រោះថ្នាក់ចរាចរ

តួនាទី នៃក្រុមជំនួយបន្ទាន់ គឺត្រូវនាំយកអ្នករងគ្រោះធ្ងន់ធ្ងរទៅកាន់មន្ទីរពេទ្យ ជាបន្ទាន់តាមដែលអាចធ្វើទៅបាន និងផ្តល់ឱ្យពួកគេនូវការជួយស្រោចស្រង់ទីមួយនៅពេលធ្វើការផ្លាស់ប្តូរ ។

(ជ) ការធ្វើយុទ្ធនាការសាធារណៈសំរាប់សុវត្ថិភាពចរាចរតាមដងផ្លូវ

ការធ្វើយុទ្ធនាការសាធារណៈពីសុវត្ថិភាពចរាចរ គួរតែផ្តោលលើអ្នកថ្មើរជើង អ្នកជិះកង់ អ្នកជិះម៉ូតូ ដែលជាអ្នកគួរតែប្រើប្រាស់ផ្លូវច្រើនឱ្យបានសមស្រប ដែលតែងតែមានគ្រោះថ្នាក់ចរាចរ ។

TR-5 គំរោងស្តារប្រព័ន្ធបណ្តាញផ្លូវនៅតំបន់បេតិកភ័ណ្ឌជនបទ

ដូចក្នុងរបាយការណ៍ជំពូក ទី ៤.២.១ ផ្លូវចូលទៅតំបន់បេតិកភ័ណ្ឌដាច់ស្រយាលមួយចំនួន ត្រូវបានស្នើដោយផែនការមេបានកែលំអរួចហើយ ។ គោលបំណងនៃគំរោងនេះ គឺត្រូវស្តារកែលំអនូវ "ផ្លូវចូលណាដែលមិនទាន់បានកែលំអ " ចំពោះគំរោងដែលស្នើដោយផែនការមេ និងផ្លូវខេត្តបន្ថែមទៀតដែលមានក្នុងតារាងខាងក្រោម ។ ជាលទ្ធផលនៃផ្លូវចូលដែលបានកែលំអកាលពីមុន ចំនួនអ្នកទេសចរទៅទស្សនាតំបន់បេតិកភ័ណ្ឌជនបទ ដូចជាភ្នំគូលេន (ឧទ្យានជាតិ)និង បឹងមាលា មានការកើនឡើង ដោយសារតែមានបេតិកភ័ណ្ឌនៅតាមជនបទជាច្រើន រាប់បញ្ចូលទាំងបេតិកភ័ណ្ឌដែលរកមិនទាន់ឃើញផងនោះ ជាការចាំបាច់ត្រូវតែកែលំអផ្លូវជនបទ ដើម្បីបង្កើនតំបន់ទេសចរណ៍ និងទំលាប់ពួកគេ ផ្អែកលើយុទ្ធសាស្ត្រវិស័យទេសចរណ៍ ក្នុងផែនការមេ ក៏ដូចជាការផ្តល់នូវទីតាំងទាក់ទាញទេសចរណ៍ថ្មីនៅតំបន់ជនបទ និងធ្វើឱ្យទេសចរណ៍ស្នាក់នៅបានយូរ ។

**តារាង ៤.១២ បញ្ជីផ្លូវតំបន់ជនបទដែលត្រូវបានស្នើនៃគំរោង TR-5**

| ផ្លូវលេខ | ប្រវែងផ្លូវ (គីឡូម៉ែត្រ) | បេតិកភ័ណ្ឌជនបទ |
|---|---|---|

| | | |
|---|---|---|
| ផ្លូវខេត្តលេខ: ២៦៤៤ | ៦៥ | បាកាន |
| ផ្លូវខេត្តលេខ: ២៦៤១ D | ១០ | កោះកេរ |
| ផ្លូវខេត្តលេខ: ២៦៤១ | ២៥ | ភ្នំគូលេន |
| ផ្លូវខេត្តលេខ: ២៦៦ E | ៤៦ | |
| ផ្លូវខេត្ត 2SR1 | ៦ | |
| ផ្លូវខេត្ត 2SR2 | ៤៥ | |
| ផ្លូវខេត្តលេខ: ២៦៩ | ១៣ | |
| ផ្លូវខេត្ត ២៦៥E | ៦.៥ | |
| ផ្លូវខេត្តលេខ: ២៦៧ | ១៨ | |

ប្រភព: ការសិក្សាតាមដាន




**រូបភាព ៤.៣៣ ទីតាំងផែនទីផ្លូវដែលបានស្នើនៃគំរោង TR-5**

TR-6 ការណែនាំឱ្យមានការប្រើប្រាស់សេវាដឹងជញ្ជូនសាធារណៈដែលមិនប៉ះពាល់បរិស្ថាននៅតំបន់ឧទ្យានអង្គរ

ទិដ្ឋភាពរួមនៃការអភិរក្សបេតិភ័ណ្ឌបុរាណ និងការការពារនៃការកើនឡើងកំដៅ ត្រូវបានយកចិត្តទុកដាក់ការដាក់ឱ្យប្រើប្រាស់សេវាដឹកជញ្ជូនសាធារណៈដែលមិនប៉ះពាល់បរិស្ថាន (រថយន្តប្រើអគ្គីសនីយ) នៅតំបន់ឧទ្យានអង្គរ គឺជាការល្អប្រសើរ និងជាអ្វីដែលយើងចង់បាន ។ ក្នុងក្របខ័ណ្ឌនៃការអភិវឌ្ឍន៍ក្រុងសៀមរាប ដែលជាតំបន់ប៉ូលទេសចរណ៍បេតិភ័ណ្ឌបុរាណ ការដាក់ឱ្យប្រើប្រាស់នូវសេវាដឹកជញ្ជូនសាធារណៈមិនប៉ះពាល់បរិស្ថាន មិនមែន

មានតែនៅអង្គរធំនោះទេ សូម្បីតែនៅឧទ្យានអង្គរក៏ត្រូវមានដែរ ។

សមាសធាតុនៃគំរោងមានដូចខាងក្រោមៈ

- ដាក់ឱ្យប្រើប្រាស់រថយន្តក្រុងមិនប៉ះពាល់បរិស្ថាន
- ការដាក់ដំឡើងនូវចំណតរថយន្តក្រុង និងគ្រឿងបំពាក់ដែលពាក់ព័ន្ធ
- សាងសង់ទីតាំងចែកចាយ

ជាយោបល់បន្ថែម សេវាដឹកជញ្ជូនសាធារណៈដែលត្រូវបានស្នើ គឺត្រូវរៀបចំនៅតំបន់ឧទ្យានអង្គររួមគ្នាជាមួយនឹងការបង្កើតច្បាប់ហាមឃាត់ ការចូលនៃរថយន្តឯកជនរាប់បញ្ចូលទាំងរថយន្តទេសចរណ៍ ម៉ូតូកង់បីទៅក្នុងតំបន់ឧទ្យានអង្គរ ដើម្បីដោះស្រាយបញ្ហាអនាធិប្បតេយ្យនៃល័ក្ខខ័ណ្ឌចរាចរ ។ ផ្លូវដែលបានស្នើសំរាប់សេវាដឹកជញ្ជូនសាធារណៈ និងតំបន់រឹតបន្តឹងសំរាប់រថយន្តឯកជនចូលដែលបានបង្ហាញក្នុង រូបភាព ៤.៣៤ ។ផ្លូវដែលស្នើសេវាដឹកជញ្ជូនមិនប៉ះពាល់បរិស្ថាននេះមាន ៣ ខ្សែៈ

- ផ្លូវវង់តូច ដែលភ្ជាប់ពី ប្រាសាទបន្ទាយក្ដី តាព្រហ្ម បាយន្ត ភ្នំបាខែង និងប្រាសាទអង្គរវត្ត ។
- ផ្លូវវង់ធំ ដែលរាប់បញ្ចូលទាំង ប្រាសាទប្រែរូប ព្រះខ័ណ្ឌ បូកជាមួយនឹងផ្លូវវង់តូច និងតាព្រហ្មផងដែរ ។
- ក្របខ័ណ្ឌផ្លូវ ទៅកាន់ប្រាសាទបន្ទាយស្រីរហូតដល់ផ្លូវទៅកាន់ប្រាសាទបន្ទាយសំរ៉ែ ។

ការងារនេះត្រូវបានស្នើថា អាជ្ញាធរអប្សារា ជាអ្នកអនុវត្តនីរៀបចំបណ្ដាញសេវាដឹកជញ្ជូនមិនប៉ះពាល់បរិស្ថាន និងតំលៃនៃការដឹកជញ្ជូននឹងត្រូវរាប់បញ្ចូលទាំងតំលៃចូលទស្សនានៅតំបន់ឧទ្យានអង្គរ ។ សេវាកម្មដឹកជញ្ជូនភ្ញៀវទេសចរណ៍ទៀតទាត់នឹងអាចបញ្ចៀសនូវការប្រើប្រាស់ចំណតដ៏ធំខាងមុខឧស្សានបេតិកភណ្ឌនីមួយៗ ក្នុងតំបន់១ បាន។

ច្បាប់ហាមឃាត់មិនឱ្យរថយន្តឯកជនចូលបរិវេណឧទ្យានអង្គរ គួរតែត្រូវបានបង្កើតឡើងជាមួយនឹងការយល់ព្រមដោយសមស្របពីគ្រប់ភាគីដែលពាក់ព័ន្ធ រាប់បញ្ចូលទាំងអ្នកបើកបរ ម៉ូតូកង់បី អ្នកបើបររថយន្តក្រុងដឹកអ្នកទេសចរ និងភ្នាក់ងារដឹកជញ្ជូន ។ ជាយោបល់បន្ថែម អាជ្ញាធរអប្សារា ត្រូវតែផ្ដល់អាទិភាពនូវឱកាសការងារដល់អ្នកបើកបរម៉ូតូកង់បី អ្នកបើកបររថយន្តក្រុងដឹកទេសចរ ក្នុងពេលជ្រើសរើសអ្នកបើកបរសេវាដឹកជញ្ជូនសាធារណៈមិនប៉ះពាល់ដល់បរិស្ថាន ។




ប្រភព: ការសិក្សាផែនការមេ

**រូបភាព ៤.៣៤ ផ្លូវដែលស្នើសំរាប់សេវាដឹកជញ្ជូនសាធារណៈ និងតំបន់រឹតបន្តឹងមិនឱ្យរថយន្តឯកជនចូល**

TR-7 សាងសង់ផ្លូវជិះកង់នៅតំបន់ឧទ្យានអង្គរ

ចំនួនអ្នកជិះកង់ទស្សនាតំបន់ឧទ្យានអង្គរច្រើនគួរឱ្យកត់សំគាល់ ទោះបីជាយ៉ាងណាក៏ដោយផ្លូវជិះកង់មិនទាន់ត្រូវបានសាងសង់នៅឡើងទេ នៅតំបន់នោះចាប់តាំងពីផែនការមេដែលបានស្នើឡើង ។ បច្ចុប្បន្ននេះភ្ញៀវទេសចរជិះកង់នៅតែប្រើប្រាស់ផ្លូវរថយន្តសំរាប់ជិះកង់ដដែល ដែលប្រើបាស់ស្ថានភាពចរាចររួមគ្នា ។ទស្សនៈវិស័យនៃការថែរក្សាសុវត្ថិភាព និងភាពងាយស្រួលដល់អ្នកទេសចរជិះកង់ ។

ការសាងសង់ផ្លូវជិះកង់ ដើម្បីចែកដាច់នូវផ្លូវកង់ និងផ្លូវរថយន្ត គួរតែត្រូវបានធ្វើឡើងក្នុងតំបន់ឧទ្យានអង្គរ ។ ប្រវែងការសាងសង់ផ្លូវជិះកង់ក្នុងឧទ្យានអង្គរតាមដងផ្លូវដែលមានស្រាប់ប្រមាណជា ២៨.៥ គីឡូម៉ែត្រ ។

## (៤) ការជួសជុលផ្លូវឱ្យមានប្រសិទ្ធិភាពល្អ

TR-8 ការពង្រឹងស្ថាប័នសំរាប់ថែរក្សាផ្លូវឱ្យមានប្រសិទ្ធិភាព

ដើម្បីធ្វើការថែទាំផ្លូវឱ្យមានប្រសិទ្ធិភាពខ្ពស់ ជាការចាំបាច់ត្រូវរៀបចំកាលវិភាគឱ្យបានសមរម្យចំពោះគំរោងអាទិភាពណាដែលបានផ្តល់ឱ្យ តាមស្ថានភាពបច្ចុប្បន្ននៃផ្លូវនីមួយៗ ។ ការជួសជុលនេះ ជាប្រយោជន៍ដើម្បីធ្វើបញ្ជីសារពើភ័ណ្ឌផ្លូវចំពោះផ្លូវសំខាន់ៗផងដែរ ។ ទោះយ៉ាងណាមន្ទីរសាធារណៈការ និងដឹកជញ្ជូនដឹងពីភាពចាំបាច់ដែលត្រូវធ្វើបញ្ជីសារពើភ័ណ្ឌ វីក៏ថាល័ក្ខខ័ណ្ឌច្បាស់លាស់សំរាប់អាទិភាពធ្វើការជួសជុសដែលមិនទាន់ត្រូវបានបង្កើតឡើងដោយសារថវិកាមិនគ្រប់គ្រាន់ និងធនធានមនុស្ស ។ ដូច្នេះហើយ កម្មវិធីជាបន្តបន្ទាប់នេះត្រូវបានស្នើឡើងក្នុងការពង្រឹងប្រសិទ្ធិភាពការងារនៃការថែទាំជួសជុលផ្លូវ ។

(ក) ការរៀបចំបញ្ជីសារពើភ័ណ្ឌផ្លូវ

បញ្ជីផ្លូវ គឺជាទិន្នន័យដ៏សំខាន់ជាមូលដ្ឋានក្នុងការរៀបចំផ្លូវ ។ ដូច្នេះ ផ្លូវទាំងអស់ដែលស្ថិតក្រោមការទទួលខុសត្រូវនៃមន្ទីរសាធារណៈការនៅក្នុងតំបន់គួរតែត្រូវបានធ្វើបញ្ជីសារពើភ័ណ្ឌ ។ កិច្ចការនេះត្រូវបានស្នើឡើងកម្មវត្ថុក្នុងតារាង ៤.១៣ ត្រូវតែស្ថិតក្នុងបញ្ជីសារពើភ័ណ្ឌ។ ការដាក់ចំណាត់ថ្នាក់សំរាប់ស្ពានជួសជុលផ្លូវ និងការ ជួសជុលផ្លូវតាមកាលកំណត់ គួរតែត្រូវបានធ្វើឡើងដោយផ្អែកតាមទិន្នន័យបញ្ជីសារពើភ័ណ្ឌ និងយុទ្ធសាស្ត្រ អភិវឌ្ឍន៍ផ្លូវថ្នាក់ជាតិ និងថ្នាក់ខេត្ត ។

**តារាង ៤.១៣ កម្មវត្ថុដែលស្នើតាមទិន្នន័យសារពើភ័ណ្ឌ**

| ប្រភេទ | កម្មវត្ថុ |
|---|---|
| ១. ទូទៅ | ១-១ ប្រភេទ និងឈ្មោះផ្លូវ |
| | ១-២ ចំនុចចាប់ផ្តើម និងចំនុចបញ្ចប់ |
| | ១-៣ ស្ថាប័នទទួលខុសត្រូវ |
| | ១-៤ កំណាត់ផ្លូវលេខ ១ទីតាំង កមច |
| ២. ក្រាលកៅស៊ូ | ២-១ ទិន្នន័យផ្លូវឆ្លងកាត់ |
| | ២-២ ប្រភេទក្រាល |
| | ២-៣ គុណភាពក្រាល (គ្រើម ប្រេះស្រាំ គ្រហុក ។ល។) |
| ៣. លូទឹក | ៣-១ ទិន្នន័យរចនាសម្ព័ន្ធ |
| | ៣-២ រចនាសម្ព័ន្ធសុខភាព (ប្រេះស្រាំ ការធ្វើឱ្យខូច ។ល។) |
| ៤. ស្ពាន | ៤-១ ទិន្នន័យរចនាសម្ព័ន្ធ |
| | ៤-២ រចនាសម្ព័ន្ធសុខភាព (ប្រេះស្រាំ ការខូចខាត ច្រេះអាស៊ីត ធ្វើរាងផ្លាត ការសឹករិចរិល ។ល។) |
| ៥. ចរាចរ | ៥-១ ចំនួនចរាចរ |
| | ៥-២ ចំនួនរថយន្តធុនធ្ងន់ |
| | ៥-៣ ល្បឿនបើកបរមធ្យម |
| ៦. ផ្សេងៗ | ៦-១ កំណត់ហេតុថែទាំជួសជុល |
| | ៦-២ ការប្រើប្រាស់ដីចំណីផ្លូវ |

ប្រភព: ផែនការមេ JICA

(ខ) ត្រួតពិនិត្យស្ថានភាពផ្លូវ

ស្ថានភាពសាងសង់/ផ្ទៃលើនៃផ្លូវដែលមិនមានបញ្ហាគ្រប់ស្ថានភាពអាកាសធាតុ ដូចជាផ្លូវមិនទាន់ក្រាល ផ្លូវក្រាលគ្រួសក្រហម គឺត្រូវបានខូចទៅវិញក្នុងរយៈពេលមួយខ្លី ដូច្នេះ ការត្រួតពិនិត្យជាប្រចាំនូវស្ថានភាពផ្លូវ និងធ្វើបច្ចុប្បន្នភាពទិន្នន័យផ្លូវ គឺចាំបាច់ទាមទារត្រូវធ្វើ ។ការរកឃើញទាពេលថ្មីៗ វិធីសាស្ត្រការពារដែលបណ្តាលឱ្យខូចផ្លូវ និងលទ្ធផលដែលត្រូវកាត់បន្ថយគ្រោះថ្នាក់ចរាចរ ។ទោះជាយ៉ាងណា ការជួសជុលសំរាប់ការខូចខាតតូច អាចធ្វើឱ្យតំលៃជួសជុលទាប ។

ចំនួនចរាចរ គឺជាកត្តាមួយសំខាន់ក្នុងចំណោមកត្តាសំខាន់ដទៃទៀត សំរាប់ធ្វើការសម្រេចចិត្តចំពោះផ្លូវសំខាន់ៗ និងកាលបរិច្ឆេទជួសជុល ។ការធ្វើការស្ទង់មតិចរាចរតាមកាលកំណត់ គួរតែត្រូវបានធ្វើនៅតាមដងផ្លូវសំខាន់ៗ យ៉ាងហោចណាស់ ធ្វើម្តងក្នុង១ឆ្នាំ និងលទ្ធផលគឺឆ្លើយតបទៅនឹងផែនការអភិវឌ្ឍន៍ និងជួសជុលផ្លូវប្រចាំឆ្នាំ ។

(គ) ការសម្របសម្រួលគ្នានូវគោលការណ៍ជួសជុលផ្លូវ រវាងមន្ទីរសាធារណៈការ និងដឹកជញ្ជូន និងមន្ទីរអភិវឌ្ឍន៍ជនបទ

ដើម្បីពង្រឹងការងារជួសជុលផ្លូវឱ្យមានប្រសិទ្ធិភាព ត្រូវបានស្នើថា ត្រូវរៀបចំផែនការជួសជុលផ្លូវជាចាំបាច់ ដែលពិចារណាលើបណ្តាញផ្លូវទាំងមូលរាប់ទាំងផ្លូវជនបទផងដែរ ។ កិច្ចការនេះ ស្ថាប័នទទួលខុសត្រូវជួសជុលផ្លូវចាំបាច់ត្រូវធ្វើការពិភាក្សាឱ្យកាន់តែស៊ីជម្រៅក្នុងការរៀបចំផែនការអភិវឌ្ឍន៍និងជួសជុលផ្លូវជាពិសេសមន្ទីរសាធារណការ និងមន្ទីរអភិវឌ្ឍន៍ជនបទ ត្រូវបានណែនាំថា មានការយល់ព្រមគ្នា ក្នុងផែនការជួសជុលផ្លូវ និងធ្វើឱ្យមានប្រសិទ្ធិភាពខ្ពស់ ។

## ៤.២.៣ គំរោងអាទិភាពក្នុងវិស័យដឹកជញ្ជូន

### (១) ការជ្រើសរើសគំរោងអាទិភាព

ក្នុងចំណោម គំរោង/កម្មវិធីដែលបានស្នើឡើងបានពន្យល់ហើយក្នុងជំពូកទី ៤.២.៣ ជាបន្តបន្ទាប់នេះជាគំរោង/កម្មវិធីអាទិភាពដែលបានជ្រើសរើសចេញពីទស្សនៈ បន្ទាន់ ការត្រៀមរៀបចំ ឥទ្ធិពលបន្ថែម និងឥទ្ធិពលវិជ្ជមាន។

TR-1: កែលំអបណ្តាញផ្លូវប្រទាក់ក្រឡា ភ្ជាប់គ្នារវាងផ្លូវជាតិលេខ០៦ និងផ្លូវក្រវ៉ាត់ក្រុង ។

TR-2: កែលំអបណ្តាញផ្លូវប្រទាក់ក្រឡា ខាងក្រៅផ្លូវវាងក្រុង

TR-3: ស្ថាបនាផ្លូវវាណបផ្លូវជាតិលេខ៦

TR-5: គំរោងស្តារកែលំអបណ្តាញផ្លូវប្រទាក់ក្រឡាជនបទ

## (២) ការបង្កើតថ្លៃប៉ាន់ស្មាន

TR-1 ការកែលំអបណ្តាញផ្លូវក្នុងក្រុងក្នុងផ្លូវជាតិលេខ៦ និងផ្លូវវាងក្រុង

បណ្តាញផ្លូវក្នុងក្រុងក្នុងផ្លូវជាតិលេខ៦ និងផ្លូវវាងក្រុងមានប្រវែងសរុបប្រមាណជា ៥៥.១១៩ គីឡូម៉ែត្រ។ ជាមួយនឹងការប្រើប្រាស់ទទឹងផ្លូវទំហំ ១0ម៉ែត្រ ថ្លៃដើមក្នុងការសាងសង់ត្រូវបានប៉ាន់ស្មានដូចខាងក្រោមៈ

ការងារចាក់ដី និងក្រាលកៅស៊ូ : ៥៥ ១១៩ម៉ែត្រ x ៣៨៨.៥ ដុល្លារអាមេរិក/ម៉ែត្រ= ២១.៤លានដុល្លារ

ការងារប្រព័ន្ធបង្ហូរទឹក : ៥៥ ១១៩ម៉ែត្រ x ៥៦១.0 ដុល្លារអាមេរិក/ម៉ែត្រ= ៣0.៩លានដុល្លារ

ពត៌មានលំអិតទាក់ទងនឹងប្រវែងផ្លូវត្រូវបានផ្តល់ជូនក្នុងទំព័របន្ថែម D-៤ និងការបំបែកថ្លៃដើមសាងសង់ក្នុងមួយឯកតាត្រូវបានពិភាក្សាក្នុងទំព័របន្ថែម D-២។

TR-2 ការកែលំអបណ្តាញផ្លូវក្នុងក្រុងខាងក្រៅផ្លូវវាងក្រុង

បណ្តាញផ្លូវក្នុងក្រុងខាងក្រៅផ្លូវវាងក្រុង មានប្រវែងសរុបប្រមាណជា ៤៨.៣៩៥ គីឡូម៉ែត្រ។ជាមួយនឹងការប្រើប្រាស់ទទឹងផ្លូវទំហំ ១២ម៉ែត្រ ថ្លៃដើមក្នុងការសាងសង់ត្រូវបានប៉ាន់ស្មានដូចខាងក្រោមៈ

ការងារចាក់ដី និងក្រាលកៅស៊ូ : ៤៨ ៣៩៥ម៉ែត្រ x ៤៦៦.២ ដុល្លារអាមេរិក/ម៉ែត្រ= ២២.៦លានដុល្លារ

ការងារប្រព័ន្ធបង្ហូរទឹក : ៤៨ ៣៩៥ម៉ែត្រ x ២១.0 ដុល្លារអាមេរិក/ម៉ែត្រ= ១.0លានដុល្លារ

ទំព័របន្ថែម D -២ និង D -៤ បង្ហាញពីថ្លៃដើមសាងសង់ក្នុងមួយឯកតាជាគោល និងប្រវែងផ្លូវ។

TR-3 ការកសាងបណ្តាញផ្លូវរណបនឹងផ្លូវជាតិលេខ៦

បណ្តាញផ្លូវរណបនឹងផ្លូវជាតិលេខ៦ នៅភាគខាងជើង និងខាងត្បូង មានប្រវែងសរុបប្រមាណជា ២៣.៥៣៤ គីឡូម៉ែត្រ។ ទទឹងផ្លូវមានទំហំ ១២ម៉ែត្រ ដូចនឹងទំហំទទឹងផ្លូវ TR-2 ខាងលើដែរ។ ថ្លៃដើមក្នុងការសាងសង់ត្រូវបានប៉ាន់ស្មានដូចខាងក្រោមៈ

ការងារចាក់ដី និងក្រាលកៅស៊ូ : ២៣ ៥៣៤ម៉ែត្រ x ៤៦៦.២ ដុល្លារអាមេរិក/ម៉ែត្រ= ១១.0លានដុល្លារ

ការងារប្រព័ន្ធបង្ហូរទឹក : ២៣ ៥៣៤ម៉ែត្រ x ២១.0 ដុល្លារអាមេរិក/ម៉ែត្រ= 0.៥លានដុល្លារ

ទំព័របន្ថែម D-២ និង D-៤ បង្ហាញពីថ្លៃដើមសាងសង់ក្នុងមួយឯកតាជាគោល និងប្រវែងផ្លូវ។

TR-5 គំរោងស្ថារប្រព័ន្ធបណ្តាញផ្លូវនៅតំបន់បេតិកភ័ណ្ឌជនបទ

ថ្លៃដើមក្នុងការសាងសង់ផ្លូវជនបទ ទៅកាន់បេតិកភណ្ឌជនបទត្រូវបានប៉ាន់ស្មានដូចខាងក្រោម។ ការសាងសង់នឹងត្រូវក្រាលកៅស៊ូ DBST នៅផ្ទៃខាងលើ។

## តារាង ៤.១៤ ការប៉ាន់ស្មានថ្លៃដើមសាងសង់សំរាប់បណ្តាញផ្លូវទៅកាន់បេតិកភណ្ឌជនបទ

| លេខផ្លូវ | ប្រវែងប្រហាក់ប្រហែល (គីឡូម៉ែត្រ) | ២ថ្លៃដើមសាងសង់ (គិតជាលានដុល្លារ) | កំណត់សំគាល់ |
|---|---|---|---|
| ផ្លូវខេត្តលេខ:២៦៤៤ | ៩១ | ១៦.០ | សូមមើលសំគាល់ខាងក្រោម |
| ផ្លូវខេត្តលេខ: ២៦៤១D | ១០ | ១.៨ | |
| ផ្លូវខេត្តលេខ: ២៦៤១A | ២៥ | ៤.៤ | |
| ផ្លូវខេត្តលេខ:២៦៥E | ៦.៥ | ១.២ | ការប៉ាន់ស្មានរបស់មន្ទីរសាធារណៈការ និងដឹកជញ្ជូនខេត្ត |
| ផ្លូវខេត្តលេខ:២៦៧ | ១១ | ១.៥ | |
| ផ្លូវខេត្តលេខ:២៦៩ | ១២ | ១.៧ | |
| ផ្លូវខេត្តលេខ: ២៦៦E | ៤៦ | ៥.៨ | |
| ផ្លូវខេត្តលេខ:២SR២ | ៤៥ | ៥.២ | |
| ផ្លូវខេត្តលេខ:២SR១ | ១៧.៣ | ២.៤ | |

សំគាល់: មន្ទីរសាធារណៈការ និងដឹកជញ្ជូនខេត្តបានប៉ាន់ស្មានថ្លៃកែលំអផ្លូវខេត្តលេខ:២៦៥E ប្រវែង ៦.៥ គីឡូម៉ែត្រដែលមានតំលៃ ១ ១៣៧ ៥០០ ដុល្លារអាមេរិក។ ថ្លៃដើមសាងសង់ក្នុង ១គីឡូម៉ែត្រ គឺ ១៧៥ ០០០ ដុល្លារ។ ថ្លៃដើមក្នុងការសាងសង់ផ្លូវខេត្តលេខ:២៦៤៤ ផ្លូវខេត្តលេខ: ២៦៤១D និង ផ្លូវខេត្តលេខ: ២៦៤១A ក៏ត្រូវប្រើថ្លៃដើមដែលបានប៉ាន់ស្មាននេះដែរ ដែលមានចំនួន ១៧៥ ០០០ដុល្លារ។

# ឧបសម្ព័ន្ធទី៧៖

# រូបភាព

# ឧបសម្ព័ន្ធរូបភាព



រូបភាពទី១៖ សកម្មភាពរៀបចំសួនច្បារមាត់ស្ទឹង និងកែលម្អផ្លូវខាងជើងស្ពានថ្មព្រះរាជដំណាក់



រូបភាពទី២៖ សកម្មភាពរៀបចំសួនច្បារខាងក្រោយព្រះអង្គចេកព្រះអង្គចម

រូបភាពទី៨៖ សកម្មភាពសាងសង់ស្ពានព្រះរាជដំណាក់ទី២



រូបភាពទី៣៖ សកម្មភាពជួសជុលផ្លូវ៦០ម៉ែត្រ


រូបភាពទី៤៖ សកម្មភាពសាងសង់ស្ពានព្រះរាជដំណាក់ទី២



រូបភាពទី៥៖ គំនរសំរាមដែលមិនត្រូវបានប្រមូលនៅសង្កាត់សាលាកំរើក




រូបភាពទី៦៖ សំរាមនៅកកស្ទះក្នុងលូ ក្នុងក្រុងសៀមរាប




រូបភាពទី៧៖ ការបំពាក់ឧបករណ៍ហាត់ប្រាណនៅសួនច្បារព្រះរាជដំណាក់



រូបភាពទី៨៖ ការរៀបចំភ្លើងលម្អនៅពេលរាត្រី